2015

ACCOUNTING AND AUDITING REGULATOR

# ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

CamEd Business School

IFRS® for SMEs

# ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ
# សម្រាប់អង្គភាពធុនតូចនិងមធ្យម

# មាតិកា

## សេចក្តីផ្តើម


ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម

អារម្ភកថា 1


## ផ្នែក


| | |
|---|---|
| ១ អង្គភាពធុនតូចនិងមធ្យម | 7 |
| ២ ទស្សនទាន និងគោលការណ៍ទូទៅ | 9 |
| ៣ ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ | 21 |
| ៤ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | 27 |
| ៥ របាយការណ៍ចំណូលពេញលេញ និង របាយការណ៍លទ្ធផល | 33 |
| ៦ របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍ចំណូលនិងចំណេញរក្សាទុក | 37 |
| ៧ របាយការណ៍លំហូរសាច់ប្រាក់ | 39 |
| ៨ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 45 |
| ៩ របាយការណ៍ហិរញ្ញវត្ថុរួម និង របាយការណ៍ហិរញ្ញវត្ថុដោយឡែក | 47 |
| ១០ គោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និង កំហុសឆ្គង | 55 |
| ១១ របាយការណ៍ហិរញ្ញវត្ថុមូលដ្ឋាន | 61 |
| ១២ បញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ | 79 |
| ១៣ សន្និធិ | 89 |
| ១៤ ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | 95 |
| ១៥ ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន | 101 |
| ១៦ ទ្រព្យវិនិយោគ | 105 |
| ១៧ ទ្រព្យ រោងចក្រ និង បរិក្ខារ | 109 |
| ១៨ ទ្រព្យសកម្មអរូបីដែលមិនមែនជាកេរ្តិ៍ឈ្មោះអាជីវកម្ម | 117 |
| ១៩ ការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម | 123 |

២០ ភតិសន្យា 129

២១ សំវិធានធន និង យថាភាព 139

ឧបសម្ព័ន្ធ-- សេចក្តីណែនាំអំពីការទទួលស្គាល់និងការវាស់វែងសំវិធានធន

២២ បំណុល និង មូលធន 151

ឧបសម្ព័ន្ធ-- ឧទាហរណ៍អំពីគណនេយ្យកម្មសម្រាប់បំណុលអាចបំប្លែងបាន របស់ក្រុមហ៊ុនបោះផ្សាយ

២៣ ចំណូល 163

ឧបសម្ព័ន្ធ-- ឧទាហរណ៍អំពីការទទួលស្គាល់ចំណូលតាមគោលការណ៍នៅក្នុងផ្នែក ២៣

២៤ អំណោយរបស់រដ្ឋាភិបាល 179

២៥ បន្ទុកលើប្រាក់កម្ចី 181

២៦ ការទូទាត់ដោយផ្អែកលើភាគហ៊ុន 183

២៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម 191

២៨ អត្ថប្រយោជន៍និយោជិត 201

២៩ ពន្ធលើប្រាក់ចំណូល 215

៣០ ការបកប្រែរូបិយប័ណ្ណបរទេស 225

៣១ អតិផរណាខ្ពស់ 231

៣២ ព្រឹត្តិការណ៍ក្រោយចុងការិយបរិច្ឆេទរាយការណ៍ 235

៣៣ ការលាត្រដាងព័ត៌មានរបស់ភាគីពាក់ព័ន្ធ 239

៣៤ សកម្មភាពពិសេស 245

៣៥ ការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម 251

សទ្ទានុក្រម 259

តារាងប្រភព 281

ការសម្រេចអនុម័តដោយក្រុមប្រឹក្សាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូច និងមធ្យម ដែលបានចេញផ្សាយនៅក្នុងខែកក្កដា ឆ្នាំ២០០៩ 284

ការសម្រេចអនុម័តដោយក្រុមប្រឹក្សាលើវិសោធនកម្មស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម ឆ្នាំ២០១៥ ដែលបានចេញផ្សាយនៅក្នុងខែឧសភា ឆ្នាំ២០១៥

ស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម ត្រូវបានកំណត់នៅក្នុងផ្នែក១ ផ្នែក៣៥ និងនៅក្នុងសទ្ទានុក្រម។ ពាក្យកំណត់អត្ថន័យនៅក្នុងសទ្ទានុក្រមជាប្រភេទដិតខ្មៅ ខណៈដែលវាកើតមានលើកដំបូងនៅក្នុងផ្នែក នីមួយៗ។ ស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យមភ្ជាប់មកជាមួយនឹងអារម្ភកថា សេចក្តីណែនាំអនុវត្តតារាងឥទ្ធិតកម្ម របាយការណ៍ហិរញ្ញវត្ថុគម្រូ និងការដាក់បង្ហាញ ព្រមទាំងបញ្ជីនៃការលាតត្រដាង និង មូលដ្ឋាននៃការសន្និដ្ឋាន។

# អារម្ភកថា នៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

## ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ

អ១ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (IASB) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១ ដោយជាផ្នែកមួយនៃមូលនិធិគណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិ (IASC)។ នៅក្នុងឆ្នាំ២០១០ មូលនិធិគណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិ ត្រូវបានប្តូរឈ្មោះជាមូលនិធិស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ។

អ២ អភិបាលកិច្ចនៃមូលនិធិគណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិ មានអភិបាលចំនួន ២២រូប។ ការទទួលខុសត្រូវរបស់អភិបាល រួមមាន តែងតាំងសមាជិករបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ និងរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការដែលទាក់ទិននានា ព្រមទាំងធានានូវហិរញ្ញប្បទានចំពោះអង្គភាពទាំងមូល។

អ៣ គោលដៅរបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ៖

(ក) បង្កើតឡើង ដើម្បីប្រយោជន៍សាធារណៈនូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ ដែលមានគុណភាពខ្ពស់ អាចយល់បាន អាចអនុវត្ត និងដែលត្រូវបានទទួលយកជាសាកល ផ្អែកលើគោលការណ៍ ដែលមានការពន្យល់ច្បាស់លាស់។ ស្តង់ដារទាំងនេះ គួរទាមទារនូវព័ត៌មាន ដែលមានគុណភាពខ្ពស់ មានតម្លាភាព និងព័ត៌មានអាចប្រៀបធៀបបាន នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងការរាយការណ៍ហិរញ្ញវត្ថុផ្សេងទៀត ដើម្បីជួយដល់វិនិយោគិន អ្នកចូលរួមផ្សេងទៀត នៅក្នុងទីផ្សារមូលធនផ្សេងៗរបស់ពិភពលោក និងដល់អ្នកប្រើប្រាស់ផ្សេងទៀត ដើម្បីធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

(ខ) ជម្រុញការប្រើប្រាស់ និងការអនុវត្តដ៏ម៉ឺងម៉ាត់នូវស្តង់ដារទាំងនោះ។

(គ) ក្នុងការបំពេញគោលដៅដែលទាក់ទងនឹង (ក) និង (ខ) គិតគូរតាមការគួរអំពីសេចក្តីត្រូវការពិសេសរបស់អង្គភាពធុនតូចនិងមធ្យម និងបណ្តាសេដ្ឋកិច្ចកំពុងរីកលូតលាស់ ដែលអង្គភាពមានទំហំ និងប្រភេទផ្សេងៗនៅក្នុងមជ្ឈដ្ឋានសេដ្ឋកិច្ចចម្រុះ និង

(ឃ) ជម្រុញ និងជួយសម្រួលការប្រើប្រាស់ស្តង់ដាររបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិ ដែលជាស្តង់ដារដែលបានចេញផ្សាយ ដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ តាមរយៈការបង្រួបបង្រួមគ្នានៃស្តង់ដារគណនេយ្យជាតិ និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ។

អ៤ ការអនុម័តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (ហៅថា ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញនៅក្នុងឯកសារនេះ) និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមជាមួយនឹងឯកសារពាក់ព័ន្ធ ដូចជា សេចក្តីព្រាងសុំមតិ និងឯកសារសម្រាប់ពិភាក្សា គឺជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។

# ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ

អ៥ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ សម្រេចនូវគោលដៅរបស់ខ្លួនជាបឋមដោយការបង្កើត និងការបោះផ្សាយស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ និងជម្រុញឱ្យមានការប្រើប្រាស់ស្តង់ដារទាំងនោះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅនិងការរាយការណ៍ហិរញ្ញវត្ថុដទៃទៀត។ការរាយការណ៍ហិរញ្ញវត្ថុផ្សេងទៀត រួមមានព័ត៌មានដែលផ្តល់ក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ ដែលជួយដល់ការបកប្រែសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ ឬធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់អ្នកប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចផ្នែកសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព។ ពាក្យ “ការរាយការណ៍ហិរញ្ញវត្ថុ” រួមមានរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ បូកនឹងការរាយការណ៍ហិរញ្ញវត្ថុដទៃទៀត។

អ៦ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ កំណត់នូវការតម្រូវនានា សម្រាប់ការទទួលស្គាល់ការវាស់វែង ការបង្ហាញ និងការលាតត្រដាង ដែលអនុវត្តចំពោះប្រតិបត្តិការ ព្រមទាំងព្រឹត្តិការណ៍និងលក្ខខណ្ឌដទៃទៀត ដែលមានសារៈសំខាន់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ។ ស្តង់ដារទាំងនោះអាចកំណត់ផងដែរនូវការតម្រូវនានាបែបនេះសម្រាប់ប្រតិបត្តិការ ព្រឹត្តិការណ៍ និងលក្ខខណ្ឌដទៃទៀត ដែលកើតឡើងជាចម្បងនៅក្នុងវិស័យជាក់លាក់។ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ផ្អែកលើគ្រោងក្របខ័ណ្ឌ ដែលបានធ្វើឱ្យមានស្តង់ដារនូវមូលដ្ឋានទស្សនទាន ដែលបង្កើតជាព័ត៌មានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ។ គោលដៅរបស់គ្រោងក្របខ័ណ្ឌ គឺជម្រុញនូវការបង្កើតស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិប្រកបដោយសង្គតិភាពនិងស្របនឹងតក្កវិជ្ជា។ គ្រោងក្របខ័ណ្ឌក៏ផ្តល់ផងដែរនូវមូលដ្ឋានសម្រាប់ការប្រើប្រាស់ការវិនិច្ឆ័យក្នុងការដោះស្រាយបញ្ហាគណនេយ្យនានា។

# របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ

អ៧ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ត្រូវបានបង្កើតឡើងដើម្បីអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅនិងចំពោះការរាយការណ៍ហិរញ្ញវត្ថុដទៃទៀត របស់អង្គភាពមានគោលដៅរកប្រាក់ចំណេញ។ របាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅ ត្រូវបានតម្រង់ទិសទៅនឹងសេចក្តីត្រូវការព័ត៌មានជារួមរបស់អ្នកប្រើប្រាស់ជាច្រើន ដូចជា ម្ចាស់ភាគហ៊ុន ម្ចាស់បំណុល និយោជិត និងសាធារណៈជនទូទៅ។គោលដៅរបស់របាយការណ៍ហិរញ្ញវត្ថុ គឺផ្តល់នូវព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលផ្នែកហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាពមួយដែលព័ត៌មានទាំងនោះ មានអត្ថប្រយោជន៍ សម្រាប់អ្នកប្រើប្រាស់ទាំងនោះ ក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

អ៨ របាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅគឺជារបាយការណ៍ ដែលផ្តល់នូវព័ត៌មានហិរញ្ញវត្ថុទូទៅ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ទូទៅ ដែលមិនទាមទារនូវព័ត៌មានដ៏ជាក់លាក់ណាមួយ សម្រាប់ពួកគេ។របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ រួមមានរបាយការណ៍ដែលបានបង្ហាញដាច់ដោយឡែក ឬជាមួយឯកសារជាសាធារណៈផ្សេងទៀត ដូចជា របាយការណ៍ប្រចាំឆ្នាំ ឬបរិយាយប័ណ្ណ។

## ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម

អ៩ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ក៏បង្កើតនិងបោះផ្សាយស្តង់ដារដាច់ដោយឡែកមួយ សម្រាប់អនុវត្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅរបស់អង្គភាព និងការរាយការណ៍ហិរញ្ញវត្ថុដទៃទៀត ដែលធ្វើដោយអង្គភាព ដែលមានការហៅខុសៗគ្នា នៅក្នុងបណ្តាប្រទេសជាច្រើន រួមមានអង្គភាពធុនតូចនិងមធ្យម អង្គភាពឯកជន និងអង្គភាពដែលមិនទទួលខុសត្រូវជាសាធារណៈ។ ស្តង់ដារនោះ គឺជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម។

អ១០ ពាក្យ "អង្គភាពធុនតូចនិងមធ្យម" ដែលប្រើដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ត្រូវបានផ្តល់និយមន័យនិងពន្យល់ក្នុងផ្នែកទី១ ស្តីពីអង្គភាពធុនតូចនិងមធ្យម។ យុត្តាធិការជាច្រើននៅលើពិភពលោក បានបង្កើតនូវនិយមន័យផ្ទាល់ខ្លួនរបស់គេដល់ពាក្យអង្គភាពធុនតូចនិងមធ្យមនេះ សម្រាប់គោលបំណងផ្សេងគ្នាជាច្រើនរួមទាំងចែងអំពីកាតព្វកិច្ចក្នុងការរាយការណ៍ហិរញ្ញវត្ថុ។ ជារឿយៗ និយមន័យតាមបែបជាតិឬបែបតំបន់ទាំងនោះ រួមបញ្ចូលនូវលក្ខណៈវិនិច្ឆ័យបានបំប្លែងជាបរិមាណ ដោយផ្អែកលើមូលដ្ឋាននៃចំណូល ទ្រព្យសកម្ម និយោជិតឬកត្តាដទៃទៀត។ ជាញឹកញាប់ពាក្យ "អង្គភាពធុនតូចនិងមធ្យម" ត្រូវបានប្រើក្នុងន័យ ឬដោយរួមបញ្ចូលអង្គភាពតូចៗដោយមិនគិតថាតើអង្គភាពនោះបោះផ្សាយ របាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅ សម្រាប់អ្នកប្រើប្រាស់ខាងក្រៅឬអត់នោះទេ។

អ១១ អង្គភាពធុនតូចនិងមធ្យម តែងតែបង្កើតរបាយការណ៍ហិរញ្ញវត្ថុ តែសម្រាប់ការប្រើប្រាស់ដោយម្ចាស់អ្នកគ្រប់គ្រងផ្ទាល់ ឬសម្រាប់តែការប្រើប្រាស់ដោយអាជ្ញាធរសារពើពន្ធ ឬសម្រាប់អាជ្ញាធររបស់រដ្ឋាភិបាលដទៃទៀតតែប៉ុណ្ណោះ។ របាយការណ៍ហិរញ្ញវត្ថុដែលបង្កើតឡើងសម្រាប់តែគោលបំណងទាំងនោះ មិនប្រាកដជារបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅទេ។

អ១២ ច្បាប់ពន្ធខុសប្លែកគ្នាទៅតាមយុត្តាធិការនីមួយៗ ហើយគោលដៅរបស់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅខុសពីគោលដៅនៃការរាយការណ៍របស់ប្រាក់ចំណេញជាប់ពន្ធ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ប្រហែលជាមិនអនុលោមទាំងស្រុងតាមគ្រប់ការវាស់វែង ដែលតម្រូវដោយច្បាប់និងបទប្បញ្ញត្តិសារពើពន្ធរបស់យុត្តាធិការទាំងនោះទេ។ យុត្តាធិការមួយមានលទ្ធភាពក្នុងការបន្ថយ "បន្ទុករាយការណ៍ទ្វេដង" លើអង្គភាពធុនតូចនិងមធ្យម ដោយបង្កើតជារចនាសម្ព័ន្ធរបាយការណ៍ពន្ធដារជាការផ្ទៀងផ្ទាត់ពីចំណេញឬខាត ដែលត្រូវបានកំណត់ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យមនិងតាមមធ្យោបាយដទៃទៀត។

## សិទ្ធិអំណាចរបស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

អ១៣ ការតម្រូវឬការអនុញ្ញាតឱ្យអង្គភាពណាខ្លះ ប្រើប្រាស់ស្តង់ដាររបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ត្រូវបានសម្រេចដោយអាជ្ញាធរច្បាប់និងនិយ័តករ និងអ្នកកំណត់ស្តង់ដារនៅក្នុងយុត្តាធិការនីមួយៗ។ នេះពិតចំពោះស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ និងពិតចំពោះស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម។ ប៉ុន្តែ ការឱ្យនិយមន័យច្បាស់លាស់ថាតើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមសមស្របអនុវត្ត សម្រាប់អង្គភាពប្រភេទណា (ដូចដែលបានពន្យល់ក្នុងផ្នែកទី១ នៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ) មានសារៈសំខាន់ណាស់ ដូច្នេះទើប (ក) ក្រុមប្រឹក្សាស្តង់ដារ

គណនេយ្យអន្តរជាតិ បានអាចសម្រេចថាតើតម្រូវការគណនេយ្យ និងការលាតត្រដាងណាខ្លះសមរម្យ សម្រាប់ចំណាត់ថ្នាក់អង្គភាពនោះ និង (ខ) អាជ្ញាធរច្បាប់និងនិយ័តករ អ្នកកំណត់ស្តង់ដារ និងអង្គភាពត្រូវរាយការណ៍និងសវនកររបស់ពួកគេត្រូវបានប្រាប់អំពីវិសាលភាពសម្រាប់អនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។ ការឱ្យនិយមន័យច្បាស់លាស់នៅមានប្រយោជន៍សំខាន់មួយទៀត គឺថាអង្គភាពដែលមិនមែនធុនតូចឬមធ្យម ដោយមិនបានបំពេញលក្ខខណ្ឌប្រើប្រាស់របស់ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម មិនអាចប្រកាសថាខ្លួនអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម (សូមមើលកថាខណ្ឌ១.៥)។

## រចនាសម្ព័ន្ធរបស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

អ១៤ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម ត្រូវបានរៀបចំឡើងតាមប្រធានបទដោយប្រធានបទនីមួយៗ ត្រូវបានបង្ហាញតាមផ្នែកដែលបានបង់លេខដាច់ពីគ្នា។ សេចក្តីយោងឆ្លងរវាងកថាខណ្ឌត្រូវបានសម្គាល់ដោយលេខផ្នែកនិងលេខកថាខណ្ឌ។ លេខកថាខណ្ឌមានទម្រង់ xx .yy ដែល xx គឺជាលេខផ្នែកហើយ yy គឺជាលេខកថាខណ្ឌ។ លេខកថាខណ្ឌ ត្រូវបានធ្វើឡើងតាមទម្រង់ xx.yy ដែល xx គឺជាលេខផ្នែក ហើយ yy គឺជាលេខកថាខណ្ឌក្នុងផ្នែកនោះ។ ក្នុងឧទាហរណ៍ ដែលរួមមានចំនួនទឹកប្រាក់រូបិយវត្ថុ ឯកតាវាស់វែងជាឯកតារូបិយប័ណ្ណ (សរសេរអក្សរកាត់ថា CU) ។

អ១៥ គ្រប់កថាខណ្ឌរបស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យមនេះ មានសិទ្ធិអំណាចស្មើគ្នា។ ផ្នែកខ្លះរួមបញ្ចូលឧបសម្ព័ន្ធការណែនាំអនុវត្ត ដែលមិនមែនជាផ្នែកនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមនេះទេ ប៉ុន្តែផ្តល់ការណែនាំអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យមនេះ។

## ការថែរក្សាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

អ១៦ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិរំពឹងថា នឹងស្នើសុំធ្វើវិសោធនកម្មស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ដោយបោះផ្សាយនូវសេចក្តីព្រាងសុំមតិពេញលេញមួយ ជាសាធារណៈតាមកាលកំណត់ តែមិនឱ្យលើសពីប្រមាណមួយដងក្នុងបីឆ្នាំ។ ក្នុងការបង្កើតសេចក្តីព្រាងសុំមតិទាំងនោះ ក្រុមប្រឹក្សារំពឹងថានឹងពិចារណានូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិថ្មី និងដែលបានធ្វើវិសោធនកម្មរួច ក៏ដូចជាបញ្ហាជាក់លាក់នានា ដែលត្រូវបានដាក់ឱ្យក្រុមប្រឹក្សាយកចិត្តទុកដាក់ទាក់ទងនឹងការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។ ជួនកាល ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ អាចនឹងកំណត់នូវបញ្ហាបន្ទាន់ ដែលវិសោធនកម្មស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម អាចត្រូវបានពិចារណា នៅក្រៅដំណើរការពិនិត្យឡើងវិញតាមកាលកំណត់។ ប៉ុន្តែស្ថានការណ៍បែបនេះ ត្រូវបានរំពឹងថា កម្រមាន។

អ១៧ ការប្រែប្រួលនានា ដែលក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ អាចធ្វើឡើងឬ ស្នើឡើងលើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ មិនត្រូវអនុវត្តលើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យមទេ លុះត្រាតែស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម ត្រូវបានធ្វើវិសោធនកម្ម។ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម គឺជាឯកសារដោយឡែក។ អង្គភាពធុនតូចនិងមធ្យម មិនត្រូវរំពឹងថានឹងមាន ឬអនុវត្តការកែប្រែ ដែលបានធ្វើឡើងនៅក្នុងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិពេញលេញ មុនពេលដែលការកែប្រែទាំងនោះ ត្រូវបានបញ្ចូលក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមឡើយ លុះត្រាតែក្នុងពេលអវត្តមានការណែនាំពិសេស នៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម អង្គភាពធុនតូច និងមធ្យម ជ្រើសរើសអនុវត្តការណែនាំ នៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ហើយគោលការណ៍ទាំងនោះមិនផ្ទុយគ្នាជាមួយការតម្រូវ នៅក្នុងឋានានុក្រមក្នុងកថាខណ្ឌ១០.៤-១០.៥។

អ១៨ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិគិតទុកថា យ៉ាងតិចឃ្លាតគ្នាមួយឆ្នាំ រវាងពេលបោះផ្សាយវិសោធនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម និងកាលបរិច្ឆេទចូលជាធរមាននៃវិសោធនកម្មទាំងនោះ។

# ផ្នែកទី ១
# អង្គភាពធុនតូចនិងមធ្យម

## វិសាលភាពអនុវត្តរបស់ស្តង់ដារនេះ

១.១ ស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម គឺសម្រាប់ឱ្យអង្គភាពធុនតូចនិងមធ្យមប្រើប្រាស់។ ផ្នែកនេះពិពណ៌នាអំពីចរិកលក្ខណៈរបស់អង្គភាពធុនតូចនិងមធ្យម។

## ការពិព័រណ៌នាអំពីចរិកលក្ខណៈរបស់អង្គភាពធុនតូចនិងមធ្យម

១.២ អង្គភាពធុនតូចនិងមធ្យម គឺជាអង្គភាពនានាដែល ៖

(ក) មិនមានការទទួលខុសត្រូវជាសាធារណៈ និង

(ខ) បោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅសម្រាប់អ្នកប្រើប្រាស់ខាងក្រៅ។ ឧទាហរណ៍នៃអ្នកប្រើប្រាស់ខាងក្រៅរួមមាន ម្ចាស់ដែលមិនពាក់ព័ន្ធក្នុងការគ្រប់គ្រងអាជីវកម្ម ម្ចាស់បំណុលបច្ចុប្បន្ន និងម្ចាស់បំណុលសក្តានុពល ព្រមទាំងភ្នាក់ងារវាយតម្លៃឥណទាន។

១.៣ អង្គភាពមួយមានការទទួលខុសត្រូវជាសាធារណៈ ប្រសិនបើ ៖

(ក) ឧបករណ៍បំណុលឬឧបករណ៍មូលធនរបស់អង្គភាពនោះ ត្រូវបានជួញដូរលើទីផ្សារសាធារណៈឬវាកំពុងតែស្ថិតក្នុងដំណើរការបោះផ្សាយលក់ឧបករណ៍បែបនេះ សម្រាប់ការជួញដូរលើទីផ្សារសាធារណៈ (ទីផ្សារហ៊ុនក្នុងស្រុក ឬ បរទេស ឬទីផ្សារជួញដូរក្រៅបរិវេណ រាប់បញ្ចូលទាំងទីផ្សារក្នុងស្រុក និងតាមតំបន់) ឬ

(ខ) ជាអាជីវកម្មចម្បងមួយក្នុងចំណោមអាជីវកម្មចម្បងនានារបស់អង្គភាពនេះ អង្គភាពនេះទទួលកាន់ទ្រព្យសកម្មក្នុងនាមជាអ្នកទទួលបញ្ញើសម្រាប់ក្រុមអ្នកក្រៅដ៏ច្រើន។ ធនាគារ សហភាពឥណទាន ក្រុមហ៊ុនធានារ៉ាប់រង ពាណិជ្ជករឬអន្តរការីមូលបត្រ មូលនិធិសង្គហធន និងធនាគារវិនិយោគភាគច្រើន នឹងបំពេញលក្ខណៈវិនិច្ឆ័យទីពីរនេះ។

១.៤ អង្គភាពខ្លះក៏ប្រហែលជាកាន់កាប់ទ្រព្យសកម្មឱ្យជនខាងក្រៅយ៉ាងច្រើនក្រុមតាមបែបបរធនបាលកិច្ច ពីព្រោះពួកគេកាន់កាប់និងគ្រប់គ្រងនូវធនធានហិរញ្ញវត្ថុ ដែលដាក់ផ្ញើនៅនឹងពួកគេដោយបណ្តាអតិថិជន ភ្ញៀវឬសមាជិកដែលមិនចូលរួមគ្រប់គ្រងអង្គភាព។ ប៉ុន្តែ ប្រសិនបើពួកគេធ្វើបែបនោះដោយសារមូលហេតុដែលកើតចេញពីអាជីវកម្មចម្បង (ឧទាហរណ៍ដូចជាករណីភ្នាក់ងារទេសចរណ៍ឬអចលនទ្រព្យ សាលារៀន អង្គការសប្បុរសធម៌ សហគ្រាសសហការដែលតម្រូវឱ្យដាក់ប្រាក់កក់និមិត្តរូបសម្រាប់សមាជិក និងអាជីវករដែលទទួលការទូទាត់មុនការផ្គត់ផ្គង់ទំនិញឬសេវាកម្មដូចជាក្រុមហ៊ុនផ្គត់ផ្គង់សាធារណៈជាដើម) ទង្វើនោះមិនធ្វើឱ្យពួកគេមានការទទួលខុសត្រូវជាសាធារណៈឡើយ។

១.៥ ប្រសិនបើអង្គភាព ដែលទទួលខុសត្រូវជាសាធារណៈប្រើប្រាស់ស្តង់ដារនេះ របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពនោះនឹងមិនត្រូវបានពិពណ៌នាថាបានអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យមទេ បើទោះបីជាច្បាប់ឬបទប្បញ្ញត្តិ នៅក្នុងយុត្តាធិការរបស់អង្គភាពនោះ បានអនុញ្ញាតឬតម្រូវឱ្យអង្គភាពទទួលខុសត្រូវជាសាធារណៈអនុវត្តតាមស្តង់ដារនេះក៏ដោយ។

១.៦ ចំពោះក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលក្រុមហ៊ុនមេរបស់ខ្លួន ប្រើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ឬក៏ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ ជាផ្នែកមួយនៃក្រុមរួម ដែលប្រើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ មិនត្រូវបានហាមឃាត់ពីការប្រើស្តង់ដារនេះ ក្នុងរបាយការណ៍ហិរញ្ញវត្ថុផ្ទាល់របស់ខ្លួនឡើយ ប្រសិនបើក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ ខ្លួនឯងមិនមានការទទួលខុសត្រូវជាសាធារណៈ។ ប្រសិនបើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ ត្រូវបានពិពណ៌នាថាអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ ត្រូវតែអនុលោមតាមវិធានទាំងអស់នៃស្តង់ដារនេះ។

១.៧ អង្គភាពមេ (រាប់បញ្ចូលទាំងក្រុមហ៊ុនមេខ្ពស់បំផុត ឬក្រុមហ៊ុនមេមធ្យម) វាយតម្លៃគុណវុឌ្ឍិរបស់ខ្លួន ក្នុងការប្រើប្រាស់ស្តង់ដារនេះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ខ្លួន ដោយផ្អែកលើស្ថានភាពរបស់ខ្លួនផ្ទាល់ ដោយមិនពិចារណាថាតើ អង្គភាពក្រុមដទៃ ឬក្រុមទាំងមូលមានការទទួលខុសត្រូវជាសាធារណៈដែរឬអត់ឡើយ។ ប្រសិនបើអង្គភាពមេខ្លួនឯងផ្ទាល់ មិនមានការទទួលខុសត្រូវជាសាធារណៈទេ អង្គភាពមេនោះ អាចបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ខ្លួន ស្របតាមស្តង់ដារនេះ (សូមមើលផ្នែកទី៩ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក) ទោះបីជាអង្គភាពមេនោះ បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ខ្លួន ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ឬបណ្តុំផ្សេងទៀតនៃគោលការណ៍គណនេយ្យទទួលយកជាទូទៅ (GAAP) ដូចជាស្តង់ដារគណនេយ្យជាតិរបស់អង្គភាពមេជាដើម។ របាយការណ៍ហិរញ្ញវត្ថុណាមួយ ដែលត្រូវបានរៀបចំស្របតាមស្តង់ដារនេះ ត្រូវបែងចែកឱ្យច្បាស់ពីរបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវបានរៀបចំស្របតាមការតម្រូវផ្សេងទៀត។

# ផ្នែកទី ២
# ទស្សនទាន និងគោលការណ៍ទូទៅ

## វិសាលភាពនៃផ្នែកនេះ

២.១ ផ្នែកនេះបរិយាយអំពី គោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពធុនតូចនិងមធ្យម (SMEs) និងគុណភាពដែលធ្វើឱ្យព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពធុនតូចនិងមធ្យម មានប្រយោជន៍ក្នុងការប្រើប្រាស់។ ផ្នែកនេះក៏កំណត់ផងដែរនូវទស្សនទាន និងគោលការណ៍គ្រឹះដែលជាសំអាង នៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពធុនតូចនិងមធ្យម។

## គោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពធុនតូច និងមធ្យម

២.២ គោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពធុនតូចឬមធ្យម គឺដើម្បីផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុលទ្ធផលអាជីវកម្ម និងលំហូរសាច់ប្រាក់របស់អង្គភាព ដែលមានប្រយោជន៍ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចដោយអ្នកប្រើប្រាស់ច្រើនមជ្ឈដ្ឋានរបស់របាយការណ៍ហិរញ្ញវត្ថុ ដែលមិនមានជំហរទាមទារឱ្យរបាយការណ៍ធ្វើតាមការតម្រូវជាពិសេស ដើម្បីបំពេញការត្រូវការព័ត៌មានជាក់លាក់របស់អ្នកប្រើប្រាស់ទាំងនោះ។

២.៣ របាយការណ៍ហិរញ្ញវត្ថុក៏បង្ហាញនូវលទ្ធផល នៃភាពជាអ្នកគ្រប់គ្រងរបស់អ្នកគ្រប់គ្រង ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើធនធានដែលគេបានផ្តល់ការទុកចិត្ត។

## លក្ខណៈផ្នែកគុណភាពនៃព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

### ភាពអាចយល់បាន

២.៤ ព័ត៌មានដែលផ្តល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបង្ហាញតាមរបៀប ដែលអាចយល់បានសម្រាប់អ្នកប្រើប្រាស់ ដែលមានចំណេះដឹងសមរម្យខាងសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច និងគណនេយ្យ និងមានឆន្ទៈសិក្សាអំពីព័ត៌មាននោះដោយការព្យាយាមដែលសមរម្យ។ ប៉ុន្តែ សេចក្តីត្រូវការនូវភាពអាចយល់បាន មិនអនុញ្ញាតឱ្យព័ត៌មានដែលពាក់ព័ន្ធត្រូវបានខកខានមិនបានដាក់បញ្ចូល ដោយសារតែប្រហែលជាពិបាកយល់ពេក សម្រាប់អ្នកប្រើប្រាស់មួយចំនួន។

### ភាពពាក់ព័ន្ធ

២.៥ ព័ត៌មានដែលផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវតែពាក់ព័ន្ធ សម្រាប់សេចក្តីត្រូវការក្នុងការសម្រេចចិត្តរបស់អ្នកប្រើប្រាស់។ ព័ត៌មានមានគុណភាពនៃភាពពាក់ព័ន្ធ នៅពេលដែលព័ត៌មាននោះអាចមានឥទ្ធិពលលើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយជួយដល់ពួកគេ ក្នុងការវាយតម្លៃព្រឹត្តិការណ៍អតីតកាល បច្ចុប្បន្នកាល ឬអនាគតកាល ឬអះអាង ឬកែតម្រូវលើការវាយតម្លៃកាលពីពេលមុនៗរបស់ពួកគេ។

## ភាពជាសារវន្ត

២.៦ ព័ត៌មានមានភាពជាសារវន្ត - និងដូច្នោះមានភាពពាក់ព័ន្ធ - ប្រសិនបើការខកខានមិនបានដាក់បញ្ចូល ឬការថ្លែងខុសអាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយផ្អែកលើ របាយការណ៍ហិរញ្ញវត្ថុនោះ។ ភាពជាសារវន្ត អាស្រ័យលើទំហំនិងសារជាតិនៃការខកខានមិនបានដាក់បញ្ចូល ឬការថ្លែងខុសដែលបានវិនិច្ឆ័យតាមកាលៈទេសៈជុំវិញខ្លួន។ ប៉ុន្តែ វាមិនសមស្របឡើយ ក្នុងការធ្វើ ឬទុកចោលមិនកែតម្រូវ ការងាកចេញមិនជាសារវន្តពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ដើម្បីសម្រេចការបង្ហាញជាក់លាក់ណាមួយនៃស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ ឬលំហូរសាច់ប្រាក់របស់អង្គភាព។

## ភាពជឿជាក់

២.៧ ព័ត៌មានដែលផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវតែអាចជឿជាក់បាន។ ព័ត៌មាន អាចជឿជាក់បាន នៅពេលដែលព័ត៌មាននោះ មិនមានកំហុសឆ្គង និងការលម្អៀងជាសារវន្ត ព្រមទាំងបង្ហាញយ៉ាងស្មោះត្រង់នូវអ្វីដែលព័ត៌មាននោះអះអាងតំណាងឱ្យ ឬអាចរំពឹងទុកយ៉ាងសមហេតុផលថាតំណាងឱ្យ។ របាយការណ៍ហិរញ្ញវត្ថុ មានការលម្អៀង (ពោលគឺ មិនអព្យាក្រឹត) ប្រសិនបើរបាយការណ៍ទាំងនោះ មានបំណងធ្វើឱ្យមានឥទ្ធិពលលើការសម្រេចចិត្តឬការវិនិច្ឆ័យ ដោយការជ្រើសរើស ឬការបង្ហាញព័ត៌មាន ដើម្បីសម្រេចបានលទ្ធផលដែលបានគិតទុកជាមុន។

## ខ្លឹមសារលើសទម្រង់

២.៨ ប្រតិបត្តិការ និងព្រឹត្តិការណ៍និងកាលៈទេសៈដទៃទៀត ត្រូវតែធ្វើគណនេយ្យកម្ម និងបង្ហាញស្របតាមខ្លឹមសាររបស់ប្រតិបត្តិការ និងព្រឹត្តិការណ៍និងកាលៈទេសៈដទៃទៀតទាំងនោះ និងមិនមែនត្រឹមតែទម្រង់ច្បាប់នោះទេ។ នេះបង្កើននូវភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ការប្រុងប្រយ័ត្ន

២.៩ ភាពមិនប្រាកដប្រជានៅជុំវិញព្រឹត្តិការណ៍ និងកាលៈទេសៈជាច្រើនដែលមិនអាចជៀសផុត ត្រូវបានទទួលស្គាល់តាមរយៈការលាតត្រដាងអំពីសារជាតិ និងកម្រិតនៃព្រឹត្តិការណ៍ និងកាលៈទេសៈទាំងនោះ និងដោយប្រើការប្រុងប្រយ័ត្ន ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ការប្រុងប្រយ័ត្ន គឺជាការបញ្ចូល នូវកម្រិតនៃការប្រយ័ត្នប្រយែងក្នុងការប្រើការវិនិច្ឆ័យដែលចាំបាច់ ដើម្បីធ្វើការប៉ាន់ស្មានដែលបានតម្រូវក្រោម ស្ថានការណ៍មិនប្រាកដប្រជា ដូចនេះហើយទើប ទ្រព្យសកម្ម ឬចំណូល មិនត្រូវបានថ្លែងពន្លើស ហើយបំណុល ឬចំណាយ មិនត្រូវបានថ្លែងបន្ទាប។ ទោះយ៉ាងណា ការអនុវត្តការប្រុងប្រយ័ត្ន មិនអនុញ្ញាតការថ្លែងបន្ទាបដោយចេតនានៃទ្រព្យសកម្ម ឬចំណូល ឬការថ្លែងពន្លើសដោយចេតនានៃបំណុល ឬចំណាយ។ និយាយឱ្យខ្លីការប្រុងប្រយ័ត្នមិនអនុញ្ញាតឱ្យមានភាពលំអៀងឡើយ។

## ភាពពេញលេញ

២.១០ ដើម្បីឱ្យជឿជាក់បាន ព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវតែមានលក្ខខណៈពេញលេញ ក្នុងវិសាលភាពនៃភាពជាសារវន្ត និងថ្លៃដើម។ ការខកខានមិនបានដាក់បញ្ចូលណាមួយ អាចធ្វើឱ្យព័ត៌មានក្លែងក្លាយ ឬនាំឱ្យយល់ខុស ដូច្នេះហើយធ្វើឱ្យមិនអាចជឿជាក់បាន និងខ្វះខាតដោយនិយាយក្នុងវិសាលភាពភាពទាក់ទិនរបស់ព័ត៌មាននោះ។

## ភាពអាចប្រៀបធៀបបាន

២.១១ អ្នកប្រើប្រាស់ត្រូវតែអាចធ្វើការប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយ តាមរយៈពេលវេលា ដើម្បីកំណត់និន្នាការនៃស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាពនោះ។ អ្នកប្រើប្រាស់ក៏ត្រូវតែអាចប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពខុសៗគ្នា ដើម្បីវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ លទ្ធផលអាជីវកម្ម និងលំហូរសាច់ប្រាក់ប្រៀបធៀបរបស់អង្គភាពទាំងនោះ។ ដូច្នេះ ការវាស់វែង និងការបង្ហាញនៃឥទ្ធិពលហិរញ្ញវត្ថុ នៃប្រតិបត្តិការប្រភេទដូចគ្នា និងព្រឹត្តិការណ៍ និងស្ថានការណ៍ផ្សេងទៀត ត្រូវតែប្រព្រឹត្តទៅប្រកបដោយសង្គតិភាពទូទាំងអង្គភាពទាំងមូល និងតាមការខិតទៅនៃពេលវេលាសម្រាប់អង្គភាពនោះ និងប្រកបដោយសង្គតិភាព រវាងអង្គភាពនានា។ បន្ថែមពីនេះ អ្នកប្រើប្រាស់ត្រូវតែបានប្រាប់នូវគោលនយោបាយគណនេយ្យ ដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងដឹងអំពីការប្រែប្រួលនានានៃគោលនយោបាយទាំងនោះ ព្រមទាំងឥទ្ធិពលនៃការប្រែប្រួលទាំងនោះ។

## ភាពទាន់ពេល

២.១២ ដើម្បីឱ្យមានការពាក់ព័ន្ធ ព័ត៌មានហិរញ្ញវត្ថុ ត្រូវតែអាចមានឥទ្ធិពល លើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់។ ភាពទាន់ពេល សំដៅទៅលើការផ្តល់ព័ត៌មានស្ថិតក្នុងគ្រោងពេលវេលាធ្វើការសម្រេចចិត្ត។ ប្រសិនបើមានការពន្យារពេលហួសហេតុ ក្នុងការរាយការណ៍ព័ត៌មាន ព័ត៌មាននោះអាចបាត់បង់ភាពទាក់ទិនរបស់វា។ ថ្នាក់គ្រប់គ្រង ត្រូវធ្វើការថ្លឹងថ្លែងពីគុណសម្បត្តិប្រៀបធៀបនៃការរាយការណ៍ទាន់ពេលវេលា និងការផ្តល់ព័ត៌មាន ដែលគួរឱ្យជឿទុកចិត្ត។ ដើម្បីទទួលបានតុល្យភាពរវាង ភាពទាក់ទិន និងភាពគួរឱ្យជឿទុកចិត្ត ការពិចារណា ដែលសំខាន់បំផុតគឺ ត្រូវធ្វើយ៉ាងណាឱ្យបានល្អបំផុត ដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ ក្នុងការធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

## តុល្យភាពរវាងអត្ថប្រយោជន៍ និងថ្លៃដើម

២.១៣ អត្ថប្រយោជន៍ដែលទាញបានពីព័ត៌មាន គួរតែលើសពីថ្លៃដើមនៃការផ្តល់ព័ត៌មាននោះ។ ការវាយតម្លៃអត្ថប្រយោជន៍ និងថ្លៃដើម ជាតុពិតទៅគឺជាប្រភេទមួយនៃដំណើរការការវិនិច្ឆ័យ។ ម្យ៉ាងវិញទៀត ថ្លៃដើមមិនប្រាកដជាប៉ះរងដោយអ្នកដែលទទួលបានអត្ថប្រយោជន៍ទាំងនោះនោះទេ ហើយជារឿយៗ អត្ថប្រយោជន៍នៃព័ត៌មាន ត្រូវបានទទួលដោយអ្នកប្រើប្រាស់ខាងក្រៅច្រើនមជ្ឈដ្ឋាន។

២.១៤ ព័ត៌មានរាយការណ៍ហិរញ្ញវត្ថុ ជួយឱ្យអ្នកផ្តល់មូលធនធ្វើការសម្រេចចិត្តដែលល្អជាង ដែលជាលទ្ធផលធ្វើឱ្យទីផ្សារមូលធនដំណើរការកាន់តែមានប្រសិទ្ធភាព និងថ្លៃដើមមូលធនដែលទាបជាងសម្រាប់សេដ្ឋកិច្ចទាំងមូល។ អង្គភាពទោលនានា ក៏ទទួលអត្ថប្រយោជន៍ដែរ រួមមាន ការអាចប្រើប្រាស់ទីផ្សារមូលធនមានភាពប្រសើរជាងមុន ឥទ្ធិពលអំណោយផលលើទំនាក់ទំនងសាធារណៈ និងប្រហែលជាថ្លៃដើមមូលធនដែលទាបជាង។ អត្ថប្រយោជន៍ ក៏អាចរាប់បញ្ចូលការសម្រេចចិត្តល្អជាងរបស់ថ្នាក់គ្រប់គ្រង ពីព្រោះព័ត៌មានហិរញ្ញវត្ថុដែលប្រើប្រាស់ផ្ទៃក្នុងជារឿយៗ ផ្អែកលើយ៉ាងហោចណាស់មួយចំណែកនៃព័ត៌មាន ដែលបានរៀបចំសម្រាប់គោលបំណងរាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ។

## ចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ

២.១៤ក ការលើកលែងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ត្រូវបានបញ្ជាក់ សម្រាប់ការតម្រូវមួយចំនួននៅក្នុងស្តង់ដារនេះ។ ការលើកលែងនេះ មិនត្រូវបានប្រើប្រាស់សម្រាប់ការតម្រូវដទៃទៀត នៅក្នុងស្តង់ដារនេះឡើយ។

២.១៤ខ ការពិចារណាថាតើការទទួលបាន ឬការកំណត់ព័ត៌មាន ដែលចាំបាច់ ក្នុងការប្រតិបត្តិតាមការតម្រូវ នឹងពាក់ព័ន្ធចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ដែរឬអត់ គឺអាស្រ័យទៅលើស្ថានការណ៍ជាក់លាក់របស់អង្គភាព និងការវិនិច្ឆ័យរបស់អ្នកគ្រប់គ្រង លើថ្លៃដើម និងអត្ថប្រយោជន៍ពីការអនុវត្តការតម្រូវនោះ។ ការវិនិច្ឆ័យនេះ តម្រូវឱ្យមានការពិចារណាថា តើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកដែលត្រូវបានរំពឹងថា នឹងប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនោះ អាចប៉ះពាល់ដោយការខ្វះខាតព័ត៌មាននោះដូចម្តេចដែរ។ ការអនុវត្តការតម្រូវនោះ នឹងពាក់ព័ន្ធជាមួយចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុរបស់អង្គភាពធុនតូច និងមធ្យម ប្រសិនបើថ្លៃដើមបន្ថែម (ឧទាហរណ៍៖ ថ្លៃឈ្នួលរបស់អ្នកវាយតម្លៃ) ឬកិច្ចប្រឹងប្រែងបន្ថែម (ឧទាហរណ៍៖ ការប្រឹងប្រែងរបស់និយោជិត) ហួសហេតុខ្លាំងគួរឱ្យកត់សម្គាល់លើសអត្ថប្រយោជន៍ ដែលជនទាំងឡាយ ដែលគេរំពឹងថានឹងប្រើប្រាស់ របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពធុនតូចនិងមធ្យម នឹងទទួលបានពីការមានព័ត៌មាននោះ។ ការវាយតម្លៃចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុដោយអង្គភាពធុនតូច និងមធ្យមស្របតាមស្តង់ដារនេះ ជាធម្មតានឹងបង្កើតជាឧបសគ្គទាបជាងការវាយតម្លៃចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ដោយអង្គភាពទទួលខុសត្រូវជាសាធារណៈ ពីព្រោះអង្គភាពធុនតូចនិងមធ្យមមិនទទួលខុសត្រូវចំពោះអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ។

២.១៤គ ការវាយតម្លៃថាតើការតម្រូវនឹងពាក់ព័ន្ធនឹងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុឬអត់ លើការទទួលស្គាល់ដំបូងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឧទាហរណ៍ដូចជានៅកាលបរិច្ឆេទប្រតិបត្តិការ គួរផ្អែកលើព័ត៌មានអំពីថ្លៃដើម និងអត្ថប្រយោជន៍នៃការតម្រូវ នៅពេលទទួលស្គាល់ដំបូង។ ប្រសិនបើការលើកលែងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុក៏អនុវត្តចំពោះក្រោយការទទួលស្គាល់ដំបូង ឧទាហរណ៍៖ ទៅលើការវាស់វែងជាបន្តបន្ទាប់ទៀតលើធាតុមួយការវាយតម្លៃថ្មីលើចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ គួរត្រូវធ្វើឡើងនៅកាលបរិច្ឆេទបន្តបន្ទាប់នោះ ដោយផ្អែកលើព័ត៌មានដែលអាចរកបាន នៅថ្ងៃនោះ។

២.១៤ឃ វៀរលែងតែការលើកលែងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ នៅក្នុងកថាខណ្ឌ១៩.១៥ ដែលត្រូវបាននិយាយដល់ដោយការតម្រូវឱ្យលាតត្រដាងនៅក្នុងកថាខណ្ឌ១៩.២៥ នៅពេលណាដែលការលើកលែងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ត្រូវបានប្រើប្រាស់ដោយអង្គភាពមួយ អង្គភាពនោះត្រូវលាតត្រដាងអង្គហេតុនោះ និងមូលហេតុ ដែលនាំឱ្យការអនុវត្តការតម្រូវនោះ នឹងពាក់ព័ន្ធនឹងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ។

# ស្ថានភាពហិរញ្ញវត្ថុ

២.១៥ ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពមួយ គឺជាទំនាក់ទំនងនៃទ្រព្យសកម្ម បំណុល និងមូលធន នាកាលបរិច្ឆេទជាក់លាក់ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ទ្រព្យសកម្ម បំណុល និងមូលធនត្រូវបានឱ្យនិយមន័យដូចខាងក្រោម៖

(ក) ទ្រព្យសកម្ម គឺជាធនធានដែលគ្រប់គ្រងដោយអង្គភាព ដែលជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាលហើយដែលគេរំពឹងថាអត្ថប្រយោជន៍សេដ្ឋកិច្ចពីធនធាននោះ នឹងហូរចូលអង្គភាពនាពេលអនាគត

(ខ) បំណុល គឺជាកាតព្វកិច្ចបច្ចុប្បន្នរបស់អង្គភាព ដែលកើតពីព្រឹត្តិការណ៍អតីតកាល ហើយដែលការទូទាត់កាតព្វកិច្ចនេះត្រូវបានរំពឹងថា នឹងនាំឱ្យមានលំហូរចេញនូវធនធានដែលជាអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់អង្គភាព និង

(គ) មូលធន គឺជាផលប្រយោជន៍ដែលនៅសល់ក្នុងទ្រព្យសកម្មរបស់អង្គភាព បន្ទាប់ពីកាត់កងជាមួយ បំណុលទាំងអស់របស់ខ្លួន។

២.១៦ ជាតុមួយចំនួនដែលបំពេញនិយមន័យនៃទ្រព្យសកម្ម ឬបំណុល អាចមិនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ឬបំណុល នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ពីព្រោះធាតុទាំងនោះមិនបំពេញលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់ដូចក្នុងកថាខណ្ឌ ២.២៧- ២.៣២។ ជាពិសេស ការរំពឹងទុកដែលថា អត្ថប្រយោជន៍ សេដ្ឋកិច្ចអនាគតនឹងហូរចូល ឬហូរចេញពីអង្គភាព ត្រូវតែមានភាពប្រាកដប្រជាគ្រប់គ្រាន់ ដើម្បីបំពេញលក្ខណៈវិនិច្ឆ័យភវនីយភាពមុនពេលទ្រព្យសកម្ម ឬបំណុលត្រូវបានទទួលស្គាល់។

## ទ្រព្យសកម្ម

២.១៧ អត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតនៃទ្រព្យសកម្មមួយ គឺជាសក្ដានុពលរបស់វា ក្នុងការរួមចំណែក ដោយផ្ទាល់ឬដោយប្រយោលក្តី ចំពោះលំហូរសាច់ប្រាក់ និងសាច់ប្រាក់សមមូល ចូលអង្គភាពនោះ។ លំហូរសាច់ប្រាក់ទាំងនោះអាចបានមកពីការប្រើប្រាស់ ឬការបញ្ចេញចោលនូវទ្រព្យសកម្មនោះ។

២.១៨ ទ្រព្យសកម្មជាច្រើន ដូចជាទ្រព្យ រោងចក្រ និងបរិក្ខារ មានទម្រង់រូបវិទ្យារបស់វា។ ប៉ុន្តែ ទម្រង់រូបវិទ្យាមិនសំខាន់សម្រាប់អត្ថិភាពនៃទ្រព្យសកម្មនោះទេ។ ទ្រព្យសកម្មខ្លះ អរូបី។

២.១៩ នៅក្នុងកំណត់អំពីអត្ថិភាពនៃទ្រព្យសកម្មមួយ សិទ្ធិកម្មសិទ្ធិ មិនសំខាន់ឡើយ។ ដូច្នេះ ឧទាហរណ៍ អចលនទ្រព្យដែលកាន់កាប់តាមរយៈភតិសន្យា គឺជាទ្រព្យសកម្មមួយ ប្រសិនបើអង្គភាពគ្រប់គ្រង អត្ថប្រយោជន៍ដែលរំពឹងថានឹងហូរពីអចលនទ្រព្យនោះ។

## បំណុល

២.២០ លក្ខណៈចម្បងនៃបំណុលគឺថា អង្គភាពមានកាតព្វកិច្ចបច្ចុប្បន្ន ដែលត្រូវអនុវត្ត ឬបំពេញតាមមធ្យោបាយជាក់លាក់មួយ។ កាតព្វកិច្ចអាចជាកាតព្វកិច្ចផ្លូវច្បាប់ បើមិនអញ្ចឹងទេជាកាតព្វកិច្ចដោយសន្មត។ កាតព្វកិច្ចផ្លូវច្បាប់ គឺត្រូវបង្ខំឱ្យអនុវត្តតាមច្បាប់ ដែលជាលទ្ធផលនៃកិច្ចសន្យា ត្រូវប្រតិបត្តិតាម ឬការតម្រូវផ្លូវច្បាប់។ កាតព្វកិច្ចដោយសន្មតគឺជាកាតព្វកិច្ចដែលកើតចេញពីទង្វើរបស់អង្គភាព នៅពេលដែល៖

(ក) ផ្អែកលើទម្លាប់ដែលបានអនុវត្តកន្លងមក គោលនយោបាយដែលបានចេញផ្សាយ ឬសេចក្តីថ្លែងការណ៍បច្ចុប្បន្នជាក់លាក់គ្រប់គ្រាន់ អង្គភាពបានបង្ហាញដល់ភាគីផ្សេងទៀតថា អង្គភាពនោះនឹងរ៉ាប់រងការទទួលខុសត្រូវជាក់លាក់ និង

(ខ) ជាលទ្ធផល អង្គភាពបានធ្វើឱ្យភាគីផ្សេងទៀតកើតឡើងនូវការរំពឹងទុកដ៏សមហេតុផលថា ខ្លួននឹងបំពេញការទទួលខុសត្រូវទាំងនោះ។

២.២១ ជាធម្មតា ការបំពេញកាតព្វកិច្ចបច្ចុប្បន្ន ពាក់ព័ន្ធនឹងការទូទាត់ជាសាច់ប្រាក់ ការផ្ទេរទ្រព្យសកម្មដទៃទៀត ការផ្តល់សេវា ការជំនួសកាតព្វកិច្ចនោះជាមួយកាតព្វកិច្ចផ្សេងទៀត ឬការបង្វែរពីកាតព្វកិច្ចទៅជាមូលធន។ កាតព្វកិច្ចក៏អាចរំលត់តាមមធ្យោបាយផ្សេងទៀត ដូចជា ការលះបង់ ឬបាត់បង់សិទ្ធិរបស់ម្ចាស់បំណុល។

## មូលធន

២.២២ មូលធន គឺជាសំណល់នៃទ្រព្យសកម្មបានទទួលស្គាល់ ដកបំណុលបានទទួលស្គាល់។ មូលធនអាចត្រូវបានចាត់ជាចំណាត់ថ្នាក់ឈានមួយកម្រិតទៀត នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ឧទាហរណ៍៖ នៅក្នុងអង្គភាពសាជីវកម្មមួយ ការចាត់ចំណាត់ថ្នាក់ឈានមួយកម្រិតទៀត អាចរួមបញ្ចូលនូវថវិកា ដែលបានផ្តល់ដោយម្ចាស់ភាគហ៊ុន ប្រាក់ចំណេញរក្សាទុកនិងធាតុនានានៃចំណូលលម្អិតផ្សេងៗ ដែលត្រូវបានទទួលស្គាល់ជាស

មាស ជាតុដោយឡែកមួយនៃមូលធន។ ស្តង់ដារនេះ មិនបានដាក់បញ្ញត្តិថា តើចំនួនទឹកប្រាក់អាចត្រូវបានផ្ទេររវាងសមាសធាតុនៃមូលធន ដោយរបៀបណា នៅពេលណា ឬបានឬអត់នោះទេ។

## លទ្ធផលអាជីវកម្ម

២.២៣ លទ្ធផលអាជីវកម្ម គឺជាទំនាក់ទំនងនៃចំណូល និងចំណាយរបស់អង្គភាពមួយ ក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។ ស្តង់ដារនេះអនុញ្ញាតឱ្យអង្គភាពនានា បង្ហាញលទ្ធផលអាជីវកម្មនៅក្នុងរបាយការណ៍ទោល (របាយការណ៍ចំណូលពេញលេញ) ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុពីរ (របាយការណ៍លទ្ធផល និងរបាយការណ៍ចំណូលពេញលេញ)។ ជារឿយៗ ចំណូលពេញលេញសរុបនិងចំណេញ ឬខាត ត្រូវបានប្រើប្រាស់ជាការវាស់វែងលទ្ធផលអាជីវកម្ម ឬជាមូលដ្ឋានសម្រាប់ការវាស់វែងដទៃទៀត ដូចជាការតបស្នងពីការវិនិយោគ ឬចំណេញក្នុងមួយភាគហ៊ុន។ ចំណូល និងចំណាយត្រូវបានឱ្យនិយមន័យដូចខាងក្រោម៖

(ក) ចំណូល គឺជាកំណើននៃអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ក្នុងទម្រង់ជាលំហូរចូល ឬកំណើនទ្រព្យសកម្ម ឬការថយចុះនៃបំណុល ដែលជាលទ្ធផលនាំឱ្យមូលធនមានការកើនឡើងក្រៅពីការកើនឡើងដែលទាក់ទិននឹងវិភាគទានពីម្ចាស់ និង

(ខ) ចំណាយ គឺជាការថយចុះនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ក្នុងទម្រង់ជាលំហូរចេញ ឬតនុកម្ម (ការប្រើអស់) នៃទ្រព្យសកម្ម ឬការកើតឡើងនៃបំណុល ដែលជាលទ្ធផលនាំឱ្យមូលធនថយចុះ ក្រៅពីការថយនោះ ដែលទាក់ទិននឹងការបែងចែកទៅឱ្យម្ចាស់។

២.២៤ ការទទួលស្គាល់ចំណូល និងចំណាយ កើតចេញដោយផ្ទាល់ពីការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មនិងបំណុល។ លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ចំណូល និងចំណាយ ត្រូវបានពិភាក្សានៅក្នុងកថាខណ្ឌ ២.២៧-២.៣២។

### ចំណូល

២.២៥ និយមន័យនៃចំណូល បូករួមទាំងប្រាក់ចំណូល និងចំណេញ។

(ក) ប្រាក់ចំណូល គឺជាចំណូលដែលកើតពីប្រតិបត្តិការសកម្មភាពធម្មតារបស់អង្គភាព និងមានឈ្មោះច្រើនប្រភេទដូចជា ចំណូលពីការលក់ ថ្លៃសេវា ការប្រាក់ ភាគលាភ សួយសារនិងថ្លៃជួល។

(ខ) ចំណេញ គឺជាធាតុផ្សេងទៀត ដែលបំពេញតាមនិយមន័យនៃចំណូល ប៉ុន្តែមិនមែនជាប្រាក់ចំណូលទេ។ នៅពេលដែលចំណេញត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលពេញលេញចំណេញទាំងនោះជាទូទៅត្រូវបានបង្ហាញដោយឡែក ពីព្រោះការយល់ដឹងស្ថានការណ៍ចំណេញ មានប្រយោជន៍សម្រាប់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

### ចំណាយ

២.២៦ និយមន័យនៃចំណាយរួមមានការខាត ក៏ដូចជាចំណាយទាំងអស់ដែលកើតចេញពីប្រតិបត្តិការសកម្មភាពធម្មតារបស់អង្គភាព។

(ក) ចំណាយ ដែលកើតចេញពីប្រតិបត្តិការសកម្មភាពធម្មតារបស់អង្គភាពរួមមាន ឧទាហរណ៍ ថ្លៃដើមនៃការលក់

ប្រាក់ឈ្នួល និងរំលស់។ ចំណាយទាំងនោះ តាមធម្មតាយកទម្រង់ជាលំហូរចេញ ឬតនុកម្ម (ការប្រើអស់) នៃទ្រព្យសកម្ម ដូចជា សាច់ប្រាក់ និងសាច់ប្រាក់សមមូល សន្និធិ ឬទ្រព្យ រោងចក្រ និងបរិក្ខារ។

(ខ) ការខាត គឺជាធាតុផ្សេងទៀត ដែលបំពេញតាមនិយមន័យនៃចំណាយ និងអាចកើតពីសកម្មភាពប្រតិបត្តិការធម្មតារបស់អង្គភាព។ នៅពេលដែលការខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលពេញលេញជាធម្មតា ការខាតទាំងនោះត្រូវបានបង្ហាញដាច់ដោយឡែក ពីព្រោះការយល់ដឹងស្ថានការណ៍ការខាតមានប្រយោជន៍សម្រាប់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

## ការទទួលស្គាល់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ

២.២៧ ការទទួលស្គាល់ គឺជាដំណើរការនៃការបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុនូវធាតុ ដែលបំពេញនិយមន័យនៃទ្រព្យសកម្ម បំណុល ចំណូល ឬចំណាយ និងបំពេញលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

(ក) អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចអនាគត ដែលជាប់ពាក់ព័ន្ធជាមួយធាតុនោះ អាចនឹងហូរចូលឬចេញពីអង្គភាព និង

(ខ) ធាតុនោះមានថ្លៃដើម ឬតម្លៃ ដែលអាចវាស់វែងបានដោយជឿជាក់។

២.២៨ ការខកខានមិនបានទទួលស្គាល់ធាតុ ដែលបំពេញលក្ខណៈវិនិច្ឆ័យទាំងនោះ មិនត្រូវបានកែតម្រូវដោយការលាតត្រដាងអំពីគោលនយោបាយគណនេយ្យ ដែលបានប្រើប្រាស់ ឬដោយកំណត់សម្គាល់ ឬសម្ភារៈបែបពន្យល់ឡើយ។

## ភាពប្រូបាបនៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត

២.២៩ ទស្សនទាននៃភាវនីយភាព ត្រូវបានប្រើប្រាស់នៅក្នុងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ដំបូង ដើម្បីសំដៅដល់កម្រិតនៃភាពមិនប្រាកដប្រជា ដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចអនាគត ដែលជាប់ពាក់ព័ន្ធជាមួយធាតុនោះនឹងហូរចូល ឬហូរចេញពីអង្គភាព។ ការវាយតម្លៃអំពីកម្រិតនៃភាពមិនប្រាកដប្រជា ដែលភ្ជាប់ទៅនឹងលំហូរនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចអនាគត ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលទាក់ទងនឹងលក្ខខណ្ឌនានាចុងការិយបរិច្ឆេទរាយការណ៍ ដែលអាចរកបាន នៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង។ ការវាយតម្លៃទាំងនោះត្រូវបានធ្វើឡើងដោយឡែកៗពីគ្នា សម្រាប់ធាតុសំខាន់ៗដោយឡែកៗពីគ្នា និងសម្រាប់ក្រុមនៃធាតុមិនសំខាន់ដោយឡែកៗពីគ្នា។

## ភាពជឿជាក់នៃការវាស់វែង

២.៣០ លក្ខណៈវិនិច្ឆ័យទីពីរ សម្រាប់ការទទួលស្គាល់ធាតុមួយគឺថា ធាតុនោះមានថ្លៃដើម ឬតម្លៃ ដែលអាចត្រូវបានវាស់វែងប្រកបដោយភាពជឿជាក់។ នៅក្នុងករណីជាច្រើន ថ្លៃដើម ឬតម្លៃនៃធាតុមួយត្រូវបានដឹង។ នៅក្នុងករណីផ្សេងទៀត ថ្លៃដើម ឬតម្លៃរបស់ធាតុនោះត្រូវតែធ្វើការប៉ាន់ស្មាន។ ការប្រើប្រាស់ការប៉ាន់ស្មានដែលសមហេតុផល គឺជាផ្នែកសំខាន់មួយនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងមិនប៉ះពាល់ដល់ភាពជឿជាក់របស់របាយការណ៍ហិរញ្ញវត្ថុទាំងនោះ។ នៅពេលដែលការប៉ាន់ស្មានសមហេតុផល មិនអាចធ្វើទៅបាន ធាតុនោះមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

២.៣១ ធាតុមួយដែលមិនបំពេញលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់អាចមានគុណវុឌ្ឍិសម្រាប់ការទទួលស្គាល់នៅថ្ងៃក្រោយ ជាលទ្ធផលនៃកាលៈទេសៈ ឬព្រឹត្តិការណ៍ ដែលកើតឡើងនៅពេលក្រោយ។

២.៣២ ជាតុមួយដែលមិនបំពេញលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់អាចនៅតែត្រូវការលាតត្រដាង នៅក្នុងកំណត់សម្គាល់ ឬសម្ភារៈបែបពន្យល់ ឬក្នុងតារាងបន្ថែម។ នេះជាការសមរម្យ នៅពេលការយល់ដឹងអំពីជាតុនោះទាក់ទិននឹងការវាយតម្លៃអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលអាជីវកម្ម និងការប្រែប្រួលនៃស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពមួយដោយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ។

## ការវាស់វែងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ

២.៣៣ ការវាស់វែង គឺជាដំណើរការនៃការកំណត់នូវបរិមាណរូបិយវត្ថុដែលអង្គភាពវាស់វែងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ ការវាស់វែងពាក់ព័ន្ធទៅដល់ការជ្រើសរើសមូលដ្ឋាននៃការវាស់វែង។ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះចង្អុលកំណត់ថា តើមូលដ្ឋាននៃការវាស់វែងមួយណាដែលអង្គភាពត្រូវប្រើប្រាស់ សម្រាប់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយជាច្រើនប្រភេទ។

២. ៣៤ មូលដ្ឋាននៃការវាស់វែងពីរប្រភេទដែលប្រើជាទូទៅ គឺថ្លៃដើមប្រវត្តិ និងតម្លៃសមស្រប៖

(ក) សម្រាប់ទ្រព្យសកម្ម ថ្លៃដើមប្រវត្តិ គឺជាចំនួនទឹកប្រាក់នៃសាច់ប្រាក់ ឬសាច់ប្រាក់សមមូលដែលបានទូទាត់ ឬតម្លៃសមស្របនៃការតបស្នង ដែលបានផ្តល់ឱ្យ ដើម្បីទទួលបានទ្រព្យសកម្ម នៅពេលទិញទ្រព្យសកម្មនោះ។ សម្រាប់បំណុល ថ្លៃដើមប្រវត្តិ គឺជាចំនួនទឹកប្រាក់សរុបដែលបាននៃសាច់ប្រាក់ ឬសាច់ប្រាក់សមមូលដែលទទួលបាន ឬតម្លៃសមស្របនៃទ្រព្យសកម្មមិនមែនជាសាច់ប្រាក់ ដែលទទួលបានជាការដោះដូរនឹងកាតព្វកិច្ច នៅពេលដែល កាតព្វកិច្ចនោះ កើតមានឡើង ឬនៅក្នុងកាលៈទេសៈមួយចំនួន (ដូចជា ពន្ធលើប្រាក់ចំណូល) ចំនួនទឹកប្រាក់នៃសាច់ប្រាក់ឬ សាច់ប្រាក់សមមូល ត្រូវបានរំពឹងថានឹងត្រូវចំណាយ ដើម្បីទូទាត់បំណុលនៅក្នុង ប្រតិបត្តិការធម្មតារបស់អាជីវកម្ម។ ថ្លៃដើមប្រវត្តិបានរំលស់ គឺជាថ្លៃដើមប្រវត្តិនៃទ្រព្យសកម្ម ឬបំណុលបូក ឬ ដកនឹងចំណែកនៃថ្លៃដើមប្រវត្តិ ដែលត្រូវបានទទួលស្គាល់ពីមុនថាជាចំណាយ ឬចំណូល។

(ខ) តម្លៃសមស្រប គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្ម អាចត្រូវបានធ្វើការដោះដូរ ឬ បំណុលត្រូវបានទូទាត់រវាងភាគីដែលដឹងរឿង និងមានបំណងធ្វើ នៅក្នុងប្រតិបត្តិការធម្មតា។

## គោលការណ៍ទូទៅនៃការទទួលស្គាល់ និងការវាស់វែង

២.៣៥ ការតម្រូវសម្រាប់ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយនៅក្នុងស្តង់ដារនេះ គឺផ្អែកលើគោលការណ៍ទូទៅ ដែលបានមកពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ។ នៅពេលដែលមិនមានការតម្រូវនៅក្នុងស្តង់ដារនេះ ដែលអនុវត្តជាពិសេសចំពោះប្រតិបត្តិការ ឬព្រឹត្តិការណ៍ ឬស្ថានការណ៍ដទៃទៀត កថាខណ្ឌ១០.៤ ផ្តល់នូវការណែនាំសម្រាប់ការធ្វើវិនិច្ឆ័យ ហើយកថាខណ្ឌ១០.៥ បង្កើតនូវឋានានុក្រមសម្រាប់អង្គភាពអនុវត្តតាម ក្នុងការសម្រេចចិត្តលើគោលនយោបាយគណនេយ្យដែលសមស្រប នៅក្នុងកាលៈទេសៈផ្សេងៗ។ កម្រិតទីពីរនៃឋានានុក្រមនោះ តម្រូវឱ្យអង្គភាពពិនិត្យនិយមន័យ លក្ខណៈវិនិច្ឆ័យការទទួលស្គាល់ និងទស្សនទាននៃការវាស់វែងសម្រាប់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ និងគោលការណ៍ ទូទៅដែលបានកំណត់នៅក្នុងផ្នែកនេះ។

# មូលដ្ឋានបង្គរ

២.៣៦ អង្គភាពត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយប្រើប្រាស់មូលដ្ឋានគណនេយ្យបង្គរលើកលែងតែព័ត៌មានអំពីលំហូរសាច់ប្រាក់។ ផ្អែកលើមូលដ្ឋានបង្គរ ធាតុនានាត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្ម បំណុល មូលធន ចំណូល ឬចំណាយ នៅពេលដែលធាតុទាំងនោះបំពេញនិយមន័យ និងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់សម្រាប់ធាតុទាំងនោះ។

# ការទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

## ទ្រព្យសកម្ម

២.៣៧ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលមានភាពប្រហែលថាអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត នឹងហូរចូលអង្គភាព ហើយទ្រព្យសកម្មមានថ្លៃដើម ឬតម្លៃដែលអាចវាស់វែង គួរឱ្យជឿជាក់។ ទ្រព្យសកម្ម មិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទេ នៅពេលដែលការចំណាយបានកើតឡើង ដែលអង្គភាពចាត់ទុកថា ការចំណាយនោះ ប្រហែលជានឹង មិននាំឱ្យអត្ថប្រយោជន៍សេដ្ឋកិច្ចហូរចូលអង្គភាពហួសពីការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន។ ផ្ទុយទៅវិញ ប្រតិបត្តិការនេះ នាំឱ្យមានការទទួលស្គាល់ចំណាយនៅក្នុងរបាយការណ៍ចំណូលពេញលេញ (ឬនៅក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ)។

២.៣៨ អង្គភាពមិនត្រូវទទួលស្គាល់ទ្រព្យសកម្មយថាហេតុថាជាទ្រព្យសកម្មទេ។ ប៉ុន្តែនៅពេលដែលលំហូរនៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតចូលក្នុងអង្គភាពសឹងតែប្រាកដទៅហើយ នោះទ្រព្យសកម្ម ដែលពាក់ព័ន្ធមិនមែនជាទ្រព្យសកម្មយថាហេតុទេ ហើយការទទួលស្គាល់ទ្រព្យសកម្មនោះ គឺជាការសមស្រប។

## បំណុល

២.៣៩ អង្គភាពត្រូវទទួលស្គាល់បំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែល៖

(ក) អង្គភាពមានកាតព្វកិច្ចនាចុងការិយបរិច្ឆេទរាយការណ៍ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាល

(ខ) អង្គភាពអាចនឹងត្រូវបានតម្រូវឱ្យផ្ទេរធនធានដែលបង្កប់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនៅក្នុងការទូទាត់ និង

(គ) ចំនួនទឹកប្រាក់ទូទាត់ អាចត្រូវបានវាស់វែងបានគួរឱ្យជឿជាក់។

២.៤០ បំណុលយថាហេតុ គឺជាកាតព្វកិច្ចដែលអាចមាន តែមិនប្រាកដ ឬកាតព្វកិច្ចបច្ចុប្បន្ន ដែលមិនត្រូវបានទទួលស្គាល់ដោយសារតែវាមិនបំពេញលក្ខខណ្ឌមួយ ឬទាំងពីរ នៃ (ខ) និង (គ) នៃកថាខណ្ឌ២. ៣៩។ អង្គភាពមិនត្រូវទទួលស្គាល់បំណុលយថាហេតុថាជាបំណុល លើកលែងតែបំណុលយថាហេតុរបស់អ្នកលក់នៅក្នុងការរួមបញ្ចូលអាជីវកម្ម (សូមមើលផ្នែកទី១៩ ការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម)។

## ចំណូល

២.៤១ ការទទួលស្គាល់ចំណូល កើតចេញដោយផ្ទាល់ពីការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្ម និងបំណុល។ អង្គភាពត្រូវទទួលស្គាល់ចំណូលនៅក្នុងរបាយការណ៍ចំណូលពេញលេញ (ឬនៅក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ) នៅពេលដែលកំណើននៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត ទាក់ទិននឹងកំណើននៃ ទ្រព្យសកម្ម ឬការថយចុះនៃបំណុលបានកើតឡើង និងអាចវាស់វែងបានគួរឱ្យជឿជាក់។

### ចំណាយ

២.៤២ ការទទួលស្គាល់ចំណាយ កើតចេញដោយផ្ទាល់ពីការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្ម និងបំណុល។ អង្គភាពត្រូវទទួលស្គាល់ចំណាយ នៅក្នុងរបាយការណ៍ចំណូលពេញលេញ (ឬនៅក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ) នៅពេលដែលការថយចុះនៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតទាក់ទិននឹងការថយចុះនៃ ទ្រព្យសកម្ម ឬការកើនឡើងនៃបំណុល បានកើតឡើង និងអាចវាស់វែងបានគួរឱ្យជឿជាក់។

### ចំណូលពេញលេញសរុប និង ចំណេញឬខាត

២.៤៣ ចំណូលពេញលេញសរុប គឺជាភាពខុសគ្នានៃបរិមាណរវាងចំណូល និងចំណាយ។ ចំណូលពេញលេញសរុប មិនមែនជាធាតុមួយដោយឡែកនៃរបាយការណ៍ហិរញ្ញវត្ថុទេ ហើយគោលការណ៍នៃការទទួលស្គាល់ដោយឡែក ក៏មិនមានការចាំបាច់សម្រាប់ចំណូលពេញលេញសរុបនេះដែរ។

២.៤៤ ចំណេញ ឬខាត គឺជាភាពខុសគ្នានៃបរិមាណរវាងចំណូល និងចំណាយ ក្រៅពីធាតុនានានៃចំណូល និងចំណាយ ដែលស្តង់ដារនេះចាត់ថ្នាក់ជាធាតុនៃចំណូលលម្អិតផ្សេងៗ។ ចំណេញ ឬខាតមិនមែនជាធាតុមួយដោយឡែក នៃរបាយការណ៍ហិរញ្ញវត្ថុទេ ហើយគោលការណ៍នៃការទទួលស្គាល់ដោយឡែក ក៏មិនមានការចាំបាច់សម្រាប់ចំណេញ ឬខាតនេះដែរ។

២.៤៥ ស្តង់ដារនេះមិនអនុញ្ញាតឱ្យទទួលស្គាល់ធាតុនានានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដែលមិនបំពេញតាមនិយមន័យនៃទ្រព្យសកម្ម ឬបំណុល ដោយមិនគិតពីថា តើធាតុទាំងនោះកើតមកពីការអនុវត្តសញ្ញាណដែលជាទូទៅហៅថា “ទស្សនទានផ្គូផ្គង” សម្រាប់ការវាស់វែងចំណេញ ឬខាតទេ។

## ការវាស់វែងនៅពេលទទួលស្គាល់ដំបូង

២.៤៦ នៅពេលទទួលស្គាល់ដំបូង អង្គភាពត្រូវវាស់វែងទ្រព្យសកម្ម និងបំណុលតាមថ្លៃដើមប្រវត្តិ វៀរលែងតែ ស្តង់ដារនេះតម្រូវឱ្យមានការវាស់វែងដំបូងដោយផ្អែកលើមូលដ្ឋានផ្សេង ដូចជា តម្លៃសមស្រប ជាដើម។

## ការវាស់វែងពេលក្រោយជាបន្តបន្ទាប់

### ទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ

២.៤៧ អង្គភាពមួយវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុជាមូលដ្ឋាន និងបំណុលហិរញ្ញវត្ថុជាមូលដ្ឋាន ដូចដែលបានឱ្យនិយមន័យនៅក្នុងផ្នែកទី១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន តាមថ្លៃដើមបានរំលស់ដកការថយចុះតម្លៃ លើកលែងតែការវិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចបម្លែងបាន និងការវិនិយោគលើភាគហ៊ុនធម្មតា ឬភាគហ៊ុនបុរិមាមិនអាចដាក់លក់បាន ដែលត្រូវបានដាក់ឱ្យទិញ-លក់ជាសាធារណៈ ឬតម្លៃសមស្របរបស់ភាគហ៊ុន ទាំងនោះអាចត្រូវបានវាស់វែងផ្សេងពីនេះ ប្រកបដោយការជឿទុកចិត្ត ដោយគ្មានការចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប ដោយការប្រែប្រួលលើតម្លៃសមស្រប ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

២.៤៨ ជាទូទៅ អង្គភាពវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុផ្សេងទៀតទាំងអស់ តាមតម្លៃសមស្រប ដោយការប្រែប្រួលលើតម្លៃសមស្រប ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត លើកលែងតែស្តង់ដារនេះ តម្រូវ ឬអនុញ្ញាតឱ្យមានការវាស់វែង ដោយផ្អែកលើមូលដ្ឋានផ្សេងទៀត ដូចជា ថ្លៃដើម ឬថ្លៃដើមដករំលស់។

## ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

២. ៤៩ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុភាគច្រើន ដែលអង្គភាពបានទទួលស្គាល់ដំបូងតាមថ្លៃដើមប្រវត្តិ ត្រូវបានវាស់វែងនៅពេលក្រោយជាបន្តបន្ទាប់ តាមមូលដ្ឋានការវាស់វែងផ្សេងទៀត។ ឧទាហរណ៍៖

(ក) អង្គភាពវាស់វែងទ្រព្យ រោងចក្រ និងបរិក្ខារ តាមចំនួនទាបជាងនៃថ្លៃដើមដកការរំលស់ និងការថយចុះតម្លៃបង្គរ និងចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន (គំរូថ្លៃដើម) ឬចំនួនទាបជាងនៃចំនួនទឹកប្រាក់ដែលបានវាយតម្លៃឡើងវិញ និងចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន (គំរូវាយតម្លៃឡើងវិញ)

(ខ) អង្គភាពវាស់វែងសន្និធិតាមចំនួនទាបជាងនៃថ្លៃដើម និងថ្លៃលក់ ដកថ្លៃដើម្បីសម្រេចការងារនិងលក់ និង

(គ) អង្គភាពទទួលស្គាល់ការខាតពីការថយចុះតម្លៃ ទាក់ទិននឹងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដែលកំពុងតែប្រើប្រាស់ ឬរក្សាទុកសម្រាប់លក់។ ការវាស់វែងទ្រព្យសកម្មក្នុងចំនួនទឹកប្រាក់ទាបជាងទាំងនោះ ត្រូវបានធ្វើឡើងក្នុងគោលបំណងជានាថា ទ្រព្យសកម្មមួយមិនត្រូវបានវាស់វែងក្នុងចំនួនទឹកប្រាក់ច្រើនជាងចំនួនទឹកប្រាក់ ដែលអង្គភាព រំពឹងថា នឹងទទួលបានមកវិញពីការលក់ ឬការប្រើប្រាស់ទ្រព្យសកម្មនោះ។

២.៥០ សម្រាប់ប្រភេទនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដូចខាងក្រោម ស្តង់ដារនេះអនុញ្ញាត ឬតម្រូវឱ្យវាស់វែងតាមតម្លៃសមស្រប៖

(ក) ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ដែលអង្គភាពវាស់វែងតាមតម្លៃសមស្រប (សូមមើលកថាខណ្ឌ១៤.១០ និង ១៥.១៥ រៀងៗគ្នា)

(ខ) ទ្រព្យវិនិយោគដែលអង្គភាពវាស់វែងតាមតម្លៃសមស្រប (សូមមើលកថាខណ្ឌ ១៦. ៧)

(គ) ទ្រព្យសកម្មកសិកម្ម (ទ្រព្យសកម្មជីវសាស្ត្រ និងផលិតផលកសិកម្មនៅពេលប្រមូលផល) ដែលអង្គភាពវាស់វែងតាមតម្លៃសមស្រប ដកចំណាយក្នុងការលក់ដែលបានប៉ាន់ស្មាន (សូមមើលកថាខណ្ឌ ៣៤.២) និង

(ឃ) ទ្រព្យ រោងចក្រ និងបរិក្ខារ ដែលអង្គភាពវាស់វែងស្របតាមគំរូវាយតម្លៃឡើងវិញ (សូមមើលកថាខណ្ឌ ១៧.១៥ខ)។

## បំណុលផ្សេងពីបំណុលហិរញ្ញវត្ថុ

២.៥១ បំណុលភាគច្រើន ក្រៅពីបំណុលហិរញ្ញវត្ថុ ត្រូវវាស់វែងតាមការប៉ាន់ស្មាន ដែលត្រឹមត្រូវបំផុតលើចំនួនទឹកប្រាក់ដែលអាចតម្រូវ ដើម្បីទូទាត់កាតព្វកិច្ចនៅការិយបរិច្ឆេទរាយការណ៍។

## ការកាត់កង

២.៥២ អង្គភាពមិនត្រូវកាត់កងទ្រព្យសកម្មនិងបំណុល ឬចំណូលនិងចំណាយ វៀរលែងតែស្តង់ដារនេះតម្រូវ ឬអនុញ្ញាតៈ

(ក) ការវាស់វែងទ្រព្យសកម្ម ដោយផាត់ចេញបម្រុងសម្រាប់ការវាយតម្លៃមិនមែនជាការកាត់កង។ ឧទាហរណ៍ៈ ការលិកសម្រាប់ ភាពហួសសម័យនៃសន្និធិ និងបម្រុងសម្រាប់គណនីត្រូវទទួលដែលមិនអាចប្រមូលបាន មិនមែនជាការកាត់កងទេ។

(ខ) ប្រសិនបើសកម្មភាពប្រតិបត្តិការធម្មតារបស់អង្គភាព មិនរាប់បញ្ចូលការទិញ និងលក់ទ្រព្យសកម្មរយៈពេលវែង រួមទាំងទ្រព្យសកម្មវិនិយោគ និងទ្រព្យសកម្មប្រតិបត្តិការផងនោះ អង្គភាពត្រូវរាយការណ៍អំពីចំណេញ និងខាត លើការបញ្ចេញចោលនូវទ្រព្យសកម្មទាំងនោះ ដោយការកាត់កងតម្លៃយោងនៃទ្រព្យសកម្មនោះ និងចំណាយលើការលក់ដែលពាក់ព័ន្ធ ពីប្រាក់ចំណូលពីការបញ្ចេញចោល។

# ផ្នែកទី ៣
# ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

## វិសាលភាពនៃផ្នែកនេះ

៣.១ ផ្នែកនេះពន្យល់អំពីការបង្ហាញត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ តើការអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាព ធុនតូច និងមធ្យមនេះ តម្រូវឱ្យធ្វើអ្វី និងថា តើអ្វីជាសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ។

## ការបង្ហាញត្រឹមត្រូវ

៣.២ របាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញដោយត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព។ ការបង្ហាញត្រឹមត្រូវទាមទារនូវការបង្ហាញប្រកបដោយការពិតអំពីឥទ្ធិពលនៃប្រតិបត្តិការ ព្រឹត្តិការណ៍ និងស្ថានការណ៍ដទៃទៀត ស្របតាមនិយមន័យនិងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់សម្រាប់ ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ដូចបានចែងនៅក្នុងផ្នែកទី២ ស្តីពីទស្សនទាន និងគោលការណ៍ទូទៅ៖

(ក) ការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម រួមជាមួយ ការលាតត្រដាងបន្ថែមបើមានការចាំបាច់ ត្រូវបានសន្មតថា នាំឱ្យមានរបាយការណ៍ហិរញ្ញវត្ថុ ដែលសម្រេចបានការបង្ហាញត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាពធុនតូច និងមធ្យម។

(ខ) ដូចបានពន្យល់នៅក្នុងកថាខណ្ឌ១.៥ ការអនុវត្តស្តង់ដារនេះដោយអង្គភាពដែលមានការទទួលខុសត្រូវ ជាសាធារណៈមិននាំឱ្យមានការបង្ហាញត្រឹមត្រូវ ស្របតាមស្តង់ដារនេះទេ។ ការលាតត្រដាងបន្ថែមដែលមានចែងក្នុងចំណុច (ក) ចាំបាច់ត្រូវធ្វើ នៅពេលដែលអនុលោម តាមការតម្រូវពិសេសនានាក្នុងស្តង់ដារនេះនៅតែមិនគ្រប់គ្រាន់សម្រាប់ឱ្យអ្នកប្រើប្រាស់ អាចយល់អំពីឥទ្ធិពលនៃប្រតិបត្តិការពិសេស ដោយឡែកនានា ព្រឹត្តិការណ៍និងស្ថានការណ៍ដទៃទៀតលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាព។

## ការអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូច និងមធ្យម

៣.៣ អង្គភាពដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន អនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម ត្រូវថ្លែងបញ្ជាក់ឱ្យបានជាក់លាក់ និងទាំងស្រុងអំពី ការអនុលោមនោះនៅក្នុងកំណត់សម្គាល់។ របាយការណ៍ហិរញ្ញវត្ថុមិនត្រូវបានពិពណ៌នាថា អនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យមទេ វៀរលែងតែរបាយការណ៍ហិរញ្ញវត្ថុ ទាំងនោះអនុលោមតាមរាល់ការតម្រូវនៅក្នុងស្តង់ដារនេះ។

៣.៤ ក្នុងកាលៈទេសៈដ៏កម្របំផុត នៅពេលណាដែលថ្នាក់គ្រប់គ្រងសម្រេចថា ការអនុលោមតាមស្តង់ដារនេះ នឹងនាំឱ្យមានការភាន់ច្រឡំខ្លាំង ដែលអាចមានទំនាស់ជាមួយគោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាពធុនតូច និងមធ្យម ដូចបានចែងក្នុងផ្នែកទី២ អង្គភាពត្រូវងាកចេញពីការតម្រូវនោះតាមវិធី ដូចមានចែងក្នុងកថាខណ្ឌ៣.៥ វៀរលែងតែគ្រោងក្របខ័ណ្ឌនិយតកម្ម ដែលពាក់ព័ន្ធហាមឃាត់ការងាកចេញនោះ។

៣.៥ នៅពេលដែលអង្គភាពមួយងាកចេញពីការតម្រូវនៃស្តង់ដារនេះ ស្របតាមកថាខណ្ឌ៣.៤ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោម៖

(ក) ថ្នាក់គ្រប់គ្រងបានសម្រេចថា របាយការណ៍ហិរញ្ញវត្ថុបង្ហាញយ៉ាងត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព

(ខ) អង្គភាពបានអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម ក៏ប៉ុន្តែអង្គភាពបានងាកចេញពីការតម្រូវជាក់លាក់ ដើម្បីសម្រេចបានការបង្ហាញត្រឹមត្រូវ និង

(គ) សារជាតិនៃការងាកចេញ រាប់ទាំងការចាត់ចែង ដែលស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យមតម្រូវ ហេតុផលដែលជាការចាត់ចែងនោះនឹងនាំមានឱ្យការភាន់ច្រឡំនៅក្នុងកាលៈទេសៈដែលនឹងមានទំនាស់ជាមួយគោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុដូចបានកំណត់ក្នុងផ្នែកទី២ និងការចាត់ចែងដែលបានប្រើប្រាស់។

៣.៦ នៅពេលដែលអង្គភាពមួយបានងាកចេញពីការតម្រូវនៃស្តង់ដារនេះនាការិយបរិច្ឆេទមុន ហើយការងាកចេញនោះមានផលប៉ះពាល់ដល់ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទបច្ចុប្បន្ន អង្គភាពនោះត្រូវធ្វើការលាតត្រដាង ដូចបានកំណត់ក្នុងកថាខណ្ឌ៣.៥ (គ)។

៣.៧ ក្នុងកាលៈទេសៈដ៏កម្របំផុត នៅពេលណាដែលថ្នាក់គ្រប់គ្រងសម្រេចថា ការអនុលោមតាមការតម្រូវ នៅក្នុងស្តង់ដារនេះ នឹងនាំឱ្យមានការភាន់ច្រឡំ ដែលនឹងនាំឱ្យមានទំនាស់ជាមួយគោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពធុនតូច និងមធ្យមដូចបានកំណត់ក្នុងផ្នែកទី២ ក៏ប៉ុន្តែគ្រោងក្របខ័ណ្ឌនិយតកម្ម ដែលពាក់ព័ន្ធហាមមិនឱ្យងាកចេញពីការតម្រូវនោះ អង្គភាពត្រូវកាត់បន្ថយជាអតិបរមានូវផ្នែកដែលបង្កការភាន់ច្រឡំដោយការអនុលោមទាំងនោះ ដោយធ្វើការលាតត្រដាងដូចខាងក្រោម៖

(ក) សារជាតិនៃការតម្រូវក្នុងស្តង់ដារនេះ និងហេតុផលដែលបានធ្វើឱ្យថ្នាក់គ្រប់គ្រងសម្រេចថា ការអនុលោមតាម ការតម្រូវនោះ នាំឱ្យមានការភាន់ច្រឡំខ្លាំងក្នុងកាលៈទេសៈ រហូលដល់មានទំនាស់ជាមួយគោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងផ្នែកទី២ និង

(ខ) សម្រាប់ការិយបរិច្ឆេទនីមួយៗ ដែលបានបង្ហាញ ការកែតម្រូវលើធាតុនីមួយៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលថ្នាក់គ្រប់គ្រងបានសម្រេចថា ជាការចាំបាច់ ដើម្បីសម្រេចបានការបង្ហាញត្រឹមត្រូវ។

## និរន្តរភាពអាជីវកម្ម

៣.៨ នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ថ្នាក់គ្រប់គ្រងនៃអង្គភាពដែលប្រើប្រាស់ស្តង់ដារនេះ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធភាពរបស់អង្គភាព ក្នុងការបន្តនិរន្តរភាពអាជីវកម្ម។ អង្គភាពមួយដំណើរការនិរន្តរភាពអាជីវកម្ម វៀរលែងតែថ្នាក់គ្រប់គ្រងមានបំណងជម្រះបញ្ជីអង្គភាព ឬបញ្ឈប់ប្រតិបត្តិការ ឬពុំមានជម្រើសអ្វីក្រៅពីធ្វើដូច្នេះ។ ក្នុងការវាយតម្លៃថា តើការសន្មតអំពីនិរន្តរភាពអាជីវកម្ម សមស្របដែរឬអត់ ថ្នាក់គ្រប់គ្រងត្រូវគិតគូរពិចារណាលើរាល់ ព័ត៌មាន

អំពីអនាគតដែលអាចរកបាន ដែលមានរយៈពេលយ៉ាងហោចណាស់ តែមិនកំណត់ត្រឹម ១២ខែ គិតចាប់ពី ការិយបរិច្ឆេទរាយការណ៍។

៣.៩ នៅពេលដែលថ្នាក់គ្រប់គ្រងបានដឹង នៅក្នុងការវាយតម្លៃរបស់ខ្លួន អំពីភាពមិនប្រាកដប្រជាជាសារវន្តទាក់ទិននឹងព្រឹត្តិការណ៍ ឬស្ថានការណ៍ដែលនាំឱ្យការសង្ស័យធំដុំ លើលទ្ធភាពរបស់អង្គភាពក្នុងការបន្តនិរន្តរភាពអាជីវកម្ម អង្គភាពត្រូវលាតត្រដាងអំពីភាពមិនប្រាកដប្រជាទាំងនោះ។ នៅពេលដែលអង្គភាពមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពអាជីវកម្ម អង្គភាពត្រូវលាតត្រដាងអង្គហេតុនោះ និងមូលដ្ឋានដែលអង្គភាពបានប្រើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនោះ និងហេតុផលដែលនាំឱ្យគេមិនចាត់ទុកអង្គភាពនោះថាជាដំណើរការនិរន្តរភាពអាជីវកម្ម។

## ភាពញឹកញាប់នៃការរាយការណ៍

៣.១០ អង្គភាពត្រូវបង្ហាញសំណុំរបាយការណ៍ហិរញ្ញវត្ថុពេញលេញ (រួមមាន ព័ត៌មានប្រៀបធៀប សូមមើលកថាខណ្ឌ ៣.១៤) យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ។ នៅពេលដែលចុងនៃការិយបរិច្ឆេទរាយការណ៍របស់អង្គភាព មានការប្រែប្រួល ហើយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបង្ហាញសម្រាប់ការិយបរិច្ឆេទវែងជាងឬខ្លីជាងមួយឆ្នាំ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោម៖

(ក) អង្គហេតុនោះ

(ខ) ហេតុផលសម្រាប់ការប្រើការិយបរិច្ឆេទដែលវែងជាងឬខ្លីជាង និង

(គ) អង្គហេតុដែលថា ចំនួនទឹកប្រាក់ប្រៀបធៀបដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ (រាប់ទាំងកំណត់សម្គាល់ដែលពាក់ព័ន្ធ) មិនអាចធ្វើការប្រៀបធៀបបានទាំងស្រុង។

## សង្គតិភាពនៃការបង្ហាញ

៣.១១ អង្គភាពត្រូវរក្សាការបង្ហាញ និងចំណាត់ថ្នាក់នៃធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពីការិយបរិច្ឆេទ មួយទៅការិយបរិច្ឆេទក្រោយទៀត វៀរលែងតែ៖

(ក) យ៉ាងច្បាស់ក្រឡែត បន្ទាប់ពីមានការប្រែប្រួលធំដុំលើសារជាតិប្រតិបត្តិការរបស់អង្គភាព ឬការពិនិត្យឡើងវិញ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែលការបង្ហាញ ឬចំណាត់ថ្នាក់មួយផ្សេងទៀត មានភាពសមស្របជាង ដោយគិតគូរដល់លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស និងការអនុវត្តគោលនយោបាយគណនេយ្យនៅក្នុងផ្នែកទី១០ ស្ដីពីគោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និងកំហុសឆ្គង ឬ

(ខ) ស្តង់ដារនេះតម្រូវឱ្យផ្លាស់ប្តូរការបង្ហាញ។

៣.១២ នៅពេលដែលការបង្ហាញ ឬចំណាត់ថ្នាក់នៃធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានការប្រែប្រួល អង្គភាពត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញលើចំនួនទឹកប្រាក់ប្រៀបធៀប វៀរលែងតែចំណាត់ថ្នាក់ឡើងវិញនោះមិនអាចធ្វើទៅរួច។ នៅពេលដែលចំនួនទឹកប្រាក់ប្រៀបធៀប ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ អង្គភាពត្រូវបង្ហាញដូចខាងក្រោម៖

(ក) សារជាតិនៃចំណាត់ថ្នាក់ឡើងវិញ។

(ខ) ចំនួនទឹកប្រាក់នៃជាតុនីមួយៗ ឬថ្នាក់នីមួយៗនៃបណ្ដាជាតុ ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ និង

(គ) ហេតុផលសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញ។

៣.១៣ ប្រសិនបើមិនអាចធ្វើទៅរួច ក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញនូវចំនួនទឹកប្រាក់ប្រៀបធៀប អង្គភាពត្រូវលាតត្រដាងអំពីមូលហេតុ ដែលចំណាត់ថ្នាក់ឡើងវិញមិនអាចធ្វើទៅរួច។

## ព័ត៌មានប្រៀបធៀប

៣.១៤ លើកលែងតែនៅពេលដែលស្តង់ដានេះអនុញ្ញាតឬតម្រូវផ្សេងពីនេះ អង្គភាពត្រូវលាតត្រដាងព័ត៌មានប្រៀបធៀបទាក់ទិននឹងការិយបរិច្ឆេទអាចប្រៀបធៀបបានមុនៗ សម្រាប់រាល់ចំនួនទឹកប្រាក់ដែលបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទបច្ចុប្បន្ន។ អង្គភាពត្រូវបញ្ចូលព័ត៌មានប្រៀបធៀបសម្រាប់ព័ត៌មានពណ៌នានិងបរិយាយនៅពេលដែលព័ត៌មានប្រៀបធៀបនោះ ពាក់ព័ន្ធទៅនឹងការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទបច្ចុប្បន្ន។

## ភាពជាសារវន្ត និងការរួមផ្តុំគ្នា

៣.១៥ អង្គភាពត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវថ្នាក់ជាសារវន្តនីមួយៗនៃជាតុប្រហាក់ប្រហែលគ្នា។ អង្គភាពត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវជាតុនានាដែលមានសារជាតិ ឬមុខងារមិនដូចគ្នា លើកលែងតែជាតុទាំងនោះមិនមានភាពជាសារវន្ត។

៣.១៦ ការខកខានមិនបានដាក់បញ្ចូល ឬការថ្លែងខុសនូវជាតុនានា មានភាពជាសារវន្ត ប្រសិនបើការខកខានមិនបានដាក់បញ្ចូល ឬការថ្លែងខុសនោះ អាចមានឥទ្ធិពលដោយខ្លួន ឬជារួមលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដែលបាន ធ្វើឡើងផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ភាពជាសារវន្ត អាស្រ័យលើទំហំ និងសារជាតិនៃការខកខានមិនបានដាក់បញ្ចូល ឬការថ្លែងខុសដែលត្រូវបានវិនិច្ឆ័យនៅក្នុងកាលៈទេសៈជុំវិញ។ ទំហំ ឬសារជាតិនៃជាតុនោះ ឬការផ្តុំគ្នាទាំងទំហំ ទាំងសារជាតិនៃជាតុនោះ អាចជាកត្តាកំណត់។

## សំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ

៣.១៧ សំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយ ត្រូវរាប់បញ្ចូលចំណុចទាំងអស់ខាងក្រោម៖

(ក) របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាកាលបរិច្ឆេទរាយការណ៍

(ខ) មួយក្នុងចំណោមពីរខាងក្រោម៖

១) របាយការណ៍ចំណូលពេញលេញទោលសម្រាប់ការិយបរិច្ឆេទរាយការណ៍ ដែលបង្ហាញ គ្រប់ជាតុទាំងអស់នៃចំណូល និងចំណាយ ដែលបានទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទនោះ រួមទាំងជាតុទាំងឡាយដែលត្រូវបានទទួលស្គាល់ ក្នុងការកំណត់ចំណេញ ឬខាត (ដែលជាសរុបរង នៅក្នុងរបាយការណ៍ចំណូលពេញលេញ) និងជាតុនានានៃចំណូលលម្អិតផ្សេងៗ។

២)	របាយការណ៍លទ្ធផលដាច់ដោយឡែកមួយ និងរបាយការណ៍ចំណូលពេញលេញដាច់ដោយឡែកមួយ។ ប្រសិនបើអង្គភាពសម្រេចជ្រើសរើសធ្វើការបង្ហាញ ទាំងរបាយការណ៍លទ្ធផលទាំងរបាយការណ៍ចំណូលពេញលេញ របាយការណ៍ចំណូលពេញលេញចាប់ផ្តើមពីចំណេញឬខាត ហើយបន្ទាប់មក បង្ហាញពីធាតុនានានៃចំណូលលម្អិតផ្សេងៗ។

(គ)	របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ការិយបរិច្ឆេទរាយការណ៍

(ឃ)	របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទរាយការណ៍ និង

(ង)	កំណត់សម្គាល់ ដែលមានការសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងទៀត។

៣.១៨	ប្រសិនបើការប្រែប្រួលលើមូលធន ក្នុងអំឡុងការិយបរិច្ឆេទ ដែលរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញ គ្រាន់តែកើតចេញពីចំណេញ ឬខាត ការទូទាត់ភាគលាភ ការកែតម្រូវកំហុសឆ្គងនៃការិយបរិច្ឆេទមុនៗ និងការផ្លាស់ប្តូរលើគោលនយោបាយគណនេយ្យ អង្គភាពអាចបង្ហាញរបាយការណ៍ចំណូល និងចំណេញរក្សាទុកទោល ជំនួសឱ្យរបាយកាណ៍ចំណូលពេញលេញ និងរបាយការណ៍បម្រែបម្រួលមូលធន (សូមមើលកថាខណ្ឌ ៦.៤)។

៣.១៩	ប្រសិនបើអង្គភាព មិនមានធាតុនៃចំណូលលម្អិតផ្សេងៗនាការិយបរិច្ឆេទណាមួយ ដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញ អង្គភាពអាចបង្ហាញតែរបាយការណ៍លទ្ធផល ឬអង្គភាពអាចបង្ហាញ របាយការណ៍ចំណូលពេញលេញដែល "បន្ទាត់ក្រោមបំផុត" ត្រូវបិទស្លាក "ចំណេញ ឬខាត"។

៣.២០	ដោយសារកថាខណ្ឌ៣.១៤ ទាមទារនូវចំនួនទឹកប្រាក់ប្រៀបធៀបទាក់ទងនឹងការិយបរិច្ឆេទមុនៗ សម្រាប់រាល់ចំនួនទឹកប្រាក់ទាំងអស់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ សំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុមានន័យថា យ៉ាងហោចណាស់អង្គភាពត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុយ៉ាងតិចពីរ នៃរបាយការណ៍ហិរញ្ញវត្ថុនីមួយៗ ដែលត្រូវបានតម្រូវ និងកំណត់សម្គាល់ដែលពាក់ព័ន្ធ។

៣.២១	នៅក្នុងសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុនីមួយៗដោយភាពលេចធ្លោស្មើគ្នា។

៣.២២	អង្គភាពអាចប្រើប្រាស់ចំណងជើងនៃរបាយការណ៍ហិរញ្ញវត្ថុ ក្រៅពីចំណងជើងដែលបានប្រើនៅក្នុងស្តង់ដារនេះ ឱ្យតែចំណងជើងនោះមិននាំឱ្យមានការភាន់ច្រឡំ។

## អត្តសញ្ញាណកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ

៣.២៣	អង្គភាពត្រូវបញ្ជាក់អត្តសញ្ញាណនៃរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់នីមួយៗឱ្យបានច្បាស់លាស់ និងត្រូវញែករបាយការណ៍និងកំណត់សម្គាល់ទាំងនោះឱ្យដាច់ពីព័ត៌មានផ្សេងទៀត នៅក្នុងឯកសារតែមួយ។ លើសពីនេះទៀត អង្គភាពត្រូវបង្ហាញព័ត៌មានខាងក្រោមឱ្យលេចធ្លោ និងធ្វើម្តងទៀត ប្រសិនបើមានការចាំបាច់ ដើម្បីការយល់ដឹងអំពីព័ត៌មានដែលបានបង្ហាញ៖

(ក)	ឈ្មោះរបស់អង្គភាពរាយការណ៍ និងការកែប្រែណាមួយនៃឈ្មោះនេះ ចាប់តាំងពីចុងការិយបរិច្ឆេទរាយការណ៍មុននេះមួយ។

(ខ)	ថាតើរបាយការណ៍ហិរញ្ញវត្ថុគ្របដណ្តប់អង្គភាពទោល ឬក្រុមអង្គភាព។

(គ) កាលបរិច្ឆេទនៃចុងការិយបរិច្ឆេទរាយការណ៍ និងការិយបរិច្ឆេទ ដែលគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុ។

(ឃ) រូបិយប័ណ្ណសម្រាប់ការបង្ហាញ ដូចបានឱ្យនិយមន័យនៅក្នុងផ្នែកទី៣០ ស្តីពីការបកប្រែរូបិយប័ណ្ណបរទេស និង

(ង) កម្រិតនៃការបង្គត់ បើសិនជាមាន ដែលបានប្រើក្នុងការបង្ហាញចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣.២៤ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោម នៅក្នុងកំណត់សម្គាល់៖

(ក) អាសយដ្ឋាន និងទម្រង់គតិយុត្តិរបស់អង្គភាព ប្រទេសដែលខ្លួនបានចុះបញ្ជីពាណិជ្ជកម្ម និងអាសយដ្ឋាន នៃការិយាល័យដែលបានចុះបញ្ជី (ឬទីតាំងចម្បងរបស់អាជីវកម្ម ប្រសិនបើវានៅផ្សេងពីការិយាល័យ ដែលបានចុះបញ្ជី) និង

(ខ) ការពិពណ៌នាអំពីសារជាតិនៃប្រតិបត្តិការរបស់អង្គភាព និងសកម្មភាពចម្បងរបស់អង្គភាព។

## ការបង្ហាញព័ត៌មាន ដែលមិនបានតម្រូវដោយស្តង់ដារនេះ

៣.២៥ ស្តង់ដារនេះ មិនពិភាក្សាអំពីការបង្ហាញព័ត៌មានតាមផ្នែក [នៃអាជីវកម្ម] ប្រាក់ចំណេញក្នុងមួយចំណែកហ៊ុនឬរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល របស់អង្គភាពធុនតូច ឬអង្គភាពធុនមធ្យមទេ។ អង្គភាពដែលធ្វើ ការលាតត្រដាងទាំងនេះ ត្រូវអធិប្បាយអំពីមូលដ្ឋានសម្រាប់ការរៀបចំ និងការបង្ហាញព័ត៌មាននោះ។

# ផ្នែកទី ៤
# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## វិសាលភាពនៃផ្នែកនេះ

៤.១ ផ្នែកនេះចែងអំពីព័ត៌មាន ដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងវិធីនៃការបង្ហាញវា។ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ជួនកាលហៅថា តារាងតុល្យការ) បង្ហាញអំពីទ្រព្យសកម្ម បំណុល និងមូលធនរបស់អង្គភាព នាកាលបរិច្ឆេទជាក់លាក់ណាមួយ គឺនាចុងការិយបរិច្ឆេទរាយការណ៍។

## ព័ត៌មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

៤.២ យ៉ាងហោចណាស់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ត្រូវបញ្ចូលនូវជាតុបន្ទាត់ ដែលបង្ហាញនូវចំនួនទឹកប្រាក់ខាងក្រោម៖

(ក) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

(ខ) គណនីត្រូវទទួល និង ត្រូវទទួលផ្សេងទៀត

(គ) ទ្រព្យសកម្មហិរញ្ញវត្ថុ (មិនរាប់បញ្ចូលបរិមាណដែលបង្ហាញនៅក្នុងចំណុច (ក) (ខ) (ញ) និង(ដ))

(ឃ) សន្និធិ

(ង) ទ្រព្យ រោងចក្រ និងបរិក្ខារ

(ងក) ទ្រព្យវិនិយោគ ដែលកត់ក្នុងបញ្ជីតាមថ្លៃដើមដកការរំលស់និងការថយចុះតម្លៃបង្គរ

(ច) ទ្រព្យវិនិយោគ ដែលកត់ក្នុងបញ្ជីតាមតម្លៃសមស្របនិងបម្រែបម្រួលកត់ចូលចំណេញ ឬខាត

(ឆ) ទ្រព្យសកម្មអរូបី

(ជ) ទ្រព្យសកម្មជីវសាស្ត្រដែលកត់ក្នុងបញ្ជីតាមថ្លៃដើមដកការរំលស់និងការថយចុះតម្លៃបង្គរ

(ឈ) ទ្រព្យសកម្មជីវសាស្ត្រ ដែលកត់ក្នុងបញ្ជីតាមតម្លៃសមស្របនិងបម្រែបម្រួលកត់ចូលចំណេញ ឬខាត

(ញ) ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ

(ដ) ការវិនិយោគនៅក្នុងអង្គភាពគ្រប់គ្រងរួមគ្នា

(ឋ) គណនីត្រូវសង និងត្រូវសងផ្សេងទៀត

(ឌ) បំណុលហិរញ្ញវត្ថុ (មិនរាប់បញ្ចូលបរិមាណដែលបង្ហាញនៅក្នុងចំណុច (ឋ) និង (ត))

(ឍ) បំណុល និងទ្រព្យសកម្មសម្រាប់ពន្ធបច្ចុប្បន្ន

(ណ) បំណុលពន្ធពន្យារនិងទ្រព្យសកម្មពន្ធពន្យារ (ទាំងនេះត្រូវតែចាត់ថ្នាក់ជាសម្រាប់រយៈពេលវែង)

(ត) សំវិធានធន

(ថ) ភាគកម្មមិនគ្រប់គ្រង បានបង្ហាញឡើងនៅក្នុងមូលធនដាច់ដោយឡែកពីមូលធនបានពីម្ចាស់នៃក្រុមហ៊ុនមេ និង

(ទ) មូលធនបានពីម្ចាស់នៃក្រុមហ៊ុនមេ។

៤.៣ អង្គភាពមួយត្រូវបង្ហាញនូវជាតុបន្ទាត់ ចំណងជើង និងសរុបរងបន្ថែមនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលដែលការបង្ហាញបែបនេះពាក់ព័ន្ធនឹងការយល់ដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព។

## ការបែងចែករវាងរយៈពេលខ្លី និងរយៈពេលវែង

៤.៤ អង្គភាពមួយត្រូវបង្ហាញអំពីទ្រព្យសកម្មរយៈពេលខ្លីនិងរយៈពេលវែង និងបំណុលរយៈពេលខ្លីនិងរយៈពេលវែង ជាការចាត់ថ្នាក់ដាច់ដោយឡែកពីគ្នា នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពនោះ ដោយស្របតាមកថាខណ្ឌ ៤. ៥-៤. ៨លើកលែងតែនៅពេលដែលបានបង្ហាញដោយផ្អែកលើមូលដ្ឋានសន្ទនីយភាព ផ្តល់នូវព័ត៌មានដែលអាចជឿទុកចិត្តបាន និងមានការជាប់ពាក់ព័ន្ធជាង។ នៅពេលអនុវត្តការលើកលែងនេះ រាល់ទ្រព្យសកម្ម និងបំណុលត្រូវតែបង្ហាញតាមលំដាប់សន្ទនីយភាពប្រហាក់ប្រហែល (លំដាប់ចុះ ឬឡើង)។

## ទ្រព្យសកម្មរយៈពេលខ្លី

៤.៥ អង្គភាពមួយ ត្រូវចាត់ថ្នាក់ទ្រព្យសកម្មមួយថាជាទ្រព្យសកម្មរយៈពេលខ្លី នៅពេលដែល ៖

(ក) អង្គភាពរំពឹងថាទទួលបានទ្រព្យសកម្ម ឬមានបំណងលក់ឬប្រើប្រាស់ទ្រព្យសកម្ម នៅក្នុងវដ្តប្រតិបត្តិការធម្មតារបស់អង្គភាព

(ខ) អង្គភាពកាន់កាប់ទ្រព្យសកម្មជាចម្បងសម្រាប់គោលបំណងជួញដូរ

(គ) អង្គភាពរំពឹងថានឹងទទួលបានទ្រព្យសកម្មក្នុងពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ឬ

(ឃ) ទ្រព្យសកម្មគឺជាសាច់ប្រាក់ឬសាច់ប្រាក់សមមូលលើកលែងតែវាត្រូវបានដាក់កំហិតថាមិនឱ្យផ្លាស់ប្តូរ ឬប្រើប្រាស់ដើម្បីទូទាត់សងបំណុលសម្រាប់រយៈពេលយ៉ាងហោចណាស់១២ខែបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។

៤.៦ អង្គភាពមួយត្រូវចាត់ថ្នាក់ទ្រព្យសកម្មដទៃទៀតទាំងអស់ ថាជាទ្រព្យសកម្មរយៈពេលវែង។ ប្រសិនបើវដ្តប្រតិបត្តិការធម្មតារបស់អង្គភាពមិនអាចបញ្ជាក់បានច្បាស់លាស់ រយៈពេលនៃវដ្តប្រតិបត្តិការធម្មតារបស់អង្គភាពនោះត្រូវបានសន្មតថា ១២ខែ។

## បំណុលរយៈពេលខ្លី

៤.៧ អង្គភាពមួយ ត្រូវចាត់ថ្នាក់បំណុលមួយថាជាបំណុលរយៈពេលខ្លី នៅពេលដែល ៖

(ក) អង្គភាពរំពឹងថានឹងទូទាត់សងបំណុលក្នុងវដ្តប្រតិបត្តិការធម្មតារបស់អង្គភាព

(ខ) អង្គភាពកាន់កាប់បំណុលជាចម្បងសម្រាប់គោលបំណងជួញដូរ

(គ) បំណុលនោះនឹងដល់ពេលត្រូវទូទាត់សងក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ឬ

(ឃ) អង្គភាពមិនមានសិទ្ធិគ្មានលក្ខខណ្ឌដើម្បីពន្យារការទូទាត់សងបំណុលនោះ សម្រាប់យ៉ាងហោចណាស់រយៈពេល១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។

៤.៨ អង្គភាពមួយត្រូវចាត់ថ្នាក់បំណុលដទៃទៀតទាំងអស់ថាជាបំណុលរយៈពេលវែង។

## ការរៀបចំតាមលំដាប់លំដោយ និងទម្រង់នៃធាតុនានានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

៤.៩ ស្តង់ដារនេះមិនពិពណ៌នាអំពីលំដាប់លំដោយឬទម្រង់ចៃធាតុនានាដែលត្រូវបង្ហាញនោះទេ។ កថាខណ្ឌ ៤.២ គ្រាន់តែផ្តល់ជាធម្មតានូវបញ្ជីនៃធាតុនានាដែលមានចរិកលក្ខណៈឬមុខងារខុសៗគ្នាយ៉ាងច្បាស់ ដើម្បីជានានូវការបង្ហាញដាច់ដោយឡែកពីគ្នានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតែប៉ុណ្ណោះ។ បន្ថែមលើសនេះទៀត៖

(ក) បណ្តាធាតុបន្ទាត់ត្រូវបានរួមបញ្ចូល នៅពេលដែល ទំហំ លក្ខណៈ ឬមុខងាររបស់ធាតុមួយ ឬការផ្តុំធាតុស្រដៀងគ្នា ធ្វើឱ្យការបង្ហាញដាច់ដោយឡែកមានភាពទាក់ទងគ្នានឹងការយល់ដឹងពីអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព, និង

(ខ) ការពិពណ៌នាដែលបានប្រើប្រាស់និងការរៀបតាមលំដាប់លំដោយនៃធាតុឬការផ្តុំធាតុស្រដៀងគ្នាអាចត្រូវបានកែប្រែអាស្រ័យទៅនឹងប្រភេទរបស់អង្គភាពនិងប្រតិបត្តិការរបស់វា ដើម្បីផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងការយល់ដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព។

៤.១០ ការវិនិច្ឆ័យថាតើធាតុបន្ថែមនានា ត្រូវបានបង្ហាញដាច់ដោយឡែកឬអត់នោះគឺ អាស្រ័យលើការវាយតម្លៃនៃចំណុចទាំងអស់ដូចខាងក្រោម ៖

(ក) បរិមាណ ចរិកលក្ខណៈ និងសន្ទនីយភាពរបស់ទ្រព្យសកម្ម

(ខ) មុខងាររបស់ទ្រព្យសកម្មនៅក្នុងអង្គភាព និង

(គ) បរិមាណ ចរិកលក្ខណៈ និងពេលវេលានៃបំណុល។

## ព័ត៌មានដែលត្រូវបង្ហាញ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឬក្នុងកំណត់សម្គាល់

៤.១១ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មាន នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឬក្នុងកំណត់សម្គាល់នូវចំណាត់ថ្នាក់រងនានាដូចខាងក្រោម នៃធាតុបន្ទាត់ដែលត្រូវបង្ហាញ ៖

(ក) ទ្រព្យ រោងចក្រ និងបរិក្ខារ តាមចំណាត់ថ្នាក់សមស្របចំពោះអង្គភាព

(ខ) គណនីត្រូវទទួលនិងត្រូវទទួលផ្សេងទៀត ត្រូវបង្ហាញដាច់ដោយឡែកនូវចំនួនទឹកប្រាក់ ដែលដល់ពេលត្រូវទទួលពីភាគីពាក់ព័ន្ធនានា ចំនួនទឹកប្រាក់ ដែលដល់ពេលត្រូវទទួលពីភាគីដទៃទៀតនិងគណនីត្រូវទទួលដែលកើតមានពីចំណូលបង្គរ ដែលមិនទាន់បានចេញវិក្កយបត្រ

(គ) សន្និធិ ត្រូវបង្ហាញដាច់ដោយឡែកចំនួនទឹកប្រាក់នៃសន្និធិ៖

១) ដែលរក្សាទុកសម្រាប់លក់ក្នុងប្រតិបត្តិការធម្មតារបស់អាជីវកម្ម

២) ដែលស្ថិតនៅក្នុងដំណើរការផលិតកម្មសម្រាប់ការលក់ និង

៣) ដែលស្ថិតក្នុងទម្រង់ជាសម្ភារៈ ឬគ្រឿងផ្គត់ផ្គង់ដែលត្រូវប្រើប្រាស់នៅក្នុងដំណើរការផលិតកម្មឬនៅក្នុងការផ្តល់សេវា។

(ឃ) គណនីត្រូវសងឬត្រូវសងផ្សេងទៀត ត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់ជំនួញ ភាគីពាក់ព័ន្ធ ចំណូលពន្យារ និងជាតុបង្គរ

(ង) សំវិធានធនសម្រាប់អត្ថប្រយោជន៍និយោជិត និងសំវិធានធនផ្សេងទៀត និង

(ច) ថ្នាក់នៃមូលធន ដូចជា គណនីដើមទុនបានបង់ជាថ្នូរនឹងភាគហ៊ុន បុព្វលាភភាគហ៊ុន ចំណេញរក្សាទុក ធាតុនានានៃចំណូលនិងចំណាយដែល ដូចបានតម្រូវដោយស្តង់ដារនេះ ត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ និងត្រូវបង្ហាញដាច់ដោយឡែកក្នុងមូលធន។

៤.១២ អង្គភាពមួយដែលមានភាគហ៊ុនដើមទុន ត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬក្នុងកំណត់សម្គាល់:

(ក) សម្រាប់ថ្នាក់នីមួយៗនៃភាគហ៊ុនដើមទុន៖

១) ចំនួនភាគហ៊ុនដែលបានអនុញ្ញាត។

២) ចំនួនភាគហ៊ុនដែលបានបោះផ្សាយនិងទទួលបានការទូទាត់ពេញលេញ និងដែលបានបោះផ្សាយតែពុំទាន់ទទួលបានការទូទាត់ពេញលេញ។

៣) តម្លៃចុះលើសន្លឹកហ៊ុន ក្នុងមួយភាគហ៊ុន ឬថាភាគហ៊ុនមិនមានតម្លៃចុះលើសន្លឹកហ៊ុន។

៤) ការផ្ទៀងផ្ទាត់នៃចំនួនភាគហ៊ុនដែលចរាចរណ៍ក្រៅក្រុមហ៊ុន នាដើមនិងចុងការិយបរិច្ឆេទ។ ការផ្ទៀងផ្ទាត់នេះមិនបាច់បង្ហាញសម្រាប់ការិយបរិច្ឆេទមុនៗឡើយ។

៥) សិទ្ធិ លក្ខខណ្ឌអនុគ្រោះ និងលក្ខខណ្ឌកំហិតនានាដែលមានភ្ជាប់ជាមួយថ្នាក់នោះ រួមបញ្ចូលទាំងលក្ខខណ្ឌកំហិតលើការបែងចែកភាគលាភ និងការទូទាត់សងដើមទុនវិញ។

៦) ភាគហ៊ុននៅក្នុងអង្គភាពដែលកាន់កាប់ដោយអង្គភាព ឬដោយក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនញាតិសម្ព័ន្ធរបស់អង្គភាពនោះ។

៧) ចំនួនភាគហ៊ុនដែលបម្រុងទុកសម្រាប់បោះផ្សាយជាសិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់និងកិច្ចសន្យា សម្រាប់ការលក់ភាគហ៊ុន ដោយរួមបញ្ចូទាំងលក្ខខណ្ឌនិងចំនួនទឹកប្រាក់ផង។

(ខ) ការពិពណ៌នាអំពីទុនបម្រុងនីមួយៗនៅក្នុងមូលធន។

៤.១៣ អង្គភាពមួយដែលគ្មានភាគហ៊ុនដើមទុន ដូចជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬបរធនបាលកិច្ច ត្រូវលាតត្រដាង ព័ត៌មានឱ្យស្មើទៅតាមការតម្រូវដោយកថាខណ្ឌ៤.១២(ក) ដោយបង្ហាញនូវការប្រែប្រួលនានាក្នុងការិយបរិច្ឆេទលើប្រភេទមូលធននីមួយៗ ព្រមទាំងសិទ្ធិ លក្ខខណ្ឌអនុគ្រោះ និងលក្ខខណ្ឌកំហិតនានាដែលភ្ជាប់ជាមួយប្រភេទមូលធននីមួយៗផង។

៤.១៤ នាកាលបរិច្ឆេទរាយការណ៍ ប្រសិនបើអង្គភាពមានចងដោយកិច្ចព្រមព្រៀងលក់ចំពោះទ្រព្យសកម្មសំខាន់ៗដែលត្រូវបញ្ចេញចោលឬក្រុមនៃទ្រព្យសកម្មនិងបំណុល អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ៖

(ក) ការពិពណ៌នាអំពីទ្រព្យសកម្មមួយឬច្រើន ឬក្រុមនៃទ្រព្យសកម្មនិងបំណុល

(ខ) ការពិពណ៌នាអំពីអង្គហេតុ និងកាលៈទេសៈនៃការលក់ ឬផែនការលក់ និង

(គ) តម្លៃយោងនៃទ្រព្យសកម្ម ឬ ប្រសិនបើការបញ្ចេញចោលពាក់ព័ន្ធនឹងក្រុមនៃទ្រព្យសកម្មនិងបំណុលតម្លៃយោងនៃទ្រព្យសកម្មនិងបំណុលទាំងនោះ ។

# ផ្នែកទី ៥
# របាយការណ៍ចំណូលពេញលេញ និង របាយការណ៍លទ្ធផល

## វិសាលភាពនៃផ្នែកនេះ

៥.១ ផ្នែកនេះតម្រូវឱ្យអង្គភាពបង្ហាញនូវចំណូលពេញលេញសរុបរបស់ខ្លួនសម្រាប់ការិយបរិច្ឆេទមួយ (ពោលគឺ លទ្ធផលហិរញ្ញវត្ថុរបស់អង្គភាពនោះសម្រាប់ការិយបរិច្ឆេទនោះ) នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមួយឬពីរ។ ផ្នែកនេះកំណត់អំពីព័ត៌មានដែលត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍ទាំងនោះនិងថាតើត្រូវធ្វើការបង្ហាញព័ត៌មាននោះយ៉ាងដូចម្តេច។

## ការបង្ហាញអំពីចំណូលពេញលេញសរុប

៥.២ អង្គភាពមួយត្រូវបង្ហាញចំណូលពេញលេញ សរុបរបស់ខ្លួនសម្រាប់ការិយបរិច្ឆេទ តាមរបៀបណាមួយខាងក្រោម៖

(ក) នៅក្នុងរបាយការណ៍ចំណូលពេញលេញតែមួយ ដែលក្នុងករណីនេះ របាយការណ៍ចំណូលពេញលេញបង្ហាញគ្រប់សមាសធាតុនៃចំណូលនិងចំណាយដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទ ឬ

(ខ) ក្នុងរបាយការណ៍ពីរ (របាយការណ៍លទ្ធផលមួយនិងរបាយការណ៍ចំណូលពេញលេញមួយ) ដែលក្នុងករណីនេះរបាយការណ៍លទ្ធផលបង្ហាញគ្រប់ធាតុនៃចំណូលនិងចំណាយដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទលើកលែងតែ បណ្តាចំណូលនិងចំណាយដែលត្រូវបានទទួលស្គាល់ក្នុងចំណូលពេញលេញសរុប មិនមែនធាតុនៃចំណេញ ឬខាត ដូចដែលបានអនុញ្ញាតឬតម្រូវដោយស្តង់ដារនេះ។

៥.៣ ការផ្លាស់ប្តូរពីការប្រើបែបផែនរបាយការណ៍តែមួយទៅជាការប្រើបែបផែនរបាយការណ៍ពីរ ឬបញ្ច្រាស់មកវិញ គឺជាការផ្លាស់ប្តូរគោលនយោបាយគណនេយ្យដែលប្រើក្នុងផ្នែកទី១០ ស្តីពីគោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និងកំហុសឆ្គង។

### បែបផែនរបាយការណ៍តែមួយ

៥.៤ តាមបែបផែនរបាយការណ៍តែមួយ របាយការណ៍ចំណូលពេញលេញត្រូវតែរួមបញ្ចូលនូវរាល់សមាសធាតុទាំងអស់នៃចំណូលនិងចំណាយ ដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទវៀរលែងតែស្តង់ដារនេះ តម្រូវផ្សេងពីនេះ។ ស្តង់ដារនេះផ្តល់នូវចំណាត់ការខុសគ្នាសម្រាប់កាលៈទេសៈខាងក្រោម៖

(ក) ឥទ្ធិពលនៃការកែតម្រូវកំហុសឆ្គង និងការផ្លាស់ប្តូរគោលនយោបាយគណនេយ្យត្រូវបានបង្ហាញថាជាការកែតម្រូវត្រឡប់ក្រោយនៃការិយបរិច្ឆេទមុនៗ មិនត្រូវដាក់ថាជាផ្នែកនៃចំណេញ ឬខាតក្នុងការិយបរិច្ឆេទដែលឥទ្ធិពលនិងការផ្លាស់ប្តូរទាំងអស់នោះកើតឡើង (សូមមើលផ្នែកទី ១០) និង

(ខ) ពេលដែលមានករណីចំណូលលម្អិតផ្សេងៗបួនប្រភេទខាងក្រោម ត្រូវទទួលស្គាល់ជាផ្នែកមួយនៃចំណូលពេញលេញសរុប ហើយមិនត្រូវចាត់ទុកជាចំណេញ ឬខាតឡើយៈ

១) ចំណេញនិងខាតមួយចំនួន ដែលកើតឡើងពីការបកប្រែរបាយការណ៍ហិរញ្ញវត្ថុនៃប្រតិបត្តិការបរទេស (សូមមើលផ្នែកទី ៣០ ស្តីពីការបកប្រែរូបិយប័ណ្ណបរទេស)

២) ចំណេញ និងខាតនៃការគណនាតាមស្ថិតិមួយចំនួន (សូមមើលផ្នែកទី២៨ ស្តីពីអត្ថប្រយោជន៍និយោជិត)

៣) ការប្រែប្រួលមួយចំនួននៃតម្លៃសមស្របនៃឧបករណ៍ទប់ស្កាត់ហានិភ័យ (សូមមើលផ្នែកទី១២ ស្តីពីបញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ) និង

៤) ការប្រែប្រួលលើអតិរេកនៃការវាយតម្លៃឡើងវិញសម្រាប់ទ្រព្យ រោងចក្រ និងបរិក្ខារ ដែលបានវាស់វែងស្របតាមគំរូវាយតម្លៃឡើងវិញ (សូមមើលផ្នែកទី១៧ ទ្រព្យ រោងចក្រ និងបរិក្ខារ)។

៥.៥ យ៉ាងហោចណាស់ អង្គភាពត្រូវបញ្ចូលទៅក្នុងរបាយការណ៍ចំណូលពេញលេញនូវបណ្តាធាតុបន្ទាត់ ដែលបង្ហាញអំពីចំនួនទឹកប្រាក់ខាងក្រោមសម្រាប់ការិយបរិច្ឆេទៈ

(ក) ចំណូល។

(ខ) ថ្លៃដើមហិរញ្ញវត្ថុ។

(គ) ចំណែកនៃចំណេញ ឬខាតនៃការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ (សូមមើលផ្នែកទី១៤ ស្តីពីការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ) និងនៅក្នុងអង្គភាពគ្រប់គ្រងរួមគ្នា (សូមមើលផ្នែកទី១៥ ស្តីពីការវិនិយោគក្នុងក្រុមហ៊ុនរួមទុន) ធ្វើគណនេយ្យកម្មដោយប្រើវិធីសាស្ត្រមូលធន។

(ឃ) ចំណាយពន្ធ ដោយមិនរាប់បញ្ចូលពន្ធ ដែលជារបស់ធាតុ (ង) (ឆ) និង (ជ) (សូមមើលកថាខណ្ឌ ២៩.៣៥)។

(ង) ចំនួនទឹកប្រាក់តែមួយ ដែលសរុបនូវ ៖

១) ចំណេញ ឬខាតក្រោយបង់ពន្ធនៃប្រតិបត្តិការមិនបន្ត និង

២) ចំណេញ ឬខាតក្រោយបង់ពន្ធ ដែលបណ្តាលមកពីការថយចុះតម្លៃ ឬការបញ្ច្រាស់ទៅវិញនៃការថយចុះតម្លៃ នៃទ្រព្យសកម្មនៅក្នុងប្រតិបត្តិការមិនបន្ត (សូមមើលផ្នែកទី២៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម) ទាំងនៅពេលនិងក្រោយពេលធ្វើចំណាត់ថ្នាក់ជាប្រតិបត្តិការមិនបន្ត និងក្រោយការបញ្ចេញចោលនូវទ្រព្យសកម្មសុទ្ធ ដែលបង្កើតបានជាប្រតិបត្តិការមិនបន្ត។

(ច) ចំណេញ ឬខាត( ប្រសិនបើអង្គភាពពុំមានធាតុនៃចំណូលលម្អិតផ្សេងៗ បន្ទាត់នេះមិនចាំបាច់បង្ហាញនោះទេ)។

(ឆ) ធាតុនីមួយៗនៃចំណូលលម្អិតផ្សេងៗ (សូមមើលកថាខណ្ឌ ៥.៤ (ខ)) ដែលបានចាត់ថ្នាក់តាមប្រភេទ (មិនរាប់បញ្ចូលចំនួនទឹកប្រាក់ក្នុង(ជ))។ សមាសធាតុទាំងនេះ ត្រូវដាក់ជាក្រុមដែល យោងតាមស្តង់ដារនេះៈ

(១) នឹងមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញបន្ទាប់ពីនេះ ទៅក្នុងចំណេញឬខាត ពោលគឺ ធាតុទាំងឡាយនៅក្នុងកថាខណ្ឌ៥.៤(ខ)(១)-(២) និង (៤) និង

(២) នឹងត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញបន្ទាប់ពីនេះ ទៅក្នុងចំណេញឬខាត នៅពេលលក្ខខណ្ឌជាក់លាក់ ត្រូវបានបំពេញ ពោលគឺជាតុទាំងឡាយនៅក្នុងកថាខណ្ឌ៥.៤(ខ)(៣)។

(ជ) ភាគចំណែកនៃចំណូលលម្អិតផ្សេងៗរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ និងអង្គភាពគ្រប់គ្រងរួមគ្នា ត្រូវបានធ្វើគណនេយ្យកម្មតាមវិធីសាស្ត្រមូលធន។

(ឈ) ចំណូលពេញលេញសរុប (ប្រសិនបើអង្គភាពពុំមានជាតុនៃចំណូលលម្អិតផ្សេងៗ អង្គភាពអាចប្រើពាក្យផ្សេងទៀតសម្រាប់បន្ទាត់នេះ ដូចជាចំណេញ ឬខាតជាដើម)។

៥.៦ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានដាច់ដោយឡែកពីគ្នានូវជាតុនានា ដូចខាងក្រោម នៅក្នុងរបាយការណ៍ចំណូលពេញលេញ ថាចំណេញឬខាតសម្រាប់ការិយបរិច្ឆេទ ៖

(ក) ចំណេញ ឬខាត សម្រាប់ការិយបរិច្ឆេទ ដែលជារបស់៖

១) ភាគកម្មមិនគ្រប់គ្រង

២) ម្ចាស់នៃក្រុមហ៊ុនមេ

(ខ) ចំណូលពេញលេញសរុប សម្រាប់ការិយបរិច្ឆេទ ដែលជារបស់៖

១) ភាគកម្មមិនគ្រប់គ្រង

២) ម្ចាស់នៃក្រុមហ៊ុនមេ

## បែបផែនរបាយការណ៍ពីរ

៥.៧ តាមបែបផែនរបាយការណ៍ពីរ របាយការណ៍លទ្ធផលត្រូវតែបង្ហាញយ៉ាងហោចណាស់នូវជាតុបន្ទាត់ ដែលបង្ហាញចំនួនទឹកប្រាក់នៅក្នុងកថាខណ្ឌ ៥.៥(ក)-៥.៥(ច) សម្រាប់ការិយបរិច្ឆេទ ដោយដាក់ចំណេញ ឬខាតនៅបន្ទាត់ចុងក្រោយ។ របាយការណ៍ចំណូលពេញលេញត្រូវចាប់ផ្តើមដោយដាក់ចំណេញ ឬខាតនៅបន្ទាត់ទីមួយ និងត្រូវបង្ហាញយ៉ាងហោចណាស់នូវជាតុបន្ទាត់ដែលបង្ហាញចំនួនទឹកប្រាក់ក្នុងកថាខណ្ឌ៥.៥(ឆ)-៥.៥(ឈ) និងកថាខណ្ឌ ៥.៦ សម្រាប់ការិយបរិច្ឆេទ។

## ការតម្រូវនានាដែលអាចអនុវត្តចំពោះបែបផែនទាំងពីរខាងលើ

៥.៨ តាមស្តង់ដារនេះ ឥទ្ធិពលនៃការកែតម្រូវនូវកំហុសឆ្គង និងការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ត្រូវបានបង្ហាញថាជាការកែតម្រូវត្រឡប់ក្រោយនៃការិយបរិច្ឆេទមុនៗ មិនត្រូវដាក់ថាជាផ្នែកនៃចំណេញឬខាតក្នុងការិយបរិច្ឆេទដែលឥទ្ធិពលនិងការផ្លាស់ប្តូរទាំងអស់នោះកើតឡើង (សូមមើលផ្នែកទី១០)។

៥.៩ អង្គភាពមួយត្រូវបង្ហាញនូវជាតុបន្ទាត់ ចំណងជើងនិងសរុបរងបន្ថែមទៀត នៅក្នុងរបាយការណ៍ចំណូលពេញលេញ (និងក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ) នៅពេលដែលការបង្ហាញនេះ ពាក់ព័ន្ធនឹងការយល់ដឹងអំពីលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាពនោះ។

៥.១០ អង្គភាពមួយមិនត្រូវបង្ហាញឬពិពណ៌នាអំពីជាតុណាខ្លះនៃចំណូលនិងចំណាយថាជា “ជាតុមិនធម្មតា” នៅក្នុងរបាយការណ៍ចំណូលពេញលេញ (ឬក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ) ឬ នៅក្នុងកំណត់សម្គាល់នោះទេ។

## ការវិភាគលើចំណាយ

៥.១១ អង្គភាពមួយត្រូវបង្ហាញអំពីការវិភាគលើចំណាយដោយធ្វើចំណាត់ថ្នាក់ ដោយផ្អែកលើមូលដ្ឋាននៃប្រភេទចំណាយ ឬតួនាទីរបស់ចំណាយនៅក្នុងអង្គភាពមួយណា ដែលផ្តល់ព័ត៌មានគួរជាទីទុកចិត្តនិងពាក់ព័ន្ធជាង។

## ការវិភាគតាមប្រភេទចំណាយ

(ក) តាមវិធីសាស្ត្រនៃចំណាត់ថ្នាក់នេះ ចំណាយត្រូវបានផ្តុំនៅក្នុងរបាយការណ៍ចំណូលពេញលេញ ស្របតាមប្រភេទរបស់ចំណាយទាំងនោះ (ឧទាហរណ៍ ការរំលស់ ការទិញសម្ភារៈ ថ្លៃដឹកជញ្ជូន អត្ថប្រយោជន៍និយោជិត និងថ្លៃផ្សាយពាណិជ្ជកម្ម) ហើយដែលចំណាយទាំងនោះមិនត្រូវបានបែងចែកឡើងវិញតាមមុខងារផ្សេងៗគ្នានៅក្នុងអង្គភាពឡើយ។

## ការវិភាគតាមតួនាទីរបស់ចំណាយ

(ខ) តាមវិធីសាស្ត្រនៃចំណាត់ថ្នាក់នេះ ចំណាយត្រូវបានផ្តុំតាមតួនាទីរបស់ចំណាយទាំងនោះ ឧទាហរណ៍ ថ្លៃដើមចែកចាយ ឬថ្លៃដើមសកម្មភាពរដ្ឋបាល។ យ៉ាងហោចណាស់ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីថ្លៃដើមលក់របស់ខ្លួនតាមវិធីសាស្ត្រនេះដាច់ដោយឡែកពីចំណាយផ្សេងៗទៀត។

# ផ្នែកទី ៦
# របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍ចំណូលនិងចំណេញរក្សាទុក

## វិសាលភាពនៃផ្នែកនេះ

៦.១ ផ្នែកនេះកំណត់អំពីលក្ខខណ្ឌតម្រូវនានាសម្រាប់ការបង្ហាញនូវការប្រែប្រួលនានានៃមូលធនរបស់អង្គភាពសម្រាប់ការិយបរិច្ឆេទមួយ ក្នុងរបាយការណ៍បម្រែបម្រួលមូលធន ឬប្រសិនបើបំពេញបាននូវលក្ខខណ្ឌកំណត់ និងជាជម្រើសរបស់អង្គភាព ក្នុងរបាយការណ៍ចំណូលនិងចំណេញរក្សាទុក ។

## របាយការណ៍បម្រែបម្រួលមូលធន

### គោលបំណង

៦.២ របាយការណ៍បម្រែបម្រួលមូលធន បង្ហាញនូវចំណេញ ឬខាតរបស់អង្គភាពសម្រាប់ការិយបរិច្ឆេទរាយការណ៍មួយ ចំណូលលម្អិតផ្សេងៗសម្រាប់ការិយបរិច្ឆេទនោះ ឥទ្ធិពលនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ និងការកែតម្រូវកំហុសឆ្គងដែលបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ព្រមទាំងបរិមាណនៃវិនិយោគដោយ និង ភាគលាភ និងការបែងចែកទៅឱ្យផ្សេងទៀត ម្ចាស់ក្នុងតួនាទីរបស់ពួកគេជាម្ចាស់ នៅក្នុងអំឡុងការិយបរិច្ឆេទ។

## ព័ត៌មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍បម្រែបម្រួលមូលធន

៦.៣ របាយការណ៍បម្រែបម្រួលមូលធន រួមបញ្ចូលព័ត៌មានដូចខាងក្រោម៖

(ក) ចំណូលពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ ដោយបង្ហាញដាច់ដោយឡែកពីគ្នានូវចំនួនទឹកប្រាក់សរុបដែលជារបស់ម្ចាស់នៃក្រុមហ៊ុនមេ និងភាគកម្មមិនគ្រប់គ្រង

(ខ) សម្រាប់សមាសភាគនីមួយៗនៃមូលធន ឥទ្ធិពលនៃការអនុវត្តត្រឡប់ក្រោយ ឬការថ្លែងត្រឡប់ក្រោយដែលបានទទួលស្គាល់ស្របតាមផ្នែកទី១០ ស្តីពីគោលនយោបាយគណនេយ្យការប៉ាន់ស្មាន និងកំហុសឆ្គង និង

(គ) សម្រាប់សមាសភាគនីមួយៗនៃមូលធន ការផ្ទៀងផ្ទាត់រវាងតម្លៃយោងនាដើម និងចុងការិយបរិច្ឆេទ ដោយលាតត្រដាងដាច់ដោយឡែកពីគ្នានូវការប្រែប្រួលនានាដែលជាលទ្ធផលនៃ៖

១) ចំណេញ ឬខាត

២) ចំណូលលម្អិតផ្សេងៗ និង

៣) បរិមាណនៃការវិនិយោគដោយ ព្រមទាំងភាគលាភ និងការបែងចែកផ្សេងទៀតទៅឱ្យ ម្ចាស់ក្នុងតួនាទីរបស់ពួកគេជាម្ចាស់ ដោយបង្ហាញដាច់ដោយឡែកពីគ្នានូវការបោះផ្សាយភាគហ៊ុន ប្រតិបត្តិការ

ភាគហ៊ុនរតន: ភាគលាភ និងការបែងចែកផ្សេងទៀត ទៅឱ្យម្ចាស់ និងការប្រែប្រួលនានាលើភាគកម្ម ជាកម្មសិទ្ធិ នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិននាំឱ្យបាត់បង់ការគ្រប់គ្រង។

# របាយការណ៍ចំណូលនិងចំណេញរក្សាទុក

## គោលបំណង

៦.៤ របាយការណ៍ចំណូលនិងចំណេញ រក្សាទុកបង្ហាញអំពីចំណេញ ឬខាតរបស់អង្គភាពនិងការប្រែប្រួលនានានៃចំណេញរក្សាទុកសម្រាប់ការិយបរិច្ឆេទរាយការណ៍មួយ។ កថាខណ្ឌ ៣.១៨ អនុញ្ញាតឱ្យអង្គភាព មួយបង្ហាញនូវរបាយការណ៍ចំណូលនិងចំណេញរក្សាទុក ជំនួសឱ្យរបាយការណ៍ចំណូលពេញលេញ និង របាយការណ៍បម្រែបម្រួលមូលធន ប្រសិនបើការប្រែប្រួលទៅលើមូលធនរបស់ អង្គភាពក្នុងអំឡុងការិយបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញ គឺគ្រាន់តែបណ្តាលមកពីចំណេញ ឬខាត ការទូទាត់ភាគលាភ ការកែកំហុសឆ្លងការិយបរិច្ឆេទមុនៗ និងការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ។

## ព័ត៌មានដែលត្រូវបង្ហាញនៅក្នុង របាយការណ៍ចំណូលនិងចំណេញរក្សាទុក

៦.៦ អង្គភាពមួយត្រូវបង្ហាញនៅក្នុងរបាយការណ៍ចំណូលនិងចំណេញរក្សាទុក នូវសមាសធាតុនានា ដូចខាងក្រោម ដោយបន្ថែមលើព័ត៌មានដែលតម្រូវដោយផ្នែកទី៥ ស្តីពីរបាយការណ៍ចំណូលពេញលេញ និងរបាយការណ៍លទ្ធផល៖

(ក) ចំណេញរក្សាទុកនាដើមការិយបរិច្ឆេទរាយការណ៍

(ខ) ភាគលាភដែលបានប្រកាស និងបានទូទាត់ ឬត្រូវសងនៅក្នុងអំឡុងការិយបរិច្ឆេទ

(គ) ការថ្លែងឡើងវិញនូវចំណេញរក្សាទុក សម្រាប់ការកែកំហុសឆ្លងការិយបរិច្ឆេទមុនៗ

(ឃ) ការថ្លែងឡើងវិញនូវចំណេញរក្សាទុក សម្រាប់ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ និង

(ង) ចំណេញរក្សាទុកនាចុងការិយបរិច្ឆេទរាយការណ៍។



CamEd Business School

# ផ្នែកទី ៧
# របាយការណ៍លំហូរសាច់ប្រាក់

## វិសាលភាពនៃផ្នែកនេះ

៧.១ ផ្នែកនេះកំណត់អំពីព័ត៌មាន ដែលត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ និងថាតើត្រូវបង្ហាញព័ត៌មាននោះយ៉ាងដូចម្តេច។ របាយការណ៍លំហូរសាច់ប្រាក់ផ្តល់នូវព័ត៌មានអំពីការប្រែប្រួលនានាលើសាច់ប្រាក់ និងសាច់ប្រាក់សមមូលរបស់អង្គភាព សម្រាប់ការិយបរិច្ឆេទរាយការណ៍ ដោយបង្ហាញដាច់ដោយឡែកពីគ្នានូវការប្រែប្រួលបានពីសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន។

## សាច់ប្រាក់សមមូល

៧.២ សាច់ប្រាក់សមមូលមានរយៈពេលខ្លី និងជាការវិនិយោគដែលមានសន្ទនីយភាពខ្ពស់ ដែលអាចបំប្លែងជាចំនួនទឹកប្រាក់បានដឹងភ្លាមៗ ហើយអាចប្រឈមនឹងហានិភ័យតិចតួចនៃការប្រែប្រួលតម្លៃ។ សាច់ប្រាក់សមមូលត្រូវបានកាន់កាប់ដើម្បីបំពេញតម្រូវការសន្យាសាច់ប្រាក់រយៈពេលខ្លី ជាជាងទុកសម្រាប់ការវិនិយោគឬសម្រាប់គោលបំណងផ្សេងទៀត។ ដូចនេះ ការវិនិយោគមួយ ជាធម្មតាមានគុណសម្បត្តិជាសាច់ប្រាក់សមមូល តែនៅពេលដែលការវិនិយោគនោះមានកាលកំណត់រយៈពេលខ្លី ឧបមាប្រហែលជាបីខែ ឬតិចជាងនេះគិតពីថ្ងៃទទួលបាន។ ឥណទានវិបារូបន៍ធនាគារជាធម្មតា ត្រូវបានរាប់ជាសកម្មភាពហិរញ្ញប្បទានស្រដៀងនឹងប្រាក់កម្ចី។ ប៉ុន្តែ ប្រសិនបើ ឥណទានវិបារូបន៍ធនាគារត្រូវសងវិញតាមការតម្រូវ និងបង្កើតជាផ្នែកសំខាន់មួយនៃការគ្រប់គ្រងសាច់ប្រាក់របស់អង្គភាព ឥណទានវិបារូបន៍ធនាគារជាសមាសធាតុមួយនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល។

## ព័ត៌មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់

៧.៣ អង្គភាពមួយ ត្រូវបង្ហាញនូវរបាយការណ៍លំហូរសាច់ប្រាក់ ដែលបង្ហាញនូវលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទរាយការណ៍ដែលត្រូវបានចាត់ថ្នាក់តាមសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន។

### សកម្មភាពប្រតិបត្តិការ

៧.៤ សកម្មភាពប្រតិបត្តិការ គឺជាសកម្មភាពបង្កើតចំណូលចម្បងរបស់អង្គភាព។ ដូចនេះ លំហូរសាច់ប្រាក់ពី សកម្មភាពប្រតិបត្តិការ ជាទូទៅ បានមកពីប្រតិបត្តិការ និងព្រឹត្តិការណ៍និងកាលៈទេសៈផ្សេងៗទៀត ដែលកំណត់ចំណេញ ឬខាត។ ឧទាហរណ៍នៃលំហូរសាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការមានដូចជា៖

(ក) ចំណូលជាសាច់ប្រាក់ពីការលក់ទំនិញ និងការផ្តល់សេវា

(ខ) ចំណូលជាសាច់ប្រាក់ពីសួយសារ កម្រៃនានា កម្រៃជើងសារ និងចំណូលផ្សេងៗទៀត

(គ) ការទូទាត់ជាសាច់ប្រាក់ថ្លៃទំនិញនិងសេវាដល់អ្នកផ្គត់ផ្គង់

(ឃ) ការទូទាត់ជាសាច់ប្រាក់ដល់និយោជិត ឬក្នុងនាមនិយោជិត

(ង) ការទូទាត់ជាសាច់ប្រាក់ ឬការសងត្រឡប់នៃពន្ធលើប្រាក់ចំណូល វៀរលែងតែចំណាយទាំងនោះអាចត្រូវបានកំណត់ជាក់លាក់ជារបស់សកម្មភាពហិរញ្ញប្បទាន និងវិនិយោគ និង

(ច) ចំណូលនិងការទូទាត់ជាសាច់ប្រាក់ពីការវិនិយោគ កម្ចី និងកិច្ចសន្យាផ្សេងទៀត ទុកសម្រាប់គោលបំណងនៃការជួញដូរ ឬសម្រាប់ការធ្វើពាណិជ្ជកម្ម ដែលស្រដៀងគ្នាទៅនឹងសន្និធិដែលបានទិញទុកសម្រាប់លក់វិញ។ ប្រតិបត្តិការខ្លះ ដូចជា ការលក់សមាសធាតុមួយនៃរោងចក្រដោយអង្គភាពផលិតកម្ម អាចនាំឱ្យចំណេញឬខាតកើតមាន ដែលត្រូវបានសាច់ប្រាក់ ដែលទាក់ទិននឹងប្រតិបត្តិការបែបនេះ គឺជាលំហូរសាច់ពីសកម្មភាពវិនិយោគ។ញូលទៅក្នុងចំណេញឬខាត។

## សកម្មភាពវិនិយោគ

៧.៥ សកម្មភាពវិនិយោគ គឺជាការទិញ និងការបញ្ចេញចោលនូវទ្រព្យសកម្មរយៈពេលវែង និងការវិនិយោគផ្សេងទៀតដែលមិនបានចាត់បញ្ចូលជាសាច់ប្រាក់សមមូល។ ឧទាហរណ៍នៃលំហូរសាច់ ប្រាក់ដែលកើតពីសកម្មភាពវិនិយោគមានដូចជា៖

(ក) ការទូទាត់ជាសាច់ប្រាក់ដើម្បីទិញទ្រព្យ រោងចក្រ និងបរិក្ខារ (រាប់បញ្ចូលទាំងទ្រព្យ រោងចក្រ និងបរិក្ខាដែលបានសាងសង់ខ្លួនឯង) ទ្រព្យសកម្មអរូបី និងទ្រព្យសកម្មរយៈពេលវែងដទៃទៀត

(ខ) ចំណូលជាសាច់ប្រាក់បានពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ ទ្រព្យសកម្មអរូបី និងទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត

(គ) ការទូទាត់ជាសាច់ប្រាក់ក្នុងការទិញមូលធនឬឧបករណ៍បំណុលរបស់អង្គភាពផ្សេងទៀត ព្រមទាំងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន (លើកលែងតែ ការទូទាត់សម្រាប់ឧបករណ៍ទាំងនោះដែលបានចាត់ជាសាច់ប្រាក់សមមូល ឬដែលបានរក្សាទុកសម្រាប់ជួញដូរ ឬពាណិជ្ជកម្ម)

(ឃ) ចំណូលជាសាច់ប្រាក់ ដែលបានមកពីការលក់មូលធនឬឧបករណ៍បំណុលរបស់អង្គភាពផ្សេងទៀត និងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន (លើកលែងតែចំណូលសម្រាប់ឧបករណ៍ទាំងនោះដែលបានចាត់ជាសាច់ប្រាក់សមមូល ឬដែលបានរក្សាទុកសម្រាប់ជួញដូរ ឬពាណិជ្ជកម្ម)

(ង) សាច់ប្រាក់បុរេប្រទាន និងកម្ចី ដែលបានធ្វើឡើងសម្រាប់ភាគីផ្សេងទៀត

(ច) សាច់ប្រាក់ទទួលបានពីការបង់សងត្រឡប់នូវបុរេប្រទាន និងកម្ចីដែលបានធ្វើជាមួយភាគីផ្សេងទៀត

(ឆ) ការទូទាត់ជាសាច់ប្រាក់សម្រាប់កិច្ចសន្យាអនាគត កិច្ចសន្យាទិញទុកជាមុន សិទ្ធិទិញឬលក់ហ៊ុនក្នុងថ្លៃកំណត់ និងកិច្ចសន្យាដោះដូរ លើកលែងតែកិច្ចសន្យាទាំងនោះត្រូវបានធ្វើឡើងសម្រាប់ការជួញដូរ ឬពាណិជ្ជកម្ម ឬការទូទាត់ទាំងនោះ ត្រូវបានចាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទាន និង

(ជ) ចំណូលជាសាច់ប្រាក់បានពីកិច្ចសន្យាអនាគត កិច្ចសន្យាទិញទុកជាមុន សិទ្ធិទិញឬលក់ហ៊ុនក្នុងថ្លៃកំណត់ និងកិច្ចសន្យាដោះដូរ លើកលែងតែកិច្ចសន្យាទាំងនោះត្រូវបានធ្វើឡើងសម្រាប់ការជួញដូរ ឬពាណិជ្ជកម្ម ឬចំណូលទាំងនោះត្រូវបានចាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទាន។

នៅពេលដែលកិច្ចសន្យាមួយ ត្រូវបានធ្វើគណនេយ្យកម្មជាការទប់ស្កាត់ហានិភ័យ (សូមមើលផ្នែកទី១២ ស្តីពីបញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ) អង្គភាពត្រូវចាត់ថ្នាក់លំហូរសាច់ប្រាក់នៃកិច្ចសន្យានោះ តាមរបៀបដូចគ្នានឹងលំហូរសាច់ប្រាក់នៃធាតុដែលត្រូវបានទប់ស្កាត់ហានិភ័យ។

### សកម្មភាពហិរញ្ញប្បទាន

៧.៦ សកម្មភាពហិរញ្ញប្បទាន គឺជាសកម្មភាពដែលធ្វើឱ្យមានការប្រែប្រួលទំហំនិងសមាសភាគនៃ ទុនបរិច្ចាគ និងនៃកម្ចីរបស់អង្គភាពមួយ។ ឧទាហរណ៍នៃ លំហូរសាច់ប្រាក់ដែលកើតពី សកម្មភាពហិរញ្ញប្បទានមានដូចជា៖

(ក) សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយភាគហ៊ុន ឬឧបករណ៍មូលធនផ្សេងទៀត។

(ខ) ការទូទាត់ជាសាច់ប្រាក់ដល់ម្ចាស់សម្រាប់ទិញ ឬលោះមកវិញនូវភាគហ៊ុនរបស់អង្គភាព។

(គ) សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយសញ្ញាបណ្ណឥណទាន កម្ចី កំណត់សន្យា សញ្ញាបណ្ណ ប័ណ្ណបញ្ចាំ និងកម្ចីរយៈពេលខ្លីនិងវែងដទៃទៀត។

(ឃ) ការទូទាត់សងសាច់ប្រាក់វិញនូវចំនួនទឹកប្រាក់ដែលបានខ្ចី និង

(ង) ការទូទាត់ជាសាច់ប្រាក់ដោយភតិក: សម្រាប់កាត់បន្ថយបំណុលដែលនៅសល់ទាក់ទិននឹងភតិសន្យាហិរញ្ញវត្ថុ។

## ការរាយការណ៍លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ

៧.៧ អង្គភាពមួយត្រូវបានបង្ហាញអំពីលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិ ដោយប្រើវិធីសាស្ត្រមួយ ក្នុងចំណោមវិធីសាស្ត្រពីរខាងក្រោម៖

(ក) វិធីសាស្ត្រប្រយោល ដែលតាមវិធីសាស្ត្រនេះ ចំណេញឬខាតត្រូវបានកែតម្រូវដោយសារឥទ្ធិពលនៃប្រតិបត្តិការមិនមែនជាសាច់ប្រាក់ ការពន្យារ ឬបង្គរ នៃប្រតិបត្តិការចំណូលឬការទូទាត់ជាសាច់ប្រាក់ពីអតីត ឬ នាពេលអនាគត ព្រមទាំងធាតុនានានៃចំណូល ឬចំណាយ ដែលទាក់ទងនឹងលំហូរសាច់ប្រាក់វិនិយោគ ឬហិរញ្ញប្បទាន ឬ

(ខ) វិធីសាស្ត្រផ្ទាល់ ដែលតាមវិធីសាស្ត្រនេះ ចំណាត់ថ្នាក់ចម្បងនៃចំណូលសាច់ប្រាក់ដុល និងចំណាយសាច់ប្រាក់ដុល ត្រូវបានលាតត្រដាង។

### វិធីសាស្ត្រប្រយោល

៧.៨ តាមវិធីសាស្ត្រប្រយោលនេះ លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការត្រូវបានកំណត់ដោយការធ្វើការកែតម្រូវលើចំណេញ ឬខាត ដោយសារឥទ្ធិពលនៃ៖

(ក) ការប្រែប្រួលក្នុងអំឡុងការិយបរិច្ឆេទនៃសន្និធិ និងនៃប្រតិបត្តិការត្រូវទទួលនិងត្រូវសង

(ខ) បណ្តាធាតុមិនមែនជាសាច់ប្រាក់ ដូចជា ការរំលស់ សំវិធានធន ពន្ធពន្យារ ចំណូល (ចំណាយ) បង្គរដែលមិនទាន់បានទទួល (គេមិនទាន់បង់) ជាសាច់ប្រាក់ ចំណេញនិងខាតរូបិយប័ណ្ណបរទេសមិនទាន់ក្លាយជាការពិត ចំណេញមិនទាន់បែងចែករបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ និងភាគកម្មមិនគ្រប់គ្រង និង

(គ) ជាតុដទៃទៀតទាំងអស់ ដែលឥទ្ធិពលសាច់ប្រាក់របស់ជាតុដទៃទៀតទាំងអស់នោះ ទាក់ទិនទៅនឹងការវិនិយោគឬហិរញ្ញប្បទាន។

## វិធីសាស្ត្រ ផ្ទាល់

៧.៩ តាមវិធីសាស្ត្រផ្ទាល់ លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ ត្រូវបានបង្ហាញដោយការលាតត្រដាង ព័ត៌មានអំពីថ្នាក់ចម្បងនៃចំណូលសាច់ប្រាក់ដុលនិងចំណាយសាច់ប្រាក់ដុល។ ព័ត៌មានទាំងនេះអាចត្រូវបានទទួលបានតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

(ក) ពីការកត់ត្រាគណនេយ្យកម្មរបស់អង្គភាព ឬ

(ខ) ពីការកែតម្រូវការលក់ ថ្លៃដើមលក់ និងជាតុផ្សេងទៀតនៅក្នុងរបាយការណ៍ ចំណូលពេញលេញ (ឬក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ) សម្រាប់ ៖

១) ការប្រែប្រួលក្នុងអំឡុងការិយបរិច្ឆេទនៃសន្និធិ និងប្រតិបត្តិការត្រូវទទួលនិងត្រូវសង

២) សមាសជាតុមិនមែនជាសាច់ប្រាក់ដទៃទៀត និង

៣) ជាតុដទៃទៀតដែលឥទ្ធិពលសាច់ប្រាក់របស់ជាតុដទៃទៀតនោះ គឺលំហូរសាច់ប្រាក់វិនិយោគ ឬហិរញ្ញប្បទាន។

# ការរាយការណ៍លំហូរសាច់ប្រាក់ពីសកម្មភាព វិនិយោគ និងសកម្មភាពហិរញ្ញប្បទាន

៧.១០ អង្គភាពមួយត្រូវបង្ហាញដោយឡែកពីគ្នានូវថ្នាក់ចម្បងនៃចំណូលសាច់ប្រាក់ដុល និងការទូទាត់សាច់ប្រាក់ដុលដែលបណ្តាលមកពីសកម្មភាពវិនិយោគនិងហិរញ្ញប្បទាន។ លំហូរសាច់ប្រាក់សរុបដែលកើតមកពីការទិញនិងពីការបញ្ចេញចោលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬអង្គភាពអាជីវកម្មដទៃទៀតត្រូវបានធ្វើការបង្ហាញដាច់ដោយឡែក និងត្រូវចាត់ថ្នាក់ជាសកម្មភាពវិនិយោគ។

# លំហូរសាច់ប្រាក់រូបិយប័ណ្ណបរទេស

៧.១១ អង្គភាពមួយត្រូវកត់ត្រាលំហូរសាច់ប្រាក់ ដែលកើតឡើងពីប្រតិបត្តិការជារូបិយប័ណ្ណបរទេសក្នុងរូបិយប័ណ្ណមុខងាររបស់អង្គភាព ដោយអនុវត្តចំពោះចំនួនទឹកប្រាក់រូបិយប័ណ្ណបរទេសនូវអត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណមុខងារនិងរូបិយប័ណ្ណបរទេសនៅកាលបរិច្ឆេទនៃលំហូរសាច់ប្រាក់។ កថាខណ្ឌ៣០.១៩ពេលវេលាដែលអត្រាប្តូរប្រាក់ដែលប្រហាក់ប្រហែលនឹងអត្រាពិតប្រាកដអាចត្រូវបានប្រើ។

៧.១២ អង្គភាពត្រូវបកប្រែលំហូរសាច់ប្រាក់នៃក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស នៅអត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណមុខងាររបស់អង្គភាពនិងរូបិយប័ណ្ណបរទេសនៅបណ្តាកាលបរិច្ឆេទនៃលំហូរសាច់ប្រាក់។

៧.១៣ ចំណេញនិងខាតមិនទាន់ក្លាយជាការពិត ដែលបណ្តាលមកពីការប្រែប្រួលនៃអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស មិនមែនជាលំហូរសាច់ប្រាក់ទេ។ ប៉ុន្តែ ដើម្បីផ្ទុផ្ទងសាច់ប្រាក់និងសាច់ប្រាក់សមមូលនៅដើមនិងចុងការិយបរិច្ឆេទ ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់ទៅលើសាច់ប្រាក់និងសាច់ប្រាក់សមមូលដែលបានរក្សាទុកឬដល់ពេលកំណត់នៃរូបិយប័ណ្ណបរទេសត្រូវតែបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់។ ដូចនេះ អង្គភាពនោះត្រូវវាស់វែងឡើងវិញនូវសាច់ប្រាក់និងសាច់ប្រាក់សមមូលដែលបានរក្សាទុកក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ (ដូចជាចំនួនទឹកប្រាក់នៃរូបិយប័ណ្ណបរទេស ដែលបានរក្សាទុកនិងគណនីធនាគាររូបិយប័ណ្ណបរទេសជាដើម) នៅអត្រាប្តូរប្រាក់ចុងការិយបរិច្ឆេទ។ អង្គភាពត្រូវបង្ហាញនូវលទ្ធផលចំណេញឬខាត ដែលមិនទាន់ក្លាយជាការពិតដាច់ដោយឡែកពី លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ វិនិយោគនិងហិរញ្ញប្បទាន។

## ការប្រាក់ និង ភាគលាភ

៧.១៤ អង្គភាពមួយត្រូវបង្ហាញដាច់ដោយឡែក នូវលំហូរសាច់ប្រាក់ពីការប្រាក់ និងភាគលាភដែលទទួលបាន និងបានទូទាត់។ អង្គភាព ត្រូវចាត់ថ្នាក់លំហូរសាច់ប្រាក់ឱ្យមានសង្គតិភាព ពីកាលបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀតជាសកម្មភាពប្រតិបត្តិការ វិនិយោគ ឬហិរញ្ញប្បទាន។

៧.១៥ អង្គភាពត្រូវចាត់ថ្នាក់ការប្រាក់ដែលបានទូទាត់ និងការប្រាក់និងភាគលាភដែលបានទទួល ជាលំហូរសាច់ប្រាក់ប្រតិបត្តិការ ពីព្រោះទាំងនោះត្រូវបានរួមបញ្ចូលក្នុងចំណេញឬខាត។ ឬក៏ អង្គភាពត្រូវចាត់ថ្នាក់ការប្រាក់ដែលបានទូទាត់ និងការប្រាក់និងភាគលាភដែលបានទទួល បែងចែកផ្សេងគ្នាជាលំហូរសាច់ប្រាក់ហិរញ្ញប្បទាននិងលំហូរសាច់ប្រាក់វិនិយោគ ពីព្រោះទាំងអស់នោះជាថ្លៃដើមក្នុងការទទួលបានធនធានហិរញ្ញវត្ថុឬផលពីការវិនិយោគ។

៧.១៦ អង្គភាពត្រូវចាត់ថ្នាក់ភាគលាភដែលបានទូទាត់ជាលំហូរសាច់ប្រាក់ហិរិញ្ញប្បទាន ពីព្រោះទាំងនោះជាថ្លៃដើមក្នុងការទទួលបានធនធានហិរញ្ញវត្ថុ។ ឬក៏ អង្គភាពត្រូវចាត់ថ្នាក់ភាគលាភដែលបានទូទាត់ជាសមាសធាតុនៃលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ ពីព្រោះទាំងនោះត្រូវបានទូទាត់ចេញពីលំហូរសាច់ប្រាក់ប្រតិបត្តិការ។

## ពន្ធលើប្រាក់ចំណូល

៧.១៧ អង្គភាពត្រូវបង្ហាញដាច់ដោយឡែកនូវលំហូរសាច់ប្រាក់ ដែលកើតឡើងពីពន្ធលើប្រាក់ចំណូល និងត្រូវចាត់ថ្នាក់ទាំងនោះជាលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ វៀរលែងតែទាំងនោះអាចត្រូវបានកំណត់ជាក់លាក់ជាសកម្មភាពហិរញ្ញប្បទាននិងវិនិយោគ។ ពេលដែលលំហូរសាច់ប្រាក់ពន្ធ ត្រូវបានចាត់ចែងទៅកាន់ថ្នាក់នៃសកម្មភាពលើសពីមួយ អង្គភាពនោះ ត្រូវលាតត្រដាងនូវចំនួនទឹកប្រាក់សរុបនៃពន្ធដែលបានទូទាត់។

## ប្រតិបត្តិការមិនមែនជាសាច់ប្រាក់

៧.១៨ អង្គភាពត្រូវដកចេញពីរបាយការណ៍លំហូរសាច់ប្រាក់នូវប្រតិបត្តិការវិនិយោគនិ ងហិរញ្ញប្បទាន ដែលមិនទាមទារនូវការប្រើប្រាស់សាច់ប្រាក់ឬសាច់ប្រាក់សមមូល។ អង្គភាពត្រូវលាតត្រដាងប្រតិបត្តិការបែបនេះនៅកន្លែងផ្សេងក្នុងរបាយការណ៍ហិរញ្ញវត្ថុ តាមរបៀបដែលផ្តល់នូវព័ត៌មានពាក់ព័ន្ធទាំងអស់អំពីសកម្មភាពវិនិយោគនិងហិរញ្ញប្បទានទាំងនោះ។

៧.១៩ សកម្មភាពវិនិយោគនិងហិរញ្ញប្បទានជាច្រើន មិនមានផលប៉ះពាល់ផ្ទាល់លើលំហូរសាច់ប្រាក់បច្ចុប្បន្ន ទោះបីជាសកម្មភាពទាំងនោះប៉ះពាល់ដល់រចនាសម្ព័ន្ធមូលធន និងទ្រព្យសកម្មរបស់អង្គភាពក៏ដោយ។ ការដកចេញនូវប្រតិបត្តិការមិនមែនសាច់ប្រាក់ពីរបាយការណ៍លំហូរសាច់ប្រាក់ គឺមានសង្គតិភាពនឹងកម្មវត្ថុនៃរបាយការណ៍លំហូរសាច់ប្រាក់ ពីព្រោះធាតុទាំងនេះមិនមានលំហូរសាច់ប្រាក់ពេលបច្ចុប្បន្នចូលរួមជាមួយឡើយ។ ឧទាហរណ៍នៃប្រតិបត្តិការមិនមែនសាច់ប្រាក់មានដូចជា៖

(ក) ការទទួលបានទ្រព្យសកម្ម ដោយរ៉ាប់រងផ្ទាល់នូវបំណុលពាក់ព័ន្ធ ឬតាមរយៈភតិសន្យាហិរញ្ញវត្ថុ

(ខ) ការទិញអង្គភាព តាមរយៈការបោះផ្សាយមូលធន និង

(គ) ការបំប្លែងបំណុលទៅជាមូលធន។

## សមាសធាតុនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល

៧.២០ អង្គភាពត្រូវបង្ហាញនូវសមាសធាតុនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល និងត្រូវបង្ហាញការផ្ទៀងផ្ទាត់នៃចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ ទៅនឹងធាតុសមមូល ដែលបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ប៉ុន្តែ អង្គភាពមិនត្រូវបានតម្រូវឱ្យបង្ហាញការផ្ទៀងផ្ទាត់នេះ ប្រសិនបើចំនួនទឹកប្រាក់នៃសាច់ប្រាក់និងសាច់ប្រាក់សមមូល ដែលបានបង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ គឺដូចគ្នាទៅនឹងចំនួនទឹកប្រាក់ ដែលបានពិពណ៌នាយ៉ាងស្រដៀងក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ការលាតត្រដាងផ្សេងទៀត

៧.២១ អង្គភាពត្រូវលាតត្រដាង អមជាមួយការបញ្ចេញមតិរបស់ថ្នាក់គ្រប់គ្រង នូវចំនួនទឹកប្រាក់នៃសមតុល្យសាច់ប្រាក់និងសាច់ប្រាក់សមមូលសំខាន់ ដែលរក្សាទុកដោយអង្គភាព ដែលមិនអាចប្រើប្រាស់បានដោយអង្គភាពនោះ។ សាច់ប្រាក់និងសាច់ប្រាក់សមមូលដែលរក្សាទុកដោយអង្គភាពអាចជាមិនអាចប្រើប្រាស់បានដោយអង្គភាពនោះ ដោយសារតែ ក្នុងចំណោមមូលហេតុផ្សេងទៀត ការគ្រប់គ្រងរូបិយប័ណ្ណបរទេសឬការដាក់កំហិតខាងផ្លូវច្បាប់ជាដើម។

# ផ្នែកទី ៨
# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## វិសាលភាពនៃផ្នែកនេះ

៨.១ ផ្នែកនេះកំណត់គោលការណ៍ជាមូលដ្ឋាន នៃព័ត៌មាននានាដែលត្រូវធ្វើការបង្ហាញ នៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ និងវិធីបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។ កំណត់សម្គាល់ មានផ្ទុកព័ត៌មានបន្ថែមពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណូលពេញលេញ (ប្រសិនបើបង្ហាញ) របាយការណ៍លទ្ធផល (ប្រសិនបើបានបង្ហាញ) របាយការណ៍រួមនៃចំណូលនិងចំណេញរក្សាទុក (ប្រសិនបើបង្ហាញ) របាយការណ៍បម្រែបម្រួលមូលធន (ប្រសិនបើបង្ហាញ) និងរបាយការណ៍លំហូរសាច់ប្រាក់។ កំណត់សម្គាល់ ផ្តល់នូវការពិពណ៌នាបែបរៀបរាប់ ឬការបំបែកសមាសធាតុនានាដែលបានបង្ហាញនៅក្នុងរបាយការណ៍ទាំងនោះ ព្រមទាំងព័ត៌មានអំពីសមាសធាតុ ដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ការទទួលស្គាល់នៅក្នុងរបាយការណ៍ទាំងនោះ។ បន្ថែមលើ ការតម្រូវនៅក្នុងផ្នែកនេះ ស្ទើរតែគ្រប់ផ្នែកផ្សេងទៀតនៃស្តង់ដារនេះ តម្រូវនូវការលាតត្រដាងដែលជាធម្មតាមានបង្ហាញនៅក្នុងកំណត់សម្គាល់។

## រចនាសម្ព័ន្ធនៃកំណត់សម្គាល់

៨.២ កំណត់សម្គាល់ត្រូវ ៖

(ក) បង្ហាញនូវព័ត៌មានអំពីមូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងគោលនយោបាយគណនេយ្យជាក់លាក់ ដែលបានប្រើប្រាស់ ដោយស្របតាមកថាខណ្ឌ ៨. ៥-៨. ៧

(ខ) លាតត្រដាងព័ត៌មានដែលតម្រូវដោយស្តង់ដារនេះ ដែលមិនបង្ហាញកន្លែងណាផ្សេង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(គ) ផ្តល់នូវព័ត៌មាន ដែលមិនបង្ហាញនៅកន្លែងណាផ្សេង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែព័ត៌មាននោះពាក់ព័ន្ធនឹងការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុណាមួយ។

៨.៣ ឱ្យតែអាចធ្វើទៅបាន អង្គភាពត្រូវបង្ហាញនូវកំណត់សម្គាល់ក្នុងលក្ខណៈជាប្រព័ន្ធ។ អង្គភាពត្រូវធ្វើ សេចក្តីយោងឆ្លងនូវសមាសធាតុនីមួយៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុជាមួយ នឹងព័ត៌មាន ពាក់ព័ន្ធនានានៅក្នុងកំណត់សម្គាល់។

៨.៤ ជាធម្មតា អង្គភាពបង្ហាញនូវកំណត់សម្គាល់ តាមលំដាប់ដូចតទៅ ៖

(ក) សេចក្តីថ្លែងការណ៍ដែលថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម (សូមមើលកថាខណ្ឌ ៣.៣)

(ខ) ការសង្ខេបនូវគោលនយោបាយគណនេយ្យសំខាន់ៗដែលបានអនុវត្ត (សូមមើលកថាខណ្ឌ ៨. ៥)

(គ) ព័ត៌មានគាំទ្រសម្រាប់សមាសធាតុនានា ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ តាមលំដាប់លំដោយដែលក្នុងនោះការអះអាងនីមួយៗ និងធាតុបន្ទាត់នីមួយៗត្រូវបានបង្ហាញ និង

(ឃ) ការលាតត្រដាងផ្សេងទៀតណាមួយ។

## ការលាតត្រដាងអំពីគោលនយោបាយគណនេយ្យ

៨.៥ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មាននៅក្នុងការសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ ដូចខាងក្រោម ៖

(ក) មូលដ្ឋាននៃការវាស់វែង (ឬមូលដ្ឋាននានា) ដែលបានប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និង

(ខ) គោលនយោបាយគណនេយ្យដទៃទៀត ដែលបានប្រើប្រាស់ដែលពាក់ព័ន្ធទៅនឹងការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុ។

## ព័ត៌មានអំពីការវិនិច្ឆ័យ

៨.៦ នៅក្នុងសេចក្ដីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ ឬនៅក្នុងកំណត់សម្គាល់ផ្សេងទៀត អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីការវិនិច្ឆ័យ ដោយឡែកពីអ្វីពាក់ព័ន្ធនឹងការប៉ាន់ស្មាន (សូមមើលកថាខណ្ឌ ៨. ៧) ដែលថ្នាក់គ្រប់គ្រងបានធ្វើឡើង ក្នុងដំណើរការនៃអនុវត្តគោលនយោបាយគណនេយ្យរបស់អង្គភាព ហើយដែលនោះមានឥទ្ធិពលយ៉ាងខ្លាំងលើចំនួនទឹកប្រាក់នានា ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ព័ត៌មានអំពីប្រភពគន្លឹះនៃភាពមិនប្រាកដប្រជាការប៉ាន់ស្មាន

៨.៧ អង្គភាពមួយត្រូវលាតត្រដាង នៅក្នុងកំណត់សម្គាល់អំពីព័ត៌មានស្ដីពីការសន្មតគន្លឹះ ដែលពាក់ព័ន្ធនឹងអនាគតកាល ព្រមទាំងប្រភពគន្លឹះនៃភាពមិនប្រាកដប្រជាការប៉ាន់ស្មានដទៃទៀត នាការិយបរិច្ឆេទរាយការណ៍ ដែល មានហានិភ័យខ្ពស់អាចបណ្ដាលឱ្យមានការកែតម្រូវជាសារវន្តលើតម្លៃ យោងរបស់ទ្រព្យសកម្មនិង បំណុលនាក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់។ អំពីទ្រព្យសកម្មនិងបំណុលទាំងនោះ កំណត់សម្គាល់ត្រូវបញ្ចូលនូវភាពលម្អិតនៃ ៖

(ក) ប្រភេទរបស់ទ្រព្យសកម្មនិងបំណុលទាំងនោះ និង

(ខ) តម្លៃយោងរបស់ទ្រព្យសកម្មនិងបំណុលទាំងនោះនាចុងការិយបរិច្ឆេទរាយការណ៍។

# ផ្នែកទី ៩

# របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក

## វិសាលភាពនៃផ្នែកនេះ

៩.១ ផ្នែកនេះកំណត់កាលៈទេសៈការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមដោយអង្គភាពដែលអនុវត្តស្តង់ដារនេះ និងនីតិវិធីសម្រាប់រៀបចំរបាយការណ៍ទាំងនោះស្របតាម ស្តង់ដារនេះ។ ផ្នែកនេះក៏រួមបញ្ចូលផងដែរនូវគោលការណ៍ណែនាំអំពីរបាយការណ៍ហិរញ្ញវត្ថុដោយឡែក និងរបាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា ប្រសិនបើរបាយការណ៍ទាំងនេះត្រូវបានរៀបចំស្របតាម ស្តង់ដារនេះ។ ប្រសិនបើអង្គភាពមេខ្លួនឯង មិនមានការទទួលខុសត្រូវជាសាធារណៈ អង្គភាពនោះអាចបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ទោះបីជាអង្គភាពនោះ បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមរបស់អង្គភាព ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ឬបណ្តុំគោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ (GAAP) ផ្សេងទៀតក៏ដោយ។

## ការតម្រូវឱ្យបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម

៩.២ លើកលែងតែកថាខណ្ឌ ៩.៣ និង ៩.៣(គ) បានអនុញ្ញាត ឬតម្រូវ អង្គភាពមេត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដែលក្នុងនោះអង្គភាពបូករួមនូវការវិនិយោគរបស់ខ្លួនក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ របាយការណ៍ហិរញ្ញវត្ថុរួម ត្រូវរួមបញ្ចូលនូវក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់នៃក្រុមហ៊ុនមេ។

៩.៣ ក្រុមហ៊ុនមេ មិនចាំបាច់បង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុរួម ប្រសិនបើបំពេញបានតាមលក្ខខណ្ឌទាំងពីរខាងក្រោម៖

ក) ក្រុមហ៊ុនមេខ្លួនឯងគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយ និង

ខ) ក្រុមហ៊ុនមេធំបំផុត (ឬក្រុមហ៊ុនមេមធ្យមណាមួយ) បង្កើតរបាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់គោលបំណងទូទៅ ដែលអនុលោមតាម ស្តង់ដារនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ឬតាមស្តង់ដារនេះ។

៩.៣ក ក្រៅពីមានការបញ្ជាក់ដោយឡែកនៅកថាខណ្ឌ៩.៣ខ ក្រុមហ៊ុនញាតិសម្ព័ន្ធ មិនត្រូវបានរួមបញ្ចូលទេ ប្រសិនបើត្រូវបានទិញ និងកាន់កាប់ ក្នុងបំណងលក់ ឬបញ្ចេញចោល ក្នុងអំឡុងមួយឆ្នាំ គិតចាប់ពីថ្ងៃទិញក្រុមហ៊ុននោះ (គឺនៅកាលបរិច្ឆេទដែលអ្នកទិញទទួលបានការត្រួតត្រាពីអ្នកលក់)។ ក្រុមហ៊ុនបុត្រសម្ព័ន្ធបែបនេះត្រូវបានកត់ត្រាដោយស្របតាមការតម្រូវនៅក្នុងផ្នែកទី១១ ស្តីអំពីការវិនិយោគនៅក្នុងកថាខណ្ឌ១១.៨(ឃ) ជាជាងស្របតាមផ្នែកនេះ។ អង្គភាពមេ ក៏ត្រូវផ្តល់ការលាតត្រដាងនៅក្នុងកថាខណ្ឌ៩.២៣ក ផងដែរ។

៩.៣ខ ប្រសិនបើក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានផាត់ចេញពីការរួមបញ្ចូល ស្របតាមកថាខណ្ឌ៩.៣ក មិនត្រូវបានបញ្ចេញចោល ក្នុងអំឡុងមួយឆ្នាំគិតពីកាលបរិច្ឆេទទិញ (ពោលគឺអង្គភាពមេនៅតែត្រួតត្រាក្រុមហ៊ុនបុត្រសម្ព័ន្ធនោះនៅឡើយ)៖

(ក) អង្គភាពមេត្រូវរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ គិតពីកាលបរិច្ឆេទទិញ វៀរលែងក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ បំពេញលក្ខខណ្ឌក្នុងកថាខណ្ឌ៩.៣ខ(ខ)។ ដូច្នេះ ប្រសិនបើកាលបរិច្ឆេទទិញនៅក្នុងការិយបរិច្ឆេទមុន ការិយបរិច្ឆេទមុនៗដែលពាក់ព័ន្ធ ត្រូវរៀបរាប់ឡើងវិញ។

(ខ) ប្រសិនបើមានការយឺតយ៉ាវបណ្តាលមកពីហេតុការណ៍ ឬកាលៈទេសៈ ដែលហួសពីការគ្រប់គ្រងរបស់អង្គភាពមេ ហើយមានភ័ស្តុតាងគ្រប់គ្រាន់នៅកាលបរិច្ឆេទធ្វើរបាយការណ៍ថាអង្គភាពមេ នៅតែមានការតាំងចិត្តចំពោះផែនការរបស់ខ្លួន ក្នុងការលក់ ឬបញ្ចេញចោលក្រុមហ៊ុនបុត្រសម្ព័ន្ធនៅឡើយ អង្គភាពមេត្រូវបន្តការកត់ត្រាក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ ដោយស្របតាមកថាខណ្ឌ៩.៣ក។

៩.៣គ ប្រសិនបើក្រុមហ៊ុនមេ ពុំមានក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រៅពីក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនត្រូវបានតម្រូវឱ្យរួមបញ្ចូលស្របតាមកថាខណ្ឌ៩.៣ក-៩.៣ខ ក្រុមហ៊ុនមេមិនត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមឡើយ។ ទោះបីជាយ៉ាងនេះក្តី ក្រុមហ៊ុនមេ ត្រូវផ្តល់ការលាតត្រដាងនៅក្នុងកថាខណ្ឌ៩.២៣ក។

៩.៤ ក្រុមហ៊ុនបុត្រសម្ព័ន្ធគឺជាអង្គភាពមួយ ដែលត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនមេ។ ការគ្រប់គ្រងគឺជាអំណាចគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុនិងប្រតិបត្តិការរបស់អង្គភាព ដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់អង្គភាពនោះ។ ប្រសិនបើ អង្គភាពមួយបានបង្កើតនូវអង្គភាពគោលបំណងពិសេស ដើម្បីបំពេញគោលដៅតូចៗ និងបានកំណត់ច្បាស់លាស់ អង្គភាពនោះត្រូវបូករួមនូវអង្គភាពគោលបំណងពិសេស នៅពេលដែលជាតុពិតនៃទំនាក់ទំនងបង្ហាញថា អង្គភាពគោលបំណងពិសេសត្រូវបានគ្រប់គ្រងដោយអង្គភាពនោះ (សូមមើលកថាខណ្ឌ៩.១០-៩.១២)។

៩.៥ ការត្រួតពិនិត្យ ត្រូវបានសន្មតថាមាននៅពេលដែលអង្គភាពមេជាម្ចាស់ មានសិទ្ធិអំណាចបោះឆ្នោតច្រើនជាងពាក់កណ្តាលនៃសិទ្ធិបោះឆ្នោតសរុបរបស់អង្គភាពតាមក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនដោយផ្ទាល់ឬដោយប្រយោល។ ការសន្មតនេះអាចនឹងបរាជ័យក្នុងកាលៈទេសៈពិសេសនានា ប្រសិនបើអាចបង្ហាញយ៉ាងច្បាស់ថាកម្មសិទ្ធិបែបនេះមិនបង្កើតបានជាការគ្រប់គ្រងទេ។ ការគ្រប់គ្រង ក៏មាននៅពេលដែលក្រុមហ៊ុនមេមានអំណាចបោះឆ្នោតស្មើពាក់កណ្តាលឬក្រោមនេះនៃអំណាចបោះឆ្នោតរបស់អង្គភាព ប៉ុន្តែក្រុមហ៊ុនមេមាន៖

(ក) អំណាចលើសពាក់កណ្តាលនៃសិទ្ធិបោះឆ្នោតដោយសារតែកិច្ចព្រមព្រៀងជាមួយវិនិយោគិនផ្សេងទៀត

(ខ) អំណាចគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុនិងប្រតិបត្តិការរបស់អង្គភាព តាមលក្ខន្តិកៈ ឬតាមការព្រមព្រៀង

(គ) អំណាចតែងតាំងឬដកហូតសមាជិកភាគច្រើនរបស់ក្រុមប្រឹក្សាភិបាលឬនៃស្ថាប័នគ្រប់គ្រងសមមូល ហើយការគ្រប់គ្រងអង្គភាពគឺដោយក្រុមប្រឹក្សា ឬស្ថាប័នគ្រប់គ្រងនោះ ឬ

(ឃ) អំណាចបោះឆ្នោតភាគច្រើននៅការប្រជុំនានានៃក្រុមប្រឹក្សាភិបាល ឬស្ថាប័នគ្រប់គ្រងសមមូល ហើយការគ្រប់គ្រងអង្គភាពគឺដោយក្រុមប្រឹក្សា ឬស្ថាប័នគ្រប់គ្រងនោះ។

៩.៦ ការគ្រប់គ្រងអាចត្រូវបានសម្រេចបាន ដោយមានសិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់ ឬឧបករណ៍អាចបំប្លែង ដែលអាចប្រើប្រាស់បាននាពេលបច្ចុប្បន្ន ឬដោយមានភ្នាក់ងារដែលមានសមត្ថភាពដឹកនាំសកម្មភាពសម្រាប់ជាប្រយោជន៍នៃអង្គភាពគ្រប់គ្រង។

៩.៧ ក្រុមហ៊ុនបុត្រសម្ព័ន្ធមិនត្រូវបានដកចេញពីការបូករួម គ្រាន់តែពីព្រោះវិនិយោគិននោះគឺជាអង្គការទុនវិនិយោគផ្សងព្រេង ឬអង្គភាពស្រដៀង។

៩.៨ ក្រុមហ៊ុនបុត្រសម្ព័ន្ធមួយ មិនត្រូវបានដកចេញពីការបូករួម ពីព្រោះសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះមិនស្រដៀងនឹងសកម្មភាពអាជីវកម្មរបស់អង្គភាពដទៃក្នុងការបូករួម។ ព័ត៌មានពាក់ព័ន្ធត្រូវបានផ្តល់ដោយការបូករួមក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងនេះ និងការលាតត្រដាងបន្ថែមនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ស្តីពីបណ្តាសកម្មភាពអាជីវកម្មខុសគ្នារបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ។

៩.៩ អង្គភាពបុត្រសម្ព័ន្ធមួយមិនត្រូវបានដកចេញពីការបូករួម ពីព្រោះអង្គភាពនោះធ្វើប្រតិបត្តិការនៅក្នុងយុត្តាធិការមួយដែលដាក់កំហិតនូវការផ្ទេរសាច់ប្រាក់ ឬទ្រព្យសកម្មផ្សេងទៀតចេញពីយុត្តាធិការនោះ។

## អង្គភាពគោលបំណងពិសេស

៩.១០ អង្គភាពមួយអាចត្រូវបានបង្កើតឡើងដើម្បីសម្រេចកម្មវត្ថុតូចមួយ (ឧទាហរណ៍ ធ្វើឱ្យភតិសន្យាមានអនុភាព ចាប់ផ្តើមសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ ឬធ្វើមូលបត្រកម្មទ្រព្យសកម្មហិរញ្ញវត្ថុជាដើម)។

អង្គភាពគោលបំណងពិសេសបែបនេះ អាចយកទម្រង់ជាសាជីវកម្ម បរធនបាលកិច្ច សហកម្មសិទ្ធិ ឬអង្គភាពមិនចុះបញ្ជីក្រុមហ៊ុន។ ជារឿយៗ អង្គភាពគោលបំណងពិសេស ត្រូវបានបង្កើតឡើងតាមការរៀបចំផ្នែកច្បាប់ ដែលដាក់ការតម្រូវយ៉ាងតឹងរឹងលើប្រតិបត្តិការរបស់អង្គភាពគោលបំណងពិសេសនោះ។

៩.១១ អង្គភាពត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដែលរួមបញ្ចូលនូវអង្គភាព និងអង្គភាពគោលបំណងពិសេសណា ដែលត្រូវបានគ្រប់គ្រងដោយអង្គភាពនោះ។ បន្ថែមលើកាលៈទេសៈដែលបានពិពណ៌នាក្នុងថាខណ្ឌ៩.៥ កាលៈទេសៈខាងក្រោម អាចចង្អុលបង្ហាញថាអង្គភាពមួយគ្រប់គ្រងអង្គភាពគោលបំណងពិសេស (នេះមិនមែនជាបញ្ជីពិស្តារអស់សេចក្តីទេ)៖

(ក) សកម្មភាពរបស់អង្គភាពគោលបំណងពិសេស ត្រូវបានធ្វើឡើងក្នុងនាមអង្គភាពនោះ ស្របតាមសេចក្តីត្រូវការជាក់លាក់នៃអាជីវកម្មរបស់អង្គភាពនោះ។

(ខ) អង្គភាពមានអំណាចសម្រេចចុងក្រោយលើសកម្មភាពរបស់អង្គភាពគោលបំណងពិសេសនោះ ទោះបីជាការសម្រេចចិត្តប្រចាំថ្ងៃត្រូវបានផ្ទេរឱ្យអង្គភាពគោលបំណងពិសេសក៏ដោយ។

(គ) អង្គភាពមានសិទ្ធិទទួលបាននូវផលប្រយោជន៍ភាគច្រើននៃអង្គភាពគោលបំណងពិសេស ដូចនេះអាចនឹងប្រឈមនឹងហានិភ័យចៃដន្យពីសកម្មភាពរបស់អង្គភាពគោលបំណងពិសេស ឬ

(ឃ) អង្គភាពរក្សាទុកនូវហានិភ័យសំណល់ឬកម្មសិទ្ធិភាគច្រើន ដែលទាក់ទិននឹងអង្គភាពគោលបំណងពិសេស ឬទ្រព្យសកម្មរបស់អង្គភាពនោះ។

៩.១២ កថាខណ្ឌ ៩.១០ និង ៩.១១ មិនអនុវត្តចំពោះផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ ឬផែនការអត្ថប្រយោជន៍និយោជិតរយៈពេលវែងដទៃ ដែលអនុវត្តតាមផ្នែកទី២៨ ស្តីពីអត្ថប្រយោជន៍និយោជិតនោះទេ។

# នីតិវិធីក្នុងការបូករួម

៩.១៣ របាយការណ៍ហិរញ្ញវត្ថុរួម បង្ហាញព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមជាអង្គភាពសេដ្ឋកិច្ចតែមួយ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម អង្គភាពត្រូវ៖

(ក) រួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេនិងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមេ តាមបន្ទាត់មួយទៅបន្ទាត់មួយទៀត ដោយបូកបញ្ចូលគ្នាបណ្តាធាតុស្រដៀងនៃទ្រព្យសកម្ម បំណុល មូលធន ចំណូល និងចំណាយ។

(ខ) លុបចោលតម្លៃយោងនៃការវិនិយោគរបស់ក្រុមហ៊ុនមេ ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗ និងភាគចំណែកមូលធននៃក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗរបស់ក្រុមហ៊ុនមេ។

(គ) វាស់វែង និងបង្ហាញភាគកម្មមិនគ្រប់គ្រង នៅក្នុងចំណេញ ឬខាតនៃក្រុមហ៊ុនបុត្រសម្ព័ន្ធនានាដែលបានបូករួម សម្រាប់ការិយបរិច្ឆេទរាយការណ៍ ដាច់ដោយឡែកពីភាគកម្មរបស់ម្ចាស់នៃក្រុមហ៊ុនមេ។

(ឃ) វាស់វែងនិងបង្ហាញភាគកម្មមិនគ្រប់គ្រង នៅក្នុងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានបូករួមនានា ដាច់ដោយឡែកពីមូលធនរបស់ម្ចាស់ភាគហ៊ុនក្រុមហ៊ុនមេ ដែលមានក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងនោះ។ ភាគកម្មមិនគ្រប់គ្រងនៅក្នុងទ្រព្យសកម្មសុទ្ធរួមមាន៖

១) ចំនួនទឹកប្រាក់នៃភាគកម្មមិនគ្រប់គ្រងនាកាលបរិច្ឆេទនៃការរួមបញ្ចូលគ្នាពីដើមទី ដោយធ្វើការគណនាស្របតាម ផ្នែកទី១៩ ស្តីពីការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម និង

២) ចំណែកនៃការប្រែប្រួលក្នុងមូលធនរបស់ភាគកម្មមិនគ្រប់គ្រង ចាប់តាំងពីកាលបរិច្ឆេទការបូករួម។

៩.១៤ សមាមាត្រនៃចំណេញឬខាត និងការប្រែប្រួលលើមូលធន ដែលត្រូវផ្តល់ដល់ម្ចាស់របស់ក្រុមហ៊ុនមេ និងដល់ភាគកម្មមិនគ្រប់គ្រង ត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាននៃភាគកម្មកម្មសិទ្ធិដែលមានស្រាប់ និងមិនឆ្លុះបញ្ចាំងអំពីការអនុវត្ត ឬការបំប្លែងនៃសិទ្ធិទិញភាគហ៊ុនពិសេស ឬឧបករណ៍អាចបំប្លែងបាននោះទេ។

## សមតុល្យ និងប្រតិបត្តិការទៅមកផ្ទៃក្នុងរបស់ក្រុម

៩.១៥ សមតុល្យ និងប្រតិបត្តិការទៅមកផ្ទៃក្នុងរបស់ក្រុម រួមបញ្ចូលចំណូល ចំណាយនិងភាគលាភ ត្រូវលុបចោលទាំងស្រុង។ ចំណេញនិងខាតដែលកើតឡើងពីប្រតិបត្តិការទៅមកផ្ទៃក្នុងរបស់ក្រុម ដែលត្រូវបានទទួលស្គាល់ក្នុងទ្រព្យសកម្ម ដូចជា សន្និធិ និង ទ្រព្យ រោងចក្រនិងបរិក្ខារ ត្រូវលុបចោលទាំងស្រុង។ ការខាតផ្ទៃក្នុងក្រុមអាចបង្ហាញនូវការថយចុះតម្លៃដែលតម្រូវឱ្យមានការទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម (សូមមើលផ្នែកទី២៧ ស្តីពីការថយចុះតម្លៃនៃទ្រព្យសកម្ម)។ ផ្នែកទី២៩ ស្តីពីពន្ធលើប្រាក់ចំណូលអនុវត្តចំពោះភាពខុសគ្នាបណ្តោះអាសន្នដែលកើតឡើងពីការលុបចោលនូវចំណេញនិងខាតដែលបណ្តាលកពីប្រតិបត្តិការទៅមកផ្ទៃក្នុង។

## កាលបរិច្ឆេទរាយការណ៍ឯកសណ្ឋាន

៩.១៦ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ដែលបានប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ត្រូវតែរៀបចំនាកាលបរិច្ឆេទរាយការណ៍ដូចគ្នា លើកលែងតែមិនអាចធ្វើទៅរួច។ ប្រសិនបើមិនអាចធ្វើទៅរួច ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅកាលបរិច្ឆេទរាយការណ៍ដូចគ្នា ជាមួយក្រុមហ៊ុនមេ ក្រុមហ៊ុនមេត្រូវរួមបញ្ចូលព័ត៌មានហិរញ្ញវត្ថុ របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុថ្មីៗបំផុតរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានកែតម្រូវសម្រាប់ឥទ្ធិពលនៃប្រតិបត្តិការ ឬហេតុការណ៍ធំៗ ដែលកើតឡើងចន្លោះកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ និងកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុរួម។

## គោលនយោបាយគណនេយ្យឯកសណ្ឋាន

៩.១៧ របាយការណ៍ហិរញ្ញវត្ថុរួម ត្រូវតែបានរៀបចំដោយប្រើគោលនយោបាយគណនេយ្យឯកសណ្ឋាន សម្រាប់ប្រតិបត្តិការស្រដៀង និងព្រឹត្តិការណ៍ផ្សេងទៀត និងលក្ខខណ្ឌដែលមាននៅក្នុងកាលៈទេសៈស្រដៀងគ្នា។ ប្រសិនបើសមាជិកនៃក្រុមនោះប្រើគោលនយោបាយគណនេយ្យផ្សេងពីគោលនយោបាយគណនេយ្យដែលបានទទួលយកនៅក្នុង

របាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់ប្រតិបត្តិការនិងព្រឹត្តិការណ៍ស្រដៀងនានាក្នុងកាលៈទេសៈស្រដៀង ការកែតម្រូវសមរម្យ ត្រូវបានធ្វើឡើងចំពោះរបាយការណ៍ហិរញ្ញវត្ថុក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមនោះ។

## ការទិញ និងការបញ្ចេញចោលនូវក្រុមហ៊ុនបុត្រសម្ព័ន្ធ

៩.១៨ ចំណូល និងចំណាយរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធមួយ ត្រូវបានរួមបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ដោយគិតចាប់តាំងពីកាលបរិច្ឆេទទិញ រហូតដល់កាលបរិច្ឆេទដែលក្រុមហ៊ុនមេលែងគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ។ នៅពេលដែលក្រុមហ៊ុនមេលែងគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ ភាពខុសគ្នារវាងប្រាក់ទទួលបានពីការបញ្ចេញចោលនូវក្រុមហ៊ុនបុត្រសម្ព័ន្ធ ព្រមទាំងតម្លៃយោងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនាកាលបរិច្ឆេទដែលការគ្រប់គ្រងនោះត្រូវបាត់បង់ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៅក្នុងរបាយការណ៍ចំណូលពេញលេញ (ឬរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ) ជាចំណេញ ឬខាតពីការបញ្ចេញចោលក្រុមហ៊ុនបុត្រសម្ព័ន្ធ។ បរិមាណបង្គរនៃភាពខុសគ្នានៃអត្រាប្តូរប្រាក់ដែលពាក់ព័ន្ធនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស ដែលទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ ស្របតាមផ្នែកទី៣០ ស្តីពីការបកប្រែរូបិយប័ណ្ណបរទេស មិនត្រូវចាត់ថ្នាក់ឡើងវិញជាចំណេញ ឬខាត លើការបញ្ចេញចោលក្រុមហ៊ុនបុត្រសម្ព័ន្ធទេ។

៩.១៩ ប្រសិនបើអង្គភាពមួយលែងជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ប៉ុន្តែវិនិយោគិន (អង្គភាពមេពីមុន) នៅតែបន្តរក្សាការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធពីមុននោះ ការវិនិយោគនោះត្រូវធ្វើគណនេយ្យកម្មជាទ្រព្យសកម្មហិរញ្ញវត្ថុ ស្របតាមផ្នែកទី១១ ឬផ្នែកទី១២ ស្តីពី បញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ ចាប់ពីកាលបរិច្ឆេទដែលអង្គភាពនោះលែងជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឱ្យតែថាអង្គភាពនោះមិនក្លាយជាក្រុមហ៊ុនញាតិសម្ព័ន្ធនោះទេ (ករណីនេះអនុវត្តផ្នែកទី១៤ ស្តីពីការនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ) ឬអង្គភាពគ្រប់គ្រងរួមគ្នា (ករណីនេះអនុវត្តផ្នែកទី១៥ ស្តីពីការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន)។ តម្លៃយោងនៃការវិនិយោគនាកាលបរិច្ឆេទដែលអង្គភាពលែងជាក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានចាត់ទុកជាថ្លៃដើមនៃការវាស់វែងដំបូងលើទ្រព្យសកម្មហិរញ្ញវត្ថុ។

## ភាគកម្មមិនគ្រប់គ្រងនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

៩.២០ អង្គភាពមួយត្រូវបង្ហាញអំពីភាគកម្មមិនគ្រប់គ្រង នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមនៅក្នុងផ្នែក មូលធនដាច់ដោយឡែកពីមូលធនរបស់ម្ចាស់នៃក្រុមហ៊ុនមេ តាមការតម្រូវដោយកថាខណ្ឌ ៤.២(ថ)។

៩.២១ អង្គភាពមួយត្រូវលាតត្រដាងភាគកម្មមិនគ្រប់គ្រងនៅក្នុងចំណេញ ឬខាតរបស់ក្រុម ដាច់ដោយឡែកនៅក្នុងរបាយការណ៍ចំណូលពេញលេញ តាមការតម្រូវដោយកថាខណ្ឌ៥.៦ (ឬនៅក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ តាមការតម្រូវដោយកថាខណ្ឌ ៥.៧)។

៩.២២ ចំណេញ ឬខាត និងសមាសធាតុនីមួយៗនៃចំណូលលម្អិតផ្សេងៗ ត្រូវបានចាត់ទុកជារបស់ម្ចាស់នៃក្រុមហ៊ុនមេ និងនៃភាគកម្មមិនគ្រប់គ្រង។ ចំណូលពេញលេញសរុប ត្រូវបានចាត់ទុកជារបស់ម្ចាស់នៃក្រុមហ៊ុនមេនិងនៃភាគកម្មមិនគ្រប់គ្រង ទោះបីនេះធ្វើឱ្យភាគកម្មមិនគ្រប់គ្រងមានសមតុល្យអវិជ្ជមានក៏ដោយ។

## ការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម

៩.២៣ ការលាតត្រដាងដូចខាងក្រោម ត្រូវធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម៖

(ក) អង្គហេតុដែលរបាយការណ៍ គឺជារបាយការណ៍ហិរញ្ញវត្ថុរួម។

(ខ) មូលដ្ឋាននៃការសន្និដ្ឋានថាមានការគ្រប់គ្រង នៅពេលដែលក្រុមហ៊ុនមេមិនមានអំណាចបោះឆ្នោត លើសពីពាក់កណ្ដាល ដោយផ្ទាល់ឬដោយប្រយោលតាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ។

(គ) ភាពខុសគ្នាណាមួយនៃកាលបរិច្ឆេទរាយការណ៍របស់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ និង

ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនដែលបានប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និង

(ឃ) ចរិកលក្ខណៈនិងវិសាលភាពនៃការដាក់កម្រិតសំខាន់ៗ (ឧទាហរណ៍ កើតឡើងដោយសារ កិច្ចសន្យាខ្ចីប្រាក់ ឬការតម្រូវត្រួតពិនិត្យ) លើលទ្ធភាពរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដើម្បីផ្ទេរថវិកាទៅឱ្យក្រុមហ៊ុនមេក្រោមទម្រង់ភាគលាភជាសាច់ប្រាក់ឬដើម្បីសងប្រាក់កម្ចី។

៩.២៣ក ក្រៅពីការតម្រូវឱ្យលាតត្រដាងនៅក្នុងផ្នែកទី១១ អង្គភាពមេត្រូវលាតត្រដាងតម្លៃយោង នៃការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិនត្រូវបានរួមបញ្ចូល (សូមមើលកថាខណ្ឌ៩.៣ក-៩.៣គ) នៅកាលបរិច្ឆេទរាយការណ៍ ជាតួលេខសរុប នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬក្នុងកំណត់សម្គាល់។

## របាយការណ៍ហិរញ្ញវត្ថុដោយឡែក

### ការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុដោយឡែក

៩.២៤ ស្ដង់ដារនេះ មិនតម្រូវឱ្យធ្វើការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុដោយឡែក សម្រាប់អង្គភាពមេ ឬសម្រាប់ក្រុមហ៊ុនបុត្រសម្ព័ន្ធមួយៗនោះទេ។

៩.២៥ របាយការណ៍ហិរញ្ញវត្ថុដោយឡែក គឺជាបណ្ដុំទី២ នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបង្ហាញដោយអង្គភាពមួយ បន្ថែមលើរបាយការណ៍ណាមួយខាងក្រោមនេះ៖

(ក) របាយការណ៍ហិរញ្ញវត្ថុរួម ដែលរៀបចំដោយក្រុមហ៊ុនមេ

(ខ) របាយការណ៍ហិរញ្ញវត្ថុ ដែលរៀបចំដោយក្រុមហ៊ុនមេ ដែលក្រុមហ៊ុនមេនោះត្រូវបានលើកលែងពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដោយយោងតាមកថាខណ្ឌ៩.៣គ ឬ

(គ) របាយការណ៍ហិរញ្ញវត្ថុដែលរៀបចំដោយ អង្គភាពមួយដែលមិនមែនជាក្រុមហ៊ុនមេ ប៉ុន្តែជាវិនិយោគិននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធមួយ ឬមានភាគកម្មជាអ្នករួមទុននៅក្នុង ក្រុមហ៊ុនរួមទុន។

### ការជ្រើសរើសគោលនយោបាយគណនេយ្យ

៩.២៦ នៅពេលដែលក្រុមហ៊ុនមេ វិនិយោគិននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធមួយ ឬអ្នករួមទុនដែលមានភាគកម្មនៅក្នុងអង្គភាពគ្រប់គ្រងរួមគ្នា រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ហើយបានពិពណ៌នាថា របាយការណ៍ទាំងនោះស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូច និងមធ្យម របាយការណ៍ទាំងនោះ

ត្រូវតែអនុលោមតាមរាល់ការតម្រូវនានានៃស្តង់ដារនេះ លើកលែងតែករណីខាងក្រោម។ អង្គភាពត្រូវអនុវត្តយកគោលនយោបាយគណនេយ្យមួយ សម្រាប់ការវិនិយោគនានារបស់អង្គភាពនេះ នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ និងអង្គភាពគ្រប់គ្រងរួមគ្នា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ខ្លួន តាម៖

(ក) ថ្លៃដើម ដកការថយចុះតម្លៃ

(ខ) តម្លៃសមស្រប ហើយការប្រែប្រួលតម្លៃសមស្របត្រូវបានទទួលស្គាល់នៅក្នុងចំណេញឬខាត ឬ

(គ) ការប្រើប្រាស់វិធីសាស្ត្រមូលធន ដោយគោរពតាមនីតិវិធីនៅក្នុងកថាខណ្ឌ១៤.៨។

## ការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក

៩.២៧ នៅពេលដែលក្រុមហ៊ុនមេ វិនិយោគិននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ឬអ្នករួមទុនដែល មានភាគកម្មនៅក្នុងអង្គភាពគ្រប់គ្រងរួមគ្នារៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឡែក របាយការណ៍ហិរញ្ញវត្ថុដោយឡែកទាំងនោះ ត្រូវតែលាតត្រដាង ៖

(ក) ថារបាយការណ៍នោះជារបាយការណ៍ហិរញ្ញវត្ថុដោយឡែក និង

(ខ) អំពីការពិពណ៌នានូវវិធីសាស្ត្រ ដែលបានប្រើសម្រាប់គណនេយ្យកម្មការវិនិយោគនានានៅក្នុង ក្រុមហ៊ុនបុត្រសម្ព័ន្ធ អង្គភាពគ្រប់គ្រងរួមគ្នានិងក្រុមហ៊ុនញាតិសម្ព័ន្ធ ហើយត្រូវកំណត់អត្តសញ្ញាណឱ្យច្បាស់អំពីរបាយការណ៍ហិរញ្ញវត្ថុរួម ឬរបាយការណ៍ហិរញ្ញវត្ថុចម្បងដទៃដែលមានការពាក់ព័ន្ធ។

# របាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា

៩.២៨ របាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា គឺជាបណ្តុំតែមួយនៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពពីរឬលើសពីពីរ ក្រោមការគ្រប់គ្រងរួម (ដូចបានអធិប្បាយក្នុងកថាខណ្ឌ១៩.២(ក))។ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ មិនតម្រូវឱ្យរៀបចំរបាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នាទេ។

៩.២៩ ប្រសិនបើវិនិយោគិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា និងពិពណ៌នាថារបាយការណ៍ទាំងនោះអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម របាយការណ៍ទាំងនោះត្រូវតែអនុលោមតាមរាល់ការតម្រូវនានានៅក្នុងស្តង់ដារនេះ។ ប្រតិបត្តិការនិងសមតុល្យអន្តរក្រុមហ៊ុនត្រូវលុបចោល ចំណេញឬខាតដែលកើតពីប្រតិបត្តិការអន្តរក្រុមហ៊ុន ដែលបានទទួលស្គាល់ក្នុងទ្រព្យសកម្មដូចជាសន្និធិ និងទ្រព្យ រោងចក្រ និងបរិក្ខារត្រូវលុបចោល របាយការណ៍ហិរញ្ញវត្ថុនៃអង្គភា ពដែលបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នាត្រូវតែរៀបចំឡើងនាកាលបរិច្ឆេទរាយការណ៍ដូចគ្នា វៀរលែងតែ ការធ្វើបែបនេះមិនអាចធ្វើទៅរួច ហើយគោលនយោបាយគណនេយ្យឯកសណ្ឋាន ត្រូវតែអនុវត្តតាម សម្រាប់ប្រតិបត្តិការស្រដៀងគ្នានិងព្រឹត្តិការណ៍ផ្សេងទៀតក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នា។

## ការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា

៩.៣០ របាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា ត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ៖

(ក) អង្គហេតុដែលរបាយការណ៍ហិរញ្ញវត្ថុជារបាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា

(ខ)   ហេតុផលនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា

(គ)   មូលដ្ឋានសម្រាប់កំណត់ថាតើអង្គភាពណាខ្លះដែលបានបញ្ចូលក្នុង របាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា

(ឃ)   មូលដ្ឋាននៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបញ្ចូលគ្នា និង

(ង)   ការលាតត្រដាងអំពីភាគីពាក់ព័ន្ធដែលតម្រូវដោយផ្នែកទី៣៣ ស្តីពីការលាតត្រដាងភាគីពាក់ព័ន្ធ។

# ផ្នែកទី ១០
# គោលនយោបាយគណនេយ្យ ការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង

## វិសាលភាពនៃផ្នែកនេះ

១០.១ ផ្នែកនេះផ្តល់នូវគោលការណ៍ណែនាំអំពីការជ្រើសរើស និងការអនុវត្តគោលនយោបាយគណនេយ្យ ដែលប្រើនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ផ្នែកនេះក៏គ្របដណ្តប់ផងដែរអំពីការប្រែប្រួលនានាលើការប៉ាន់ស្មានគណនេយ្យ និងការកែតម្រូវលើកំហុសឆ្គងក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទមុន។

## ការជ្រើសរើស និងការអនុវត្តគោលនយោបាយគណនេយ្យ

១០.២ គោលនយោបាយគណនេយ្យ គឺជាគោលការណ៍ជាក់លាក់ មូលដ្ឋាន ទម្លាប់ វិធាន និងការអនុវត្តនានាដែលអនុវត្តដោយអង្គភាពក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។

១០.៣ ប្រសិនបើស្តង់ដារនេះនិយាយជាពិសេសអំពីប្រតិបត្តិការ ព្រឹត្តិការណ៍ឬស្ថានភាពផ្សេងទៀត អង្គភាពត្រូវអនុវត្តស្តង់ដារនេះ។ ប៉ុន្តែអង្គភាពមិនចាំបាច់ធ្វើតាមតម្រូវការនៅក្នុងស្តង់ដារនេះទេ ប្រសិនបើឥទ្ធិពលនៃការធ្វើបែបនេះនឹងមិនមានលក្ខណៈជាសារវន្ត។

១០.៤ ប្រសិនបើស្តង់ដារនេះមិនបាននិយាយជាពិសេសអំពីប្រតិបត្តិការ ព្រឹត្តិការណ៍ ឬស្ថានភាពផ្សេងទៀតទេ ថ្នាក់គ្រប់គ្រងរបស់អង្គភាពត្រូវប្រើការវិនិច្ឆ័យរបស់ខ្លួនក្នុងការបង្កើតនិងអនុវត្តគោលនយោបាយគណនេយ្យដែលនាំឱ្យមានព័ត៌មានដែល៖

(ក) ពាក់ព័ន្ធនឹងតម្រូវការការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់ និង

(ខ) ជឿទុកចិត្តបាន ដោយសាររបាយការណ៍ហិរញ្ញវត្ថុ ៖

១) បង្ហាញដោយស្មោះត្រង់នូវស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព

២) ឆ្លុះបញ្ចាំងនូវជាតុពិតផ្នែកសេដ្ឋកិច្ចនៃប្រតិបត្តិការ ព្រឹត្តិការណ៍និងស្ថានភាពដទៃទៀត និងមិនគ្រាន់តែជាទម្រង់ច្បាប់នោះទេ

៣) មានលក្ខណៈអព្យាក្រឹត្យ នោះគឺមិនមានលំអៀង

៤) មានលក្ខណៈប្រុងប្រយ័ត្ន និង

៥) មានលក្ខណៈពេញលេញក្នុងទិដ្ឋភាពសារវន្តទាំងអស់។

១០.៥ ក្នុងការវិនិច្ឆ័យដូចបានពិពណ៌នាក្នុងកថាខណ្ឌ ១០. ៤ ថ្នាក់គ្រប់គ្រងត្រូវតែយោងទៅលើ និងពិចារណាអំពីភាពអាចអនុវត្តបាននៃប្រភពតាមលំដាប់ពីធំទៅតូចខាងក្រោម៖

(ក) ការតម្រូវនិងគោលការណ៍ណែនាំនៅក្នុងស្តង់ដារនេះ ក្នុងការដោះស្រាយបញ្ហាស្រដៀងនិងពាក់ព័ន្ធ និង

(ខ) និយមន័យ លក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ និងទស្សនទាននៃការវាស់វែងសម្រាប់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ និងគោលការណ៍សយភាយនៅក្នុងផ្នែកទី២ ស្តីពីទស្សនទាន និងគោលការណ៍ទូទៅ។

១០.៦ ក្នុងការវិនិច្ឆ័យដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ១០. ៤ ថ្នាក់គ្រប់គ្រងក៏អាចពិចារណាលើការតម្រូវនានា និងគោលការណ៍ណែនាំនៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ក្នុងការដោះស្រាយបញ្ហាស្រដៀងនិងពាក់ព័ន្ធ។

## សង្គតិភាពនៃគោលនយោបាយគណនេយ្យ

១០.៧ អង្គភាពមួយត្រូវជ្រើសរើស និងអនុវត្តនូវគោលនយោបាយគណនេយ្យរបស់ខ្លួនប្រកបដោយសង្គតិភាពចំពោះប្រតិបត្តិការស្រដៀង ព្រឹត្តិការណ៍និងស្ថានភាពដទៃទៀត វៀរលែងតែស្តង់ដារនេះតម្រូវ ឬអនុញ្ញាតជាពិសេស ឱ្យធ្វើចំណាត់ប្រភេទសមាសធាតុនានាដែលគោលនយោបាយផ្សេងអាចនឹងស័ក្តិសម។ ប្រសិនបើស្តង់ដារនេះតម្រូវ ឬអនុញ្ញាតការធ្វើចំណាត់ប្រភេទបែបនេះ គោលនយោបាយគណនេយ្យសមរម្យមួយត្រូវបានជ្រើសរើសនិងអនុវត្តប្រកបដោយសង្គតិភាពចំពោះប្រភេទនីមួយៗ។

## ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

១០.៨ អង្គភាពមួយ ត្រូវផ្លាស់ប្តូរគោលនយោបាយគណនេយ្យតែប្រសិនបើការផ្លាស់ប្តូរនោះ៖

(ក) ត្រូវបានតម្រូវឱ្យមានការផ្លាស់ប្តូរតាមស្តង់ដារនេះ ឬ

(ខ) ធ្វើឱ្យរបាយការណ៍ហិរញ្ញវត្ថុ ផ្តល់នូវព័ត៌មានគួរជាទីទុកចិត្ត និងកាន់តែទាក់ទងអំពីឥទ្ធិពលនៃប្រតិបត្តិការ ព្រឹត្តិការណ៍និងស្ថានភាពដទៃលើស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ ឬលំហូរសាច់ប្រាក់របស់អង្គភាព។

១០.៩ ករណីខាងក្រោម មិនមែនជាការផ្លាស់ប្តូរគោនយោបាយគណនេយ្យទេ ៖

(ក) ការអនុវត្តគោលនយោបាយគណនេយ្យសម្រាប់ប្រតិបត្តិការ ព្រឹត្តិការណ៍និងស្ថានភាពដទៃ ដែលមានភាពខុសគ្នាជាសារវន្តនៅនិង ប្រតិបត្តិការ ព្រឹត្តិការណ៍និងស្ថានភាពដទៃ ដែលបានកើតមាននាពេលមុនៗ។

(ខ) ការអនុវត្តគោលនយោបាយគណនេយ្យថ្មីសម្រាប់ប្រតិបត្តិការ ព្រឹត្តិការណ៍និងស្ថានភាពដទៃ ដែលមិនបានកើតមាននាពេលមុនៗ ឬដែលមិនមានភាពជាសារវន្ត។

(គ) ការផ្លាស់ប្តូរទៅកាន់គំរូថ្លៃដើម នៅពេលដែលការវាស់វែងដែលអាចជឿទុកចិត្តបាននៃតម្លៃសមស្រប មិនអាចរកបានតទៅទៀតទេ (ឬផ្ទុយមកវិញ) សម្រាប់ទ្រព្យសកម្មដែលស្តង់ដារនេះតាមដើមឡើយបានតម្រូវ ឬបានអនុញ្ញាត ឱ្យវាស់វែងតាមតម្លៃសមស្រប។

១០.១០ ប្រសិនបើស្តង់ដារនេះអនុញ្ញាតឱ្យធ្វើការជ្រើសរើសចំណាត់ការគណនេយ្យ (រួមបញ្ចូលទាំងមូលដ្ឋាននៃការវាស់វែង) សម្រាប់ប្រតិបត្តិការ ឬព្រឹត្តិការណ៍ឬស្ថានភាពដទៃ ហើយអង្គភាពផ្លាស់ប្តូរនូវជម្រើសពីពេលមុនរបស់ខ្លួន នោះការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ។

១០.១០ក ការអនុវត្តបឋមនូវគោលនយោបាយមួយ ក្នុងការវាយតម្លៃទ្រព្យសកម្មឡើងវិញ ស្របតាមផ្នែកទី១៧ ស្តីពីទ្រព្យ រោងចក្រ និងបរិក្ខារ គឺជាការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ដែលត្រូវដោះស្រាយជាការវាយតម្លៃឡើងវិញ ស្របតាមផ្នែកទី១៧។ ដូច្នេះ ការផ្លាស់ប្តូរពីគំរូថ្លៃដើមទៅជាគំរូការវាយតម្លៃឡើងវិញ សម្រាប់ថ្នាក់នៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវកត់ត្រាជាការអនុវត្តទៅមុខ ជំនួសឱ្យការកត់ត្រាស្របតាមកថាខណ្ឌ១០.១១-១០.១២។

## ការអនុវត្តការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

១០.១១ អង្គភាពមួយ ត្រូវធ្វើគណនេយ្យកម្មសម្រាប់ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យដូចខាងក្រោម ៖

(ក) អង្គភាពមួយ ត្រូវធ្វើគណនេយ្យកម្មសម្រាប់ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ដែលបណ្តាលមកពីការផ្លាស់ប្តូរនៃការតម្រូវនៃស្តង់ដារនេះ ស្របតាមវិធានអន្តរកាល ប្រសិនបើមាន ដែលបញ្ជាក់ច្បាស់នៅក្នុងការកែប្រែនេះ។

(ខ) នៅពេលដែលអង្គភាពបានសម្រេចអនុវត្តតាមស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩ ស្តីពីឧបករណ៍ហិរញ្ញវត្ថុ: ការទទួលស្គាល់និងការវាស់វែង ជំនួសឱ្យការអនុវត្តតាមផ្នែកទី១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និងផ្នែកទី១២ ស្តីពីបញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ ដូចដែលបានអនុញ្ញាតដោយកថាខណ្ឌទី ១១.២ និងការតម្រូវនានានៃស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩ផ្លាស់ប្តូរ អង្គភាពត្រូវធ្វើគណនេយ្យកម្មការផ្លាស់ប្តូរគោលនយោបាយគណនេយ្យនោះ ដោយស្របតាមវិធានអន្តរកាល ប្រសិនបើមាន ដូចដែលបានបញ្ជាក់ច្បាស់នៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩ ដែលបានកែលម្អ និង

(គ) អង្គភាពមួយត្រូវត្រូវធ្វើគណនេយ្យកម្មសម្រាប់ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យផ្សេងទៀតទាំងអស់ដោយអនុវត្តត្រឡប់ក្រោយ (សូមមើលកថាខណ្ឌ ១០.១២)។

## ការអនុវត្តត្រឡប់ក្រោយ

១០.១២ នៅពេលដែលការផ្លាស់ប្តូរគោលនយោបាយគណនេយ្យត្រូវបានអនុវត្តត្រឡប់ក្រោយស្របតាមកថាខណ្ឌ១០.១១ អង្គភាពត្រូវអនុវត្តគោលនយោបាយគណនេយ្យថ្មីនោះចំពោះរាល់ពត៌មានប្រៀបធៀបនានាសម្រាប់ការិយបរិច្ឆេទមុនៗ ដល់កាលបរិច្ឆេទមុនបំផុតដែលធ្វើទៅរួច ហាក់ដូចជាគោលនយោបាយគណនេយ្យថ្មីនោះតែងតែត្រូវបានអនុវត្តកន្លងមក។ នៅពេលដែលមិនអាចធ្វើទៅរួចក្នុងការកំណត់នូវឥទ្ធិពលការិយបរិច្ឆេទនីមួយៗនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យទៅលើព័ត៌មានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទមុនមួយឬច្រើនដែលបានបង្ហាញ អង្គភាពត្រូវអនុវត្តគោលនយោបាយគណនេយ្យថ្មីនោះចំពោះតម្លៃយោងនៃទ្រព្យសកម្មនិងបំណុល នាដើមការិយបរិច្ឆេទមុនបំផុតដែលការអនុវត្តត្រឡប់ក្រោយអាចធ្វើទៅរួច ដែលអាចជាការិយបរិច្ឆេទបច្ចុប្បន្ន ហើយត្រូវធ្វើការកែតម្រូវដែលឆ្លើយតបចំពោះតុល្យការដើមគ្រានៃសមាសធាតុប៉ះពាល់នីមួយៗនៃមូលធនសម្រាប់ការិយបរិច្ឆេទនោះ។

## ការលាតត្រដាងអំពីការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

១០.១៣ នៅពេលដែលវិសោធនកម្មទៅលើស្តង់ដារនេះមានឥទ្ធិពលលើការិយបរិច្ឆេទបច្ចុប្បន្ន ឬការិយបរិច្ឆេទមុនណាមួយ

ឬអាចមានឥទ្ធិពលលើការិយបរិច្ឆេទអនាគត អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម៖

(ក) សារជាតិនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ។

(ខ) សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទមុននីមួយៗដែលបានបង្ហាញ ក្នុងវិសាលភាពជាក់ស្តែងដែលអាចធ្វើទៅរួច បរិមាណនៃការកែតម្រូវសម្រាប់ជាតុបន្ទាត់នីមួយៗដែលប៉ះពាល់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) បរិមាណនៃការកែតម្រូវទាក់ទិននឹងការិយបរិច្ឆេទមុននឹងការិយបរិច្ឆេទដែលបានបង្ហាញទាំងនោះ ទៅតាមវិសាលភាពដែលអាចធ្វើទៅរួច និង

(ឃ) ការពន្យល់ប្រសិនបើមិនអាចធ្វើទៅរួចក្នុងការកំណត់អំពីចំនួនទឹកប្រាក់ដែលត្រូវបានលាតត្រដាងនៅក្នុង (ខ) ឬ (គ) ខាងលើ។

របាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទបន្តបន្ទាប់មិនចាំបាច់ធ្វើសារឡើងវិញម្តងទៀតនូវការលាតត្រដាងទាំងនេះទេ។

១០.១៤ នៅពេលដែលការផ្លាស់ប្តូរដោយស្ម័គ្រចិត្តលើគោលនយោបាយគណនេយ្យមានឥទ្ធិពលលើការិយបរិច្ឆេទ បច្ចុប្បន្ន ឬការិយបរិច្ឆេទមុនណាមួយ អង្គភាពត្រូវធ្វើការលាតត្រដាងដូចខាងក្រោម ៖

(ក) សារជាតិនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

(ខ) ហេតុផលដែលការអនុវត្តគោលនយោបាយគណនេយ្យថ្មី ផ្តល់ព័ត៌មានអាចជឿទុកចិត្តបាន និងកាន់តែពាក់ព័ន្ធ។

(គ) តាមវិសាលភាពដែលអាចធ្វើទៅរួច បរិមាណនៃការកែតម្រូវសម្រាប់ជាតុបន្ទាត់នីមួយៗដែលប៉ះពាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយបង្ហាញដាច់ដោយឡែក៖

១) សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។

២) សម្រាប់ការិយបរិច្ឆេទមុននីមួយៗដែលបានបង្ហាញ និង

៣) សរុបរួមសម្រាប់ការិយបរិច្ឆេទនានា មុនទាំងនោះបានបង្ហាញ។

(ឃ) ការពន្យល់ ប្រសិនបើការកំណត់បរិមាណដែលត្រូវលាតត្រដាងនៅក្នុងចំណុច(គ) មិនអាចធ្វើទៅរួច។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់ មិនចាំបាច់ធ្វើសារឡើងវិញ នូវការលាតត្រដាងទាំងនេះទេ។

## ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ

១០.១៥ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ គឺជាការកែតម្រូវនូវតម្លៃយោងនៃទ្រព្យសកម្ម ឬបំណុលមួយ ឬចំនួនទឹកប្រាក់នៃការប្រើប្រាស់ទ្រព្យសកម្មប្រចាំការិយបរិច្ឆេទ ដែលជាលទ្ធផលនៃការវាយតម្លៃលើស្ថានភាពបច្ចុប្បន្ន និងអត្ថប្រយោជន៍និងកាតព្វកិច្ចនាពេលអនាគតដែលបានរំពឹងទុក ដែលទាក់ទងនឹងទ្រព្យសកម្មនិងបំណុល។ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យកើតមាន ពីព័ត៌មានថ្មី ឬការអភិវឌ្ឍថ្មី ដូច្នេះមិនមែនជាការកែតម្រូវកំហុសឆ្គងនោះទេ។ នៅពេលដែលមានការលំបាកក្នុងការបែងចែកឱ្យដាច់នូវការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ពីការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យការផ្លាស់ប្តូរត្រូវបានចាត់ទុកជាការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ។

១០.១៦ អង្គភាពមួយត្រូវទទួលស្គាល់ឥទ្ធិពលនៃការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ លើកលែងតែការផ្លាស់ប្តូរដែលអនុវត្តតាមកថាខណ្ឌ ១០.១៧ អនុវត្តទៅមុខដោយរាប់បញ្ចូលនៅក្នុងចំណេញ ឬខាត ក្នុង៖

(ក) ការិយបរិច្ឆេទនៃការផ្លាស់ប្តូរ ប្រសិនបើការផ្លាស់ប្តូរប៉ះពាល់តែការិយបរិច្ឆេទនោះតែប៉ុណ្ណោះ ឬ

(ខ) ការិយបរិច្ឆេទនៃការផ្លាស់ប្តូរ និងការិយបរិច្ឆេទអនាគត ប្រសិនបើការផ្លាស់ប្តូរប៉ះពាល់ដល់ការិយបរិច្ឆេទទាំងពីរ។

១០.១៧ ប្រសិនបើការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យធ្វើឱ្យទ្រព្យសកម្មនិងបំណុលប្រែប្រួល ឬពាក់ព័ន្ធនឹងធាតុនៃមូលធន អង្គភាពត្រូវទទួលស្គាល់នូវការផ្លាស់ប្តូរនោះ ដោយធ្វើការកែតម្រូវនូវតម្លៃយោងនៃធាតុទ្រព្យសកម្ម បំណុល ឬមូលធនដែលពាក់ព័ន្ធនោះ ក្នុងការិយបរិច្ឆេទដែលមានការផ្លាស់ប្តូរ។

## ការលាតត្រដាងនូវការផ្លាស់ប្តូរការប៉ាន់ស្មាន

១០.១៨ អង្គភាពមួយត្រូវលាតត្រដាងអំពីសារជាតិនៃការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យណាមួយ និងឥទ្ធិពលនៃការផ្លាស់ប្តូរនោះទៅលើទ្រព្យសកម្ម បំណុល ចំណូល និងចំណាយសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ ប្រសិនបើអាចធ្វើទៅរួចនូវការដែលអង្គភាពប៉ាន់ស្មាននូវឥទ្ធិពលនៃការផ្លាស់ប្តូរសម្រាប់ការិយបរិច្ឆេទមួយ ឬច្រើននាពេលអនាគត អង្គភាពត្រូវលាតត្រដាងការប៉ាន់ស្មានទាំងនោះ។

# ការកែតម្រូវនូវកំហុសឆ្គងការិយបរិច្ឆេទមុនៗ

១០.១៩ កំហុសឆ្គងការិយបរិច្ឆេទមុនៗ គឺជាការមិនបានធ្វើ និង ការថ្លែងខុសនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពនាការិយបរិច្ឆេទមុនៗមួយ ឬច្រើន ដែលកើតចេញពីការខកខានមិនបានប្រើ ឬការប្រើខុសនូវព័ត៌មានដែលគួរជាទីទុកចិត្តបាន ដែល៖

(ក) អាចរកបាននៅពេលដែលរបាយណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទទាំងនោះត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ និង

(ខ) អាចរំពឹងទាំងសមហេតុសមផលថាបានទទួលហើយ និងបានធ្វើការពិចារណាហើយក្នុងការរៀបចំ និងបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ។

១០.២០ បណ្តាកំហុសឆ្គងបែបនេះ រួមមានឥទ្ធិពលនៃកំហុសការគណនា កំហុសពីការអនុវត្តគោលនយោបាយគណនេយ្យ ការធ្វេសប្រហែសឬការបកស្រាយខុសនូវហេតុការណ៍និងការបន្លំ។

១០.២១ តាមដែលអាចធ្វើទៅរួច អង្គភាពត្រូវកែតម្រូវកំហុសសារវន្តការិយបរិច្ឆេទមុនៗ ដោយអនុវត្តត្រឡប់ក្រោយ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទីមួយដែលបានអនុញ្ញាតបោះផ្សាយក្រោយការរកឃើញកំហុសឆ្គង ដោយ៖

(ក) ថ្លែងឡើងវិញនូវចំនួនទឹកប្រាក់ប្រៀបធៀប សម្រាប់ការិយបរិច្ឆេទមុនៗដែលបានបង្ហាញ ដែលក្នុងនោះកើតមានកំហុសឆ្គងនោះ ឬ

(ខ) ប្រសិនបើកំហុសឆ្គងបានកើតឡើងមុននឹងការិយបរិច្ឆេទមុនៗដែលមុនបង្អស់បានបង្ហាញ នោះថ្លែងឡើងវិញនូវសមតុល្យដើមគ្រានៃទ្រព្យសកម្ម បំណុល និងមូលធន សម្រាប់ការិយបរិច្ឆេទមុនបង្អស់បានបង្ហាញ។

១០.២២ នៅពេលដែលមិនអាចធ្វើទៅរួច នូវការដែលកំណត់ឥទ្ធិពលនៃកំហុសឆ្គងទៅលើព័ត៌មានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទមុនដែលបានបង្ហាញមួយឬច្រើន អង្គភាពត្រូវថ្លែងឡើងវិញនូវសមតុល្យដើមគ្រានៃទ្រព្យសកម្ម បំណុលនិងមូលធនសម្រាប់ការិយបរិច្ឆេទមុនបង្អស់ តាមដែលការថ្លែងឡើងវិញត្រឡប់ក្រោយអាចធ្វើទៅរួច (គឺប្រហែលជាការិយបរិច្ឆេទបច្ចុប្បន្ន)។

## ការលាតត្រដាងកំហុសឆ្គងការិយបរិច្ឆេទមុន

១០.២៣ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោមនូវកំហុសឆ្គងការិយបរិច្ឆេទមុនៈ

(ក) សារជាតិនៃកំហុសឆ្គងការិយបរិច្ឆេទមុន

(ខ) សម្រាប់ការិយបរិច្ឆេទមុនដែលបានបង្ហាញនីមួយៗ តាមដែលអាចធ្វើទៅរួច ចំនួនទឹកប្រាក់នៃការកែតម្រូវសម្រាប់ជាតុបន្ទាត់របាយការណ៍ហិរញ្ញវត្ថុនីមួយៗដែលបានប៉ះពាល់

(គ) តាមដែលអាចធ្វើទៅរួច ចំនួនទឹកប្រាក់នៃការកែតម្រូវនៅដើមគ្រានៃការិយបរិច្ឆេទមុនដែលមុនបង្អស់បានបង្ហាញ និង

(ឃ) ការពន្យល់ ប្រសិនបើមិនអាចធ្វើទៅរួច នូវការដែលកំណត់ចំនួនទឹកប្រាក់ដើម្បីលាតត្រដាងក្នុង(ខ)ឬ(គ)។ របាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទបន្តបន្ទាប់មិនចាំបាច់ធ្វើសារឡើងវិញនូវការលាតត្រដាងទាំងនេះទេ។

# ផ្នែកទី ១១
# ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន

## វិសាលភាពនៃផ្នែកទី ១១ និង ១២

### ១១.១ ផ្នែកទី ១១ និងផ្នែកទី១២ ស្តីពីបញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ

មានប្រធានបទរួមទាក់ទងនឹងការទទួលស្គាល់ ការឈប់ទទួលស្គាល់ ការវាស់វែង និងការលាតត្រដាងអំពីឧបករណ៍ហិរញ្ញវត្ថុ (ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ)។ ផ្នែកទី១១ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ហើយមានការពាក់ព័ន្ធជាមួយអង្គភាពទាំងអស់។ ផ្នែកទី១២ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុ និងប្រតិបត្តិការដទៃទៀតដែលស្មុគស្មាញជាង។ ប្រសិនបើអង្គភាពមួយ មានតែប្រតិបត្តិការឧបករណ៍ ហិរញ្ញវត្ថុមូលដ្ឋាន នោះផ្នែកទី១២ មិនត្រូវបានអនុវត្តនោះទេ។ ប៉ុន្តែ ទោះបីជាអង្គភាពដែលមានតែឧបករណ៍ហិរញ្ញវត្ថុ មូលដ្ឋាន ត្រូវពិចារណាលើវិសាលភាពនៃផ្នែកទី១២ ដើម្បីជានាថា អង្គភាពរបស់ខ្លួន ត្រូវបានលើកលែង។

## ការជ្រើសរើសគោលនយោបាយគណនេយ្យ

១១.២ អង្គភាពមួយត្រូវជ្រើសរើសប្រើប្រាស់មួយក្នុងចំណោមពីរខាងក្រោម៖

(ក) ការតម្រូវដែលមានចែងនៅក្នុងទាំងផ្នែកទី ១១ និងផ្នែកទី ១២ ទាំងស្រុង ឬ

(ខ) ការតម្រូវនៃការទទួលស្គាល់ និងការវាស់វែង នៃស្តង់ដារគណនេយ្យអន្តរជាតិលេខ ៣៩ ស្តីពីឧបករណ៍ហិរញ្ញវត្ថុ៖ ការទទួលស្គាល់និងការវាស់វែង[១] និងការតម្រូវនៃការលាតត្រដាងនៃផ្នែកទី ១១ និង ១២ ដើម្បីធ្វើគណនេយ្យកម្មសម្រាប់ឧបករណ៍ហិរញ្ញវត្ថុទាំងអស់របស់ខ្លួន។ ជម្រើសរបស់អង្គភាពមួយថាតើ (ក) ឬ (ខ) គឺជាការជ្រើសរើសគោលនយោបាយគណនេយ្យមួយ។ កថាខណ្ឌ ១០.៨-១០.១៤ មាន ការតម្រូវនានាដើម្បីកំណត់ថាតើពេលណាដែលការផ្លាស់ប្តូរគោលនយោបាយគណនេយ្យមានភាពសមរម្យ ការផ្លាស់ប្តូរបែបនេះត្រូវធ្វើគណនេយ្យកម្មយ៉ាងដូចម្តេច និងព័ត៌មានអ្វីខ្លះគួរត្រូវបានលាតត្រដាងអំពីការផ្លាស់ប្តូរនោះ។

---

១ លុះត្រាតែស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩ ត្រូវបានជំនួសដោយស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ៩ ស្តីពីឧបករណ៍ហិរញ្ញវត្ថុ អង្គភាពមួយត្រូវអនុវត្តកំណែស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩ ដែលមានប្រសិទ្ធភាព នៅកាលបរិច្ឆេទរាយការណ៍របស់អង្គភាពនោះ ដោយយោងលើឯកសារបោះពុម្ពផ្សាយ នៃស្តង់ដាររបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ដែលមានចំណងជើងថា ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ IFRS® ត្រូវបានរួមបញ្ចូលគ្នា ដោយគ្មានការអនុវត្តមុនពេល (សៀវភៅពណ៌ខៀវ)។ នៅពេលដែលស្តង់ដារគណនេយ្យ អន្តរជាតិលេខ៣៩ ត្រូវបានជំនួសដោយស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ៩ អង្គភាពមួយត្រូវអនុវត្ត កំណែស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩ ដែលបានអនុវត្តភ្លាមៗ មុនពេលដែលស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិលេខ៩ ជំនួសស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩។ សេចក្តីចម្លងមួយនៃកំណែនោះ នឹងត្រូវបានរក្សាទុកជា ឯកសារយោងនៅលើគេហទំព័រអង្គភាពធុនតូច និងមធ្យមនៃវិបសាយរបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (http://go.ifrs.org/IFRSforSMEs)។

# សេចក្តីផ្តើមអំពីផ្នែកទី ១១

១១.៣ ឧបករណ៍ហិរញ្ញវត្ថុមួយគឺជាកិច្ចសន្យាមួយដែលបង្កើតជាទ្រព្យសកម្មហិរញ្ញវត្ថុមួយរបស់អង្គភាពមួយ និងបំណុលហិរញ្ញវត្ថុ ឬឧបករណ៍មូលធនរបស់អង្គភាពមួយផ្សេងទៀត។

១១.៤ ផ្នែកទី១១ តម្រូវឱ្យប្រើគំរូថ្លៃដើមដករំលស់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋានទាំងអស់ លើកលែងតែ ការវិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចបំប្លែងបាន និងភាគហ៊ុនធម្មតាឬបុរិមាដែលមិនអាច លក់វិញបាន ដែលត្រូវបានជួញដូរជាសាធារណៈ ឬដែលតម្លៃសមស្របរបស់ភាគហ៊ុនទាំងនោះ អាចត្រូវបានវាស់វែង ប្រកបដោយការជឿទុកចិត្តបានតាមវិធីផ្សេង ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ។

១១.៥ ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋានដែលស្ថិតក្នុងវិសាលភាពនៃផ្នែកទី ១១ គឺជាឧបករណ៍ហិរញ្ញវត្ថុដែលបំពេញ តាមលក្ខខណ្ឌក្នុងកថាខណ្ឌ ១១.៨។ ឧទាហរណ៍នៃឧបករណ៍ហិរញ្ញវត្ថុដែលជាធម្មតាបំពេញបានតាមលក្ខខណ្ឌទាំងនោះរួមមាន ៖

(ក) សាច់ប្រាក់

(ខ) ប្រាក់បញ្ញើដកបានតាមតម្រូវការ និងប្រាក់បញ្ញើមានកាលកំណត់ នៅពេលអង្គភាពគឺជាអ្នកដាក់ប្រាក់បញ្ញើ ឧទាហរណ៍គណនីធនាគារ

(គ) ក្រដាសពាណិជ្ជកម្ម និងរូបិយណត្តិពាណិជ្ជកម្មដែលរក្សាទុក

(ឃ) គណនី កំណត់សន្យា និងកម្ចីដែលត្រូវទទួលនិងត្រូវបង់

(ង) សញ្ញាបណ្ណ និងឧបករណ៍បំណុលប្រហាក់ប្រហែល

(ច) ការវិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចបំប្លែងបាន និងភាគហ៊ុនធម្មតានិងបុរិមាដែលមិនអាចលក់វិញបាន និង

(ឆ) ការសន្យាទទួលកម្ចី ប្រសិនបើការសន្យានោះមិនអាចទូទាត់ដាច់ស្រេចជាសាច់ប្រាក់។

១១.៦ ឧទាហរណ៍នៃឧបករណ៍ហិរញ្ញវត្ថុ ដែលជាធម្មតាមិនបំពេញបានតាមលក្ខខណ្ឌក្នុងកថាខណ្ឌ ១១.៨ និងដូច្នេះហើយស្ថិតក្នុងវិសាលភាពនៃផ្នែកទី ១២ រួមមាន៖

(ក) មូលបត្របំណុលដែលមានទ្រព្យធានា ដូចជា មូលបត្រអចលនទ្រព្យមានវត្ថុបញ្ចាំ កិច្ចព្រមព្រៀងទិញត្រឡប់វិញ និង កញ្ចប់បានធ្វើមូលបត្រកម្មនៃគណនីត្រូវទទួល

(ខ) សិទ្ធិទិញលក់ក្នុងគ្រានិងតម្លៃកំណត់ សិទ្ធិ ប័ណ្ណធានា កិច្ចសន្យាអនាគត កិច្ចសន្យាទិញទុកជាមុន និង កិច្ចសន្យាដោះដូរអត្រាការប្រាក់ដែលអាចត្រូវបានទូទាត់ជាសាច់ប្រាក់ ឬដោយដោះដូរឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត

(គ) ឧបករណ៍ហិរញ្ញវត្ថុដែលមានគុណវុឌ្ឍិ និងត្រូវបានកំណត់ជាឧបករណ៍ទប់ស្កាត់ហានិភ័យ ដោយអនុលោមតាមការតម្រូវដែលមានក្នុងផ្នែកទី ១២

(ឃ) ការសន្យាផ្តល់ប្រាក់កម្ចីដល់អង្គភាពមួយផ្សេងទៀត និង

(ង) ការសន្យាទទួលកម្ចី ប្រសិនបើការសន្យានោះត្រូវបានទូទាត់ដាច់ស្រេចជាសាច់ប្រាក់។

## វិសាលភាពនៃផ្នែកទី ១១

១១.៧ ផ្នែកទី១១ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុទាំងអស់ដែលបំពេញបានតាមលក្ខខណ្ឌនៃកថាខណ្ឌ ១១.៨ លើកលែង តែឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

(ក) ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ដែលត្រូវបានធ្វើគណនេយ្យកម្មដោយស្របតាមផ្នែកទី៩ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ផ្នែកទី១៤ ស្តីពីការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ឬផ្នែកទី១៥ ស្តីពីការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន។

(ខ) ឧបករណ៍ហិរញ្ញវត្ថុដែលបំពេញបានតាមនិយមន័យមូលធនផ្ទាល់របស់អង្គភាព រួមបញ្ចូលទាំងសមាសធាតុមូលធននៃឧបករណ៍ហិរញ្ញវត្ថុផ្សំ ដែលបានបោះផ្សាយដោយអង្គភាពនោះ (សូមមើលផ្នែកទី២២ ស្តីពីបំណុល និងមូលធន)។

(គ) ភតិសន្យា ដែលអនុវត្តតាមផ្នែកទី២០ ស្តីពីភតិសន្យា ឬកថាខណ្ឌ១២.៣(ច)។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយការតម្រូវនៃការឈប់ទទួលស្គាល់ក្នុងកថាខណ្ឌ១១.៣៣-១១.៣៨ ត្រូវអនុវត្តចំពោះការឈប់ទទួលស្គាល់នៃភតិសន្យាត្រូវទទួលដែលបានទទួលស្គាល់ដោយភតិបតី និងភតិសន្យាត្រូវបង់ដែលបានទទួលស្គាល់ដោយភតិក: ហើយការតម្រូវនៃការថយចុះតម្លៃក្នុងកថាខណ្ឌ១១.២១-១១.២៦ត្រូវអនុវត្តចំពោះភតិសន្យាត្រូវ ទទួលដែលបានទទួលស្គាល់ដោយភតិបតី។

(ឃ) សិទ្ធិនិងកាតព្វកិច្ចរបស់និយោជក នៅក្រោមផែនការអត្ថប្រយោជន៍និយោជិត ដែលត្រូវអនុវត្តតាមផ្នែកទី២៨ ស្តីពីផែនការអត្ថប្រយោជន៍និយោជិត។

(ង) ឧបករណ៍ហិរញ្ញវត្ថុ កិច្ចសន្យា និងកាតព្វកិច្ចស្ថិតក្រោម ប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុន ដែលត្រូវអនុវត្តតាមផ្នែកទី២៦ ស្តីពីការទូទាត់ដោយផ្អែកលើភាគហ៊ុន។

(ច) ទ្រព្យសកម្មសំណង ដែលត្រូវបានធ្វើគណនេយ្យកម្មដោយស្របតាមផ្នែកទី២១ ស្តីពីសំវិធានធន និងយថាភាព (សូមមើលកថាខណ្ឌ២១.៩)។

## ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន

១១.៨ អង្គភាពត្រូវធ្វើគណនេយ្យកម្មសម្រាប់ឧបករណ៍ហិរញ្ញវត្ថុខាងក្រោម ជាឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ដោយស្របតាមផ្នែកទី១១៖

(ក) សាច់ប្រាក់

(ខ) ឧបករណ៍បំណុល (ដូចជា គណនី ធនបត្រ ឬកម្ចី ដែលត្រូវទទួលឬត្រូវបង់) ដែលបំពេញបានតាមលក្ខខណ្ឌនានាក្នុងកថាខណ្ឌ ១១.៩

(គ) ការសន្យាទទួលកម្ចីដែល៖

១) មិនអាចទូទាត់ជាសាច់ប្រាក់សុទ្ធ និង

២) ត្រូវបានរំពឹងថាបំពេញតាមលក្ខខណ្ឌក្នុងកថាខណ្ឌ១១.៩នៅពេលដែលការសន្យាត្រូវបានអនុវត្ត

(ឃ) ការវិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចបំប្លែងបាន និងភាគហ៊ុនធម្មតាឬភាគហ៊ុនបុរិមាដែលមិនអាចលក់វិញបាន។

១១.៩ ឧបករណ៍បំណុល ដែលបំពេញបានតាមលក្ខខណ្ឌទាំងអស់នៅក្នុង (ក)-(ឃ) ត្រូវបានធ្វើគណនេយ្យកម្មដោយអនុលោមតាមផ្នែកទី១១៖

(ក) ប្រាក់ចំណេញដែលផ្តល់ដល់អ្នកកាន់ឧបករណ៍ (ម្ចាស់បំណុល/ឥណទាយក) ដែលត្រូវបានវាយតម្លៃតាមរូបិយប័ណ្ណដែលកំណត់ប្រើដោយឧបករណ៍បំណុល គឺមួយក្នុងចំណោមខាងក្រោម៖

១) ចំនួនទឹកប្រាក់ថេរ

២) អត្រាចំណេញថេរក្នុងមួយរយៈពេលនៃជីវិតរបស់ឧបករណ៍

៣) ផលចំណេញប្រែប្រួលក្នុងមួយរយៈពេលទាំងមូលនៃជីវិតរបស់ឧបករណ៍ គឺស្មើនឹងអត្រាការប្រាក់យោងទោលបានធ្វើសម្រង់ឬអាចអង្កេតបាន (ដូចជា អត្រាការប្រាក់អន្តរធនាគារទីក្រុងឡុងដ៍ LI-BOR) ឬ

៤) ការបន្សំចូលគ្នារវាងអត្រាថេរ និងអត្រាប្រែប្រួលបែបនេះ ឱ្យតែថាទាំងអត្រាថេរ និងអត្រាប្រែប្រួលមានភាពវិជ្ជមាន (ឧទាហរណ៍ ការដោះដូរអត្រាការប្រាក់ ដែលអត្រាថេរវិជ្ជមានជាមួយអត្រាប្រែប្រួលអវិជ្ជមាន មិនបំពេញទៅនឹងលក្ខណៈវិនិច្ឆ័យនេះឡើយ)។

ចំពោះផលនៃអត្រាការប្រាក់ថេរ និងអត្រាការប្រាក់ប្រែប្រួល ការប្រាក់ត្រូវបានគណនាដោយគុណ អត្រាការប្រាក់ជាមួយនឹងរយៈពេលសមស្របមួយទៅនឹងប្រាក់ដើមនៅជាប់ជំពាក់នៅក្នុងអំឡុងគ្រា។

(ខ) ផ្អែកលើលក្ខខណ្ឌរបស់វា ពុំមានវិធាននៃកិច្ចសន្យាណាដែលនាំឱ្យអ្នកកាន់ឧបករណ៍បំណុលនោះ (ម្ចាស់បំណុល/ឥណទាយក) បាត់បង់នូវបំណុលដើមរបស់គេ ឬបាត់បង់ការប្រាក់ដែលអាចផ្តល់ជូននាការិយបរិច្ឆេទ បច្ចុប្បន្ន ឬការិយបរិច្ឆេទមុនៗនោះទេ។ ក្នុងករណីដែលឧបករណ៍បំណុលមួយ ចំណុះឱ្យឧបករណ៍បំណុល ដទៃទៀត វាមិនមែនជាឧទាហរណ៍ដែលអនុវត្តចំពោះវិធាននៃកិច្ចសន្យានេះទេ។

(គ) វិធាននៃកិច្ចសន្យានានា ដែលអនុញ្ញាត ឬតម្រូវឱ្យអ្នកបោះផ្សាយប័ណ្ណបំណុល (កូនបំណុល) សងជាមុននូវឧបករណ៍បំណុល ឬអនុញ្ញាត ឬតម្រូវឱ្យអ្នកកាន់ប័ណ្ណបំណុល (ម្ចាស់បំណុល/ឥណទាយក) ប្រគល់ប័ណ្ណបំណុលត្រឡប់ទៅអ្នកបោះផ្សាយប័ណ្ណបំណុល (ពោលគឺ ដើម្បីទាមទារការទូទាត់សង) មុនកាលកំណត់សង គឺមិនអាស្រ័យលើព្រឹត្តិការណ៍នាពេលអនាគតនោះទេ ក្រៅពីមានបំណងការពារ៖

(១) អ្នកកាន់ប័ណ្ណបំណុលពីការប្រែប្រួលលើហានិភ័យឥណទាន របស់អ្នកបោះផ្សាយប័ណ្ណបំណុល ឬឧបករណ៍ (ឧទាហរណ៍៖ រំលោភកិច្ចសន្យា ការថយចុះកម្រិតឥណទាន ឬការបំពានកិច្ចព្រមព្រៀងបំណុល) ឬការផ្លាស់ប្តូរការគ្រប់គ្រងនៃអ្នកបោះផ្សាយប័ណ្ណបំណុល ឬ

(២) អ្នកកាន់ប័ណ្ណបំណុល ឬអ្នកបោះផ្សាយប័ណ្ណបំណុលពីការផ្លាស់ប្តូរលើពន្ធដារ ឬច្បាប់ពាក់ព័ន្ធ។

(ឃ) វាមិនមានប្រាក់ចំណេញដែលមានដាក់លក្ខខណ្ឌ ឬសំវិធានធនដែលត្រូវទូទាត់ឡើងវិញ លើកលែងតែអត្រាប្រាក់ចំណេញប្រែប្រួលដែលបានរៀបរាប់នៅក្នុងចំណុច (ក) និងវិធាននៃការទូទាត់មុន ដែលមានចែងនៅក្នុងចំណុច (គ)។

១១.៩ក ឧទាហរណ៍នៃឧបករណ៍បំណុល ដែលជាធម្មតាបំពេញបានតាមលក្ខខណ្ឌ ក្នុងកថាខណ្ឌ១១.៩(ក)(៤) រួមមាន៖

(ក) ប្រាក់កម្ចីធនាគារ ដែលមានអត្រាការប្រាក់ថេរសម្រាប់រយៈពេលដំបូង ដែលក្រោយមកត្រឡប់ទៅរកអត្រា

ការប្រាក់ប្រែប្រួល ដែលបានធ្វើសម្រង់ ឬដែលអាចអង្កេតបានវិញ បន្ទាប់ពីរយៈពេលនោះ និង

(ខ) ប្រាក់កម្ចីធនាគារ ដែលត្រូវបង់ការប្រាក់ក្នុងអត្រាការប្រាក់ប្រែប្រួល ដែលបានធ្វើសម្រង់ ឬដែលអាចអង្កេតបាន បូកថែមអត្រាការប្រាក់ថេរ ពេញមួយអាយុកាលនៃកម្ចី ឧទាហរណ៍៖ LIBOR បូកថែម ២០០ចំណុចគោល)។

១១.៩ខ ឧទាហរណ៍នៃឧបករណ៍បំណុល ដែលជាធម្មតាបំពេញបានតាមលក្ខខណ្ឌ ដែលកំណត់ក្នុងកថាខណ្ឌ១១.៩(គ) គឺជាប្រាក់កម្ចីធនាគារ ដែលអនុញ្ញាតឱ្យកូនបំណុល បញ្ចប់កិច្ចសន្យាមុនពេលកំណត់ ទោះបីជាកូនបំណុល អាចត្រូវបាន តម្រូវឱ្យបង់ប្រាក់ពិន័យ ដើម្បីទូទាត់សងធនាគារចំពោះថ្លៃចំណាយ ដែលកើតឡើងដោយសារកូនបំណុលបញ្ចប់កិច្ចសន្យា មុនកាលកំណត់។

១១.១០ ខាងក្រោមគឺជាឧបករណ៍នៃឧបករណ៍ហិរញ្ញវត្ថុដែលជាធម្មតាបំពេញតាមលក្ខខណ្ឌនានានៅក្នុងកថាខណ្ឌ១១.៩៖

(ក) គណនីទិញ-លក់ និងធនបត្រដែលអាចទទួលបាននិងធនបត្រដែលអាចទូទាត់បាន ព្រមទាំងកម្ចីពីធនាគារ ឬពីភាគីទី ៣ ផ្សេងទៀត

(ខ) គណនីត្រូវទូទាត់ជារូបិយប័ណ្ណបរទេស។ ទោះបីជាយ៉ាងណាក៏ដោយ រាល់ការប្រែប្រួលលើគណនីត្រូវទូទាត់ ដែលបណ្តាលមកពីការប្រែប្រួលនៃអត្រាប្តូរប្រាក់ត្រូវបានទទួលស្គាល់ថាជាចំណេញឬខាត ដូចដែលបានតម្រូវដោយកថាខណ្ឌ ៣០.១០។

(គ) កម្ចីដែលត្រូវផ្តល់ឱ្យ ឬទាពីក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬញាតិសម្ព័ន្ធ ដែលមានកាលកំណត់តាមការទាមទារ

(ឃ) ឧបករណ៍បំណុលដែលនឹងអាចទទួលបានភ្លាមៗ ប្រសិនបើអ្នកបោះផ្សាយប័ណ្ណបំណុលខកខានមិនបានបង់ការប្រាក់ ឬបង់ប្រាក់ដើម (វិធាននេះ មិនបំពានលើលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌ ១១.៩នោះទេ)។

១១.១១ ឧទាហរណ៍នៃឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបំពេញបានតាមលក្ខខណ្ឌ ក្នុងកថាខណ្ឌ១១.៩ (ហើយដូច្នេះស្ថិតក្នុងវិសាលភាពនៃផ្នែកទី១២) រួមមាន៖

(ក) ការវិនិយោគក្នុងឧបករណ៍មូលធនរបស់អង្គភាពផ្សេងទៀត លើកលែងតែភាគហ៊ុនបុរិមាដែលមិនអាចបំប្លែងបាន និងភាគហ៊ុនធម្មតានិងបុរិមាដែលមិនអាចលក់វិញបាន (សូមមើលកថាខណ្ឌ១១.៨ (ឃ))។

(ខ) ការប្តូរអត្រាការប្រាក់ ដែលបានទទួលជាលំហូរសាច់ប្រាក់វិជ្ជមានឬអវិជ្ជមាន ឬការសន្យានាពេលអនាគតសម្រាប់ទិញទំនិញ ឬឧបករណ៍ហិរញ្ញវត្ថុដែលអាចទូទាត់បានជាសាច់ប្រាក់ ហើយនៅពេលដែលទូទាត់អាចបង្កើតលំហូរសាច់ប្រាក់វិជ្ជមាន ឬ ពីព្រោះការប្តូរ និងការសន្យានាពេលអនាគតនេះ មិនបាន បំពេញតាមលក្ខខណ្ឌនៅក្នុងកថាខណ្ឌ ១១.៩(ក)។

(គ) សិទ្ធិធ្វើជម្រើស និងកិច្ចសន្យានាពេលអនាគត ពីព្រោះចំណេញដែលត្រូវផ្តល់ជូនអ្នកកាន់ឧបករណ៍នោះមិនត្រូវបានកំណត់ ហើយមិនបំពេញបានតាមលក្ខខណ្ឌក្នុងកថាខណ្ឌ ១១.៩ (ក)។

(ឃ) ការវិនិយោគលើបំណុលដែលអាចបំប្លែងបាន ពីព្រោះចំណេញចំពោះអ្នកកាន់ឧបករណ៍ អាចប្រែប្រួលតាមតម្លៃនៃភាគហ៊ុនជាមូលធនរបស់អ្នកបោះផ្សាយប័ណ្ណបំណុល ជាជាងតាមអត្រាការប្រាក់ទីផ្សារ។

## ការទទួលស្គាល់ជាដំបូងនូវទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

១១.១២ អង្គភាពមួយត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ នៅពេលដែលអង្គភាពនោះក្លាយទៅជាភាគីនៃកិច្ចសន្យាពាក់ព័ន្ធនឹងឧបករណ៍។

## ការវាស់វែងបឋម

១១.១៣ នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ជាដំបូង អង្គភាពត្រូវវាស់វែងទ្រព្យសកម្ម/បំណុលនោះតាមតម្លៃប្រតិបត្តិការ (រួមទាំងថ្លៃប្រតិបត្តិការ លើកលែងតែការវាស់វែងដំបូងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលពេលធ្វើការវាស់វែងជាបន្តបន្ទាប់ ផ្អែកលើតម្លៃសមស្របតាមរយៈចំណេញឬខាត) លើកលែងតែកិច្ចសន្យាបង្កើតឱ្យមានប្រតិបត្តិការហិរញ្ញប្បទាននៅក្នុងការអនុវត្តជាក់ស្តែង សម្រាប់អង្គភាព (ចំពោះបំណុលហិរញ្ញវត្ថុ) ឬភាគីម្ខាងទៀត (ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ) នៃកិច្ចសន្យា។ កិច្ចសន្យាមួយ បង្កើតបានជាប្រតិបត្តិការហិរញ្ញប្បទាន ប្រសិនបើការទូទាត់ត្រូវបានពន្យារលើសពីរយៈពេលអាជីវកម្មធម្មតា ឧទាហរណ៍៖ ការផ្តល់ឥណទានគ្មានការប្រាក់ ដល់អ្នកទិញសម្រាប់ការលក់ទំនិញ ឬផ្តល់ហិរញ្ញប្បទានក្នុងអត្រាការប្រាក់មួយ ដែលមិនមែនជាអត្រាការប្រាក់ទីផ្សារ ឧទាហរណ៍៖ ប្រាក់កម្ចីគ្មានការប្រាក់ ឬក្នុងអត្រាការប្រាក់ក្រោមទីផ្សារសម្រាប់និយោជិត។ ប្រសិនបើកិច្ចសន្យានាំឱ្យមានប្រតិបត្តិការហិរញ្ញប្បទាន អង្គភាពត្រូវវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុតាមតម្លៃបច្ចុប្បន្ននៃការទូទាត់នាពេលអនាគត ដោយធ្វើអប្បហារតាមអត្រាការប្រាក់ទីផ្សារសម្រាប់ឧបករណ៍ បំណុលប្រហាក់ប្រហែលគ្នា ដូចបានកំណត់នៅក្នុង ការទទួលស្គាល់បឋម។

### ឧទាហរណ៍- ទ្រព្យសកម្មហិរញ្ញវត្ថុ

១. ចំពោះប្រាក់កម្ចីរយៈពេលវែងដែលបានផ្តល់ដល់អង្គភាពមួយផ្សេងទៀត ប្រាក់ដែលត្រូវទទួលបានត្រូវបានទទួលស្គាល់តាមតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់ដែលនឹងទទួលបានពីអង្គភាពនោះ (រាប់បញ្ចូលទាំងការទូទាត់ការប្រាក់ និងការបង់សងវិញនូវប្រាក់ដើម)។

២. ចំពោះទំនិញដែលបានលក់ជូនអតិថិជនដោយឱ្យជំពាក់រយៈពេលខ្លី ប្រាក់ដែលត្រូវទទួលបានត្រូវបានទទួលស្គាល់ជាបរិមាណសាច់ប្រាក់ ដែលអាចទទួលបានពីអង្គភាពនោះដោយមិនធ្វើអប្បហារ ដែលជាធម្មតាគឺជាតម្លៃលើវិក្កយបត្រ។

៣. ចំពោះវត្ថុមួយដែលបានលក់ទៅឱ្យអតិថិជនដោយឱ្យជំពាក់រយៈពេល២ឆ្នាំដោយគ្មានការប្រាក់ ប្រាក់ដែលត្រូវទទួលបានត្រូវបានទទួលស្គាល់តាមតម្លៃលក់ជាសាច់ប្រាក់បច្ចុប្បន្ននៃវត្ថុនោះ។ ប្រសិនបើយើងមិនបានដឹងអំពីតម្លៃលក់ជាសាច់ប្រាក់បច្ចុប្បន្ន នោះតម្លៃលក់អាចត្រូវបានប៉ាន់ស្មានតាមតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់ដែលត្រូវទទួលបានដោយធ្វើអប្បហារដោយប្រើប្រាស់អត្រាការប្រាក់ទីផ្សារទូទៅ សម្រាប់ប្រាក់ដែលត្រូវទទួលបានប្រហាក់ប្រហែលគ្នា។

៤. ចំពោះការទិញភាគហ៊ុនធម្មតារបស់អង្គភាពផ្សេងទៀតដោយចំណាយជាសាច់ប្រាក់ ការវិនិយោគនេះត្រូវបានទទួលស្គាល់តាមបរិមាណសាច់ប្រាក់ដែលបានបង់ដើម្បីទទួលបានចំណែកហ៊ុន។

### ឧទាហរណ៍- បំណុលហិរញ្ញវត្ថុ

១. ចំពោះប្រាក់កម្ចីដែលទទួលបានពីធនាគារ ប្រាក់ដែលត្រូវបង់ត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃបច្ចុប្បន្ន នៃសាច់ប្រាក់ដែលត្រូវបង់ឱ្យធនាគារ (ឧទាហរណ៍ ការទូទាត់ការប្រាក់ និងការបង់សងវិញនូវប្រាក់ដើម)។

២. ចំពោះទំនិញដែលទិញពីអ្នកផ្គត់ផ្គង់ដោយឱ្យជំពាក់រយៈពេលខ្លី ប្រាក់ដែលត្រូវបង់ត្រូវបានទទួលស្គាល់ជាបរិមាណសាច់ប្រាក់ដែលជំពាក់អ្នកផ្គត់ផ្គង់ដោយមិនធ្វើអប្បហារ ដែលជាធម្មតាគឺជាតម្លៃលើវិក្កយបត្រ។

## ការវាស់វែងជាបន្តបន្ទាប់

១១.១៤ នាចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ អង្គភាពត្រូវវាយតម្លៃឧបករណ៍ហិរញ្ញវត្ថុ ដោយមិនកាត់ចោលនូវថ្លៃប្រតិបត្តិការដែលអង្គភាពអាចចំណាយលើការលក់ឬការបញ្ចេញចោលផ្សេងៗទៀតដូចខាងក្រោម ៖

(ក) ឧបករណ៍បំណុលដែលបំពេញបានតាមលក្ខខណ្ឌចែងក្នុងកថាខណ្ឌ ១១.៨ (ខ) នឹងត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ កថាខណ្ឌ១១.១៥-១១.២០ បានផ្តល់នូវការណែនាំក្នុងការកំណត់ថ្លៃដើមដករំលស់ដោយប្រើវិធីសាស្ត្រ ការប្រាក់ប្រសិទ្ធភាព។ ឧបករណ៍បំណុលដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មចរន្ត ឬបំណុលចរន្ត នឹងត្រូវបានវាស់វែងតាមបរិមាណសាច់ប្រាក់ដោយមិនធ្វើអប្បហារ ឬតាមតម្លៃតបស្នងផ្សេងទៀត ដែលរំពឹងថានឹងត្រូវទូទាត់សង ឬនឹងត្រូវទទួលបាន (ពោលគឺ បន្ទាប់ពីកាត់កងការថយចុះតម្លៃ - សូមមើលកថាខណ្ឌ ១១.២១-១១.២៦) លើកលែងតែនៅក្នុងការជាក់ស្តែង កិច្ចសន្យាបានបង្កើតឱ្យមានប្រតិបត្តិការហិរញ្ញប្បទាន (សូមមើលកថាខណ្ឌ ១១.១៣)។

(ខ) ការសន្យាទទួលនូវកម្ចីតាមលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌ១១.៨ (គ) ត្រូវបានវាស់វែងដោយយកថ្លៃដើម (ជួនកាលពុំមាន) ដកជាមួយការថយចុះតម្លៃ។

(គ) ការវិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចបំប្លែងបាន និងភាគហ៊ុនធម្មតា ឬបុរិមាដែលមិនអាចលក់វិញបាន ត្រូវធ្វើការវាស់វែងដូចខាងក្រោម (កថាខណ្ឌ១១.២៧-១១.៣២ ផ្តល់នូវការណែនាំអំពីតម្លៃសមស្រប)៖

១- ប្រសិនបើភាគហ៊ុនត្រូវបានដាក់លក់ជាសាធារណៈ ឬផ្សេងពីនេះតម្លៃសមស្របរបស់វាអាចត្រូវបានវាស់វែងប្រកបដោយការជឿទុកចិត្តបាន ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ការវិនិយោគត្រូវតែវាស់វែងតាមតម្លៃសមស្រប ដោយបម្រែបម្រួលនៃតម្លៃសមស្របត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។ និង

២- សម្រាប់ការវិនិយោគបែបនេះផ្សេងទៀតទាំងអស់ ត្រូវវាស់វែងដោយយកថ្លៃដើម ដកជាមួយការថយចុះតម្លៃ។ ការថយចុះតម្លៃ ឬ ភាពដែលមិនអាចប្រមូលបាន ត្រូវតែធ្វើការវាយតម្លៃសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានចែងក្នុងចំណុច (ក), (ខ) និងចំណុច (គ)(២) ខាងលើ។ កថាខណ្ឌ១១.២១-១១.២៦ ផ្តល់នូវការណែនាំអំពីករណីនេះ។

## ថ្លៃដើមដករំលស់ និងវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព

១១.១៥ ថ្លៃដើមដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុមួយនាការិយបរិច្ឆេទរាយការណ៍នីមួយៗ គឺជាផលកាត់កងនៃចំនួនខាងក្រោម៖

(ក) ចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនាពេលទទួលស្គាល់ដំបូង

(ខ) ដកជាមួយការការបង់សងវិញនូវប្រាក់ដើម

(គ) បូកឬដក រំលស់បង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៃភាពខុសគ្នារវាងចំនួន ដែលបានទទួល

ស្គាល់ ដំបូង និងចំនួននាពេលដល់កាលកំណត់សង

(ឃ) ដកចេញ នូវការកាត់ចេញ (ដោយផ្ទាល់ ឬដោយការប្រើគណនីវិភាជន៍) នូវការថយចុះតម្លៃ ឬការដែលមិនអាចប្រមូលបានក្នុងករណីវាជាទ្រព្យសកម្មហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមិនមានអត្រាការប្រាក់បានកំណត់ ដែលមិនទាក់ទងនឹងកិច្ចសន្យាមួយដែលនាំឱ្យមានប្រតិបត្តិការហិរញ្ញវត្ថុ និងដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលខ្លី ឬបំណុលរយៈពេលខ្លី ត្រូវបានធ្វើការវាស់វែងជាដំបូងតាមបរិមាណមួយដោយមិនធ្វើអប្បហារស្របតាមកថាខណ្ឌ ១១.១៣។ ដូចនេះ ចំណុច (គ) ខាងលើមិនត្រូវបានអនុវត្តចំពោះទ្រព្យសកម្ម និងបំណុលនោះឡើយ។

១១.១៦ វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព គឺជាវិធីសាស្ត្រមួយនៃការគណនាថ្លៃដើមដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុមួយ (ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ) និងជាវិធីសាស្ត្រនៃការធ្វើវិភាជន៍ចំណូលពីការប្រាក់ ឬចំណាយលើការប្រាក់តាមការិយបរិច្ឆេទពាក់ព័ន្ធ។ អត្រាការប្រាក់ប្រសិទ្ធភាពគឺជាអត្រាដែលធ្វើអប្បហារយ៉ាងជាក់លាក់លើការទូទាត់ ឬការទទួលបានសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ទៅតាម អាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ ឬ នៅពេលសមស្រប សម្រាប់រយៈពេលខ្លីជាងនេះ ធ្វើអប្បហារ ទៅកាន់តម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានកំណត់ ដោយផ្អែកលើមូលដ្ឋាននៃតម្លៃយោងនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុនាពេលទទួលស្គាល់ដំបូង។ តាមវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព:

(ក) ថ្លៃដើមដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ(បំណុល) គឺជាតម្លៃបច្ចុប្បន្ននៃចំណូលជាសាច់ប្រាក់នាពេលអនាគត (ចំណាយ) ដែលបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាព និង

(ខ) ចំណាយលើការប្រាក់(ចំណូល)ក្នុងការិយបរិច្ឆេទស្មើនឹងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុ (ទ្រព្យសកម្ម) នាដើមការិយបរិច្ឆេទ គុណនឹងអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ការិយបរិច្ឆេទនោះ។

១១.១៧ នាពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព អង្គភាពត្រូវប៉ាន់ស្មាននូវលំហូរសាច់ប្រាក់ ដោយពិចារណាលើលក្ខខណ្ឌទាំងអស់ក្នុងកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ (ឧទាហរណ៍ ការទូទាត់មុន ជម្រើសនៃការទិញត្រឡប់វិញ ឬជម្រើសប្រហាក់ប្រហែល) ព្រមទាំងការខាតបង់ឥណទានដែលបានដឹង និងបានកើតឡើង ប៉ុន្តែមិនត្រូវ ពិចារណាលើការខាតបង់ឥណទានដែលអាចកើតមាននាពេលអនាគត និងពុំទាន់កើតឡើងនោះទេ។

១១.១៨ នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព អង្គភាពត្រូវរំលស់នូវសោហ៊ុយទាក់ទិនផ្សេងៗ បន្ទុកហិរញ្ញវត្ថុដែលបានបង់ឬ ដែលបានទទួល (ដូចជា 'points') ថ្លៃប្រតិបត្តិការ និងបុព្វលាភ ឬការបញ្ចុះតម្លៃដទៃទៀតក្នុងអំឡុងអាយុកាលប៉ាន់ស្មាននៃឧបករណ៍ លើកលែងតែករណីដូចតទៅ។ អង្គភាពត្រូវប្រើរយៈពេលខ្លីជាងមួយ ប្រសិនបើវាជារយៈពេលដែលសោហ៊ុយ បន្ទុកហិរញ្ញវត្ថុដែលបានបង់ឬដែលបានទទួល ថ្លៃប្រតិបត្តិការបុព្វលាភ ឬការបញ្ចុះតម្លៃទាក់ទិន។ ករណីនេះ វាអាចកើតមាននៅពេលដែលបម្រែបម្រួលលើសោហ៊ុយទាក់ទិនផ្សេងៗ បន្ទុកហិរញ្ញវត្ថុដែលបានបង់ឬដែលបានទទួល ថ្លៃប្រតិបត្តិការ បុព្វលាភ ឬការបញ្ចុះតម្លៃ ត្រូវបានកំណត់ថ្លៃឡើងវិញតាមអត្រាទីផ្សារ មុនដល់កាលកំណត់នៃឧបករណ៍។

ក្នុងករណីនេះ ការិយបរិច្ឆេទរំលស់ត្រឹមត្រូវ គឺជាការិយបរិច្ឆេទបន្ទាប់ពីថ្ងៃកំណត់ថ្លៃឡើងវិញ។

១១.១៩ សម្រាប់អត្រាប្រែប្រួលនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងអត្រាប្រែប្រួលនៃបំណុលហិរញ្ញវត្ថុ ការប៉ាន់ស្មានឡើងវិញតាម ដំណាក់កាលនៃលំហូរសាច់ប្រាក់ដើម្បីបង្ហាញឱ្យឃើញនូវការផ្លាស់ប្តូរនូវអត្រាការប្រាក់លើទីផ្សារនាំឱ្យមានការប្រែប្រួលនូវអត្រាការប្រាក់ប្រសិទ្ធភាព។ ប្រសិនបើអត្រាប្រែប្រួលនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងអត្រាប្រែប្រួលនៃ

បំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ពីដំបូងក្នុងបរិមាណមួយស្មើនឹងបរិមាណដើមដែលត្រូវទទួលឬត្រូវបង់ នាពេលដល់កាលកំណត់ ការធ្វើការប៉ាន់ស្មានឡើងវិញនូវចំណាយលើការប្រាក់នាពេលអនាគតជាធម្មតា មិននាំឱ្យមានផលប៉ះពាល់ខ្លាំងដល់តម្លៃយោងនៃទ្រព្យសកម្ម ឬបំណុលនោះទេ។

១១.២០ ប្រសិនបើអង្គភាពមួយផ្លាស់ប្តូរការប៉ាន់ស្មានចំណូលឬចំណាយរបស់ខ្លួន អង្គភាពត្រូវកែតម្រូវតម្លៃយោងនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ (ឬក្រុមនៃឧបករណ៍ហិរញ្ញវត្ថុ) ដើម្បីបង្ហាញឱ្យឃើញនូវលំហូរសាច់ប្រាក់ប៉ាន់ស្មានជាក់ស្តែង និងដែលបានកែតម្រូវ។ អង្គភាពត្រូវធ្វើការគណនាឡើងវិញនូវតម្លៃយោងដោយគិតតាមតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត តាមអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃឧបករណ៍ហិរញ្ញវត្ថុ។ អង្គភាពត្រូវទទួលស្គាល់ការកែតម្រូវនោះថាជាចំណូល ឬចំណាយ នៅក្នុងចំណេញឬខាត នាកាលបរិច្ឆេទផ្លាស់ប្តូរនោះ។

| |
|---|
| ឧទាហរណ៍នៃការកំណត់នូវថ្លៃដើមរំលស់សម្រាប់កម្ចីរយៈពេលប្រាំឆ្នាំដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាពនៅថ្ងៃទី 01 មករា 20X0 អង្គភាពមួយបានទិញសញ្ញាប័ណ្ណជាឯកតារូបិយប័ណ្ណចំនួន 900 ហើយ ចំណាយថ្លៃដើមប្រតិបត្តិការ 50 ឯកតារូបិយប័ណ្ណ។ ការប្រាក់សម្រាប់40 ឯកតារូបិយប័ណ្ណ អាចទទួលបាន ជារៀងរាល់ឆ្នាំ សម្រាប់រយៈពេល ៥ ឆ្នាំ រហូតដល់អស់បំណុល( ពីថ្ងៃទី 31 ធ្នូ 20X0- 31 ធ្នូ 20X4)។ សញ្ញាប័ណ្ណ មានរំលស់ជាចាំបាច់ប្រមាណ 50 ឯកតារូបិយប័ណ្ណ នៅថ្ងៃទី31 ធ្នូ 20X4។ |

| ឆ្នាំ | តម្លៃយោង ដើមការិយបរិច្ឆេទ | ចំណូលការប្រាក់តាមអត្រា 6.9583% * | លំហូរចូលសាច់ប្រាក់ | តម្លៃយោងចុងការិយបរិច្ឆេទ |
|---|---|---|---|---|
| | ឯកតារូបិយប័ណ្ណ | ឯកតារូបិយប័ណ្ណ | ឯកតារូបិយប័ណ្ណ | ឯកតារូបិយប័ណ្ណ |
| 20x0 | 950.00 | 66.10 | (40.00) | 976.11 |
| 20x1 | 976.11 | 67.92 | (40.00) | 1,004.03 |
| 20x2 | 1,004.03 | 69.86 | (40.00) | 1,033.89 |
| 20x3 | 1,033.89 | 71.94 | (40.00) | 1,065.83 |
| 20x4 | 1,065.83 | 74.16 | (40.00) | (1,100.00) |
| | | | (1,100.00) | 0 |
| *អត្រាការប្រាក់ប្រសិទ្ធភាព 6.9583% ជាអត្រាដែលបញ្ចុះតម្លៃលំហូរសាច់ប្រាក់ដែលរំពឹងទុកលើ សញ្ញាប័ណ្ណចំពោះតម្លៃយោងដើមដំបូង: | | | | |
| $40/(1.069583)^1 + 40/(1.069583)^2 + 40/(1.069583)^3 + 40/(1.069583)^4 + 1,140/(1.069583)^5 = 950$ | | | | |

# ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើម ឬថ្លៃដើមដករំលស់

## ការទទួលស្គាល់

១១.២១ នាចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ អង្គភាពត្រូវវាយតម្លៃថាតើមានភ័ស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុណាមួយដែលត្រូវបានវាស់វែងតាមថ្លៃដើម ឬថ្លៃដើមដករំលស់ដែរឬទេ។ ប្រសិនបើមានភ័ស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃនេះ អង្គភាពត្រូវតែទទួលស្គាល់នូវការខាតពីការថយចុះតម្លៃក្នុងចំណេញ ឬខាតជាបន្ទាន់។

១១.២២ ភ័ស្តុតាងជាក់ស្តែងដែលទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានថយចុះតម្លៃ រួមមានទិន្នន័យដែលគួរឱ្យកត់សម្គាល់ដែលទាញចំណាប់អារម្មណ៍របស់អ្នកកាន់កាប់ទ្រព្យសកម្មអំពីព្រឹត្តិការណ៍ដែលនាំឱ្យខាតបង់ដូចខាងក្រោម ៖

(ក) ការលំបាកផ្នែកហិរញ្ញវត្ថុគួរឱ្យកត់សម្គាល់របស់អ្នកបោះផ្សាយឧបករណ៍ ឬរបស់អ្នកជាប់កាតព្វកិច្ច

(ខ )ការមិនបំពេញតាមកិច្ចសន្យា ដូចជា ការបំពាន ឬអំពើល្មើសមិនបង់ការប្រាក់ ឬមិនបង់ប្រាក់ដើម។

(គ) ពេលមានហេតុផលខាងសេដ្ឋកិច្ច ឬខាងផ្លូវច្បាប់ទាក់ទិននឹងផលវិបាកផ្នែកហិរញ្ញវត្ថុរបស់កូនបំណុល ម្ចាស់បំណុលព្រមព្រៀង ផ្តល់សិទ្ធិឱ្យកូនបំណុលនូវសម្បទានមួយដែលជាក់ស្តែងម្ចាស់បំណុលពុំមាន បំណងនឹងគិតគូប្រសិនបើពុំមានហេតុផលខាងលើ។

(ឃ) កូនបំណុលអាចនឹងឈានទៅរកការក្ស័យធុនឬមានការរៀបចំឡើងវិញផ្នែកហិរញ្ញវត្ថុផ្សេងៗ

(ង) ទិន្នន័យគួរឱ្យកត់សម្គាល់បង្ហាញថា មានការកាត់បន្ថយដែលអាចវាស់វែង បានអំពីលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ពីក្រុមទ្រព្យសកម្មណាមួយ ចាប់ពីពេលទទួលស្គាល់ទ្រព្យសកម្មទាំងនោះជាលើកដំបូង ទោះបីជាការកាត់បន្ថយនោះមិនអាចកំណត់បាននៅឡើយទៅលើទ្រព្យសកម្មនីមួយៗនៅក្នុងក្រុម ដូចជា លក្ខខណ្ឌសេដ្ឋកិច្ចមិនអំណោយផល ក្នុងស្រុក ឬការប្រែប្រួលមិនអំណោយផលនៃលក្ខខណ្ឌឧស្សាហ កម្ម។

១១.២៣ មានកត្តាផ្សេងទៀតអាចជាភ័ស្តុតាងនៃការថយចុះតម្លៃ រួមមានការប្រែប្រួលគួរឲ្យកត់សម្គាល់ដែលជះឥទ្ធិពលអាក្រក់ត្រូវបានកើតឡើងទៅលើបរិស្ថានបច្ចេកវិទ្យា ទីផ្សារ សេដ្ឋកិច្ច ឬច្បាប់ដែល អ្នកចេញឧបករណ៍ហិរញ្ញវត្ថុធ្វើប្រតិបត្តិការ។

១១.២៤ អង្គភាពត្រូវវាយតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុខាងក្រោមដោយឡែកពីគ្នា អំពីការថយចុះតម្លៃរបស់វា៖

(ក) ឧបករណ៍មូលធនទាំងអស់ ដោយមិនគិតពីសារៈសំខាន់ និង

(ខ) ទ្រព្យសកម្មហិរញ្ញវត្ថុដទៃទៀត ដែលមានសារៈសំខាន់ដោយឡែកពីគ្នា។

អង្គភាពត្រូវវាយតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុដទៃទៀតសម្រាប់ការថយចុះតម្លៃ ដោយឡែកៗពីគ្នា ឬជាក្រុមដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា។

## ការវាស់វែង

១១.២៥ អង្គភាពត្រូវវាស់វែងការខាតពីការថយចុះតម្លៃទៅលើទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើម ឬថ្លៃដើមដករំលស់ ដូចខាងក្រោម ៖

(ក) ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមដករំលស់ស្របតាមកថាខណ្ឌ១១.១៤(ក) ការខាតពីការថយចុះតម្លៃគឺជាភាពខុសគ្នារវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ប៉ាន់ស្មានដោយធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដើមដំបូងរបស់ទ្រព្យសកម្ម។ ប្រសិនបើទ្រព្យសកម្ម ហិរញ្ញវត្ថុនោះ មានអត្រាការប្រាក់ប្រែប្រួល អត្រាធ្វើអប្បហារសម្រាប់វាស់វែងការខាតពីការថយចុះតម្លៃ គឺជាអត្រាការប្រាក់ប្រសិទ្ធភាពបច្ចុប្បន្នដែលបានកំណត់ក្នុងកិច្ចសន្យា។

(ខ) ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមដកការថយចុះតម្លៃ ស្របតាមកថាខណ្ឌ១១.១៤(ខ) និង(គ) (២) ការខាតពីការថយចុះតម្លៃ គឺជាភាពខុសគ្នារវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងការប៉ាន់ស្មាន

ដ៏ត្រឹមត្រូវ (ដែលមានការប្រហាក់ប្រហែលជាចាំបាច់) នៃបរិមាណ (ដែលអាចមានចំនួនសូន្យ) ដែលអង្គភាពអាចទទួលបានពីទ្រព្យសកម្ម ប្រសិនបើវាត្រូវបានលក់នាកាលបរិច្ឆេទរាយការណ៍។

## ការបង្វិលត្រឡប់មកវិញ

១១.២៦ ក្នុងការិយបរិច្ឆេទបន្តបន្ទាប់ ប្រសិនបើបរិមាណនៃការខាតពីការថយចុះតម្លៃមានការថយចុះ ហើយការថយចុះនេះអាចមានការពាក់ព័ន្ធចម្បងទៅនឹងព្រឹត្តិការណ៍មួយដែលបានកើតឡើងបន្ទាប់ពីការថយចុតម្លៃត្រូវបានទទួលស្គាល់ (ដូចជា ការតម្លើងចំណាត់ថ្នាក់ឥណទានរបស់កូនបំណុល) អង្គភាពត្រូវបង្វិលត្រឡប់មកវិញនូវការខាតពីការថយចុះតម្លៃដែលបានទទួលស្គាល់ពីពេលមុនៗ ដោយផ្ទាល់ ឬដោយការកែតម្រូវនូវគណនីវិភាជន៍។ ការបង្វិលត្រឡប់មកវិញនេះ មិនត្រូវធ្វើឲ្យតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ(បន្ទាប់ពីកាត់កងជាមួយគណនីវិភាជន៍) លើសពីអ្វីដែលតម្លៃយោងអាចមានប្រសិនបើពុំមានការទទួលស្គាល់ ការថយចុះតម្លៃពីមុនៗមក។ អង្គភាពត្រូវទទួលស្គាល់បរិមាណនៃការបង្វិលត្រឡប់មកវិញនៅក្នុងចំណេញ ឬខាតភ្លាមៗ។

## តម្លៃសមស្រប

១១.២៧ អង្គភាពត្រូវប្រើនូវចំណុចតាមលំដាប់លំដោយដូចខាងក្រោម ដើម្បីប៉ាន់ស្មានតម្លៃសមស្របរបស់ទ្រព្យសកម្មៈ

(ក) ភ័ស្តុតាងប្រសើរបំផុតនៃតម្លៃសមស្រប គឺជាតម្លៃដែលបានស្រង់សម្រាប់ទ្រព្យសកម្មដែលអាចកំណត់បាន (ឬទ្រព្យសកម្មប្រហាក់ប្រហែល) នៅក្នុងទីផ្សារសកម្មមួយ។ ជាទូទៅ នេះគឺជាតម្លៃទិញបច្ចុប្បន្ន។

(ខ) នៅពេលតម្លៃដែលបានស្រង់មិនមានស្រាប់ តម្លៃនៅក្នុងកិច្ចសន្យាលក់ដែលមានប្រសិទ្ធភាពច្បាប់ ឬប្រតិបត្តិការ ថ្មីៗ របស់ទ្រព្យសកម្មដែលអាចកំណត់បាន (ឬទ្រព្យសកម្មប្រហាក់ប្រហែល) នៅក្នុងប្រតិបត្តិការជំហោងដៃ រវាងភាគី ដែលដឹងរឿងរ៉ាវ និងមានបំណងធ្វើ ផ្តល់ជាភ័ស្តុតាងនៃតម្លៃសមស្រប។ ប៉ុន្តែ តម្លៃនេះមិនអាចជាការប៉ាន់ស្មានដ៏ល្អ នៃតម្លៃសមស្របទេ ប្រសិនបើមានការប្រែប្រួលជំដុំណាមួយនៃស្ថានភាពសេដ្ឋកិច្ច ឬរយៈពេលវែង រវាង កាលបរិច្ឆេទនៃកិច្ចសន្យាលក់ដែលមានប្រសិទ្ធភាពច្បាប់ ឬនៃប្រតិបត្តិការ និងកាលបរិច្ឆេទនៃការវាស់វែង។ ប្រសិនបើអង្គភាព អាចបង្ហាញថាតម្លៃប្រតិបត្តិការកន្លងទៅមិនមែនជាការប៉ាន់ស្មានដ៏ល្អនៃតម្លៃសមស្របនោះទេ (ឧទាហរណ៍ ពីព្រោះថាវាឆ្លុះបញ្ចាំងឱ្យឃើញនូវបរិមាណដែលអង្គភាពអាចទទួលបាន ឬអាចចំណាយលើ ប្រតិបត្តិការដោយបង្ខំ ការជម្រះបញ្ជីដោយបង្ខំ ឬការលក់បង្ខំ) តម្លៃនោះត្រូវបានធ្វើការកែតម្រូវ។

(គ) ប្រសិនបើទីផ្សារនៃទ្រព្យសកម្មមិនមានដំណើរការ ហើយកិច្ចសន្យាលក់ដែលមានប្រសិទ្ធភាពច្បាប់ ឬប្រតិបត្តិការថ្មីៗណាមួយ នៃទ្រព្យសកម្មដែលអាចកំណត់បាន (ឬទ្រព្យសកម្មប្រហាក់ប្រហែល) ផ្ទាល់ មិនអាចកំណត់នូវតម្លៃសមស្របបានល្អទេ អង្គភាពធ្វើការប៉ាន់ស្មាននូវតម្លៃសមស្របដោយប្រើនូវ បច្ចេកទេសវាយតម្លៃផ្សេងទៀត។ គោលដៅនៃការប្រើបច្ចេកទេសវាយតម្លៃនេះ គឺដើម្បីប៉ាន់ស្មានថា តម្លៃប្រតិបត្តិការនាកាលបរិច្ឆេទវាស់វែងលើការដោះដូរជំហោងដៃ ដែលធ្វើឡើងដោយគោលបំណងធម្មតានៅក្នុង អាជីវកម្ម។

ផ្នែកផ្សេងទៀតនៃស្តង់ដារនេះ ធ្វើការយោងនូវគោលការណ៍តម្លៃសមស្របចែងក្នុងកថាខណ្ឌ ១១.២៧-១១.៣២ រាប់បញ្ចូលទាំង ផ្នែកទី៩, ផ្នែកទី១២, ផ្នែកទី១៤, ផ្នែកទី១៥, ផ្នែកទី១៦ ស្តីពីទ្រព្យវិនិយោគ, ផ្នែកទី១៧ ស្តីពីទ្រព្យ រោងចក្រ និងបរិក្ខារ និងផ្នែកទី២៨។

## បច្ចេកទេសវាយតម្លៃ

១១.២៨ បច្ចេកទេសវាយតម្លៃមមាន ប្រតិបត្តិការទីផ្សាជំហោងដៃថ្មីៗប្រសិនបើមានស្រាប់សម្រាប់ទ្រព្យសកម្មដូចគ្នា រវាងភាគីដែលដឹងរឿងរ៉ាវនិងមានបំណងធ្វើ យោងលើតម្លៃសមស្របបច្ចុប្បន្នរបស់ទ្រព្យសកម្មមួយទៀត ដែលមានលក្ខណៈដូចគ្នាច្រើនទៅនឹងទ្រព្យសកម្មដែលកំពុងតែបានវាស់វែង ការវិភាគអំពីលំហូរសាច់ប្រាក់ ដោយធ្វើអប្បហារ និងវិធីសាស្ត្រជម្រើសកំណត់ថ្លៃ។ ប្រសិនបើមានបច្ចេកទេសវាយតម្លៃដែលប្រើប្រាស់ ជាទូទៅដោយអ្នកចូលរួមក្នុងទីផ្សារដើម្បីកំណត់តម្លៃទ្រព្យសកម្ម ហើយបច្ចេកទេសនោះត្រូវបានបង្ហាញថា ផ្តល់នូវការប៉ាន់ស្មានតម្លៃអាចឱ្យទុកចិត្តបានដែលទទួលបានពីប្រតិបត្តិការទីផ្សារជាក់ស្តែង អង្គភាពនឹងប្រើ បច្ចេកទេសនោះ។

១១.២៩ គោលដៅនៃការប្រើបច្ចេកទេសវាយតម្លៃគឺដើម្បីបង្កើតនូវតម្លៃប្រតិបត្តិការនាកាលបរិច្ឆេទវាស់វែង ក្នុងការដោះដូរជំហោងដៃដែលបណ្តាលមកពីគោលបំណងអាជីវកម្មធម្មតា។ តម្លៃសមស្របត្រូវបានប៉ាន់ស្មាន ដោយផ្អែកលើមូលដ្ឋាននៃលទ្ធផលពីបច្ចេកទេសវាយតម្លៃដែលប្រើធាតុចូលទីផ្សារជាអតិបរមា និងពឹងផ្អែកលើធាតុចូលដែលកំណត់ដោយអង្គភាពឱ្យបានកាន់តែតិចតាមតែអាចធ្វើទៅបាន។ បច្ចេកទេសវាយតម្លៃអាចត្រូវបានរំពឹងថាឈានដល់ការប៉ាន់ស្មានតម្លៃសមស្របមួយដែលអាចជឿទុកចិត្តបាន ប្រសិនបើ ៖

(ក) បច្ចេកទេសវាយតម្លៃឆ្លុះបញ្ចាំងយ៉ាងសមហេតុសមផលនូវការរំពឹងទុកនៃតម្លៃទ្រព្យសកម្មរបស់ទីផ្សា ហើយ

(ខ) ធាតុចូលនៅក្នុងបច្ចេកទេសវាយតម្លៃតំណាងឲ្យយ៉ាងសមហេតុសមផលនូវការរំពឹងទុករបស់ទីផ្សារ និងការវាស់វែងកត្តាហានិភ័យត្រឡប់ដែលមានជាប់ជាមួយទ្រព្យសកម្ម។

## គ្មានទីផ្សារសកម្ម

១១.៣០ តម្លៃសមស្របនៃការវិនិយោគលើទ្រព្យសកម្ម ដែលមិនមានតម្លៃដែលបានស្រង់ពីក្នុងទីផ្សារសកម្មមួយ ត្រូវបានវាស់វែងយ៉ាងត្រឹមត្រូវប្រសិនបើ ៖

(ក) ភាពខុសគ្នារវាងចន្លោះនៃការប៉ាន់ស្មានតម្លៃសមស្របសមហេតុផល គឺមិនគួរឲ្យកត់សម្គាល់សម្រាប់ទ្រព្យសកម្ម ឬ

(ខ) ភវនីយភាពនៃការប៉ាន់ស្មានផ្សេងៗនៅក្នុងចន្លោះនេះអាចត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ ហើយបានប្រើប្រាស់នៅក្នុងការប៉ាន់ស្មានតម្លៃសមស្រប។

១១.៣១ មានស្ថានភាពច្រើនណាស់ដែលភាពខុសគ្នារវាងចន្លោះនៃការប៉ាន់ស្មានតម្លៃសមស្របសមហេតុផលនៃទ្រព្យសកម្មដែលមិនមានតម្លៃដែលបានស្រង់ពីក្នុងទីផ្សារសកម្មមួយអាចមិនមានភាពគួរឲ្យកត់សម្គាល់។ ជាធម្មតាគេអាចប៉ាន់ស្មានតម្លៃសមស្របរបស់ទ្រព្យសកម្មមួយ ដែលអង្គភាពបានទិញពីភាគីខាងក្រៅ។

ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើចន្លោះនៃការប៉ាន់ស្មានតម្លៃសមស្របសមហេតុផលមាន ភាពគួរឲ្យកត់សម្គាល់ ហើយភវនីយភាពនៃការប៉ាន់ស្មានផ្សេងៗមិនអាចត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ អង្គភាពត្រូវប្រានចោលនូវការវាស់វែងទ្រព្យសកម្មតាមតម្លៃសមស្រប។

១១.៣២ ប្រសិនបើការវាស់វែងលើតម្លៃសមស្របគួរឱ្យទុកចិត្ត មិនអាចធ្វើបានលើទ្រព្យសកម្មមួយ ដែលបានវាស់វែង តាមតម្លៃសមស្របបានតទៅទៀតទេ (ឬមិនអាចរកបាន ប្រសិនបើគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ នៅពេលដែលការលើកលែងបែបនោះ ត្រូវបានផ្តល់ឱ្យ (សូមមើលកថាខណ្ឌ១១.១៤ (គ) និងកថាខណ្ឌ១២.៨(ខ)) នោះតម្លៃយោងរបស់វានាកាលបរិច្ឆេទចុងក្រោយដែលទ្រព្យសកម្ម អាចវាស់វែង បានដោយគួរឲ្យទុកចិត្ត នឹងក្លាយទៅជាថ្លៃដើមថ្មីរបស់វា។ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មតាមបរិមាណ ថ្លៃដើមនេះ ដកជាមួយការថយចុះតម្លៃរហូតទាល់តែអាចធ្វើ ការវាស់វែងតម្លៃសមស្របគួរឱ្យទុកចិត្តបាន (ឬអាចរកបាន ដោយមិនចាំបាច់ចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ នៅពេលដែលការលើកលែងបែបនោះ ត្រូវបានផ្តល់ឱ្យ)។

## ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ

១១.៣៣ អង្គភាពមួយត្រូវឈប់ទទួលស្គាល់នូវទ្រព្យសកម្មហិរញ្ញវត្ថុ តែនៅពេលដែល ៖

(ក) សិទ្ធិតាមកិច្ចសន្យាលើលំហូរសាច់ប្រាក់ទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបានផុតកំណត់ ឬបានទូទាត់រួច

(ខ) អង្គភាពផ្ទេរដល់ភាគីផ្សេងទៀតនូវហានិភ័យនិងប្រាក់រង្វាន់កម្មសិទ្ធិភាគធំនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ

(គ) ទោះបីជាអង្គភាពបានទុកនូវហានិភ័យនិងប្រាក់រង្វាន់កម្មសិទ្ធិដែលគួរឲ្យកត់សម្គាល់ខ្លះៗក៏ដោយ អង្គភាពបានផ្ទេរការគ្រប់គ្រងលើទ្រព្យសកម្មដល់ភាគីផ្សេង ហើយភាគីផ្សេងមានលទ្ធភាពលក់ទ្រព្យសកម្ម ទាំងអស់ទៅឱ្យតតិយជនដែលមិនពាក់ព័ន្ធ ហើយភាគីផ្សេងនោះអាចអនុវត្តលទ្ធភាពនេះ ជាឯកតោភាគី និងដោយមិនចាំបាច់ដាក់លក្ខខណ្ឌបន្ថែមទៀតលើការផ្ទេរនេះ។ ក្នុងករណីនេះ អង្គភាពត្រូវ៖

១- ឈប់ទទួលស្គាល់ទ្រព្យសកម្ម និង

២- ទទួលស្គាល់ដោយឡែកពីគ្នានូវសិទ្ធិនិងកាតព្វកិច្ចដែលមានឬដែលបានបង្កើតឡើងនៅក្នុងការផ្ទេរ។

តម្លៃយោងនៃទ្រព្យសកម្មដែលបានផ្ទេរ នឹងត្រូវបានធ្វើវិភាជន៍រវាងសិទ្ធិនិងកាតព្វកិច្ចដែលមាន ជាមួយនឹងអ្វីដែលបានផ្ទេរដែលត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃតម្លៃសមស្របទាក់ទិននាកាលបរិច្ឆេទផ្ទេរ។ សិទ្ធិ និងកាតព្វកិច្ចដែលត្រូវបានបង្កើតឡើងថ្មី ត្រូវបានវាស់វែងតាមតម្លៃសមស្របនាកាលបរិច្ឆេទផ្ទេរនោះ។ រាល់ភាពខុសគ្នារវាងបរិមាណទឹកប្រាក់ដែលទទួលបាន និងបរិមាណទឹកប្រាក់ដែលទទួលស្គាល់ និងឈប់ ទទួលស្គាល់ស្របតាមកថាខណ្ឌនេះត្រូវតែទទួលស្គាល់នៅក្នុងចំណេញ ឬខាតក្នុងការិយបរិច្ឆេទផ្ទេរ។

១១.៣៤ ប្រសិនបើការផ្ទេរមិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ដោយសារតែអង្គភាពបានរក្សាទុកនូវហានិភ័យ និងប្រាក់រង្វាន់កម្មសិទ្ធិគួរឲ្យកត់សម្គាល់នៃទ្រព្យសកម្មដែលបានផ្ទេរ អង្គភាពត្រូវបន្តទទួលស្គាល់ទ្រព្យសកម្ម ដែលបានផ្ទេរទាំងមូល ហើយត្រូវទទួលស្គាល់បំណុលហិរញ្ញវត្ថុសម្រាប់ចំនួនទឹកប្រាក់ដែលទទួលបាន។ ទ្រព្យសកម្មនិងបំណុលមិនត្រូវបានកាត់កងគ្នាឡើយ។ សម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់ អង្គភាពត្រូវទទួលស្គាល់នូវចំណូលពីទ្រព្យសកម្មដែលបានផ្ទេរ និងទទួលស្គាល់នូវចំណាយនានាដែលកើតមានពីបំណុលហិរញ្ញវត្ថុ។

១១.៣៥ ប្រសិនបើអង្គភាពដែលផ្ទេរផ្តល់នូវវត្ថុបញ្ចាំមិនមែនជាសាច់ប្រាក់ (ដូចជា ឧបករណ៍បំណុល ឬឧបករណ៍មូលធន) ដល់អ្នកទទួល គណនេយ្យកម្មសម្រាប់វត្ថុបញ្ចាំដែលធ្វើដោយអង្គភាពផ្ទេរ និងដោយអ្នកទទួលអាស្រ័យលើថាតើអ្នកទទួលមានសិទ្ធិលក់ ឬធ្វើកិច្ចសន្យាបន្តលើវត្ថុបញ្ចាំ និងថាតើអង្គភាពផ្ទេរបានបំពានកិច្ចសន្យាឬទេ។ អង្គភាពផ្ទេរ និងអ្នកទទួល ត្រូវធ្វើគណនេយ្យកម្មលើវត្ថុបញ្ចាំដូចតទៅ ៖

(ក) ប្រសិនបើអ្នកទទួលមានសិទ្ធតាមកិច្ចសន្យា ឬតាមទម្លាប់ក្នុងការលក់ ឬធ្វើកិច្ចសន្យាបន្តនូវវត្ថុបញ្ចាំ អង្គភាពផ្ទេរត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញលើទ្រព្យសកម្មដាច់ដោយឡែកពីគ្នាពីទ្រព្យសកម្មផ្សេងៗទៀត នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ដូចជា ទ្រព្យសកម្មដែលបានឱ្យខ្ចី ឧបករណ៍មូលធនដែលបានដាក់សន្យា ឬគណនីត្រូវទទួលពីការទិញវិញ)។

(ខ) ប្រសិនបើអ្នកទទួលលក់វត្ថុបញ្ចាំដែលជាប់កិច្ចសន្យា នោះអ្នកទទួលត្រូវទទួលស្គាល់នូវចំណូលដែលបានពី ការលក់ ព្រមតាំងបំណុលដែលបានវាស់វែងតាមតម្លៃសមស្រប សម្រាប់កាតព្វកិច្ចរបស់ខ្លួនក្នុងការបង្វិលត្រឡប់ នូវវត្ថុបញ្ចាំនោះវិញ។

(គ) ប្រសិនបើអង្គភាពដែលផ្ទេរបំពាននូវលក្ខខណ្ឌនៅក្នុងកិច្ចសន្យា និងលែងមានសិទ្ធិរំលស់វត្ថុបញ្ចាំតទៅទៀត នោះអង្គភាពផ្ទេរត្រូវឈប់ទទួលស្គាល់នូវវត្ថុបញ្ចាំ ហើយអ្នកទទួលត្រូវទទួលស្គាល់នូវវត្ថុបញ្ចាំថាជា

ទ្រព្យសកម្ម របស់ខ្លួនដែលត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប ឬ ឈប់ទទួលស្គាល់កាតព្វកិច្ច របស់ខ្លួនក្នុង ការបង្វិលត្រឡប់នូវវត្ថុបញ្ចាំនោះ ប្រសិនបើគេបានលក់វត្ថុបញ្ចាំនោះហើយ។

(ឃ) លើកលែងតែបានចែងក្នុងចំណុច (គ)ខាងលើ អង្គភាពផ្ទេរត្រូវបន្តកាន់កាប់វត្ថុបញ្ចាំថាជាទ្រព្យសកម្ម របស់ខ្លួន ហើយអ្នកទទួលមិនត្រូវទទួលស្គាល់នូវវត្ថុបញ្ចាំថាជាទ្រព្យសកម្មរបស់ខ្លួនឡើយ។

ឧទាហរណ៍ ៖ ការផ្ទេរដែលបំពេញលក្ខខណ្ឌមិនទទួលស្គាល់អង្គភាពមួយ លក់គណនីអតិថិជនរបស់គេមួយចំនួនដល់ធនាគារមួយ ដែលមានតម្លៃទាបជាងបរិមាណចរិកពិតអង្គភាព នៅតែបន្តប្រមូលចំណូលពីកូនបំណុលរបស់ខ្លួនក្នុងនាមធនាគារ ដោយរួមទាំងបានផ្ញើរបាយការណ៍ប្រចាំខែដល់ធនាគារ ហើយធនាគារចំណាយដល់អង្គភាពនោះ នូវកម្រៃតាមអត្រាទីផ្សារលើសេវាកម្មទទួលនូវចំណូលពីអតិថិជន។ អង្គភាពត្រូវបានចាប់បង្ខំឱ្យបញ្ជូននូវបរិមាណសាច់ប្រាក់ ដែលប្រមូលបានភ្លាមទៅធនាគារ ប៉ុន្តែអង្គភាពពុំមានកាតព្វកិច្ចចំពោះ ធនាគារចំពោះការយឺតយ៉ាវបង់ ឬមិនបានបង់របស់កូនបំណុលនោះទេ។ ករណីនេះ អង្គភាពបានផ្ទេរនូវហានិភ័យ និងប្រាក់រង្វាន់កម្មសិទ្ធសំខាន់ៗលើប្រាក់ ដែលអតិថិជនជំពាក់រួចហើយ។ ដូចនេះ អង្គភាពត្រូវលុបនូវប្រាក់ដែលអតិថិជន ជំពាក់ពីរបាយការណ៍ស្ថានភាពហិរញ្ញរបស់ខ្លួន (មានន័យថា ឈប់ទទួលស្គាល់វា) ហើយវាមិនបង្ហាញនូវបំណុល ពាក់ព័ន្ធនឹងចំណូលដែលទទួលបានពីធនាគារនោះទេ។ អង្គភាពទទួលស្គាល់នូវបំណុលក្នុងក្របខណ្ឌដែលគាត់បានប្រមូល មូលនិធិពីកូនបំណុលដែលមិនទាន់បានប្រគល់ទៅឱ្យធនាគារតែប៉ុណ្ណោះ។

ឧទាហរណ៍ ៖ ការផ្ទេរដែលមិនបំពេញលក្ខខណ្ឌមិនទទួលស្គាល់ព្រឹត្តិការណ៍គឺដូចគ្នានឹងឧទាហរណ៍ខាងលើដែរលើកលែងតែថាអង្គភាពបានយល់ព្រមទិញត្រឡប់មកវិញពីធនាគារនូវចំណូលដែលអតិថិជនជំពាក់ដែលកូនបំណុលនៅជំពាក់ថ្លៃដើម ឬការប្រាក់រយៈពេលលើសពី១២០ ថ្ងៃ។ ករណីនេះ អង្គភាពបានរក្សាទុកនូវហានិភ័យពីការបង់ប្រាក់យឺតយ៉ាវ ឬការមិនបង់ប្រាក់ពីសំណាក់កូនបំណុល ដែលចាត់ទុកថា ជាហានិភ័យចម្បងនៃសាច់ប្រាក់ដែលអតិថិជនជំពាក់នោះ។ ដូចនេះអង្គភាពមិនត្រូវចាត់ទុកថា សាច់ប្រាក់របស់អតិថិជននោះត្រូវបានលក់ឱ្យធនាគារនោះទេ ហើយអង្គភាពមិនត្រូវមិនទទួលស្គាល់វាទេ។ ផ្ទុយមកវិញ អង្គភាព ត្រូវចាត់ទុកចំណូលទទួលបានពីធនាគារថាជាប្រាក់កម្ចីដែលធានាដោយសាច់ប្រាក់ដែលអតិថិជនជំពាក។ អង្គភាព បន្តទទួលស្គាល់នូវសាច់ប្រាក់ដែលអតិថិជនជំពាក់ ថាជាទ្រព្យសកម្មមួយរហូតទាល់តែសាច់ប្រាក់នោះត្រូវបានប្រមូល ឬចាត់ទុកថាមិនអាចប្រមូលបាន។

## ការឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ

១១.៣៦ អង្គភាពមួយ ត្រូវឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ (ឬបំណុលហិរញ្ញវត្ថុមួយចំណែក) តែនៅពេលដែលបំណុលនោះបានបញ្ចប់ មានន័យថា នៅពេលដែលកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យាត្រូវបានបំពេញចប់បាន លើកលែង ឬផុតអាយុកាល។

១១.៣៧ ប្រសិនបើកូនបំណុល និងម្ចាស់បំណុលធ្វើការដោះដូរឧបករណ៍ហិរញ្ញវត្ថុរវាងគ្នាជាមួយនឹងលក្ខខណ្ឌ ខុសគ្នាភាគច្រើន អង្គភាពត្រូវធ្វើគណនេយ្យកម្មប្រតិបត្តិការនេះថាជាការបញ្ចប់បំណុលហិរញ្ញវត្ថុដើម ហើយទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មី។ ដូចគ្នានេះដែរ អង្គភាពត្រូវធ្វើគណនេយ្យកម្មនូវការកែប្រែ មួយភាគធំទៅលើលក្ខខណ្ឌនៃបំណុលហិរញ្ញវត្ថុដែលមានស្រាប់ឬ មួយចំណែកនៃបំណុលនោះ (មិនថាវាដោយសារ ឬមិនមែនដោយសារតែផលវិបាកផ្នែកហិរញ្ញវត្ថុរបស់កូនបំណុល) ថាជាការបញ្ចប់ បំណុលហិរញ្ញវត្ថុដើម ហើយទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មី។

១១.៣៨ អង្គភាពត្រូវទទួលស្គាល់ក្នុងចំណេញ ឬខាតនូវភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុ (ឬបំណុល ហិរញ្ញវត្ថុ

មួយចំណែក) ដែលបានបញ្ចប់ ឬដែលបានផ្ទេរទៅភាគីផ្សេងទៀត និងរវាងបរិមាណទឹកប្រាក់ដែលបានបង់ រាប់បញ្ចូលទាំងទ្រព្យសកម្មដែលមិនមែនជាសាច់ប្រាក់ទាំងឡាយដែលបានផ្ទេរ ឬបំណុលសន្មត។

## ការលាតត្រដាង

១១.៣៩ ការលាតត្រដាងខាងក្រោម ត្រូវបានធ្វើឡើងដោយយោងលើការលាតត្រដាងអំពីបំណុលហិរញ្ញវត្ថុដែលបាន វាស់វែងតាមតម្លៃសមស្របក្នុងចំណេញ ឬខាត។ អង្គភាពដែលមានតែឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន(ហើយមិនចាំបាច់អនុវត្តផ្នែកទី ១២) នឹងមិនមានបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្រប ក្នុងចំណេញ ឬខាត ហើយដូចនេះមិនចាំបាច់ធ្វើការលាតត្រដាងនេះទេ។

## ការលាតត្រដាងអំពីគោលនយោបាយគណនេយ្យសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ

១១.៤០ ស្របតាមកថាខណ្ឌ ៨.៥ អង្គភាពត្រូវលាតត្រដាងអំពីមូលដ្ឋាននៃការវាស់វែង (ឬគោលការណ៍មូលដ្ឋាន) ដែលបានប្រើប្រាស់ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយគណនេយ្យផ្សេងៗទៀត ដែលបានប្រើប្រាស់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលទាក់ទិនទៅនឹងការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងសេចក្ដីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗរបស់ខ្លួន។

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ - ប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ

១១.៤១ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីតម្លៃយោង សម្រាប់ប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដូចខាងក្រោមនាកាលបរិច្ឆេទរាយការណ៍ជាចំនួនសរុប នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬនៅក្នុងកំណត់សម្គាល់ ៖

(ក) ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ ឬខាត (កថាខណ្ឌ១១.១៤(គ)១ និងកថាខណ្ឌ ១២.៨ និង ១២.៩)

(ខ) ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាឧបករណ៍បំណុ លដែលបានវាស់វែងតាមថ្លៃដើមដករំលស់ (កថាខណ្ឌ ១១.១៤ (ក))

(គ) ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាឧបករណ៍មូលធ នដែលបានវាស់វែងតាមថ្លៃដើមដកការថយចុះតម្លៃ (កថាខណ្ឌ១១.១៤(គ)២ និងកថាខណ្ឌ ១២.៨ និង១២.៩)

(ឃ) បំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ ឬខាត (កថាខណ្ឌ ១២.៨ និង ១២.៩)

(ង) បំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដករំលស់ (កថាខណ្ឌ ១១.១៤(ក)) និង

(ច) ការសន្យាកម្ចីដែលបានវាស់វែងតាមថ្លៃដើមដកការថយចុះតម្លៃ (កថាខណ្ឌ ១១.១៤(ខ))

១១.៤២ អង្គភាពត្រូវលាតត្រដាងព័ត៌មាន ដែលអាចឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន វាយតម្លៃលើសារៈសំខាន់នៃឧបករណ៍ហិរញ្ញវត្ថុចំពោះស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ខ្លួន។ ឧទាហរណ៍សម្រាប់បំណុលរយៈពេលវែង ព័ត៌មានបែបនេះជាធម្មតាអាចរាប់បញ្ចូលនូវលក្ខខណ្ឌនៃឧបករណ៍បំណុល (ដូចជា អត្រាការប្រាក់ ថ្ងៃដល់កាលកំណត់សង តារាងទូទាត់សង ព្រមទាំងលក្ខខណ្ឌកំណត់នានាដែលឧបករណ៍បំណុលដាក់កំហិតទៅលើអង្គភាព)។

១១.៤៣ សម្រាប់គ្រប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុទាំងអស់ដែលបានវាស់វែងតាមតម្លៃសមស្រប អង្គភាព

ត្រូវលាតត្រដាងព័ត៌មានអំពីមូលដ្ឋាននៃការកំណត់តម្លៃសមស្រប ឧទាហរណ៍ដូចជាតម្លៃទីផ្សារដែល បានស្រង់ពីទីផ្សារសកម្មមួយ ឬបច្ចេកទេសវាយតម្លៃ។ នៅពេលដែលបច្ចេកទេសវាយតម្លៃត្រូវបានប្រើប្រាស់ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីការសន្មតនានាដែលបានអនុវត្តក្នុងការកំណត់តម្លៃសមស្របសម្រាប់ ចំណាត់ថ្នាក់នីមួយៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ ឧទាហរណ៍ដូចជា អង្គភាព ប្រសិនបើអាចធ្វើបាន ត្រូវលាតត្រដាងព័ត៌មានអំពីការសន្មតនានាទាក់ទិនទៅនឹងអត្រានៃការទូទាត់មុន អត្រានៃការខាតបង់ឥណទានប៉ាន់ស្មាន និងអត្រាការប្រាក់ ឬអត្រាអប្បហារ។

១១.៤៤ ប្រសិនបើការវាស់វែងគួរឱ្យទុកចិត្តលើតម្លៃសមស្របមិនអាចរកបានទៀតហើយ ឬមិនអាចរកបានដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ នៅពេលដែលការលើកលែងបែបនេះត្រូវបានផ្តល់ឱ្យ សម្រាប់ ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានតម្រូវឱ្យវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ ឬខាតស្របតាមស្តង់ដារនេះ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីអង្គហេតុនេះ តម្លៃយោងនៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះ និង មូលហេតុ ដែលការវាស់វែងតម្លៃសមស្របគួរឱ្យទុកចិត្តបាននេះ នឹងនាំឱ្យមានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ប្រសិនបើការលើកលែងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុត្រូវបានប្រើ។

## ការឈប់ទទួលស្គាល់

១១.៤៥ ប្រសិនបើអង្គភាពបានផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុដល់ភាគីផ្សេងទៀត ក្នុងប្រតិបត្តិការមួយដែលមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឈប់ទទួលស្គាល់ (សូមមើលកថាខណ្ឌ ១១.៣៣-១១.៣៥) អង្គភាពត្រូវលាតត្រដាងព័ត៌មានសម្រាប់ថ្នាក់នីមួយៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដូចខាងក្រោម ៖

(ក) ប្រភេទនៃទ្រព្យសកម្ម

(ខ) ប្រភេទនៃហានិភ័យនិងប្រាក់រង្វាន់កម្មសិទ្ធិ ដែលអង្គភាពនៅមាន

(គ) តម្លៃយោងនៃទ្រព្យសកម្ម និងនៃបំណុលមានភ្ជាប់មកជាមួយនានា ដែលអង្គភាពបន្តទទួលស្គាល់។

## វត្ថុបញ្ចាំ

១១.៤៦ នៅពេលដែលអង្គភាពមួយបានយកទ្រព្យសកម្មហិរញ្ញវត្ថុបញ្ចាំសម្រាប់បំណុលហិរញ្ញវត្ថុ ឬបំណុលយថាហេតុ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចតទៅ ៖

(ក) តម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានបញ្ចាំ

(ខ) លក្ខខណ្ឌទាក់ទិននឹងការបញ្ចាំ។

## ការខកខាន និងការបំពានលើកម្ចីត្រូវសង

១១.៤៧ ចំពោះកម្ចីត្រូវសងដែលបានទទួលស្គាល់នាកាលបរិច្ឆេទរាយការណ៍ ដែលមានការបំពានលក្ខខណ្ឌ ឬខកខានមិនបានសងប្រាក់ដើម ការប្រាក់ មូលនិធិបណ្តាក់ទុន (ប្រាក់សន្សំទុកសងបំណុលពេលអនាគត) ឬលក្ខខណ្ឌរំលស់ ដែលមិនទាន់បានទូទាត់សងនាកាលបរិច្ឆេទរាយការណ៍ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម៖

(ក) ភាពលម្អិតនៃការខកខាន ឬការបំពាននោះ

(ខ) តម្លៃយោងនៃកម្ចីត្រូវសងដែលពាក់ព័ន្ធនាកាលបរិច្ឆេទរាយការណ៍

(គ) មិនថាការបំពានឬការខកខានត្រូវបានទូទាត់សង ឬមិនថាលក្ខខណ្ឌនៃកម្ចីត្រូវសងត្រូវបានចរចានោះទេ ការលាតត្រដាងត្រូវធ្វើមុនរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។

## ធាតុនៃចំណូល ចំណាយ ចំណេញ ឬខាត

១១.៤៨ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីធាតុនៃចំណូល ចំណាយ ចំណេញ ឬខាត ដូចខាងក្រោម៖

(ក) ចំណូល ចំណាយ ចំណេញ ឬខាត រួមទាំងការប្រែប្រួលនៃតម្លៃសមស្រប ដែលបានទទួលស្គាល់ទៅលើ៖

១- ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ ឬខាត

២- បំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ ឬខាត

៣- ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដករំលស់ និង

៤- បំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដករំលស់។

(ខ) ចំណូលពីការប្រាក់សរុប និងចំណាយលើការប្រាក់សរុប (ដែលត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព) សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាមតម្លៃសមស្រប ក្នុងចំណេញ ឬខាត។

(គ) បរិមាណនៃការខាតពីការថយចុះតម្លៃសម្រាប់ថ្នាក់នីមួយៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

# ផ្នែកទី ១២
# បញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ

## វិសាលភាពនៃផ្នែកទី ១១ និង១២

១២.១ ជារួម ផ្នែកទី១១ ស្តីពី ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និងផ្នែកទី ១២ នេះទាក់ទងទៅនឹងការទទួលស្គាល់ ការឈប់ទទួលស្គាល់ ការវាស់វែង និងការលាតត្រដាងអំពីឧបករណ៍ហិរញ្ញវត្ថុ (ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ)។ ផ្នែកទី១១ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ហើយទាក់ទិនទៅគ្រប់អង្គភាព ទាំងអស់។ ផ្នែកទី១២វិញ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុ និងប្រតិបត្តិការផ្សេងទៀតដែលស្មុគស្មាញជាង។ ប្រសិនបើអង្គភាពមួយមានតែប្រតិបត្តិការឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ផ្នែកទី១២ មិនត្រូវបានអនុវត្តឡើយ។ ប៉ុន្តែ ទោះបីជាអង្គភាពទាំងនោះមានតែឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋានក៏ដោយ អង្គភាពទាំងនោះត្រូវពិនិត្យមើល វិសាលភាពនៃផ្នែកទី១២ ដើម្បីធានាថាខ្លួនពិតជាត្រូវបានលើកលែង។

## ការជ្រើសរើសគោលនយោបាយគណនេយ្យ

១២.២ អង្គភាពមួយត្រូវជ្រើសរើសអនុវត្តចំណុចណាមួយខាងក្រោម៖

(ក) ការតម្រូវទាំងស្រុងដែលមាននៅក្នុងផ្នែកទី១១ និងផ្នែកទី១២ ឬ

(ខ) ការតម្រូវនៃការទទួលស្គាល់ និងការវាស់វែងតាមស្តង់ដារគណនេយ្យអន្តរជាតិលេខ ៣៩ ស្តីពី ឧបករណ៍ហិរញ្ញវត្ថុៈការទទួលស្គាល់ និងការវាស់វែង និងការតម្រូវឱ្យលាតត្រដាងព័ត៌មានតាមផ្នែកទី១១ និងផ្នែកទី១២ ដើម្បីធ្វើគណនេយ្យកម្មនូវរាល់ឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួនទាំងអស់។ ជម្រើសរបស់អង្គភាពរវាងចំណុច (ក) ឬ (ខ) គឺជាការជ្រើសរើសគោលនយោបាយគណនេយ្យ។ កថាខណ្ឌ ១០.៨-១០.១៤ មានចែងអំពីការតម្រូវនានា សម្រាប់កំណត់លើពេលវេលាសមរម្យក្នុងការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ លើការធ្វើគណនេយ្យកម្ម ទៅលើការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ និងព័ត៌មាននានាដែលគួរត្រូវលាតត្រដាងអំពីការផ្លាស់ប្តូរគោល នយោបាយគណនេយ្យ។

## វិសាលភាពនៃផ្នែកទី១២

១២.៣ ផ្នែកទី ១២ អនុវត្តចំពោះគ្រប់ឧបករណ៍ហិរញ្ញវត្ថុ លើកលែងតែឧបករណ៍មួយចំនួនដូចខាងក្រោម:

(ក) ឧបករណ៍ហិរញ្ញវត្ថុដែលគ្របដណ្តប់ក្នុងផ្នែកទី ១១។

(ខ) ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ដែលត្រូវបានកត់ត្រាស្របតាមផ្នែកទី៩ ស្តីពី របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ផ្នែកទី១៤ ស្តីពីការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ឬផ្នែកទី១៥ ស្តីពី ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន។

(គ) សិទ្ធិ និងកាតព្វកិច្ចរបស់និយោជក ស្ថិតក្រោមផែនការអត្ថប្រយោជន៍និយោជិត (សូមមើលផ្នែកទី ២៨ ស្ដីពីអត្ថប្រយោជន៍និយោជិត)។

(ឃ) សិទ្ធិតាមកិច្ចសន្យាធានារ៉ាប់រង លើកលែងតែកិច្ចសន្យាធានារ៉ាប់រងដែលអាចនាំឱ្យមានការខាតបង់ចំពោះភាគីណាមួយដោយសារលក្ខខណ្ឌនៃកិច្ចសន្យាដែលមិនពាក់ព័ន្ធទៅនឹង៖

១- ការប្រែប្រួលនៃហានិភ័យដែលត្រូវបានធានា ឬ

២- ការប្រែប្រួលនៃអត្រាប្តូររូបិយបណ្ណបរទេស ឬ

៣- ការខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដោយភាគីម្ខាងទៀត។

(ង) ឧបករណ៍ហិរញ្ញវត្ថុដែលបំពេញបានតាមនិយមន័យនៃមូលធនផ្ទាល់របស់អង្គភាព រួមបញ្ចូលទាំង សមាសធាតុមូលធននៃឧបករណ៍ហិរញ្ញវត្ថុផ្សំដែលបោះផ្សាយដោយអង្គភាព (សូមមើលផ្នែកទី២២ ស្ដីពីបំណុល និងមូលធន)។

(ច) ភតិសន្យាដែលស្ថិតក្នុងវិសាលភាពនៃផ្នែកទី២០ ស្ដីពីភតិសន្យា។ ដូច្នេះ ផ្នែកទី១២ អនុវត្តចំពោះភតិសន្យាទាំងឡាយដែលអាចបណ្តាលឱ្យមានការខាតបង់ចំពោះភតិបតី ឬភតិក: ដោយសារតែលក្ខខណ្ឌនៃកិច្ចសន្យា ដែលមិនពាក់ព័ន្ធនឹង៖

១- ការប្រែប្រួលថ្លៃនៃទ្រព្យសកម្មក្រោមភតិសន្យា ឬ

២- ការប្រែប្រួលនៃអត្រាប្តូររូបិយបណ្ណបរទេស ឬ

៣- ការប្រែប្រួលនៃការទូទាត់ភតិសន្យា ផ្អែកលើបម្រែបម្រួលនៃអត្រាការប្រាក់ទីផ្សារ ឬ

៤- ការខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដោយភាគីម្ខាងទៀត។

(ឆ) កិច្ចសន្យាសម្រាប់តម្លៃតបស្នងយថាហេតុនៅក្នុងការរួមបញ្ចូលអាជីវកម្ម (សូមមើលផ្នែកទី ១៩ ស្ដីពី ការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម)។ ការលើកលែងនេះអនុវត្តតែចំពោះតែអ្នកទិញប៉ុណ្ណោះ។

(ជ) ឧបករណ៍ហិរញ្ញវត្ថុកិច្ចសន្យា និងកាតព្វកិច្ចស្ថិតក្រោមប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុនដែលត្រូវ អនុវត្តតាមផ្នែកទី២៦ ស្ដីពីការទូទាត់ដោយផ្អែកលើភាគហ៊ុន។

(ឈ) ទ្រព្យសកម្មសំណងដែលត្រូវបានកត់ត្រាស្របតាមផ្នែកទី២១ ស្ដីពីសំវិធានធន និងយថាភាព (សូមមើលកថាខណ្ឌ២១.៩)។

១២.៤ កិច្ចសន្យាភាគច្រើនដែលប្រើដើម្បីទិញ ឬលក់ធាតុមិនមែនជាហិរញ្ញវត្ថុណាមួយដូចជា វត្ថុធាតុដើម សន្និធិ ឬទ្រព្យរោងចក្រ និងបរិក្ខារ មិនត្រូវរាប់បញ្ចូលក្នុងផ្នែកនេះទេ ពីព្រោះថាវាមិនមែនជាឧបករណ៍ហិរញ្ញវត្ថុទេ។ យ៉ាងណាមិញ ផ្នែកនេះអនុវត្តចំពោះគ្រប់កិច្ចសន្យាទាំងអស់ដែលដាក់ហានិភ័យលើអ្នកទិញ ឬអ្នកលក់ដែលមិនមានបែបផែនជាកិច្ចសន្យាទិញ ឬលក់ធាតុមិនមែនជាប្រភេទហិរញ្ញវត្ថុណាមួយ។ ឧទាហរណ៍ ផ្នែកនេះ អនុវត្តចំពោះកិច្ចសន្យាដែលអាចបណ្តាលឱ្យមានការខាតបង់ចំពោះអ្នកទិញ ឬអ្នកលក់ដោយសារតែលក្ខខណ្ឌ នៃកិច្ចសន្យាដែលពាក់ព័ន្ធនឹងកាប្រែប្រួលនៃតម្លៃរបស់ធាតុមិនមែនជាហិរញ្ញវត្ថុ ការប្រែប្រួលអត្រាប្តូរ រូបិយបណ្ណបរទេស ឬការខកខានមិនបានបំពេញតាមកិច្ចសន្យាដោយភាគីម្ខាងទៀត។

១២.៥ បន្ថែមពីលើកិច្ចសន្យាដែលបានពិពណ៌នាក្នុងកថាខណ្ឌ ១២.៤ ផ្នែកនេះអនុវត្តចំពោះកិច្ចសន្យាទិញ ឬលក់ធាតុមិនមែនជាហិរញ្ញវត្ថុ ប្រសិនបើកិច្ចសន្យាអាចត្រូវបានទូទាត់ជាសាច់ប្រាក់ ឬជាឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត

ឬ ទូទាត់ដោយការដោះដូរឧបករណ៍ហិរញ្ញវត្ថុ ដូចទៅនឹងកិច្ចសន្យាសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀត ដែលលើកលែងចំពោះកិច្ចសន្យាមិនមែនជាឧបករណ៍ហិរញ្ញវត្ថុដែលបានធ្វើឡើង និងបន្តសុពលភាពក្នុងគោលបំណងទទួលយក ឬប្រគល់ជាតុមិនមែនជាហិរញ្ញវត្ថុស្របតាមការតម្រូវនៃការទិញ លក់ ឬប្រើប្រាស់ដែលអង្គភាពរំពឹងទុក។

## ការទទួលស្គាល់លើកដំបូងនូវទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

១២.៦ អង្គភាពមួយត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬបំណុលហិរញ្ញវត្ថុមួយ តែនៅពេលដែលអង្គភាពនោះក្លាយជាភាគីនៃកិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ។

## ការវាស់វែងលើកដំបូង

១២.៧ នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬបំណុលហិរញ្ញវត្ថុមួយត្រូវបានទទួលស្គាល់លើកដំបូង អង្គភាពត្រូវវាស់វែងនូវទ្រព្យ ឬបំណុលនោះតាមតម្លៃសមស្រប ដែលជាធម្មតាគឺជាតម្លៃនៃប្រតិបត្តិការ។

## ការវាស់វែងជាបន្តបន្ទាប់

១២.៨ នាចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ អង្គភាពត្រូវវាស់វែងឧបករណ៍ហិរញ្ញវត្ថុទាំងអស់ដែលស្ថិតក្រោមវិសាលភាពនៃផ្នែកទី១២នេះតាមតម្លៃសមស្រប ហើយត្រូវទទួលស្គាល់ការប្រែប្រួលនៃតម្លៃសមស្របនេះនៅក្នុងចំណេញ ឬខាត លើកលែងករណីដូចតទៅ:

(ក) ការប្រែប្រួលមួយចំនួនលើតម្លៃសមស្របនៃឧបករណ៍ទប់ស្កាត់ហានិភ័យ នៅក្នុងទំនាក់ទំនងទប់ស្កាត់ហានិភ័យដែលបានកំណត់ ត្រូវបានតម្រូវឱ្យទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀត តាមកថាខណ្ឌ ១២.២៣។

(ខ) ឧបករណ៍មូលធនដែលមិនត្រូវបានដាក់លក់ជាសាធារណៈ ហើយដែលតម្លៃសមស្របរបស់វាមិនអាច វាស់វែងគួរឱ្យទុកចិត្តដោយគ្មានតម្លៃដើម ឬកិច្ចប្រឹងប្រែងហួសហេតុ និងកិច្ចសន្យានានាទាក់ទិននឹងឧបករណ៍មូលធនដែលប្រសិនបើអនុវត្ត នឹងបណ្តាលឱ្យមានការប្រគល់ឧបករណ៍មូលធននោះ។ អង្គភាពត្រូវវាស់វែងដោយយកថ្លៃដើមដកការថយចុះតម្លៃវិញ។

១២.៩ ប្រសិនបើការវាស់វែងដែលគួរឱ្យទុកចិត្តបានលើតម្លៃសមស្របមិនអាចប្រើប្រាស់បានទៀតទេដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុសម្រាប់ឧបករណ៍មូលធនដែលមិនត្រូវបានដាក់លក់ជាសាធារណៈ ឬ កិច្ចសន្យា ទាក់ទិននឹងឧបករណ៍មូលធនដែលប្រសិនបើអនុវត្ត នឹងបណ្តាលឱ្យមានការប្រគល់ឧបករណ៍មូលធន ប៉ុន្តែវាត្រូវ បានវាស់វែងតាមតម្លៃសមស្របឆ្លងកាត់ចំណេញ ឬខាត ដូចនេះ តម្លៃសមស្របរបស់វានាកាលបរិច្ឆេទចុង ក្រោយដែលឧបករណ៍នោះត្រូវបានវាស់វែងគួរឱ្យទុកចិត្តបានដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុត្រូវ បានចាត់ទុកថាជាថ្លៃដើមនៃឧបករណ៍ ។ អង្គភាពត្រូវវាស់វែងឧបករណ៍ ដោយយកថ្លៃដើមដកការថយចុះតម្លៃ រហូតទាល់តែអង្គភាពអាចកំណត់ការវាស់វែងដែលគួរឱ្យទុកចិត្តលើតម្លៃសមស្របបាន ដោយគ្មានចំណាយ ឬ កិច្ចប្រឹងប្រែងហួសហេតុ។

## តម្លៃសមស្រប

១២.១០ អង្គភាពត្រូវអនុវត្តគោលការណ៍ណែនាំអំពីតម្លៃសមស្របក្នុងកថាខណ្ឌ ១១.២៧-១១.៣២ សម្រាប់ការវាស់វែងតម្លៃសមស្របឱ្យស្របតាមផ្នែកនេះ ក៏ដូចជាចំពោះការវាស់វែងតម្លៃសមស្របឱ្យស្របតាម ផ្នែកទី១១។

១២.១១ តម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុដែលត្រូវបង់តាមតម្រូវការ គឺមិនទាបជាងចំនួនដែលត្រូវសងតាមតម្រូវការ ដោយមានការបញ្ចុះតម្លៃពីកាលបរិច្ឆេទដំបូងដែលចំនួននេះអាចតម្រូវឱ្យបង់នោះទេ។

១២.១២ អង្គភាពមិនត្រូវគិតបញ្ចូលនូវថ្លៃដើមប្រតិបត្តិការនៅក្នុងការវាស់វែងលើកដំបូងលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលនឹងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃសមស្របឆ្លងកាត់ការចំណេញឬខាត។ ប្រសិនបើការទូទាត់ចំពោះទ្រព្យសកម្មមួយត្រូវបានពន្យារ ឬត្រូវបានធ្វើហិរញ្ញប្បទានតាមអត្រាការប្រាក់ ដែល មិនមែនជាអត្រាការប្រាក់ទីផ្សារ អង្គភាពត្រូវវាស់វែងលើកដំបូងនូវទ្រព្យសកម្មតាមតម្លៃជាក់ស្តែង នៃការទូទាត់នា ពេលអនាគតដោយត្រូវបញ្ចុះតម្លៃតាមអត្រាការប្រាក់លើទីផ្សារ។

## ការថយចុះតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើម ឬតាមថ្លៃដើមដករំលស់

១២.១៣ អង្គភាពត្រូវអនុវត្តគោលការណ៍ណែនាំស្តីពីការថយចុះតម្លៃដែលចែងក្នុងកថាខណ្ឌ ១១.២១-១១.២៦ លើឧបករណ៍ហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដកការថយចុះតម្លៃស្របតាមផ្នែកនេះ។

## ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ

១២.១៤ អង្គភាពត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការឈប់ទទួលស្គាល់ក្នុងកថាខណ្ឌ ១១. ៣៣-១១. ៣៨ លើ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ តាមការអនុវត្តរបស់ផ្នែកនេះ។

## គណនេយ្យទប់ស្កាត់ហានិភ័យ

១២.១៥ ប្រសិនបើបំពេញគ្រប់តាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ អង្គភាពអាចកំណត់នូវទំនាក់ទំនងទប់ស្កាត់ ហានិភ័យរវាងឧបករណ៍ទប់ស្កាត់ហានិភ័យមួយ និង ជាតុទប់ស្កាត់ហានិភ័យមួយតាមវិធីណាមួយដើម្បីធ្វើឱ្យមាន គុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យ។ គណនេយ្យទប់ស្កាត់ហានិភ័យអនុញ្ញាតឱ្យមានការ ទទួលស្គាល់នូវផលចំណេញ ឬខាតលើឧបករណ៍ទប់ស្កាត់ហានិភ័យ និងលើជាតុទប់ស្កាត់ហានិភ័យនៅក្នុង របាយការណ៍ចំណេញឬខាតនៅពេលតែមួយ។

១២.១៦ ដើម្បីឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រើគណនេយ្យទប់ស្កាត់ហានិភ័យ អង្គភាពត្រូវអនុលោមតាមលក្ខខណ្ឌដូចតទៅ ៖

(ក) អង្គភាពកំណត់ និងកត់ត្រាជាឯកសារនូវទំនាក់ទំនងទប់ស្កាត់ហានិភ័យ ដើម្បីឱ្យហានិភ័យដែលត្រូវទប់ស្កាត់ ជាតុទប់ស្កាត់ហានិភ័យ និងឧបករណ៍ទប់ស្កាត់ហានិភ័យត្រូវបានកំណត់យ៉ាងច្បាស់ និងហានិ

ភ័យលើជាតុទប់ស្កាត់ទប់ស្កាត់ហានិភ័យនោះ ត្រូវបានទប់ស្កាត់ដោយឧបករណ៍ទប់ស្កាត់ហានិភ័យនោះ។

(ខ) ហានិភ័យដែលបានទប់ស្កាត់ គឺជាហានិភ័យមួយដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១២.១៧។

(គ) ឧបករណ៍ទប់ស្កាត់ហានិភ័យ មានដូចជាបានបញ្ជាក់នៅក្នុងកថាខណ្ឌ១២.១៨។

(ឃ) អង្គភាពរំពឹងថាឧបករណ៍ទប់ស្កាត់ហានិភ័យ ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការទូទាត់ជាមួយហានិភ័យដែលបានទប់ស្កាត់កំណត់ជាមុន។ ប្រសិទ្ធភាពនៃការទប់ស្កាត់ គឺជាកម្រិតដែលការប្រែប្រួលលើតម្លៃសមស្រប ឬលើលំហូរសាច់ប្រាក់នៃជាតុទប់ស្កាត់ហានិភ័យដែលអាចកំណត់បានតាមរយៈហានិភ័យដែលបានទប់ស្កាត់ ទូទាត់ជាមួយការប្រែប្រួលនៃតម្លៃសមស្រប ឬនៃលំហូរសាច់ប្រាក់នៃឧបករណ៍ទប់ស្កាត់ហានិភ័យនោះ។

១២.១៧ ស្តង់ដារនេះអនុញ្ញាតឱ្យមានការធ្វើគណនេយ្យទប់ស្កាត់ហានិភ័យសម្រាប់តែហានិភ័យដូចខាងក្រោម ៖

(ក) ហានិភ័យលើអត្រាការប្រាក់នៃឧបករណ៍បំណុលដែលវាស់វែងតាមថ្លៃដើមដករំលស់។

(ខ) ហានិភ័យលើអត្រាប្តូររូបិយបណ្ណបរទេស ឬអត្រាការប្រាក់ក្នុងការសន្យាយ៉ាងមុតមាំមួយ ឬប្រតិបត្តិការព្យាករណ៍ដែលអាចនឹងមានកម្រិតខ្ពស់។

(គ) ហានិភ័យលើតម្លៃវត្ថុធាតុដើមដែលអង្គភាពមាន ឬមានការសន្យាយ៉ាងមុតមាំមួយ ឬប្រតិបត្តិការ ព្យាករណ៍ដែលអាចនឹងមានកម្រិតខ្ពស់ ដើម្បីទិញ ឬលក់វត្ថុធាតុដើមនោះ។

(ឃ) ហានិភ័យលើអត្រាប្តូររូបិយបណ្ណបរទេសរបស់ការវិនិយោគសរុបនៅក្នុងប្រតិបត្តិការបរទេស។

ហានិភ័យលើអត្រាប្តូររូបិយបណ្ណបរទេសនៃឧបករណ៍បំណុលមួយដែលបានវាស់វែងតាមថ្លៃដើមដករំលស់មិនស្ថិតនៅក្នុងបញ្ជីខាងលើទេ ពីព្រោះថាគណនេយ្យទប់ស្កាត់ហានិភ័យមិនមានឥទ្ធិពលអ្វីខ្លាំងលើរបាយការណ៍ហិរញ្ញវត្ថុឡើយ។ គណនីមូលដ្ឋាន បំណុល និង កម្ចីត្រូវទទួល និងត្រូវសង ជាធម្មតាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ (សូមមើលកថាខណ្ឌ ១១.៥(ឃ))។ នេះរួមមានទឹកប្រាក់ដែលត្រូវសងដែលបានកំណត់ជារូបិយបណ្ណបរទេស។ កថាខណ្ឌ ៣០.១០ តម្រូវឱ្យរាល់ការប្រែប្រួលលើតម្លៃយោងនៃទឹកប្រាក់ដែលត្រូវបង់ ដែលបណ្តាល មកពីការប្រែប្រួលអត្រាប្តូរប្រាក់ ត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ ដូចនេះ ទាំងការប្រែប្រួលលើតម្លៃ សមស្របរបស់ឧបករណ៍ទប់ស្កាត់ហានិភ័យ (ការផ្លាស់ប្តូររូបិយបណ្ណ) និងការប្រែប្រួលលើតម្លៃយោងនៃទឹក ប្រាក់ដែលត្រូវបង់ ដែលបណ្តាលមកពីការប្រែប្រួលនៃអត្រាប្តូរប្រាក់ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត ហើយគួរត្រូវបានទូទាត់គ្នា លើកលែងតែមានវិសាលភាពនៃភាពខុសគ្នារវាងអត្រាជាក់ស្តែង (ដែលបំណុលត្រូវ បានវាស់វែងតាមនោះ) និងអត្រានាពេលអនាគត (ដែលការដោះដូរត្រូវបានវាស់វែង)។

១២.១៨ ស្តង់ដារនេះអនុញ្ញាតឱ្យធ្វើគណនេយ្យកម្មទប់ស្កាត់ហានិភ័យ លុះត្រាតែពេលដែលឧបករណ៍ទប់ស្កាត់ហានិភ័យមាន ខចែង និងលក្ខខណ្ឌទាំងអស់ដូចខាងក្រោម ៖

(ក) វាគឺជាការដោះដូរអត្រាការប្រាក់ ការដោះដូររូបិយបណ្ណបរទេស កិច្ចសន្យាប្តូររូបិយបណ្ណបរទេសនាពេលអនាគត ឬកិច្ចសន្យាប្តូរវត្ថុធាតុដើមនាពេលអនាគត ដែលរំពឹងថានឹងមានប្រសិទ្ធភាពខ្ពស់លើការទូទាត់ហានិភ័យដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១២.១៧ ដែលបានកំណត់ថាជាហានិភ័យដែលបានទប់ស្កាត់។

(ខ) វាបញ្ចូលភាគីមួយដែលផ្សេងពីអង្គភាពរាយការណ៍ (មានន័យថា ក្រៅពីសម្ព័ន្ធក្រុមហ៊ុន ផ្នែកណាមួយ ឬអង្គភាពផ្ទាល់ដែលត្រូវបានរាយការណ៍)។

(គ) ចំនួនជាសញ្ញាររបស់វាស្មើនឹងបរិមាណនៃតម្លៃដើមដែលបានកំណត់ ឬស្មើនឹងបរិមាណជាសញ្ញាណ នៃធាតុទប់ស្កាត់ហានិភ័យ។

(ឃ) វាមានកាលបរិច្ឆេទកំណត់ដែលបានបញ្ជាក់មិនលើសពី ៖

១- កាលបរិច្ឆេទកំណត់នៃឧបករណ៍ហិរញ្ញវត្ថុដែលបានទប់ស្កាត់ហានិភ័យ ឬ

២- ការទូទាត់ដែលរំពឹងទុកនៃការសន្យាទិញ ឬលក់វត្ថុធាតុដើម ឬ

៣- មានការកើតឡើងនូវការព្យាករណ៍ដែលអាចនឹងមានកម្រិតខ្ពស់លើរូបិយបណ្ណបរទេស ឬលើប្រតិបត្តិការទិញលក់វត្ថុធាតុដើមដែលបានទប់ស្កាត់ហានិភ័យ។

(ង) វាមិនមានលក្ខណៈនូវការទូទាត់មុន ការបញ្ចប់មុន ឬការពន្យារ។

## ការទប់ស្កាត់ហានិភ័យលើអត្រាការប្រាក់ថេរនៃឧបករណ៍ហិរញ្ញវត្ថុមួយដែលបានទទួលស្គាល់ ឬហានិភ័យ លើតម្លៃវត្ថុធាតុដើមសម្រាប់វត្ថុធាតុដើមដែលមាន

១២.១៩ ប្រសិនបើលក្ខខណ្ឌនៅក្នុងកថាខណ្ឌ ១២.១៦ ត្រូវបានបំពេញ ហើយហានិភ័យដែលបានទប់ស្កាត់គឺជាការបង្ហាញអំពីហានិភ័យលើអត្រាការប្រាក់ថេរនៃឧបករណ៍បំណុលដែលបានវាស់វែងតាមថ្លៃដើមដករំលស់ ឬ បង្ហាញអំពីហានិភ័យលើតម្លៃវត្ថុធាតុដើមដែលអង្គភាពមាន អង្គភាពនោះត្រូវ៖

(ក) ទទួលស្គាល់នូវឧបករណ៍ទប់ស្កាត់ហានិភ័យថាជាទ្រព្យសកម្មមួយ ឬបំណុលមួយ និងទទួលស្គាល់នូវការប្រែប្រួលតម្លៃសមស្របនៃឧបករណ៍ទប់ស្កាត់ហានិភ័យនៅក្នុងចំណេញ ឬខាត និង

(ខ) ទទួលស្គាល់នូវការប្រែប្រួលតម្លៃសមស្របនៃធាតុទប់ស្កាត់ហានិភ័យទាក់ទងនឹងហានិភ័យដែលបានទប់ស្កាត់នៅក្នុងចំណេញ ឬខាត ហើយត្រូវទទួលស្គាល់ថាជាការធ្វើនិយ័តកម្មលើតម្លៃយោងនៃធាតុដែលបានទប់ស្កាត់ហានិភ័យ។

១២.២០ ប្រសិនបើហានិភ័យដែលបានទប់ស្កាត់ គឺជាហានិភ័យលើអត្រាការប្រាក់ថេរនៃឧបករណ៍បំណុលដែលបានវាស់វែងតាមថ្លៃដើមដករំលស់ អង្គភាពត្រូវទទួលស្គាល់នូវការទូទាត់ជាសាច់ប្រាក់សុទ្ធតាមកាលបរិច្ឆេទកំណត់ លើការដោះដូរ អត្រាការប្រាក់ដែលវាជាឧបករណ៍ទប់ស្កាត់ហានិភ័យក្នុងចំណេញ ឬខាតនៅក្នុងគ្រាដែលការ ទូទាត់សុទ្ធត្រូវបានបង្គរ។

១២.២១ អង្គភាពមិនត្រូវបន្តការធ្វើគណនេយ្យកម្មទប់ស្កាត់ហានិភ័យ ដែលបានកំណត់នៅក្នុងកថាខណ្ឌ ១២.១៩ ប្រសិនបើ ៖

(ក) ឧបករណ៍ទប់ស្កាត់ហានិភ័យហួសកាលកំណត់ ឬត្រូវបានលក់ ឬត្រូវបានបញ្ចប់ ឬ

(ខ) ការទប់ស្កាត់ហានិភ័យលែងបំពេញតាមលក្ខខណ្ឌសម្រាប់ធ្វើគណនេយ្យកម្មទប់ស្កាត់ហានិភ័យដែលបានកំណត់ក្នុងកថាខណ្ឌ ១២.១៦ ឬ

(គ) អង្គភាពដកហូតការកំណត់នោះ។

១២.២២ ប្រសិនបើគណនេយ្យកម្មទប់ស្កាត់ហានិភ័យមិនត្រូវបានបន្ត ហើយជាតុទប់ស្កាត់ហានិភ័យគឺជាទ្រព្យសកម្មឬបំណុលដែលបានគិតតម្លៃយោងតាមថ្លៃដើមដករំលស់ ដែលមិនត្រូវបានឈប់ទទួលស្គាល់ នោះផលចំណេញឬខាតដែលទទួលស្គាល់ថាជាការធ្វើនិយ័តកម្មលើតម្លៃយោងរបស់ជាតុទប់ស្កាត់ហានិភ័យនោះត្រូវបានរំលស់នៅ ក្នុងរបាយការណ៍លទ្ធផល ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព សម្រាប់រយៈពេលជីវិតនៃជាតុទប់ស្កាត់ហានិភ័យនោះ។

## ការទប់ស្កាត់ហានិភ័យលើអត្រាការប្រាក់អថេរនៃឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់ ហានិភ័យលើការប្តូររូបិយបណ្ណបរទេស ឬហានិភ័យលើតម្លៃវត្ថុធាតុដើម នៅក្នុងការសន្យារមុតមាំមួយ ឬប្រតិបត្តិការព្យាករណ៍ដែលអាច

១២.២៣ ប្រសិនបើលក្ខខណ្ឌក្នុងកថាខណ្ឌ ១២.១៦ ត្រូវបានបំពេញ ហើយហានិភ័យទប់ស្កាត់គឺជា ៖

(ក) ហានិភ័យលើអត្រាការប្រាក់អថេរនៅក្នុងឧបករណ៍បំណុលដែលបានវាស់វែងតាមថ្លៃដើមដករំលស់ ឬ

(ខ) ហានិភ័យលើការប្តូររូបិយបណ្ណបរទេសនៅក្នុងការសន្យារមុតមាំមួយ ឬ ប្រតិបត្តិការព្យាករណ៍ដែលអាចនឹងមានកម្រិតខ្ពស់ ឬ

(គ) ហានិភ័យលើតម្លៃវត្ថុធាតុដើមនៅក្នុងការសន្យារមុតមាំមួយ ឬ ប្រតិបត្តិការព្យាករណ៍ដែលអាចនឹងមានកម្រិតខ្ពស់ ឬ

(ឃ) ហានិភ័យលើការប្តូររូបិយបណ្ណបរទេសនៅក្នុងការវិនិយោគសុទ្ធក្នុងប្រតិបត្តិការបរទេស

អង្គភាពត្រូវទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀតនូវចំណែកនៃការប្រែប្រួលលើតម្លៃសមស្របនៃ ឧបករណ៍ទប់ស្កាត់ហានិភ័យដែលមានប្រសិទ្ធភាពក្នុងការកាត់កងជាមួយការប្រែប្រួលលើតម្លៃសមស្រប ឬ ការប្រែប្រួលលំហូរសាច់ប្រាក់ដែលបានរំពឹងទុករបស់ជាតុទប់ស្កាត់ហានិភ័យ។ អង្គភាពត្រូវទទួលស្គាល់ក្នុង ចំណេញ ឬខាត ក្នុងការិយបរិច្ឆេទនីមួយៗ នូវចំនួនលើស (ក្នុងចំនួនដាច់ខាត) រវាងការប្រែប្រួលនៃតម្លៃសមស្រប របស់ឧបករណ៍ទប់ស្កាត់ហានិភ័យដែលបានបង្គរ និងការប្រែប្រួលនៃតម្លៃសមស្របនៃលំហូរសាច់ប្រាក់ ដែល បានរំពឹងទុក និងដែលបានបង្គរតាំងពីការចាប់ផ្តើមនៃការទប់ស្កាត់ហានិភ័យ (ជួនកាលហៅថា អប្រសិទ្ធភាព នៃការទប់ស្កាត់ហានិភ័យ)។ ផលចំណេញ ឬខាតពីការទប់ស្កាត់ ហានិភ័យដែលបានទទួលស្គាល់នៅក្នុងចំណូល លម្អិតផ្សេងទៀត ត្រូវធ្វើការចាត់ថ្នាក់ឡើងវិញក្នុងចំណេញ ឬ ខាត នៅពេលដែលជាតុទប់ស្កាត់ហានិភ័យត្រូវ បានទទួលស្គាល់នៅក្នុងចំណេញ ឬខាត អនុលោមតាមលក្ខខណ្ឌ នៅក្នុងកថាខណ្ឌ១២.២៥។ ប៉ុន្តែ ចំនួនបង្គរ នៃភាពខុសគ្នានានានៃការប្តូររូបិយបណ្ណបរទេស ដែលទាក់ទងនឹងការការទប់ស្កាត់ហានិភ័យលើការវិនិយោគសុទ្ធក្នុង ប្រតិបត្តិការបរទេសដែលត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀតមិនត្រូវបានធ្វើចំណាត់ថ្នាក់ ឡើងវិញក្នុងចំណេញ ឬខាត នៅពេលដែលមានការលក់ទាំងស្រុង ឬការលក់ជាចំណែកណាមួយនៃប្រតិបត្តិការ បរទេសឡើយ។

១២.២៤ ប្រសិនបើហានិភ័យដែលបានទប់ស្កាត់ជាហានិភ័យលើអត្រាការប្រាក់អថេរក្នុងឧបករណ៍បំណុល ដែលបានវាស់វែងតាមថ្លៃដើមដករំលស់ អង្គភាពត្រូវទទួលស្គាល់ជាបន្តបន្ទាប់នៅក្នុងចំណេញ ឬខាត នូវការទូទាត់ជាសាច់ប្រាក់សុទ្ធតាមការិយបរិច្ឆេទកំណត់ បានមកពីការដោះដូរអត្រាការប្រាក់ដែលជាឧបករណ៍ទប់ស្កាត់ ហានិភ័យក្នុងការិយបរិច្ឆេទដែលការទូទាត់សុទ្ធត្រូវបានបង្គរ។

១២.២៥ អង្គភាពមិនត្រូវបន្តការធ្វើគណនេយ្យកម្មទប់ស្កាត់ហានិភ័យ ដែលបានកំណត់នៅក្នុងកថាខណ្ឌ ១២.២៣ ប្រសិនបើ ៖

(ក) ឧបករណ៍ទប់ស្កាត់ហានិភ័យហួសកាលកំណត់ ឬត្រូវបានលក់ ឬត្រូវបានបញ្ចប់ ឬ

(ខ) ការទប់ស្កាត់ហានិភ័យលែងបំពេញតាមលក្ខខណ្ឌសម្រាប់ធ្វើគណនេយ្យកម្មទប់ស្កាត់ហានិភ័យដែលបានកំណត់ក្នុងកថាខណ្ឌ ១២.១៦ ឬ

(គ) ក្នុងការទប់ស្កាត់ហានិភ័យនៃប្រតិបត្តិការព្យាករណ៍ ប្រតិបត្តិការព្យាករណ៍នោះលែងមានភាពដែលអាចកើតឡើងខ្ពស់ទៀត ឬ

(ឃ) អង្គភាពដកហូតការកំណត់នោះ។

ប្រសិនបើប្រតិបត្តិការព្យាករណ៍មិនត្រូវបានរំពឹងថាកើតឡើងទៀត ឬឧបករណ៍បំណុលដែលបានទប់ស្កាត់ ហានិភ័យ និងបានវាស់វែងតាមថ្លៃដើមដករំលស់ត្រូវបានគេឈប់ទទួលស្គាល់ ផលចំណេញឬខាតណាមួយលើឧបករណ៍ទប់ស្កាត់ហានិភ័យដែលបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀតនឹងត្រូវចាត់ថ្នាក់ឡើង វិញក្នុងចំណេញ ឬខាត។

## ការលាតត្រដាង

១២.២៦ អង្គភាពដែលអនុវត្តផ្នែកនេះត្រូវតែលាតត្រដាងព័ត៌មានទាំងអស់ដែលតម្រូវដោយផ្នែកទី១១ និងរួមបញ្ចូលទាំងការលាតត្រដាងអំពីឧបករណ៍ហិរញ្ញវត្ថុនានាដែលស្ថិតក្រោមវិសាលភាពនៃផ្នែកនេះ ក៏ដូចជាឧបករណ៍ហិរញ្ញវត្ថុនានាស្ថិតក្រោមវិសាលភាពនៃផ្នែកទី១១។ បន្ថែមលើសនេះទៀត ប្រសិនបើអង្គភាពប្រើគណនេយ្យកម្មទប់ ស្កាត់ហានិភ័យ អង្គភាពនោះត្រូវលាតត្រដាងបន្ថែមនូវព័ត៌មានដែលមាននៅក្នុង កថាខណ្ឌ ១២.២៧-១២.២៩។

១២.២៧ អង្គភាពត្រូវលាតត្រដាងការទប់ស្កាត់ហានិភ័យនីមួយៗនៃហានិភ័យទាំងបួនប្រភេទដូចបានពិពណ៌នានៅក្នុងកថាខណ្ឌ ១២.១៧ នូវព័ត៌មានដាច់ដោយឡែកពីគ្នាដូចខាងក្រោម ៖

(ក) ការពិពណ៌នានៃការទប់ស្កាត់ហានិភ័យ

(ខ) ការពិពណ៌នាអំពីឧបករណ៍ហិរញ្ញវត្ថុនានាដែលបានកំណត់ថាជាឧបករណ៍ទប់ស្កាត់ហានិភ័យ ព្រមទាំងតម្លៃសមស្របនៃឧបករណ៍ទាំងនោះនៅការិយបរិច្ឆេទរាយការណ៍ និង

(គ) ចរិកលក្ខណៈនៃហានិភ័យដែលត្រូវទប់ស្កាត់ រួមទាំងការពិពណ៌នាអំពីធាតុទប់ស្កាត់ហានិភ័យ។

១២.២៨ ប្រសិនបើអង្គភាពប្រើគណនេយ្យកម្មទប់ស្កាត់ហានិភ័យសម្រាប់ការទប់ស្កាត់ហានិភ័យលើអត្រាការប្រាក់ថេរ ឬហានិភ័យលើតម្លៃវត្ថុធាតុដើមនៃវត្ថុធាតុដើមដែលមាន (កថាខណ្ឌ ១២.១៩-១២.២២) អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ៖

(ក) ចំនួននៃការប្រែប្រួលលើតម្លៃសមស្របរបស់ឧបករណ៍ទប់ស្កាត់ហានិភ័យ ដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទ និង

(ខ) ចំនួននៃការប្រែប្រួលលើតម្លៃសមស្របរបស់ធាតុទប់ស្កាត់ហានិភ័យដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទ។

១២.២៩ ប្រសិនបើអង្គភាពប្រើគណនេយ្យកម្មទប់ស្កាត់ហានិភ័យសម្រាប់ការទប់ស្កាត់ហានិភ័យលើអត្រាការប្រាក់អថេរ ហានិភ័យលើការប្តូររូបិយបណ្ណបរទេស ហានិភ័យលើតម្លៃវត្ថុធាតុដើមក្នុងការសន្យារមុតមាំមួយ ឬប្រតិបត្តិការព្យាករណ៍ដែលអាចនឹងមានកម្រិតខ្ពស់ ឬការវិនិយោគសុទ្ធក្នុងប្រតិបត្តិការបរទេស (កថាខណ្ឌ១២.២៣-១២.២៥)

អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ៖

(ក) ការិយបរិច្ឆេទពេលដែលលំហូរសាច់ប្រាក់ត្រូវបានរំពឹងថានឹងកើតមាន និងពេលដែលលំហូរសាច់ប្រាក់នោះត្រូវបានរំពឹងថាវានឹងមានផលប៉ះពាល់ដល់ចំណេញ ឬខាត។

(ខ) ការពិពណ៌នាអំពីប្រតិបត្តិការព្យាករណ៍ដែលធ្លាប់បានប្រើគណនេយ្យកម្មទប់ស្កាត់ហានិភ័យពីពេលមុន ប៉ុន្តែរំពឹងថាវានឹងមិនកើតឡើងទៀតទេ។

(គ) ចំនួននៃការប្រែប្រួលលើតម្លៃសមស្របរបស់ឧបករណ៍ទប់ស្កាត់ហានិភ័យ ដែលបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀតក្នុងអំឡុងការិយបរិច្ឆេទ (កថាខណ្ឌ ១២.២៣)។

(ឃ) ចំនួនដែលត្រូវបានចាត់ថ្នាក់ឡើងវិញទៅក្នុងចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទ (កថាខណ្ឌ១២.២៣-១២.២៥) និង

(ង) ចំនួនលើសរវាង ការប្រែប្រួលនៃតម្លៃសមស្របរបស់ឧបករណ៍ទប់ស្កាត់ហានិភ័យដែលបានបង្គរ និងការ ប្រែប្រួលនៃតម្លៃសមស្របរបស់លំហូរសាច់ប្រាក់រំពឹងទុកដែលបានបង្គរ និងបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត សម្រាប់ការិយបរិច្ឆេទ (កថាខណ្ឌ១២.២៣)។

# ផ្នែកទី ១៣
# សន្និធិ

## វិសាលភាពនៃផ្នែកនេះ

១៣.១ ផ្នែកនេះកំណត់នូវគោលការណ៍នានាសម្រាប់ទទួលស្គាល់ និងវាស់វែងសន្និធិ។ សន្និធិ គឺជាទ្រព្យសកម្មៈ

(ក) ដែលរក្សាទុកសម្រាប់លក់ក្នុងសកម្មភាពអាជីវកម្មធម្មតារបស់អង្គភាព

(ខ) ដែលមានក្នុងដំណើរការផលិតកម្មសម្រាប់ការលក់ឬ

(គ) ដែលមានទម្រង់ជាសម្ភារៈ ឬគ្រឿងផ្គត់ផ្គង់ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការផលិតកម្ម ឬក្នុងការផ្តល់សេវាកម្ម។

១៣.២ ផ្នែកនេះអនុវត្តចំពោះគ្រប់ប្រភេទនៃសន្និធិ លើកលែងតែ ៖

(ក) ផលិតផលមិនទាន់សម្រេច (ការដ្ឋានកំពុងដំណើរការ) ដែលកើតមាននៅក្នុងកិច្ចសន្យាសាងសង់ រួមបញ្ចូលដោយផ្ទាល់នូវសេវាកម្មពាក់ព័ន្ធនឹងកិច្ចសន្យា (សូមមើលផ្នែកទី ២៣ ស្តីពី ចំណូល)។

(ខ) ឧបករណ៍ហិរញ្ញវត្ថុ (សូមមើល ផ្នែកទី ១១ ស្តីពី ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និង ផ្នែកទី ១២ ស្តីពីការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ)។

(គ) ទ្រព្យសកម្មជីវសាស្ត្រ ដែលទាក់ទិនទៅនឹងសកម្មភាពនៅក្នុងវិស័យកសិកម្ម និង ផលិតផលកសិកម្ម នាកន្លែងប្រមូលផល (សូមមើលផ្នែកទី ៣៤ ស្តីពីសកម្មភាពឯកទេស) ។

១៣.៣ ផ្នែកនេះមិនអនុវត្តចំពោះការវាស់វែងសន្និធិដែលកាន់កាប់ដោយៈ

(ក) ផលិតករនៃផលិតផលកសិកម្មនិងព្រៃឈើ ផលិតផលកសិកម្មបន្ទាប់ពីប្រមូលផល ព្រមទាំងរ៉ែនិងផលិតផលរ៉ែដែលអាចវាស់វែងតាម តម្លៃសមស្រប ដកថ្លៃដើមលក់ ក្នុងចំណេញឬខាតឬ

(ខ) ឈ្មួញកណ្តាល និងអ្នកជួញដូរទំនិញ ដែលធ្វើការវាស់វែងសន្និធិរបស់គេតាមតម្លៃសមស្រប ដកថ្លៃដើមលក់ក្នុងចំណេញ ឬខាត

## ការវាស់វែងសន្និធិ

១៣.៤ អង្គភាពត្រូវវាស់វែងសន្និធិតាមថ្លៃដើមទាប និងថ្លៃលក់ប៉ាន់ស្មាន ដោយដកថ្លៃដើមដែលត្រូវផលិតសម្រេចនិងលក់។

## ថ្លៃដើមសន្និធិ

១៣.៥ អង្គភាពត្រូវបញ្ចូលក្នុងថ្លៃដើមសន្និធិនូវរាល់ថ្លៃដើមទិញ ថ្លៃដើមបំប្លែង និងថ្លៃដើមដទៃទៀត ដែលបានកើតឡើងក្នុងការនាំយកសន្និធិមកទីតាំងនិងលក្ខខណ្ឌទុកដាក់បច្ចុប្បន្នរបស់វា។

## ថ្លៃដើមទិញ

១៣.៦ ថ្លៃដើមទិញនៃសន្និធិរួមមាន ថ្លៃដើមទិញ ពន្ធនាំចូលនិងពន្ធផ្សេងទៀត (ក្រៅពីចំណាយពន្ធផ្សេងទៀត ដែលអង្គភាពបាន ទទួលការអនុគ្រោះពីអាជ្ញាធរពន្ធជាបន្តបន្ទាប់មក) ព្រមទាំងការដឹកជញ្ជូន លើកដាក់និងថ្លៃដើមផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញផលិតផលសម្រេច សម្ភារៈនិងសេវាកម្ម។ អប្បហាពាណិជ្ជកម្ម ការបង្វិលឱ្យវិញនិងធាតុប្រហាក់ប្រហែលផ្សេងទៀត ត្រូវបានដកចេញ ដើម្បីកំណត់នូវថ្លៃដើមទិញ។

១៣.៧ អង្គភាពអាចទិញសន្និធិក្រោមលក្ខខណ្ឌពន្យារការទូទាត់។ ករណីខ្លះ៖ កិច្ចសន្យាមានចែងអំពីសមាសធាតុហិរញ្ញប្បទានដែលមិនបានចែង ឧទាហរណ៍ដូចជា ភាពខុសគ្នារវាងថ្លៃទិញសម្រាប់លក្ខខណ្ឌឥណទានធម្មតា និងបរិមាណដែលត្រូវទូទាត់ពន្យារ។ ក្នុងករណីនេះ ភាពខុសគ្នាត្រូវបានទទួលស្គាល់ថាជាចំណាយការប្រាក់ក្នុងអំឡុងការិយបរិច្ឆេទនៃការធ្វើហិរញ្ញប្បទាន ហើយមិនត្រូវបានបូកបញ្ចូលជាថ្លៃដើមសន្និធិេទ។

## ថ្លៃដើមនៃការបំប្លែង

១៣.៨ ថ្លៃដើមបំប្លែងរបស់សន្និធិ រួមមានថ្លៃដើមដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងឯកតាផលិតកម្ម ដូចជា ពលកម្មផ្ទាល់។ សន្និធិនោះគិតបញ្ចូលផងដែរនូវវិភាជន៍ជាប្រព័ន្ធនៃចំណាយផលិតកម្មថេរនិងអថេរ ដែលបានកើតឡើងក្នុងការបំប្លែងសម្ភារៈវត្ថុធាតុដើមទៅជាផលិតផលសម្រេច។ ចំណាយផលិតកម្មថេរ គឺជាថ្លៃដើមផលិតកម្មដោយប្រយោលដែលមានលក្ខណៈមិនប្រែប្រួល ដោយមិនគិតពីទំហំនៃផលិតកម្ម ដូចជា ការកាត់រំលស់ និងការថែទាំអគារនិងសម្ភារៈរោងចក្រ ព្រមទាំងថ្លៃដើមនៃការគ្រប់គ្រងនិងរដ្ឋបាលរបស់រោងចក្រ។ ចំណាយផលិតកម្មអថេរ គឺជាថ្លៃដើមផលិតកម្មប្រយោលទាំងនោះ ដែលមានការប្រែប្រួលដោយផ្ទាល់ ឬស្ទើរតែផ្ទាល់ ជាមួយនឹងទំហំផលិតកម្ម ដូចជាសម្ភារៈវត្ថុធាតុដើមនិងពលកម្មមិនផ្ទាល់។

## វិភាជន៍នៃចំណាយផលិតកម្មផ្សេងៗ

១៣.៩ អង្គភាពត្រូវធ្វើវិភាជន៍ចំណាយផលិតកម្មថេរ ជាថ្លៃដើមបំប្លែងដោយផ្អែកលើមូលដ្ឋាននៃសមត្ថភាពជាធម្មតារបស់គ្រឿងបរិក្ខារផលិតកម្ម។ សមត្ថភាពធម្មតាគឺជាផលិតកម្មដែលរំពឹងថានឹងសម្រេចបានជាមធ្យមក្នុងការិយបរិច្ឆេទឬរដូវកាលនានាក្រោមកាលៈទេសៈធម្មតា ដោយគិតបញ្ចូលទាំងការបាត់បង់សមត្ថភាពដែលបណ្ដាលមកពីការថែទាំដែលបានគ្រោងទុក។ កម្រិតផលិតកម្មជាក់ស្ដែង អាចត្រូវបានប្រើប្រាស់ ប្រសិនបើវាប្រហាក់ប្រហែលនឹងសមត្ថភាពធម្មតា។ បរិមាណទឹកប្រាក់នៃចំណាយថេរដែលបានធ្វើវិភាជន៍ដល់ផ្នែកនីមួយៗ មិនមានការកើតឡើងដូចគ្នានោះទេ ដោយសារតែផលិតកម្មទាបឬរោងចក្រដែលមិនដំណើរការ។ចំណាយដែលមិនបានធ្វើវិភាជន៍ត្រូវបានទទួលស្គាល់ជាចំណាយការិយបរិច្ឆេទដែលចំណាយបានកើតឡើង។ ក្នុងការិយបរិច្ឆេទដែលផលិតកម្មមាន

កំណើនខុសធម្មតា បរិមាណទឹកប្រាក់នៃចំណាយថេរដែលបានធ្វើវិភាជន៍ទៅផ្នែកផលិតកម្មនីមួយៗ ត្រូវបានថយចុះ ដូចនេះសន្និធិមិនត្រូវបានវាស់វែងលើសថ្លៃដើមនោះទេ។ចំណាយផលិតកម្មអថេរត្រូវបានធ្វើវិភាជន៍ទៅផ្នែកនីមួយៗនៃផលិតកម្មដោយផ្អែកលើមូលដ្ឋាននៃកាប្រើប្រាស់គ្រឿងបរិក្ខារ ផលិតកម្ម ជាក់ស្តែង។

## ផលិតផលបន្ទាប់បន្សំ និងអនុផលិតផល

១៣.១០ ដំណើរការផលិតកម្ម អាចមានផលិតផលលើសពីមួយត្រូវបានផលិតក្នុងពេលតែមួយ។ ឧទាហរណ៍ដូចជាករណីដែលថាផលិតផលបន្ទាប់បន្សំត្រូវបានផលិត ឬនៅពេលដែលមានផលិតផលចម្បងមួយ និងអនុផលិតផលមួយទៀត។ នៅពេលដែលថ្លៃដើមនៃវត្ថុធាតុដើម ឬនៃការបំប្លែងផលិតផលនីមួយៗមិនអាចបែងចែកពីគ្នាឱ្យដាច់អង្គភាពត្រូវធ្វើវិភាជន៍ថ្លៃវត្ថុធាតុដើមនិងបំប្លែងទាំងនោះ រវាងផលិតផលដោយឈរលើមូលដ្ឋានមួយសមហេតុផល និងប្រាកដប្រជា។ ឧទាហរណ៍ វិភាគន៍អាចធ្វើឡើងដោយផ្អែកលើចំនួនលក់ប្រហាក់ ប្រហែលនៃផលិតផលនីមួយៗ ទាំងនៅក្នុងដំណាក់កាល ក្នុងដំណើរការផលិតកម្ម នៅពេល ដែលផលិតផលអាចបែងចែកពីគ្នាឱ្យដាច់ ឬនៅពេលដែលផលិតកម្មបានបញ្ចប់។ ផ្អែកតាមប្រភេទរបស់វា អនុផលិតផលភាគច្រើនមិនសំខាន់ទេ។ នៅពេលមានករណីនេះ អង្គភាពត្រូវវាស់វែងនូវអនុផលទាំងនោះដោយយកថ្លៃលក់ ដកថ្លៃដើមផលិតបង្ហើយ និងលក់ ហើយដកបរិមាណទឹកប្រាក់នេះពីថ្លៃដើមទំនិញចម្បង។ ជាលទ្ធផល តម្លៃយោងរបស់ផលិតផលច្បងមិនមានភាពខុសគ្នាជាសារវន្តពីថ្លៃដើមរបស់វា។

## ថ្លៃដើមផ្សេងទៀតដែលបានបញ្ចូលក្នុងសន្និធិ

១៣.១១ អង្គភាពត្រូវគិតបញ្ចូលនូវថ្លៃដើមផ្សេងទៀតក្នុងថ្លៃដើមសន្និធិតែនៅពេលដែលថ្លៃដើមទាំងនោះបានកើតមាននៅក្នុងការបំលាស់ទីសន្និធិទាំងនោះទៅដល់ទីតាំងនិងលក្ខខណ្ឌទុកដាក់បច្ចុប្បន្នរបស់វា។

១៣.១២ កថាខណ្ឌ១២.១៩(ខ)ចែងថា ក្នុងកាលៈទេសៈខ្លះការប្រែប្រួលនៃតម្លៃសមស្របរបស់ឧបករណ៍ទប់ស្កាត់ហានិភ័យក្នុងការទប់ស្កាត់ហានិភ័យអត្រាការប្រាក់ថេរ ឬហានិភ័យថ្លៃទំនិញនៃទំនិញមួយដែលធ្វើឡើងដើម្បីកែតម្រូវតម្លៃយោងនៃទំនិញនោះ។

## ថ្លៃដើមដែលត្រូវដកចេញពីសន្និធិ

១៣.១៣ ឧទាហរណ៍នៃថ្លៃដើមដែលត្រូវដកចេញពីថ្លៃដើមសន្និធិនិងត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទដែលចំណាយទាំងនោះបានកើតឡើង រួមមាន ៖

(ក) បរិមាណទឹកប្រាក់មិនប្រក្រតីនៃសម្ភារៈដែលបានប្រើខ្ជះខ្ជាយ ពលកម្ម ឬថ្លៃដើមផលិតកម្មផ្សេងទៀត។

(ខ) ថ្លៃដើមនៃការតម្កល់ទុក វៀរលែងតែថ្លៃដើមនោះមានសារៈសំខាន់ក្នុងអំឡុងពេលនៃដំណើរការផលិតកម្មមុននឹងចាប់ផ្តើមដំណាក់កាលផលិតកម្មបន្តទៀត។

(គ) ចំណាយរដ្ឋបាលបន្ទាប់បន្សំដែលមិនមែនជាចំណាយសម្រាប់នាំសន្និធិទាំងនោះទៅទីតាំងនិងលក្ខខណ្ឌទុកដាក់បច្ចុប្បន្នរបស់វា

(ឃ) ថ្លៃដើមលក់។

## ថ្លៃដើមសន្និធិសម្រាប់អ្នកផ្តល់សេវា

១៣.១៤ ក្នុងករណីដែលអ្នកផ្តល់សេវាមានសន្និធិ អ្នកនោះត្រូវវាស់វែងនូវសន្និធិទាំងនោះតាមថ្លៃដើមផលិតកម្មរបស់វា។ ជាបឋម ថ្លៃដើមនេះមានថ្លៃដើមពលកម្មនិងថ្លៃដើមចំណាយសម្រាប់បុគ្គលិកដែលជាប់ទាក់ទិនដោយផ្ទាល់ទៅនឹងការផ្តល់សេវា រួមទាំងបុគ្គលិកគ្រប់គ្រង និងចំណាយបន្ទាប់បន្សំចូលរួមផ្សេងទៀត។ ថ្លៃដើមពលកម្មនិងថ្លៃដើមផ្សេងទៀតសម្រាប់បុគ្គលិករដ្ឋបាលទូទៅ មិនត្រូវបានគិតបញ្ចូល ប៉ុន្តែត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទដែលចំណាយនោះបានកើតឡើង។ ថ្លៃដើមនៃសន្និធិរបស់អ្នកផ្តល់សេវាកម្ម មិនរាប់បញ្ចូលអត្រាចំណេញ ឬចំណាយបន្ទាប់បន្សំពាក់ព័ន្ធផ្សេងទៀត ដែលតែងតែដាក់បញ្ចូលក្នុងថ្លៃយកដោយអ្នកផ្តល់សេវានោះទេ។

## ថ្លៃដើមនៃផលិតផលកសិកម្មដែលប្រមូលពីទ្រព្យសកម្មជីវសាស្ត្រ

១៣.១៥ ផ្នែកទី៣៤ តម្រូវថាសន្និធិដែលមានផលិតផលកសិកម្មដែលអង្គភាពប្រមូលបានពីទ្រព្យសកម្មជីវសាស្ត្ររបស់ខ្លួនត្រូវតែបានវាស់វែងនាពេលទទួលស្គាល់លើកដំបូង តាមតម្លៃសមស្របរបស់វា ដកថ្លៃដើមលក់ប៉ាន់ស្មាននៅពេលប្រមូលផល។ នេះក្លាយជាថ្លៃដើមនៃសន្និធិនាកាលបរិច្ឆេទនោះដើម្បីអនុវត្តផ្នែកនេះ។ បច្ចេកទេសសម្រាប់វាស់វែងថ្លៃដើម ដូចជា ការដាក់ថ្លៃដើមស្តង់ដារ វិធីសាស្ត្រលក់រាយ និងថ្លៃទិញថ្មីៗបំផុត

១៣.១៦ អង្គភាពអាចប្រើបច្ចេកទេសមួយចំនួន ដូចជា វិធីសាស្ត្រថ្លៃដើមស្តង់ដារ វិធីសាស្ត្រលក់រាយឬថ្លៃទិញថ្មីៗបំផុតសម្រាប់វាស់វែងថ្លៃដើមសន្និធិ ប្រសិនបើលទ្ធផលប្រហាក់ប្រហែលថ្លៃដើម។ ថ្លៃដើមស្តង់ដារ គិតបញ្ចូលនូវសម្ភារៈនិងគ្រឿងផ្គត់ផ្គង់ ពលកម្ម ប្រសិទ្ធ ភាពនិងសមត្ថភាពប្រើប្រាស់ក្នុងកម្រិតធម្មតា។ ប្រសិនបើចាំបាច់ ថ្លៃដើមទាំងនោះជាធម្មតាត្រូវពិនិត្យនិងកែតម្រូវឡើងវិញតាមលក្ខខណ្ឌជាក់ស្តែង។ វិធីសាស្ត្រលក់រាយ វាស់វែងថ្លៃដើមដោយកាត់បន្ថយតម្លៃលក់សន្និធិតាមអត្រាភាគរយដុលសមរម្យមួយ។

## រូបមន្តថ្លៃដើម

១៣.១៧ អង្គភាពត្រូវវាស់វែងថ្លៃដើមសន្និធិនៃសន្និធិនានា ដែលជាធម្មតាមិនអាចផ្លាស់ប្តូរគ្នាបាននិងទំនិញឬសេវាទាំងឡាយណាដែលបានផលិតនិងបំបែកដោយឡែកសម្រាប់គម្រោងពិសេសនានាដោយប្រើលក្ខណៈពិសេសនៃថ្លៃដើមរបស់វានីមួយៗ។

១៣.១៨ អង្គភាពត្រូវវាស់វែងថ្លៃដើមសន្និធិ លើកលែងតែវាបានកំណត់ដោយកថាខណ្ឌ ១៣.១៧ ដោយប្រើ វិធីសាស្ត្រចូលមុន-ចេញមុន(FIFO) ឬរូបមន្តថ្លៃដើមមធ្យមសមតា។ អង្គភាពត្រូវប្រើរូបមន្តថ្លៃដើមដូចគ្នាដែរ ចំពោះសន្និធិទាំងឡាយដែលមានប្រភេទដូចគ្នា និងប្រើប្រាស់សម្រាប់អង្គភាព។ សម្រាប់សន្និធិដែលមានប្រភេទ ឬការប្រើប្រាស់ខុសគ្នា រូបមន្តថ្លៃដើមផ្សេងគ្នាអាចត្រូវបានធ្វើសក្តិកម្ម។ វិធីសាស្ត្រចូលក្រោយ-ចេញមុន (LIFO) មិនត្រូវបានអនុញ្ញាតដោយស្តង់ដារនេះទេ។

## ការថយចុះតម្លៃនៃសន្និធិ

១៣.១៩ កថាខណ្ឌ ២៧. ២-២៧. ៤ តម្រូវឱ្យអង្គភាពវាយតម្លៃនាចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗថាតើមានសន្និធិដែលបានថយចុះតម្លៃដែរឬទេ មានន័យថា តម្លៃយោងមិនត្រូវបានស្តារឡើងវិញទាំងស្រុង (ឧទាហរណ៍ថាដោយសារតែខូច ភាពហួសសម័យ ឬថ្លៃលក់ធ្លាក់ចុះ)។ ប្រសិនបើសមាសធាតុមួយ (ឬសមាសធាតុមួយក្រុម) នៃសន្និធិត្រូវបានថយចុះតម្លៃកថាខណ្ឌទាំងនោះតម្រូវឱ្យអង្គភាពវាស់វែង សន្និធិដោយយកថ្លៃលក់វាដកថ្លៃដើមសម្រេចនិងលក់ ហើយត្រូវទទួលស្គាល់ថាជាការខាតបង់ដោយសារការថយចុះតម្លៃ។កថាខណ្ឌទាំងនោះ ក៏តម្រូវឱ្យបង្វិលត្រឡប់នូវការថយចុះតម្លៃមុនៗ នោះក្នុងករណីខ្លះ។

## ការទទួលស្គាល់ថាជាចំណាយ

១៣.២០ នៅពេលដែលសន្និធិត្រូវបានលក់ អង្គភាពត្រូវទទួលស្គាល់នូវតម្លៃយោងរបស់សន្និធិទាំងនោះថាជាចំណាយក្នុងការិយបរិច្ឆេទ ដែលពេលនោះចំណូលពាក់ព័ន្ធត្រូវបានទទួលស្គាល់។

១៣.២១ សន្និខ្លះអាចត្រូវបានធ្វើវិភាជន៍ទៅគណនីទ្រព្យសកម្មដទៃទៀត ឧទាហរណ៍ សន្និធិដែលបាប្រើប្រាស់ជាសមាសធាតុមួយនៃទ្រព្យ រោងចក្រនិងបរិក្ខាដែលបានសាងសង់។ សន្និធិដែលបានធ្វើវិភាជន៍ដល់ទ្រព្យសកម្មផ្សេងទៀតដូចនេះត្រូវតែគិតបញ្ចូលជាបន្តបន្ទាប់ ស្របតាមផ្នែកពាក់ព័ន្ធទៅនឹងប្រភេទនៃទ្រព្យសកម្មនៃស្តង់ដារនេះ។

## ការលាតត្រដាង

១៣.២២ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ៖

(ក) គោលនយោបាយគណនេយ្យ ដែលបានអនុវត្តក្នុងការវាស់វែងសន្និធិ រួមទាំងរូបមន្តថ្លៃដើមដែលបានប្រើ។

(ខ) តម្លៃយោងសរុបនៃសន្និធិ និងតម្លៃយោងក្នុងការធ្វើចំណាត់ថ្នាក់នានាដែលមានលក្ខណៈសមស្របចំពោះអង្គភាព។

(គ) បរិមាណនៃសន្និធិដែលបានទទួលស្គាល់ជាចំណាយក្នុងអំឡុងនៃការិយបរិច្ឆេទ។

(ឃ) ការខាតពីការថយចុះតម្លៃដែលបានទទួលស្គាល់ ឬដែលបានបង្វិលត្រឡប់ក្នុងចំណេញឬខាតស្របតាមផ្នែកទី ២៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម។ និង

(ង) តម្លៃយោងសរុបរបស់សន្និធិដែលបានដាក់ជាទ្រព្យធានាបំណុល។

# ផ្នែកទី ១៤
# ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ

## វិសាលភាពនៃស្តង់ដារនេះ

១៤.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មសម្រាប់ ក្រុមហ៊ុនញាតិសម្ព័ន្ធ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់វិនិយោគិន ដែលមិនជាក្រុមហ៊ុនមេ ប៉ុន្តែមានការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធមួយឬច្រើន។ កថាខណ្ឌ ៩.២៦ បង្កើតនូវតម្រូវការមួយចំនួនសម្រាប់ធ្វើគណនេយ្យកម្មនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក។

## ការកំណត់និយមន័យក្រុមហ៊ុនញាតិសម្ព័ន្ធ

១៤.២ ក្រុមហ៊ុនញាតិសម្ព័ន្ធគឺជាអង្គភាពមួយ រួមបញ្ចូលទាំងអង្គភាពដែលមិនបានរួមញ្ចូលគ្នា ដូចជាក្រុមហ៊ុនសហកម្មសិទ្ធិ ដែលវិនិយោគិនមានឥទ្ធិពលខ្លាំងលើអង្គភាពនេះ ហើយដែលមិនមែនជា ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងមិនមានភាគកម្មនៅក្នុង ក្រុមហ៊ុនរួមទុន។

១៤.៣ ឥទ្ធិពលសំខាន់គឺ ជាអំណាចក្នុងការចូលរួមក្នុងការសម្រេចលើគោលនយោបាយប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ប៉ុន្តែមិនមែនជាការត្រួតពិនិត្យឬការត្រួតពិនិត្យរួមគ្នាលើគោលនយោបាយទាំងអស់នោះទេ៖

(ក) ប្រសិនបើវិនិយោគិនកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោល (ឧទាហរណ៍ តាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ) នូវអំណាចបោះឆ្នោត២០% ឬលើសពីនេះនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វាត្រូវបានសន្មតថាវិនិយោគិន មានឥទ្ធិពលខ្លាំងហើយ លើកលែងតែអំណាចនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា មិនអាចមានករណីនេះ។

(ខ) ផ្ទុយមកវិញ ប្រសិនបើវិនិយោគិនកាន់កាប់ដោយផ្ទាល់ឬដោយប្រយោល (ឧទាហរណ៍ តាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ) នូវអំណាចបោះឆ្នោតតិចជាង២០% ក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វាត្រូវបានសន្មតថាវិនិយោគិនមិនមានឥទ្ធិពលខ្លាំងហើយ លើកលែងតែអំណាចនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា មិនអាចមានករណីនេះ។

(គ) ភាពជាកម្មសិទ្ធិក្នុងចំណែកភាគច្រើនដោយវិនិយោគិនផ្សេងទៀត មិនរារាំងវិនិយោគិនណាម្នាក់ មិនឱ្យមានឥទ្ធិពលសំខាន់នោះទេ។

## ការវាស់វែង-ការជ្រើសយកគោលនយោបាយគណនេយ្យ

១៤.៤ វិនិយោគិនត្រូវគិតបញ្ចូលនូវការវិនិយោគរបស់ខ្លួនទាំងអស់នៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ដោយប្រើម៉ូដែលមួយក្នុងចំណោមខាងក្រោម ៖

(ក) ម៉ូដែលថ្លៃដើម ក្នុងកថាខណ្ឌ ១៤. ៥។

(ខ) វិធីសាស្ត្រមូលធន ក្នុងកថាខណ្ឌ ១៤. ៨។

(គ) ម៉ូដែលតម្លៃសមស្រប ក្នុងកថាខណ្ឌ ១៤. ៩។

## ម៉ូដែលថ្លៃដើម

១៤.៥ វិនិយោគិនត្រូវវាស់វែងការវិនិយោគរបស់ខ្លួននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វៀរលែងតែការវិនិយោគនោះមានតារាងថ្លៃ ដែលបានបោះផ្សាយរួច (សូមមើលកថាខណ្ឌ១៤.៧) ដោយយកថ្លៃដើម ដកការខាតបង់ដោយការថយចុះតម្លៃបង្គរពីមុនមក ដែលបានទទួលស្គាល់ ស្របតាមផ្នែកទី ២៧ ស្តីពី ការថយចុះតម្លៃនៃទ្រព្យសកម្ម។

១៤.៦ វិនិយោគិនត្រូវទទួលស្គាល់ថាជាចំណូល នូវរាល់ភាគលាភនិងវិភាគទានផ្សេងទៀតដែលទទួលបានពីការវិនិយោគ ដោយមិនចាំបាច់គិតថាវិភាគទាននោះ បានមកពីប្រាក់ចំណេញបង្គររបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ដែលកើតមានមុន ឬក្រោយកាលបរិច្ឆេទទទួលបាននោះទេ។

១៤.៧ វិនិយោគិនត្រូវវាស់វែងការវិនិយោគរបស់ខ្លួនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធដែលការវិនិយោគនោះមានបោះផ្សាយតារាងថ្លៃដោយប្រើម៉ូដែលតម្លៃសមស្រប (សូមមើល កថាខណ្ឌ១៤.៩)។

## វិធីសាស្ត្រមូលធន

១៤.៨. តាមវិធីសាស្ត្រមូលធននៃការធ្វើគណនេយ្យកម្ម ការវិនិយោគលើមូលធនត្រូវបានទទួលស្គាល់ជាបឋមតាមថ្លៃប្រតិបត្តិការ (រួមបញ្ចូលទាំងថ្លៃដើមប្រតិបត្តិការ) និងត្រូវបានធ្វើការកែតម្រូវជាបន្តបន្ទាប់ ដើម្បីបង្ហាញនូវភាគកម្មរបស់វិនិយោគិនលើចំណេញឬខាត និងអំពីរបាយការណ៍ចំណូលផ្សេងៗទៀតរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ៖

(ក) វិភាគទាន និងការកែតម្រូវផ្សេងទៀតលើតម្លៃយោង វិភាគទានដែលទទួលបានពីក្រុមហ៊ុនញាតិសម្ព័ន្ធកាត់បន្ថយតម្លៃពិតគណនេយ្យរបស់វិនិយោគទុន។ ការកែតម្រូវនានាលើតម្លៃយោង ក៏អាចតម្រូវឱ្យថាជាផលវិបាកមួយនៃការប្រែប្រួលលើមូលធន របស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ដែលកើតមកពីធាតុនានានៃចំណូលលម្អិតផ្សេងៗ។

(ខ) សិទ្ធិបោះឆ្នោតសក្តានុពល ទោះបីជាសិទ្ធិបោះឆ្នោតសក្តានុពល ត្រូវបានយកមកពិចារណាដើម្បីសម្រេចថា តើឥទ្ធិពលខ្លាំងមានឬអត់នោះ វិនិយោគិនត្រូវវាស់វែងនូវចំណែករបស់ខ្លួននៅក្នុងចំណេញ ឬខាតរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ព្រមទាំងចំណែក នៃការប្រែប្រួលនានា ទៅលើមូលធនរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធដោយផ្អែកលើមូលដ្ឋាននៃភាគកម្មកម្មសិទ្ធិជាក់ស្តែង។ការវាស់វែងទាំងនោះមិនបង្ហាញនូវការអនុវត្ត ឬការបំប្លែងដែលអាចកើតមាននៃសិទ្ធិបោះឆ្នោតសក្តានុពល។

(គ) កេរ្តិ៍ឈ្មោះអាជីវកម្មវាទរហិត (មិនច្បាស់លាស់)និងការកែតម្រូវលើតម្លៃសមស្រប ក្នុងការទទួលបានវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វិនិយោគិនត្រូវគិតបញ្ចូលនូវភាពខុសគ្នា (ទោះបីជាវិជ្ជមាន ឬអវិជ្ជមាន) រវាងថ្លៃដើមក្នុងការទទួលបានវិនិយោគ និងភាគកម្មរបស់វិនិយោគិននៃតម្លៃសមស្របនៃទ្រព្យសកម្ម សុទ្ធដែលអាចកំណត់បានរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ស្របតាមកថាខណ្ឌ ១៩.២២-១៩.២៤។ វិនិយោគិន ត្រូវកែតម្រូវភាគកម្មនៃចំណេញឬខាតរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ បន្ទាប់ពីបានទទួល ដើម្បីគិតដករំលស់បន្ថែមលើទ្រព្យសកម្មដែលអាចរំលស់បានរបស់ក្រុមហ៊ុននេះ (រួមបញ្ចូលទាំងកេរ្តិ៍ឈ្មោះអាជីវកម្មផង) ដោយផ្អែកលើមូលដ្ឋាននៃភាពលើសនៃតម្លៃសមស្របលើតម្លៃយោង របស់ទ្រព្យសកម្មនោះ នាពេលដែលវិនិយោគត្រូវបានទទួល។

(ឃ) ការថយចុះតម្លៃ ប្រសិនបើមានការចង្អុលបង្ហាញថាវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធអាចត្រូវបាន ថយចុះតម្លៃ វិនិយោគិនត្រូវធ្វើតេស្តទៅលើតម្លៃយោងនៃការវិនិយោគនោះសម្រាប់ការថយចុះតម្លៃស្របតាមផ្នែកទី២៧ ថាជាទ្រព្យសកម្មតែមួយ។ កេរ្តិ៍ឈ្មោះអាជីវកម្មណាដែលបានបញ្ចូលជាផ្នែកមួយនៃតម្លៃយោងនៃវិនិយោគទុននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធមិនត្រូវធ្វើតេស្តដាច់ដោយឡែក សម្រាប់ការថយចុះតម្លៃនោះទេ ប៉ុន្តែត្រូវបញ្ចូលជាការធ្វើតេស្តសម្រាប់ការថយចុះតម្លៃនៃការវិនិយោគទាំងមូល។

(ង) ប្រតិបត្តិការរបស់វិនិយោគិនជាមួយក្រុមហ៊ុនញាតិសម្ព័ន្ធ វិនិយោគិនត្រូវ បំបាត់ចោលនូវចំណេញនិងខាតដែលមិនបានទទួលស្គាល់ ដែលកើតឡើងពីប្រតិបត្តិការខាងលើ (ពីក្រុមហ៊ុនញាតិសម្ព័ន្ធទៅវិនិយោគិន) និងប្រតិបត្តិការខាងក្រោម (ពីវិនិយោគិនទៅក្រុមហ៊ុនញាតិសម្ព័ន្ធ) ទៅតាមកម្រិតភាគកម្មរបស់វិនិយោគិននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ។ ការខាតបង់មិនបានទទួលស្គាល់ពាក់ព័ន្ធនឹងប្រតិបត្តិការបែបនេះ អាចផ្តល់ជាភ័ស្តុតាងនៃការថយចុះតម្លៃនៃទ្រព្យសកម្មដែលបានផ្ទេរ។

(ច) កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ក្នុងការអនុវត្តវិធីសាស្ត្រមូលធន វិនិយោគិនត្រូវប្រើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ នាកាលបរិច្ឆេទដូចគ្នាជាមួយកាលបរិច្ឆេទរបស់ខ្លួន លើកលែងតែ មិនអាចធ្វើទៅរួច។ប្រសិនបើមិនអាចអនុវត្តបាន វិនិយោគិនត្រូវប្រើរបាយការណ៍ហិរញ្ញវត្ថុថ្មីៗដែលអាចធ្វើទៅបានរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធនេះជាមួយការកែតម្រូវនានាដែលត្រូវបានធ្វើឡើងសម្រាប់ឥទ្ធិពលនៃប្រតិបត្តិការសំខាន់ ឬនៃព្រឹត្តិការណ៍ដែលបានកើតឡើងរវាងចុងការិយបរិច្ឆេទគណនេយ្យ។

(ឆ) គោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ប្រសិនបើក្រុមហ៊ុនញាតិសម្ព័ន្ធប្រើប្រាស់ គោលនយោបាយគណនេយ្យដែលខុសពីគោលនយោបាយគណនេយ្យរបស់វិនិយោគិន វិនិយោគិនត្រូវកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ដើម្បីបង្ហាញអំពីគោលនយោបាយគណនេយ្យរបស់វិនិយោគិន ក្នុងគោលបំណងអនុវត្តវិធីសាស្ត្រមូលធន លើកលែងតែមិនអាចធ្វើទៅរួច។

(ជ) ការខាតបង់លើសពីការវិនិយោគ ប្រសិនបើចំណែកនៃការខាតបង់របស់វិនិយោគិនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធស្មើឬលើសតម្លៃយោងនៃការវិនិយោគរបស់ខ្លួនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វិនិយោគិនមិនត្រូវបន្តទទួលស្គាល់ចំណែកនៃការខាតបង់របស់ខ្លួនបន្ថែមទៀតទេ។បន្ទាប់ពីភាគកម្មរបស់វិនិយោគិនត្រូវបានកាត់បន្ថយរហូតដល់សូន្យ វិនិយោគិនត្រូវទទួលស្គាល់ការខាតបង់បន្ថែមដោយសំវិធានធន (សូមមើលផ្នែកទី ២១ ស្តីពីសំវិធានធននិងយថាភាព) តែករណីដែលវិនិយោគិនបានបង្កើតឱ្យមានកាតព្វកិច្ចនីត្យានុកូល ឬកាតព្វកិច្ចស្ថាបនា ឬបានធ្វើការទូទាត់ជំនួសក្រុមហ៊ុនញាតិសម្ព័ន្ធ។ ប្រសិនបើក្រុមហ៊ុនញាតិសម្ព័ន្ធរាយការណ៍អំពីប្រាក់ចំណេញជាបន្តបន្ទាប់ នោះវិនិយោគិនត្រូវបន្តទទួលស្គាល់ចំណែក នៃប្រាក់ចំណេញរបស់ខ្លួន ឡើងវិញតែបន្ទាប់ពីចំណែកនៃប្រាក់ចំណេញរបស់ខ្លួន ស្មើនឹងចំណែកនៃការខាតបង់ដែលមិនបានទទួលស្គាល់។

(ឈ) ការមិនបន្តវិធីសាស្ត្រមូលធន វិនិយោគិនត្រូវបញ្ឈប់ការប្រើប្រាស់វិធីសាស្ត្រមូលធនចាប់ពីពេលដែលឥទ្ធិពលសំខាន់បានបញ្ចប់។

១- ប្រសិនបើក្រុមហ៊ុនញាតិសម្ព័ន្ធ ប្រែក្លាយទៅជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន វិនិយោគិនត្រូវធ្វើការវាស់វែងឡើងវិញនូវភាគកម្មមូលធនដែលមានពីមុនទៅរកតម្លៃសមស្របនិងត្រូវទទួលស្គាល់លទ្ធផលចំណេញឬខាតនៅក្នុងចំណេញ ឬខាត ប្រសិនបើមាន។

២- ប្រសិនបើវិនិយោគិនបាត់ឥទ្ធិពលសំខាន់លើក្រុមហ៊ុនញាតិសម្ព័ន្ធ ដោយសារតែគេលក់ចោលនូវការវិនិយោគរបស់ខ្លួនមួយផ្នែក ឬទាំងស្រុង នោះវិនិយោគិនត្រូវឈប់ទទួលស្គាល់នូវក្រុមហ៊ុននេះ ហើយម្យ៉ាងទៀតត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាតនូវភាពខុសគ្នារវាងចំនួននៃចំណូលដែលទទួលបានបូករួមជាមួយនឹងតម្លៃសមស្របនៃភាគកម្មដែលរក្សាទុក និងម្យ៉ាងវិញទៀត ត្រូវទទួលស្គាល់នូវ

តម្លៃយោង នៃការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធនាកាលបរិច្ឆេទដែលឥទ្ធិពលនោះត្រូវបានបាត់បង់។ ក្រោយពីពេលនោះមក វិនិយោគិនត្រូវគិតបញ្ចូលនូវរាល់ភាគកម្មដែលបានរក្សាទុក ដោយប្រើផ្នែកទី១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និងផ្នែកទី ១២ស្តីពីការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ តាមភាពសមស្រប។

៣- ប្រសិនបើវិនិយោគិនបាត់បង់នូវឥទ្ធិពលសំខាន់ ដោយមកពីហេតុផលផ្សេងក្រៅពីការ បញ្ចេញចោលមួយផ្នែកនៃ ការវិនិយោគរបស់ខ្លួននោះ វិនិយោគិនត្រូវចាត់ទុកតម្លៃយោងនៃការវិនិយោគនាកាលបរិច្ឆេទនោះ ថាជាមូលដ្ឋានថ្លៃដើមថ្មី និងត្រូវគិតបញ្ចូលការវិនិយោគដោយប្រើផ្នែកទី ១១ និងទី ១២ តាមភាពសមស្រប។

### ម៉ូដែលតម្លៃសមស្រប

១៤.៩ នៅពេលដែលវិនិយោគមួយនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធត្រូវបានទទួលស្គាល់ជាដំបូង វិនិយោគិនត្រូវវាស់វែងវាតាមតម្លៃប្រតិបត្តិការ។ តម្លៃប្រតិបត្តិការមិនរាប់បញ្ចូលថ្លៃដើមប្រតិបត្តិការ។

១៤.១០ នាកាលបរិច្ឆេទរាយការណ៍នីមួយៗ វិនិយោគិនត្រូវវាស់វែងការវិនិយោគរបស់ខ្លួនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធតាមតម្លៃសមស្របដោយត្រូវទទួលស្គាល់ការប្រែប្រួលនៃតម្លៃសមស្របនេះ នៅក្នុងចំណេញឬខាតដោយប្រើប្រាស់នូវការណែនាំវាយតម្លៃសមស្របក្នុងកថាខណ្ឌ ១១.២៧-១១.៣២។ វិនិយោគិនដែលប្រើម៉ូដែលតម្លៃសមស្របត្រូវប្រើម៉ូដែលថ្លៃដើមសម្រាប់ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ពេលដែលតម្លៃសមស្របមិនអាចវាស់វែងគួរឱ្យទុកចិត្តបាន ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។

## ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

១៤.១១ វិនិយោគិនត្រូវចាត់ថ្នាក់ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធថាជាទ្រព្យសកម្មរយៈពេលវែង។

## ការលាតត្រដាង

១៤.១២ អង្គភាព ត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ៖

(ក) គោលនយោបាយគណនេយ្យ របស់ខ្លួនចំពោះការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ។

(ខ) តម្លៃយោងនៃការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ (សូមមើលកថាខណ្ឌ ៤.២(ញ))។

(គ) តម្លៃសមស្របនៃការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ដែលបានគិតគូរដោយប្រើវិធីសាស្ត្រមូលធន ដែលមានតារាងថ្លៃបានបោះផ្សាយ។

១៤.១៣ ចំពោះការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ដែលបានគិតតាមម៉ូដែលថ្លៃដើម វិនិយោគិនត្រូវលាតត្រដាងនូវបរិមាណនៃភាគលាភនិងវិភាគទានផ្សេងទៀតដែលត្រូវបានទទួលស្គាល់ថាជាចំណូល។

១៤.១៤ ចំពោះការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធដែលបានគិតតាមវិធីសាស្ត្រមូលធនវិនិយោគិនត្រូវលាតត្រដាងដាច់ដោយឡែកពីគ្នាអំពីចំណែកនៃចំណេញឬខាតរបស់ខ្លួននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធនោះ ព្រមទាំងចំណែកនៃប្រតិបត្តិការមិនបន្ត របស់ខ្លួននៅក្នុងក្រុមហ៊ុននេះផងដែរ។

១៤.១៥ ចំពោះការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធដែលបានគិតតាមម៉ូដែលតម្លៃសមស្រប វិនិយោគិនត្រូវលាតត្រដាងនូវព័ត៌មាននានាដែលតម្រូវដោយកថាខណ្ឌ ១១.៤១-១១.៤៤។ ប្រសិនបើវិនិយោគិន អនុវត្តការលើកលែងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ នៅក្នុងកថាខណ្ឌ១៤.១០ សម្រាប់ក្រុមហ៊ុនញាតិសម្ព័ន្ធណាមួយ វិនិយោគិននោះត្រូវលាតត្រដាងអំពីអង្គហេតុនោះ មូលហេតុដែលការវាស់វែងតម្លៃសមស្របនឹងនាំឱ្យមានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ និងតម្លៃយោងនៃការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ដែលត្រូវបានគណនាតាមម៉ូដែលថ្លៃដើម។

# ផ្នែកទី ១៥
# ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន

## វិសាលភាពនៃផ្នែកនេះ

១៥.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មនូវក្រុមហ៊ុនរួមទុន ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់វិនិយោគិនដែលមិនមែនជាក្រុមហ៊ុនមេ ប៉ុន្តែដែលមានភាគកម្មរបស់អ្នករួមទុន នៅក្នុងក្រុមហ៊ុនរួមទុនមួយឬច្រើន។ កថាខណ្ឌ ៩.២៦ បង្កើតនូវលក្ខខណ្ឌតម្រូវនានាសម្រាប់ធ្វើគណនេយ្យកម្មនូវ ភាគកម្ម របស់អ្នករួមទុននៅក្នុងក្រុមហ៊ុនរួមទុននៅក្នុង របាយការណ៍ហិរញ្ញវត្ថុដោយឡែក។

## ការកំណត់និយមន័យក្រុមហ៊ុនរួមទុន

១៥.២ ការត្រួតពិនិត្យរួមគ្នាគឺជាចែកគ្នាការត្រួតពិនិត្យដែលបានព្រមព្រៀងតាមកិច្ចសន្យាលើសកម្មភាពសេដ្ឋកិច្ចអ្វីមួយ ហើយវាកើតមានតែនៅពេលដែលសេចក្តីសម្រេចផ្នែកហិរញ្ញវត្ថុនិងប្រតិបត្តិការជាយុទ្ធសាស្ត្រទាក់ទិនទៅនឹងសកម្មភាពដែលតម្រូវឱ្យមានការព្រមព្រៀងជាឯកច្ឆ័ន្ទរបស់ភាគីដែលចែករំលែកការត្រួតពិនិត្យ (អ្នករួមទុន)។

១៥.៣ ក្រុមហ៊ុនរួមទុនគឺជាកិច្ចសន្យាមួយដែលធ្វើឡើងដោយភាគីពីរនាក់ ឬច្រើននាក់ ក្នុងការធ្វើសកម្មភាពសេដ្ឋកិច្ចអ្វីមួយដែលជាកម្មវត្ថុនៃការត្រួតពិនិត្យរួម។ក្រុមហ៊ុនរួមទុនអាចមានទម្រង់ជាប្រតិបត្តិការត្រួតពិនិត្យរួមគ្នា ទ្រព្យសកម្មដែល មានការត្រួតពិនិត្យរួមគ្នា ឬជា អង្គភាពគ្រប់គ្រងរួមគ្នា ។

## ប្រតិបត្តិការដែលបានពិនិត្យរួមគ្នា

១៥.៤ ប្រតិបត្តិការរបស់ក្រុមហ៊ុនរួមទុនមួយចំនួន ពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសកម្មនិងធនធានផ្សេងទៀត របស់អ្នករួមទុនជាជាងគាត់ទៅបង្កើតសាជីវកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬអង្គភាពផ្សេងទៀតឬពាក់ព័ន្ធទៅនឹងរចនា សម្ព័ន្ធហិរញ្ញវត្ថុដែលដាច់ចេញពីអ្នករួមទុនខ្លួនឯង។ អ្នករួមទុននីមួយៗ ប្រើទ្រព្យ រោងចក្រ និងបរិក្ខារ របស់ខ្លួនផ្ទាល់ព្រមទាំងកាន់កាប់សន្និធិផ្ទាល់របស់ខ្លួន។ វាក៏ត្រូវរ៉ាប់រងចំណាយនិងបំណុលផ្ទាល់ខ្លួនរបស់ខ្លួនផងដែរ និងវាបង្កើតបានជាហិរញ្ញវត្ថុផ្ទាល់របស់ខ្លួន ដែលតំណាងឱ្យកាតព្វកិច្ចរបស់ខ្លួន។សកម្មភាពរបស់ក្រុមហ៊ុនរួមទុនអាចធ្វើឡើងដោយបុគ្គលិករបស់អ្នករួមទុនដែលអមដោយសកម្មភាពប្រហាក់ប្រហែលរបស់អ្នករួមទុន។ កិច្ចសន្យាដាក់ទុនរួមគ្នាតែងតែផ្តល់នូវមធ្យោបាយ ដែលតាមមធ្យោបាយនេះចំណូលពីការលក់នូវផលិតផលរួម ព្រមទាំងចំណាយដែលបានកើតមានឡើងជារួម ត្រូវបានចែករំលែករវាងអ្នករួមទុន។

១៥.៥ ចំពោះភាគកម្មរបស់អ្នករួមទុនក្នុងប្រតិបត្តិការត្រួតពិនិត្យរួមគ្នា អ្នករួមទុនត្រូវទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួននូវ ៖

(ក) ទ្រព្យសកម្មដែលអ្នករួមទុនត្រួតពិនិត្យ និងបំណុលដែលអ្នករួមទុនបង្កើតឡើង និង

(ខ) ចំណាយដែលអ្នករួមទុនបង្កើតឡើង និងចំណែកនៃចំណូលដែលអ្នករួមទុនទទួលបានពីការលក់ទំនិញនិងសេវាដោយក្រុមហ៊ុនរួមទុន។

## ទ្រព្យសកម្មដែលបានត្រួតពិនិត្យរួមគ្នា

១៥.៦ ក្រុមហ៊ុនរួមទុនមួយចំនួនពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យរួមគ្នាដោយអ្នករួមទុនលើទ្រព្យសកម្មមួយឬច្រើនដែលបានផ្តល់ទៅឱ្យ និងទទួលបានសម្រាប់ក្រុមហ៊ុនរួមទុន ហើយតែងតែមានកម្មសិទ្ធិរួមគ្នាលើទ្រព្យសកម្មនោះ ហើយ ទ្រព្យនោះត្រូវបានផ្តល់ជូនសម្រាប់គោលបំណងរួមទុន។

១៥.៧ ចំពោះភាគកម្មរបស់ខ្លួននៅក្នុងទ្រព្យសកម្មដែលត្រូវត្រួតពិនិត្យរួមគ្នា អ្នករួមទុនត្រូវទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួននូវ៖

(ក) ចំណែករបស់ខ្លួននៅក្នុងទ្រព្យសកម្មដែលត្រូវត្រួតពិនិត្យរួមគ្នា ដែលបានចាត់ថ្នាក់ស្របតាមប្រភេទនៃទ្រព្យសកម្ម

(ខ) បំណុលនានាដែលបានកើតឡើង

(គ) បំណុលនានាដែលបានកើតឡើងរួមគ្នាជាមួយអ្នករួមទុនដទៃទៀត ទាក់ទិននឹងក្រុមហ៊ុនរួមទុន

(ឃ) ចំណូលនានាដែលបានមកពីការលក់ ឬការប្រើប្រាស់នូវចំណែកលទ្ធផលនៃក្រុមហ៊ុនរួមទុន ជាមួយនឹងចំណែក នៃចំណាយដែលបានកើតឡើងក្នុងក្រុមហ៊ុនរួមទុន និង

(ង) ចំណាយនានាដែលបានកើតឡើងដោយសារតែភាគកម្មរបស់ខ្លួននៅក្នុងក្រុមហ៊ុនរួមទុន។

## អង្គភាពគ្រប់គ្រងរួមគ្នា

១៥.៨ អង្គភាពគ្រប់គ្រងរួមគ្នាគឺជាក្រុមហ៊ុនរួមទុនមួយ ដែលទាក់ទិនទៅនឹងការបង្កើតក្រុមហ៊ុនសាជីវកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬអង្គភាពផ្សេងទៀត ដែលអ្នករួមទុនមានភាគកម្មរបស់ខ្លួន។ អង្គភាពប្រតិបត្តិការដូច អង្គភាពដទៃទៀតដែរ វៀរលែងតែខនៃកិច្ចសន្យារវាងអ្នករួមទុនបង្កើតឡើងនូវការត្រួតពិនិត្យរួមគ្នា លើសកម្មភាពសេដ្ឋកិច្ចរបស់អង្គភាព។

### ការវាស់វែង - ការជ្រើសរើសគោលនយោបាយគណនេយ្យ

១៥.៩ អ្នករួមទុនត្រូវទទួលខុសត្រូវចំពោះផលប្រយោជន៍ទាំងអស់របស់ខ្លួន នៅក្នុងអង្គភាពត្រួតពិនិត្យរួមគ្នា ដោយប្រើម៉ូដែលណាមួយដូចខាងក្រោម ៖

(ក) ម៉ូដែលថ្លៃដើម ក្នុងកថាខណ្ឌ ១៥.១០

(ខ) វិធីសាស្រ្តមូលធន ក្នុងកថាខណ្ឌ ១៥.១៣

(គ) ម៉ូដែលតម្លៃសមស្រប ក្នុងកថាខណ្ឌ ១៥.១៤

### ម៉ូដែលថ្លៃដើម

១៥.១០ អ្នករួមទុន ត្រូវវាស់វែងនូវការវិនិយោគរបស់ខ្លួននៅក្នុងអង្គភាពត្រួតពិនិត្យរួមគ្នា លើកលែងតែការវិនិយោគ នោះមានតារាងថ្លៃដែលត្រូវបានបោះផ្សាយរួចហើយ (មើល កថាខណ្ឌ ១៥.១២)ដោយយកថ្លៃដើម ដក ការខាតពីការថយចុះតម្លៃ ដែលបានទទួលស្គាល់តាមផ្នែកទី ២៧ ស្តីពី ការថយចុះតម្លៃនៃទ្រព្យសកម្ម។

១៥.១១ វិនិយោគិន ត្រូវទទួលស្គាល់នូវភាគទាននានាដែលទទួលបានការវិនិយោគជាចំណូល ដោយមិនគិតពីថា តើភាគទានទាំងនោះបានមកពីប្រាក់ចំណេញ ដែលបានបង្គររបស់អង្គភាពគ្រប់គ្រងរួមគ្នា ដែលបានកើតឡើងមុន ឬក្រោយកាលបរិច្ឆេទទទួលបាន។

១៥.១២ អ្នករួមទុនត្រូវវាស់វែងការវិនិយោគរបស់ខ្លួនក្នុងអង្គភាពគ្រប់គ្រងរួមគ្នា ដែលការវិនិយោគនោះមានតារាងថ្លៃ ដែលបានបោះផ្សាយដោយប្រើតម្លៃសមស្រប (សូមមើលកថាខណ្ឌទី ១៥.១៤)។

## វិធីសាស្ត្រមូលធន

១៥.១៣ អ្នករួមទុនត្រូវវាស់វែងការវិនិយោគរបស់ខ្លួននៅក្នុងអង្គភាពគ្រប់គ្រងរួមគ្នាតាមរយៈវិធីសាស្ត្រមូលធន ដោយប្រើនីតិវិធីនានានៅក្នុងកាថាខណ្ឌ១៤.៨ (ដែលជំនួសដោយពាក្យ "ការត្រួតពិនិត្យរួមគ្នា" ដែលកថាខណ្ឌនោះសំដៅដល់ "ឥទ្ធិពលខ្លាំង")។

## ម៉ូដែលតម្លៃសមស្រប

១៥.១៤ នៅពេលដែលការវិនិយោគននៅក្នុងអង្គភាពត្រួតពិនិត្យរួមគ្នាត្រូវបានទទួលស្គាល់ជាដំបូង អ្នករួមទុនត្រូវវាស់វែងការវិនិយោគនោះតាមថ្លៃប្រតិបត្តិការ។ ថ្លៃប្រតិបត្តិការ មិនរាប់បញ្ចូលថ្លៃដើមប្រតិបត្តិការទេ។

១៥.១៥ នាកាលបរិច្ឆេទរាយការណ៍ អ្នករួមទុនត្រូវវាស់វែងការវិនិយោគរបស់ខ្លួនក្នុងអង្គភាពគ្រប់គ្រងរួមគ្នាតាមតម្លៃ សមស្រប ស្របតាមការប្រែប្រួលតម្លៃសមស្របក្នុងចំណេញឬខាត ដោយប្រើគោលការណ៍ណែនាំស្តីពីការ វាយតម្លៃក្នុងកថាខណ្ឌទី១១.២៧-១១.៣២។អ្នករួមទុនដែលប្រើម៉ូដែលតម្លៃសមស្រប ត្រូវប្រើម៉ូដែលថ្លៃដើមសម្រាប់ វិនិយោគទុនក្នុងអង្គភាពគ្រប់គ្រងរួមគ្នា ដែលការវិនិយោគនោះ មិនអាចវាស់វែងវាតាមតម្លៃសមស្របគួរឱ្យទុកចិត្តបានដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។

# ប្រតិបត្តិការរវាងអ្នករួមទុន និងក្រុមហ៊ុនរួមទុន

១៥.១៦ នៅពេលដែលអ្នករួមទុនផ្តល់ឬលក់ទ្រព្យសកម្មដល់ក្រុមហ៊ុនរួមទុន ការទទួលស្គាល់នូវផ្នែកណាមួយនៃចំណេញ ឬខាតពីប្រតិបត្តិការត្រូវបង្ហាញនូវសារជាតិរបស់ប្រតិបត្តិការនោះ។ នៅពេលដែលទ្រព្យសកម្មត្រូវបានកាន់កាប់ដោយក្រុមហ៊ុនរួមទុន និងត្រូវបានផ្តល់ដល់អ្នករួមទុន ហើយអ្នករួមទុនបានផ្ទេរហានិភ័យនិង ប្រយោជន៍ចម្បងលើកម្មសិទ្ធិ នោះនាំឱ្យអ្នករួមទុនត្រូវទទួលស្គាល់តែចំណែកនៃចំណេញឬខាតនោះ ដែលចូលជាភាគកម្មរបស់អ្នករួមទុនផ្សេងទៀត។ អ្នករួមទុន ត្រូវទទួលស្គាល់បរិមាណសរុបនៃការខាតបង់ នៅពេលដែលវិភាគទាន ឬការលក់ផ្តល់ភ័ស្តុតាងអំពីការខាតពីការថយចុះតម្លៃ។

១៥.១៧ នៅពេលដែលអ្នករួមទុនទិញទ្រព្យសកម្មពីក្រុមហ៊ុនរួមទុន អ្នករួមទុនមិនត្រូវទទួលស្គាល់ចំណែករបស់ខ្លួន លើប្រាក់ចំណេញពីប្រតិបត្តិការរបស់ក្រុមហ៊ុនរួមទុន រហូតទាល់តែក្រុមហ៊ុនលក់ទ្រព្យសកម្មនោះទៅភាគីឯករាជ្យណាមួយ។ អ្នករួមទុន ត្រូវទទួលស្គាល់ចំណែកនៃការខាតបង់របស់ខ្លួនដែលជាលទ្ធផលនៃប្រតិបត្តិការទាំងនោះ ដូចការទទួលស្គាល់ចំណូលដែរ លើកលែងតែការខាតបង់ទាំងនោះ ត្រូវបានទទួលស្គាល់ភ្លាម នៅពេលការខាតបង់ទាំងនោះបង្ហាញអំពីការខាតពីការថយចុះតម្លៃ។

## ប្រសិនបើវិនិយោគិនមិនមានការគ្រប់គ្រងរួម

១៥.១៨ វិនិយោគិនក្នុងក្រុមហ៊ុនរួមទុនដែលមិនមានការគ្រប់គ្រងរួម ត្រូវគិតគូរការវិនិយោគរបស់ខ្លួនស្របតាមផ្នែកទី១១ ស្ដីពីឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន និង ផ្នែកទី ១២ ស្ដីពីការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ឬប្រសិនបើគាត់មានឥទ្ធិពលខ្លាំងលើក្រុមហ៊ុនរួមទុន ស្របតាមផ្នែកទី ១៤ ស្ដីពីការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ។

## ការលាតត្រដាង

១៥.១៩ ក្រុមហ៊ុនរួមទុន ត្រូវលាតត្រដាងព័ត៌មាន ៖

(ក) គោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនប្រើដើម្បីទទួលស្គាល់ផលប្រយោជន៍របស់ក្រុមហ៊ុន នៅក្នុងអង្គភាព ដែលត្រួតពិនិត្យរួមគ្នា

(ខ) តម្លៃយោងនៃការវិនិយោគក្នុងអង្គភាពគ្រប់គ្រងរួមគ្នា (មើលកថាខណ្ឌ ៤. ២ (ដ))

(គ) តម្លៃសមស្របនៃការវិនិយោគក្នុងអង្គភាពគ្រប់គ្រងរួមគ្នា ដោយប្រើវិធីសាស្ត្រមូលធន ដែលតម្លៃ ទាំងនោះបានបោះផ្សាយក្នុងតារាងតតម្លៃ

(ឃ) ចំនួនសរុបនៃការសន្យាទាក់ទិនទៅនឹងក្រុមហ៊ុនរួមទុន រួមបញ្ចូលទាំងចំណែកហ៊ុនរបស់ វិនិយោគិននៅក្នុងកិច្ចសន្យាមូលធន ដែលបានកើតមានរួមគ្នាជាមួយអ្នករួមទុនផ្សេងទៀត ក៏ដូចជា ចំណែកហ៊ុនរបស់វិនិយោគិននៃកិច្ចសន្យាមូលធននៃការរកស៊ីរួមគ្នាខ្លួនឯង។

១៥.២០ សម្រាប់អង្គភាពគ្រប់គ្រងរួមគ្នាដែលទទួលខុសត្រូវស្របតាមវិធីសាស្ត្រមូលធន អ្នករួមទុន ក៏ត្រូវលាតត្រដាងផងដែរនូវព័ត៌មានដែលតម្រូវដោយកថាខណ្ឌ ១៤.១៤ សម្រាប់ការវិនិយោគតាមវិធីសាស្ត្រមូលធនកម្ម។

១៥.២១ សម្រាប់អង្គភាពគ្រប់គ្រងរួមគ្នាដែលទទួលខុសត្រូវស្របតាមម៉ូដែលតម្លៃសមស្រប អ្នករួមទុន ក៏ត្រូវលាតត្រដាងព័ត៌មាន ដែលតម្រូវដោយកថាខណ្ឌ ១១.៤១-១១.៤៤។ ប្រសិនបើអ្នករួមទុនអនុវត្តការលើកលែងចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ នៅក្នុងកថាខណ្ឌ១៥.១៥ សម្រាប់អង្គភាពគ្រប់គ្រងរួមគ្នាណាមួយ អង្គភាពគ្រប់គ្រងរួមគ្នានោះ ត្រូវលាតត្រដាងអំពីអង្គហេតុនោះ មូលហេតុដែលការវាស់វែងតម្លៃសមស្របនឹងនាំឱ្យមានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ និងតម្លៃយោងនៃការវិនិយោគក្នុងអង្គភាពគ្រប់គ្រងរួមគ្នា ដែលត្រូវបានគណនាតាមម៉ូដែលថ្លៃដើម។

# ផ្នែកទី ១៦
# ទ្រព្យវិនិយោគ

## វិសាលភាពនៃផ្នែកនេះ

១៦.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មលើវិនិយោគទុនជាអគារ ឬដី ដែលបំពេញបានតាមលក្ខខណ្ឌនៃទ្រព្យវិនិយោគ តាមកថាខណ្ឌ ១៦.២ និងលើទ្រព្យសម្បត្តិមួយចំនួនដែលកាន់កាប់ដោយភតិកៈ ក្រោមភតិសន្យាប្រតិបត្តិការ (សូមមើលកថាខណ្ឌ ១៦.៣) ដែលត្រូវបានចាត់ទុកដូចជា ទ្រព្យវិនិយោគ។ មានតែទ្រព្យវិនិយោគដែលតម្លៃសមស្របរបស់វាអាចត្រូវបានវាស់វែងគួរឱ្យទុកចិត្តបានដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុតែប៉ុណ្ណោះ ដែលត្រូវធ្វើគណនេយ្យកម្មស្របតាមផ្នែកនេះតាមតម្លៃសមស្របក្នុងចំណេញ ឬខាត។ រីឯ ទ្រព្យវិនិយោគដទៃទៀតទាំងអស់ ត្រូវបានធ្វើគណនេយ្យកម្មដោយប្រើ ម៉ូដែលការខាតបង់ដោយរំលស់ថ្លៃដើម តាមផ្នែកទី ១៧ ស្តីពី ទ្រព្យ រោងចក្រ និងបរិក្ខារ ហើយស្ថិតក្នុងវិសាល ភាពនៃផ្នែកទី១៧ វៀរលែងតែការវាស់វែងតម្លៃសមស្របគួរឱ្យទុកចិត្ត នឹងអាចធ្វើទៅបាន ហើយត្រូវ គេបានរំពឹងថា តម្លៃសមស្របនឹងអាចវាស់វែងគួរឱ្យទុកចិត្តបាន ផ្អែកលើមូលដ្ឋាននិរន្តរភាព។

## និយមន័យ និងការទទួលស្គាល់លើកដំបូងនូវទ្រព្យវិនិយោគ

១៦.២ ទ្រព្យវិនិយោគ គឺជាទ្រព្យ (ដី ឬអគារ, ឬផ្នែកមួយនៃអគារ ឬទាំងពីរ) ដែលកាន់កាប់ដោយម្ចាស់របស់វា ឬ ដោយភតិកៈក្រោមភតិសន្យាហិរញ្ញវត្ថុ ដើម្បីទទួលបានចំណូលពីការជួល ឬសម្រាប់រំលស់លើមូលធន ឬ សម្រាប់គោលបំណងទាំងពីរ លើកលែងតែសម្រាប់ ៖

(ក) ប្រើប្រាស់ក្នុងផលិតកម្ម ឬក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា ឬសម្រាប់គោលបំណងរដ្ឋបាល ឬ

(ខ) លក់ក្នុងអាជីវកម្មជាធម្មតា។

១៦.៣ ភាគកម្មជាទ្រព្យដែលកាន់កាន់ដោយភតិកៈ ក្រោមភតិសន្យាប្រតិបត្តិការ អាចត្រូវបានចាត់ថ្នាក់ និងគិតថាជា ទ្រព្យវិនិយោគ ដោយប្រើផ្នែកនេះ ប្រសិនបើ និងតែក្នុងករណីបើ ទ្រព្យនោះបំពេញបាននូវនិយមន័យនៃទ្រព្យ វិនិយោគ ភតិកៈអាចវាស់វែងតម្លៃសមស្របរបស់ភាគកម្មនៃទ្រព្យនោះដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ ផ្អែកលើមូលដ្ឋាននិរន្តរភាព។ ជម្រើសនៃការចាត់ថ្នាក់នេះ អាចធ្វើទៅបានដោយឈរលើមូលដ្ឋានតាមប្រភេទនៃទ្រព្យ។

១៦.៤ ការប្រើប្រាស់ទ្រព្យចម្រុះ ត្រូវតែបែងចែកឱ្យដាច់ រវាងទ្រព្យវិនិយោគ និង ទ្រព្យ រោងចក្រ និងបរិក្ខារ។ ប៉ុន្តែទោះ បីជាយ៉ាងណាក៏ដោយ ប្រសិនបើតម្លៃសមស្របរបស់សមាសធាតុទ្រព្យវិនិយោគ និង ទ្រព្យ រោងចក្រ និងបរិក្ខារ មិនអាចត្រូវបានវាស់វែងប្រកបដោយការជឿជាក់ ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ ទ្រព្យ ទាំងអស់ ត្រូវតែចាត់ទុកជាទ្រព្យ រោងចក្រ និងបរិក្ខារ ស្របតាមផ្នែកទី ១៧។

## ការវាស់វែងនាពេលទទួលស្គាល់ដំបូង

១៦.៥ អង្គភាពត្រូវវាស់វែងទ្រព្យវិនិយោគតាមថ្លៃដើមរបស់វា នាពេលទទួលស្គាល់លើកដំបូង។ ថ្លៃដើមនៃការទិញ ទ្រព្យវិនិយោគមាន ថ្លៃទិញរបស់វា និងចំណាយចូលរួមផ្ទាល់នានា ដូចជា សោហ៊ុយច្បាប់និងសោហ៊ុយអន្តរកម្ម (ឈ្មួញកណ្តាល) ពន្ធលើការផ្ទេរទ្រព្យ និងថ្លៃដើមប្រតិបត្តិការដទៃទៀត។ ប្រសិនបើការទូទាត់ត្រូវបានពន្យារ លើសពីលក្ខខណ្ឌឥណទានធម្មតា ថ្លៃដើម គឺជាថ្លៃបច្ចុប្បន្ន នៃការទូទាត់នាពេលអនាគត។ អង្គភាពត្រូវកំណត់ ថ្លៃដើមនៃទ្រព្យដែលបានសាងសង់ដោយខ្លួនឯង ស្របតាមកថាខណ្ឌ ១៧.១០-១៧.១៤។

១៦.៦ ថ្លៃដើមដំបូងនៃភាគកម្មទ្រព្យក្រោមភតិសន្យា ហើយដែលត្រូវបានចាត់ថ្នាក់ថាជាទ្រព្យវិនិយោគត្រូវអនុវត្តតាមភតិសន្យាហិរញ្ញវត្ថុ ដូចបានរៀបរាប់ក្នុងកថាខណ្ឌ ២០.៩ ទោះបីជាភតិសន្យានោះអាចត្រូវបានចាត់ថ្នាក់ ផ្សេងថាជាភតិសន្យាប្រតិបត្តិការ តាមវិសាលភាពនៃផ្នែកទី២០ ស្តីពីភតិសន្យា។ និយាយម្យ៉ាងទៀត ទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របទាបរបស់ទ្រព្យនោះ និងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាអប្បរមា។ បរិមាណទឹកប្រាក់ប្រហាក់ប្រហែលត្រូវបានទទួលស្គាល់ថាជាបំណុលស្របតាមកថាខណ្ឌ២០.៩។

## ការវាស់វែងបន្ទាប់ពីការទទួលស្គាល់

១៦.៧ ទ្រព្យវិនិយោគដែលតម្លៃសមស្របរបស់វា អាចបានវាស់វែងគួរឱ្យទុកចិត្តបាន ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ ត្រូវតែធ្វើការវាស់វែងតាមតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍នីមួយៗ ដោយយោលលើការប្រែប្រួលនៃតម្លៃសមស្របដែលបានទទួលស្គាល់នៅក្នុងចំណេញឬខាត។ ប្រសិនបើ ភាគកម្មជាទ្រព្យតាមភតិសន្យាត្រូវបានចាត់ថ្នាក់ថាជាទ្រព្យវិនិយោគ ធាតុដែលបានគិតគូតាមតម្លៃសមស្រប គឺជាភាគកម្មនោះ ហើយមិនមែនជា ទ្រព្យតាមភតិសន្យាទេ។ កថាខណ្ឌ ១១.២៧-១១.៣២ ផ្តល់នូវគោលការណ៍ណែនាំក្នុងការកំណត់នូវតម្លៃសមស្រប។អង្គភាពត្រូវគិតគូនូវទ្រព្យវិនិយោគផ្សេងទៀតទាំងអស់ដោយប្រើ ម៉ូដែលការខាតបង់ដោយរំលស់ថ្លៃដើមតាមផ្នែកទី ១៧។

## ការផ្ទេរ

១៦.៨ ប្រសិនបើការវាស់វែងតម្លៃសមស្រប ដែលអាចទុកចិត្តបាន មិនអាចធ្វើទៅបានទៀតដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ លើធាតុមួយនៃទ្រព្យវិនិយោគដែលបានវាស់វែងដោយប្រើម៉ូដែលតម្លៃសមស្របនោះទេលំដាប់តទៅ អង្គភាពត្រូវចាត់ទុកនូវធាតុនោះស្របតាមផ្នែកទី ១៧ រហូតទាល់តែការវាស់វែង ដែលអាចជឿទុកចិត្តលើតម្លៃសមស្របអាចធ្វើទៅបាន។តម្លៃយោងនៃទ្រព្យវិនិយោគនាកាលបរិច្ឆេទនោះ ក្លាយ ទៅជាថ្លៃដើមរបស់វាតាមផ្នែកទី១៧។កថាខណ្ឌ១៦.១០ (ក)( ៣) តម្រូវឱ្យលាតត្រដាងព័ត៌មានអំពីការប្រែប្រួលនេះ។ វាគឺជាការប្រែប្រួលនៃកាលៈទេសៈ និងមិនមែនជាការផ្លាស់ប្តូរគោលនយោបាយគណនេយ្យទេ។

១៦.៩ វៀរលែងតែមានការតម្រូវដោយកថាខណ្ឌ ១៦.៨ អង្គភាពត្រូវផ្ទេរទ្រព្យទៅជា ឬមកជាទ្រព្យវិនិយោគ តែនៅពេលដែលទ្រព្យបំពេញបាននូវនិយមន័យនៃទ្រព្យវិនិយោគជាមុន ឬលែងបំពេញតាមនិយមន័យនេះ។

# ការលាតត្រដាង

១៦.១០ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីទ្រព្យវិនិយោគដោយគិតតាមតម្លៃសមស្រប ដោយបង្ហាញនូវចំណេញ ឬ ខាត (កថាខណ្ឌ ១៦.៧)ដូចខាងក្រោម ៖

(ក) វិធីសាស្រ្ត និង ការសន្មតសំខាន់ៗនានា ដែលប្រើប្រាស់នៅក្នុងការកំណត់តម្លៃ ទីផ្សាររបស់ទ្រព្យវិនិយោគ

(ខ) ទំហំឬវិសាលភាពនៃតម្លៃសមស្របរបស់ទ្រព្យវិនិយោគ (ដូចដែលបានវាស់វែងឬបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) ត្រូវបានកំណត់ដោយផ្អែកលើការវាយតម្លៃដោយអ្នកវាយតម្លៃឯករាជ្យដែលមានគុណវុឌ្ឍិខាងវិជ្ជាជីវៈនិងត្រូវបានគេទទួលស្គាល់ ហើយដែលមានបទពិសោធថ្មីៗនៅក្នុងតំបន់និងថ្នាក់នៃទ្រព្យវិនិយោគដែលត្រូវវាយតម្លៃ។ ប្រសិនបើមិនមានការវាយតម្លៃខាងលើត្រូវបានធ្វើឡើងទេ អង្គភាពត្រូវបង្ហាញផងដែរ។

(គ) អត្ថិភាព និងបរិមាណនៃលក្ខខណ្ឌកំហិតនានានៃភាពអាចកើតមានរបស់ទ្រព្យវិនិយោគឬ ការបង្វែចំណូល និងចំណូលនៃការបញ្ចេញចោល។

(ឃ) កាតព្វកិច្ចតាមកិច្ចសន្យា ក្នុងការទិញ ការសាងសង់ ឬការបង្កើនទ្រព្យវិនិយោគ ឬកាតព្វកិច្ចតាមកិច្ចសន្យាសម្រាប់ការជួសជុល ការថែទាំ ឬ ការធ្វើឱ្យប្រសើរឡើង ទ្រព្យវិនិយោគ។

(ង) ការផ្ទៀងផ្ទាត់រវាងតម្លៃយោងនៃទ្រព្យវិនិយោគ នាដើមនិងចុងការិយបរិច្ឆេទត្រូវបង្ហាញដាច់ពីគ្នានូវ ៖

១- ជាតុបន្ថែមនានា ដោយបង្ហាញដាច់ដោយឡែកនូវជាតុបន្ថែមទាំងនោះ ដែល បានមកពីការទិញ ឬ លទ្ធកម្ម តាមរយៈការបញ្ចូលគ្នានៃអាជីវកម្ម

២- ចំណេញសុទ្ធ ឬ ខាតសុទ្ធ ពីការកែតម្រូវតម្លៃសមស្រប

៣- ការផ្ទេរទៅក្នុង និងពីទ្រព្យវិនិយោគ គិតតាមថ្លៃដើម ដករំលស់បង្គរ និងការថយចុះតម្លៃ (សូមមើលកថាខណ្ឌ១៦.៨)

៤- ការផ្ទេរទៅ និង ផ្ទេរពីសន្និធិ និងទ្រព្យដែលកាន់កាប់ដោយម្ចាស់។

៥- ការប្រែប្រួលផ្សេងៗទៀត។

ការផ្ទៀងផ្ទាត់នេះ មិនចាំបាច់បង្ហាញសម្រាប់ការិយបរិច្ឆេទមុនៗទេ។

១៦.១១ ដោយអនុលោមតាម ផ្នែកទី ២០ ម្ចាស់ទ្រព្យវិនិយោគ ត្រូវផ្តល់នូវការលាតត្រដាងរបស់ ភតិបតី អំពី ភតិសន្យាដែលម្ចាស់ទ្រព្យនោះបានចូលរួមជាភាគី។ អង្គភាពមួយដែលមានទ្រព្យវិនិយោគក្រោមភតិសន្យាហិរញ្ញវត្ថុ ឬភតិសន្យាប្រតិបត្តិការ ត្រូវលាតត្រដាងព័ត៌មានរបស់ ភតិបតីសម្រាប់ភតិសន្យាហិរញ្ញវត្ថុ និងផ្តល់នូវ ការលាតត្រដាងរបស់ភតិកៈ សម្រាប់ភតិសន្យាប្រតិបត្តិការនានាដែលអង្គភាពនោះបានចូលរួមជាភាគី។

# ផ្នែកទី ១៧
# ទ្រព្យ រោងចក្រ និងបរិក្ខារ

## វិសាលភាពនៃផ្នែកនេះ

១៧.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មសម្រាប់ ទ្រព្យ រោងចក្រ និងបរិក្ខារ និង ការធ្វើគណនេយ្យកម្ម សម្រាប់ទ្រព្យវិនិយោគ ដែលតម្លៃសមស្របរបស់វាមិនអាចត្រូវវាស់វែងគួរឱ្យ ទុកចិត្តបាន ដោយគ្មាន ចំណាយឬកិច្ចប្រឹងប្រែងហួសហេតុផ្អែកលើមូលដ្ឋាននិរន្តរភាព។

ផ្នែកទី១៦ស្តីពី ទ្រព្យវិនិយោគ អនុវត្តចំពោះទ្រព្យវិនិយោគដែលតម្លៃសមស្របរបស់វា អាចត្រូវបានវាស់វែងគួរឱ្យទុកចិត្ត បានដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។

១៧.២ ទ្រព្យ រោងចក្រ និងបរិក្ខារ គឺជាទ្រព្យសកម្មរូបិយ ដែល ៖

(ក) ទុកសម្រាប់ប្រើក្នុងផលិតកម្ម ឬក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា, ទុកសម្រាប់ជួលឱ្យអ្នកដទៃ ឬទុកសម្រាប់គោលបំណងរដ្ឋបាល, និង

(ខ) រំពឹងថានឹងត្រូវប្រើប្រាស់ក្នុងអំឡុងពេលលើសពីមួយការិយបរិច្ឆេទ។

១៧.៣ ទ្រព្យ រោងចក្រ និងបរិក្ខារ មិនរាប់បញ្ចូលនូវ ៖

(ក) ទ្រព្យសកម្មជីវសាស្ត្រដែលទាក់ទិននឹងសកម្មភាពកសិកម្ម (សូមមើលផ្នែកទី៣ ៤ ស្តីពីសកម្មភាពឯកទេស), ឬ

(ខ) សិទ្ធិលើធនធានរ៉ែ និងទុនបម្រុងលើធនធានរ៉ែ ដូចជា ប្រេង ហ្គាសធម្ម ជាតិ និងធនធានមិនកើតមានប្រហាក់ប្រហែលផ្សេងទៀត។

## ការទទួលស្គាល់

១៧.៤ អង្គភាពត្រូវអនុវត្តតាមលក្ខខណ្ឌនៃការទទួលស្គាល់ក្នុងកថាខណ្ឌ ២.២៧ ក្នុងការកំណត់ថាតើត្រូវទទួលស្គាល់ធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ ឬទេ។ ដូចនេះ អង្គភាពត្រូវទទួលស្គាល់ថ្លៃដើមនៃធាតុរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ ថាជាទ្រព្យសកម្មប្រសិនបើ និងតែក្នុងករណីដែល ៖

(ក) អត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលភ្ជាប់ជាមួយធាតុនោះអាចនឹងហូរចូលអង្គភាព និង

(ខ) ថ្លៃដើមនៃធាតុនោះ អាចវាស់វែងគួរឱ្យទុកចិត្តបាន។

១៧.៥ ធាតុនានា ដូចជាគ្រឿងបន្លាស់ បរិក្ខារបម្រុង និងឧបករណ៍ជួសជុល ត្រូវបានទទួលស្គាល់ ស្របតាមផ្នែកនេះនៅពេលដែលធាតុទាំងនេះ បំពេញតាមនិយមន័យនៃទ្រព្យ រោងចក្រ និងបរិក្ខារ។ បើមិនដូច្នោះទេ គ្រឿងបន្លាស់ បរិក្ខារបម្រុង និងឧបករណ៍ជួសជុល ត្រូវបានចាត់ថ្នាក់ជាសន្និធិ។

១៧.៦ ផ្នែកនៃជាតុមួយចំនួនរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ អាចតម្រូវឱ្យមានការជំនួសក្នុងចន្លោះពេលជាធម្មតា (ដូចជា ដំបូលអគារ)។ អង្គភាពត្រូវបន្ថែមទៅក្នុងតម្លៃយោងរបស់ជាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ នូវថ្លៃដើមនៃផ្នែក ជំនួសនៃជាតុនោះ នៅពេលដែលថ្លៃដើមនោះបានកើតឡើង ប្រសិនបើផ្នែកដែលជំនួសត្រូវបានរំពឹងថានឹងផ្តល់ នូវប្រយោជន៍បន្ថែមនាពេលអនាគតដល់អង្គភាព។ តម្លៃយោងរបស់ផ្នែកទាំងនោះដែលត្រូវបានជំនួស គឺត្រូវបាន ឈប់ទទួលស្គាល់តាមកថាខណ្ឌ១៧.២៧-១៧.៣០ ដោយមិនគិតថា តើផ្នែកដែលបានជំនួសទាំងនោះ ត្រូវបាន រំលស់ដោយឡែកៗពីគ្នា ឬអត់ឡើយ។ ប្រសិនបើអង្គភាព មិនអាចកំណត់តម្លៃយោងនៃផ្នែកដែលបានផ្លាស់នោះ អង្គភាពអាចប្រើថ្លៃដើមការជំនួស ជាការបង្ហាញអំពីថ្លៃដើមនៃផ្នែកដែលបានជំនួសនោះ នៅពេលទិញ ឬបង្កើត ឡើង។ កថាខណ្ឌ១៧.១៦ ចែងថា ប្រសិនបើសមាសជាតុសំខាន់នៃជាតុមួយរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ មានវិធីសាស្ត្រខុសគ្នាខ្លាំងលើការប្រើអត្ថប្រយោជន៍សេដ្ឋកិច្ច អង្គភាពត្រូវធ្វើវិភាជន៍ថ្លៃដើមដំបូងនៃទ្រព្យសកម្មទៅ សមាសជាតុចម្បងរបស់ទ្រព្យនោះហើយត្រូវរំលស់សមាសជាតុនីមួយៗនេះដាច់ដោយឡែកសម្រាប់ អាយុកាល អាចប្រើបានរបស់សមាសជាតុនោះ។

១៧.៧ លក្ខខណ្ឌនៃការបន្តប្រតិបត្តិការលើជាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ (ដូចជា ឡានក្រុង) អាចត្រូវធ្វើ អធិការកិច្ច ចម្បងជាធម្មតាដើម្បីរកកំហុស ដោយមិនគិតថាតើផ្នែកនានានៃជាតុនោះត្រូវបានជំនួស។ នៅពេល ដែលអធិការកិច្ច ចម្បងត្រូវបានធ្វើឡើង ថ្លៃដើមរបស់វាត្រូវបានទទួលស្គាល់ក្នុងតម្លៃយោងរបស់ជាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ថាជាការដាក់ជំនួសឬទេ ប្រសិនបើលក្ខណៈវិនិច្ឆ័យនៃការទទួល ស្គាល់ត្រូវបានបំពេញ។ រាល់តម្លៃយោងដែល នៅសល់នៃថ្លៃដើមអធិការកិច្ចដែលបានធ្វើមុនៗ (ដែលចែកដាច់ពីផ្នែកជារូបវន្ត) មិនត្រូវបានទទួលស្គាល់ទេ។ ការ ធ្វើបែបនេះដោយមិនគិតពីថាតើ ថ្លៃដើមអធិការកិច្ចដែលបានធ្វើមុនៗ ត្រូវបានបញ្ជាក់នៅក្នុងប្រតិបត្តិការដែលក្នុង នោះជាតុនៃទ្រព្យត្រូវបានទិញ ឬសាងសង់ឡើង។ ប្រសិនបើចាំបាច់ ថ្លៃដើម ប៉ាន់ស្មាននៃអធិការកិច្ចប្រហាក់ ប្រហែលនាពេលអនាគតអាចត្រូវបានប្រើប្រាស់ជាសុច្ចនករមួយនៃអ្វី ដែលថ្លៃដើមនៃសមាសជាតុអធិការកិច្ចដែល មានស្រាប់ត្រូវបានធ្វើឡើង នៅពេលដែលជាតុនៃទ្រព្យត្រូវបាន ទិញឬសាងសង់ឡើង។

១៧.៨ ដីនិងអគារ គឺ ជាទ្រព្យសកម្មដែលអាចបំបែកចេញពីគ្នាបាន ហើយអង្គ ភាពត្រូវធ្វើគណនេយ្យកម្ម ដាច់ដោយឡែក ពីគ្នា ទោះបីជាពេលនោះវាទាំងពីរត្រូវបានទិញក្នុងពេលជាមួយគ្នា។

## ការវាស់វែងនាពេលទទួលស្គាល់

១៧.៩ អង្គភាពត្រូវវាស់វែងទ្រព្យ រោងចក្រ និងបរិក្ខានាពេលទទួលស្គាល់លើកដំបូងតាមថ្លៃដើមរបស់វា។

## សមាសធាតុនៃថ្លៃដើម

១៧.១០ ថ្លៃដើមនៃជាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ មានដូចខាងក្រោម ៖

(ក) ថ្លៃទិញ រួមទាំងសោហ៊ុយច្បាប់ និងសោហ៊ុយជើងសារ ពន្ធនាំចូលនិងពន្ធលើការទិញដែលមិនអាចទា រមក វិញបាន បន្ទាប់ពីការកាត់កងអប្បហាពាណិជ្ជកម្មនិងការបង្វិលត្រឡប់។

(ខ) ថ្លៃដើមនានាដែលចូលរួមដោយផ្ទាល់ក្នុងការនាំយកទ្រព្យសកម្មទៅដល់ទីកន្លែងនិងលក្ខខណ្ឌចាំបាច់ សម្រាប់អាចអោយវាយកទៅប្រើបានតាមការចង់បានរបស់អ្នកគ្រប់គ្រង។ ថ្លៃដើមទាំងនោះអាចរាប់បញ្ចូល នូវថ្លៃដើមរៀបចំកន្លែង ការប្រគល់និងទទួលបឋម ការដាក់តាំងបង្ហាញនិងការប្រមូលផ្តុំ ព្រមទាំង ការសាកល្បង ដំណើរការ។

(គ) ការប៉ាន់ស្មានជាបឋមនូវថ្លៃដើមនៃការរំលាយចោលឬការដកចេញនូវជាតុនិងការរក្សាទុកនូវទីតាំង ដែលជាតុ មួយនោះតាំងនៅ, គឺជាកាតព្វកិច្ចដែលអង្គភាពបង្ករឡើងទាំងនៅពេលដែលទ្រព្យនោះត្រូវបានទិញឬជា

ផលវិបាកដែលបានមកដោយការប្រើទ្រព្យនោះក្នុងអំឡុងពេលដ៏ជាក់លាក់មួយក្នុងគោលបំណងមិនមែនផលិតទំនិញ សម្រាប់ការិយបរិច្ឆេទនោះ។

១៧.១១ ថ្លៃដើមខាងក្រោម មិនមែនជាថ្លៃដើមនៃធាតុមួយរបស់ទ្រព្យ រោងចក្រ និងបរិក្ខារទេ ហើយអង្គភាពត្រូវទទួល ស្គាល់នូវថ្លៃដើមទាំងនោះថាជាចំណាយនៅពេលដែលវាបានកើតឡើង ៖

(ក) ថ្លៃដើមនៃការដាក់ឱ្យដំណើរការគ្រឿងបរិក្ខារថ្មី

(ខ) ថ្លៃដើមនៃការណែនាំផលិតផល ឬសេវាថ្មី (រួមទាំងថ្លៃដើមផ្សាយពាណិជ្ជកម្មនិងសកម្ម ភាពឃោសនាផ្សេងទៀត)

(គ) ថ្លៃដើមនៃការបើកអាជីវកម្មនៅទីតាំងថ្មីឬជាមួយអតិថិជនថ្មី( រួមបញ្ចូលទាំងថ្លៃដើមបណ្តុះបណ្តាលបុគ្គលិក)

(ឃ) ថ្លៃដើមចំណាយរដ្ឋបាលនិងចំណាយទូទៅផ្សេងទៀត និង

(ង) បន្ទុកលើប្រាក់កម្ចី (សូមមើលផ្នែកទី ២៥ ស្តីពី បន្ទុកលើប្រាក់កម្ចី)

១៧.១២ ចំណូលនិងចំណាយពាក់ព័ន្ធនឹងប្រតិបត្តិការបន្ទាប់បន្សំក្នុងអំឡុងពេលសាងសង់ឬអភិវឌ្ឍជាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់ក្នុងចំណេញឬខាត ប្រសិនបើប្រតិបត្តិការទាំងនោះមិនចាំបាច់ក្នុងការ នាំជាតុ នោះទៅទីកន្លែង និងលក្ខខណ្ឌប្រតិបត្តិការគោលដៅរបស់វាទេ។

## ការវាស់វែងថ្លៃដើម

១៧.១៣ ថ្លៃដើមនៃជាតុមួយរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ គឺជាថ្លៃសាច់ប្រាក់សមមូលនាកាលបរិច្ឆេទទទួលស្គាល់។ ប្រសិនបើការទូទាត់ត្រូវបានពន្យារលើសពីលក្ខខណ្ឌឥណទានជម្មតា ថ្លៃដើមគឺជាតម្លៃបច្ចុប្បន្ននៃការទូទាត់ នាពេលអនាគតទាំងអស់។

## ការដោះដូរទ្រព្យសកម្ម

១៧.១៤ ជាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ អាចត្រូវបានទទួលដោយការផ្តោះប្តូរជាមួយទ្រព្យសកម្មមិនមែនរូបិយវត្ថុ ឬជាមួយទ្រព្យសកម្ម, ឬគឺជាការបញ្ចូលគ្នាទាំងទ្រព្យសកម្មរូបិយវត្ថុនិងមិនមែនរូបិយវត្ថុ។ អង្គភាពត្រូវវាស់វែងថ្លៃដើមនៃទ្រព្យសកម្មដែលទទួលបានតាម តម្លៃសមស្រប វៀរលែងតែ (ក) ប្រតិបត្តិការផ្តោះប្តូរខ្វះខាតនូវសារជាតិពាណិជ្ជកម្ម ឬ (ខ)តម្លៃសមស្របទាំងទ្រព្យសកម្ម ដែលទទួលបាន ទាំងទ្រព្យសកម្មដែលបោះបង់ចោលអាចត្រូវបានវាស់វែងគួរឱ្យទុកចិត្តបាន។ ករណីនេះ ថ្លៃដើមរបស់ទ្រព្យសកម្ម ត្រូវបានវាស់វែងតាមតម្លៃយោងរបស់ទ្រព្យសកម្មដែលបានបោះបង់ចោល។

# ការវាស់វែងបន្ទាប់ពីការទទួលស្គាល់លើកដំបូង

១៧.១៥ អង្គភាពត្រូវជ្រើសរើសយកគំរូថ្លៃដើម នៅក្នុងកថាខណ្ឌ១៧.១៥ក ឬគំរូវាយតម្លៃឡើងវិញ នៅក្នុងកថាខណ្ឌ ១៧.១៥ខ ជាគោលនយោបាយគណនេយ្យរបស់ខ្លួន និងត្រូវអនុវត្តគោលនយោបាយនោះ ចំពោះថ្នាក់នៃទ្រព្យ រោងចក្រ និងបរិក្ខារទាំងមូល។ អង្គភាពត្រូវអនុវត្តគំរូថ្លៃដើមនោះចំពោះទ្រព្យវិនិយោគ ដែលតម្លៃសមស្របរបស់វាមិនអាចវាស់វែងគួរឱ្យទុកចិត្តបាន ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ។ អង្គភាពត្រូវទទួលស្គាល់ចំណាយនៃការបម្រើសេវាប្រចាំថ្ងៃនៃជាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ នៅក្នុងចំណេញ ឬខាត នៅក្នុងការិយបរិច្ឆេទដែលចំណាយ បានកើតឡើង។

# គំរូថ្លៃដើម

១៧.១៥ក អង្គភាពត្រូវវាស់វែងធាតុមួយរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ បន្ទាប់ពីការទទួលស្គាល់លើកដំបូង ដោយយកថ្លៃដើម ដករំលស់បង្គរនានានិងការខាតពីការថយចុះតម្លៃបង្គរនានា។

# គំរូវាយតម្លៃឡើងវិញ

១៧.១៥ខ អង្គភាពត្រូវវាស់វែងធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដែលតម្លៃសមស្របរបស់វា អាចវាស់វែងគួរឱ្យទុកចិត្តបាន ក្នុងបរិមាណដែលបានវាយតម្លៃ ដោយយកតម្លៃសមស្របនៅថ្ងៃវាយតម្លៃឡើងវិញ ដករំលស់បង្គរជាបន្តបន្ទាប់ និងការខាតដោយការថយចុះតម្លៃបង្គរ។ ការវាយតម្លៃឡើងវិញត្រូវធ្វើឡើង ដោយភាពទៀងទាត់គ្រប់គ្រាន់ ដើម្បីធានាថា តម្លៃយោង មិនមានភាពខុសគ្នាជាសារវន្តពីតម្លៃ ដែលនឹងត្រូវបានកំណត់ ដោយប្រើប្រាស់តម្លៃសមស្របនាចុងការិយបរិច្ឆេទរាយការណ៍។ កថាខណ្ឌ១១.២៧-១១.៣២ ផ្តល់គោលការណ៍ណែនាំអំពីការកំណត់តម្លៃសមស្រប។ ប្រសិនបើធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានវាយតម្លៃឡើងវិញ ថ្នាក់ទាំងមូលនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដែលទ្រព្យសកម្មនោះនៅក្នុងចំណោម ត្រូវតែធ្វើការវាយតម្លៃឡើងវិញ។

១៧.១៥គ ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មណាមួយ កើនឡើងដោយសារការវាយតម្លៃ ការកើនឡើងនោះត្រូវទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ និងបង្គរនៅក្នុងមូលធនក្រោមចំណងជើងនៃអតិរេកនៃការវាយតម្លៃ។ ទោះបីជាយ៉ាងនេះក្តី ការកើនឡើងនេះត្រូវទទួលស្គាល់ជាចំណេញ ឬខាត ក្នុងកម្រិតដែលវាត្រឡប់ការថយចុះពីការវាយតម្លៃលើទ្រព្យសកម្មដដែល ដែលបានទទួលស្គាល់ជាចំណេញ ឬខាតពីមុន។

១៧.១៥ឃ ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មណាមួយ ថយចុះដោយសារការវាយតម្លៃឡើងវិញ ការថយចុះនោះត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ ទោះបីជាយ៉ាងនេះក្តី ការថយចុះនោះ ត្រូវទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ ក្នុងកម្រិតនៃសមតុល្យឥណទាន ដែលកើតមាន នៅក្នុងអតិរេកនៃការវាយតម្លៃឡើងវិញ ទាក់ទិននឹងទ្រព្យសកម្មនោះ។ ការថយចុះ ដែលបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ កាត់បន្ថយបរិមាណ ដែលបានបង្គរនៅក្នុងមូលធនក្រោមចំណងជើងនៃអតិរេកនៃការវាយតម្លៃឡើងវិញ។

# ការដករំលស់

១៧.១៦ ប្រសិនបើសមាសធាតុចម្បងនៃធាតុរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ មានគំរូខុសគ្នាខ្លាំងនៃការប្រើអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច អង្គភាពត្រូវវិភាជថ្លៃដើមដំបូងនៃទ្រព្យសកម្មទៅក្នុងសមាសធាតុចម្បងរបស់វា ហើយត្រូវធ្វើការដករំលស់លើសមាសធាតុនីមួយៗដាច់ដោយឡែកពីគ្នាក្នុងអំឡុងជីវិតនៃការប្រើរបស់វា។ ទ្រព្យសកម្មដទៃទៀត ត្រូវបានដករំលស់ក្នុងអំឡុងជីវិតនៃការប្រើរបស់វាជាទ្រព្យសកម្មតែមួយ។ ជាមួយការលើកលែងមួយចំនួនដូចជាការដ្ឋានយកថ្មនិងទីតាំងប្រើសម្រាប់ការចាក់បំពេញដី, ដីមានអាយុកាលគ្មានកំនត់ ដូចនេ វាមិនត្រូវបានដករំលស់ទេ។

១៧.១៧ បន្ទុកកាត់រំលស់សម្រាប់ការិយបរិច្ឆេទនីមួយៗត្រូវបានទទួលស្គាល់ក្នុងចំណេញឬខាត លើកលែងតែផ្នែក ផ្សេងទៀតនៃស្តង់ដារនេះ តម្រូវឱ្យថ្លៃដើមត្រូវ បានទទួលស្គាល់ថាជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្ម។

ឧទាហរណ៍ ការកាត់រំលស់នៃទ្រព្យ រោងចក្រ និងបរិក្ខានៃការផលិតត្រូវបានបញ្ចូលក្នុងថ្លៃដើមនៃសន្និធិ (សូមមើលផ្នែកទី ១៣ ស្តីពីសន្និធិ)។

## ចំនួនទឹកប្រាក់ដែលអាចរំលស់បាន និងកាលបរិច្ឆេទរំលស់

១៧.១៨ អង្គភាពត្រូវធ្វើវិភាជនូវចំនួនទឹកប្រាក់អាចរំលស់បាន របស់ទ្រព្យសកម្មមួយដោយឈរលើមូលដ្ឋានជាប្រព័ន្ធក្នុងអំឡុងនៃអាយុជីវិតប្រើប្រាស់របស់វា។

១៧.១៩ កត្តានានា ដូចជា ការប្រែប្រួលនូវរបៀបប្រើទ្រព្យសកម្ម ការសឹករិចរិលធំៗដែលមិនបានគិតទុកមុន វិបុលភាពនៃបច្ចេកវិទ្យានិងការប្រែប្រួលលើថ្លៃទីផ្សារអាចបង្ហាញថាតម្លៃកាកសំណល់ឬជីវិតនៃការប្រើប្រាស់ទ្រព្យសកម្ម បានប្រែប្រួលចាប់តាំងពីកាលបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំថ្មីៗបំផុត។ ប្រសិនបើសុចនករទាំងនេះ កើតមានអង្គភាពត្រូវពិនិត្យឡើងវិញការប៉ាន់ស្មានរបស់ខ្លួនពីពេលមុនៗ ហើយត្រូវកែប្រែតម្លៃដែលនៅសល់ កែប្រែវិធីសាស្ត្រដករំលស់ ឬជីវិតនៃការប្រប្រាស់ទ្រព្យសកម្ម ប្រសិនបើការរំពឹងទុកជាក់ស្តែងខុសគ្នា។ អង្គភាពត្រូវគិត ការប្រែប្រួលតម្លៃដែលនៅសល់ វិធីសាស្ត្រដករំលស់ ឬជីវិតនៃការប្រប្រាស់ទ្រព្យសកម្ម ថាជាការប្រែប្រួលនៃ ការប៉ាន់ស្មានគណនេយ្យស្របតាមកថាខណ្ឌ ១០.១៥-១០.១៨។

១៧.២០ ការដករំលស់លើទ្រព្យសកម្ម ចាប់ផ្តើមនៅពេលដែលទ្រព្យនោះអាចយកទៅប្រើប្រាស់បាន មានន័យថាពេលដែលវានៅក្នុងទីតាំងនិងក្រោមលក្ខខណ្ឌចាំបាច់សម្រាប់វា ដើម្បីអាចប្រតិបត្តិការបានតាមសេចក្តីត្រូវការរបស់អ្នកគ្រប់គ្រង។ការដករំលស់ត្រូវបញ្ចប់នៅពេលដែលវាឈប់ត្រូវបានទទួលស្គាល់។ការដករំលស់មិនត្រូវបានបញ្ឈប់ទេ នៅពេលដែលទ្រព្យសកម្មនោះ ក្លាយទៅជាគ្មានប្រយោជន៍ (គ្មានបានការ) ឬត្រូវបានដកចេញពីសកម្មភាពប្រើប្រាស់ វៀរលែងតែទ្រព្យនោះ ត្រូវបានដករំលស់ចប់សព្វគ្រប់។ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏តាមវិធីសាស្ត្រដែលប្រើដើម្បីដករំលស់ សោហ៊ុយក្នុងការរំលស់ អាចស្មើនឹងសូន្យ នៅពេលដែលគ្មានផលិតកម្ម។

១៧.២១ អង្គភាពត្រូវចាត់ទុកកត្តាទាំងអស់ខាងក្រោមដើម្បីកំណត់អំពីជីវិតប្រើប្រាស់ទ្រព្យសកម្មមួយ ៖

(ក) ការប្រើប្រាស់ទ្រព្យសកម្មដែលបានរំពឹងទុក។ការប្រើប្រាស់ត្រូវបានវាយតម្លៃដោយយោងទៅលើសមត្ថភាពរំពឹងទុករបស់ទ្រព្យសកម្ម ឬ ទិន្នផលជារូបរាង។

(ខ) ការសឹករិចរិលជារូបរាងដែលបានរំពឹងទុកដែលអាស្រ័យទៅលើកត្តប្រតិបត្តិការ ដូចជាចំនួននៃវេននៃការប្រើទ្រព្យសកម្ម ព្រមទាំងកម្មវិធីជួសជុលនិងថែទាំង, និងការថែទាំនិងថែរក្សាទ្រព្យសកម្មពេលលែងប្រើ។

(គ) ភាពហួសសម័យនៃពាណិជ្ជកម្ម ឬបច្ចេកវិទ្យា ដែលបណ្តាលមកពីការប្រែប្រួល ឬបសិដ្ឋកម្មនៃផលិតកម្ម ឬដែលបណ្តាលមកពីការប្រែប្រួលនៃតម្រូវការទិន្នផលផលិតផលឬសេវាលើទីផ្សារ របស់ទ្រព្យសកម្ម។

(ឃ) ការដាក់កម្រិតតាមផ្លូវច្បាប់ ឬការកម្រិតប្រហាក់ប្រហែលលើការប្រើប្រាស់ទ្រព្យសកម្ម ដូចជា ការហួសកាលបរិច្ឆេទនៃភតិសន្យាពាក់ព័ន្ធ។

## វិធីសាស្ត្រដករំលស់

១៧. ២២ អង្គភាពត្រូវជ្រើសរើសវិធីសាស្ត្រដករំលស់មួយ ដែលបង្ហាញអំពីគំរូ ដែលអង្គភាពរំពឹងថានឹងប្រើអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចអនាគតរបស់ទ្រព្យសកម្ម។ វិធីសាស្ត្រដករំលស់ដែលអាចអនុវត្តបាន រួមមាន វិធីសាស្ត្រដករំលស់ថេរ វិធីសាស្ត្រកាត់បន្ថយសមតុល្យ និងវិធីសាស្ត្រដែលផ្អែកលើមូលដ្ឋាននៃការប្រើប្រាស់ ដូចជា វិធីសាស្ត្រដករំលស់តាមឯកតានៃការផលិត។

១៧.២៣ ប្រសិនបើមានការចង្អុលបង្ហាញថា មានការប្រែប្រួលខ្លាំងចាប់តាំងពីកាលបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំចុងក្រោយ

លើគំរូ ដែលអង្គភាពរំពឹងថានឹងប្រើអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៃទ្រព្យសកម្មនាពេលអនាគត អង្គភាពត្រូវពិនិត្យឡើងវិញលើវិធីសាស្ត្ររំលស់បច្ចុប្បន្នរបស់ខ្លួន និងប្តូរវិធីសាស្ត្ររំលស់ដើម្បីបង្ហាញឱ្យឃើញនូវគំរូ ថ្មី ប្រសិនបើ ការរំពឹងទុកបច្ចុប្បន្នខុសពីមុន។ អង្គភាពត្រូវចាត់ទុកការប្រែប្រួលនោះថាជាការប្រែប្រួលលើ ការប៉ាន់ស្មាន គណនេយ្យ ស្របតាម កថាខណ្ឌ ១០.១៥-១០.១៨។

# ការថយចុះតម្លៃ

## ការទទួលស្គាល់ និងការវាស់វែងការថយចុះតម្លៃ

១៧.២៤ នាកាលបរិច្ឆេទរាយការណ៍នីមួយៗ អង្គភាពត្រូវអនុវត្តតាមផ្នែកទី២៧ស្តីពីការថយចុះតម្លៃនៃទ្រព្យសកម្ម ដើម្បីកំណត់ថា តើជាតុណាមួយឬក្រុមនៃជាតុរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានថយចុះតម្លៃឬទេ ហើយប្រសិនបើដូច្នោះ តើវានឹងត្រូវទទួលស្គាល់និងវាស់វែងការខាតពីការថយចុះតម្លៃយ៉ាងដូចម្តេច។ ផ្នែកនេះនឹងពន្យល់ថា តើអង្គភាពត្រូវពិនិត្យឡើងវិញលើតម្លៃយោងនៃទ្រព្យសកម្មរបស់ខ្លួន នៅពេលណានិងយ៉ាងដូចម្តេច ហើយថាតើអង្គភាពកំណត់នូវចំនួនទឹកប្រាក់ដែលបានប្រមូលមកវិញបានលើទ្រព្យសកម្ម យ៉ាងដូចម្តេចនិងតើអង្គភាពទទួលស្គាល់ឬធ្វើឱ្យការខាតពីការថយចុះតម្លៃត្រឡប់មកវិញនៅពេលណា។

## សំណងទូទាត់សម្រាប់ការថយចុះតម្លៃ

១៧.២៥ អង្គភាពត្រូវបញ្ចូលក្នុងចំណេញឬខាតនូវសំណងទូទាត់ពីទតិយជនសម្រាប់ជាតុនានានៃទ្រព្យ រោងចក្រ និង បរិក្ខារ ដែលបានថយចុះតម្លៃ ត្រូវបានចាត់ទុកថាបានបាត់បង់ឬត្រូវបានបោះបង់ចោលតែនៅពេល ដែលសំណង ទូទាត់ បានក្លាយជាចំនួនអាចទារមកវិញបាន។

## ទ្រព្យ រោងចក្រ និងបរិក្ខារទុកសម្រាប់លក់

១៧.២៦ កថាខណ្ឌ២៧.៩(ច) ចែងថាផែនការបញ្ចេញចោលទ្រព្យសកម្មមុនកាលបរិច្ឆេទរំពឹងទុកដែលបានកំណត់ពីមុន គឺជាសុច្ចនករនៃការថយចុះតម្លៃ ដែលធ្វើជាគន្លឹះនៃការគណនាបរិមាណទឹកប្រាក់ ដែលទទួលបានមកវិញនៃទ្រព្យសកម្មសម្រាប់កំណត់ថា តើទ្រព្យសកម្មត្រូវបានថយចុះតម្លៃឬអត់។

# ការឈប់ទទួលស្គាល់

១៧.២៧ អង្គភាពត្រូវឈប់ទទួលស្គាល់ជាតុមយនៃទ្រព្យ រោងចក្រ និងបរិក្ខារ ៖

(ក) ពេលវាត្រូវបានបញ្ចេញចោល ឬ

(ខ) នៅពេលដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចអនាគតមិនត្រូវបានរំពឹងថានឹងទទួលបានពីវា ឬពីការលក់បញ្ចេញចោល។

១៧.២៨ អង្គភាពត្រូវទទួលស្គាល់ចំណេញ ឬការខាតបង់លើការឈប់ទទួលស្គាល់ជាតុណាមួយនៃទ្រព្យ រោងចក្រនិងបរិក្ខារក្នុងចំណេញឬខាត នៅពេលដែលជាតុនោះលែងត្រូវបានទទួលស្គាល់ (វៀរលែងតែ ផ្នែកទី ២២ ស្តីពីភតិសន្យាបានតម្រូវផ្ទុយពីនេះលើការលក់និងការធ្វើភតិសន្យាត្រឡប់)។ អង្គភាពមិនត្រូវធ្វើការចាត់ថ្នាក់ចំណេញជាចំណូលនោះទេ។

១៧.២៩ ក្នុងការកំណត់កាលបរិច្ឆេទបញ្ចេញចោលនូវជាតុមួយ អង្គភាពត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យក្នុង ផ្នែកទី ២៣ ស្តីពី ចំណូលសម្រាប់ការទទួលស្គាល់ចំណូលពីការលក់ទំនិញ។ ផ្នែកទី ២០ អនុវត្តចំពោះការបញ្ចេញចោល ដោយការលក់និងការធ្វើភតិសន្យាត្រឡប់។

១៧.៣០ អង្គភាពត្រូវកំណត់នូវចំណេញឬខាត ដែលកើតចេញពីការមិនទទួលស្គាល់លើជាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារ ថាជាភាពខុសគ្នារវាងចំណូលពីការបញ្ចេញចោលសរុប និងតម្លៃយោងនៃជាតុនោះ ប្រសិនបើមាន។

## ការលាតត្រដាង

១៧.៣១ អង្គភាពត្រូវលាតត្រដាងព័ត៌មានខាងក្រោម អំពីថ្នាក់នៃទ្រព្យ រោងចក្រ និងបរិក្ខារនីមួយៗ ដែលបានកំណត់អនុលោមតាមកថាខណ្ឌទី៤.១១(ក) និងដាច់ដោយឡែកសម្រាប់ទ្រព្យវិនិយោគ ដែលបានកត់ក្នុងបញ្ជីតាមថ្លៃដើមដករំលស់និងការថយចុះតម្លៃបង្គរ៖

(ក) មូលដ្ឋានវាស់វែងដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់អំពីតម្លៃយោងសរុប

(ខ) វិធីសាស្ត្ររំលស់ដែលបានប្រើប្រាស់

(គ) អាយុកាលប្រើប្រាស់នៃបរិក្ខារ និង អត្រារំលស់ដែលបានប្រើប្រាស់

(ឃ) តម្លៃយោងសរុប និងរំលស់បង្គរ (ដោយសរុបជាមួយផលបូក ការខាតបង់ដែលបាត់ទៅ) នាដើមនិងចុងការិយបរិច្ឆេទរាយការណ៍

(ង) ការផ្ទៀងផ្ទាត់តម្លៃយោងនៅដើម និងចុងការិយបរិច្ឆេទរាយការណ៍ ដោយបង្ហាញដាច់ដោយឡែកនូវ

១- ជាតុបន្ថែមផ្សេងៗ

២- ការបញ្ចេញចោល

៣- ការទទួលបាន ឬលទ្ធកម្ម តាមរយៈការរួមបញ្ចូលអាជីវកម្ម

៤- ការកើនឡើង ឬការថយចុះ ដោយសារការវាយតម្លៃឡើងវិញស្របតាមកថាខណ្ឌ១៧.១៥ខ-១៧.១៥ឃ និងពីការខាតបង់ពីការថយចុះតម្លៃ ដែលបានទទួលស្គាល់ ឬត្រូវបានត្រឡប់ទៅ ក្នុងចំណូលលម្អិតផ្សេងៗ ស្របតាមផ្នែកទី២៧

៥- ការផ្ទេរទៅ និងពីទ្រព្យវិនិយោគ ដែលកត់ក្នុងបញ្ជីតាម តម្លៃសមស្របតាមរយៈចំណេញឬខាត (សូមមើលកថាខណ្ឌ១៦.៨)

៦- ការខាតបង់ពីការថយចុះតម្លៃត្រូវបានទទួលស្គាល់ឬត្រូវបានត្រឡប់ទៅជាចំណេញ ឬខាត ស្របតាមផ្នែកទី២៧

៧- ការរំលស់ និង

៨- ការប្រែប្រួលផ្សេងទៀត។

ការផ្ទៀងផ្ទាត់នេះ មិនចាំបាច់បង្ហាញទេសម្រាប់ការិយបរិច្ឆេទមុនៗទេ។

១៧.៣២ អង្គភាពមួយ ក៏ត្រូវបង្ហាញផងដែរនូវ ៖

(ក) អត្ថិភាព និង តម្លៃយោងរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ ដែលអង្គភាពបានកំណត់នូវកម្មសិទ្ធិ ឬទ្រព្យ រោងចក្រ និងបរិក្ខារ ដែលត្រូវបានសន្យាដាក់ធានា បំណុល

(ខ) បរិមាណនៃចំណាយតាមកិច្ចសន្យាក្នុងទទួលបាននូវទ្រព្យ រោងចក្រ បរិក្ខារ និង

(គ) ប្រសិនបើអង្គភាពមួយមានទ្រព្យវិនិយោគ ដែលតម្លៃសមស្របរបស់វា មិនអាចវាស់វែងគួរឱ្យទុកចិត្តបាន ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ អង្គភាពនោះត្រូវលាតត្រដាងអំពីអង្គហេតុនោះ និងមូលហេតុដែលការវាស់វែងតម្លៃសមស្រប នឹងនាំឱ្យមានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ សម្រាប់ធាតុទាំងនោះនៃទ្រព្យវិនិយោគ។

១៧.៣៣ ប្រសិនបើធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានកត់ក្នុងបញ្ជីតាមតម្លៃដែលបានវាយតម្លៃឡើងវិញ អង្គភាពត្រូវលាតត្រដាងនូវព័ត៌មានដូចខាងក្រោម៖

(ក) កាលបរិច្ឆេទប្រសិទ្ធភាពនៃការវាយតម្លៃឡើងវិញ

(ខ) តើមានការចូលរួមពីអ្នកវាយតម្លៃឯករាជ្យឬទេ

(គ) វិធីសាស្ត្រ និងការសន្មតសំខាន់ ដែលបានអនុវត្តនៅក្នុងការប៉ាន់ស្មានតម្លៃសមស្របរបស់ធាតុទាំងនោះ

(ឃ) សម្រាប់ថ្នាក់នីមួយៗនៃទ្រព្យ រោងចក្រ និងបរិក្ខារដែលបានវាយតម្លៃឡើងវិញ តម្លៃយោង ដែលនឹងត្រូវបានទទួលស្គាល់ ប្រសិនបើទ្រព្យសកម្មទាំងនោះត្រូវបានកត់ក្នុងបញ្ជីតាមគំរូថ្លៃដើម និង

(ង) អតិរេកនៃការវាយតម្លៃឡើងវិញ ដោយគូសបញ្ជាក់អំពីការប្រែប្រួលសម្រាប់ការិយបរិច្ឆេទ និងការដាក់កំហិតណាមួយលើការបែងចែកសមតុល្យ ដល់ម្ចាស់ភាគហ៊ុន។

# ផ្នែកទី ១៨
# ទ្រព្យសកម្មអរូបីមិនមែនជាកេរ្តិ៍ឈ្មោះអាជីវកម្ម

## វិសាលភាពនៃផ្នែកនេះ

១៨.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មនូវរាល់ ទ្រព្យសកម្មអរូបី លើកលែងតែកេរ្តិ៍ឈ្មោះអាជីវកម្ម (សូមមើលផ្នែកទី ១៩ ស្តីពី ការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម) និងទ្រព្យសកម្មអរូបី ដែលកាន់កាប់ដោយអង្គភាពសម្រាប់លក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន (សូមមើលផ្នែកទី ១៣ ស្តីពីសន្និធិ និងផ្នែកទី ២៣ ស្តីពីចំណូល)។

១៨.២ ទ្រព្យសកម្មអរូបី គឺជាទ្រព្យដែលអាចសំគាល់ជាទ្រព្យសកម្មមិនមែនរូបិយវត្ថុ ដោយគ្មានរូបរាង។ ទ្រព្យសកម្មបែបនេះ អាចកំណត់បាននៅពេលដែល ៖

(ក) ទ្រព្យដែលអាចបែងចែកបាន ដូចជា អាចបែងចែក ឬញែកដាច់ពីអង្គភាព និងយកទៅលក់ ផ្ទេរ ផ្តល់អជ្ញាប័ណ្ណ ជួល ឬផ្លោះប្តូរ ទាំងជាលក្ខណៈដាច់ដោយឡែក ឬជាមួយកិច្ចសន្យា ជាមួយទ្រព្យសកម្ម ឬបំណុលពាក់ព័ន្ធ ឬ

(ខ) ទ្រព្យដែលកើតចេញពីកិច្ចសន្យាឬសិទ្ធិតាមផ្លូវច្បាប់ដទៃទៀត ដោយមិនគិតដល់ថាសិទ្ធិទាំងនោះអាចផ្ទេរឬអាចបំបែកបានពីអង្គភាព ឬពីសិទ្ធិនិងកាតព្វកិច្ចដទៃទៀតនោះទេ។

១៨.៣ ផ្នែកនេះមិនត្រូវអនុវត្តចំពោះ ៖

(ក) ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ

(ខ) សិទ្ធិលើធនធានរ៉ែ និងទុនបម្រុងលើធនធានរ៉ែ ដូចជាប្រេង ឧស្ម័នធម្មជាតិ និងធនធានមិនកើតឡើងវិញផ្សេងទៀត។

## ការទទួលស្គាល់

### គោលការណ៍ទូទៅនៃការទទួលស្គាល់ទ្រព្យសកម្មអរូបី

១៨.៤ អង្គភាពត្រូវអនុវត្តតាមលក្ខខណ្ឌទទួលស្គាល់ដែលមានចែងក្នុងកថាខណ្ឌ២.២៧ ក្នុងការកំណត់ការទទួល ស្គាល់ថាតើទ្រព្យនោះជាទ្រព្យសកម្មអរូបី។ ដូចនេះ អង្គភាពត្រូវទទួលស្គាល់នូវទ្រព្យសកម្មអរូបី ថាជាទ្រព្យសកម្មមួយ ប្រសិនបើ និង ក្នុងករណីបើ ៖

(ក) អត្ថប្រយោជន៍សេដ្ឋកិច្ចដែលបានរំពឹងទុកនាពេលអនាគតដែលភ្ជាប់ជាមួយទ្រព្យសកម្មនោះអាចនឹងហូរចូលអង្គភាព

(ខ) ថ្លៃដើម ឬតម្លៃរបស់ទ្រព្យសកម្ម បានវាស់វែងដោយមានភាពទុកចិត្ត និង

(គ) ទ្រព្យសកម្មមិនបានមកពីការចំណាយដែលកើតមាននៅក្នុងអង្គភាពលើធាតុអរូបីនោះ។

១៨.៥ អង្គភាពត្រូវធ្វើការវាយតម្លៃលើភវនីយភាពនៃអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបានរំពឹងទុកនាពេលអនាគត ដោយប្រើការសន្មតសមស្របនិងអាចទទួលយកបាន ដែលបង្ហាញឱ្យឃើញនូវការប៉ាន់ស្មានដ៏ល្អបំផុតរបស់អ្នកគ្រប់គ្រងលើលក្ខខណ្ឌសេដ្ឋកិច្ចដែលនឹងអាយុកាលអាចប្រើបានរបស់ទ្រព្យសកម្ម។

១៨.៦ អង្គភាពមួយប្រើការវិនិច្ឆ័យដើម្បីប៉ាន់ស្មានកម្រិតនៃភាពច្បាស់លាស់ដែលភ្ជាប់ទៅនឹងលំហូរនៃអត្ថប្រយោជន៍សេដ្ឋកិច្ចដែលភ្ជាប់ជាមួយការប្រើប្រាស់នូវទ្រព្យសកម្ម ដោយផ្អែកលើភ័ស្តុតាងដែលមាននៅពេលទទួលស្គាល់ដំបូង ដោយផ្តល់ទម្ងន់ខ្លាំងចំពោះភ័ស្តុតាងខាងក្រៅ។

១៨.៧ លក្ខណៈវិនិច្ឆ័យក្នុងការទទួលស្គាល់ភវនីយភាពក្នុងកថាខណ្ឌ ១៨.៤ (ក) តែងតែត្រូវបានចាត់ទុកថាគ្រប់គ្រាន់សម្រាប់ទ្រព្យសកម្មអរូបីដែលទទួលបានដោយឡែកពីគ្នា។

## ការទទួលបានជាផ្នែកមួយនៃការរួមបញ្ចូលអាជីវកម្ម

១៨.៨ ទ្រព្យសកម្មអរូបីដែលទទួលបានតាម ការរួមបញ្ចូលអាជីវកម្ម ត្រូវទទួលស្គាល់ វៀរលែងតែតម្លៃសមស្របរបស់វាមិនអាចវាស់វែងដោយការទុកចិត្ត ដោយគ្មានការចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ នាកាលបរិច្ឆេទទទួលបាន។

# ការវាស់វែងដំបូង

១៨.៩ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មអរូបីជាដំបូងតាមថ្លៃដើមរបស់វា។

## ការទទួលបានដាច់ដោយឡែក

១៨.១០ ថ្លៃដើមរបស់ទ្រព្យសកម្មអរូបីដែលទទួលបានដាច់ដោយឡែក មាន ៖

(ក) ថ្លៃទិញរបស់វា រួមទាំងពន្ធគយ និងពន្ធលើការទិញដែលមិនអាចប្រមូលមកវិញបាន បន្ទាប់ពីកាត់កងជាមួយអប្បហារពាណិជ្ជកម្មនិងការចុះថ្លៃ និង

(ខ) ថ្លៃដើមរួមផ្សំដោយផ្ទាល់នានាសម្រាប់រៀបចំទ្រព្យសកម្មសម្រាប់ប្រើប្រាស់តាមគោលបំណង។

## ការទទួលបានជាផ្នែកមួយនៃការរួមបញ្ចូលអាជីវកម្ម

១៨.១១ ប្រសិនបើទ្រព្យសកម្មអរូបី ត្រូវបានទទួលតាមការរួមបញ្ចូលអាជីវកម្ម ថ្លៃដើមនៃទ្រព្យសកម្មអរូបីនោះ គឺជា តម្លៃសមស្របនាកាលបរិច្ឆេទទទួលបាន។

## ការទទួលបានតាមរយៈអំណោយរបស់រដ្ឋាភិបាល

១៨.១២ ប្រសិនបើទ្រព្យសកម្មអរូបីត្រូវបានទទួលតាមរយៈ អំណោយរបស់រដ្ឋាភិបាល ថ្លៃដើមនៃទ្រព្យនោះ គឺជាតម្លៃសមស្របរបស់វានាកាលបរិច្ឆេទ ដែលអំណោយនោះត្រូវបានទទួល ឬនឹងអាចទទួលបាន ស្របតាមផ្នែកទី ២៤ ស្តីពី អំណោយរបស់រដ្ឋាភិបាល។

### ការដោះដូរទ្រព្យសកម្ម

១៨.១៣ ទ្រព្យសកម្មអរូបីអាចត្រូវបានទទួលតាមការផ្តោះប្តូរជាមួយទ្រព្យសកម្មមិនមែនរូបិយវត្ថុ ឬទ្រព្យសកម្ម, ឬ ការបញ្ចូលគ្នារវាងទ្រព្យសកម្មរូបិយវត្ថុនិងមិនមែនរូបិយវត្ថុ។ អង្គភាពត្រូវវាស់វែងថ្លៃដើមនៃទ្រព្យសកម្មអរូបី នេះតាមតម្លៃសមស្រប វៀរលែងតែ (ក)- ប្រតិបត្តិការផ្តោះប្តូរខ្វះនូវសារជាតិពាណិជ្ជកម្ម ឬ (ខ)-តម្លៃសមស្របនៃទ្រព្យសកម្មដែលទទួលបាននិងទាំងទ្រព្យសកម្មដែលបោះបង់ចោលមិនអាចវាស់វែងបានគួរឱ្យទុកចិត្តបាន។

ករណីនេះ ថ្លៃដើមនៃទ្រព្យសកម្ម ត្រូវបានវាស់វែងតាម តម្លៃយោង នៃទ្រព្យសកម្មដែលបានបោះបង់ចោល។

### ទ្រព្យសកម្មអរូបីដែលកើតឡើងផ្ទៃក្នុង

១៨.១៤ អង្គភាពត្រូវទទួលស្គាល់ចំណាយដែលកើតឡើងផ្ទៃក្នុងលើជាតុរូបអរូបិយ រួមបញ្ចូលទាំងចំណាយទាំងអស់សម្រាប់ទាំងសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍ ជាជាចំណាយ ដែលត្រូវបានកើតឡើង វៀរលែងតែ វាជាផ្នែកមួយនៃ ថ្លៃដើមរបស់ទ្រព្យសកម្មដទៃទៀត ដែលបំពេញលក្ខខណ្ឌទទួលស្គាល់ក្នុងស្តង់ដារនេះ។

១៨.១៥ ជាឧទាហរណ៍នៃការអនុវត្តកថាខណ្ឌមុនៗ អង្គភាពត្រូវទទួលស្គាល់ចំណាយលើធាតុនានាខាងក្រោមថាជាចំណាយ និងមិនត្រូវទទួលស្គាល់ការចំណាយថាជាទ្រព្យសកម្មអរូបី ៖

(ក) ស្លាកយីហោដែលបង្កើតឡើងដោយផ្ទៃក្នុង ស្លាកសញ្ញា សិទ្ធិនៃការបោះផ្សាយ បញ្ជីអតិថិជន និងធាតុប្រហាក់ប្រហែលៗ

(ខ) សកម្មភាពចាប់ផ្តើម (ដូចជា ថ្លៃចាប់ផ្តើម) ដែលរួមមានថ្លៃដើមបង្កបង្កើត ដូចជា ថ្លៃដើមខាងច្បាប់និងកិច្ចការលេខាធិការ ដែលបានកើតឡើងក្នុងការបង្កើតអង្គភាពតាមផ្លូវច្បាប់ ចំណាយក្នុងការបើករោងចក្រ ឬអាជីវកម្ម (ដូចជា ថ្លៃដើមមុនបើកដំណើរការ) និងចំណាយសម្រាប់ចាប់ប្រតិបត្តិការថ្មី ឬចាប់ផ្តើមបង្ហាញផលិតផល ឬដំណើរការថ្មី (ដូចជា ថ្លៃដើមមុនប្រតិបត្តិការដំបូង)

(គ) សកម្មភាពបណ្តុះបណ្តាល

(ឃ) សកម្មភាពផ្សព្វផ្សាយនិងផ្សាយពាណិជ្ជកម្ម

(ង) ការផ្លាស់ប្តូរទីតាំង ឬការរៀបចំផ្នែកឬអង្គភាពទាំងមូលឡើងវិញ

(ច) កេរ្តិ៍ឈ្មោះអាជីវកម្មដែលបង្កើតឡើងផ្ទៃក្នុង។

១៨.១៦ កថាខណ្ឌ១៨.១៥មិនបានរាំងការទទួលស្គាល់ការចំណាយមុនថាជាទ្រព្យសកម្ម នៅពេលដែលការចំណាយលើទំនិញឬសេវាត្រូវបានធ្វើឡើងមុនការមកដល់នូវទំនិញឬការផ្តល់សេវាកម្ម។

## ចំណាយពីអតីតកាលដែលមិនត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្ម

១៨.១៧ ចំណាយលើធាតុអរូបីមួយដែលត្រូវបានទទួលស្គាល់ដំបូងថាជាចំណាយ មិនត្រូវទទួលស្គាល់ ជាផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្មនៅកាលបរិច្ឆេទក្រោយនោះទេ។

## ការវាស់វែងបន្ទាប់ពីការទទួលស្គាល់

១៨.១៨ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មអរូបី ដោយយកថ្លៃដើមដករំលស់បង្គរនានា និងដកការខាតបង់ពី ការថយចុះតម្លៃបង្គរនានា។ តម្រូវការក្នុងការទទួលស្គាល់ការរំលស់លើទ្រព្យសកម្មអរូបីត្រូវបានកំណត់ក្នុងផ្នែកនេះ។ តម្រូវការក្នុងការទទួលស្គាល់ការថយចុះតម្លៃត្រូវបានកំណត់ក្នុងផ្នែកទី ២៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម។

## អាយុកាលអាចប្រើបាន

១៨.១៩ សម្រាប់គោលបំណងនៃស្តង់ដារនេះ រាល់ទ្រព្យសកម្មអរូបីទាំងអស់ត្រូវបានចាត់ទុកថាមានអាយុកាលប្រើប្រាស់មានកំណត់។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបីមួយដែលកើតពីសិទ្ធិតាមផ្លូវច្បាប់ ឬកើតពីសិទ្ធិតាមកិច្ចសន្យាមិនត្រូវលើសពីការិយបរិច្ឆេទនៃសិទ្ធិតាមផ្លូវច្បាប់ ឬសិទ្ធិតាមកិច្ចសន្យាទេ ប៉ុន្តែអាចមានរយៈ ពេលខ្លីជាងអាស្រ័យដោយការិយបរិច្ឆេទដែលអង្គភាពរំពឹងថានឹងប្រើប្រាស់ទ្រព្យសកម្មនោះ។ ប្រសិនបើសិទ្ធិតាមកិច្ចសន្យាឬសិទ្ធិតាមផ្លូវច្បាប់ដទៃទៀត ត្រូវបានផ្ទេរក្នុងរយៈពេលកំណត់មួយ ដែលអាចត្រូវបានធ្វើឡើងវិញ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបីត្រូវបញ្ចូលការិយបរិច្ឆេទធ្វើឡើងវិញ ប្រសិនបើមានភស្តុតាង បញ្ជាក់ការធ្វើឡើងវិញដោយអង្គភាពដោយគ្មានថ្លៃដើមចាំបាច់។

១៨.២០ ប្រសិនបើអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបី មិនអាចកំណត់ប្រកបដោយភាពឱ្យទុកចិត្តបាន អាយុកាលត្រូវធ្វើការកំណត់ផ្អែកលើការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតរបស់ថ្នាក់គ្រប់គ្រង តែមិនត្រូវឱ្យលើសពី ១០ឆ្នាំ ឡើយ។

### ការិយបរិច្ឆេទដករំលស់ និងវិធីសាស្រ្តដករំលស់

១៨.២១ អង្គភាពត្រូវធ្វើវិភាជចំនួនទឹកប្រាក់អាចរំលស់បានលើទ្រព្យសកម្មអរូបីដោយឈរលើមូលដ្ឋានជាប្រព័ន្ធក្នុងអំឡុងនៃ អាយុកាលប្រើប្រាស់របស់វា។ សោហ៊ុយរំលស់សម្រាប់ការិយបរិច្ឆេទនីមួយៗ ត្រូវទទួលស្គាល់ថាជាចំណាយ វៀរលែងតែផ្នែកផ្សេងទៀតរបស់ស្តង់ដារនេះតម្រូវឱ្យថ្លៃដើមត្រូវទទួលស្គាល់ថាជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្ម ដូចជា សន្និធិ ឬទ្រព្យ រោងចក្រ និងបរិក្ខារ។

១៨.២២ ការរំលស់ចាប់ផ្តើមនៅពេលដែលទ្រព្យសកម្មអរូបី អាចយកទៅប្រើប្រាស់បាន មានន័យថាពេលដែលវានៅក្នុងទីតាំងនិងក្រោមតាមលក្ខខណ្ឌចាំបាច់សម្រាប់វាដើម្បីអាចប្រតិបត្តិការបានតាមសេចក្តីត្រូវការអ្នកគ្រប់គ្រង។ ការដករំលស់ត្រូវបញ្ចប់ នៅពេលដែលទ្រព្យសកម្មឈប់ត្រូវបានទទួលស្គាល់។ អង្គភាពត្រូវជ្រើសរើសវិធីសាស្រ្តដករំលស់ដែលបង្ហាញអំពីគំរូដែលអង្គភាពរំពឹងនឹងអាស្រ័យលើផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់ទ្រព្យសកម្មនាពេលអនាគត។ ប្រសិនបើអង្គភាពមិនអាចកំណត់គំរូនោះគួរឱ្យទុកចិត្តបាន អង្គភាពត្រូវប្រើវិធីសាស្រ្តដករំលស់ថេរ។

### តម្លៃកាកសំណល់

១៨.២៣ អង្គភាពត្រូវសន្មតថា តម្លៃកាកសំណល់ របស់ទ្រព្យសកម្មអរូបីស្មើនឹងសូន្យ វៀរលែងតែ ៖

(ក) មានកិច្ចសន្យាពីសំណាក់តតិយជនក្នុងការទិញទ្រព្យសកម្មនាចុងអាយុកាលប្រើប្រាស់របស់វា ឬ

(ខ) មានទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ហើយ ៖

១- តម្លៃដែលនៅសល់អាចត្រូវបានកំណត់ដោយផ្អែកលើទីផ្សារនោះ និង

២- ទីផ្សារនោះអាចនឹងនៅមាននាចុងអាយុកាលប្រេប្រាស់របស់ទ្រព្យសកម្ម។

## ការត្រួតពិនិត្យឡើងវិញលើការិយបរិច្ឆេទដករំលស់ និងវិធីសាស្ត្រដករំលស់

១៨.២៤ កត្តានានា ដូចជា ការប្រែប្រួលនៃវិធីប្រើទ្រព្យសកម្មអរូបី ការប្រែប្រួលនៃការជឿនលឿននៃបច្ចេកវិទ្យា និង ការប្រែប្រួលលើថ្លៃទីផ្សារអាចបង្ហាញថាតម្លៃដែលនៅសល់ឬអាយុកាលប្រើប្រាស់ទ្រព្យសកម្មអរូបីត្រូវបានប្រែប្រួល ក្នុងអំឡុងកាលបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំថ្មីៗបំផុត។ប្រសិនបើសុច្ចនករនេះកើតមាន អង្គភាពត្រូវ ត្រួតពិនិត្យឡើងវិញលើការប៉ាន់ស្មានមុនៗរបស់ខ្លួន ហើយត្រូវកែប្រែតម្លៃដែលនៅសល់ កែប្រែវិធីសាស្ត្រដករំលស់ ឬអាយុកាលប្រើប្រាស់ ប្រសិនបើការប៉ាន់ស្មានបច្ចុប្បន្នខុសគ្នា។ អង្គភាពត្រូវចាត់ទុកការប្រែប្រួលលើតម្លៃដែលនៅសល់ កែប្រែវិធីសាស្ត្រដករំលស់ឬអាយុកាលប្រើប្រាស់ថាជា ការប្រែប្រួលលើ ការប៉ាន់ស្មានគណនេយ្យ ស្របតាមកថាខណ្ឌ ១០.១៥-១០.១៨។

## ការស្តារឡើងវិញនៃតម្លៃយោង - ការខាតពីការថយចុះតម្លៃ

១៨.២៥ ដើម្បីកំណត់ថាតើទ្រព្យសកម្មអរូបីមួយត្រូវបានថយចុះតម្លៃ អង្គភាពត្រូវអនុវត្តផ្នែកទី ២៧។ ផ្នែកនោះ ពន្យល់ថាតើអង្គភាពត្រួតពិនិត្យឡើងវិញលើតម្លៃយោងនៃទ្រព្យសកម្មរបស់ខ្លួនពេលណានិងយ៉ាងដូចម្តេច តើអង្គភាពកំណត់នូវចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន របស់ទ្រព្យសកម្មយ៉ាងដូចម្តេច ហើយតើនៅ ពេលណាអង្គភាពទទួលស្គាល់ ឬត្រលប់ការខាតពីការថយចុះតម្លៃ។

## ភាពហួសសម័យ និងការបញ្ចេញចោល

១៨.២៦ អង្គភាពត្រូវឈប់ទទួលស្គាល់ទ្រព្យសកម្មអរូបី និងត្រូវទទួលស្គាល់ចំណេញ ឬខាត ក្នុងចំណេញ ឬខាត៖

(ក) ពេលបញ្ចេញចោល ឬ

(ខ) នៅពេលដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចអនាគត មិនត្រូវបានរំពឹងនឹងទទួលបានពីការប្រើប្រាស់វាឬពីការបញ្ចេញចោល។

## ការលាតត្រដាង

១៨.២៧ អង្គភាពត្រូវលាតត្រដាងព័ត៌មានសម្រាប់ចំណាត់ថ្នាក់នីមួយៗនៃទ្រព្យសកម្មអរូបី ដូចខាងក្រោម ៖

(ក) អាយុកាលប្រើប្រាស់ ឬ អត្រាដករំលស់ដែលបានប្រើ។

(ខ) វិធីសាស្ត្រដករំលស់ដែលបានប្រើ។

(គ) តម្លៃយោងសរុប និងរំលស់បង្គរនានា (ដោយសរុបជាមួយផលបូក នូវការខាតបង់ ដែលបាត់ទៅ) នៅដើម និង នៅចុងការិយបរិច្ឆេទរាយការណ៍។

(ឃ) ជាតុបន្ទាត់នៅក្នុងរបាយការណ៍ចំណូលពេញលេញ( និងនៅក្នុងរបាយការណ៍លទ្ធផល ប្រសិនបើត្រូវបានបង្ហាញ) ដែលត្រូវបញ្ចូលនូវរំលស់នានាលើ ទ្រព្យសកម្មអរូបីដែលកើតមានឡើង។

(ង) ការផ្ទៀងផ្ទាត់តម្លៃយោងនៅដើម និង ចុងការិយបរិច្ឆេទរាយការណ៍ ដោយបង្ហាញដាច់ដោយឡែកនូវ ៖

១) ជាតុបន្ថែមផ្សេងៗ

២) ការបញ្ចេញចោល

៣) ការទទួលបាន ឬលទ្ធកម្ម តាមរយៈការរួមបញ្ចូលអាជីវកម្ម

៤) ការដករំលស់

៥) ការខាតពីការថយចុះតម្លៃ និង

៦) ការប្រែប្រួលផ្សេងទៀត។

ការផ្ទៀងផ្ទាត់នេះ មិនចាំបាច់បង្ហាញសម្រាប់ការិយបរិច្ឆេទមុនៗទេ។

១៨.២៨ អង្គភាពត្រូវលាតត្រដាងព័ត៌មានផងដែរនូវ ៖

(ក) ការពិពណ៌នា តម្លៃយោង និង ការិយបរិច្ឆេទរំលស់ដែលនៅសល់របស់ ទ្រព្យសកម្មអរូបីនីមួយៗ ដែលជាសារវន្តសម្រាប់របាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាព។

(ខ) ចំពោះទ្រព្យសកម្មអរូបីដែលទទួលបានតាមរយៈអំណោយរបស់រដ្ឋាភិបាល ហើយដែលត្រូវបានទទួល ស្គាល់ដំបូងតាមតម្លៃសមស្រប (មើលកថាខណ្ឌទី ១៨.១២) ៖

១- តម្លៃសមស្របដែលត្រូវបានទទួលស្គាល់ដំបូងសម្រាប់ទ្រព្យទាំងនោះ និង

២- តម្លៃយោងរបស់វា។

(គ) អត្ថិភាពនិងតម្លៃយោងនៃទ្រព្យសកម្មអរូបីដែលអង្គភាពបានកំណត់កម្មសិទ្ធិដល់វាឬ ដែលត្រូវបានសន្យាជានាបំណុល និង

(ឃ) បរិមាណនៃចំណាយតាមកិច្ចសន្យា ក្នុងការទទួលបាននូវទ្រព្យសកម្មអរូបី។

១៨.២៩ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីចំនួនសរុបនៃចំណាយលើការស្រាវជ្រាវនិងការអភិវឌ្ឍដែលត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទ (ដូចជា បរិមាណនៃចំណាយ ដែលកើតមានផ្ទៃក្នុងលើការស្រាវជ្រាវនិងការអភិវឌ្ឍ ដែលមិនត្រូវបានគិតគូរថាជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្មផ្សេងទៀត ដែលស្របតាមលក្ខណៈ វិនិច្ឆ័យទទួលស្គាល់ក្នុងស្តង់ដារនេះ)។

# ផ្នែកទី ១៩
# ការរួមបញ្ចូលអាជីវកម្ម និង កេរ្តិ៍ឈ្មោះអាជីវកម្ម

## វិសាលភាពនៃផ្នែកនេះ

១៩.១ ផ្នែកនេះអនុវត្តចំពោះគណនេយ្យកម្មសម្រាប់ការរួមបញ្ចូលអាជីវកម្ម។ ផ្នែកនេះផ្តល់ការណែនាំពីការកំណត់សញ្ញាណអ្នកទិញ ការវាស់វែងថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្ម និងការបែងចែកថ្លៃដើមនោះទៅក្នុងទ្រព្យសកម្ម ដែលបានទិញ និងបំណុល និងសំវិធានធនសម្រាប់បំណុលយថាហេតុដែលបានសន្មត។ បន្ថែមពីនេះ ផ្នែកនេះ ក៏បង្ហាញពីគណនេយ្យកម្មសម្រាប់កេរ្តិ៍ឈ្មោះអាជីវកម្មទាំងនៅពេលនៃការរួមបញ្ចូលអាជីវកម្ម និងការិយបរិច្ឆេទ បន្តបន្ទាប់។

១៩.២ ផ្នែកនេះបញ្ជាក់ពីការធ្វើគណនេយ្យកម្មសម្រាប់ការរួមបញ្ចូលអាជីវកម្ម លើកលែង:

(ក) ការបញ្ចូលអង្គភាព ឬអាជីវកម្មស្ថិតក្រោមការគ្រប់គ្រងរួម។ ការគ្រប់គ្រងរួមមានន័យថា រាល់អង្គភាព ឬអាជីវកម្មបញ្ចូលគ្នាត្រូវបានគ្រប់គ្រងចុងក្រោយដោយភាគីតែមួយ ឬភាគីច្រើនដែលទាំងមុន និងក្រោយ ការបញ្ចូលអាជីវកម្មដូចគ្នា ហើយការគ្រប់គ្រងនោះមិនមានការផ្លាស់ប្តូរទេ។

(ខ) ការបង្កើតក្រុមហ៊ុនរួមទុន។

(គ) ការទិញក្រុមទ្រព្យសកម្មដែលមិនមានបង្កើតជាអាជីវកម្ម។

## និយមន័យនៃការរួមបញ្ចូលអាជីវកម្ម

១៩.៣ ការរួមបញ្ចូលអាជីវកម្មគឺជាបញ្ចូលអង្គភាពឬអាជីវកម្មដោយឡែកៗពីគ្នា ឱ្យទៅជាអង្គភាពរាយការណ៍តែមួយ។ លទ្ធផលនៃការបញ្ចូលអាជីវកម្មស្ទើរតែទាំងអស់នេះ គឺអង្គភាពមួយដែលជាអ្នកទិញទទួលបានសិទ្ធិក្នុងការគ្រប់គ្រងអាជីវកម្មមួយឬច្រើនទៀតដែលជាអ្នកលក់។ ថ្ងៃទិញគឺថ្ងៃដែលអ្នកទិញទទួលបានការគ្រប់គ្រងពីអ្នកលក់។

១៩.៤ ការរួមបញ្ចូលអាជីវកម្មអាចត្រូវបានរៀបចំរចនាសម្ព័ន្ធតាមវិធីផ្សេងគ្នា សម្រាប់ហេតុផលផ្លូវច្បាប់ ពន្ធដារ ឬ ហេតុផលផ្សេងទៀត។ វាអាចជាការទិញមូលធនរបស់អង្គភាពមួយដោយអង្គភាពមួយទៀត ឬការទិញនៃទ្រព្យ សកម្មសុទ្ធរបស់អង្គភាពមួយទៀត ឬការទទួលយកបំណុលរបស់អង្គភាពមួយទៀត ឬការទិញចំណែកខ្លះនៃទ្រព្យ សកម្មសុទ្ធរបស់អង្គភាពមួយទៀតដែលរួមគ្នាបង្កើតជាអាជីវកម្មមួយឬច្រើនបាន។

១៩.៥ ការរួមបញ្ចូលអាជីវកម្មអាចមានប្រសិទ្ធភាពដោយការបោះផ្សាយឧបករណ៍មូលធន ឬការផ្ទេរសាច់ប្រាក់ ឬសាច់ប្រាក់សមមូល ឬទ្រព្យសកម្មផ្សេងទៀត ឬក៏ជាការបញ្ចូលគ្នាមួយនៃចំណុចខាងដើមនេះ។ ប្រតិបត្តិការអាច កើតឡើងរវាងម្ចាស់ភាគហ៊ុននានានៃអង្គភាពរួមបញ្ចូលគ្នា ឬរវាងអង្គភាពមួយ និងម្ចាស់ភាគហ៊ុននៃអង្គភាពមួយ ទៀត។ ការរួមបញ្ចូលអាជីវកម្មអាចបង្កើតឱ្យមាននូវអង្គភាពថ្មីមួយដើម្បីគ្រប់គ្រងអង្គភាពរួមបញ្ចូលគ្នា ឬទ្រព្យ សកម្មសុទ្ធដែលបានផ្ទេរ ឬការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃអង្គភាពមួយ ឬច្រើនដែលបានរួមបញ្ចូលគ្នា។

## អំពីគណនេយ្យ

១៩.៦ ការរួមបញ្ចូលអាជីវកម្មទាំងអស់ត្រូវបានធ្វើគណនេយ្យកម្មដោយអនុវត្តវិធីសាស្ត្រទិញ។

១៩.៧ ការអនុវត្តវិធីសាស្ត្រទិញរួមមានជំហានមួយចំនួនដូចខាងក្រោម:

(ក) កំណត់សញ្ញាណអ្នកទិញ

(ខ) វាស់វែងថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្ម និង

(គ) នៅថ្ងៃទិញ ត្រូវបែងចែកថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្មទៅក្នុងទ្រព្យសកម្មដែលបានទិញ និងបំណុល និងសំវិធានធនសម្រាប់បំណុលយថាហេតុដែលបានសន្មត។

## ការកំណត់សញ្ញាណអ្នកទិញ

១៩.៨ ការរួមបញ្ចូលអាជីវកម្មទាំងអស់ត្រូវកំណត់សញ្ញាណអ្នកទិញ។ អ្នកទិញគឺជាអង្គភាពរួមបញ្ចូលគ្នាដែលទទួលបានការគ្រប់គ្រងលើអង្គភាពឬអាជីវកម្មរួមបញ្ចូលគ្នាផ្សេងទៀត។

១៩.៩ ការគ្រប់គ្រងគឺជាអំណាចដើម្បីគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់អង្គភាពមួយដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់អង្គភាពនោះ។ ការគ្រប់គ្រងលើអង្គភាពមួយដោយអង្គភាពមួយទៀតត្រូវ បានពិព៌ណនាក្នុងផ្នែកទី៩ របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក។

១៩.១០ ទោះបីជាពេលខ្លះការកំណត់សញ្ញាណអ្នកទិញអាចពិបាក តែវាតែងតែមានសញ្ញាមួយចំនួនដែលបញ្ជាក់ពីសញ្ញាណអ្នកទិញ។ ឧទាហរណ៍៖

(ក) ប្រសិនបើតម្លៃសមស្របរបស់អង្គភាពមួយនៃអង្គភាពបញ្ចូលគ្នា មានតម្លៃខ្ពស់គួរឱ្យកត់សម្គាល់ជាង តម្លៃសមស្របនៃអង្គភាពរួមបញ្ចូលគ្នាមួយទៀត អង្គភាពដែលមានតម្លៃសមស្របខ្ពស់នោះគឺភាគច្រើនជាអ្នកទិញ។

(ខ) ប្រសិនបើការរួមបញ្ចូលអាជីវកម្មបង្កើតឡើងតាមរយៈនៃការដោះដូររវាងឧបករណ៍មូលធនធម្មតាដែលមានសិទ្ធិបោះឆ្នោត និងសាច់ប្រាក់ ឬទ្រព្យសកម្មផ្សេងទៀត អង្គភាពដែលបានចំណាយសាច់ប្រាក់ ឬទ្រព្យសកម្មនោះគឺភាគច្រើនជាអ្នកទិញ។

(គ) ប្រសិនបើការរួមបញ្ចូលអាជីវកម្មបង្កើតឱ្យគណៈគ្រប់គ្រងរបស់អង្គភាពមួយ នៃអង្គភាពរួមបញ្ចូលគ្នាមានលទ្ធភាពត្រួតត្រាការជ្រើសរើសក្រុមគណៈគ្រប់គ្រងនៃអង្គភាព ដែលបានរួមបញ្ចូលគ្នា អង្គភាពរបស់គណៈគ្រប់គ្រងដែលមានលទ្ធភាពត្រួតត្រាគឺភាគច្រើនជាអ្នកទិញ។

## ថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្ម

១៩.១១ អ្នកទិញត្រូវវាស់វែងថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្មជាតម្លៃសរុបនៃ:

(ក) តម្លៃសមស្របនៅថ្ងៃទិញនៃទ្រព្យសកម្មដែលបានផ្តល់ បំណុលដែលបានកើតឡើង ឬបានសន្មត និងឧបករណ៍មូលធនដែលបានបោះផ្សាយដោយអ្នកទិញជាការដោះដូរ ដើម្បីទទួលបានការគ្រប់គ្រងពីអ្នកលក់ បូកនឹង

(ខ) ចំណាយណាមួយដែលចូលរួមដោយផ្ទាល់ចំពោះការរួមបញ្ចូលអាជីវកម្ម។

## និយ័តកម្មលើថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្មដែលជាយថាហេតុលើព្រឹត្តិការណ៍អនាគត

១៩.១២ នៅពេលកិច្ចសន្យានៃការរួមបញ្ចូលអាជីវកម្មបង្ហាញ ឱ្យមាននិយ័តកម្មចំពោះថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្មជាយថាហេតុលើព្រឹត្តិការណ៍អនាគត អ្នកទិញត្រូវបញ្ចូលនូវចំនួនទឹកប្រាក់ប៉ាន់ស្មាននៃនិយ័តកម្មនេះនៅក្នុង ថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្មនៅថ្ងៃទិញ ប្រសិនបើនិយ័តកម្មនេះអាចនឹងកើតមាន និងអាចវាស់វែងគួរឱ្យទុកចិត្តបាន។

១៩.១៣ ម៉្យាងវិញទៀត ប្រសិនបើនិយ័តកម្មដែលអាចកើតមានមិនត្រូវបានទទួលស្គាល់នៅថ្ងៃទិញ ប៉ុន្តែបន្តបន្ទាប់មកអាចនឹងកើតមាន និងអាចវាស់វែងគួរឱ្យទុកចិត្តបាន នោះតម្លៃបន្ថែមនឹងត្រូវបានទទួលស្គាល់ជានិយ័តកម្មចំពោះថ្លៃ ដើមនៃការរួមបញ្ចូលអាជីវកម្ម។

ការបែងចែកថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្មចំពោះទ្រព្យសកម្មដែលបានទិញ និងបំណុល និង បំណុលយថាហេតុដែលបានសន្មត

១៩.១៤ នៅថ្ងៃទិញ អ្នកទិញត្រូវបែងចែកថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្មដោយទទួលស្គាល់ទ្រព្យសកម្ម និងបំណុលរបស់អ្នកលក់ដែលអាចកំណត់បាន និងសំវិធានធនចំពោះបំណុលយថាហេតុដែលបំពេញលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ក្នុងកថាខណ្ឌ១៩.១៥ តាមតម្លៃសមស្របនៅថ្ងៃទិញនោះ លើកលែងតែដូចខាងក្រោម៖

(ក) ទ្រព្យសកម្មពន្ធពន្យារ ឬបំណុលពន្ធពន្យារដែលកើតចេញពីទ្រព្យសកម្មដែលបានទិញ និងបំណុលដែលបានសន្មតនៅក្នុងការរួមបញ្ចូលអាជីវកម្មត្រូវបានទទួលស្គាល់ និងវាស់វែងអនុលោមតាមផ្នែកទី២៩ ស្តីពីពន្ធលើប្រាក់ចំណូល និង

(ខ) បំណុល (ឬទ្រព្យសកម្ម បើសិនជាមាន) ដែលទាក់ទិននឹងការរៀបចំអត្ថប្រយោជន៍និយោជិតរបស់អ្នកលក់ត្រូវទទួលស្គាល់ និងវាស់វែងអនុលោមតាមផ្នែកទី២៨ ស្តីពីអត្ថប្រយោជន៍និយោជិត។

ភាពខុសគ្នារវាងថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្ម និងភាគកម្មរបស់អ្នកទិញក្នុងតម្លៃសមស្របសុទ្ធរបស់ទ្រព្យសកម្មដែលអាចកំណត់បាន បំណុលដែលអាចកំណត់បាន និងសំវិធានធនចំពោះបំណុលយថាហេតុដែលអាចកំណត់បាន ត្រូវធ្វើគណនេយ្យកម្មដោយអនុលោមតាមកថាខណ្ឌ១៩.២២-១៩.២៤ (ជាកេរ្តិ៍ឈ្មោះអាជីវកម្ម ឬជាកេរ្តិ៍ឈ្មោះអាជីវកម្មអវិជ្ជមាន)។ ភាគកម្មមិនគ្រប់គ្រងណាមួយរបស់អ្នកលក់ត្រូវវាស់វែងតាមចំណែក សមាមាត្រនៃភាគកម្មនៃបរិមាណដែលបានទទួលស្គាល់នៃទ្រព្យសកម្មសុទ្ធដែលអាចកំណត់បានរបស់អ្នកលក់។

១៩.១៥ អ្នកទិញត្រូវទទួលស្គាល់ដាច់ដោយឡែកនូវទ្រព្យសកម្ម បំណុល និង បំណុលយថាហេតុដែលអាចកំណត់បានរបស់អ្នកលក់នៅថ្ងៃទិញតែក្នុងករណីដែលធាតុទាំងនោះបំពេញលក្ខខណ្ឌខាងក្រោមនៅថ្ងៃទិញនោះ៖

(ក) ក្នុងករណីទ្រព្យសកម្មមួយ (លើកលែងទ្រព្យសកម្មអរូបី) វាអាចនឹងមានអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតនានា ដែលផ្តល់ឱ្យអ្នកទិញ ហើយតម្លៃសមស្របរបស់វាអាចវាស់វែងគួរឱ្យទុកចិត្តបាន។

(ខ) ក្នុងករណីបំណុលមួយ (លើកលែងតែបំណុលយថាហេតុ) វាអាចនឹងមានលំហូរចេញនៃធនធាននឹងត្រូវបានតម្រូវឱ្យទូទាត់កាតព្វកិច្ច ហើយតម្លៃសមស្របរបស់វាអាចវាស់វែងគួរឱ្យទុកចិត្តបាន។

(គ) ក្នុងករណីទ្រព្យសកម្មអរូបី តម្លៃសមស្របរបស់វាអាចវាស់វែងគួរឱ្យទុកចិត្តបានដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ។

(ឃ) ក្នុងករណីបំណុលយថាហេតុ តម្លៃសមស្របរបស់វាអាចត្រូវបានវាស់វែងគួរឱ្យទុកចិត្តបាន។

១៩.១៦ បន្ទាប់ពីថ្ងៃទិញ របាយការណ៍ចំណូលពេញលេញរបស់អ្នកទិញត្រូវបញ្ចូលចំណេញ និងខាតរបស់អ្នកលក់ដោយបញ្ចូលចំណូល និងចំណាយដែលផ្អែកលើថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្មចំពោះអ្នកទិញ។ ឧទាហរណ៍ដូចជាបន្ទាប់ពីថ្ងៃទិញ ចំណាយរំលស់ទាក់ទងនឹងទ្រព្យសកម្មដែលអាចរំលស់បានរបស់អ្នកលក់ដែលត្រូវបញ្ចូលក្នុងរបាយការណ៍ចំណូលពេញលេញរបស់អ្នកទិញ ត្រូវផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មទាំងនោះនៅថ្ងៃទិញ ពោលគឺថ្លៃដើមនៃទ្រព្យសកម្មទាំងនោះចំពោះអ្នកទិញ។

១៩.១៧ ការអនុវត្តវិធីសាស្ត្រទិញត្រូវចាប់ផ្តើមពីថ្ងៃទិញ គឺជាថ្ងៃដែលអ្នកទិញទទួលបានការគ្រប់គ្រងលើអ្នកលក់។ ដោយសារតែការគ្រប់គ្រងគឺជាអំណាចក្នុងការគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់អង្គភាពមួយ ឬអាជីវកម្មមួយដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់អង្គភាពនោះ ដូចនេះប្រតិបត្តិការមួយនេះពុំចាំបាច់ដែលត្រូវបិទ ឬបញ្ចប់ដោយច្បាប់មុនពេលអ្នកទិញទទួលបានការគ្រប់គ្រង។ អង្គហេតុ និង ហេតុការណ៍សមស្របទាំងអស់ជុំវិញការរួមបញ្ចូលអាជីវកម្មត្រូវបានយកមកពិចារណាក្នុងការកំណត់ពេលដែលអ្នកទិញបានទទួលការគ្រប់គ្រង។

១៩.១៨ ដោយអនុលោមតាមកថាខណ្ឌ១៩.១៤ អ្នកទិញទទួលស្គាល់ដាច់ដោយឡែកតែទ្រព្យសកម្ម បំណុលនិង បំណុលយថាហេតុដែលអាចកំណត់បានរបស់អ្នកលក់ដែលមាននៅថ្ងៃទិញ និងបំពេញលក្ខខណ្ឌនៃការទទួល ស្គាល់មានចែងក្នុងកថាខណ្ឌ ១៩.១៥។ ដូចនេះ ៖

(ក) អ្នកទិញត្រូវទទួលស្គាល់បំណុលដើម្បីបញ្ចប់ ឬកាត់បន្ថយសកម្មភាពរបស់អ្នកលក់ដែលជាផ្នែកនៃការបែង ចែកថ្លៃដើមនៃការរួមបញ្ចូល តែនៅពេលដែលអ្នកលក់មានបំណុលសម្រាប់ធ្វើការរៀបចំរចនាសម្ព័ន្ធឡើងវិញដែលបានទទួលស្គាល់ដោយអនុលោមតាមផ្នែកទី ២១សំវិធានធន និង យថាហេតុ នៅថ្ងៃទិញ និង

(ខ) ពេលដែលបែងចែកថ្លៃដើមនៃការបញ្ចូលអាជីវកម្ម អ្នកទិញមិនត្រូវទទួលស្គាល់បំណុលសម្រាប់ការខាតនៅពេលអនាគត ឬចំណាយផ្សេងទៀតដែលបានរំពឹងថានឹងកើតឡើងបណ្តាលពីការរួមបញ្ចូលអាជីវកម្ម។

១៩.១៩ ប្រសិនបើការធ្វើគណនេយ្យកម្មលើកដំបូងសម្រាប់ការរួមបញ្ចូលអាជីវកម្មមិនទាន់បញ្ចប់បាននៅចុងការិយ បរិច្ឆេទរាយការណ៍ដែលការរួមបញ្ចូលគ្នាកើតមានឡើង អ្នកទិញត្រូវទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនូវ ចំនួនដែលបានប៉ាន់ប្រមាណនៃធាតុដែលមិនទាន់បានធ្វើគណនេយ្យកម្មចប់។ នៅក្នុងកំឡុងពេល១២ខែបន្ទាប់ ពីថ្ងៃទិញ អ្នកទិញត្រូវធ្វើនិយ័តកម្មត្រឡប់ថយក្រោយលើចំនួនដែលបានប៉ាន់ប្រមាណដែលបានទទួលស្គាល់ជា ទ្រព្យសកម្ម និងបំណុលនៅថ្ងៃទិញ (ពោលគឺ ធ្វើគណនេយ្យកម្មលើចំនួនដែលបានប៉ាន់ប្រមាណទាំងនោះប្រៀប ដូចការធ្វើគណនេយ្យកម្មនៅថ្ងៃទិញដែរ) ដើម្បីឆ្លុះបញ្ចាំងពីព័ត៌មានថ្មីដែលបានទទួល។ ក្រោយពី១២ខែបន្ទាប់ពី ថ្ងៃទិញ ការធ្វើនិយ័តកម្មចំពោះការធ្វើគណនេយ្យកម្មលើកដំបូងសម្រាប់ការរួមបញ្ចូលអាជីវកម្មត្រូវបានទទួល ស្គាល់ ដើម្បីតែកែប្រែកំហុសឆ្គងណាមួយដោយអនុលោមតាមផ្នែកទី១០ គោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និងកំហុសឆ្គង។

## បំណុលយថាហេតុ

១៩.២០ កថាខណ្ឌ ១៩.១៥ បញ្ជាក់ថាអ្នកទិញទទួលស្គាល់សំវិធានធនសម្រាប់បំណុលយថាហេតុរបស់អ្នកលក់ដាច់ដោយឡែក តែក្នុងករណីដែលតម្លៃសមស្របរបស់វាអាចវាស់វែងគួរឱ្យទុកចិត្តបាន។ ប្រសិនបើតម្លៃសមស្រប មិនអាចវាស់វែងគួរឱ្យទុកចិត្តបាន:

(ក) វាមានផលប៉ះពាល់លើចំនួនដែលបានទទួលស្គាល់ ឬបានធ្វើគណនេយ្យកម្មជាកេរ្តិ៍ឈ្មោះអាជីវកម្មដោយអនុលោមតាមកថាខណ្ឌ១៩.២៤ និង

(ខ) អ្នកទិញត្រូវលាតត្រដាងបង្ហាញព័ត៌មានអំពីបំណុលយថាហេតុនោះដូចដែលបានតម្រូវដោយផ្នែកទី២១ ។

១៩.២១ បន្ទាប់ពីការទទួលស្គាល់លើកដំបូង អ្នកទិញត្រូវវាស់វែងបំណុលយថាហេតុដែលត្រូវបានទទួលស្គាល់ដាច់ ដោយឡែកដោយអនុលោមតាមកថាខណ្ឌ១៩.១៤ តាមតម្លៃខ្ពស់ជាងនេះ:

(ក) ចំនួនដែលត្រូវបានទទួលស្គាល់ដោយអនុលោមតាមផ្នែកទី២១ និង

(ខ) ចំនួនដែលបានទទួលស្គាល់លើកដំបូងដកនឹងចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់ជាចំណូលពីមុន ដោយអនុលោមតាមផ្នែកទី២៣ ចំណូល។

## កេរ្តិ៍ឈ្មោះអាជីវកម្ម

១៩.២២ នៅថ្ងៃទិញ អ្នកទិញត្រូវ:

(ក) ទទួលស្គាល់កេរ្តិ៍ឈ្មោះអាជីវកម្មដែលទទួលបានក្នុងការរួមបញ្ចូលអាជីវកម្មជាទ្រព្យសកម្ម និង

(ខ) វាស់វែងជាលើកដំបូងនូវកេរ្តិ៍ឈ្មោះអាជីវកម្មនោះតាមថ្លៃដើមដែលបានពីចំនួនលើសនៃថ្លៃដើមរបស់ការរួម បញ្ចូលអាជីវកម្ម លើភាគកម្មរបស់អ្នកទិញក្នុងតម្លៃសមស្របសុទ្ធនៃទ្រព្យសកម្ម បំណុល និង បំណុលយថាហេតុ ដែលកំណត់បាន និងដែលបានទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ១៩.១៤។

១៩.២៣ បន្ទាប់ពីការទទួលស្គាល់លើកដំបូង អ្នកទិញត្រូវវាស់វែងកេរ្តិ៍ឈ្មោះអាជីវកម្មដែលទទួលបានក្នុងការរួមបញ្ចូលអាជីវកម្មតាមថ្លៃដើមដកនឹងរំលស់បង្គរលើទ្រព្យសកម្មអរូបី និងការខាតដោយការថយចុះតម្លៃ:

(ក) អង្គភាពត្រូវអនុវត្តតាមគោលការណ៍ក្នុងកថាខណ្ឌ១៨.១៩-១៨.២៤ សម្រាប់ការរំលស់កេរ្តិ៍ឈ្មោះអាជីវកម្ម។ ប្រសិនបើអាយុកាលអាចប្រើបានរបស់កេរ្តិ៍ឈ្មោះអាជីវកម្មមិនអាចកំណត់ប្រកបដោយភាពឱ្យទុកចិត្តបាន អាយុកាលនោះត្រូវបានកំណត់ផ្អែកលើការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតរបស់គណៈគ្រប់គ្រង តែមិនត្រូវឱ្យលើសពី ១០ឆ្នាំឡើយ។

(ខ) អង្គភាពត្រូវអនុវត្តតាមផ្នែកទី២៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម សម្រាប់ការទទួលស្គាល់ និងការវាស់វែងការថយចុះតម្លៃកេរ្តិ៍ឈ្មោះអាជីវកម្ម។

ចំនួនលើសនៃថ្លៃដើមនៃភាគកម្មរបស់អ្នកទិញលើតម្លៃសមស្របសុទ្ធនៃទ្រព្យសកម្ម បំណុល និង បំណុលយថាហេតុដែលកំណត់បានរបស់អ្នកលក់

១៩.២៤ ប្រសិនបើភាគកម្មរបស់អ្នកទិញក្នុងតម្លៃសមស្របសុទ្ធនៃទ្រព្យសកម្ម បំណុល និងសំវិធានធនសម្រាប់បំណុលយថាហេតុដែលកំណត់បាន និងដែលបានទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ១៩.១៤ លើសពីថ្លៃដើម នៃការរួមបញ្ចូលអាជីវកម្ម (ជួនកាលសំដៅទៅលើកេរ្តិ៍ឈ្មោះអាជីវកម្មអវត្តមាន) អ្នកទិញត្រូវ:

(ក) វាយតម្លៃឡើងវិញពីអត្តសញ្ញាណកម្ម និងការវាស់វែងលើទ្រព្យសកម្ម បំណុល និងសំវិធានធនសម្រាប់បំណុលយថាហេតុរបស់អ្នកលក់ និការវាស់វែងថ្លៃដើមនៃការរួមបញ្ចូលគ្នា និង

(ខ) ទទួលស្គាល់ភ្លាមក្នុងចំណេញ ឬខាតនូវចំនួនលើសដែលនៅសល់បន្ទាប់ពីការវាយតម្លៃនោះ។

# ការលាតត្រដាង

## សម្រាប់ការរួមបញ្ចូលអាជីវកម្មក្នុងការិយបរិច្ឆេទរាយការណ៍

១៩.២៥ សម្រាប់ការរួមបញ្ចូលអាជីវកម្មនីមួយៗក្នុងការិយបរិច្ឆេទ អ្នកទិញត្រូវលាតត្រដាងនូវព័ត៌មានដូចខាងក្រោមៈ

(ក) ឈ្មោះ និងពិពណ៌នាពីអង្គភាព ឬ អាជីវកម្មដែលរួមបញ្ចូលគ្នា

(ខ) ថ្ងៃទិញ

(គ) ភាគរយនៃឧបករណ៍មូលធនមានសិទ្ធិបោះឆ្នោតដែលបានទិញ

(ឃ) ថ្លៃដើមនៃការរួមបញ្ចូលអាជីវកម្ម និងពិពណ៌នានៃសមាសធាតុនៃថ្លៃដើមនោះ (ដូចជា សាច់ប្រាក់ ឧបករណ៍មូលធន និងឧបករណ៍បំណុល)

(ង) ចំនួនដែលបានទទួលស្គាល់នៅថ្ងៃទិញសម្រាប់ថ្នាក់នីមួយៗនៃទ្រព្យសកម្ម បំណុល និងបំណុលយថាហេតុរបស់អ្នកលក់ រួមទាំងកេរ្តិ៍ឈ្មោះអាជីវកម្មផង

(ច) ចំនួនលើសណាមួយដែលបានទទួលស្គាល់ក្នុងចំណេញ ឬខាតដោយអនុលោមតាមកថាខណ្ឌ ១៩.២៤ និងធាតុក្នុងជួរនីមួយៗនៃរបាយការណ៍ចំណូលពេញលេញ (និងក្នុងរបាយការណ៍លទ្ធផល ប្រសិនបានបង្ហាញ) ករណីដែលចំនួនលើសនោះត្រូវបានទទួលស្គាល់។

(ឆ) ការពិពណ៌នាផ្នែកគុណភាពអំពីកត្តាទាំងឡាយ ដែលបង្កើតនូវកេរ្តិ៍ឈ្មោះអាជីវកម្ម ដែលត្រូវបានទទួលស្គាល់ដូចជាផលចំណេញរំពឹងទុកដែលបានពីការរួមបញ្ចូលប្រតិបត្តិការរបស់អ្នកលក់ និងអ្នកទិញ ឬទ្រព្យសកម្មអរូបី ឬធាតុផ្សេងៗទៀតដែលមិនបានទទួលស្គាល់ស្របតាមកថាខណ្ឌ១៩.១៥។

## សម្រាប់ការរួមបញ្ចូលអាជីវកម្មទាំងអស់

១៩.២៦ អ្នកទិញត្រូវលាតត្រដាងពីអាយុកាលប្រើប្រាស់ដែលបានប្រើលើកេរ្តិ៍ឈ្មោះអាជីវកម្ម និងការផ្ទៀងផ្ទាត់នៃតម្លៃ យោងរបស់កេរ្តិ៍ឈ្មោះអាជីវកម្មនៅដើមគ្រា និងចុងការិយបរិច្ឆេទរាយការណ៍ ដោយបង្ហាញដាច់ដោយឡែកពីគ្នា នូវៈ

(ក) ការផ្លាស់ប្តូរដែលកើតឡើងពីការរួមបញ្ចូលអាជីវកម្មថ្មី

(ខ) ការខាតពីការថយចុះតម្លៃ

(គ) ការលក់អាជីវកម្មដែលបានទិញពីមុន និង

(ឃ) ការប្រែប្រួលផ្សេងទៀត។

ការផ្ទៀងផ្ទាត់មិនចាំបាច់ត្រូវបង្ហាញសម្រាប់ការិយបច្ឆេទមុនៗឡើយ។

# ផ្នែកទី ២០
# ភតិសន្យា

## វិសាលភាពនៃផ្នែកនេះ

២០.១ ផ្នែកនេះគ្របដណ្ដប់ការធ្វើគណនេយ្យកម្មលើភតិសន្យាទាំងអស់ លើកលែងតែ:

(ក) ភតិសន្យាដើម្បីរុករក ឬប្រើប្រាស់ធនធានរ៉ែ ប្រេង ហ្គាសធម្មជាតិ និង ធនធានមិនបង្កើតឡើងវិញ (សូមមើលផ្នែកទី៣៤ សកម្មភាពពិសេស)

(ខ) កិច្ចព្រមព្រៀងផ្ដល់អាជ្ញាបណ្ណសម្រាប់ធាតុទាំងឡាយ ដូចជា ខ្សែភាពយន្តទស្សនីយភាព ការថតចំលងខ្សែភាពយន្ត ខ្សែភាពយន្ត អត្ថបទសរសេរ ប៉ាតង់ និងកម្មសិទ្ធិបញ្ញា (សូមមើលផ្នែកទី១៨ ទ្រព្យសកម្មអរូបីដែលមិនមែនជាកេរ្តិ៍ឈ្មោះអាជីវកម្ម)។

(គ) ការវាស់វែងទ្រព្យរក្សាទុកដោយភតិកៈដែលត្រូវធ្វើគណនេយ្យកម្មជាទ្រព្យវិនិយោគ និងការវាស់វែងទ្រព្យវិនិយោគផ្ដល់ដោយភតិបតីក្រោមភតិសន្យាប្រតិបត្តិការ (សូមមើលផ្នែកទី១៦ ទ្រព្យវិនិយោគ)។

(ឃ) ការវាស់វែងទ្រព្យជីវសាស្ត្រដែលរក្សាទុកដោយភតិកៈក្រោមភតិសន្យាហិរញ្ញវត្ថុ និង ទ្រព្យជីវសាស្ត្រដែលផ្ដល់ដោយភតិបតីក្រោមភតិសន្យាប្រតិបត្តិការ (សូមមើលផ្នែកទី៣៤)

(ង) ភតិសន្យាដែលអាចនាំដល់ការខាតបង់ចំពោះភតិបតី

ឬភតិកៈដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងដែលមិនពាក់ព័ន្ធនឹងការផ្លាស់ប្ដូរតម្លៃទ្រព្យសកម្មដែលបានធ្វើភតិសន្យា ការផ្លាស់ប្ដូរអត្រាប្ដូរប្រាក់ ការប្រែប្រួលក្នុងការទូទាត់ភតិសន្យាផ្អែកលើអត្រាការប្រាក់ទីផ្សារប្រែប្រួល ឬការខូចខាតដោយភាគីណាមួយ (សូមមើលកថាខណ្ឌ១២.៣(ច) និង

(ច) ភតិសន្យាប្រតិបត្តិការដែលនាំឱ្យមានការខាតបង់។

២០.២ ផ្នែកនេះអនុវត្តចំពោះកិច្ចព្រមព្រៀងដែលផ្ទេរសិទ្ធិដើម្បីប្រើប្រាស់ទ្រព្យសកម្មទោះបីសេវាកម្មសំខាន់ៗផ្ដល់ដោយភតិបតីអាចត្រូវបានស្នើឡើងក្នុងការជាប់ពាក់ព័ន្ធជាមួយប្រើប្រាស់ឬការថែទាំទ្រព្យសកម្មនោះ។ ផ្នែកនេះមិនអនុវត្តចំពោះកិច្ចព្រមព្រៀងដែលជាកិច្ចសន្យាសម្រាប់សេវាកម្មដែលមិនផ្ទេរសិទ្ធិ ដើម្បីប្រើប្រាស់ទ្រព្យសកម្មពីភាគីមួយទៅភាគីមួយទៀត។

២០.៣ កិច្ចព្រមព្រៀងខ្លះ ដូចជាកិច្ចព្រមព្រៀងជួលសេវាខាងក្រៅ កិច្ចសន្យាលើសេវាទំនាក់ទំនងដែលផ្ដល់សិទ្ធិលើសមត្ថភាព និងកិច្ចសន្យាទទួល ឬទូទាត់ មិនមានទម្រង់ច្បាប់ជាភតិសន្យា ប៉ុន្តែមានការផ្ទេរសិទ្ធិដើម្បីប្រើប្រាស់ទ្រព្យសកម្មជាថ្នូរនៃការទូទាត់សង។ កិច្ចព្រមព្រៀងបែបនេះជាភតិសន្យាទ្រព្យសកម្មជាក់ស្ដែង ហើយទ្រព្យសកម្មទាំងនោះត្រូវធ្វើគណនេយ្យកម្មក្រោមផ្នែកនេះ។

# ការចាត់ថ្នាក់ភតិសន្យា

២០.៤ ភតិសន្យាត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ ប្រសិនបើភតិសន្យានេះផ្ទេរហានិភ័យ និងផលប្រយោជន៍សំខាន់ៗទាំងអស់ចំពោះកម្មសិទ្ធ។ ភតិសន្យាត្រូវបានចាត់ថ្នាក់ជា ភតិសន្យាប្រតិបត្តិការ ប្រសិនបើ ភតិសន្យានោះមិនផ្ទេរហានិភ័យនិងផលប្រយោជន៍សំខាន់ៗទាំងអស់ចំពោះកម្មសិទ្ធិ។

២០.៥ ភតិសន្យាមួយជាភតិសន្យាហិរញ្ញវត្ថុឬភតិសន្យាប្រតិបត្តិការ អាស្រ័យលើសារៈសំខាន់នៃ ប្រតិបត្តិការជាជាងទម្រង់នៃកិច្ចព្រមព្រៀង។ ឧទាហរណ៍ចំពោះហេតុការណ៍មួយចំនួន ដែលហេតុការណ៍មួយឬរួមគ្នា ជាធម្មតានាំអោយភតិសន្យាត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ គឺ:

(ក) ភតិសន្យាផ្ទេរកម្មសិទ្ធិនៃទ្រព្យសកម្មទៅឱ្យភតិកៈនៅចុងបញ្ចប់នៃភតិសន្យា

(ខ) ភតិកៈមានជម្រើសដើម្បីទិញទ្រព្យសកម្មនៅតម្លៃមួយដែលត្រូវបានរំពឹងថា នឹងទាបជាងតម្លៃសមស្របនៅកាលបរិច្ឆេទដែលជម្រើសនោះអាចអនុវត្តបានដើម្បីអោយមានភាពប្រាកដប្រជាថាជម្រើសនោះនឹងត្រូវបានអនុវត្តនៅពេលចាប់ផ្តើមធ្វើភតិសន្យា

(គ) រយៈពេលនៃភតិសន្យាមានភាគច្រើនជារយៈពេលនៃអាយុកាលរបស់ទ្រព្យសកម្ម ទោះបីជាកម្មសិទ្ធិមិនត្រូវបានផ្ទេរក៏ដោយ

(ឃ) នៅពេលចាប់ផ្តើមភតិសន្យាតម្លៃបច្ចុប្បន្ន នៃការទូទាត់ភតិសន្យាអប្បបរមាមានចំនួនយ៉ាងហោចណាស់ស្មើនឹងតម្លៃសមស្របនៃទ្រព្យសកម្មដែលបានធ្វើភតិសន្យា។

(ង) ទ្រព្យបានធ្វើភតិសន្យាដែលមានលក្ខណៈពិសេសដែលមានតែភតិកៈទេអាចប្រើទ្រព្យសកម្មនោះ ដោយគ្មានការផ្លាស់ប្តូរសំខាន់ៗ

២០.៦ សុច្ចនករពីហេតុការណ៍ដែលហេតុការណ៍នីមួយៗ ឬ រួមបញ្ចូលគ្នា អាចនាំឱ្យមានភតិសន្យាត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ គឺ:

(ក) ប្រសិនបើភតិកៈអាចលុបចោលភតិសន្យា នោះការខាតបង់របស់ភតិបតីទាក់ទងនឹងការ លុបចោលគឺទទួលខុសត្រូវដោយភតិកៈ។

(ខ) ចំណេញ ឬ ខាត ពីការឡើងចុះតម្លៃកាកសំណល់នៃទ្រព្យសកម្មបានភតិសន្យាបង្គរចំពោះភតិកៈ( ឧ. ក្នុងទម្រង់ការបញ្ចុះតម្លៃជួលស្មើនឹងភាគច្រើននៃចំណូលពីការលក់នៅចុង បញ្ចប់នៃភតិសន្យា)

(គ) ភតិកៈមានលទ្ធភាពបន្តភតិសន្យាសម្រាប់រយៈពេលទី២ ជាការជួលដែលមានតម្លៃទាបច្រើនជាងតម្លៃជួលនៅលើទីផ្សារ។

២០.៧. ឧទាហរណ៍ និងសុច្ចនករ នៅក្នុងកថាខណ្ឌ ២០.៥ និង២០.៦ មិនតែងតែច្បាស់លាស់ទេ។ ប្រសិនបើលក្ខណៈផ្សេងទៀតមានភាពច្បាស់លាស់ថាភតិសន្យាមិនផ្ទេរហានិភ័យនិងផលប្រយោជន៍សំខាន់ៗ ទាំងអស់ទាក់ទងនឹងកម្មសិទ្ធិ ភតិសន្យានោះត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។ ជាឧទាហរណ៍ អាចជាករណីមួយប្រសិនបើកម្មសិទ្ធិនៃទ្រព្យសកម្មត្រូវបានផ្ទេរទៅឱ្យភតិកៈនៅចុងបញ្ចប់នៃភតិសន្យា

សម្រាប់ការទូទាត់អថេរស្មើនឹងតម្លៃសមស្របនៃទ្រព្យសកម្ម ឬ ប្រសិនបើមានការជួលយថាហេតុ ជាលទ្ធផលដែលភតិកៈមិនមានហានិភ័យ និងផលប្រយោជន៍សំខាន់ៗទាំងអស់ទាក់ទងនឹងកម្មសិទ្ធិ។

២០.៨ ការចាត់ថ្នាក់ភតិសន្យាត្រូវបានធ្វើឡើងនៅពេលចាប់ផ្ដើមធ្វើភតិសន្យា និង មិនត្រូវបានផ្លាស់ប្ដូរក្នុងអំឡុងពេលភតិសន្យាលុះត្រាតែភតិកៈនិងភតិបតីយល់ព្រមផ្លាស់ប្ដូរកិច្ចព្រមព្រៀង ភតិសន្យា (មិនមែន ការបន្តកិច្ចព្រមព្រៀងធម្មតាតាមនោះទេ) នៅក្នុងករណីនេះការចាត់ថ្នាក់ភតិសន្យាត្រូវតែ វាយតម្លៃឡើងវិញ។

# របាយការណ៍ហិរញ្ញវត្ថុរបស់ភតិកៈ - ភតិសន្យាហិរញ្ញវត្ថុ

## ការទទួលស្គាល់លើកដំបូង

២០.៩ នៅពេលចាប់ផ្ដើមនៃរយៈពេលភតិសន្យា ភតិកៈត្រូវទទួលស្គាល់សិទ្ធិប្រើប្រាស់និងកាតព្វកិច្ច ក្រោមភតិសន្យាហិរញ្ញវត្ថុជាទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាមចំនួនទឹកប្រាក់ស្មើនឹងតម្លៃសមស្របនៃទ្រព្យដែលបានធ្វើភតិសន្យា ឬ ប្រសិនបើទាបជាងគឺតម្លៃបច្ចុប្បន្ននៃការទូទាត់សងភតិសន្យា អប្បបរមាត្រូវបានកំណត់នៅពេលចាប់ផ្ដើមភតិសន្យាដំបូង។ ចំណាយផ្ទាល់ ដំបូងណាមួយរបស់ភតិកៈ (ចំណាយផ្សេងៗដែលចូលរួមដោយផ្ទាល់ក្នុងការចរចារនិងការរៀបចំភតិសន្យា) ត្រូវបានបញ្ចូលទៅក្នុង តម្លៃទ្រព្យសកម្ម។

២០.១០ តម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាអប្បបរមា ត្រូវបានគណនាដោយប្រើអាត្រាការប្រាក់បង្កប់ក្នុងភតិសន្យា។ ប្រសិនបើអត្រានេះមិនអាចកំណត់បាន គេអាចប្រើអត្រាការប្រាក់កម្ចីបន្ថែមរបស់ភតិកៈបាន។

## ការវាស់វែងបន្ទាប់

២០.១១ ភតិកៈត្រូវញែកការទូទាត់ភតិសន្យាអប្បបរមារវាងចំណាយហិរញ្ញវត្ថុ និងការកាត់បន្ថយបំណុលដែលនៅសល់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព (សូមមើលកថាខណ្ឌ១១.១៥-១១.២០) ។ ភតិកៈត្រូវបែងចែកចំណាយហិរញ្ញវត្ថុចំពោះការិយបរិច្ឆេទនីមួយៗក្នុងអំឡុងពេលភតិសន្យា ដើម្បីបង្កើតអត្រាការប្រាក់ថេរលើសមតុល្យបំណុលនៅសល់។ ភតិកៈត្រូវគិតការជួលយថាហេតុ ជាចំណាយនៅក្នុងគ្រាដែលការជួលនោះកើតឡើង។

២០.១២ ភតិកៈត្រូវរំលស់ទ្រព្យសកម្មដែលបានធ្វើភតិសន្យាក្រោមភតិសន្យាហិរញ្ញវត្ថុ ដោយអនុលោម តាមផ្នែកពាក់ព័ន្ធនៃស្តង់ដារនេះសម្រាប់ប្រភេទទ្រព្យសកម្មនោះ ជាឧទាហរណ៍ ផ្នែកទី១៧ ទ្រព្យ រោងចក្រ និង បរិក្ខារ ផ្នែកទី១៨ ឬ ផ្នែកទី១៩ ការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម។

ប្រសិនបើមិនមានភាពច្បាស់លាស់ដែលថាភតិកៈនឹងទទួលបានកម្មសិទ្ធិនៅចុងបញ្ចប់នៃរយៈពេលភតិសន្យាទ្រព្យសកម្មគួរត្រូវដករំលស់ពេញលេញលើរយៈពេលខ្លីជាងរវាងរយៈពេលភតិសន្យា និង អាយុកាលអាចប្រើបានរបស់វា។ ភតិកៈត្រូវវាយតម្លៃផងដែរនៅកាលបរិច្ឆេទរាយការណ៍នីមួយៗថាតើទ្រព្យសកម្ម ដែលបានធ្វើភតិសន្យាក្រោមភតិសន្យាហិរញ្ញវត្ថុមាន ការថយចុះតម្លៃឬទេ។ (សូមមើលផ្នែកទី២៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម)។

## ការលាតត្រដាង

២០.១៣ ភតិកៈត្រូវធ្វើការលាតត្រដាងដូចខាងក្រោមសម្រាប់ភតិសន្យាហិរញ្ញវត្ថុៈ ៖

(ក) សម្រាប់ថ្នាក់ទ្រព្យសកម្មនីមួយៗ តម្លៃយោងពិតនៅចុងការិយបរិច្ឆេទរាយការណ៍

(ខ) ចំនួនទឹកប្រាក់សរុបនៃការទូទាត់ភតិសន្យាអប្បបរមានាអនាគត នៅចុងការិយបរិច្ឆេទរាយការណ៍សម្រាប់ការិយបរិច្ឆេទ ដូចខាងក្រោម ៖

(១) មិនលើសពីមួយឆ្នាំ

(២) លើសពី១ឆ្នាំ និង មិនលើសពី៥ឆ្នាំ និង

(៣) លើសពី៥ឆ្នាំ

(គ) ការបរិយាយទូទៅពីកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗរបស់ភតិកៈរួមមាន ជាឧទាហរណ៍ ព័ត៌មានអំពីការជួលយថាហេតុ ការបន្តកិច្ចព្រមព្រៀងឬជម្រើសទិញនិង ខសន្យាសំខាន់ៗ ភតិសន្យាបន្ត និង ការដាក់កំហិតដែលបានកំណត់ដោយកិច្ចព្រមព្រៀងភតិសន្យា។

២០.១៤ លើសពីនេះទៅទៀត ការតម្រូវសម្រាប់លាតត្រដាងព័ត៌មានអំពីទ្រព្យសកម្ម ដោយអនុលោមទៅតាមផ្នែកទី១៧ ១៨ ២៧ និងទី៣៤ អនុវត្តចំពោះភតិកៈសម្រាប់ទ្រព្យសកម្មដែលបានធ្វើភតិសន្យាក្រោមភតិសន្យាហិរញ្ញវត្ថុ។

# របាយការណ៍ហិរញ្ញវត្ថុរបស់ភតិកៈ - ភតិសន្យាប្រតិបត្តិការ

## ការទទួលស្គាល់ និង ការវាស់វែង

២០.១៥ ភតិកៈត្រូវទទួលស្គាល់ការទូទាត់ភតិសន្យាក្រោមភតិសន្យាប្រតិបត្តិការ (ដកចេញថ្លៃដើមសេវាដូចជា ថ្លៃធានារ៉ាប់រង និងការថែទាំ) ជាចំណាយក្នុងរយៈពេលភតិសន្យាតាមមូលដ្ឋានថេរ វៀរលែងតែ ៖

(ក) មូលជាប្រព័ន្ធផ្សេងទៀតតំណាងឱ្យគំរូពេលវេលានៃផលប្រយោជន៍របស់អ្នកប្រើប្រាស់ ទោះបីការទូទាត់មិនផ្អែកលើមូលដ្ឋាននោះ ឬ

(ខ) ការទូទាត់ទៅឱ្យភតិបតីត្រូវបានរៀបចំឡើងដើម្បីបង្កើនឱ្យស្របតាមអតិផរណាទូទៅដែលបានរំពឹងទុក (ផ្អែកលើសន្ទស្សន៍ ឬ ស្ថិតិដែលបានផ្សាយ) ដើម្បីតបស្នងសម្រាប់ការចំណាយដែលកើនឡើងដោយសារអតិផរណារបស់ភតិបតី។ ប្រសិនការទូទាត់ទៅឱ្យភតិបតីប្រែប្រួល ដោយសារកត្តាផ្សេងៗក្រៅពីអតិផរណាទូទៅ ដូច្នេះលក្ខខណ្ឌ (ខ) មិនត្រូវបានបំពេញទេ។

ឧទាហរណ៍ ពីការអនុវត្តកថាខណ្ឌទី ២០.១៥ (ខ)

X ដំណើរការនៅក្នុងប្រទេសមួយដែលការព្យាករណ៍ជារួមដោយធនាគារក្នុងស្រុកថាសន្ទស្សន៍កម្រិតតម្លៃ

ទូទៅ ដូចដែលរដ្ឋាភិបាលបានផ្សាយ នឹងមានការកើនជាមធ្យម១០ភាគរយក្នុងមួយឆ្នាំក្នុងរយៈពេល៥ឆ្នាំ ទៀត។ X ធ្វើភតិសន្យាការិយាល័យខ្លះពីY សម្រាប់រយៈពេល៥ឆ្នាំក្រោមភតិសន្យាប្រតិបត្តិការ។ ការទូទាត់ភតិសន្យាត្រូវបានរៀបចំដើម្បីឆ្លុះបញ្ចាំងអតិផរណាទូទៅប្រចាំឆ្នាំ១០ភាគរយតាមរយៈពេលភតិសន្យា៥ឆ្នាំដូចខាងក្រោម

| | |
|---|---|
| ឆ្នាំទី១ | ១០០.០០០ ឯកតារូបិយប័ណ្ណ |
| ឆ្នាំទី២ | ១១០.០០០ ឯកតារូបិយប័ណ្ណ |
| ឆ្នាំទី៣ | ១២១.០០០ ឯកតារូបិយប័ណ្ណ |
| ឆ្នាំទី៤ | ១៣៣.០០០ ឯកតារូបិយប័ណ្ណ |
| ឆ្នាំទី៥ | ១៤៦.០០០ ឯកតារូបិយប័ណ្ណ |

X ទទួលស្គាល់ចំណាយជួលប្រចាំឆ្នាំស្មើនឹងចំនួនទឹកប្រាក់ដែលបានជំពាក់ភតិបតីខាងលើ។ ប្រសិនបើការទូទាត់សងមិនត្រូវបានរៀបចំដើម្បីតបស្នងទៅឱ្យភតិបតីសម្រាប់ការកើនឡើងចំណាយអតិផរណារំពឹងទុកដែលផ្អែកលើសន្ទស្សន៍ ឬស្ថិតិដែលបានផ្សាយទេ ដូច្នេះ X ទទួលស្គាល់ចំណាយជួលប្រចាំឆ្នាំតាម មូលដ្ឋានថេរ ៖ ១២២.០០០ ឯកតារូបិយប័ណ្ណ សម្រាប់ឆ្នាំនីមួយៗ (ផលបូកបំណុលទាំងអស់ ចែកនឹង ៥ ឆ្នាំ) ។

### ការលាតត្រដាង

២០.១៦ ភតិក:ត្រូវធ្វើការលាតត្រដាងដូចខាងក្រោមសម្រាប់ភតិសន្យាប្រតិបត្តិការ ៖

(ក) ការទូទាត់ភតិសន្យាសរុបអប្បរមានាអនាគតក្រោមភតិសន្យាប្រតិបត្តិការដែលមិនអាចលុបចោលបានសម្រាប់គ្រានីមួយៗដូចខាងក្រោម ៖

(១) មិនលើសពី១ឆ្នាំ

(២) លើសពី១ឆ្នាំ និងមិនលើសពី៥ឆ្នាំ និង

(៣) លើសពី៥ឆ្នាំ

(ខ) ការទូទាត់ភតិសន្យាដែលបានទទួលស្គាល់ជាចំណាយ និង

(គ) ការពិព៌ណនាទូទៅនៃកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗរបស់ភតិក:ឧទាហរណ៍ រួមមាន ព័ត៌មានអំពីការជួលយថាហេតុ ការបន្តកិច្ចសន្យា ឬជម្រើសទិញនិង ខសន្យាសំខាន់ៗ ភតិសន្យាបន្ត និង ការដាក់កំហិតដែលបានកំណត់ដោយកិច្ចព្រមព្រៀងភតិសន្យា។

## របាយការណ៍ហិរញ្ញវត្ថុរបស់ភតិបតី: - ភតិសន្យាហិរញ្ញវត្ថុ

### ការទទួលស្គាល់ និងការវាស់វែងលើកដំបូង

២០.១៧ ភតិបតីត្រូវទទួលស្គាល់ទ្រព្យសកម្មដែលរក្សាទុកក្រោមភតិសន្យាហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងបង្ហាញភតិសន្យាហិរញ្ញវត្ថុនោះជាចំនួនត្រូវទទួលបានស្មើនឹងតម្លៃវិនិយោគសុទ្ធក្នុងភតិសន្យា។តម្លៃវិនិយោគសុទ្ធនៅក្នុងភតិសន្យាគឺជាតម្លៃវិនិយោគដុលរបស់ភតិបក្នុងភតិសន្យាដែលបានធ្វើអប្បហាររួចតាមអត្រាការប្រាក់បង្កប់ក្នុងភតិសន្យា។ ការវិនិយោគដុលក្នុងភតិសន្យាគឺជាតម្លៃសរុបនៃ ៖

(ក) ការទូទាត់ភតិសន្យាអប្បបរមាដែលត្រូវទទួលដោយភតិបតីក្រោមភតិសន្យាហិរញ្ញវត្ថុ និង

(ខ) តម្លៃកាកសំណល់មិនធានាបង្ករទុកសម្រាប់ភតិបតី។

២០.១៨ សម្រាប់ភតិសន្យាហិរញ្ញវត្ថុក្រៅពីភតិសន្យាទាក់ទងនឹងរោងចក្រផលិត ឬ ភតិបតីជាអ្នកលក់ ចំណាយផ្ទាល់ដំបូងដែលបានកើតឡើងនិងចូលរួមដោយផ្ទាល់នៅក្នុងការចរចារនិងរៀបចំភតិសន្យា) ត្រូវបញ្ចូលនៅក្នុងការវាស់វែងលើកដំបូងនៃភតិសន្យាហិរញ្ញវត្ថុដែលត្រូវទទួលបាននិងកាត់បន្ថយប្រាក់ចំណូល ដែលបានទទួលស្គាល់ក្នុងរយ:ពេលភតិសន្យា។

## ការខាតបង់នៃចំណូលបន្ទាប់

២០.១៩ ការទទួលស្គាល់ចំណូលហិរញ្ញវត្ថុត្រូវផ្អែកលើគំរូដែលឆ្លុះបញ្ចាំងពីអត្រាចំណូលថេរប្រចាំឆ្នាំ លើការវិនិយោគសុទ្ធរបស់ភតិបតីក្នុងភតិសន្យាហិរញ្ញវត្ថុ។ ការទូទាត់ភតិសន្យាសម្រាប់ការិយបរិច្ឆេទដោយមិនបញ្ចូលថ្លៃសេវាកម្មត្រូវបាន កាត់កងនឹងការវិនិយោគដុលក្នុងភតិសន្យាដើម្បីកាត់បន្ថយទាំងប្រាក់ដើម និងចំណូលហិរញ្ញវត្ថុមិនទាន់ទទួ លស្គាល់។ ប្រសិនបើមានសញ្ញាដែលថាតម្លៃប៉ាន់ស្មានលើកាកសំណល់មិនធានា ដែលបានប្រើនៅក្នុងការគណនាការវិនិយោគដុលរបស់ភតិបតីក្នុងភតិសន្យាបានផ្លាស់ប្តូរយ៉ាងខ្លាំង ការបែងចែកប្រាក់ចំណូលលើរយៈពេលភតិសន្យាគឺត្រូវបានកែប្រែ និងការកាត់បន្ថយណាមួយទាក់ទងនឹងចំនួនទឹកប្រាក់ ដែលបានបង្គរត្រូវបានទទួលស្គាល់ភ្លាមនៅក្នុង ចំណេញ ឬខាត ។

## ភតិបតីជាអ្នកផលិតឬអ្នកលក់

២០.២០ អ្នកផលិតឬអ្នកលក់តែងតែផ្តល់ឱ្យអតិថិជននូវជម្រើសនៃការទិញឬភតិសន្យាទ្រព្យសកម្ម។ ភតិសន្យាហិរញ្ញវត្ថុនៃទ្រព្យសកម្មដោយភតិបតីជាអ្នកផលិតឬអ្នកលក់ផ្តល់ការកើតឡើងចំណូលពីរប្រភេទ ៖

(ក) ចំណេញឬខាតដែលសមមូលទៅនឹងចំណេញឬខាតកើតចេញពីការលក់ទ្រព្យសកម្ម ដែលកំពុងត្រូវបានធ្វើភតិសន្យា តាមតម្លៃលក់ធម្មតា ដោយឆ្លុះបញ្ចាំងពីទំហំឬអប្បហារពាណិជ្ជកម្ម និង

(ខ) ចំណូលហិរញ្ញវត្ថុក្នុងរយៈពេលភតិសន្យា

២០.២១ ចំណូលការលក់ ដែលបានទទួលស្គាល់នៅពេលចាប់ផ្តើមនៃរយៈពេលភតិសន្យាដោយភតិបតីគឺជាអ្នកផលិត ឬអ្នកលក់គឺជាតម្លៃសមស្របនៃទ្រព្យសកម្មឬ ប្រសិនបើទាបជាង ជាតម្លៃបច្ចុប្បន្ននៃ ការទូទាត់ភតិសន្យាអប្បរមាដែលបង្គរសម្រាប់ភតិបតីហើយត្រូវបានគេគណនាតាមអត្រាការប្រាក់ទីផ្សារ។ ថ្លៃដើមលក់ដែលបានទទួលស្គាល់នៅពេលចាប់ផ្តើមរយៈពេលភតិសន្យាគឺជាថ្លៃដើម ឬ តម្លៃយោងនៃទ្រព្យធ្វើភតិសន្យាប្រសិនបើខុសគ្នា ដោយដកចេញនូវតម្លៃបច្ចុប្បន្ននៃកាកសំណល់មិនធានា។ ភាពខុសគ្នារវាងចំណូលពីការលក់និងថ្លៃដើមលក់គឺជាប្រាក់ចំណេញដែលត្រូវបានទទួលស្គាល់ដោយអនុលោមតាមគោលនយោបាយរបស់អង្គភាពសម្រាប់ការលក់។

២០.២២ ប្រសិនបើការប្រាក់មានអត្រាទាបខុសពីធម្មតាចំណេញពីការលក់ត្រូវបានកម្រិតត្រឹមចំនួន ដែលអត្រាការប្រាក់ទីផ្សារត្រូវបានគេប្រើ។ ចំនាយកើតឡើងដោយភតិបតីគឺជាអ្នកផលិត ឬអ្នកលក់ មានទំនក់ទំនងនឹងការចរចារ និងរៀបចំ ភតិសន្យាត្រូវបានទទួលស្គាល់ជាចំណាយនៅពេលចំនេញលក់ត្រូវបានទទួលស្គាល់។

## ការលាតត្រដាង

២០.២៣ ភតិបតីត្រូវធ្វើការលាតត្រដាងដូចខាងក្រោមសម្រាប់ភតិសន្យាហិរញ្ញវត្ថុ ៖

(ក) ការផ្ទៀងផ្ទាត់រវាងការវិនិយោគដុលក្នុងភតិសន្យានៅចុងបញ្ចប់នៃការិយបរិច្ឆេទរាយការណ៍ និងតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាអប្បបរមាត្រូវទទួលបាននៅចុងការិយបរិច្ឆេទរាយការណ៍។

លើសពីនេះ ភតិបតីត្រូវបង្ហាញ ការវិនិយោគដុលក្នុងភតិសន្យា និងតម្លៃបច្ចុប្បន្ន នៃការទូទាត់ភតិសន្យាអប្បបរមាត្រូវទទួលបាន នៅ ចុងការិយបរិច្ឆេទរាយការណ៍ សម្រាប់គ្រានីមួយៗដូចខាងក្រោម ៖

(១) មិនលើសពី១ឆ្នាំ

(២) លើសពី១ឆ្នាំ និងមិនលើពី៥ឆ្នាំ និង

(៣) លើសពី៥ឆ្នាំ

(ខ) ចំណូលហិរញ្ញវត្ថុមិនទាន់ទទួលស្គាល់

(គ) តម្លៃកាកសំណល់មិនធានាដែលបង្គរទុកចំពោះអត្ថប្រយោជន៍របស់ភតិបតី

(ឃ) តម្លៃដកបង្ការបង្គរសម្រាប់គណនីត្រូវទទួលការទូទាត់អប្បបរមា

(ង) ការជួលយថាហេតុដែលបានទទួលស្គាល់ជាចំណូលនៅក្នុងគ្រា

(ច) ការពិព៌ណនាទូទៅនៃកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗរបស់ភតិបតី ជាឧទាហរណ៍ រួមមាន ព័ត៌មានអំពីការជួលយថាហេតុ ការបន្តកិច្ចព្រមព្រៀង ឬជម្រើសទិញនិង ខសន្យាសំខាន់ៗ ភតិសន្យាបន្ត និងការដាក់កំហិតទាំងឡាយដែលបានកំណត់ដោយកិច្ចព្រមព្រៀង។

## របាយការណ៍ហិរញ្ញវត្ថុរបស់ភតិបតី: - ភតិសន្យាប្រតិបត្តិការ

### ការទទួលស្គាល់ និង ការវាស់វែង

២០.២៤ ភតិបតីត្រូវបង្ហាញទ្រព្យសកម្មជាភតិសន្យាប្រតិបត្តិការនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយអនុលោមតាមប្រភេទទ្រព្យសកម្ម។

២០.២៥ ភតិបតីត្រូវទទួលស្គាល់ចំណូលពីភតិសន្យាប្រតិបត្តិការ (ដោយមិនបញ្ចូលចំនួនទឹកប្រាក់សម្រាប់សេវាកម្មដូចជាធានារ៉ាប់រង និង ការថែទាំ) នៅក្នុងចំណេញ ឬខាតតាមមូលដ្ឋានថេរតាមរយៈពេលភតិសន្យាវៀរលែងតែ ៖

(ក) មូលដ្ឋានជាប្រព័ន្ធផ្សេងទៀតតំណាងឱ្យគំរូពេលវេលានៃផលប្រយោជន៍របស់ភតិកៈពីទ្រព្យសកម្មបានធ្វើភតិសន្យា ទោះបីជាការទទួលបានការទូទាត់សងមិនផ្អែកតាមមូលដ្ឋាននោះក៏ដោយ ឬ

(ខ) ការទូទាត់សងទៅឱ្យភតិបតីត្រូវបានគេរៀបចំឡើងដើម្បីបង្កើនឱ្យស្របតាមអតិផរណាទូទៅដែលបានរំពឹងទុក (ផ្អែកលើសន្ទស្សន៍ ឬ ស្ថិតិដែលបានផ្សាយ) ដើម្បីតបស្នងចំពោះការកើនឡើងថ្លៃអតិផរណាដែលបានរំពឹងទុករបស់ភតិបតី។ ប្រសិនបើការទូទាត់ទៅឱ្យភតិបតីប្រែប្រួលតាមកត្តាផ្សេងៗក្រៅពីអតិផរណា ដូច្នេះលក្ខខណ្ឌ(ខ)មិនត្រូវបានបំពេញទេ។

២០.២៦ ភតិបតីត្រូវទទួលស្គាល់ជាចំណាយ រួមមាន រំលស់ដែលបានកើតឡើងនៅក្នុងការរកចំណូលពីភតិសន្យា។ គោលនយោបាយរំលស់សម្រាប់ទ្រព្យសកម្មភតិសន្យា ដែលអាចដករំលស់បានត្រូវមានសង្គតិភាពជាមួយគោលនយោបាយរំលស់ធម្មតារបស់ភតិបតីសម្រាប់ទ្រព្យសកម្មស្រដៀងគ្នា។

២០.២៧ ភតិបតីត្រូវបូកបន្ថែមតម្លៃយោងទ្រព្យសកម្មភតិសន្យានូវថ្លៃដើមផ្ទាល់ដំបូងណា ដែលកើតឡើងពីការចរចារនិងរៀបចំកិច្ចព្រមព្រៀងភតិសន្យាប្រតិបត្តិការ និងត្រូវទទួលស្គាល់ថ្លៃដើមនោះ ជាចំណាយក្នុងរយៈពេលភតិសន្យាតាមមូលដ្ឋានដូចគ្នានឹងចំណូលភតិសន្យា។

២០.២៨ ដើម្បីកំណត់ថាតើទ្រព្យសកម្មភតិសន្យាបានថយចុះតម្លៃ ភតិបតីត្រូវអនុវត្តផ្នែកទី២៧។

២០.២៩ ភតិបតីជាអ្នកផលិតឬអ្នកលក់មិនត្រូវទទួលស្គាល់ចំណេញពីការលក់ណាមួយ ចំពោះកិច្ចព្រមព្រៀងប្រតិបត្តិការពីព្រោះវាមិនសមមូលនឹងការលក់។

## ការលាតត្រដាង

២០.៣០ ភតិបតីត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោមទាក់ទងនឹងភតិសន្យាប្រតិបត្តិការ:

(ក) ការទូទាត់ភតិសន្យាអប្បបរមាអនាគតក្រោមភតិសន្យាប្រតិបត្តិការមិនអាចលុបចោលបានសម្រាប់គ្រានីមួយៗដូចខាងក្រោម:

(១) មិនលើសពី១ឆ្នាំ និង

(២) លើសពី១ឆ្នាំ និងមិនលើសពី៥ឆ្នាំ និង

(៣) លើសពី៥ឆ្នាំ។

(ខ) ការជួលយថាហេតុសរុបដែលបានទទួលស្គាល់ជាចំណូល និង

(គ) ការពិពណ៌នាទូទៅនៃកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗរបស់ភតិបតី ឧទាហរណ៍ រួមមាន ព័ត៌មានអំពីការជួលយថាហេតុ ការបន្តកិច្ចព្រមព្រៀង ឬ ជម្រើសទិញ និង ខសន្យាសំខាន់ៗ និង ការកម្រិតទាំងឡាយដែលកំណត់ដោយកិច្ចព្រមព្រៀងភតិសន្យា។

២០.៣១ លើសពីនេះ ការតម្រូវទាំងឡាយសម្រាប់ការលាតត្រដាងអំពីទ្រព្យសកម្ម ដោយអនុលោមតាមផ្នែកទី១៧.១៨.២៧ និង ៣៤ អនុវត្តចំពោះភតិបតីសម្រាប់ទ្រព្យសកម្មដែលបានផ្តល់ក្រោមភតិសន្យាប្រតិបត្តិការ។

# ប្រតិបត្តិការលក់ និង ភតិសន្យាត្រឡប់វិញ

២០.៣២ ប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់វិញទាក់ទិននឹងការលក់ទ្រព្យសកម្ម និងការជួលត្រឡប់មកវិញនូវទ្រព្យសកម្មដូចគ្នា។ តម្លៃទូទាត់សងភតិសន្យា និងតម្លៃលក់ជាធម្មតាមានទំនាក់ទំនងគ្នាទៅវិញទៅមក ពីព្រោះពួកវាត្រូវបានចរចារជាកញ្ចប់។ការអនុវត្តគោលនយោបាយគណនីលើប្រតិបត្តិការលក់និងភតិសន្យាត្រឡប់វិញ ផ្អែកលើប្រភេទភតិសន្យា។

## ប្រតិបត្តិការលក់ និង ភតិសន្យាត្រឡប់វិញបណ្តាលឱ្យមានភតិសន្យាហិរញ្ញវត្ថុ

២០.៣៣ ប្រសិបបើប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់វិញបណ្តាលឱ្យមានភតិសន្យាហិរញ្ញវត្ថុ ភតិកៈ-អ្នកលក់ មិនត្រូវទទួលស្គាល់ភ្លាមនូវផ្នែកលើសនៃចំណូលពីការលក់លើតម្លៃយោងជាចំណូលទេ។ភតិកៈ-អ្នកលក់ត្រូវពន្យារផ្នែកលើសនោះ និង រំលស់វាតាមរយៈពេលភតិសន្យាវិញ។

## ប្រតិបត្តិការលក់ និង ភតិសន្យាត្រឡប់វិញបណ្តាលឱ្យមានភតិសន្យាប្រតិបត្តិការ

២០.៣៤ ប្រសិនបើប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់វិញបណ្តាលឱ្យមានភតិសន្យាប្រតិបត្តិការ ហើយគេច្បាស់ថាប្រតិបត្តិការត្រូវបានបង្កើតតាមតម្លៃសមស្រប ភតិកៈ-អ្នកលក់ត្រូវទទួលស្គាល់ប្រាក់ចំណេញ ឬខាតភ្លាម។ ប្រសិនបើតម្លៃលក់ទាបជាងតម្លៃសមស្រប ភតិកៈ-អ្នកលក់ត្រូវទទួលស្គាល់ប្រាក់ចំណេញ ឬខាតភ្លាមវៀរលែងតែការខាតត្រូវបានកាត់កងពីការទូទាត់សងភតិសន្យាអនាគតតាមតម្លៃទាបជាងទីផ្សារ។ នៅក្នុងករណីនេះ ភតិកៈ-អ្នកលក់ត្រូវពន្យារនិងរំលស់ការខាតនោះតាមសមាមាត្រទៅនឹងការទូទាត់ភតិសន្យា តាមរយៈពេលដែលទ្រព្យសកម្មនោះត្រូវបានរំពឹងទុកថានឹងត្រូវប្រើ។ ប្រសិនបើតម្លៃលក់លើសពីតម្លៃសមស្រប ភតិកៈ-អ្នកលក់ត្រូវពន្យារផ្នែកលើសលើតម្លៃសមស្របនោះនិងរំលស់តាមរយៈពេលដែលទ្រព្យសកម្មត្រូវបានរំពឹងទុកថានឹងត្រូវប្រើ។

## ការលាតត្រដាង

២០.៣៥ ការតម្រូវឱ្យលាតត្រដាងព័ត៌មានសម្រាប់ភតិក:និងភតិបតីពីអនុវត្តដូចគ្នាចំពោះប្រតិបត្តិការលក់និងភតិសន្យាត្រឡប់វិញ។ ការពិព័ណនាពីកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗដែលបានតម្រូវ ត្រូវរួមបញ្ចូលការពិព័ណនាពីលក្ខខណ្ឌពិសេសឬ មិនប្រក្រតីនៃកិច្ចព្រមព្រៀង ឬ លក្ខខណ្ឌនៃប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់វិញ ។

# ផ្នែកទី ២១
# សំវិធានធន និង យថាភាព

## វិសាលភាពនៃផ្នែកនេះ

២១.១ ផ្នែកនេះអនុវត្តចំពោះសំវិធានធនទាំងអស់ (ពោលគឺបំណុលដែលមានពេលវេលានិងចំនួនទឹកប្រាក់មិនទៀងទាត់) បំណុលយថាហេតុ និង ទ្រព្យសកម្មយថាហេតុ លើកលែងសំវិធានទាំងឡាយដែល ត្រូវគ្របដណ្តប់ដោយផ្នែកផ្សេងទៀតនៃស្តង់ដារនេះ។ ទាំងនេះរាប់បញ្ចូលសំវិធានធនដែលពាក់ព័ន្ធនឹង៖

(ក) ភតិសន្យា (ផ្នែកទី២០ ស្តីពីភតិសន្យា)។ ប៉ុន្តែផ្នែកនេះអនុវត្តចំពោះភតិសន្យាប្រតិបត្តិការ ដែលមានការខាតបង់ទៅហើយ។

(ខ) កិច្ចសន្យាសាងសង់ (ផ្នែកទី២៣ ស្តីពីចំណូល)។ ប៉ុន្តែផ្នែកនេះអនុវត្តចំពោះកិច្ចសន្យា សាងសង់ដែលមានការខាតបង់ទៅហើយ។

(គ) កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត (ផ្នែកទី២៨ ស្តីពីអត្ថប្រយោជន៍និយោជិត)។

(ឃ) ពន្ធលើប្រាក់ចំណូល (ផ្នែកទី២៩ ស្តីពីពន្ធលើប្រាក់ចំណូល)។

២១.២ ការតម្រូវនៅក្នុងផ្នែកនេះមិនអនុវត្តចំពោះកិច្ចសន្យាប្រតិបត្តិលុះត្រាតែ កិច្ចសន្យានោះជាកិច្ចសន្យាដែលនាំឱ្យមានការខាតបង់។ កិច្ចសន្យាប្រតិបត្តិគឺជាកិច្ចសន្យាដែលពុំមានភាគីណាមួយបានអនុវត្តកាតព្វកិច្ចណាមួយនៃកាតព្វកិច្ចទាំងឡាយ ឬ ភាគីទាំងពីរបានអនុវត្តកាតព្វកិច្ចមួយផ្នែកដែលទំហំស្មើគ្នា។

២១.៣ ពាក្យ 'សំវិធានធាន' ជួនកាល ត្រូវបានប្រើនៅក្នុងបរិការណ៍នៃធាតុមួយចំនួន ដូចជាការរំលស់ ការថយចុះតម្លៃទ្រព្យសកម្ម គណនីត្រូវទទួលមិនអាចប្រមូលបាន។ ទាំងអស់នោះគឺជាការកែសម្រួលនៃ តម្លៃយោង នៃទ្រព្យសកម្ម ជាជាងការទទួលស្គាល់បំណុល និងដូច្នេះហើយមិនត្រូវបានគ្របដណ្តប់ដោយផ្នែកនេះទេ។

## ការទទួលស្គាល់លើកដំបូង

២១.៤ អង្គភាពមួយត្រូវទទួលស្គាល់សំវិធានធនតែនៅពេលដែល៖

(ក) អង្គភាពមានកាតព្វកិច្ចនៅ កាលបរិច្ឆេទរាយការណ៍ដែលជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាល

(ខ) អង្គភាពអាចនឹង (ពោលគឺ ប្រហែលកើតឡើងច្រើនជាងមិនកើតឡើង) ត្រូវបានតម្រូវ ឱ្យផ្ទេរអត្ថប្រយោជន៍សេដ្ឋកិច្ចនៅក្នុងការទូទាត់សង និង

(គ) ចំនួនទឹកប្រាក់នៃកាតព្វកិច្ចអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់

២១.៥ អង្គភាពត្រូវទទួលស្គាល់សំវិធានធននោះជាបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងទទួលស្គាល់ចំនួនទឹកប្រាក់នៃសំវិធានធនជាចំណាយ លុះត្រាផ្នែកផ្សេងទៀតនៃស្តង់ដារនេះ តម្រូវឱ្យថ្លៃដើមនឹងត្រូវបានទទួលស្គាល់ជាផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្ម ដូចជាសន្និធិ ឬ ទ្រព្យ រោងចក្រ និងបរិក្ខារ។

២១.៦ លក្ខខណ្ឌនៅក្នុងកថាខណ្ឌ ២១.៤ (ក) (កាតព្វកិច្ចនៅកាលបរិច្ឆេទរាយការណ៍ដែលជាលទ្ធផល នៃព្រឹត្តិការណ៍អតីតកាល) មានន័យថាអង្គភាពមិនមានជម្រើសជាក់ស្តែងចំពោះកាតព្វកិច្ចទូទាត់សង។ ករណីនេះអាចកើតឡើង នៅពេលអង្គភាពមានកាតព្វកិច្ចផ្លូវច្បាប់ដែលអាចត្រូវបង្ខំដោយច្បាប់ ឬ នៅពេលដែលអង្គភាពមានកាតព្វកិច្ចដោយសន្មត ពីព្រោះព្រឹត្តិការណ៍អតីតកាល (ដែលអាចជាសកម្មភាពរបស់អង្គភាព) បានបង្កើតឡើងនូវការរំពឹងត្រឹមត្រូវលើភាគីផ្សេងដែលអង្គភាពនឹងអនុវត្តកាតព្វកិច្ច។ កាតព្វកិច្ចដែលនឹងកើតឡើងពីសកម្មភាពនាពេលអនាគតរបស់អង្គភាព (ពោលគឺសកម្មភាពអាជីវកម្មរបស់ខ្លួននាពេលអនាគត) មិនបំពេញលក្ខខណ្ឌនៅក្នុងកថាខណ្ឌ ២១. ៤(ក) មិនថាតើកាតព្វកិច្ចទាំងឡាយអាចនឹងកើតឡើងកម្រិតណាក៏ដោយ និងទោះបីកាតព្វកិច្ចទាំងនោះមានលក្ខណៈជាកិច្ចសន្យា។ ជាឧទាហរណ៍ ដោយសារសំពាធពាណិជ្ជកម្មឬ ការតម្រូវផ្លូវច្បាប់ អង្គភាពមួយអាចមានបំណងឬត្រូវការបង្កើតចំណាយដើម្បីធ្វើប្រតិបត្តិការក្នុងរបៀបជាក់លាក់ណាមួយនៅពេលអនាគត (ឧទាហរណ៍ ដោយការបំពាក់តំរងផ្សែងនៅក្នុងប្រភេទរោងចក្រជាក់លាក់)។ ដោយសារអង្គភាព អាចជៀសវាងការចំណាយអនាគតដោយសកម្មភាពអនាគតរបស់ខ្លួន ជាឧទាហរណ៍ដោយការប្តូរវិធីសាស្ត្រប្រតិបត្តិការ ឬ ការលក់រោងចក្រ អង្គភាពមិនមានកាតព្វកិច្ចបច្ចុប្បន្នសម្រាប់ចំណាយអនាគតនោះ និងពុំមានសំវិធានធនណាត្រូវបានទទួលស្គាល់។

## ការវាស់វែងលើកដំបូង

២១.៧ អង្គភាពត្រូវវាស់វែងសំវិធានធនតាមការប៉ាន់ស្មានល្អបំផុតនៃចំនួនទឹកប្រាក់ ដែលត្រូវការដើម្បីទូទាត់កាតព្វកិច្ចនៅកាលបរិច្ឆេទរាយការណ៍។ ការប៉ាន់ស្មានដ៏ល្អបំផុតគឺជាចំនួនទឹកប្រាក់ដែលអង្គភាពនឹងបង់យ៉ាងសមហេតុផលដើម្បីទូទាត់កាតព្វកិច្ចនៅចុងការិយបរិច្ឆេទរាយការណ៍ ឬ ដើម្បីផ្ទេរកាតព្វកិច្ចទៅឱ្យភាគីទីពនៅពេលនោះ៖

(ក) នៅពេលសំវិធានធននោះជាប់ទាក់ទិននឹងធាតុច្រើន ការប៉ាន់ស្មាននៃចំនួនទឹកប្រាក់ឆ្លុះបញ្ចាំងពីការដាក់ទម្ងន់នៃលទ្ធផលដែលអាចកើតឡើងទាំងអស់ ទៅតាមភវនីយភាពជាប់ពាក់ព័ន្ធរបស់លទ្ធផល ដែលអាចកើតឡើងទាំងនោះ។ នៅកន្លែងដែលមានជួរបន្តឥតដាច់នៃលទ្ធផលដែលអាចកើតមាន ហើយចំណុចនីមួយៗក្នុងជួរនោះមានភាពអាចកើតឡើងស្មើៗគ្នាទៅនឹងចំណុចផ្សេងៗឯទៀត ចំណុចកណ្តាលនៃជួរត្រូវបានប្រើ

(ខ) នៅពេលដែលសំវិធានធននោះកើតឡើងពីកាតព្វកិច្ចទោល លទ្ធផលតែមួយដែលអាចកើតឡើងបំផុតអាចជាការប៉ាន់ស្មានដ៏ល្អបំផុតនៃចំនួនទឹកប្រាក់ដែលត្រូវការដើម្បីទូទាត់កាតព្វកិច្ច។ ក៏ប៉ុន្តែ ទោះបីជាក្នុងករណីបែបនេះក៏ដោយ អង្គភាពពិចារណាបណ្តាលទ្ធផលដែលអាចកើតឡើងដទៃទៀត។ នៅពេលដែលបណ្តាលទ្ធផលដែលអាចកើតឡើងដទៃទៀត គឺភាគច្រើនខ្ពស់ជាងឬភាគច្រើនទាបជាងលទ្ធផលដែលអាចកើតឡើងបំផុត ការប៉ាន់ស្មានល្អបំផុតនឹងជាចំនួនទឹកប្រាក់ដែលខ្ពស់ជាងឬទាបជាងលទ្ធផលដែលអាចកើតឡើងបំផុតនោះ។

នៅពេលឥទ្ធិពលនៃតម្លៃពេលវេលានៃលុយមានភាពជាសារវន្ត ចំនួនទឹកប្រាក់សំវិធានធនត្រូវជាតម្លៃបច្ចុប្បន្ននៃចំនួនទឹកប្រាក់ដែលរំពឹងថានឹងត្រូវតម្រូវឱ្យទូទាត់សងកាតព្វកិច្ចនោះ។ អត្រាអប្បហារ (ឬបណ្តាអត្រា) ត្រូវជាអត្រាមុនកាត់ពន្ធ (ឬបណ្តាអត្រា) ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលានៃលុយ។ ហានិភ័យជាក់លាក់ ចំពោះបំណុលត្រូវតែបានឆ្លុះបញ្ចាំងនៅក្នុងអត្រាអប្បហារ ឬនៅក្នុងការប៉ាន់ស្មាននៃចំនួនទឹកប្រាក់ដែលត្រូវការដើម្បីទូទាត់សងកាតព្វកិច្ច ប៉ុន្តែមិនទាំងពីរទេ។

២១.៨ អង្គភាពត្រូវមិនរាប់បញ្ចូលនូវចំណេញពីការបញ្ចេញចោលរំពឹងទុកនៃទ្រព្យសកម្ម ក្នុងការវាស់វែងនៃសំវិធានធនទេ។

២១.៩ នៅពេលចំនួនទឹកប្រាក់ខ្លះ ឬទាំងអស់ដែលត្រូវការដើម្បីទូទាត់សងសំវិធានធន អាចត្រូវបានចេញសងវិញដោយភាគីផ្សេងទៀត (ឧទាហរណ៍ តាមរយៈការទាមទារសំណងធានារ៉ាប់រង) អង្គភាពត្រូវទទួលស្គាល់ការចេញសងវិញនោះជាទ្រព្យសកម្មដោយឡែក នៅពេលដែលសឹងតែប្រាកដទៅហើយថាអង្គភាពនោះនឹងទទួលបានការចេញសងវិញនៅពេលមានការទូទាត់សងកាតព្វកិច្ច។ ចំនួនទឹកប្រាក់ដែលទទួលស្គាល់សម្រាប់ការចេញសងវិញនោះ មិនត្រូវលើសចំនួនទឹកប្រាក់សំវិធានធន។ ការចេញសងវិញដែលត្រូវទទួលនោះត្រូវបានបង្ហាញនៅក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុជាទ្រព្យសកម្មមួយ និងមិនត្រូវបានកាត់កងជាមួយនឹង សំវិធានធននោះទេ។ នៅក្នុងរបាយការណ៍ចំណូលពេញលេញ អង្គភាពអាចកាត់កងការចេញសងវិញពីភាគីផ្សេងមួយទៀត ជាមួយនឹងចំណាយដែលពាក់ព័ន្ធនឹងសំវិធានធននោះ។

## ការវាស់វែងក្រោយបន្ទាប់

២១.១០ អង្គភាពត្រូវកាត់ចេញពីសំវិធានធនតែនូវរាល់ចំណាយណា ដែលសំវិធានធននោះត្រូវបានទទួលស្គាល់ដំបូងប៉ុណ្ណោះ។

២១.១១ អង្គភាពត្រូវពិនិត្យមើលឡើងវិញនូវសំវិធានធាននៅកាលបរិច្ឆេទរាយការណ៍នីមួយៗ និងកែសម្រួលសំវិធានធនទាំងនោះដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតបច្ចុប្បន្ននៃចំនួនទឹកប្រាក់ដែលនឹងត្រូវបានតម្រូវឱ្យទូទាត់សងកាតព្វកិច្ចនៅកាលបរិច្ឆេទរាយការណ៍នោះ។ ការកែសម្រួលណាមួយ ទៅលើចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ពីមុនត្រូវកត់ត្រានៅក្នុងចំណេញឬខាត វៀរលែងតែសំវិធានធននោះត្រូវបានទទួលស្គាល់ដំបូងបំផុតជា ផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្ម (សូមមើលកថាខណ្ឌ ២១.៥)។ នៅពេលសំវិធានធនត្រូវបានវាស់វែង តាមតម្លៃបច្ចុប្បន្ននៃចំនួនទឹកប្រាក់រំពឹងទុក ដែលតម្រូវឱ្យទូទាត់សងកាតព្វកិច្ចនោះ ការលាតចេញនៃអប្បហារត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុនៅក្នុងចំណេញឬខាត នៅក្នុងការិយបរិច្ឆេទដែលការលាតចេញនៃអប្បហារនោះកើតឡើង។

## បំណុលយថាហេតុ

២១.១២ បំណុលយថាហេតុគឺជាកាតព្វកិច្ចដែលអាចកើតមាន ប៉ុន្តែមិនប្រាកដ ឬជាកាតព្វកិច្ចបច្ចុប្បន្នដែលមិនត្រូវបានទទួលស្គាល់ ពីព្រោះកាតព្វកិច្ចបច្ចុប្បន្ននោះមិនបានបំពេញលក្ខខណ្ឌមួយឬទាំងពីរ (ខ) និង (គ) នៅក្នុងកថាខណ្ឌ២១.៤។ អង្គភាពមិនត្រូវទទួលស្គាល់បំណុលយថាហេតុជាបំណុល វៀរលែងតែសំវិធានធន សម្រាប់បំណុលយថាហេតុរបស់អ្នកលក់នៅក្នុងការរួមបញ្ចូលអាជីវកម្ម (សូមមើលកថាខណ្ឌ ១៩.២០ និង ១៩.២១)។ ការលាតត្រដាងនៃបំណុលយថាហេតុត្រូវបានតម្រូវដោយកថាខណ្ឌ ២១.១៥ លុះត្រាតែភាពដែលអាចកើតមានឡើងនៃលំហូរចេញធនធានគឺតូចណាស់។ នៅពេលដែលអង្គភាពទទួលខុសត្រូវកាតព្វកិច្ចរួម ឬដោយខ្លួន ផ្នែកនៃកាតព្វកិច្ចដែលត្រូវបានរំពឹងថានឹងត្រូវបំពេញដោយភាគីផ្សេងទៀត ត្រូវបានចាត់ទុកជាបំណុលយថាហេតុ។

### ទ្រព្យសកម្មយថាហេតុ

២១.១៣ អង្គភាពមិនត្រូវទទួលស្គាល់ទ្រព្យសកម្មយថាហេតុជាទ្រព្យសកម្ម។ ការលាតត្រដាងនៃទ្រព្យសកម្មយថាហេតុត្រូវបានតម្រូវដោយកថាខណ្ឌ ២១.១៦ នៅពេលលំហូរចូលនៃអត្ថប្រយោជន៍ សេដ្ឋកិច្ចអាចនឹងកើតមាន។ ប៉ុន្តែនៅពេលលំហូរនៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតមកអង្គភាពមានភាពជាក់ស្តែង ដូច្នេះទ្រព្យសកម្មទាក់ទិនមិនមានជាទ្រព្យសកម្មយថាហេតុទេ ហើយការទទួលស្គាល់មានភាពសមស្រប។

# ការលាតត្រដាង

## ការលាតត្រដាងអំពីសំវិធានធន

២១.១៤ សម្រាប់ថ្នាក់សំវិធានធននីមួយៗ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោមទាំងអស់៖

(ក) ការផ្ទៀងផ្ទាត់ដោយបង្ហាញ៖

(១) តម្លៃយោងនៅដើម និង ចុងការិយបរិច្ឆេទ

(២) ការបន្ថែមក្នុងការិយបរិច្ឆេទ រួមបញ្ចូលនូវ ការកែសម្រួលដែលកើតចេញពីការកែប្រែក្នុងការវាស់វែងចំនួនទឹកប្រាក់បានធ្វើអប្បហារ

(៣) ចំនួនទឹកប្រាក់ដែលបានកាត់ចេញពីសំវិធានធនក្នុងការិយបរិច្ឆេទ និង

(៤) ចំនួនទឹកប្រាក់មិនបានប្រើដែលបានកត់ត្រាត្រឡប់ទៅវិញក្នុងការិយបរិច្ឆេទ។

(ខ) ការរៀបរាប់ដោយសង្ខេបនៃសារជាតិនៃកាតព្វកិច្ចនិងចំនួនទឹកប្រាក់ និងពេលវេលាដែលបានរំពឹងទុកនៃការទូទាត់សងដែលកើតឡើង

(គ) ការបញ្ជាក់នូវភាពមិនប្រាកដប្រជាអំពីចំនួនទឹកប្រាក់ឬពេលវេលានៃលំហូរចេញទាំងនោះ និង

(ឃ) ចំនួនទឹកប្រាក់នៃការចេញសងវិញរំពឹងទុកណាមួយ ដោយថ្លែងពីចំនួនទឹកប្រាក់នៃទ្រព្យសកម្មណាមួយដែលត្រូវបានទទួលស្គាល់សម្រាប់ការចេញសងវិញរំពឹងទុកនោះ។

ព័ត៌មានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទមុនៗមិនត្រូវបានតម្រូវនោះទេ។

## ការលាតត្រដាងអំពីបំណុលយថាហេតុ

២១.១៥ វៀរលែងតែភាពអាចកើតមានឡើងនៃលំហូរចេញធនធាននៅក្នុងការទូទាត់សងគឺតូចណាស់ សម្រាប់ថ្នាក់នីមួយៗនៃបំណុលយថាហេតុនៅកាលបរិច្ឆេទរាយការណ៍ អង្គភាពត្រូវលាតត្រដាងការរៀបរាប់ដោយសង្ខេបពីសារជាតិនៃបំណុលយថាហេតុ និង នៅពេលដែលអាចធ្វើទៅរួច៖

(ក) ការប៉ាន់ស្មាននៃឥទ្ធិពលហិរញ្ញវត្ថុរបស់បំណុលយថាហេតុនោះ ត្រូវបានវាស់វែងដោយអនុលោមតាមកថាខណ្ឌ ២១.៧-២១.១១

(ខ) ការបញ្ជាក់នៃភាពមិនប្រាកដប្រជាដែលទាក់ទងនឹងចំនួនទឹកប្រាក់ឬពេលវេលានៃលំហូរចេញណាមួយ និង

(គ) ភាពអាចកើតឡើងនៃការចេញសងវិញណាមួយ។

ប្រសិនបើមិនអាចធ្វើទៅរួចក្នុងការលាតត្រដាងទាំងនេះមួយឬច្រើន អង្គហេតុនោះត្រូវបានថ្លែង។

## ការលាតត្រដាងអំពីទ្រព្យសកម្មយថាហេតុ

២១.១៦ ប្រសិនបើអាចនឹងមានការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច (ទំនងកើតឡើងច្រើនជាងមិនកើតឡើង) ប៉ុន្តែមិនសឹងតែប្រាកដនោះទេ អង្គភាពត្រូវលាតត្រដាងការពិពណ៌នាអំពីសារជាតិទ្រព្យសកម្មយថាហេតុនៅចុងការិយបរិច្ឆេទរាយការណ៍ និង លើកលែងតែវានាំឱ្យមានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ការប៉ាន់ស្មាននៃឥទ្ធិពលហិរញ្ញវត្ថុរបស់ពួកគេ ត្រូវបានវាស់វែងដោយប្រើគោលការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌ២១.៧-២១.១១។ ប្រសិនបើការប៉ាន់ស្មាននោះនាំឱ្យមានចំណាយ ឬកិច្ចខំប្រឹងប្រែងហួសហេតុ អង្គភាពត្រូវលាតត្រដាងអង្គហេតុនោះ និងមូលហេតុ ដែលការប៉ាន់ស្មានឥទ្ធិពលហិរញ្ញវត្ថុនោះ នឹងនាំឱ្យមានចំណាយ ឬកិច្ចខំប្រឹងប្រែងហួសហេតុ។

## ការលាតត្រដាងដែលខូចខាតប្រយោជន៍

២១.១៧ នៅក្នុងករណីដ៏កម្របំផុត ការលាតត្រដាងនៃព័ត៌មានមួយចំនួន ឬទាំងអស់ដែលបានតម្រូវដោយ កថាខណ្ឌ ២១.១៤-២១.១៦ អាចត្រូវបានរំពឹងថានឹងធ្វើឱ្យខូចធ្ងន់ធ្ងរនូវស្ថានភាពរបស់អង្គភាពនៅក្នុងជម្លោះជាមួយ ភាគីផ្សេងទៀតនូវរឿងរ៉ាវសំវិធានធន បំណុលយថាហេតុ ឬ ទ្រព្យសកម្មយថាហេតុ។ នៅក្នុងករណីបែបនេះ អង្គភាពមិនចាំបាច់បង្ហាញព័ត៌មាននោះទេ ប៉ុន្តែត្រូវបង្ហាញសារជាតិទូទៅនៃជម្លោះនោះ រួមជាមួយនឹង អង្គហេតុ និងមូលហេតុដែលព័ត៌មានមិនត្រូវបានលាតត្រដាង។

# ឧបសម្ព័ន្ធនៃផ្នែកទី ២១
# ការណែនាំអំពីការទទួលស្គាល់ និងការវាស់វែង សំវិធានធន

ឧបសម្ព័ន្ធនេះ អមជាមួយផ្នែកទី២១ ប៉ុន្តែមិនមែនជាចំណែកនៃផ្នែកទី២១ ទេ។ ឧបសម្ព័ន្ធនេះផ្តល់ ការណែនាំសម្រាប់ការអនុវត្តការតម្រូវនៅក្នុងផ្នែកទី២១ ក្នុងការទទួលស្គាល់ និងការវាស់វែង សំវិធានធន។

គ្រប់អង្គភាពនៅក្នុងឧទាហរណ៍ក្នុងឧបសម្ព័ន្ធនេះ យកថ្ងៃទី៣១ ខែធ្នូ ជាកាលបរិច្ឆេទរាយការណ៍។ ក្នុងគ្រប់ករណីមានការសន្និដ្ឋានថា គេអាចធ្វើការប៉ាន់ស្មានគួរឱ្យជឿទុកចិត្តបាន លើលំហូរចេញទាំងឡាយ ដែលបានរំពឹងទុក។ នៅក្នុងឧទាហរណ៍មួយចំនួន កាលៈទេសៈដែលបានពណ៌នា អាចបណ្តាលឱ្យមានការថយចុះតម្លៃនៃទ្រព្យសកម្ម។ ទិដ្ឋភាពនេះ មិនត្រូវបាននិយាយដល់នៅក្នុងឧទាហរណ៍ទាំងនេះទេ។ ការលើកឡើងទាំងឡាយនូវ "ការប៉ាន់ស្មានដែលល្អបំផុត" និយាយសំដៅទៅលើចំនួនទឹកប្រាក់នៃតម្លៃបច្ចុប្បន្ន នៅពេលដែលឥទ្ធិពលនៃតម្លៃពេលវេលារបស់ប្រាក់ មានភាពជាសារវន្ត។

## ឧទាហរណ៍ទី១៖ ការខាតលើប្រតិបត្តិការអនាគត

២១ក.១ អង្គភាពកំណត់ថា ប្រហែលជាផ្នែកមួយនៃប្រតិបត្តិការរបស់ខ្លួន នឹងទទួលរងការខាតលើប្រតិបត្តិការអនាគតសម្រាប់រយៈពេលច្រើនឆ្នាំ។

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍ជាកាតព្វកិច្ចអតីតកាល-ពុំមាន ហេតុការណ៍អតីតកាលដែលដាក់កាតព្វកិច្ចតម្រូវឱ្យអង្គភាពចំណាយធនធានទេ។

ការសន្និដ្ឋាន- អង្គភាពមិនទទួលស្គាល់សំវិធានធនសម្រាប់ការខាតលើប្រតិបត្តិការអនាគត។ ការខាតអនាគតដែលបានរំពឹងទុក មិនបំពេញនិយមន័យនៃបំណុលទេ។ ការរំពឹងទុកអំពីការខាតលើប្រតិបត្តិការអនាគតអាចជាសូចនាករបង្ហាញថា ទ្រព្យសកម្មមួយ ឬច្រើន មានការថយចុះតម្លៃ - សូមមើលផ្នែកទី២៧ ការថយចុះតម្លៃនៃ ទ្រព្យសកម្ម។

## ឧទាហរណ៍ទី២៖ កិច្ចសន្យាដែលនាំឱ្យមានការខាតបង់

២១ក.២ កិច្ចសន្យាដែលនាំឱ្យមានការខាតបង់ គឺជាកិច្ចសន្យាមួយ ដែលចំណាយមិនអាចចៀសផុតលើ ការបំពេញកាតព្វកិច្ចក្រោមកិច្ចសន្យា លើសអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលគេរំពឹងថា នឹងទទួលបានក្រោម កិច្ចសន្យានោះ។ ចំណាយមិនអាចចៀសផុតក្រោមកិច្ចសន្យាមួយ ឆ្លុះបញ្ចាំងពីចំណាយសុទ្ធតិចតួចបំផុត នៃការចាកចេញពីកិច្ចសន្យានោះ ដែលជាចំនួនទាបជាងនៃចំណាយនៃការបំពេញកិច្ចសន្យា និងសំណង ឬការពិន័យទាំងឡាយ ដែលកើតចេញពីការខកខានក្នុងការបំពេញកិច្ចសន្យា។ ឧទាហរណ៍ អង្គភាពមួយអាចត្រូវបានតម្រូវតាមកិច្ចសន្យា ក្រោមភតិសន្យាប្រតិបត្តិការឱ្យធ្វើការទូទាត់ជួលទ្រព្យសកម្មមួយដែលលែងមានការប្រើប្រាស់អ្វីទៀត។

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍ជាកាតព្វកិច្ចអតីតកាល -អង្គភាពត្រូវបានតម្រូវតាមកិច្ចសន្យាឱ្យចំណាយធនធាន ដែលការចំណាយធនធានទាំងនោះនឹងមិនទទួលបានអត្ថប្រយោជន៍សមាមាត្រ។

ការសន្និដ្ឋាន - បើសិនជាអង្គភាពមួយមានកិច្ចសន្យាមួយ ដែលនាំឱ្យមានការខាតបង់ អង្គភាព នោះត្រូវទទួលស្គាល់ និងវាស់វែងកាតព្វកិច្ចបច្ចុប្បន្នក្រោមកិច្ចសន្យានោះ ជាសំវិធានធនមួយ។

## ឧទាហរណ៍ទី៣៖ ការរៀបចំរចនាសម្ព័ន្ធឡើងវិញ

២១ក.៣ ការរៀបចំរចនាសម្ព័ន្ធឡើងវិញ គឺជាផែនការដែលបានគ្រោង និងគ្រប់គ្រងដោយថ្នាក់គ្រប់គ្រង និងផ្លាស់ប្តូរជាសារវន្ត លើវិសាលភាពនៃអាជីវកម្មដែលផ្តើមធ្វើដោយអង្គភាពមួយ ឬរបៀបធ្វើប្រតិបត្តិការអាជីវកម្មនោះ។

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍កាតព្វកិច្ចអតីតកាល -កាតព្វកិច្ចដោយសន្មតដើម្បីរៀបចំរចនាសម្ព័ន្ធឡើងវិញ កើតឡើងតែនៅពេលដែលអង្គភាពមួយ៖

(ក) មានផែនការលម្អិតជាផ្លូវការសម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញនោះ ដោយស្វែងយល់ឱ្យច្បាស់ យ៉ាងហោចណាស់នូវ៖

(i) អាជីវកម្ម ឬផ្នែកមួយនៃអាជីវកម្មដែលទាក់ទង

(ii) ទីតាំងចម្បងនានាដែលទទួលរងផលប៉ះពាល់

(iii) ទីតាំង មុខងារ និងចំនួនប្រហាក់ប្រហែលនៃនិយោជិត ដែលនឹងទទួលបានប្រាក់សំណងសម្រាប់ការបញ្ចប់ការងារ

(iv) ចំណាយដែលនឹងត្រូវបានទទួលរ៉ាប់រង និង

(v) ពេលដែលផែនការនឹងត្រូវបានអនុវត្ត និង

(ខ) បានបង្កើតជាការរំពឹងទុកដែលសមរម្យដល់ភាគីទាំងឡាយដែលទទួលរងផលប៉ះពាល់ ឱ្យរំពឹងថាអង្គភាពនឹងអនុវត្តការរៀបចំរចនាសម្ព័ន្ធឡើងវិញ ដោយការចាប់ផ្តើមអនុវត្តផែនការនោះ ឬដោយការប្រកាសអំពីលក្ខណៈសំខាន់ៗរបស់ផែនការនោះ ដល់ភាគីទាំងឡាយដែលទទួលរងផលប៉ះពាល់ដោយផែនការនោះ។

ការសន្និដ្ឋាន -អង្គភាពមួយទទួលស្គាល់សំវិធានធនសម្រាប់ចំណាយលើការរៀបចំរចនាសម្ព័ន្ធឡើងវិញ តែនៅពេលដែលអង្គភាពមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដោយសន្មត ក្នុងការអនុវត្ត ការរៀបចំរចនាសម្ព័ន្ធឡើងវិញនោះ នៅការិយបរិច្ឆេទរាយការណ៍។

## ឧទាហរណ៍ទី៤៖ ការធានា

២១ក.៤ អ្នកផលិតផ្តល់ការធានានៅពេលលក់ដល់អ្នកទិញផលិតផលរបស់ខ្លួន។ ក្រោមលក្ខខណ្ឌនៃកិច្ចសន្យាសម្រាប់ការលក់ អ្នកផលិតសន្យាសង តាមរយៈការជួសជុល និងការដូរថ្មី នូវពិការភាពផលិតកម្មដែលស្តែងឡើង ក្នុងរយៈពេលបីឆ្នាំ គិតចាប់ពីកាលបរិច្ឆេទលក់។ ផ្អែកលើបទពិសោធន៍ អាចនឹង (ពោលគឺ មានភាពទំនងច្រើនជាងមិនទំនង) មានការទាមទារសងមួយចំនួនក្រោមការធានាទាំងនេះ។

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍កាតព្វកិច្ចអតីតកាល -ហេតុការណ៍ កាតព្វកិច្ចនោះ គឺការលក់ផលិតផលដែលមានការធានា ដែលជាហេតុនាំឱ្យមានកាតព្វកិច្ច ផ្លូវច្បាប់។

លំហូរចេញនូវធនធាន ដែលបង្កប់អត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងពេលបំពេញកាតព្វកិច្ច -អាចនឹងមានសម្រាប់ការធានាទាំងមូល។

ការសន្និដ្ឋាន-អង្គភាពទទួលស្គាល់សំវិធានធន សម្រាប់ការប៉ាន់ស្មានល្អបំផុតនៃចំណាយលើការសងក្រោម ផលិតផលមានការធានាដែលបានលក់ មុនកាលបរិច្ឆេទរាយការណ៍។

## ការពន្យល់ដោយលើកឧទាហរណ៍ការគណនា៖

នៅក្នុងឆ្នាំ២០X០ ទំនិញត្រូវបានលក់ក្នុងតម្លៃ ១,០០០,០០០ឯកតារូបិយប័ណ្ណ។ បទពិសោធន៍បង្ហាញ ថា ៩០% នៃផលិតផលដែលបានលក់ មិនត្រូវការជួសជុលតាមការធានាទេ។ ៦% នៃផលិតផលដែលបានលក់ ត្រូវការជួសជុលតិចតួច ដោយចំណាយ៣០% នៃ ថ្លៃលក់ ហើយ៤%នៃផលិតផលដែលបានលក់ ត្រូវការជួសជុលធំដុំ ឬត្រូវដូរថ្មី ដោយចំណាយ៧០% នៃថ្លៃលក់។ ដូច្នេះ ចំណាយលើការធានាដែលបានប៉ាន់ស្មាន គឺ៖

| | |
|---|---|
| ១,០០០,០០០ឯកតារូបិយប័ណ្ណ × ៩០% × ០ | = ០ឯកតារូបិយប័ណ្ណ |
| ១,០០០,០០០ឯកតារូបិយប័ណ្ណ × ៦% × ៣០% | = ១៨,០០០ឯកតារូបិយប័ណ្ណ |
| ១,០០០,០០០ឯកតារូបិយប័ណ្ណ × ៤% × ៧០% | = ២៨,០០០ឯកតារូបិយប័ណ្ណ |
| សរុប | = ៤៦,០០០ឯកតារូបិយប័ណ្ណ |

ការចំណាយសម្រាប់ការជួសជុលនិងការដូរថ្មីតាមការធានាសម្រាប់ផលិតផលដែលបានលក់ក្នុងឆ្នាំ ២០×០ ត្រូវបានរំពឹងទុកថានឹងធ្វើឡើង៦០ភាគរយក្នុងឆ្នាំ២០×១ ៣០ភាគរយក្នុងឆ្នាំ២០×២ និង១០ភាគរយក្នុងឆ្នាំ២០×៣ ក្នុងករណីនីមួយៗនៅចុងការិយបរិច្ឆេទ។ ពីព្រោះលំហូរសាច់ប្រាក់ដែលបានប៉ាន់ស្មាន ឆ្លុះបញ្ចាំងរួចហើយនូវភាពនៃលំហូរចេញនៃសាច់ប្រាក់ ហើយដោយសន្មតជាមុនថាគ្មានហានិភ័យនិងភាពមិនប្រាកដប្រជាផ្សេងទៀតដែលត្រូវតែបានឆ្លុះបញ្ចាំង ដើម្បីកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះអង្គភាពនេះប្រើប្រាស់អត្រាអប្បហារ "គ្មានហានិភ័យ" មួយដែលផ្អែកលើសញ្ញាប័ណ្ណរដ្ឋាភិបាលជាមួយនឹងកាលកំណត់ដូចគ្នានឹងលំហូរចេញនៃសាច់ប្រាក់បានរំពឹងទុក (៦ភាគរយសម្រាប់សញ្ញាប័ណ្ណមួយឆ្នាំ និង៧ភាគរយសម្រាប់សញ្ញាប័ណ្ណពីរឆ្នាំនិងបីឆ្នាំ)។

ការគណនាតម្លៃបច្ចុប្បន្ន នៅដំណាច់ឆ្នាំ២០X០ នៃលំហូរសាច់ប្រាក់ដែលបានប៉ាន់ស្មាន ដែលទាក់ទងនឹងការធានាសម្រាប់ផលិតផលដែលបានលក់ក្នុងឆ្នាំ២០X០ មានដូចខាងក្រោម៖

| ឆ្នាំ | | ការទូទាត់សាច់ប្រាក់ដែលបានរំពឹងទុក (ឯកតារូបិយប័ណ្ណ) | អត្រាអប្បហារ | កត្តាអប្បហារ | តម្លៃបច្ចុប្បន្ន (ឯកតារូបិយប័ណ្ណ) |
|---|---|---|---|---|---|
| ១ | ៦០% × ៤៦,០០០ ឯកតារូបិយប័ណ្ណ | ២៧,៦០០ | ៦% | ០.៩៤៣៤ (៦% សម្រាប់១ឆ្នាំ) | ២៦,០៣៨ |
| ២ | ៣០% × ៤៦,០០០ ឯកតារូបិយប័ណ្ណ | ១៣,៨០០ | ៧% | ០.៨៧៣៤ (៧% សម្រាប់២ ឆ្នាំ) | ១២,០៥៣ |
| | ១០% × ៤៦,០០០ ឯកតារូបិយប័ណ្ណ | ៤,៦០០ | ៧% | ០.៨១៦៣ (៧% សម្រាប់៣ឆ្នាំ | ៣,៧៥៥ |
| សរុប | | | | | ៤១,៨៤៦ |

អង្គភាពនឹងទទួលស្គាល់កាតព្វកិច្ចជានា ៤១,៨៤៦ឯកតារូបិយប័ណ្ណ នៅដំណាច់ឆ្នាំ២០X០ សម្រាប់ ផលិតផលដែលបានលក់ ក្នុងឆ្នាំ២០X០។

## ឧទាហរណ៍ទី៥៖ គោលនយោបាយសងប្រាក់វិញ

២១ក.៥ ហាងលក់រាយមួយ មានគោលនយោបាយសងប្រាក់វិញនូវការទិញដោយអតិថិជនដែលមិនពេញចិត្ត ទោះបីជាហាងលក់រាយនេះពុំមានកាតព្វកិច្ចផ្លូវច្បាប់ ក្នុងការធ្វើបែបនេះក្តី។ គោលនយោបាយសងប្រាក់វិញរបស់ហាងលក់រាយនេះ ត្រូវបានគេដឹងជាទូទៅ។

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍កាតព្វកិច្ចអតីតកាល—ហេតុការណ៍កាតព្វកិច្ច គឺការលក់ផលិតផលដែលជាហេតុនាំឱ្យមានកាតព្វកិច្ចដោយសន្មត ពីព្រោះការប្រព្រឹត្តរបស់ហាង បានបង្កើត ឱ្យមានការរំពឹងទុកសមហេតុផលពីអតិថិជនរបស់ខ្លួនថា ហាងនឹងសងប្រាក់វិញនូវទំនិញដែលបានទិញ។

លំហូរចេញនូវធនធាន ដែលបង្កប់អត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងពេលបំពេញកាតព្វកិច្ច—មួយចំណែកនៃទំនិញនានាអាចនឹងត្រូវបានប្រគល់ជូនវិញសម្រាប់ការសងប្រាក់វិញ។

ការសន្និដ្ឋាន—អង្គភាពទទួលស្គាល់នូវសំវិធានធនមួយសម្រាប់ការប៉ាន់ស្មានល្អបំផុតនៃចំនួនទឹកប្រាក់ដែលតម្រូវក្នុងការទូទាត់ការសងប្រាក់វិញ។

## ឧទាហរណ៍ទី៦៖ ការបិទផ្នែកមួយ - គ្មានការអនុវត្តមុនដំណាច់ការិយបរិច្ឆេទរាយការណ៍

២១ក.៦ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០X០ ក្រុមប្រឹក្សាភិបាលរបស់អង្គភាពមួយ បានសម្រេចបិទផ្នែកមួយ។ មុនដំណាច់ការិយបរិច្ឆេទរាយការណ៍ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X០) សេចក្តីសម្រេចនេះមិនត្រូវបានជូនដំណឹងប្រាប់ អ្នកដែលបានទទួលរងការប៉ះពាល់ណាម្នាក់ ហើយមិនបានចាត់វិធានការផ្សេង ដើម្បីអនុវត្តសេចក្តីសម្រេចនេះ។

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍កាតព្វកិច្ចអតីតកាល—មិនបានមានហេតុការណ៍កាតព្វកិច្ច ដូច្នេះ ពុំមានកាតព្វកិច្ចទេ។

ការសន្និដ្ឋាន—អង្គភាពមិនទទួលស្គាល់សំវិធានធន។

## ឧទាហរណ៍ទី៧៖ ការបិទផ្នែកមួយ ការប្រាស្រ័យទាក់ទង និងការអនុវត្តមុនដំណាច់ការិយបរិច្ឆេទរាយការណ៍

២១ក.៧ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០X០ ក្រុមប្រឹក្សាភិបាលនៃអង្គភាពមួយ បានសម្រេច បិទផ្នែកមួយ ដែលផលិតផលិតផលជាក់លាក់មួយ។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០X០ ផែនការលម្អិតសម្រាប់ការបិទផ្នែកនោះ ត្រូវបានព្រមព្រៀងដោយក្រុមប្រឹក្សាភិបាល លិខិតត្រូវបានផ្ញើទៅអតិថិជន ដោយដាស់តឿនពួកគេឱ្យស្វែងរកប្រភពនៃការផ្គត់ផ្គង់ជំនួស ហើយលិខិតជូនដំណឹងអំពីការកាត់បន្ថយបុគ្គលិក ត្រូវបានផ្ញើជូនបុគ្គលិកនៅផ្នែកនោះ។

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍កាតព្វកិច្ចអតីតកាល —ហេតុការណ៍កាតព្វកិច្ច គឺការប្រាស្រ័យទាក់ទងអំពីសេចក្តីសម្រេច ទៅកាន់អតិថិជន និងបុគ្គលិក ហេតុការណ៍កាតព្វកិច្ចនោះ បង្កើតជាកាតព្វកិច្ចដោយសន្មត គិតចាប់ពីកាលបរិច្ឆេទនោះ ពីព្រោះវាបង្កើតឱ្យមានការរំពឹងទុកសមហេតុផលថាផ្នែកនោះ នឹងត្រូវបានបិទ។

លំហូរចេញនូវធនធាន ដែលបង្កប់អត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងពេលបំពេញកាតព្វកិច្ច - អាចនឹងមាន។

ការសន្និដ្ឋាន—អង្គភាពទទួលស្គាល់សំវិធានធនមួយ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X០ សម្រាប់ការប៉ាន់ស្មានដែលល្អបំផុតនៃចំណាយ ដែលនឹងកើតឡើង ក្នុងការបិទផ្នែកនោះ នៅកាលបរិច្ឆេទរាយការណ៍។

## ឧទាហរណ៍ទី៨៖ ការហ្វឹកហ្វឺនបុគ្គលិកសាជាថ្មី ដែលជាលទ្ធផល នៃការប្រែប្រួលក្នុងប្រព័ន្ធពន្ធលើប្រាក់ចំណូល

២១ក.៨ រដ្ឋាភិបាលដាក់ចេញនូវការផ្លាស់ប្តូរទៅលើប្រព័ន្ធពន្ធលើប្រាក់ចំណូល។ ជាលទ្ធផលនៃការផ្លាស់ប្តូរទាំងនោះ អង្គភាពនៅក្នុងវិស័យសេវាហិរញ្ញវត្ថុ នឹងត្រូវហ្វឹកហ្វឺនសាជាថ្មីនូវផ្នែកជំមួយនៃ កម្លាំងការងារផ្នែករដ្ឋបាល និងផ្នែកលក់របស់ខ្លួន ដើម្បីធានានូវការអនុលោមតាមនិយតកម្មពន្ធដារ ជាបន្ត។ នៅចុងការិយបរិច្ឆេទរាយការណ៍ គ្មានការហ្វឹកហ្វឺនបុគ្គលិកបានកើតឡើងទេ។

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍កាតព្វកិច្ចអតីតកាល—ការកែប្រែច្បាប់ ពន្ធដារមិនដាក់កាតព្វកិច្ចឱ្យអង្គភាពធ្វើការហ្វឹកហ្វឺនសាឡើងវិញណាមួយឡើយ។ ហេតុការណ៍កាតព្វកិច្ច សម្រាប់ការទទួលស្គាល់សំវិធានធន (ការហ្វឹកហ្វឺនសាឡើងវិញខ្លួនផ្ទាល់) មិនបានកើតឡើងទេ។

ការសន្និដ្ឋាន—អង្គភាពមិនទទួលស្គាល់សំវិធានធន។

## ឧទាហរណ៍ទី៩៖ សំណុំរឿងតុលាការ

២១ក.៩ អតិថិជនម្នាក់ បានប្តឹងអង្គភាព X ដោយទាមទារជំងឺចិត្តចំពោះ ការខូចខាត ដែលអតិថិជននោះ ចោទថា ខ្លួនបានទទួលរងពីការប្រើប្រាស់ ផលិតផល ដែលអង្គភាព X បានលក់ឱ្យ។ អង្គភាព X បដិសេធការទទួលខុសត្រូវនេះ ដោយមូលហេតុថា អតិថិជននោះ មិនបានអនុវត្តតាមការណែនាំអំពីការប្រើប្រាស់ផលិតផល។ រហូតដល់ថ្ងៃដែល ក្រុមប្រឹក្សាភិបាលបានអនុញ្ញាតរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X១ សម្រាប់ការចេញផ្សាយ មេធាវីរបស់អង្គភាព នោះផ្តល់យោបល់ថា ប្រហែលជា អង្គភាពនឹងមិនត្រូវបានធ្វើការសម្រេចថា មានការទទួលខុសត្រូវទេ។ ក៏ប៉ុន្តែ នៅពេលដែលអង្គភាពរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ឆ្នាំត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X២ មេធាវីរបស់អង្គភាពផ្តល់យោបល់ថា ដោយសារការវិវត្តក្នុងសំណុំរឿងនេះ ពេលនេះ ប្រហែលជាអង្គភាពនឹងត្រូវ បានធ្វើការសម្រេចថា មានការទទួលខុសត្រូវ៖

(ក) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X១

កាតព្វកិច្ចបច្ចុប្បន្ន ដែលជាលទ្ធផលនៃហេតុការណ៍កាតព្វកិច្ចអតីតកាល—ផ្អែកលើ ភ័ស្តុតាងដែលអាចរកបាន នៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័ត ពុំមានកាតព្វកិច្ចជាលទ្ធផលនៃហេតុការណ៍អតីតកាលទេ។

ការសន្និដ្ឋាន—គ្មានសំវិធានធនត្រូវបានទទួលស្គាល់។ បញ្ហានេះត្រូវបានលាត ត្រដាងជាបំណុលយថាហេតុ វៀរលែងតែភវនីយភាពនៃលំហូរចេញណាមួយ ត្រូវបានចាត់ទុកថា តិចតួចណាស់។

(ខ) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X២

កាតព្វកិច្ចបច្ចុប្បន្នដែលជាលទ្ធផលនៃហេតុការណ៍កាតព្វកិច្ចអតីតកាល—ផ្អែកលើភ័ស្តុតាងដែលអាចរកបាន មានកាតព្វកិច្ចបច្ចុប្បន្នមួយ។ ហេតុការណ៍កាតព្វកិច្ចនោះ គឺការលក់ ផលិតផលឱ្យអតិថិជននោះ។

លំហូរចេញនូវធនធាន ដែលបង្កប់អត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងពេលបំពេញកាតព្វកិច្ច—អាចនឹងមាន។

ការសន្និដ្ឋាន—សំវិធានធនមួយ ត្រូវបានទទួលស្គាល់ តាមការប៉ាន់ស្មានល្អបំផុត នូវចំនួនទឹកប្រាក់ដើម្បីបំពេញកាតព្វកិច្ច នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X២ ហើយការចំណាយត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ វាមិនមែនជា ការកែតម្រូវកំហុសក្នុងឆ្នាំ២០X១ ទេ ពីព្រោះ ផ្អែកលើភ័ស្តុតាង ដែលអាចរកបាន នៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០X១ ត្រូវបានអនុម័ត សំវិធានធនមួយមិនគួរត្រូវបានទទួលស្គាល់នៅពេលនោះឡើយ។

# ផ្នែកទី ២២
# បំណុល និងមូលធន

## វិសាលភាពនៃផ្នែកនេះ

២២.១ ផ្នែកនេះបង្កើតគោលការណ៍សម្រាប់ការធ្វើចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុជាបំណុល ឬដើមទុន និងបង្ហាញពីការធ្វើគណនេយ្យកម្មសម្រាប់ឧបករណ៍មូលធនដែលបានចេញផ្សាយទៅឱ្យបុគ្គលទាំងឡាយ ឬភាគីផ្សេងទៀតដែលដើរតួក្នុងតួនាទីរបស់ពួកគេជាអ្នកវិនិយោគនៅក្នុងឧបករណ៍មូលធន (ពោលគឺក្នុងតួនាទីរបស់ពួកគេជាម្ចាស់)។ ផ្នែកទី២៦ ការទូទាត់ផ្អែកលើភាគហ៊ុន បង្ហាញពីការធ្វើគណនេយ្យកម្មលើប្រតិបត្តិការដែលអង្គភាពមួយទទួលទំនិញ ឬ សេវាកម្ម (រួមមានសេវាកម្មរបស់និយោជិត) ជាតម្លៃតបស្នងសម្រាប់ឧបករណ៍មូលធន (រួមមាន ភាគហ៊ុន ឬ សិទ្ធិទិញភាគហ៊ុន) ពីនិយោជិត និងអ្នកផ្គត់ផ្គង់ផ្សេងទៀតដែលដើរតួក្នុងតួនាទីរបស់ពួកគេជាអ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្ម។

២២.២ ផ្នែកនេះត្រូវបានអនុវត្តនៅពេលធ្វើចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុគ្រប់ប្រភេទ លើកលែងតែ៖

(ក) ភាគកម្មទាំងឡាយនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ដែលត្រូវធ្វើគណនេយ្យកម្មដោយអនុលោមតាមផ្នែកទី៩ របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ឬផ្នែកទី១៤ ការវិនិយោគនៅក្នុង ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬផ្នែកទី១៥ ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។

(ខ) សិទ្ធិ និងកាតព្វកិច្ចរបស់និយោជកស្ថិតក្រោមផែនការអត្ថប្រយោជន៍និយោជិតដែលត្រូវអនុវត្តតាមផ្នែកទី២៨ អត្ថប្រយោជន៍និយោជិត។

(គ) កិច្ចសន្យាសម្រាប់ការតបស្នងយថាហេតុនៅក្នុងការរួមបញ្ចូលអាជីវកម្ម (សូមមើលផ្នែកទី១៩ ការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម) ។ ការលើកលែងនេះអនុវត្តតែចំពោះអ្នកទិញ។

(ឃ) ឧបករណ៍ហិរញ្ញវត្ថុ កិច្ចសន្យា និង កាតព្វកិច្ចក្រោម ប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុនត្រូវអនុវត្តតាមផ្នែកទី២៦ លើកលែងតែកថាខណ្ឌ២២.៣ -២២.៦ ត្រូវបានអនុវត្តចំពោះភាគហ៊ុនរតនៈដែលបានទិញលក់ បោះផ្សាយ ឬលុបចោល ទាក់ទងនឹងផែនការសិទ្ធិទិញភាគហ៊ុនរបស់និយោជិត ផែនការទិញភាគហ៊ុនរបស់ និយោជិត និងរាល់ការរៀបចំទូទាត់ផ្អែកលើភាគហ៊ុនផ្សេងទៀត។

## ចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុជាបំណុល ឬមូលធន

២២.៣ មូលធនគឺជាតម្លៃកាកសំណល់នៃទ្រព្យសកម្មរបស់អង្គភាពបន្ទាប់ពីដកបំណុលទាំងអស់របស់អង្គភាពនោះ។ បំណុលគឺជាកាតព្វកិច្ចបច្ចុប្បន្នរបស់អង្គភាពដែលកើតចេញពីព្រឹត្តិការណ៍អតីតកាលហើយការទូទាត់នៃកាតព្វកិច្ចនេះត្រូវបានរំពឹងថានឹងកើតមានលំហូរចេញនៃធនធានរបស់អង្គភាពដែលមានផលប្រយោជន៍សេដ្ឋកិច្ច។ ដើមទុនរួមបញ្ចូលការវិនិយោគដោយម្ចាស់អង្គភាព បូកបន្ថែមលើការវិនិយោគទាំងនោះដែលរកបានតាមរយៈ ប្រតិបត្តិការដែលចំណេញ និងបានរក្សាទុកសម្រាប់ប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់អង្គភាពនោះ ដកចេញនូវ ការថយចុះនៃការវិនិយោគដែលជាលទ្ធផលនៃប្រតិបត្តិការមិនចំណេញ និងការបែងចែកទៅឱ្យម្ចាស់អង្គភាព។

២២.៣ក អង្គភាពត្រូវចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុជាបំណុលហិរញ្ញវត្ថុ ឬជាមូលធន ស្របតាមខ្លឹមសារនៃការរៀបចំ កិច្ចសន្យា មិនមែនគ្រាន់តែទម្រង់ផ្លូវច្បាប់របស់វាប៉ុណ្ណោះទេ និងស្របតាមនិយមន័យនៃបំណុលហិរញ្ញវត្ថុ និង ឧបករណ៍មូលធន។ ប្រសិនជាអង្គភាពមិនមានសិទ្ធិដែលគ្មានលក្ខខណ្ឌ ដើម្បីគេចផុតពីការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតក្នុងការដោះស្រាយកាតព្វកិច្ចតាមកិច្ចសន្យា កាតព្វកិច្ចនោះបំពេញបានតាម និយមន័យនៃបំណុលហិរញ្ញវត្ថុ និងត្រូវធ្វើចំណាត់ថ្នាក់បែបនោះ លើកលែងតែឧបករណ៍ទាំងឡាយដែលបាន ចាត់ថ្នាក់ជាឧបករណ៍មូលធនអនុលោមតាមកថាខណ្ឌ២២.៤។

២២.៤ ឧបករណ៍ហិរញ្ញវត្ថុមួយចំនួនដែលបំពេញតាមនិយមន័យបំណុល ត្រូវបានចាត់ថ្នាក់ជាមូលធនដោយសារ ឧបករណ៍ហិរញ្ញវត្ថុទាំងនោះតំណាងឱ្យភាគកម្មដែលសល់នៅក្នុងទ្រព្យសកម្មសុទ្ធរបស់អង្គភាព៖

(ក) ឧបករណ៍ដែលអាចប្តូរបាន (Puttable instrument) ជាឧបករណ៍ហិរញ្ញវត្ថុដែលផ្តល់ឱ្យអ្នកកាន់ឧបករណ៍នូវ សិទ្ធិដើម្បីលក់ឧបករណ៍នោះត្រឡប់ទៅឱ្យអ្នកបោះផ្សាយវិញបានជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេង ទៀត ឬត្រូវបានហៅត្រឡប់មកវិញ ឬទិញមកវិញដោយស្វ័យប្រវត្តិដោយអ្នកបោះផ្សាយនៅពេលកើតមាន ព្រឹត្តិការណ៍មិនច្បាស់លាស់ណាមួយនាពេលអនាគត ឬមរណភាព ឬការចូលនិវត្តន៍របស់អ្នកកាន់ឧបករណ៍។ ឧបករណ៍ដែលអាចប្តូរបានដែលមានលក្ខណៈទាំងអស់ដូចខាងក្រោមត្រូវចាត់ថ្នាក់ជាឧបករណ៍មូលធន៖

(១) ឧបករណ៍ផ្តល់សិទ្ធិឱ្យអ្នកកាន់នូវភាគហ៊ុនតាមសមាមាត្រនៃទ្រព្យសកម្មរបស់អង្គភាពនៅក្នុងករណីជំរះបញ្ជីអង្គភាព។ ទ្រព្យសកម្មសុទ្ធរបស់អង្គភាពគឺជាទ្រព្យសកម្មទាំងឡាយណាដែលនៅសល់បន្ទាប់ ពីដកចេញនូវការទាមទារទាំងអស់នូវទ្រព្យសកម្មរបស់អង្គភាព។

(២) ឧបករណ៍នោះស្ថិតនៅក្នុងថ្នាក់នៃឧបករណ៍ដែលនៅក្រោមចំណាត់ថ្នាក់នៃឧបករណ៍ផ្សេងទៀត។

(៣) ឧបករណ៍ហិរញ្ញវត្ថុទាំងអស់នៅក្នុងថ្នាក់នៃឧបករណ៍ ដែលនៅក្រោមចំណាត់ថ្នាក់នៃឧបករណ៍ផ្សេងទៀតដែលមានលក្ខណៈដូចគ្នាសុទ្ធសាធ។

(៤) ក្រៅពីកាតព្វកិច្ចតាមកិច្ចសន្យារបស់អ្នកបោះផ្សាយដែលត្រូវទិញមកវិញ ឬហៅមកវិញនូវ ឧបករណ៍នោះសម្រាប់ជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឧបករណ៍នោះមិនមានបញ្ចូល នូវកាតព្វកិច្ចតាមកិច្ចសន្យាដើម្បីប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតទៅឱ្យអង្គភាពផ្សេងទៀត ឬដើម្បីដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយអង្គភាពមួយទៀតក្រោមលក្ខខណ្ឌដែលមិនអំណោយផលខ្លាំងដល់អង្គភាព និងវាមិនមែនជាកិច្ចសន្យាដែលនឹង ឬអាចនឹងត្រូវ បានទូទាត់ជាឧបករណ៍មូលធនរបស់អង្គភាពខ្លួនឯង។

(៥) លំហូរសាច់ប្រាក់បានរំពឹងទុកសរុប ដែលចូលរួមចំណែកចំពោះឧបករណ៍នោះលើអាយុកាលនៃឧបករណ៍ត្រូវបានផ្អែកយ៉ាងសំខាន់លើចំណេញ ឬខាត ការប្រែប្រួលនៅក្នុងទ្រព្យសកម្មសុទ្ធដែលបាន ទទួលស្គាល់ ឬការប្រែប្រួលនៃតម្លៃសមស្របរបស់ទ្រព្យសកម្មសុទ្ធរបស់អង្គភាពដែលបានទទួលស្គាល់ និងមិនបានទទួលស្គាល់ក្នុងអាយុកាលនៃឧបករណ៍នោះ (មិនបញ្ចូលនូវផលប៉ះពាល់ណាមួយនៃ ឧបករណ៍)។

(ខ) ឧបករណ៍ ឬសមាសធាតុនានានៃឧបករណ៍ដែលនៅក្រោមចំណាត់ថ្នាក់ឧបករណ៍ទាំងអស់ផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាមូលធន ប្រសិនបើឧបករណ៍ ឬសមាសធាតុនានានោះកំណត់ឱ្យអង្គភាពមានកាតព្វកិច្ចដើម្បី ប្រគល់ឱ្យភាគីមួយទៀតនូវសមាមាត្រភាគហ៊ុននៃតម្លៃទ្រព្យសកម្មសុទ្ធរបស់អង្គភាព តែនៅពេលជំរះបញ្ជី ប៉ុណ្ណោះ។

២២.៥ ខាងក្រោមជាឧទាហរណ៍នៃឧបករណ៍ដែលត្រូវបានចាត់ថ្នាក់ជាបំណុល មិនមែនជាមូលធន៖

(ក) ឧបករណ៍មួយត្រូវបានចាត់ថ្នាក់ជាបំណុល ប្រសិនបើការបែងចែកទ្រព្យសកម្មសុទ្ធនៅពេលជំរះបញ្ជីគឺជាកម្មវត្ថុនៃចំនួនទឹកប្រាក់អតិបរមា(ពិដាន)។ ឧទាហរណ៍ ប្រសិនបើនៅក្នុងការជំរះបញ្ជីអ្នកកាន់ឧបករណ៍ទទួលបានភាគហ៊ុនតាមសមាមាត្រនៃទ្រព្យសកម្ម ប៉ុន្តែចំនួននេះត្រូវបានកំណត់ពិដាន និងទ្រព្យសកម្មសុទ្ធដែលលើសត្រូវបែងចែកទៅឱ្យអង្គការសប្បុរសធម៌ ឬរដ្ឋាភិបាល ឧបករណ៍នោះមិនត្រូវបានចាត់ថ្នាក់ជាមូលធនទេ។

(ខ) ឧបករណ៍ដែលអាចប្តូរបានត្រូវចាត់ថ្នាក់ជាមូលធន ប្រសិនបើអ្នកកាន់ទទួលបាននូវភាគហ៊ុនតាមសមាមាត្រនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពដែលបានវាស់វែងដោយអនុលោមតាមស្តង់ដារនេះ នៅពេលដែល ជម្រើសលក់ឧបករណ៍នេះត្រូវបានអនុវត្ត។ ប៉ុន្តែ ប្រសិនបើអ្នកកាន់ឧបករណ៍មានសិទ្ធិទទួលបានចំនួនដែលបាន វាស់វែងតាមមូលដ្ឋានមួយចំនួនផ្សេងទៀត (ដូចជាគោលការណ៍គណនេយ្យទទួលស្គាល់ជាទូទៅ ក្នុងប្រទេស) ឧបករណ៍នោះត្រូវបានចាត់ថ្នាក់ជាបំណុល។

(គ) ឧបករណ៍មួយត្រូវបានចាត់ថ្នាក់ជាបំណុល ប្រសិនបើវាតម្រូវឱ្យអង្គភាពធ្វើការទូទាត់ទៅឱ្យអ្នកកាន់មុនពេលជំរះបញ្ជីដូចជាភាគលាភតាមការកំណត់។

(ឃ) ឧបករណ៍ដែលអាចប្តូរបានដែលត្រូវបានចាត់ថ្នាក់ជាមូលធននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានចាត់ថ្នាក់ជាបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុនមេ។

(ង) ភាគហ៊ុនអាទិភាពផ្តល់ឱ្យសម្រាប់ការហៅមកវិញជាកំហិតដោយអ្នកបោះផ្សាយតាមចំនួនថេរ ឬចំនួនដែលអាចកំណត់បាននៅថ្ងៃអនាគតជាក់លាក់ ឬថ្ងៃដែលអាចកំណត់បានណាមួយ ឬផ្តល់ឱ្យអ្នកកាន់នូវសិទ្ធិដើម្បីតម្រូវ ឱ្យអ្នកបោះផ្សាយហៅត្រឡប់មកវិញនូវឧបករណ៍នៅ ឬបន្ទាប់ពីថ្ងៃជាក់លាក់ណាមួយសម្រាប់ចំនួនថេរ ឬចំនួន ដែលអាចកំណត់បានគឺជាបំណុលហិរញ្ញវត្ថុ។

២២.៦ ភាគហ៊ុនរបស់សមាជិកនៅអង្គភាពសហប្រតិបត្តិការ និងឧបករណ៍ស្រដៀងគ្នាគឺជាមូលធន ប្រសិន៖

(ក) អង្គភាពនោះមានសិទ្ធិដោយឥតលក្ខខណ្ឌដើម្បីបដិសេធការហៅមកវិញនូវភាគហ៊ុនរបស់សមាជិក ឬ

(ខ) ការហៅត្រឡប់មកវិញត្រូវបានគេហាមឃាត់ដោយឥតលក្ខខណ្ឌតាមច្បាប់ បទប្បញ្ញត្តិក្នុងស្រុក ឬធម្មនុញ្ញគ្រប់គ្រងរបស់អង្គភាព។

## ការបោះផ្សាយដំបូងនៃភាគហ៊ុន ឬឧបករណ៍មូលធនផ្សេងទៀត

២២.៧ អង្គភាពមួយត្រូវទទួលស្គាល់ការបោះផ្សាយភាគហ៊ុន ឬឧបករណ៍មូលធនផ្សេងទៀតជាមូលធននៅពេលអង្គភាពបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុទាំងនោះ និងភាគីមួយទៀតមានកាតព្វកិច្ចផ្តល់សាច់ប្រាក់ ឬធនធានផ្សេងទៀតទៅឱ្យអង្គភាពនោះក្នុងការដោះដូរឧបករណ៍៖

(ក) ប្រសិនឧបករណ៍មូលធនត្រូវបានបោះផ្សាយមុនអង្គភាពទទួលបានសាច់ប្រាក់ ឬធនធានផ្សេងទៀតអង្គភាព ត្រូវបង្ហាញចំនួនដែលត្រូវទទួលបានជាចំនួនសម្រាប់កាត់កងទៅនឹងមូលធននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មិនមែនជាទ្រព្យសកម្មទេ។

(ខ) ប្រសិនបើអង្គភាពទទួលបានសាច់ប្រាក់ ឬ ធនធានផ្សេងទៀតមុនពេលឧបករណ៍មូលធនត្រូវបាន

បោះផ្សាយ ហើយអង្គភាពនោះមិនអាចត្រូវបានតម្រូវឱ្យសងត្រឡប់វិញនូវសាច់ប្រាក់ ឬធនធានផ្សេងទៀត ដែលបានទទួល អង្គភាពត្រូវទទួលស្គាល់ការកើនឡើងនៅក្នុងមូលធនស្របគ្នាជាមួយតម្លៃតបស្នងដែល បានទទួល។

(គ) ក្នុងករណីដែលឧបករណ៍មូលធនត្រូវបានទិញ ប៉ុន្តែមិនទាន់បោះផ្សាយ ហើយអង្គភាពមិនទាន់ទទួលបាន សាច់ប្រាក់ ឬធនធានផ្សេងទៀត អង្គភាពមិនត្រូវទទួលស្គាល់ការកើនឡើងនៅក្នុងមូលធនឡើយ។

២២.៨ ក្រៅពីឧបករណ៍ដែលបានបោះផ្សាយជាផ្នែកមួយនៃការរួមបញ្ចូលអាជីវកម្ម ឬឧបករណ៍នានាដែលត្រូវបានធ្វើ គណនេយ្យកម្មអនុលោមតាមកថាខណ្ឌ២២.១៥ក-២២.១៥ខ អង្គភាពត្រូវវាស់វែងឧបករណ៍មូលធនតាមតម្លៃ សមស្របនៃសាច់ប្រាក់ ឬធនធានផ្សេងទៀតដែលបានទទួល ឬត្រូវទទួលបាន ដកចេញថ្លៃដើមប្រតិបត្តិការ។ ប្រសិនបើការទូទាត់ត្រូវបានពន្យារ ហើយតម្លៃពេលវេលានៃលុយមានចំនួនជាសារវន្ត ការវាស់វែងលើកដំបូង ត្រូវ ធ្វើតាមមូលដ្ឋានតម្លៃបច្ចុប្បន្ន។

២២.៩ អង្គភាពត្រូវទទួលស្គាល់ថ្លៃដើមប្រតិបត្តិការនៃប្រតិបត្តិការមូលធនជាការកាត់បន្ថយពីមូលធន។ ពន្ធលើប្រាក់ ចំណូលដែលទាក់ទិននឹងថ្លៃដើមប្រតិបត្តិការត្រូវធ្វើគណនេយ្យកម្មស្របតាមផ្នែកទី២៩ ស្តីពី ពន្ធលើប្រាក់ ចំណូល។

២២.១០ របៀបនៃការកើនឡើងនៅក្នុងមូលធនដែលកើតឡើងពីការបោះផ្សាយភាគហ៊ុន ឬឧបករណ៍មូលធនផ្សេងទៀត ត្រូវ បានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានកំណត់ដោយច្បាប់។ ឧទាហរណ៍ តម្លៃចារិក ( ឬ តម្លៃ មានតែនាមផ្សេងទៀត) នៃភាគហ៊ុន និងចំនួនដែលបានបង់លើសពីចំនួនតម្លៃចារិកអាចនឹងត្រូវតម្រូវឱ្យ បង្ហាញ ដោយឡែកពីគ្នា។

## ការលក់នៃជម្រើស សិទ្ធិ និងលិខិតធានា

២២.១១ អង្គភាពត្រូវអនុវត្តគោលការណ៍នៅក្នុងកថាខណ្ឌ ២២.៧ - ២២.១០ ចំពោះមូលធនដែលបានបោះផ្សាយតាម មធ្យោបាយនៃការលក់ជម្រើស សិទ្ធិ លិខិតធានា និងឧបករណ៍មូលធនស្រដៀងគ្នាដទៃទៀត។

## មូលធនកម្ម ឬប្រាក់បន្ថែមដែលបោះផ្សាយនៃភាគហ៊ុន និងភាគហ៊ុនបំបែក

២២.១២ មូលធនកម្ម ឬប្រាក់បន្ថែម( ពេលខ្លះត្រូវបានសំដៅទៅលើភាគលាភរបស់ភាគហ៊ុន) គឺជាការបោះផ្សាយភាគហ៊ុន ថ្មីទៅឱ្យម្ចាស់ភាគហ៊ុនតាមសមាមាត្រចំពោះភាគហ៊ុនដែលមានស្រាប់របស់គាត់។ ឧទាហរណ៍ អង្គភាពអាចផ្តល់ ឱ្យម្ចាស់ភាគហ៊ុននូវភាគលាភមួយ ឬ ភាគហ៊ុនបន្ថែមសម្រាប់រាល់ភាគហ៊ុនចំនួន ៥ ដែលបានកាន់កាប់។ ភាគហ៊ុន បំបែក (share splits ឬ stock splits) គឺជាការបំបែកភាគហ៊ុនរបស់អង្គភាពដែលមានស្រាប់ទៅជា ភាគហ៊ុន ច្រើនទៀត។ ឧទាហរណ៍ នៅក្នុងការបំបែកភាគហ៊ុនម្ចាស់ភាគហ៊ុននីមួយៗអាចទទួលភាគហ៊ុនមួយបន្ថែមទៀត សម្រាប់ភាគហ៊ុនមួយដែលបានកាន់កាប់។ ក្នុងករណីខ្លះ ភាគហ៊ុនដែលកំពុងចរាចរណ៍ពីមុនត្រូវបាន លុបចោល និងជំនួសវិញដោយភាគហ៊ុនថ្មី។ មូលធនកម្ម និងការបោះផ្សាយប្រាក់បន្ថែម និងភាគហ៊ុនបំបែកមិន បានផ្លាស់ប្តូរ តម្លៃមូលធនសរុបទេ។ អង្គភាពមួយត្រូវចាត់ថ្នាក់ឡើងវិញនូវចំនួននៅក្នុងមូលធនតាមការតម្រូវ ដោយច្បាប់។

## បំណុលអាចបំលែងបាន ឬឧបករណ៍ហិរញ្ញវត្ថុផ្សបស្រដៀងគ្នា

២២.១២ ក្នុងការបោះផ្សាយបំណុលអាចបំលែងបាន ឬឧបករណ៍ហិរញ្ញវត្ថុផ្សបស្រដៀងគ្នាដែលមានទាំងសមាសធាតុ បំណុល និងមូលធន អង្គភាពត្រូវបែងចែកចំណូលពីការលក់រវាងសមាសធាតុបំណុល និងមូលធន។ ដើម្បីធ្វើការ បែងចែកជាដំបូងអង្គភាពត្រូវកំណត់នូវចំនួនសមាសធាតុបំណុលតាមតម្លៃសមស្របនៃបំណុលស្រដៀងគ្នាដែល មិនមានលក្ខណៈបំលែងបាន ឬសមាសធាតុមូលធនដែលពាក់ព័ន្ធស្រដៀងគ្នា។ អង្គភាពត្រូវបែងចែកចំនួនកាក សំណល់ជាសមាសធាតុមូលធន។ ថ្លៃដើមប្រតិបត្តិការត្រូវបានបែងចែករវាងសមាសធាតុបំណុល និងមូលធន ដោយផ្អែកលើមូលដ្ឋាននៃតម្លៃសមស្របដែលទាក់ទិន។

២២.១៤ អង្គភាពមិនត្រូវកែប្រែការបែងចែកនៅក្នុងការិយបរិច្ឆេទបន្តបន្ទាប់នោះទេ។

២២.១៥ នៅក្នុងការិយបរិច្ឆេទបន្ទាប់ពីឧបករណ៍ហិរញ្ញវត្ថុត្រូវបានបោះផ្សាយ អង្គភាពត្រូវធ្វើគណនេយ្យកម្មលើ សមាសធាតុបំណុលដូចខាងក្រោម៖

(ក) អនុលោមតាមផ្នែកទី១១ស្តីពី ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ប្រសិនបើសមាសធាតុបំណុលបំពេញលក្ខខណ្ឌក្នុងកថាខណ្ឌ១១.៩។ ក្នុងករណីទាំងនេះ អង្គភាពត្រូវទទួលស្គាល់ជាប្រព័ន្ធនូវលម្អៀងរវាងសមាសធាតុបំណុល និងប្រាក់ដើមដែលត្រូវបង់នៅថ្ងៃកំណត់ ជាចំណាយការប្រាក់បន្ថែមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព (សូមមើលកថាខណ្ឌ ១១.១៥-១១.២០)។

(ខ) អនុលោមតាមផ្នែកទី១២ ស្តីពីបញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ ប្រសិនបើសមាសធាតុបំណុលមិនបំពេញលក្ខខណ្ឌក្នុងកថាខណ្ឌ១១.៩។

## ការបញ្ចប់បំណុលហិរញ្ញវត្ថុជាមួយឧបករណ៍មូលធន

២២.១៥ក អង្គភាពត្រូវចរចាឡើងវិញលើលក្ខខណ្ឌនៃបំណុលហិរញ្ញវត្ថុជាមួយឥណទាយក (ម្ចាស់បំណុល) របស់អង្គភាពជាមួយលទ្ធផលដែលអង្គភាពនោះបញ្ចប់បំណុលទាំងស្រុងឬដោយផ្អែកដោយការបោះផ្សាយឧបករណ៍មូលធនឱ្យឥណទាយក។ ការបោះផ្សាយឧបករណ៍មូលធនបង្កើតនូវតម្លៃតបស្នង ដែលទូទាត់បានអនុលោមកថាខណ្ឌ១១.៣៨។ អង្គភាពត្រូវវាស់វែងឧបករណ៍មូលធនដែលបានបោះផ្សាយតាមតម្លៃសមស្រប។ ប៉ុន្តែ ប្រសិនបើតម្លៃសមស្របរបស់ឧបករណ៍មូលធនដែលបានបោះផ្សាយមិនអាចវាស់វែងគួរឱ្យទុកចិត្តបាន ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុ ឧបករណ៍មូលធននោះត្រូវវាស់វែងតាមតម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុដែលបានបញ្ចប់។ អង្គភាពត្រូវឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ ឬផ្នែកមួយនៃបំណុលហិរញ្ញវត្ថុអនុលោមតាមកថាខណ្ឌ១១.៣៦-១១.៣៨។

២២.១៥ខ ប្រសិនបើផ្នែកនៃតម្លៃតបស្នងដែលបានទូទាត់រួចមានការទាក់ទិននឹងការកែ តម្រូវលក្ខខណ្ឌនៃចំណែកបំណុលដែលនៅសល់ អង្គភាពត្រូវធ្វើការបែងចែកតម្លៃតបស្នងដែលបានទូទាត់រវាង ចំណែកបំណុលដែលបានបញ្ចប់ និងចំណែកបំណុលដែលនៅសល់មិនទាន់សង។ ការបែងចែកនេះគួរត្រូវបានធ្វើឡើងផ្អែកលើហេតុផល សមស្រប។ ប្រសិនបើបំណុលដែលនៅសល់ត្រូវកែតម្រូវធំដុំ អង្គភាពត្រូវធ្វើគណនេយ្យកម្មលើការកែតម្រូវជា ការបញ្ចប់បំណុលដើម និងការទទួលស្គាល់បំណុលថ្មី ដូចដែលបានតម្រូវដោយកថាខណ្ឌ១១.៣៧។

២២.១៥គ អង្គភាពមិនត្រូវអនុវត្តកថាខណ្ឌ២២.១៥ក-២២.១៥ខ ចំពោះប្រតិបត្តិការនៅក្នុងស្ថានភាពដែល៖

(ក) ឥណទាយក គឺជាម្ចាស់ភាគហ៊ុនផ្ទាល់ ឬប្រយោល និងកំពុងដើរតួក្នុងតួនាទីរបស់គេជាម្ចាស់ភាគហ៊ុនផ្ទាល់ ឬប្រយោល។

(ខ) ឥណទាយក និងអង្គភាពត្រូវបានគ្រប់គ្រងដោយភាគីដូចគ្នា ឬក្រុមភាគីដូចគ្នាមុន និងក្រោយប្រតិបត្តិការ ហើយខ្លឹមសារនៃប្រតិបត្តិការនោះរាប់បញ្ចូលការបែងចែកមូលធនដោយ ឬការវិភាគទានមូលធនឱ្យអង្គភាព។

(គ) ការបញ្ចប់បំណុលហិរញ្ញវត្ថុដោយការបោះផ្សាយឧបករណ៍មូលធន គឺស្របតាមលក្ខខណ្ឌដំបូងនៃបំណុលហិរញ្ញវត្ថុ (សូមមើលកថាខណ្ឌ២២.១៣-២២.១៥)។

## ភាគហ៊ុនរតនៈ

២២.១៦ ភាគហ៊ុនរតនៈ: គឺជាឧបករណ៍មូលធនរបស់អង្គភាពដែលត្រូវបានបោះផ្សាយ និងក្រោយមកត្រូវបានទិញត្រឡប់មកវិញដោយអង្គភាព។ អង្គភាពត្រូវដកចេញពីមូលធននូវតម្លៃសមស្របនៃតម្លៃតបស្នងដែលបានផ្តល់សម្រាប់ភាគហ៊ុនរតនៈ។ អង្គភាពមិនត្រូវទទួលស្គាល់ផលចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលើការទិញ លក់ បោះផ្សាយ ឬការលុបចោលនៃភាគហ៊ុនរតនៈឡើយ។

## ការបែងចែកទៅឱ្យម្ចាស់ភាគហ៊ុន

២២.១៧ អង្គភាពត្រូវកាត់បន្ថយមូលធននូវចំនួនដែលបែងចែកទៅឱ្យម្ចាស់ (អ្នកកាន់ឧបករណ៍មូលធនរបស់អង្គភាព)។ ពន្ធលើប្រាក់ចំណូលដែលទាក់ទិននឹងការបែងចែកទៅឱ្យម្ចាស់ត្រូវធ្វើគណនេយ្យកម្មអនុលោមតាមផ្នែកទី២៩។

២២.១៨ ពេលខ្លះ អង្គភាពមួយបែងចែកទ្រព្យសកម្មដែលមិនមែនសាច់ប្រាក់ទៅឱ្យម្ចាស់របស់គេ (ការបែងចែកមិនមែនសាច់ប្រាក់)។ នៅពេលអង្គភាពមួយប្រកាសការបែងចែកបែបនេះ និងមានកាតព្វកិច្ចបែងចែកទ្រព្យសកម្មមិនមែនសាច់ប្រាក់ទៅឱ្យម្ចាស់របស់គេ អង្គភាពត្រូវទទួលស្គាល់ជាបំណុល។ អង្គភាពត្រូវវាស់វែងបំណុលនោះតាមតម្លៃសមស្របនៃទ្រព្យសកម្មដែលត្រូវបែងចែក វៀរលែងតែបំណុលនោះបំពេញលក្ខខណ្ឌក្នុងកថាខណ្ឌ២២.១៨ក។ នៅចុងការិយបរិច្ឆេទរាយការណ៍ និងនៅថ្ងៃនៃការទូទាត់សង អង្គភាពត្រូវពិនិត្យមើលឡើងវិញ និងធ្វើនិយ័តកម្ម លើតម្លៃយោងនៃភាគលាភដែលត្រូវទូទាត់ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលនៃតម្លៃសមស្របរបស់ទ្រព្យសកម្មដែល ត្រូវបែងចែក ជាមួយនឹងការប្រែប្រួលដែលបានទទួលស្គាល់នៅក្នុងមូលធន ជានិយ័តកម្មចំពោះចំនួននៃការ បែងចែក។ នៅពេលដែលអង្គភាពធ្វើការទូទាត់នូវភាគលាភត្រូវបង់ អង្គភាពត្រូវទទួលស្គាល់ក្នុងចំណេញ ឬខាត នូវលម្អៀងរវាងតម្លៃយោងនៃទ្រព្យសកម្មដែលបានបែងចែក និងតម្លៃយោងនៃភាគលាភត្រូវបង់។

២២.១៨ក ប្រសិនបើតម្លៃសមស្របនៃទ្រព្យសកម្ម ដែលត្រូវបែងចែកមិនអាចវាស់វែងគួរឱ្យទុកចិត្តបាន ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុ បំណុលនោះត្រូវវាស់វែងតាមតម្លៃយោងនៃទ្រព្យសកម្មដែលត្រូវបែងចែក។ ប្រសិនបើមុនពេលទូទាត់ តម្លៃសមស្របនៃទ្រព្យសកម្មដែលត្រូវបែងចែកអាចវាស់វែងគួរឱ្យទុកចិត្តបាន ដោយ គ្មានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុ បំណុលនោះត្រូវវាស់វែងឡើងវិញតាមតម្លៃសមស្រប រួមជាមួយ ការធ្វើនិយ័តកម្មស្របគ្នាលើចំនួននៃការបែងចែក និងធ្វើគណនេយ្យកម្មអនុលោមតាមកថាខណ្ឌ ២២.១៨។

២២.១៨ខ កថាខណ្ឌ២២.១៨-២២.១៨ក មិនអនុវត្តចំពោះការបែងចែកទ្រព្យសកម្មមិនមែនសាច់ប្រាក់ ដែលត្រូវបានគ្រប់គ្រងជាចុងក្រោយដោយភាគីតែមួយ ឬក្រុមភាគីតែមួយមុន និងក្រោយការបែងចែកទេ។ ការផាត់ចេញនេះអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុដោយឡែក រៀងខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់អង្គភាពដែលធ្វើការបែងចែកនោះ។

## ភាគកម្មមិនគ្រប់គ្រង និងប្រតិបត្តិការជាភាគហ៊ុននៃក្រុមហ៊ុនបុត្រសម្ព័ន្ធរួម

២២.១៩ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ភាគកម្មមិនគ្រប់គ្រងនៅក្នុងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធគឺត្រូវបានបញ្ចូលទៅក្នុងមូលធន។ អង្គភាពមួយត្រូវទទួលស្គាល់ការប្រែប្រួលនៅក្នុងភាគកម្មគ្រប់គ្រងរបស់ក្រុមហ៊ុនមេនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនបង្កើតមានការខាតបាត់បង់ការគ្រប់គ្រងជាប្រតិបត្តិការជាមួយម្ចាស់ក្នុងតួនាទីរបស់ពួកគេជាម្ចាស់។ ដូច្នេះតម្លៃយោងនៃភាគកម្មមិនគ្រប់គ្រងត្រូវធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួល ក្នុងភាគកម្មរបស់ក្រុមហ៊ុនមេនៅក្នុងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ។ លម្អៀងរវាងចំនួនដែលភាគកម្ម មិនគ្រប់គ្រងត្រូវបានធ្វើនិយ័តកម្ម និងតម្លៃសមស្របនៃតម្លៃតបស្នងដែលបង់ ឬទទួលត្រូវទទួលស្គាល់ដោយ ផ្ទាល់នៅក្នុងមូលធន និងបែងចែកទៅឱ្យម្ចាស់របស់ក្រុមហ៊ុនមេ។ អង្គភាពមិនត្រូវទទួលស្គាល់ចំណេញ ឬខាត លើការប្រែប្រួលទាំងនេះឡើយ។ ជាមួយគ្នានេះ អង្គភាពក៏មិនត្រូវទទួលស្គាល់ការប្រែប្រួលណាមួយនៅក្នុង តម្លៃយោងនៃទ្រព្យសកម្ម (រួមបញ្ចូលទាំងកេរ្តិ៍ឈ្មោះអាជីវកម្ម) ឬបំណុលដែលកើតចេញពីប្រតិបត្តិការបែបនេះ។

## ការលាតត្រដាង

២២.២០ ប្រសិនបើតម្លៃសមស្របនៃទ្រព្យសកម្មដែលត្រូវបែងចែកដូចបានពិពណ៌នាក្នុងកថាខណ្ឌ ២២.១៨-២២.១៨ក មិនអាចវាស់វែងគួរឱ្យទុកចិត្តបានដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុ អង្គភាពត្រូវលាតត្រដាងអង្គហេតុនោះ និងមូលហេតុបង្ហាញថាការវាស់វែងតម្លៃសមស្របគួរឱ្យទុកចិត្តនឹងនាំឱ្យការមានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុ។

# ឧបសម្ព័ន្ធនៃផ្នែកទី ២២
# ឧទាហរណ៍នៃគណនេយ្យកម្មរបស់អ្នកបោះផ្សាយ សម្រាប់បំណុលដែលអាចបំប្លែងបាន

ឧបសម្ព័ន្ធនេះ អមជាមួយផ្នែកទី២២ ប៉ុន្តែមិនមែនជាចំណែកនៃផ្នែកទី២២ទេ។ ឧបសម្ព័ន្ធនេះ ផ្តល់នូវការណែនាំសម្រាប់ ការអនុវត្តការតម្រូវនៃកថាខណ្ឌ២២.១៣–២២.១៥។

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០X៥ អង្គភាពមួយបោះផ្សាយសញ្ញាប័ណ្ណដែលអាចបំប្លែងបានចំនួន៥០០ សន្លឹក។ សញ្ញាប័ណ្ណទាំងនេះ ត្រូវបានបោះផ្សាយក្នុងតម្លៃស្មើនឹងតម្លៃលើប័ណ្ណ ជាមួយនឹងតម្លៃលើប័ណ្ណ ១០០ឯកតារូបិយប័ណ្ណក្នុងសញ្ញាប័ណ្ណមួយសន្លឹក និងមានកាលកំណត់ប្រាំឆ្នាំ ដោយគ្មានថ្លៃប្រតិបត្តិការ។ ចំនួនទឹកប្រាក់សរុបដែលរកបានពីការបោះផ្សាយ នេះគឺ៥០០០០ឯកតារូបិយប័ណ្ណ។ ការប្រាក់ត្រូវបង់ប្រចាំឆ្នាំនៅចុងគ្រា ក្នុងអត្រាការប្រាក់៤ ភាគរយ ក្នុង១ឆ្នាំ។ សញ្ញាប័ណ្ណនីមួយៗ អាចបំប្លែងបាន ជា២៥ ហ៊ុនភាគហ៊ុនធម្មតា តាមឆន្ទានុសិទ្ធិរបស់អ្នកកាន់ នៅពេលណាក៏បាន រហូតដល់កាលកំណត់ត្រូវសង។ នៅពេលដែលសញ្ញាប័ណ្ណត្រូវបានបោះផ្សាយ អត្រាការប្រាក់ទីផ្សារសម្រាប់បំណុលស្រដៀងគ្នា ដែលគ្មានសិទ្ធិជ្រើសរើសក្នុងការបំប្លែង គឺ៦ ភាគរយ។

នៅពេលដែលឧបករណ៍ត្រូវបានបោះផ្សាយ សមាសធាតុបំណុលត្រូវតែកំណត់តម្លៃជាមុន ហើយភាពខុសគ្នារវាងចំនួនទឹកប្រាក់សរុបដែលរកបានលើការបោះផ្សាយ (ដែលជាតម្លៃសមស្របរបស់ឧបករណ៍ ទាំងមូល) និងតម្លៃសមស្របរបស់សមាសធាតុបំណុលនោះ ត្រូវបានបែងចែកទៅឱ្យសមាសធាតុមូលធន។ តម្លៃសមស្របរបស់សមាសធាតុបំណុល ត្រូវបានគណនាដោយការកំណត់តម្លៃបច្ចុប្បន្នរបស់វា ដោយប្រើអត្រាអប្បហារ៦ ភាគរយ។ ការគណនា និងការចុះលេខទិនានុប្បវត្តិទាំងនេះ ត្រូវបានបកស្រាយបំភ្លឺះ

| | ឯកតារូបិយប័ណ្ណ |
|---|---|
| ចំនួនទឹកប្រាក់ដែលរកបានពីការបោះផ្សាយសញ្ញាប័ណ្ណ (ក) | ៥០,០០០ |
| តម្លៃបច្ចុប្បន្ននៃប្រាក់ដើមនៅដំណាច់ពេលប្រាំឆ្នាំ (សូមមើលការគណនា) | ៣៧,៣៦៣ |
| តម្លៃបច្ចុប្បន្ននៃការប្រាក់ដែលត្រូវបង់ប្រចាំឆ្នាំនៅចុងគ្រាសម្រាប់ប្រាំឆ្នាំ | ៨,៤២៥ |
| តម្លៃបច្ចុប្បន្ននៃបំណុល ដែលជាតម្លៃសមស្របនៃសមាសធាតុបំណុល (ខ) | ៤៥,៧៨៨ |
| សំណល់ ដែលជាតម្លៃសមស្របនៃសមាសធាតុមូលធន (ក) – (ខ) | ៤,២១២ |

អ្នកបោះផ្សាយសញ្ញាប័ណ្ណធ្វើការចុះលេខទិនានុប្បវត្តខាងក្រោម នៅពេលបោះផ្សាយ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០X៥ះ

| | | |
|---|---|---|
| ឥណពន្ធ សាច់ប្រាក់ | ៥០,០០០ ឯកតារូបិយប័ណ្ណ | |
| ឥណទាន បំណុលហិរញ្ញវត្ថុ - សញ្ញាប័ណ្ណអាចបំប្លែងបាន | | ៤៥,៧៨៨ ឯកតារូបិយប័ណ្ណ |
| ឥណទាន មូលធន | | ៤,២១២ ឯកតារូបិយប័ណ្ណ |

តំណាងឱ្យអប្បហារនៅពេលបោះផ្សាយសញ្ញាប័ណ្ណ ដូច្នេះការចុះលេខ ក៏អាចបង្ហាញជា 'ដុល' ដែរ៖

| | | |
|---|---|---|
| ឥណពន្ធ សាច់ប្រាក់ | ៥០,០០០ ឯកតារូបិយប័ណ្ណ | |
| ឥណពន្ធ អប្បហារសញ្ញាប័ណ្ណ | ៤,២១២ ឯកតារូបិយប័ណ្ណ | |
| ឥណទាន បំណុលហិរញ្ញវត្ថុ - សញ្ញាប័ណ្ណអាចបំប្លែងបាន | | ៥០,០០០ ឯកតារូបិយប័ណ្ណ |
| ឥណទាន មូលធន | | ៤,២១២ ឯកតារូបិយប័ណ្ណ |

ក្រោយការបោះផ្សាយ អ្នកបោះផ្សាយនឹងរំលស់អប្បហារសញ្ញាប័ណ្ណ ស្របតាមតារាងខាងក្រោម៖

| | (ក) ការបង់ការប្រាក់ (ឯកតារូបិយប័ណ្ណ) | (ខ) ចំណាយការប្រាក់សរុប (ឯកតារូបិយប័ណ្ណ) = ៦% x (ង) | (គ) រំលស់នៃអប្បហារសញ្ញាប័ណ្ណ (ឯកតារូបិយប័ណ្ណ) = (ខ) - (ក) | (ឃ) អប្បហារសញ្ញាប័ណ្ណ (ឯកតារូបិយ ប័ណ្ណ) = (ឃ) - (គ) | (ង) បំណុលសុទ្ធ (ឯកតារូបិយប័ណ្ណ) = ៥០,០០០ - (ឃ) |
|---|---|---|---|---|---|
| ១/១/២០X៥ | | | | ៤,២១២ | ៤៥,៧៨៨ |
| ៣១/១២/២០X៥ | ២,០០០ | ២,៧៤៧ | ៧៤៧ | ៣,៤៦៥ | ៤៦,៥៣៥ |
| ៣១/១២/២០X៦ | ២,០០០ | ២,៧៩២ | ៧៩២ | ២,៦៧៣ | ៤៧,៣២៧ |
| ៣១/១២/២០X៧ | ២,០០០ | ២,៨៤០ | ៨៤០ | ១,៨៣៣ | ៤៨,១៦៧ |
| ៣១/១២/២០X៨ | ២,០០០ | ២,៨៩០ | ៨៩០ | ៩៤៣ | ៤៩,០៥៧ |
| ៣១/១២/២០X៩ | ២,០០០ | ២,៩៤៣ | ៩៤៣ | ០ | ៥០,០០០ |
| សរុប | ១០,០០០ | ១៤,២១២ | | ៤,២១២ | |

នៅដំណាច់ឆ្នាំ ២០X៥ អ្នកបោះផ្សាយនឹងធ្វើការចុះលេខទិនានុប្បវត្តចខាងក្រោម៖

| | | |
|---|---|---|
| ឥណពន្ធ ចំណាយការប្រាក់ | ២,៧៤៧ ឯកតារូបិយប័ណ្ណ | |
| ឥណទាន អប្បហារសញ្ញាប័ណ្ណ | | ៧៤៧ ឯកតារូបិយប័ណ្ណ |
| ឥណទាន សាច់ប្រាក់ | | ២,០០០ ឯកតារូបិយប័ណ្ណ |

## ការគណនា

តម្លៃបច្ចុប្បន្ននៃប្រាក់ដើម ៥០,០០០ ឯកតារូបិយប័ណ្ណ ក្នុងអត្រា ៦ ភាគរយ

៥០,០០០ ឯកតារូបិយប័ណ្ណ / (១.០៦)^៥ = ៣៧,៣៦៣ ឯកតារូបិយប័ណ្ណ

តម្លៃបច្ចុប្បន្ននៃធនលាភការប្រាក់ ២,០០០ ឯកតារូបិយប័ណ្ណ (= ៥០,០០០ ឯកតារូបិយប័ណ្ណ x ៤ ភាគរយ) ត្រូវសងនៅដំណាច់ឆ្នាំនីមួយៗ នៃរយៈពេលប្រាំឆ្នាំ

ការបង់ការប្រាក់ប្រចាំឆ្នាំនូវ ២០០០ ឯកតារូបិយប័ណ្ណ គឺជាធនលាភមួយប្រភេទ-ចរន្តលំហូរសាច់ប្រាក់ជាមួយនឹងចំនួនមានកម្រិត (n) នៃការបង់ប្រាក់តាមកាលកំណត់ (C) ត្រូវទទួលបាននៅកាលបរិច្ឆេទពី១ ដល់ n។ ដើម្បីគណនាតម្លៃបច្ចុប្បន្ននៃ ធនលាភនេះ ការបង់ប្រាក់អនាគតត្រូវបានធ្វើអប្បហារដោយអត្រាការប្រាក់តាមកាលកំណត់ (i) ដោយប្រើ រូបមន្តខាងក្រោម៖

$$PV = \frac{C}{i} \times [1 - \frac{1}{(1+i)^n}]$$

ដូច្នេះ តម្លៃបច្ចុប្បន្ននៃការបង់ការប្រាក់ ២០០០ ឯកតារូបិយប័ណ្ណ គឺស្មើនឹង

(២,០០០/.០៦) x [១ x [(១/១.០៦)^៥] = ៨,៤២៥ ឯកតារូបិយប័ណ្ណ

នេះសមមូលនឹងចំនួនសរុបនៃតម្លៃបច្ចុប្បន្ននៃការបង់ប្រាក់ ២០០០ ឯកតារូបិយប័ណ្ណ ប្រាំលើកដោយឡែកៗពីគ្នា ដូចខាងក្រោម៖

| | ឯកតារូបិយប័ណ្ណ |
|---|---|
| តម្លៃបច្ចុប្បន្ននៃការបង់ការប្រាក់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៥ = ២០០០/១,០៦ | ១,៨៨៧ |
| តម្លៃបច្ចុប្បន្ននៃការបង់ការប្រាក់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៦ = ២០០០/១,០៦^២ | ១,៧៨០ |
| តម្លៃបច្ចុប្បន្ននៃការបង់ការប្រាក់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៧ = ២០០០/១,០៦^៣ | ១,៦៧៩ |
| តម្លៃបច្ចុប្បន្ននៃការបង់ការប្រាក់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៨ = ២០០០/១,០៦^៤ | ១,៥៨៤ |
| តម្លៃបច្ចុប្បន្ននៃការបង់ការប្រាក់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៩ = ២០០០/១,០៦^៥ | ១,៤៩៥ |
| សរុប | ៨,៤២៥ |

វិធីមួយទៀត ក្នុងការគណនានេះ គឺការប្រើតារាងតម្លៃបច្ចុប្បន្ននៃធនលាភជម្មតានៅចុងគ្រា ប្រាំគ្រា អត្រាការប្រាក់ ៦ភាគរយក្នុងមួយគ្រា។ (តារាងទាំងនោះងាយរកបានតាមអ៊ិនធើណិត)។ កត្តាតម្លៃបច្ចុប្បន្ន គឺ៤.២១២៤។ ដោយគុណចំនួននេះនឹង ការបង់ធនលាភ ២,០០០ ឯកតារូបិយប័ណ្ណ កំណត់នូវតម្លៃបច្ចុប្បន្នរបស់៨,៤២៥ ឯកតារូបិយប័ណ្ណ។

# ផ្នែកទី ២៣
# ចំណូល

## វិសាលភាពនៃផ្នែកនេះ

២៣.១ ផ្នែកនេះត្រូវអនុវត្តក្នុងគណនេយ្យកម្មសម្រាប់ចំណូលដែលកើតឡើងពីប្រតិបត្តិការនិងព្រឹត្តិការណ៍ដូចខាងក្រោម:

(ក) ការលក់ទំនិញ( មិនថាបានផលិតដោយអង្គភាពសម្រាប់គោលបំណងនៃការលក់ឬ ទិញសម្រាប់លក់ វិញ)

(ខ) ការផ្តល់សេវាកម្ម

(គ) កិច្ចសន្យាសាងសង់ដែលអង្គភាពជាអ្នកទទួលម៉ៅការសាងសង់

(ឃ) ការប្រើទ្រព្យសកម្មរបស់អង្គភាពដោយភាគីផ្សេងទៀតដែលផ្តល់ការប្រាក់ សួយសារអាករឬ ភាគលាភ។

២៣.២ ចំណូលឬចំណូលផ្សេងទៀតដែលកើតចេញពីប្រតិបត្តិការនិងព្រឹត្តិការណ៍ខ្លះទៀត ត្រូវបានដោះស្រាយនៅក្នុងផ្នែកផ្សេងទៀតនៃស្តង់ដារនេះ

(ក) កិច្ចព្រមព្រៀងភតិសន្យា (សូមមើលផ្នែកទី២០ ភតិសន្យា)

(ខ) ភាគលាភនិងចំណូលផ្សេងទៀតកើតចេញពីការវិនិយោគដែលត្រូវធ្វើគណនេយ្យកម្មដោយវិធីសាស្ត្រមូលធន ( សូមមើលផ្នែកទី១៤ ការវិនិយោគក្នុង ក្រុមហ៊ុនញាតិសម្ព័ន្ធនិង ផ្នែកទី១៥ ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន)។

(គ) ការប្រែប្រួលនៅក្នុងតម្លៃសមស្របនៃ ទ្រព្យសកម្មហិរញ្ញវត្ថុនិង បំណុលហិរញ្ញវត្ថុ ឬ ពីការលក់របស់ពួកគេ (សូមមើលផ្នែកទី ១១ ឧបករណ៍ហិរញ្ញវត្ថុសាមញ្ញនិង ផ្នែកទី១២ ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុ)។

(ឃ) ការប្រែប្រួលនៅក្នុងតម្លៃសមស្របនៃទ្រព្យវិនិយោគ( សូមមើលផ្នែកទី១៦ ទ្រព្យវិនិយោគ)

(ង) ការទទួលស្គាល់ដំបូង និងការប្រែប្រួលនៅក្នុងតម្លៃសមស្របនៃទ្រព្យសកម្មជីវសាស្ត្រ ដែលទាក់ទងនឹងសកម្មភាពកសិកម្ម( សូមមើលផ្នែកទី៣៤ សកម្មភាពឯកទេស ) ហើយ

(ច) ការទទួលស្គាល់ដំបូង នៃផលិតផលកសិកម្ម (សូមមើលផ្នែកទី៣៤)។

## ការវាស់វែងចំណូល

២៣.៣ អង្គភាពត្រូវវាស់វែងចំណូលតាមតម្លៃសមស្របនៃតម្លៃតបស្នងដែលទទួលបាន ឬនឹងត្រូវទទួល។ តម្លៃសមស្របនៃតម្លៃតបស្នងដែលទទួលបាន ឬនឹងត្រូវទទួល ត្រូវគិតពីចំនួនទឹកប្រាក់នៃអប្បហារ អប្បហារពីការទូទាត់ភ្លាមនិងប្រាក់សងវិញតាមទំហំដែលអនុញ្ញាតដោយអង្គភាព។

២៣.៤ អង្គភាពត្រូវបញ្ចូលនៅក្នុងចំណូលតែលំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលទទួលបាននិងនឹងត្រូវទទួលដោយអង្គភាពក្នុងគណនីកម្មសិទ្ធរបស់ខ្លួន។ អង្គភាពត្រូវដកចេញនូវចំនួនទឹកប្រាក់ទាំងអស់ដែលប្រមូលបានក្នុងនាមភាគីទីពពីចំណូល ដូចជាពន្ធលក់ ពន្ធលើទំនិញនិងសេវា និងអាករលើតម្លៃបន្ថែម។ ចំពោះទំនាក់ទំនងភ្នាក់ងារ អង្គភាព (ជាភ្នាក់ងារ) ត្រូវបញ្ចូលក្នុងចំណូលតែចំនួនកំរៃជើងសារ។ ចំនួនទឹកប្រាក់ដែលបានប្រមូលក្នុងនាមម្ចាស់ភាគហ៊ុនមិនមែនជាចំណូលរបស់អង្គភាពទេ។

## ការទូទាត់សងពន្យារ

២៣.៥ នៅពេលលំហូរចូលសាច់ប្រាក់ឬសាច់ប្រាក់សមមូលត្រូវបានពន្យារ ហើយកិច្ចព្រមព្រៀងចូលជាធរមានបានចូលរួមឱ្យមានប្រតិបត្តិការហិរញ្ញប្បទាន តម្លៃសមស្របនៃតម្លៃតបស្នងគឺជាតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់អនាគតទាំងអស់ដែលបានកំណត់ដោយប្រើអត្រាការប្រាក់ជាប់បន្ទុក។ ឧទាហរណ៍ ប្រតិបត្តិការហិរញ្ញប្បទាន កើតឡើងនៅពេលអង្គភាពផ្តល់ឥណទានគ្មានការប្រាក់ទៅឱ្យអ្នកទិញ ឬ ទទួលយកប័ណ្ណត្រូវទទួល ដែលមានអត្រាការប្រាក់ទាបជាងទីផ្សារពីអ្នកទិញជាតម្លៃតបស្នងសម្រាប់ការលក់ទំនិញ។ អត្រាការប្រាក់ជាប់បន្ទុកត្រូវបានកំណត់យ៉ាងច្បាស់ នៃៈ

(ក) អត្រាទូទៅសម្រាប់ឧបករណ៍ស្រដៀងគ្នារបស់អ្នកបោះផ្សាយដែលមានចំណាត់ថ្នាក់ឥណទានស្រដៀងគ្នា ឬ

(ខ) អត្រាការប្រាក់ដែលអប្បបហារពីតម្លៃធម្មតារបស់ឧបករណ៍ទៅជាតម្លៃលក់បានជាសាច់ប្រាក់នៃទំនិញ ឬ សេវាកម្ម។

អង្គភាពត្រូវទទួលស្គាល់ភាពខុសគ្នារវាងតម្លៃបច្ចុប្បន្ននៃប្រាក់ទទួលនៅអនាគតទាំងអស់ និងតម្លៃធម្មតា នៃតម្លៃតបស្នង ជាចំណូលការប្រាក់ដោយអនុលោមតាមកថាខណ្ឌ ២៣.២៨ និង ២៣.២៩ និងផ្នែកទី១១។

## ការដោះដូរទំនិញ ឬសេវាកម្ម

២៣.៦ អង្គភាពមិនត្រូវទទួលស្គាល់ចំណូលៈ

(ក) នៅពេលទំនិញឬសេវាត្រូវបានដោះដូរសម្រាប់ទំនិញឬសេវាដែលមានលក្ខណៈ និងតម្លៃស្រដៀងគ្នា ឬ

(ខ) នៅពេលទំនិញ ឬ សេវាកម្មត្រូវបានដោះដូរសម្រាប់ទំនិញ ឬសេវាកម្មមិនស្រដៀងគ្នា ប៉ុន្តែប្រតិបត្តិការនោះខ្វះស្ថានភាពជាលក្ខណៈពាណិជ្ជកម្ម។

២៣.៧ អង្គភាពត្រូវទទួលស្គាល់ចំណូល នៅពេលទំនិញត្រូវបានលក់ឬសេវាកម្មត្រូវបានដោះដូរសម្រាប់ទំនិញឬសេវាកម្មមិនស្រដៀងគ្នា ក្នុងប្រតិបត្តិការដែលមានស្ថានភាពជាលក្ខណៈពាណិជ្ជកម្ម។នៅក្នុងករណីនោះអង្គភាពត្រូវវាស់វែងប្រតិបត្តិការនោះតាមៈ

(ក) តម្លៃសមស្របនៃទំនិញឬសេវាកម្មដែលបានទទួលជាមួយនិងការ កែសម្រួលតាមសាច់ប្រាក់ឬសាច់ប្រាក់សមមូលណាមួយដែលបានផ្ទេរ ឬ

(ខ) ប្រសិនបើចំនួនទឹកប្រាក់ក្រោមលក្ខខណ្ឌ (ក) មិនអាចត្រូវបានវាស់វែងដោយជឿជាក់ ដូច្នេះត្រូវតាមតម្លៃសមស្របនៃទំនិញ ឬសេវាកម្មដែលបានលះបង់ត្រូវបានកែសម្រួលដោយសាច់ប្រាក់ ឬសាច់ប្រាក់សមមូលដែលបានផ្ទេរឬ

(គ) ប្រសិនបើគ្មានតម្លៃសមស្របសម្រាប់ទាំងទំនិញ ឬសេវាកម្មដែលបានទទួល ឬ ទំនិញ និងសេវាកម្ម ត្រូវលះបង់ចោលមិនអាចត្រូវ បានវាស់វែងដោយជឿជាក់ ដូច្នេះតាមតម្លៃយោង នៃ ទំនិញ ឬសេវាកម្ម ដែលបានលះបង់ត្រូវកែសម្រួលដោយចំនួននៃសាច់ប្រាក់ ឬសាច់ប្រាក់សមមូលដែលបានផ្ទេរ។


CamEd Business School

## ការធ្វើអត្តសញ្ញាណនៃប្រតិបត្តិការចំណូល

២៣.៨ អង្គភាព ជាធម្មតា អនុវត្តតាមលក្ខណៈ វិនិច្ឆ័យទទួលស្គាល់ចំណូលនៅក្នុងផ្នែកនេះដាច់ដោយឡែកចំពោះប្រតិបត្តិការនីមួយៗ។ ប៉ុន្តែ អង្គភាពត្រូវអនុវត្តតាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់ចំពោះសមាសធាតុដែលអាចកំណត់បានដោយឡែកនៃប្រតិបត្តិការទោល នៅពេលចាំបាច់ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពពិតនៃប្រតិបត្តិការនោះ។ ឧទាហរណ៍ អង្គភាពអនុវត្តតាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់ចំពោះសមាសធាតុដែលអាច កំណត់បាននៃប្រតិបត្តិការទោល ពេលតម្លៃលក់នៃផលិតផល រួមបញ្ចូលចំនួនទឹកប្រាក់ដែលអាចកំណត់បានសម្រាប់ការផ្តល់សេវាកម្មពេលក្រោយ។ ផ្ទុយទៅវិញ អង្គភាពត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យទទួលស្គាល់ចំពោះប្រតិបត្តិការពីរ ឬច្រើនជាមួយគ្នា នៅពេលដែលប្រតិបត្តការទាំងនោះបាន ភ្ជាប់ជាមួយគ្នាក្នុងកត្តាមួយដែល ពាណិជ្ជកម្ម មិនអាចយល់បានដោយគ្មានការយោងពីស៊េរីប្រតិបត្តិការអស់ ជាលក្ខណៈទាំងមូល។ ឧទាហរណ៍ថា អង្គភាពត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យទទួលស្គាល់ចំពោះប្រតិបត្តិការពីរឬច្រើនជាមួយគ្នា ហើយនៅពេលជាមួយគ្នា នោះអង្គភាពបានចុះកិច្ចព្រមព្រៀងដោយឡែកដើម្បីទិញមកវិញនូវទំនិញនោះនៅថ្ងៃក្រោយ ដូច្នេះត្រូវវាលុបចោលនូវផលប៉ះពាល់ជាដុំកំភួននៃប្រតិបត្តិការនោះ។

២៣.៩ ពេលខ្លះ ជាផ្នែកមួយនៃប្រតិបត្តិការលក់ អង្គភាពផ្តល់ឱ្យអតិថិជនរបស់ខ្លួននូវរង្វាន់ពីភាពស្មោះត្រង់ ហើយអតិថិជនអាចផ្លាស់ប្តូរយក ការបញ្ចុះតម្លៃ ចំពោះទំនិញឬសេវា ឬដោយឥតគិតថ្លៃ នៅពេលអនាគត។ ក្នុងករណីនេះ ដោយអនុលោមតាមកថាខណ្ឌ២៣.៨ អង្គភាពត្រូវធ្វើគណនេយ្យកម្មលើឥណទានជា រង្វាន់ ជាសមាសធាតុដែលអាចកំណត់ដាច់ដោយឡែកបានលើប្រតិបត្តិការលក់ដំបូង។អង្គភាពត្រូវបែងចែកតម្លៃសមស្របនៃតម្លៃតបស្នង ដែលបានទទួល ឬ នឹងត្រូវទទួលទាក់ទងនឹងការលក់ដំបូងរវាងឥណទានរង្វាន់ និង សមាសធាតុលក់ផ្សេងទៀត។ តម្លៃតបស្នងដែលបានបែងចែកទៅឱ្យ ឥណទានជារង្វាន់ ត្រូវវាស់វែងដោយយោងទៅលើតម្លៃសមស្រប ពោលគឺចំនួនទឹកប្រាក់ដែលឥណទានជារង្វាន់អាចត្រូវបានលក់ដាច់ដោយឡែក។

## ការលក់ទំនិញ

២៣.១០ អង្គភាព ត្រូវទទួលស្គាល់ចំណូលពីការលក់ទំនិញ នៅពេលលក្ខខណ្ឌទាំងអស់ដូចខាងក្រោមត្រូវបានបំពេញៈ

(ក) អង្គភាពបានផ្ទេរទៅឱ្យអ្នកទិញនូវហានិភ័យនិងផលប្រយោជន៍សំខាន់ៗនៃកម្មសិទ្ធិ លើទំនិញ

(ខ) អង្គភាពមិនរក្សានូវការជាប់ពាក់ព័ន្ធលើការគ្រប់គ្រងបន្តក្នុងកម្រិតណាមួយដែលជាធម្មតាទាក់ទងនឹងកម្មសិទ្ធិ ឬ មិនមានការគ្រប់គ្រងជាធរមានលើទំនិញដែលបានលក់ទៀតទេ។

(គ) ចំនួនទឹកប្រាក់ចនៃចំណូលអាចវាស់វែងបានដោយជឿជាក់

(ឃ) វាប្រហែលថា អត្ថប្រយោជន៍សេដ្ឋកិច្ចដែលទាក់ទងនឹងប្រតិបត្តិការនឹងហូរមកកាន់អង្គភាព

(ង) ថ្លៃដើមដែលបានកើតឡើង ឬ នឹងកើតឡើងទាក់ទងនឹងប្រតិបត្តិការអាចវាស់វែងដោយជឿជាក់។

២៣.១១ ការវាយតម្លៃនៃពេល ដែលអង្គភាពមួយបានផ្ទេរ នូវហានិភ័យសំខាន់ៗនិងផលប្រយោជន៍នៃកម្មសិទ្ធិទៅឱ្យអ្នកទិញតម្រូវឱ្យមានការត្រួតពិនិត្យនៃស្ថានភាពរបស់ប្រតិបត្តិការនោះ។ នៅក្នុងករណីភាគច្រើន ការផ្ទេរហានិភ័យនិងផលប្រយោជន៍នៃកម្មសិទ្ធិកើតឡើងព្រមគ្នាជាមួយនឹងការផ្ទេរសិទ្ធិស្របច្បាប់ ឬ ការផ្ទេរការកាន់កាប់ទៅឱ្យអ្នកទិញ។ នេះជាករណីភាគច្រើនសម្រាប់ការលក់រាយ។ នៅក្នុងករណីផ្សេងទៀត ការផ្ទេរហានិភ័យនិងផលប្រយោជន៍នៃកម្មសិទ្ធិកើតមានឡើងនៅពេលខុសគ្នាពីការផ្ទេរនូវកម្មសិទ្ធិស្របច្បាប់ ឬ ការផ្ទេរការកាន់កាប់។

២៣.១២ អង្គភាពមិនទទួលស្គាល់ចំណូលទេ ប្រសិនអង្គភាពនៅរក្សា ហានិភ័យសំខាន់ៗនិងផលប្រយោជន៍នៃកម្មសិទ្ធិ។ ឧទាហរណ៍នៅ ក្នុងករណីដែលអង្គភាពអាចរក្សាហានិភ័យនិងប្រយោជន៍សំខាន់ៗនៃកម្មសិទ្ធិ មាន

(ក) នៅពេលដែលអង្គភាពរក្សាកាតព្វកិច្ចសម្រាប់ការងារដែលបំពេញមិនគ្រប់លក្ខណះ ដែលមិនត្រូវបានគ្រប់ដណ្តប់ដោយការធានាជាធម្មតា

(ខ) នៅពេលដែលការទទួលប្រាក់ចំណូលពី ការលក់មួយដែលមានលក្ខណ:យថាហេតុ លើរបស់អ្នកទិញទំនិញ

(គ) នៅពេលដែលទំនិញត្រូវបានដឹកជញ្ជូនដែលមានកម្មវត្ថុត្រូវតំឡើង ហើយការតំឡើងនោះគឺជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងដែលមិនទាន់បានបំពេញចប់នៅឡើយ។ ហើយ

(ឃ) នៅពេលដែលអ្នកទិញមានសិទ្ធិចាត់ទុកជាមោឃ:នូវការទិញក្នុងហេតុផលដែលបានចែងនៅក្នុងកិច្ចសន្យា ឬតាមការសម្រេចជាឯកតោភាគីរបស់អ្នកទិញដោយគ្មានហេតុផលឡើយ ហើយអង្គភាពមិនប្រាកដអំពីភាវនីយភាពនៃបង្វិលទំនិញមកវិញ។

២៣.១៣ ប្រសិនបើអង្គភាពរក្សាទុកតែហានិភ័យនៃកម្មសិទ្ធិមិនសំខាន់ ប្រតិបត្តិការនោះគឺជាការលក់ ហើយអង្គភាពត្រូវទទួលស្គាល់ចំណូល។ ឧទាហរណ៍ អ្នកលក់ទទួលស្គាល់ចំណូលពេលអង្គភាពរក្សា នូវកម្មសិទ្ធិស្របច្បាប់ចំពោះទំនិញក្នុងបំណងមួយ គឺដើម្បីការពារការប្រមូលប្រាក់ដែលនៅជំពាក់។ ស្រដៀងគ្នានេះ អង្គភាពត្រូវទទួលស្គាល់ចំណូលនៅពេលអង្គភាពផ្តល់ឱ្យមានការបង្វិលប្រាក់វិញ ប្រសិនបើអតិថិជនរកឃើញថាទំនិញបានខូចឬមិនគ្រប់លក្ខណះ ក្នុងហេតុផលផ្សេងៗ ហើយអង្គភាពអាចប៉ាន់ស្មានពីការបង្វិលទំនិញមកវិញដោយជឿជាក់។ នៅក្នុងករណីបែបនេះ អង្គភាពទទួលស្គាល់សំវិធានធនសម្រាប់បង្វិលទំនិញមកវិញ ដោយអនុលោមតាមផ្នែកទី២១ សំវិធានធន និង យថាហេតុ។

## ការផ្តល់សេវាកម្ម

២៣.១៤ ពេលលទ្ធផលនៃប្រតិបត្តិការពាក់ព័ន្ធនឹងការផ្តល់សេវាកម្មអាចត្រូវប៉ាន់ស្មានបានដោយជឿជាក់ អង្គភាពត្រូវទទួលស្គាល់ចំណូលដែលទាក់ទងនឹងប្រតិបត្តិការនោះ ដោយយោងតាមការបញ្ចប់ការងារជាដំណាក់កាលនៃប្រតិបត្តិការនៅចុងការិយបរិច្ឆេទរាយការណ៍( ជួនកាលគេសំដៅថាជាវិធីសាស្រ្តបញ្ចប់ការងារតាមភាគរយ)។លទ្ធផលនៃប្រតិបត្តិការមួយអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់បាន នៅពេលលក្ខខណ្ឌខាងក្រោមទាំងអស់ត្រូវបានបំពេញ:

(ក) ចំនួនទឹកប្រាក់អាចវាវែងដោយជឿជាក់

(ខ) វាប្រហែលថាអត្ថប្រយោជន៍សេដ្ឋកិច្ចទាក់ទងនឹងប្រតិបត្តិការនឹងហូរចូលមកកាន់អង្គភាព។

(គ) ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការនៅចុងការិយបរិច្ឆេទរាយការណ៍អាចវាស់វែងដោយជឿជាក់

(ឃ) ចំណាយដែលបានកើតឡើងចំពោះប្រតិបត្តិការ និងចំណាយដើម្បីបញ្ចប់ប្រតិបត្តិការ អាចវាស់វែងបានដោយជឿជាក់។កថាខណ្ឌ២៣. ២១-២៣. ២៧ ផ្តល់ការណែនាំសម្រាប់ការអនុវត្តវិធីសាស្រ្តបញ្ចប់ភាគរយ។

២៣.១៥ ពេលសេវាកម្មត្រូវបានបំពេញដោយចំនួនសកម្មគ្មានកំណត់លើគ្រាមជាក់លាក់ អង្គភាពត្រូវទទួលស្គាល់ចំណូលតាមមូលដ្ឋានថេរលើគ្រាជាក់លាក់នោះ លុះត្រាតែមានភ័ស្តុតាងដែលថាវិធីសាស្រ្តផ្សេងទៀត ដែលល្អប្រសើរសម្រាប់តំណាង វិធីសាស្រ្តដំណាក់កាលនៃការបញ្ចប់ការងារ។ នៅពេលសកម្មភាពជាក់លាក់ណាមួយ មានសារ:សំខាន់ច្រើនជាងសកម្មភាពផ្សេងទៀត អង្គភាពពន្យារពេលការទទួលស្គាល់ចំណូលរហូតដល់សកម្មភាពសំខាន់ត្រូវបានអនុវត្ត។

២៣.១៦ នៅពេលដែលលទ្ធផលនៃប្រតិបត្តិការទាក់ទិននឹងការផ្តល់សេវាកម្មមិនអាចប៉ាន់ស្មានបានដោយជឿជាក់អង្គភាពត្រូវទទួលស្គាល់ចំណូលតាមការចំណាយទាំងអស់ ដែលត្រូវបានទទួលស្គាល់ថានឹងអាចប្រមូលបានមកវិញ។

## កិច្ចសន្យាសាងសង់

២៣.១៧ នៅពេលដែលលទ្ធផលនៃកិច្ចសន្យាសាងសង់អាចត្រូវបានប៉ាន់ស្មានដោយជឿជាក់ អង្គភាពត្រូវទទួលស្គាល់ចំណូលពីកិច្ចសន្យា និង ចំណាយលើកិច្ចសន្យា ដែលទាក់ទងនឹងកិច្ចសន្យាសាងសង់ ជាចំណូលនិងចំណាយដោយអនុលោមតាមដំណាក់កាលនៃការបញ្ចប់តាមសកម្មភាពរបស់កិច្ចសន្យានៅចុងការិយបរិច្ឆេទរាយការណ៍(ជារឿយៗត្រូវបាន គេសំដៅថាជាវិធីសាស្ត្របញ្ចប់ការងារតាមភាគរយ)។ លទ្ធផល នៃការប៉ាន់ស្មាន ដែលអាចជឿជាក់បានទាមទារ ឱ្យមានការប៉ាន់ស្មានពីដំណាក់កាលនៃការបញ្ចប់ការងារ ចំណាយអនាគត និង ការប្រមូលប្រាក់។ ថាខណ្ឌ ២៣. ២១- ២៣. ២៧ ផ្តល់ការណែនាំពី ការអនុវត្តវិធីសាស្ត្របញ្ចប់តាមភាគរយ។

២៣.១៨ ការតម្រូវនៃផ្នែកនេះជាធម្មតាត្រូវបានអនុវត្តដាច់ដោយឡែក ចំពោះកិច្ចសន្យាសាងសង់នីមួយៗ។ ប៉ុន្តែនៅក្នុងស្ថានភាពមួយចំនួន វាចាំបាច់ត្រូវអនុវត្តផ្នែកនេះ ចំពោះសមាសធាតុដែលអាចកំណត់បានដាច់ដោយឡែកនៃកិច្ចសន្យាទោលឬ ក្រុមកិច្ចសន្យាជារួម ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពពិតនៃកិច្ចសន្យា ឬក្រុមកិច្ចសន្យា។

២៣.១៩ នៅពេលកិច្ចសន្យាគ្របដណ្តប់លើទ្រព្យសកម្មមួយចំនួន ការសាងសង់នៃទ្រព្យសកម្មនីមួយៗត្រូវបានទទួលស្គាល់ជាកិច្ចសន្យាដាច់ដោយឡែកនៅពេល:

(ក) សំណើដាច់ដោយឡែកត្រូវបានគេដាក់បញ្ជូនសម្រាប់ទ្រព្យសកម្មនីមួយៗ

(ខ) ទ្រព្យសកម្មនីមួយៗ មានកម្មវត្ថុនៃការចរចារដាច់ដោយឡែក ហើយ អ្នកម៉ៅការសាងសង់ និង អតិថិជនអាចទទួលយក ឬ បដិសេធលើផ្នែកនៃកិច្ចសន្យាដែលទាក់ទងនឹងទ្រព្យសកម្មនីមួយៗ និង

(គ) ចំណាយ និង ចំណូលនៃទ្រព្យសកម្មនីមួយអាចកំណត់បាន។

២៣.២០ ក្រុមនៃកិច្ចសន្យា មិនថាតែជាមួយអតិថិជនទោល ឬជាមួយអតិថិជនច្រើនត្រូវទទួលចាត់ទុកជាកិច្ចសន្យាសាងសង់ទោល ពេល:

(ក) ក្រុមកិច្ចសន្យាត្រូវបានចរចារជាកញ្ចប់តែមួយ

(ខ) ពេលចូលជាធរមាន កិច្ចសន្យាទាំងឡាយមានទំនាក់ទំនងគ្នាយ៉ាងចិត្តស្និត ដែលកិច្ចសន្យា ទាំងនោះគឺជាផ្នែកនៃគំរោងទោលមួយ ដែលមានប្រាក់ចំណេញរួម និង

(គ) កិច្ចសន្យាត្រូវបានបំពេញក្នុងពេលដំណាលគ្នា ឬ តាមលំដាប់លំដោយ។

## វិធីសាស្ត្រភាគរយនៃការបញ្ចប់ការងារ

២៣.២១ វិធីសាស្ត្រនេះត្រូវប្រើដើម្បីទទួលស្គាល់ចំណូលពីការផ្តល់សេវាកម្ម (សូមមើលកថាខណ្ឌ២៣.១៤-២៣.១៦) និងពីកិច្ចសន្យាសាងសង់ (សូមមើលកថាខណ្ឌ២៣.១៧-២.២០) ។ អង្គភាពមួយត្រូវពិនិត្យឡើងវិញ និងនៅពេលចាំបាច់ កែប្រែការប៉ាន់ស្មាននៃចំណូលនិងចំណាយរបស់ប្រតិបត្តិការសេវាកម្ម ឬកិច្ចសន្យាសាងសង់កំពុងដំណើរការ។

២៣.២២ អង្គភាពមួយត្រូវកំណត់ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការ ឬ កិច្ចសន្យាដោយប្រើវិធីសាស្រ្ត ដែលវាស់វែងការងារដែលបានបំពេញប្រកបដោយជឿជាក់បំផុត។ វិធីសាស្រ្តដែលអាចកើតឡើងរួមមាន:

(ក) សមាមាត្រដែលចំណាយបានកើតឡើង សម្រាប់ការងារដែលបានបំពេញត្រឹមថ្ងៃបរិច្ឆេទ តាមចំណាយប៉ាន់ស្មានសរុប។ ចំណាយដែលបានកើតឡើងសម្រាប់ការងារដែលបានអនុវត្តត្រឹមថ្ងៃបរិច្ឆេទមិនបញ្ចូលចំណាយទាក់ទងនឹងសកម្មភាពអនាគត ដូចជាវត្ថុធាតុដើម ឬ ការបង់មុន។

(ខ) ការស្ទាបស្ទង់នៃការងារដែលបានបំពេញ។

(គ) ការបញ្ចប់នៃសមាមាត្រជាក់ស្តែង នៃប្រតិបត្តិការសេវាកម្ម ឬ ការងារសាងសង់ ការទូទាត់ជាដំណាក់កាល និងបុរេប្រទានដែលបានទទួលពីអតិថិជនជារឿយៗមិនឆ្លុះបញ្ចាំងពីការងារ ដែលបានអនុវត្ត។

២៣.២៣ អង្គភាពត្រូវទទួលស្គាល់ចំណាយ ដែលទាក់ទងនឹងសកម្មភាពអនាគតលើប្រតិបត្តិការឬកិច្ចសន្យា ដូចជាសម្រាប់វត្ថុធាតុដើម ឬ ការបង់មុន ជាទ្រព្យសកម្ម ប្រសិនបើវាប្រហែលថាចំណាយនឹងត្រូវប្រមូលបានមកវិញ។

២៣.២៤ អង្គភាពត្រូវទទួលស្គាល់ជាចំណាយភ្លាមនូវថ្លៃដើមណាដែលការប្រមូលបានមកវិញមិនទំនង ជាកើតមាន

២៣.២៥ នៅពេលដែលលទ្ធផលនៃកិច្ចសន្យាសាងសង់មិនអាចប៉ាន់ស្មានដោយជឿជាក់:

(ក) អង្គភាពត្រូវទទួលស្គាល់ចំណូលតែនៅពេលចំណាយសាងសង់បានកើតឡើង ដែលចំណាយនោះនឹងអាចប្រមូលបានមកវិញ និង

(ខ) អង្គភាពត្រូវទទួលថ្លៃដើមនៃការសាងសង់ជាចំណាយក្នុងគ្រាដែលចំណាយនោះ បានកើតឡើង។

២៣.២៦ ពេលដែលវាទំនងជាថាថ្លៃដើមនៃកិច្ចសន្យា នឹងលើសពីចំណូលនៃកិច្ចសន្យា សរុបក្នុងកិច្ចសន្យាសាងសង់ ការខាតបង់ត្រូវដែលបានរំពឹងទុក ត្រូវទទួលស្គាល់ជាចំណាយភ្លាម ជាមួយនឹងសំវិធានធនស្របពេលគ្នាសម្រាប់កិច្ចសន្យាដែលនាំឱ្យមានការខាតបង់ (សូមមើលកថាខណ្ឌ២១)។

២៣.២៧ ប្រសិនបើការប្រមូលចំនួនទឹកប្រាក់ ដែលបានពីការទទួលស្គាល់ជាចំណូលសាងសង់មិនមានភាពប្រហែលទៀតទេ អង្គភាពត្រូវទទួលស្គាល់ចំនួនទឹកប្រាក់ ដែលមិនអាចប្រមូលបានជាចំណាយជាជាងការកែតម្រូវនៃចំនួនទឹកប្រាក់ចំណូលសាងសង់។

## ការប្រាក់ សួយសារ និងភាគលាភ

២៣.២៨ អង្គភាពត្រូវទទួលស្គាល់ចំណូល ដែលបានកើតឡើងពីការប្រើប្រាស់ទ្រព្យសកម្មរបស់អង្គភាពដោយភាគីផ្សេងទៀត ដោយផ្តល់ជាការប្រាក់ សួយសារ និងភាគលាភដោយផ្អែកលើកថាខណ្ឌ ២៣.២៩ ពេល:

(ក) វាទំនងថាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលទាក់ទងនឹងប្រតិបត្តិការនឹងហូរចូលកាន់អង្គភាព និង

(ខ) ចំនួនទឹកប្រាក់នៃចំណូលអាចវាស់វែងបានដោយជឿជាក់

២៣.២៩ អង្គភាពត្រូវទទួលស្គាល់ចំណូលតាមមូលដ្ឋានដូចខាងក្រោម:

(ក) ការប្រាក់ត្រូវបានទទួលស្គាល់ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាពដូចបានរៀបរាប់នៅក្នុង កថាខណ្ឌ ១១.១៥-១១.២០ ។

(ខ) សួយសារត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរដោយអនុលោមតាមភាពជាក់ស្តែងនៃ កិច្ចព្រមព្រៀងដែលពាក់ព័ន្ធ។

(គ) ភាគលាភត្រូវបានទទួលស្គាល់ នៅពេលដែលមានការបង្កើតឡើងអោយម្ចាស់ភាគហ៊ុនមានសិទ្ធ ទទួលការទូទាត់។

# ការលាតត្រដាង

## ការលាតត្រដាងទូទៅអំពីចំណូល

២៣.៣០ អង្គភាពត្រូវបង្ហាញ:

(ក) គោលនយោបាយដែលបានប្រើសម្រាប់ការទទួលស្គាល់ចំណូល រួមបញ្ចូលនូវវិធីសាស្ត្រដែលបានប្រើ ដើម្បីកំណត់ពីដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការទាក់ទងនឹង ការផ្តល់សេវាកម្ម ហើយ

(ខ) ចំនួនទឹកប្រាក់របស់ចំណាត់ថ្នាក់ចំណូលនីមួយៗ ដែលបានទទួលស្គាល់ក្នុងអំឡុងគ្រាត្រូវបង្ហាញដាច់ដោយឡែក ជាអប្បបរមា នូវចំណូលកើតឡើងពី:

(១) ការលក់ទំនិញ

(២) ការផ្តល់សេវាកម្ម

(៣) ការប្រាក់

(៤) សួយសារ

(៥) ភាគលាភ

(៦) កំរៃជើងសារ

(៧) ជំនួយការរបស់រដ្ឋាភិបាល

(៨) ប្រភេទចំណូលសំខាន់ៗផ្សេងៗទៀត

## ការលាតត្រដាងទាក់ទងនឹងចំណូលពីកិច្ចសន្យាសាងសង់

២៣.៣១ អង្គភាពត្រូវបង្ហាញនូវព័ត៌មានដូចខាងក្រោម:

(ក) ទឹកប្រាក់ចំណូលសាងសង់ដែលបានទទួលស្គាល់ជាចំណូលនៅក្នុងគ្រា

(ខ) វិធីសាស្ត្រដែលបានប្រើដើម្បីកំណត់ចំណូលសាងសង់ដែលបានទទួលក្នុងគ្រា

(គ) វិធីសាស្ត្រដែលបានប្រើដើម្បីកំណត់ដំណាក់ការនៃការបញ្ចប់កិច្ចសន្យានៅក្នុងដំណើរការ

២៣.៣២ អង្គភាពត្រូវបង្ហាញ:

(ក) ចំនួនទឹកប្រាក់ដុលដែលអតិថិជនជំពាក់សម្រាប់ការងារសាងសង់ ជាទ្រព្យសកម្ម

(ខ) ចំនួនទឹកប្រាក់ដុលដែលអង្គភាពជំពាក់អតិថិជនសម្រាប់ការងារសាងសង់ ជាបំណុល

# ឧបសម្ព័ន្ធនៃផ្នែកទី ២៣
# ឧទាហរណ៍នៃការទទួលស្គាល់ចំណូល
# ក្រោមគោលការណ៍នៃផ្នែកទី ២៣

ឧបសម្ព័ន្ធនេះ អមជាមួយផ្នែកទី២៣ ប៉ុន្តែមិនមែនជាចំណែកនៃផ្នែកទី២៣ទេ។ ឧបសម្ព័ន្ធនេះ ផ្តល់ការណែនាំសម្រាប់ការអនុវត្តការតម្រូវនៃ ផ្នែកទី២៣ ក្នុងការទទួលស្គាល់ចំណូល។

២៣ក.១ ឧទាហរណ៍ខាងក្រោម ផ្តោតលើទិដ្ឋភាពពិសេសនៃប្រតិបត្តិការមួយ និងមិនមែនជាការពិភាក្សាគ្រប់ជ្រុងជ្រោយនៃកត្តាពាក់ព័ន្ធ ទាំងអស់ ដែលអាចមានឥទ្ធិពលលើការទទួលស្គាល់ចំណូលទេ។ ឧទាហរណ៍ទាំងនេះជាទូទៅសន្មតជាមុនថា ចំនួនទឹកប្រាក់ចំណូល អាចត្រូវ បានវាស់វែងប្រកបដោយភាពគួរឱ្យជឿទុកចិត្តបាន។ វាមានភាពប្រហែលថា អត្ថប្រយោជន៍សេដ្ឋកិច្ចនឹងហូរចូលអង្គភាព ហើយចំណាយដែលបានកើតឡើង ឬដែលនឹងកើតឡើង អាចត្រូវបានវាស់វែងប្រកបដោយភាពគួរឱ្យជឿទុកចិត្តបាន។

## ការលក់ទំនិញ

២៣ក.២ ច្បាប់នៅក្នុងប្រទេសខុសៗគ្នា អាចធ្វើឱ្យលក្ខណៈវិនិច្ឆ័យការទទួលស្គាល់ក្នុងផ្នែកទី២៣ ត្រូវបានបំពេញនៅពេលវេលា ខុសៗគ្នា។ ជាពិសេស ច្បាប់អាចកំណត់ពីចំណុចពេលវេលា ដែលអង្គភាព ផ្ទេរហានិភ័យ និងតម្លៃតបស្នងនៃភាពជាម្ចាស់សំខាន់ៗ។ ដូច្នេះ ឧទាហរណ៍នៅក្នុងឧបសម្ព័ន្ធនេះ ត្រូវតែបានអាន ក្នុងបរិបទនៃច្បាប់ ដែលពាក់ព័ន្ធនឹងការលក់ទំនិញនៅក្នុងប្រទេស ដែលប្រតិបត្តិការនោះ កើតឡើង។

ឧទាហរណ៍ទី១៖ ការលក់ "ចេញវិក្កយបត្រ និងរក្សាទុក" ដែលក្នុងនោះការប្រគល់ទំនិញ ត្រូវបានពន្យារតាមសំណើរបស់អ្នកទិញ ប៉ុន្តែអ្នកទិញយកប័ណ្ណកម្មសិទ្ធិ និងទទួលយកវិក្កយបត្រ

២៣ក.៣ អ្នកលក់ទទួលស្គាល់ចំណូល នៅពេលដែលអ្នកទិញយកប័ណ្ណកម្មសិទ្ធិ ឱ្យតែ៖

(ក) វាប្រហែលជាថា ការប្រគល់ទំនិញនឹងត្រូវបានធ្វើឡើង

(ខ) ជាតុនោះនៅក្នុងដៃ ត្រូវបានកំណត់ និងរួចរាល់សម្រាប់ការប្រគល់ឱ្យអ្នកទិញ នៅពេលដែល ការលក់ត្រូវបានទទួលស្គាល់

(គ) អ្នកទិញទទួលស្គាល់ជាពិសេសនូវការណែនាំអំពីការប្រគល់ទំនិញដែលបានពន្យារ និង

(ឃ) លក្ខខណ្ឌទូទាត់ធម្មតាត្រូវអនុវត្ត។

ចំណូលមិនត្រូវបានទទួលស្គាល់ នៅពេលដែលគ្រាន់តែមានចេតនាចង់ទិញ ឬផលិតទំនិញឱ្យទាន់ពេលវេលាសម្រាប់ការប្រគល់។

ឧទាហរណ៍ទី២៖ ទំនិញត្រូវបានដឹកជញ្ជូនដោយរងលក្ខខណ្ឌ៖ ការដំឡើង និងការត្រួតពិនិត្យ

២៣ក.៤ អ្នកលក់ជាធម្មតាទទួលស្គាល់ចំណូល នៅពេលដែលអ្នកទិញទទួលការប្រគល់ទំនិញ ហើយការដំឡើង និងការត្រួតពិនិត្យ ត្រូវបានបញ្ចប់។ ក៏ប៉ុន្តែ ចំណូល ត្រូវបានទទួលស្គាល់ភ្លាមៗ នាពេលអ្នកទិញទទួល ការប្រគល់ទំនិញ នៅពេលដែល៖

(ក) ដំណើរការដំឡើង គឺសាមញ្ញ ឧទាហរណ៍៖ ការដំឡើងឧបករណ៍ទទួល សំឡេង/រូបភាពទូរទស្សន៍ដែលបានធ្វើតេស្តនៅរោងចក្រ ត្រូវការតែការស្រាយការវេចខ្ចប់ និងការតភ្ជាប់ ថាមពល និងអង់តែនប៉ុណ្ណោះ ឬ

(ខ) ការត្រួតពិនិត្យត្រូវបានធ្វើឡើងសម្រាប់តែគោលបំណងនៃ ការកំណត់ថ្លៃកិច្ចសន្យា ចុងក្រោយប៉ុណ្ណោះ ឧទាហរណ៍៖ ការដឹកជញ្ជូនរ៉ែដែក ស្ករ ឬសណ្ដែកសៀង។

ឧទាហរណ៍ទី៣៖ ទំនិញត្រូវបានដឹកជញ្ជូនដោយរងលក្ខខណ្ឌ៖ អាចប្រគល់សងវិញក្រោយទិញ នៅពេលដែលអ្នកទិញបានចរចាលើសិទ្ធិប្រគល់សងវិញមានកម្រិត

២៣ក.៥ បើសិនជាមានភាពមិនប្រាកដប្រជាអំពីលទ្ធភាពនៃការប្រគល់សងវិញ អ្នកលក់ទទួលស្គាល់ចំណូល នៅពេលដែលការបញ្ជូនត្រូវបានទទួលជាផ្លូវការដោយ អ្នកទិញ ឬទំនិញត្រូវបានប្រគល់ ហើយថិរវេលាសម្រាប់ការបដិសេធន៍បានកន្លងហួស។

ឧទាហរណ៍ទី៤៖ ទំនិញត្រូវបានដឹកជញ្ជូនដោយរងលក្ខខណ្ឌ៖ បញ្ញើទុកលក់ ដែលក្រោមបញ្ញើទុកលក់នោះ អ្នកទទួល (អ្នកទិញ) សន្យាលក់ទំនិញសម្រាប់ជាប្រយោជន៍ឱ្យអ្នកជញ្ជូនទំនិញ (អ្នកលក់)

២៣ក.៦ អ្នកជញ្ជូនទំនិញទទួលស្គាល់ចំណូល នៅពេលដែលទំនិញនោះត្រូវបានលក់ដោយអ្នកទទួលទៅឱ្យភាគីទីបី។

ឧទាហរណ៍ទី៥៖ ទំនិញត្រូវបានដឹកជញ្ជូនដោយរងលក្ខខណ្ឌ៖ សាច់ប្រាក់នៅពេលលក់ទំនិញតាមការដឹកជញ្ជូន

២៣ក.៧ អ្នកលក់ទទួលស្គាល់ចំណូល នៅពេលដែលការដឹកជញ្ជូនប្រគល់ទំនិញត្រូវបានធ្វើឡើង ហើយសាច់ប្រាក់ ត្រូវបានទទួលដោយអ្នកលក់ ឬភ្នាក់ងាររបស់អ្នកលក់។

ឧទាហរណ៍ទី៦៖ ការលក់បែបរំលស់បង់ជាមុន ដែលក្រោមការលក់បែបរំលស់បង់ជាមុននោះ ទំនិញត្រូវបានដឹកជញ្ជូនប្រគល់ទៅឱ្យតែនៅពេលដែលអ្នកទិញធ្វើការទូទាត់ចុងក្រោយក្នុងការបង់រំលស់មួយស៊េរី

២៣ក.៨ អ្នកលក់ទទួលស្គាល់ចំណូលពីការលក់បែបនេះ នៅពេលដែលទំនិញត្រូវបានប្រគល់។ ក៏ប៉ុន្តែ នៅពេលដែលបទពិសោធន៍បង្ហាញថា ការលក់បែបនេះភាគច្រើនបំផុត ត្រូវបានសម្រេចពេញលេញ ចំណូលអាចត្រូវបានទទួលស្គាល់ នៅពេលដែល ប្រាក់កក់ជាដុំកំភួន ត្រូវបានទទួល ឱ្យតែទំនិញស្ថិតក្នុងដៃ ត្រូវបានកំណត់អត្តសញ្ញាណ និងរួចរាល់សម្រាប់ការប្រគល់ដល់ អ្នកទិញ។

ឧទាហរណ៍ទី៧៖ ការបញ្ជាទិញ នៅពេលដែលការទូទាត់ (ឬការទូទាត់មួយផ្នែក) ត្រូវបានទទួលមុនការប្រគល់សម្រាប់ទំនិញ ដែលបច្ចុប្បន្ន មិនត្រូវបានរក្សាទុកក្នុងសន្និធិ ឧទាហរណ៍៖ ទំនិញនៅតែមិនទាន់បានផលិតនៅឡើយ ឬនឹងត្រូវបានដឹកជញ្ជូនប្រគល់ទៅឱ្យអ្នកទិញដោយផ្ទាល់ពីភាគីទីបី

២៣ក.៩ អ្នកលក់ទទួលស្គាល់ចំណូល នៅពេលដែលទំនិញត្រូវបានប្រគល់ឱ្យអ្នកទិញ។

ឧទាហរណ៍ទី៨៖ កិច្ចព្រមព្រៀងលក់ និងទិញវិញ (ក្រៅពីប្រតិបត្តិការដោះដូរ) ដែលក្រោមកិច្ចព្រមព្រៀងលក់ និងទិញវិញនោះអ្នកលក់ព្រមព្រៀងដំណាលគ្នា ទិញទំនិញដដែលវិញនៅថ្ងៃក្រោយ ឬនៅពេលដែលអ្នកលក់មាន សិទ្ធិទិញក្នុងគ្រានិងតម្លៃកំណត់ ក្នុងការទិញវិញ ឬអ្នកទិញមានសិទ្ធិលក់ក្នុងគ្រានិងតម្លៃកំណត់ ក្នុងការទាមទារ ឱ្យទិញទំនិញនោះវិញ ដោយអ្នកលក់

២៣ក.១០ សម្រាប់កិច្ចព្រមព្រៀងលក់ និងទិញវិញនូវទ្រព្យសកម្មមួយក្រៅពីទ្រព្យសកម្មហិរញ្ញវត្ថុ អ្នកលក់ ត្រូវតែវិភាគលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ដើម្បីដឹងច្បាស់ថា តើតាមការពិត ហានិភ័យ និងតម្លៃតបស្នងនៃភាពជាម្ចាស់ត្រូវបានផ្ទេរឱ្យអ្នកទិញដែរឬទេ។ ប្រសិនបើហានិភ័យនិងតម្លៃតបស្នង នៃភាពជាម្ចាស់ ត្រូវបានផ្ទេរ អ្នកលក់ទទួលស្គាល់ចំណូល។ នៅពេលដែលអ្នកលក់ បានរក្សាហានិភ័យ និងតម្លៃតបស្នងនៃភាពជាម្ចាស់ ទោះបីជាកម្មសិទ្ធិស្របច្បាប់ត្រូវបានផ្ទេរក៏ដោយ ប្រតិបត្តិការនោះ គឺជាការរៀបចំហិរញ្ញប្បទានមួយ និងមិនបង្កើតជាចំណូលកើតឡើងទេ។ សម្រាបប់កិច្ចព្រមព្រៀងលក់ និងទិញវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុមួយ បញ្ញត្តិអំពីការឈប់ទទួលស្គាល់នៃផ្នែកទី១១ ត្រូវអនុវត្ត។

ឧទាហរណ៍ទី៩៖ ការលក់ឱ្យភាគីអន្តរការី មានជាអាទិ៍អ្នកចែកចាយ ឈ្មួញ ឬអ្នកដទៃទៀត សម្រាប់លក់បន្ត

២៣ក.១១ អ្នកលក់ ជាទូទៅ ទទួលស្គាល់ចំណូលពីការលក់បែបនេះ នៅពេលដែលហានិភ័យ និងតម្លៃតបស្នងនៃភាពជាម្ចាស់ ត្រូវបានផ្ទេរ។ ទោះបីជាយ៉ាងនេះក្តី នៅពេលដែលអ្នកទិញ តាមការពិតកំពុងដើរតួជាភ្នាក់ងារ ការលក់នោះត្រូវបានចាត់ទុកជាបញ្ញើទុកលក់។

ឧទាហរណ៍ទី១០៖ ការធ្វើបរិវិសកម្មទៅលើឯកសារបោះពុម្ពផ្សាយ និងមុខទំនិញស្រដៀងគ្នា

២៣ក.១២ នៅពេលដែលមុខទំនិញដែលពាក់ព័ន្ធ មានតម្លៃស្រដៀងគ្នានៅក្នុងកំណាត់ពេលវេលានីមួយៗ អ្នកលក់ ទទួលស្គាល់ចំណូលលើមូលដ្ឋានបន្ទាត់ត្រង់ ក្នុងរយៈពេលដែលមុខទំនិញទាំងនោះ ត្រូវបានបញ្ជូនទៅ។ នៅពេលដែល មុខទំនិញខុសគ្នាលើតម្លៃពីមួយគ្រាទៅមួយគ្រា អ្នកលក់ទទួលស្គាល់ចំណូលលើមូលដ្ឋាននៃ តម្លៃលក់របស់មុខទំនិញ ដែលបានបញ្ជូនទៅ ដោយធៀបនឹងតម្លៃលក់ប៉ាន់ស្មានសរុបនៃមុខទំនិញទាំងអស់ ដែលត្រូវ បានគ្របដណ្តប់ដោយបរិវិសកម្មនោះ។

ឧទាហរណ៍ទី១១៖ ការលក់បង់រំលស់ ដែលក្រោមការលក់បង់រំលស់នោះ តម្លៃតបស្នងគឺត្រូវទទួលជាវគ្គៗ

២៣ក.១៣ អ្នកលក់ទទួលស្គាល់ចំណូល ដែលបានមកពីថ្លៃលក់ ដោយមិនរាប់បញ្ចូលការប្រាក់ នៅកាលបរិច្ឆេទនៃការលក់។ ថ្លៃលក់ គឺជាតម្លៃបច្ចុប្បន្ននៃតម្លៃតបស្នង ដែលត្រូវបានកំណត់ដោយធ្វើអប្បហារប្រាក់រំលស់ត្រូវទទួលទៅតាមអត្រាការប្រាក់ដែលដាក់បន្ទុក។ អ្នកលក់ទទួលស្គាល់ធាតុការប្រាក់នោះជាចំណូល ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព។

ឧទាហរណ៍ទី១២៖ កិច្ចព្រមព្រៀងសម្រាប់ការសាងសង់អចលនទ្រព្យ

២៣ក.១៤ អង្គភាពដែលទទួលធ្វើការសាងសង់អចលនទ្រព្យ ដោយផ្ទាល់ ឬតាមរយៈអ្នកម៉ៅការបន្ត ហើយចុះកិច្ចព្រមព្រៀងជាមួយអ្នកទិញម្នាក់ ឬច្រើននាក់ មុនពេលការសាងសង់ចប់សព្វគ្រប់ ត្រូវធ្វើគណនេយ្យកម្មកិច្ចព្រមព្រៀងនោះជាការលក់ សេវា ដោយប្រើវិធីសាស្រ្តភាគរយនៃការបញ្ចប់ការងារ តែក្នុងករណីដែល៖

(ក) អ្នកទិញអាចបញ្ជាក់ពីធាតុផ្សំរចនាសម្ព័ន្ធសំខាន់ៗ នៃរចនាកម្មអចលនទ្រព្យ មុនការសាងសង់ចាប់ផ្តើម និង/ឬបញ្ជាក់ពីការផ្លាស់ប្តូររចនាសម្ព័ន្ធសំខាន់ៗ នៅពេលដែល ការសាងសង់កំពុងដំណើរការ (ទោះបីជាអ្នកទិញប្រើលទ្ធភាពនោះឬក៏អត់) ឬ

(ខ) អ្នកទិញទិញ និងផ្គត់ផ្គង់សម្ភារៈសាងសង់ ហើយអង្គភាពផ្តល់តែសេវា សាងសង់តែប៉ុណ្ណោះ។

២៣ក.១៥ ប្រសិនបើអង្គភាពត្រូវបានតម្រូវឱ្យផ្តល់សេវារួមជាមួយសម្ភារៈសំណង់ ដើម្បីបំពេញកាតព្វកិច្ចកិច្ចសន្យារបស់ខ្លួនក្នុងការប្រគល់អចលនទ្រព្យដល់អ្នកទិញ កិច្ចព្រមព្រៀងនោះត្រូវធ្វើគណនេយ្យកម្មជាការលក់ទំនិញ។ ក្នុងករណីនេះ អ្នកទិញមិនទទួលបានការគ្រប់គ្រង ឬហានិភ័យ និងតម្លៃតបស្នងជំពុំនៃភាពជាម្ចាស់របស់ការងារដែលកំពុងដំណើរការ ក្នុងសភាពបច្ចុប្បន្នរបស់វា ខណៈការងារសាងសង់ចម្រើនជាលំដាប់។ ផ្ទុយទៅវិញ ការផ្ទេរកើតឡើងតែ

នៅពេលប្រគល់ អចលនទ្រព្យដែលបានសាងសង់រួចរាល់ ទៅឱ្យអ្នកទិញ។

ឧទាហរណ៍ទី១៣៖ ការលក់ជាមួយរង្វាន់ភក្តីភាពអតិថិជន

២៣ក.១៦ អង្គភាពមួយលក់ផលិតផល ក ក្នុងតម្លៃ១០០ឯកតារូបិយប័ណ្ណ។ អ្នកទិញផលិតផល ក ទទួលបានឥណទានរង្វាន់ ដែលជួយឱ្យពួកគេអាចទិញបានផលិតផល ខ ក្នុងតម្លៃ១០ឯកតារូបិយប័ណ្ណ។ តម្លៃលក់ធម្មតានៃផលិតផល ខ គឺ១៨ឯកតារូបិយប័ណ្ណ។ អង្គភាពប៉ាន់ស្មានថា ចំនួន៤០% នៃអ្នកទិញផលិតផល ក នឹងប្រើរង្វាន់របស់ពួកគេ ដើម្បីទិញផលិតផល ខ ក្នុងតម្លៃ ១០ឯកតារូបិយប័ណ្ណ។ តម្លៃលក់ធម្មតានៃផលិតផល ក ដោយក្រោយគិតបញ្ចូលនូវការបញ្ចុះតម្លៃដែលផ្ដល់ឱ្យជាធម្មតាប៉ុន្តែ មិនអាចប្រើបាន ក្នុងអំឡុងពេលការផ្សព្វផ្សាយលក់នេះ គឺ៩៥ឯកតារូបិយប័ណ្ណ។

២៣ខ.១៧ តម្លៃសមស្របនៃឥណទានរង្វាន់ គឺ ៤០% × [១៨ឯកតារូបិយប័ណ្ណ × ១០ឯកតារូបិយប័ណ្ណ] = ៣.២០ឯកតារូបិយប័ណ្ណ។ អង្គភាពបែងចែកចំណូលសរុបនៃ១០០ឯកតារូបិយប័ណ្ណ រវាងផលិតផល ក និងឥណទានរង្វាន់ ដោយយោងលើតម្លៃសមស្របប្រៀបធៀបនៃ ៩៥ឯកតារូបិយប័ណ្ណ និង ៣.២០ឯកតារូបិយប័ណ្ណ រៀងៗខ្លួន។ ដូច្នេះ៖

(ក) ចំណូលសម្រាប់ផលិតផល ក គឺ១០០ឯកតារូបិយប័ណ្ណ × [៩៥ឯកតារូបិយប័ណ្ណ × (៩៥ឯកតារូបិយប័ណ្ណ + ៣.២០ឯកតារូបិយប័ណ្ណ)] = ៩៦.៧៤ឯកតារូបិយប័ណ្ណ និង

(ខ) ចំណូលសម្រាប់ផលិតផល ខ គឺ១០០ឯកតារូបិយប័ណ្ណ × [៣.២០ឯកតារូបិយប័ណ្ណ × (៩៥ឯកតារូបិយប័ណ្ណ + ៣.២០ឯកតារូបិយប័ណ្ណ)] = ៣.២៦ឯកតារូបិយប័ណ្ណ។

## ការផ្ដល់សេវា

ឧទាហរណ៍ទី១៤៖ ថ្លៃដំឡើង

២៣ក.១៨ អ្នកលក់ទទួលស្គាល់ថ្លៃដំឡើង ជាចំណូលដោយការយោងលើដំណាក់កាលនៃការបញ្ចប់ ការដំឡើង វៀរលែងតែថ្លៃដំឡើងទាំងនោះបានភ្ជាប់ជាមួយការលក់ផលិតផល ដែលក្នុងករណីនោះ ថ្លៃដំឡើងទាំងនេះ ត្រូវបានទទួលស្គាល់ នៅពេលដែលទំនិញនោះ ត្រូវបានលក់។

ឧទាហរណ៍ទី១៥៖ ថ្លៃសេវា ដែលបានបញ្ចូលក្នុងតម្លៃលក់របស់ផលិតផល

២៣ក.១៩ នៅពេលដែលថ្លៃលក់នៃផលិតផលមួយ រាប់បញ្ចូលចំនួនទឹកប្រាក់មួយដែលអាចកំណត់ អត្តសញ្ញាណបានសម្រាប់ សេវានៅពេលជាបន្តបន្ទាប់ (ឧទាហរណ៍៖ ការគាំទ្រ និងការកែលម្អផលិតផលក្រោយការលក់លើ ការលក់សុហ្វវែរ) អ្នកលក់ពន្យារចំនួនទឹកប្រាក់នោះ និងទទួលស្គាល់ចំនួនទឹកប្រាក់នោះជាចំណូល ក្នុងរយៈពេល ដែលសេវានោះត្រូវបានបំពេញ។ ចំនួនទឹកប្រាក់ដែលបានពន្យារ គឺជាអ្វីដែលនឹងប្រើសម្រាប់ទូទាត់ថ្លៃសេវាដែលបានរំពឹងទុក ក្រោមកិច្ចព្រមព្រៀង ជាមួយគ្នានឹងចំណេញសមហេតុផលលើសេវាទាំងនោះ។

ឧទាហរណ៍ទី១៦៖ កម្រៃជើងសារការឃោសនាផ្សាយ

២៣ក.២០ កម្រៃជើងសារប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានទទួលស្គាល់ នៅពេលដែលការឃោសនាផ្សាយ ឬការផ្សាយពាណិជ្ជកម្មតាមវិទ្យុឬទូរទស្សន៍ បង្ហាញពីមុខសាធារណជន។ កម្រៃជើងសារផលិតកម្ម ត្រូវបានទទួលស្គាល់ដោយយោងទៅលើដំណាក់កាលនៃការបញ្ចប់គម្រោង។

ឧទាហរណ៍ទី១៧៖ កម្រៃជើងសារទីភ្នាក់ងារជានាវ៉ាប់រង

២៣ក.២១ កម្រៃជើងសារទីភ្នាក់ងារជានាវ៉ាប់រង ដែលបានទទួល ឬដែលត្រូវទទួល ដែលមិនតម្រូវឱ្យភ្នាក់ងារ នោះផ្តល់សេវាបន្ថែម ត្រូវបានទទួលស្គាល់ជាចំណូល ដោយភ្នាក់ងារនោះ នៅកាលបរិច្ឆេទ ចាប់ផ្តើម ឬកាលបរិច្ឆេទបន្តជានាវ៉ាប់រងជាថ្មីមានប្រសិទ្ធភាពនៃប័ណ្ណជានាវ៉ាប់រងដែលពាក់ព័ន្ធ។ ប៉ុន្តែ នៅពេលដែលមានភាពប្រហែលថា ភ្នាក់ងារនោះនឹងត្រូវបានតម្រូវឱ្យផ្តល់សេវាបន្ថែម ក្នុងអំឡុង ពេលមានប្រសិទ្ធភាពរបស់ប័ណ្ណជានាវ៉ាប់រងនោះ ភ្នាក់ងារនោះពន្យារកម្រៃជើងសារ ឬផ្នែកនៃកម្រៃជើងសារនោះ និងទទួលស្គាល់កម្រៃជើងសារនោះជាចំណូល ក្នុងរយៈពេល ដែលប័ណ្ណជានាវ៉ាប់រងនោះ មានប្រសិទ្ធភាព។

ឧទាហរណ៍ទី១៨៖ ថ្លៃចូលបរិវេណ

២៣ក.២២ អ្នកលក់ទទួលស្គាល់ចំណូលពីការសម្តែងសិល្បៈ ពិធីជប់លៀង និងព្រឹត្តិការណ៍ពិសេសផ្សេងទៀត នៅពេលដែលព្រឹត្តិការណ៍នោះ កើតឡើង។ នៅពេលដែលការសុំជាវចូលរួមព្រឹត្តិការណ៍មួយចំនួន ត្រូវបានលក់ អ្នកលក់វិភាជន៍ថ្លៃចូលរួមសម្រាប់ព្រឹត្តិការណ៍នីមួយៗ ផ្អែកលើមូលដ្ឋាន ដែលឆ្លុះបញ្ចាំងពីវិសាលភាព ដែលសេវាត្រូវបានបំពេញនៅក្នុងព្រឹត្តិការណ៍នីមួយៗ។

ឧទាហរណ៍ទី១៩៖ ថ្លៃសិក្សា

២៣ក.២៣ អ្នកលក់ទទួលស្គាល់ចំណូលទៅតាមរយៈពេលនៃការបង្រៀន។

ឧទាហរណ៍ទី២០៖ ថ្លៃទទួលជាសមាជិក ថ្លៃចូលបរិវេណ និងថ្លៃសមាជិកភាព

២៣ក.២៤ ការទទួលស្គាល់ចំណូល គឺអាស្រ័យលើសារជាតិនៃសេវាដែលបានផ្តល់។ បើសិនជាថ្លៃត្រូវបង់ អនុញ្ញាតឱ្យសមាជិកភាពតែម្យ៉ាង ហើយសេវា ឬផលិតផលផ្សេងទៀតទាំងអស់ ត្រូវបានបង់ប្រាក់ ដោយឡែក ឬបើសិនជាមានថ្លៃបង់ទៀងទាត់ប្រចាំឆ្នាំដោយឡែក ថ្លៃត្រូវបង់នោះត្រូវបានទទួលស្គាល់ ជាចំណូល នៅពេលដែលគ្មានភាពមិនប្រាកដប្រជាជំជុំអំពីភាពអាចប្រមូលបានរបស់វា។ បើសិនជា ថ្លៃត្រូវបង់ អនុញ្ញាតឱ្យសមាជិកមានសិទ្ធិទទួលបានសេវា ឬការបោះពុម្ពផ្សាយ ដែលត្រូវផ្តល់ឱ្យ ក្នុងអំឡុងរយៈពេលសមាជិកភាព ឬជាវទំនិញ ឬសេវា ក្នុងតម្លៃទាបជាងអ្នកដែលមិនមែន ជាសមាជិក ថ្លៃត្រូវបង់នេះត្រូវបានទទួលស្គាល់ផ្អែកលើមូលដ្ឋាន ដែលឆ្លុះបញ្ចាំងពីពេលវេលាកើតឡើង សារជាតិ និងតម្លៃនៃអត្ថប្រយោជន៍ ដែលបានផ្តល់។

# ថ្លៃសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម

២៣ក.២៥ ថ្លៃសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម អាចគ្របដណ្តប់ការផ្គត់ផ្គង់សេវា បរិក្ខារ និងទ្រព្យសកម្មរូបីផ្សេងទៀត និងចំណេះធ្វើនៅពេលដំបូង និងជាបន្តបន្ទាប់។ ដូច្នេះ ថ្លៃសិទ្ធិប្រើឈ្មោះ ពាណិជ្ជកម្ម ត្រូវបានទទួលស្គាល់ជាចំណូល លើមូលដ្ឋានដែលឆ្លុះបញ្ចាំងពី គោលបំណង ដែលថ្លៃត្រូវបង់នោះ ត្រូវបានគិត។ វិធីសាស្ត្រខាងក្រោមនៃការទទួលស្គាល់ ថ្លៃសិទ្ធិប្រើឈ្មោះ ពាណិជ្ជកម្ម មានលក្ខណៈសមស្រប។

ឧទាហរណ៍ទី២១៖ ថ្លៃសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម៖ ការផ្គត់ផ្គង់បរិក្ខារ និងទ្រព្យសកម្មរូបីផ្សេងទៀត

២៣ក.២៦ អ្នកប្រគល់សិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម ទទួលស្គាល់តម្លៃសមស្របនៃទ្រព្យសកម្ម ដែលបានលក់ ជាចំណូលនៅពេលដែលវត្ថុនោះត្រូវបានប្រគល់ ឬប័ណ្ណសម្គាល់កម្មសិទ្ធិត្រូវបានផ្ទេរ។

ឧទាហរណ៍ទី២២៖ ថ្លៃសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម៖ ការផ្គត់ផ្គង់សេវាដំបូង និងបន្ទាប់ក្រោយមកទៀត

២៣ក.២៧ អ្នកប្រគល់សិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម ទទួលស្គាល់នូវថ្លៃត្រូវបង់សម្រាប់ការផ្តល់សេវាជាបន្តបន្ទាប់ ជាចំណូលពីការលក់ខណៈដែលសេវាកម្មត្រូវបានផ្តល់ ដោយមិនខ្វល់ថាជាផ្នែកនៃថ្លៃត្រូវបង់ដំបូងឬជាថ្លៃត្រូវបង់ដោយឡែកមួយ។ នៅពេលដែលថ្លៃត្រូវបង់ដោយឡែកនោះមិនគ្រប់គ្រាន់ សម្រាប់ប៉ះប៉ូវថ្លៃដើមនៃសេវាកម្មជាបន្តបន្ទាប់ជាមួយនឹងប្រាក់ចំណេញសមហេតុផល ផ្នែកនៃថ្លៃដើមដំបូងដែលគ្រប់គ្រាន់សម្រាប់ការប៉ះប៉ូវថ្លៃដើមនៃសេវាកម្មជាបន្តបន្ទាប់និងផ្តល់ប្រាក់ចំណេញសមហេតុផលពីសេវាកម្មទាំងនោះ ត្រូវបានបន្សារនិងទទួលស្គាល់ជាចំណូលពីការលក់ខណៈដែលសេវាកម្មត្រូវបានផ្តល់។

២៣ក.២៨ កិច្ចព្រមព្រៀងប្រគល់/ទទួលសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម អាចនឹងដាក់កំហិតឱ្យអ្នកប្រគល់សិទ្ធិ ប្រើឈ្មោះពាណិជ្ជកម្ម ផ្គត់ផ្គង់បរិក្ខារ សន្និធិ ឬទ្រព្យសកម្មរូបីផ្សេងទៀត ក្នុងតម្លៃទាបជាង តម្លៃដែលបានគិតសម្រាប់អ្នកដទៃ ឬតម្លៃដែលមិនផ្តល់ប្រាក់ចំណេញសមហេតុផលលើការលក់ ទាំងនោះ។ ក្នុងកាលៈទេសៈទាំងនេះ ផ្នែកនៃថ្លៃដំបូងដែលគ្រប់គ្រាន់ ដើម្បីប៉ះប៉ូវថ្លៃដើម ដែលបានប៉ាន់ស្មាន ដែលលើសពីតម្លៃលក់នោះ និងដើម្បីផ្តល់ប្រាក់ចំណេញសមហេតុផល លើការលក់ទាំងនោះ ត្រូវបានពន្យារ និងទទួលស្គាល់ តាមរយៈពេល ដែលទំនិញទំនងជា ត្រូវបានលក់ទៅឱ្យអ្នកទទួលសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម។ សមតុល្យនៃថ្លៃដំបូង ត្រូវបានទទួល ស្គាល់ជាចំណូលពីការលក់នៅពេលដែលការបំពេញសេវាដំបូងទាំងអស់ និងកាតព្វកិច្ចដទៃទៀត ដែលបានតម្រូវសម្រាប់អ្នកប្រគល់សិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម (ដូចជាជំនួយលើការជ្រើសរើស ទីតាំង ការបណ្តុះបណ្តាលបុគ្គលិក ហិរញ្ញប្បទាន និងការផ្សាយពាណិជ្ជកម្ម) ត្រូវបានសម្រេច យ៉ាងក្រាស់ក្រែល។

២៣ក.២៩ សេវាដំបូង និងកាតព្វកិច្ចដទៃទៀត ក្រោមកិច្ចព្រមព្រៀងប្រគល់/ទទួលសិទ្ធិប្រើឈ្មោះពាណិជកម្ម នៃតំបន់មួយអាចនឹងអាស្រ័យទៅលើចំនួននៃហាងដោយឡែកមួយៗ ដែលបានបង្កើតឡើង នៅក្នុងតំបន់នោះ។ ក្នុងករណីនេះថ្លៃត្រូវបង់ដែលបណ្តាលមកពីសេវាដំបូង ត្រូវបានទទួលស្គាល់ ជាចំណូលពីការលក់ ទៅតាមសមាមាត្រនៃចំនួនហាងដែលសេវាដំបូង ត្រូវបានបំពេញ យ៉ាងក្រាស់ក្រែល។

២៣ក.៣០ បើសិនជាថ្លៃដំបូង អាចប្រមូលបាន ក្នុងរយៈពេលបន្លាយ និងមានភាពមិនប្រាកដប្រជាជំដុំថា វានឹងត្រូវប្រមូលបានគ្រប់ចំនួន ថ្លៃត្រូវបង់នោះត្រូវបានទទួលស្គាល់ នៅពេលដែលសាច់ប្រាក់ បង់រំលស់ត្រូវបានទទួល។

ឧទាហរណ៍ទី២៣៖ ថ្លៃសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម៖ ថ្លៃសិទ្ធិប្រើឈ្មោះពាណិជ្ជកម្មជាបន្ត

២៣ក.៣១ ថ្លៃត្រូវបង់ដែលបានគិតសម្រាប់ការប្រើសិទ្ធិជាបន្ត ដែលបានផ្តល់ដោយកិច្ចព្រមព្រៀង ឬសម្រាប់ សេវាដទៃទៀតដែលបានផ្តល់ ក្នុងអំឡុងរយៈពេលនៃកិច្ចព្រមព្រៀង ត្រូវបានទទួលស្គាល់ជា ចំណូលពីការលក់ នៅពេលដែលសេវាត្រូវបានផ្តល់ ឬនៅពេលដែលសិទ្ធិត្រូវបានប្រើ។

ឧទាហរណ៍ទី២៤៖ ថ្លៃសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម៖ ប្រតិបត្តិការទីភ្នាក់ងារ

២៣ក.៣២ ប្រតិបត្តិការ អាចកើតឡើង រវាងអ្នកផ្តល់សិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម និងអ្នកទទួលសិទ្ធិប្រើឈ្មោះ ពាណិជ្ជកម្ម ដែលតាមការពិតជាក់ស្តែង ពាក់ព័ន្ធនឹងអ្នកផ្តល់សិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម កំពុងដើរតួជាភ្នាក់ងារសម្រាប់អ្នកទទួលសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម។ ឧទាហរណ៍៖ អ្នកផ្តល់សិទ្ធិប្រើ ឈ្មោះពាណិជ្ជកម្ម អាចបញ្ជាទិញគ្រឿងផ្គត់ផ្គង់ និងរៀបចំការប្រគល់ គ្រឿងផ្គត់ផ្គង់ទាំងនោះទៅឱ្យអ្នកទទួលសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម ដោយមិនទទួលបាន ប្រាក់ចំណេញ។ ប្រតិបត្តិការបែបនេះ មិននាំឱ្យ ចំណូលពីការលក់កើតឡើងទេ។

ឧទាហរណ៍ទី២៥៖ ថ្លៃត្រូវបង់ពីការបង្កើតសុហ្វវែរតាមការចង់បានរបស់អតិថិជន


CamEd Business School

២៣ក.៣៣ អ្នកបង្កើតសុហ្វវែរ ទទួលស្គាល់ថ្លៃត្រូវបង់ពីការបង្កើតសុហ្វវែរតាមការចង់បានរបស់អតិថិជន ជាចំណូលពីការលក់ដោយយោងលើដំណាក់កាលនៃការបញ្ចប់ការបង្កើតនោះ រាប់ទាំងការបញ្ចប់សេវា ដែលបានផ្តល់ឱ្យ សម្រាប់ការគាំទ្រសេវាក្រោយពេលប្រគល់ផង។

## ការប្រាក់ កម្រៃអ្នកនិពន្ធ និងភាគលាភ

ឧទាហរណ៍ទី២៦៖ ថ្លៃអាជ្ញាបណ្ណ និងកម្រៃអ្នកនិពន្ធ

២៣ក.៣៤ អ្នកផ្តល់អាជ្ញាបណ្ណ ទទួលស្គាល់ថ្លៃត្រូវបង់ និងកម្រៃអ្នកនិពន្ធ ដែលបានបង់សម្រាប់ការប្រើប្រាស់ ទ្រព្យសកម្ម (ដូចជាយីហោ ប៉ាតង់ សុហ្វវែរ សិទ្ធិថតចម្លងតន្ត្រី កំណែដើមថាសតន្ត្រី និងភាពយន្តរូបភាពចលនា) របស់អង្គភាពមួយ ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀង។ ក្នុងការអនុវត្តជាក់ស្តែង នេះអាចនឹងត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបន្ទាត់ត្រង់ តាមរយៈពេលធរមាននៃកិច្ចព្រមព្រៀង ឧទាហរណ៍ នៅពេលដែលអ្នកទទួលអាជ្ញាបណ្ណ មានសិទ្ធិប្រើប្រាស់បច្ចេកវិទ្យាជាក់លាក់សម្រាប់ ថិរវេលាដែលបានបញ្ជាក់ច្បាស់លាស់។

២៣ក.៣៥ ការប្រគល់សិទ្ធិសម្រាប់ថ្លៃត្រូវបង់ថេរ ឬការធានាដែលមិនអាចបង្វែរសងវិញបាន ក្រោមកិច្ចសន្យាមិនអាចលុបចោលបាន ដែលអនុញ្ញាតឱ្យអ្នកទទួលអាជ្ញាបណ្ណប្រើប្រាស់សិទ្ធិ ទាំងនោះដោយសេរី ហើយអ្នកផ្តល់អាជ្ញាបណ្ណពុំមានកាតព្វកិច្ចសេសសល់ ដែលត្រូវបំពេញ តាមការពិត គឺជាការលក់មួយ។ ឧទាហរណ៍មួយ គឺកិច្ចព្រមព្រៀងផ្តល់អាជ្ញាបណ្ណ សម្រាប់ការប្រើប្រាស់ សុហ្វវែរ នៅពេលដែលអ្នកផ្តល់អាជ្ញាបណ្ណអស់កាតព្វកិច្ច ក្រោយពេលប្រគល់។ ឧទាហរណ៍ មួយទៀតគឺ ការផ្តល់សិទ្ធិ ក្នុងការបង្ហាញភាពយន្តរូបភាព ចលនា នៅក្នុងទីផ្សារ ដែលអ្នកផ្តល់ អាជ្ញាបណ្ណ ពុំមានការគ្រប់គ្រងលើអ្នកចែកចាយ និងរំពឹងថា នឹងលែងទទួលបានចំណូល បន្ថែមទៀតពីការលក់សំបុត្រ។ ក្នុងករណីបែបនេះ ចំណូលពីការលក់ ត្រូវបានទទួលស្គាល់ នៅពេលលក់។

២៣ក.៣៦ ក្នុងករណីមួយចំនួន ថ្លៃអាជ្ញាបណ្ណ ឬកម្រៃអ្នកនិពន្ធ នឹងអាចត្រូវបានទទួល ឬមិនអាចត្រូវបានទទួល គឺត្រូវអាស្រ័យលើការកើតឡើងនៃហេតុការណ៍អនាគតមួយ។ ក្នុងករណីបែបនេះ ចំណូលពីការលក់ត្រូវបាន ទទួលស្គាល់តែនៅពេលដែលមានភាពប្រហែលថា ថ្លៃត្រូវបង់ ឬកម្រៃអ្នកនិពន្ធនោះ នឹងត្រូវបានទទួល ដែលជាធម្មតា គឺនៅពេលដែលហេតុការណ៍នោះបានកើតឡើង។

# ផ្នែកទី ២៤
# អំណោយរបស់រដ្ឋាភិបាល

## វិសាលភាពនៃផ្នែកនេះ

២៤.១ ផ្នែកនេះបញ្ជាក់ពីការធ្វើគណនេយ្យកម្មសម្រាប់អំណោយរបស់រដ្ឋាភិបាលទាំងអស់។ អំណោយរបស់រដ្ឋាភិបាល គឺជាជំនួយដែលផ្តល់ដោយរដ្ឋាភិបាលក្នុងទម្រង់នៃការផ្ទេរធនធានទៅឱ្យអង្គភាព ដើម្បីប្តូរមកវិញនូវការអនុលោមជាមួយលក្ខខណ្ឌដែលបានកំណត់ពីអតីតកាលឬនៅពេលអនាគតទាក់ទងនឹងសកម្មភាពប្រតិបត្តិការទាំងឡាយរបស់អង្គភាព។

២៤.២ អំណោយរបស់រដ្ឋាភិបាលមិនរាប់បញ្ចូលទម្រង់នៃជំនួយរដ្ឋាភិបាលទាំងឡាយណា ដែលមិនអាចឱ្យតម្លៃយ៉ាងសមហេតុផល និងប្រតិបត្តិការជាមួយរដ្ឋាភិបាល ដែលមិនអាចញែកឱ្យដាច់ពីប្រតិបត្តិការជួញដូរជាប្រក្រតីរបស់អង្គភាព។

២៤.៣ ផ្នែកនេះមិនគ្របដណ្តប់ទៅលើជំនួយរបស់រដ្ឋាភិបាលដែលត្រូវបានផ្តល់សម្រាប់អង្គភាពមួយនៅក្នុងទម្រង់ជាអត្ថប្រយោជន៍ដែលមានក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ ឬប្រាក់ខាតពន្ធ ឬត្រូវបានកំណត់ ឬកម្រិតដោយឈរលើមូលដ្ឋាននៃបំណុលពន្ធលើប្រាក់ចំណូល។ ឧទាហរណ៍នៃអត្ថប្រយោជន៍ទាំងនេះមានរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ឥណទានពន្ធវិនិយោគ ការអនុញ្ញាតរំលស់ពន្លឿន និងអត្រាពន្ធលើប្រាក់ចំណូលបានបន្ថយ។ ផ្នែកទី២៩ ស្តីពីពន្ធលើប្រាក់ចំណូល គ្របដណ្តប់ទៅលើការធ្វើគណនេយ្យកម្មសម្រាប់ពន្ធប្រាក់ចំណូលជាមូលដ្ឋាន។

## ការទទួលស្គាល់ និង ការវាស់វែង

២៤.៤ អង្គភាពមួយត្រូវទទួលស្គាល់អំណោយរបស់រដ្ឋាភិបាលដូចតទៅ៖

(ក) អំណោយដែលមិនកំណត់ពីលក្ខខណ្ឌលទ្ធផលអនាគតដាក់លាក់ទៅលើអ្នកទទួលត្រូវបានទទួលស្គាល់នៅក្នុងចំណូលនៅពេលដែលចំនួនទឹកប្រាក់សរុបនៃអំណោយ អាចទទួលបាន

(ខ) អំណោយដែលកំណត់ពីលក្ខខណ្ឌលទ្ធផលអនាគតដាក់លាក់ទៅលើអ្នកទទួលត្រូវបានទទួលស្គាល់នៅក្នុងចំណូល លុះត្រាតែពេលលក្ខខណ្ឌលទ្ធផលត្រូវបានបំពេញ និង

(គ) អំណោយដែលបានទទួលមុនពេលលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ចំណូលត្រូវបានបំពេញត្រូវបានទទួលស្គាល់ជាបំណុល។

២៤.៥ អង្គភាពមួយត្រូវវាស់វែងអំណោយតាមតម្លៃសមស្របនៃទ្រព្យសកម្មដែលបានទទួល ឬត្រូវទទួល។

### ការលាតត្រដាង

២៤.៦ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោម៖

(ក) លក្ខណៈនិងចំនួនទឹកប្រាក់នៃអំណោយរបស់រដ្ឋាភិបាល ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(ខ) លក្ខខណ្ឌមិនទាន់បានបំពេញនិងកត្តាយថាហេតុផ្សេងទៀត ដែលភ្ជាប់ជាមួយអំណោយរបស់រដ្ឋាភិបាល ដែលមិនទាន់ត្រូវបានទទួលស្គាល់នៅក្នុងចំណូល និង

(គ) ការបង្ហាញពីទម្រង់ផ្សេងៗនៃជំនួយរបស់រដ្ឋាភិបាលដែលអង្គភាពទទួលបានផលប្រយោជន៍ដោយផ្ទាល់។

២៤.៧ សម្រាប់គោលបំណងនៃការលាតត្រដាងដែលតម្រូវដោយកថាខណ្ឌ ២៤.៦(គ) ជំនួយរបស់រដ្ឋាភិបាលគឺជាសកម្មភាពដោយរដ្ឋាភិបាលដែលបានបង្កើតឡើងដើម្បីផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចជាក់លាក់ចំពោះអង្គភាពមួយ ឬ អង្គភាពច្រើន ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ក្រោមលក្ខណៈវិនិច្ឆ័យច្បាស់លាស់។ ឧទាហរណ៍ រួមមានដំបូន្មានបច្ចេកទេស ឬ ទីផ្សារដោយឥតគិតថ្លៃ ការផ្តល់ការធានា និង កម្ចីមានអត្រា ការប្រាក់សូន្យ ឬ ទាប។

# ផ្នែកទី ២៥
# បន្ទុកលើប្រាក់កម្ចី

## វិសាលភាពនៃផ្នែកនេះ

២៥.១ ផ្នែកនេះបញ្ជាក់ពីការធ្វើគណនេយ្យកម្មសម្រាប់បន្ទុកលើប្រាក់កម្ចី។ បន្ទុកលើប្រាក់កម្ចីគឺជាបន្ទុកការប្រាក់ និងបន្ទុកផ្សេងទៀតដែលអង្គភាពបានចំណាយទាក់ទិននឹងការខ្ចីមូលនិធិ។ បន្ទុកលើប្រាក់កម្ចីរួមមាន ៖

(ក) ចំណាយការប្រាក់បានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ដែលមានប្រសិទ្ធភាព ដូចដែលបានបរិយាយនៅក្នុងផ្នែកទី១១ ឧបករណ៍ហិរញ្ញវត្ថុសាមញ្ញ។

(ខ) បន្ទុកហិរញ្ញវត្ថុទាក់ទងនឹងភតិសន្យាហិរញ្ញវត្ថុបានទទួលស្គាល់ដោយអនុលោមតាមផ្នែកទី២០ ភតិសន្យា និង

(គ) ភាពខុសនៃគ្នាការផ្លាស់ប្តូរកើតឡើងពីប្រាក់កម្ចីក្នុងរូបិយប័ណ្ណបរទេស រហូតដល់ភាពខុសគ្នាទាំងនោះ ចាត់ទុកជាការកែតម្រូវចំពោះបន្ទុកការប្រាក់។

## ការទទួលស្គាល់

២៥.២ អង្គភាពមួយត្រូវទទួលស្គាល់បន្ទុកលើប្រាក់កម្ចីទាំងអស់ ជាចំណាយនៅក្នុងចំណេញឬខាត នៅក្នុងអំឡុងពេលដែលបន្ទុកនោះបានកើតឡើង។

## ការលាតត្រដាង

២៥.៣ កថាខណ្ឌ ៥.៥(ខ) តម្រូវឱ្យមានការលាតត្រដាងអំពីបន្ទុកហិរញ្ញវត្ថុ។ កថាខណ្ឌ១១.៤៨ (ខ) តម្រូវឱ្យមានការលាតត្រដាងអំពីការចំណាយការប្រាក់សរុប (ដោយប្រើប្រាស់តាម វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព) សម្រាប់បំណុលហិរញ្ញវត្ថុទាំងអស់ ដែលមិនមែនជាតម្លៃសមស្របតាមរយៈចំណេញឬខាត។ ផ្នែកនេះមិនតម្រូវឱ្យមានការលាតត្រដាងបង្ហាញបន្ថែមទៀតទេ។

# ផ្នែកទី ២៦
# ការទូទាត់ដោយផ្អែកតាមភាគហ៊ុន

## វិសាលភាពនៃផ្នែកនេះ

២៦.១ ផ្នែកនេះបញ្ជាក់ពីការធ្វើគណនេយ្យកម្ម សម្រាប់ប្រតិបត្តិការទូទាត់ដោយផ្អែកលើភាគហ៊ុនទាំងអស់ រួមបញ្ចូលទាំងប្រតិបត្តិការទូទាត់សងជាមូលធន ឬជាសាច់ប្រាក់ ឬប្រតិបត្តិការដែលក្នុងនោះលក្ខខណ្ឌនៃកិច្ចសន្យា ផ្តល់នូវជម្រើស មិនថាអង្គភាពទូទាត់ប្រតិបត្តិការជាសាច់ប្រាក់ ឬ(ទ្រព្យសកម្មផ្សេងទៀត) ឬដោយការបោះផ្សាយឧបករណ៍មូលធន។

២៦.១ក ប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុន អាចត្រូវបានទូទាត់ដោយអង្គភាពក្រុមផ្សេងទៀត (ឬម្ចាស់ភាគហ៊ុននៃអង្គភាពក្រុមផ្សេងទៀត) តាងនាមឱ្យអង្គភាព ដែលទទួលទំនិញ ឬសេវា។ ផ្នែកនេះក៏អនុវត្តចំពោះអង្គភាពដែល៖

(ក) ទទួលទំនិញ ឬសេវា នៅពេលដែល អង្គភាពមួយទៀតក្នុងក្រុមតែមួយ (ឬម្ចាស់ភាគហ៊ុននៃអង្គភាពក្រុមណាមួយ) មានកាតព្វកិច្ចទូទាត់ប្រតិបត្តិការផ្អែកលើភាគហ៊ុន ឬ

(ខ) មានកាតព្វកិច្ចទូទាត់ប្រតិបត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុន នៅពេលដែល អង្គភាពមួយទៀតក្នុងក្រុមតែមួយ ទទួលទំនិញ ឬសេវាកម្ម វៀរលែងតែប្រតិបត្តិការនោះ មានគោលបំណងច្បាស់លាស់ ក្រៅពីការទូទាត់សម្រាប់ទំនិញ ឬសេវា ដែលត្រូវផ្គត់ផ្គង់ឱ្យអង្គភាពទទួលទំនិញ ឬសេវាកម្មទាំងនោះ។

២៦.១ខ ក្នុងពេលដែលអវត្តមានទំនិញ ឬសេវាកម្មដែលអាចសម្គាល់ជាក់លាក់ កាលៈទេសៈផ្សេងទៀត អាចបង្ហាញថាទំនិញ ឬសេវាកម្ម ត្រូវបានទទួលរួចហើយ (ឬនឹងត្រូវទទួលបាន) ដែលក្នុងករណីនេះ ផ្នែកនេះត្រូវអនុវត្ត (សូមមើលកថាខណ្ឌ២៦.១៧)។

២៦.២ ប្រតិបត្តិការការទូទាត់សាច់ប្រាក់ដោយផ្អែកតាមភាគហ៊ុន រួមបញ្ចូលសិទ្ធិទទួលបានតម្លៃកើនឡើងនៃភាគហ៊ុន។ ឧទាហរណ៍ អង្គភាពអាចផ្តល់សិទ្ធិទទួលបានតម្លៃកើនឡើងនៃភាគហ៊ុនទៅឱ្យនិយោជិតជាផ្នែកមួយនៃកញ្ចប់ប្រាក់កម្រៃដែលនិយោគជិតនឹងមានសិទ្ធិទទួលចំពោះការទូទាត់សាច់ប្រាក់នាពេលអនាគត(ក្រៅពីឧបករណ៍មូលធន) ដោយផ្អែកលើការកើនឡើងនៃតម្លៃភាគហ៊ុនរបស់អង្គភាពពីកម្រិតជាក់លាក់មួយក្នុងរយៈពេលជាក់លាក់មួយ។ ឬ អង្គភាពអាចផ្តល់ឱ្យ និយោជិតនូវសិទ្ធិដើម្បីទទួលការទូទាត់សាច់ប្រាក់នាពេលអនាគតដោយផ្តល់ទៅឱ្យពួកគេនូវសិទ្ធិចំពោះភាគហ៊ុន (រួមបញ្ចូលភាគហ៊ុនដែលត្រូវបោះផ្សាយនៅពេលមានការអនុវត្តសិទ្ធិពិសេសទិញភាគហ៊ុន) ដែលអាចហៅទិញត្រឡប់មកវិញបានទាំងដល់ពេលកំណត់(ឧទាហរណ៍ នៅពេលឈប់ពីការងារ) ឬនៅពេលដែលនិយោជិតអនុវត្តសិទ្ធិពិសេសរបស់ខ្លួន។

## ការទទួលស្គាល់

២៦.៣ អង្គភាពមួយត្រូវទទួលស្គាល់ទំនិញឬសេវា ដែលបានទទួលឬបានទិញនៅក្នុងប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន នៅពេលដែលអង្គភាពទទួលបានជាទំនិញ ឬ ជាសេវាកម្ម។ អង្គភាពត្រូវទទួលស្គាល់ការកើនឡើងនៃមូលធន ប្រសិនបើទំនិញ ឬសេវាកម្មត្រូវបានទទួលនៅក្នុងប្រត្តិបត្តិការទូទាត់មូលធនផ្អែកតាមភាគហ៊ុន ឬបំណុល ប្រសិន

បើទំនិញឬសេវាកម្មត្រូវបានទិញនៅក្នុងប្រតិបត្តិការទូទាត់សាច់ប្រាក់ផ្អែកតាមភាគហ៊ុន។

២៦.៤ នៅពេលទំនិញ ឬសេវាកម្មដែលបានទទួល ឬបានទិញនៅក្នុងប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនមិនបំពេញឱ្យលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ទ្រព្យសកម្ម អង្គភាពត្រូវទទួលស្គាល់ទំនិញ ឬ សេវាកម្មនោះជាចំណាយ។

## ការទទួលស្គាល់នៅពេលដែលមានលក្ខខណ្ឌដើម្បីផ្ទេរ

២៦.៥ ប្រសិនបើការទូទាត់ដោយផ្អែកតាមភាគហ៊ុនដែលផ្តល់ទៅឱ្យនិយោជិតផ្ទេរភ្លាម និយោជិតមិនតម្រូវឱ្យបំពេញសេវាកម្មក្នុងគ្រាជាក់លាក់មួយទេ មុននឹងមានសិទ្ធិទទួលដោយឥតលក្ខខណ្ឌនូវការទូទាត់ផ្អែកលើភាគហ៊ុន។ ក្នុងពេលដែលអវត្តមាននៃភស្តុតាងចំពោះភាពផ្ទុយគ្នា អង្គភាពត្រូវសន្មតជាមុនថា សេវាកម្មដែលបានផ្តល់ដោយនិយោជិតជាតម្លៃតបស្នងសម្រាប់ការទូទាត់ដោយផ្អែកលើភាគហ៊ុន។នៅក្នុងករណីនេះ នៅកាលបរិច្ឆេទផ្តល់ឲ្យក្រុមហ៊ុនត្រូវទទួលស្គាល់សេវាដែលបានទទួលពេញលេញ ជាមួយនឹងការកើនឡើងដែលត្រូវគ្នានៃមូលធនឬបំណុល។

២៦.៦ ប្រសិនបើការទូទាត់ដោយផ្អែកតាមភាគហ៊ុន មិនបានផ្ទេរឱ្យទេរហូតដល់និយោជិតបំពេញសេវាកម្មក្នុងរយៈពេលមួយដូចបានកំណត់ អង្គភាពត្រូវសន្មតជាមុនថា សេវាកម្មទាំងឡាយដែលត្រូវផ្តល់ដោយភាគីម្ខាងទៀត ជាតម្លៃតបស្នងសម្រាប់ការទូទាត់ដោយផ្អែកតាមភាគហ៊ុននឹ ងត្រូវបានទទួលនៅពេលអនាគត ក្នុងអំឡុងពេលផ្ទេរឱ្យ។អង្គភាពត្រូវទទួលស្គាល់សេវាកម្មទាំងនោះ នៅពេលដែលសេវាត្រូវបានផ្តល់ដោយនិយោជិតក្នុងអំឡុងគ្រាផ្ទេរជាមួយនឹងការកើនឡើងដែលត្រូវគ្នានៅក្នុងមូលធន ឬ បំណុល។

## ការវាស់វែងប្រតិបត្តិការទូទាត់មូលធន ផ្អែកតាមភាគហ៊ុន

### គោលការណ៍នៃការវាស់វែង

២៦.៧ សម្រាប់ប្រតិបត្តិការទូទាត់មូលធន ផ្អែកតាមភាគហ៊ុន អង្គភាពត្រូវវាស់វែងទំនិញ ឬសេវាកម្មបានទទួល និងការកើនឡើងដែលត្រូវគ្នានៅក្នុងមូលធន តាមតម្លៃសមស្របនៃទំនិញ ឬសេវាកម្មបានទទួល លុះត្រាតែតម្លៃសមស្របនោះមិនអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់។ ប្រសិនបើអង្គភាពមិនអាចប៉ាន់ស្មានដោយជឿជាក់នូវតម្លៃសមស្របនៃទំនិញ ឬ សេវាកម្មដែលបានទទួល អង្គភាពត្រូវវាស់វែងតម្លៃរបស់ទំនិញ និង សេវាកម្ម នោះ និងការកើនឡើងដែលត្រូវគ្នានៅក្នុងមូលធនដោយយោងតាមតម្លៃសមស្របនៃឧបករណ៍មូលធនដែលបានផ្តល់។ដើម្បីអនុវត្តការតម្រូវនេះចំពោះប្រតិបត្តិការជាមួយនិយោជិត និងអ្នកដទៃទៀត ដែលបានផ្តល់សេវាកម្មស្រដៀងគ្នាអង្គភាពត្រូវវាស់វែងតម្លៃសមស្របនៃសេវាកម្មដែលបានទទួលទាំងនោះ ដោយយោងតាមតម្លៃសមស្របនៃឧបករណ៍មូលធនដែលបានផ្តល់ ពីព្រោះជាធម្មតាគេមិនអាចប៉ាន់ស្មានដោយជឿជាក់នូវតម្លៃសមស្របនៃសេវាដែលបានទទួល។

២៦.៨ សម្រាប់ប្រតិបត្តិការជាមួយនិយោជិត (រួមបញ្ចូលទាំងអ្នកដទៃទៀតដែលផ្តល់សេវាស្រដៀងគ្នា) តម្លៃសមស្របនៃឧបករណ៍មូលធនត្រូវបានវាស់វែងនៅកាលបរិច្ឆេទផ្តល់ឲ្យ។សម្រាប់ប្រតិបត្តិការជាមួយភាគីផ្សេងៗដែលមិនមែននិយោជិត កាលបរិច្ឆេទការវាស់វែងគឺជាកាលបរិច្ឆេទនៅពេលដែលអង្គភាពទទួលបានទំនិញ ឬ ភាគីម្ខាងទៀតផ្តល់សេវាកម្ម។

២៦.៩ ការផ្តល់ឧបករណ៍មូលធនអាចមានលក្ខខណ្ឌ ចំពោះនិយោជិតដែលបំពេញលក្ខខណ្ឌផ្ទេរជាក់លាក់ទាក់ទងនឹង

សេវាកម្ម ឬលទ្ធផលការងារ។ ឧទាហរណ៍នៃលក្ខខណ្ឌផ្ទេរមួយទាក់ទងនឹងសេវាកម្ម គឺនៅពេលដែលការផ្តល់ភាគហ៊ុន ឬជម្រើសភាគហ៊ុនដល់និយោជិត មានលក្ខខណ្ឌតម្រូវឱ្យនិយោជិតនោះ នៅបម្រើការងារ ក្នុងអង្គភាពសម្រាប់រយៈពេលជាក់លាក់មួយ។ ឧទាហរណ៍នៃលក្ខខណ្ឌផ្ទេរទាក់ទិននឹងសមិទ្ធិផលការងារ គឺនៅពេលដែលការផ្តល់ភាគហ៊ុន ឬសិទ្ធិទិញភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់ មានលក្ខខណ្ឌលើរយៈពេលជាក់លាក់នៃការបម្រើសេវា និងលើអង្គភាពដែលសម្រេចបាននូវការលូតលាស់ជាក់លាក់មួយនៃប្រាក់ចំណេញ (លក្ខខណ្ឌផ្ទេរមិនមែនទីផ្សារ) ឬការកើនឡើង ជាក់លាក់មួយនៃតម្លៃភាគហ៊ុនរបស់អង្គភាព (លក្ខខណ្ឌផ្ទេរតាមទីផ្សារ)។ លក្ខខណ្ឌផ្ទេរ ត្រូវធ្វើគណនេយ្យកម្ម ដូចខាងក្រោម៖

(ក) រាល់លក្ខខណ្ឌផ្ទេរទាំងអស់ទាក់ទិននឹង សេវាកម្មនិយោជិត ឬលក្ខខណ្ឌសមិទ្ធិផលការងារមិនមែនទីផ្សារ ត្រូវតែពិចារណា នៅពេលធ្វើការប៉ាន់ស្មានចំនួននៃឧបករណ៍មូលធនដែលរំពឹងទុកនឹងផ្ទេរឱ្យ។ ជាបន្តបន្ទាប់ អង្គភាពត្រូវកែសម្រួលការប៉ាន់ស្មាននោះ ប្រសិនបើព័ត៌មានថ្មីបង្ហាញថា ចំនួនឧបករណ៍មូលធន ដែលបានរំពឹងទុកនឹងផ្ទេរឱ្យ ខុសពីការប៉ាន់ស្មានមុន។ នៅកាលបរិច្ឆេទផ្ទេរឱ្យ អង្គភាពត្រូវកែសម្រួលការប៉ាន់ស្មាន ឱ្យស្មើនឹងចំនួននៃឧបករណ៍មូលធន ដែលបានផ្ទេរឱ្យចុងក្រោយ។ លក្ខខណ្ឌដើម្បីផ្ទេរទាំងអស់ទាក់ទិននឹង សេវាកម្មនិយោជិត ឬលក្ខខណ្ឌសមិទ្ធិផលការងារមិនមែនទីផ្សារ មិនត្រូវបានពិចារណាទេ នៅពេលធ្វើការប៉ាន់ស្មានតម្លៃសមស្របនៃភាគហ៊ុន សិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់ ឬឧបករណ៍មូលធនផ្សេងទៀត នៅថ្ងៃវាស់វែង។

(ខ) រាល់លក្ខខណ្ឌផ្ទេរតាមទីផ្សារ និងលក្ខខណ្ឌមិនដើម្បីផ្ទេរទាំងអស់ត្រូវពិចារណា នៅពេលដែលប៉ាន់ស្មានតម្លៃសមស្របនៃភាគហ៊ុន សិទ្ធិពិសេសទិញភាគហ៊ុន ឬឧបករណ៍មូលធនផ្សេងទៀត នៅថ្ងៃវាស់វែង ដោយគ្មានការកែតម្រូវជាបន្តបន្ទាប់លើតម្លៃសមស្រប ដែលបានប៉ាន់ស្មាន ដោយមិនគិតពីលទ្ធផលនៃលក្ខខណ្ឌផ្ទេរតាមទីផ្សារ និងលក្ខខណ្ឌមិនដើម្បីផ្ទេរ ប្រសិនបើគ្រប់លក្ខខណ្ឌដើម្បីផ្ទេរផ្សេងទៀត ត្រូវបានបំពេញ។

## ភាគហ៊ុន

២៦.១០ អង្គភាពមួយត្រូវវាស់វែងតម្លៃសមស្របនៃភាគហ៊ុន( និង ទំនិញ ឬសេវាកម្មពាក់ព័ន្ធ ដែលបានទទួល) ដោយប្រើឋានានុក្រមវាស់វែងពលំដាប់ថ្នាក់ដូចខាងក្រោម៖

(ក) ប្រសិនបើតម្លៃទីផ្សារអាចសង្កេតបានមានសម្រាប់ឧបករណ៍មូលធនដែលបានផ្តល់ គេត្រូវប្រើតម្លៃនោះ

(ខ) ប្រសិនបើតម្លៃទីផ្សារអាចសង្កេតបានមិនមានទេនោះ គេត្រូវវាស់វែងតម្លៃសមស្របនៃឧបករណ៍មូលធនដែលបានផ្តល់ ដោយប្រើទិន្នន័យទីផ្សារដែលអាចសង្កេតបានជាក់លាក់របស់អង្គភាព ដូចជា៖

(១) ប្រតិបត្តិការថ្មីៗក្នុងភាគហ៊ុនរបស់អង្គភាព ឬ

(២) ការវាយតម្លៃត្រឹមត្រូវនិងឯករាជ្យថ្មីៗរបស់អង្គភាព ឬ ទ្រព្យសកម្មចម្បង។

(គ) ប្រសិនបើតម្លៃទីផ្សារដែលសង្កេតបានមិនមាន និងការទទួលបាននូវការវាស់វែងប្រកបដោយភាពជឿជាក់នៃតម្លៃសមស្របតាមចំណុច (ខ) មិនអាចអនុវត្តបាន គេត្រូវតែវាស់វែងដោយប្រយោលនូវ តម្លៃសមស្របរបស់ភាគហ៊ុន ដោយប្រើវិធីសាស្ត្រវាយតម្លៃដែលប្រើទិន្នន័យទីផ្សារតាមដែលអាចអនុវត្តបាន ដើម្បីប៉ាន់ស្មាននូវតម្លៃនៃឧបករណ៍មូលធនទាំងនោះនៅកាលបរិច្ឆេទ ផ្តល់ឱ្យនៅក្នុងប្រតិបត្តិការជំហោងដៃរវាងភាគីដែលមានឆន្ទៈចំណេះដឹង។អភិបាលរបស់អង្គភាពត្រូវប្រើការវិនិច្ឆ័យរបស់គេដើម្បីអនុវត្តវិធីសាស្ត្រវាយតម្លៃដែលសមស្របបំផុតដើម្បីកំណត់តម្លៃសមស្រប។ វិធីសាស្ត្រវាយតម្លៃណាមួយដែលបានប្រើត្រូវតែមានភាពសមស្របជាមួយវិធីសាស្ត្រវាយតម្លៃ ដែលអាចទទួលយកបានជាទូទៅសម្រាប់ឧបករណ៍វាយតម្លៃមូលធន។

## សិទ្ធិទិញភាគហ៊ុន និង សិទ្ធិទទួលបានតម្លៃកើនឡើងនៃភាគហ៊ុន

២៦.១១ អង្គភាពមួយត្រូវវាស់វែងតម្លៃទីផ្សារនៃសិទ្ធិពិសេសសម្រាប់ទិញភាគហ៊ុន និង សិទ្ធិទទួលបានតម្លៃកើនឡើងនៃភាគហ៊ុន (និង ទំនិញ ឬ សេវាកម្មទាក់ទិនដែលបានទទួល) ដោយប្រើប្រាស់នូវឋានានុក្រមវាស់វែងបីកម្រិត ដូចខាងក្រោមៈ

(ក) ប្រសិនបើតម្លៃទីផ្សារដែលអាចសង្កេតបានមានសម្រាប់ឧបករណ៍មូលធនដែលបានផ្តល់ គេត្រូវប្រើតម្លៃនោះ

(ខ) ប្រសិនបើតម្លៃទីផ្សារដែលអាចសង្កេតបានមិនមានទេនោះ ត្រូវវាស់វែងតម្លៃសមស្របនៃសិទ្ធិពិសេសសម្រាប់ទិញភាគហ៊ុន និងសិទ្ធិទទួលបានតម្លៃកើនឡើងនៃភាគហ៊ុន ដែលបានផ្តល់ឲ្យដោយប្រើទិន្នន័យទីផ្សារដែលគេអាចសង្កេតបានជាក់លាក់របស់អង្គភាពដូចជាចំណុច (ក) សម្រាប់ប្រតិបត្តិការថ្មីៗនៃសិទ្ធិពិសេសសម្រាប់ទិញភាគហ៊ុន។

(គ) ប្រសិនបើតម្លៃទីផ្សារដែលអាចសង្កេតបានមិនមាន ហើយការទទួលបាននូវការវាស់វែងប្រកបដោយភាពជឿជាក់នៃតម្លៃសមស្របតាមចំណុច (ខ) មិនអាចអនុវត្តបាន គេត្រូវវាស់វែងដោយប្រយោលនូវតម្លៃសមស្របនៃសិទ្ធិទិញភាគហ៊ុនឬសិទ្ធិទទួលបានតម្លៃកើនឡើងនៃភាគហ៊ុនដោយប្រើវិធីសាស្ត្រកំណត់ថ្លៃសិទ្ធិពិសេស។ ជាតុចូលសម្រាប់វិធីសាស្ត្រ (ដូចជាតម្លៃភាគហ៊ុនមធ្យមទម្ងន់ តម្លៃនៃអនុវត្តសិទ្ធិ ការប្រែប្រួលដែលបានរំពឹងទុកអាយុកាលសិទ្ធិពិសេស ភាគលាភដែលរំពឹងទុក និង អត្រាការប្រាក់មិនមានហានិភ័យ) ត្រូវប្រើទិន្នន័យទីផ្សារតាម ដែលអាចធ្វើទៅបាន។ កថាខណ្ឌ២៦.១០ ផ្តល់ការណែនាំ ពីការកំណត់តម្លៃសមស្របនៃភាគហ៊ុន ដែលបានប្រើនៅក្នុងការកំណត់តម្លៃភាគហ៊ុនមធ្យមទម្ងន់។ អង្គភាពត្រូវទាញយកការប៉ាន់ស្មាននៃការប្រែប្រួលបានរំពឹងទុកដែលមានសង្គតិភាពនឹងវិធីសាស្ត្រវាយតម្លៃដែល បានប្រើដើម្បីកំណត់តម្លៃសមស្របនៃភាគហ៊ុន។

## ការកែប្រែកិច្ចព្រមព្រៀងនិងលក្ខខណ្ឌដែលឧបករណ៍មូលធនត្រូវបានផ្តល់

២៦.១២ អង្គភាពអាចកែប្រែកិច្ចព្រមព្រៀង និងលក្ខខណ្ឌ ដែលឧបករណ៍មូលធនត្រូវបានផ្តល់ ក្នុងឥរិយាបទដែលមានប្រយោជន៍ចំពោះនិយោជិត ឧទាហរណ៍ដោយការកាត់បន្ថយតម្លៃអនុវត្តនៃសិទ្ធិពិសេស ឬកាត់បន្ថយគ្រាផ្ទេរ ឬដោយការកែប្រែ ឬលុបចោលលក្ខខណ្ឌបំពេញការងារ។ ដូចគ្នាដែរ អង្គភាពអាចកែប្រែកិច្ចព្រមព្រៀង និងលក្ខខណ្ឌក្នុងឥរិយាបថ ដែលគ្មានប្រយោជន៍ចំពោះនិយោជិត ឧទាហរណ៍ដោយការបង្កើនគ្រាផ្ទេរ ឬការបន្ថែមលក្ខខណ្ឌអនុវត្តការងារ។ អង្គភាពត្រូវយកលក្ខខណ្ឌដើម្បីផ្ទេរ ដែលបានកែប្រែទៅពិចារណានៅក្នុងការធ្វើគណនេយ្យកម្មប្រតិបត្តិការនៃការទូទាត់ដោយផ្អែកតាមភាគហ៊ុន ដូចខាងក្រោមៈ

(ក) ប្រសិនបើការកែប្រែបង្កើនតម្លៃសមស្របនៃឧបករណ៍មូលធនដែលបានផ្តល់ (ឬការកើនឡើងចំនួនឧបករណ៍មូលធនដែលបានផ្តល់ឱ្យ)ដែលបានវាស់វែងភ្លាមៗពីមុន និងបន្ទាប់ពីការកែប្រែ អង្គភាពត្រូវបញ្ចូលតម្លៃសមស្របបន្ថែមដែលបានផ្តល់ឱ្យក្នុងការវាស់វែងនៃចំនួនទឹកប្រាក់ដែលបានទទួលស្គាល់សម្រាប់សេវាកម្មដែលបានទទួលជាតម្លៃតបស្នងចំពោះឧបករណ៍មូលធនដែលបានផ្តល់។ តម្លៃសមស្របកើនដែលបានផ្តល់គឺជាភាពខុសគ្នារវាងតម្លៃសមស្របនៃឧបករណ៍មូលធនដែលបានកែប្រែនិង តម្លៃសមស្របនៃឧបករណ៍មូលធនដំបូងដែលឧបករណ៍ទាំងពីរត្រូវបានប៉ាន់ស្មាននៅកាលបរិច្ឆេទនៃការកែប្រែ។ ប្រសិនបើការកែប្រែកើតឡើងក្នុងអំឡុងគ្រាផ្ទេរតម្លៃសមស្របកើនដែលបានផ្តល់ត្រូវបានបញ្ចូលនៅក្នុងការវាស់វែងនៃចំនួនទឹកប្រាក់ដែលបានទទួលស្គាល់សម្រាប់សេវាកម្មដែលបានទទួលក្នុងគ្រាពីថ្ងៃកែប្រែរហូតដល់ថ្ងៃដែលឧបករណ៍មូលធនត្រូវបានផ្ទេរ បន្ថែមលើចំនួនទឹកប្រាក់ដែលផ្អែកលើតម្លៃសមស្របនៅកាលបរិច្ឆេទផ្តល់ឲ្យនៃឧបករណ៍មូលធនដំបូងដែលត្រូវបានទទួលស្គាល់ក្នុង គ្រាផ្ទេរដំបូងដែលនៅសេសសល់។

(ខ) ប្រសិនបើការកែប្រែកាត់បន្ថយតម្លៃសមស្រប សរុបនៃការរៀបចំការទូទាត់ដោយផ្អែកលើភាគហ៊ុន ឬ ម៉្យាងវិញទៀតមិនមានអត្ថប្រយោជន៍ចំពោះនិយោជិត ទោះបីយ៉ាងណាក៏ដោយអង្គភាពត្រូវបន្តទទួលស្គាល់សេវាកម្មដែលបានទទួលជាតម្លៃតបស្នងសម្រាប់ឧបករណ៍មូលធនដែលបានផ្តល់ ដូចពេលដែលការកែប្រែនោះមិនបានកើតឡើង។

ការតម្រូវនៅក្នុងកថាខណ្ឌនេះ ត្រូវបានបង្ហាញក្នុងបរិបទ នៃប្រតិបត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុនជាមួយនិយោជិត។ ការតម្រូវទាំងនេះក៏អនុវត្តចំពោះប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុន ជាមួយភាគីទាំងឡាយ ក្រៅពីនិយោជិតផងដែរ ប្រសិនបើប្រតិបត្តិការទាំងនេះត្រូវបានវាស់វែងដោយយោងលើតម្លៃសមស្របនៃឧបករណ៍មូលធន ដែលបានផ្តល់ឱ្យ ប៉ុន្តែការយោងដល់កាលបរិច្ឆេទផ្តល់ឲ្យនោះ សំដៅដល់កាលបរិច្ឆេទ ដែលអង្គភាពទទួលបានទំនិញ ឬដែលភាគីម្ខាងទៀតផ្តល់សេវាកម្ម។

### ការលុបចោល និង ការទូទាត់សង

២៦.១៣ អង្គភាពត្រូវទទួលស្គាល់ការលុបចោល ឬការទូទាត់សងនៃប្រាក់រង្វាន់ផ្អែកលើភាគហ៊ុន ជាការពន្លឿននៃការផ្ទេរ ដូច្នេះហើយ អង្គភាពត្រូវទទួលស្គាល់ភ្លាមៗនូវចំនួនទឹកប្រាក់ដែលគួរត្រូវបានទទួលស្គាល់សម្រាប់សេវាកម្មដែលបានទទួលលើគ្រាផ្ទេរដែលនៅសល់។

## ប្រតិបត្តិការទូទាត់សាច់ប្រាក់ ផ្អែកតាមភាគហ៊ុន

២៦.១៤ សម្រាប់ប្រតិបត្តិការទូទាត់សាច់ប្រាក់ផ្អែកតាមភាគហ៊ុន អង្គភាពត្រូវវាស់វែងទំនិញឬសេវាកម្មដែលបានទិញ និងបំណុលដែលបានកើតឡើងតាមតម្លៃសមស្របនៃបំណុល។ រហូតដល់បំណុលត្រូវបានសងអង្គភាពត្រូវវាស់វែងឡើងវិញនូវតម្លៃសមស្របនៃបំណុលនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ និង នៅថ្ងៃទូទាត់ ជាមួយនឹងការផ្លាស់ប្តូរតម្លៃសមស្របដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ក្នុងគ្រា។

## ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនជាមួយនឹងជម្រើសសាច់ប្រាក់

២៦.១៥ ប្រតិបត្តិការការទូទាត់ដោយផ្អែកតាមភាគហ៊ុនមួយចំនួនផ្តល់ឱ្យអង្គភាពឬភាគីជាដៃគូនូវជម្រើសក្នុងការទូទាត់សងប្រតិបត្តិការជាសាច់ប្រាក់ (ឬទ្រព្យសកម្មផ្សេងទៀត) ឬ ដោយការផ្ទេរនៃឧបករណ៍មូលធន។ នៅក្នុងករណីបែបនេះ អង្គភាពត្រូវទទួលស្គាល់ប្រតិបត្តិការជាប្រតិបត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុន លើកលែងតែ

(ក) អង្គភាពមានការអនុវត្តពីមុនក្នុងការទូទាត់សងដោយការបោះផ្សាយឧបករណ៍មូលធន ឬ

(ខ) សិទ្ធិពិសេសពុំមានលក្ខណៈពាណិជ្ជកម្មពីព្រោះសាច់ប្រាក់ទូទាត់មិនមានទំនាក់ទំនងទៅនឹងតម្លៃសមស្របនៃឧបករណ៍មូលធន ហើយទំនងនឹងមានតម្លៃទាបជាងតម្លៃសមស្របនៃឧបករណ៍មូលធន។ នៅក្នុងលក្ខខណ្ឌ (ក)និង(ខ) អង្គភាពត្រូវទទួលស្គាល់ប្រតិបត្តិការជាប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដោយអនុលោមតាមកថាខណ្ឌ ២៦.៧-២៦.១៣។

## ផែនការជាក្រុម

២៦.១៦ ប្រសិនបើប្រាក់រង្វាន់ដែលការទូទាត់ផ្អែកតាមភាគហ៊ុន ត្រូវបានផ្តល់ដោយអង្គភាព ទៅឱ្យនិយោជិត នៃអង្គភាពជាក្រុមមួយ ឬច្រើន ហើយក្រុមបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដោយប្រើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ឬស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ អង្គភាពជាក្រុមត្រូវបានអនុញ្ញាត ជាជម្រើសជំនួសការចាត់ចែងដូចដែលបានកំណត់នៅក្នុងកថាខណ្ឌ២៦.៣-២៦.១៥ ឱ្យវាស់វែងចំណាយដែលទូទាត់ផ្អែកតាមភាគហ៊ុន ដោយឈរលើមូលដ្ឋាននៃការបែងចែកដ៏សមស្របនៃចំណាយសម្រាប់ក្រុមទាំងមូល។

## ទំនិញ ឬសេវាកម្មដែលមិនអាចកំណត់បាន

២៦.១៧ ប្រសិនបើតម្លៃតបស្នងដែលអាចកំណត់បាន ដែលបានទទួល មើលទៅដូចជាតិចជាងតម្លៃសមស្របនៃឧបករណ៍មូលធន ដែលបានផ្តល់ឱ្យ ឬបំណុលដែលបានកើតឡើង ស្ថានភាពនេះជាទូទៅសបញ្ជាក់ថា តម្លៃតបស្នងផ្សេងទៀត (ពោលគឺទំនិញ ឬសេវាដែលមិនអាចកំណត់បាន) ត្រូវបាន (ឬនឹងត្រូវ) ទទួល។ ឧទាហរណ៍៖ យុត្តាធិការមួយចំនួនមានកម្មវិធី ដែលម្ចាស់ (ដូចជានិយោជិត) មានលទ្ធភាពទិញមូលធន ដោយគ្មានការផ្តល់ទំនិញ ឬសេវាកម្មដែលអាចកំណត់បានជាក់លាក់ (ឬដោយផ្តល់ទំនិញ ឬសេវាកម្មដែលទាបជាងតម្លៃសមស្របនៃឧបករណ៍មូលធនដែលបានផ្តល់)។ នេះបង្ហាញថា តម្លៃតបស្នងផ្សេងទៀតត្រូវបានទទួល ឬនឹងត្រូវទទួល (ដូចជាសេវារបស់និយោជិតពីអតីតកាល ឬទៅអនាគត)។ អង្គភាពត្រូវវាស់វែងទំនិញ ឬសេវាកម្មដែលមិនអាចកំណត់បានដែលបានទទួល (ឬនឹងត្រូវទទួល) ជាភាពខុសគ្នារវាងតម្លៃសមស្របនៃការទូទាត់ដោយផ្អែកលើភាគហ៊ុន និងតម្លៃសមស្របនៃទំនិញ ឬសេវាកម្មដែលអាចកំណត់បាន ដែលបានទទួល (ឬនឹងត្រូវទទួល) ដែលត្រូវបានវាស់វែងនៅកាលបរិច្ឆេទផ្តល់ឲ្យ។ សម្រាប់ប្រតិបត្តិការដែលទូទាត់ជាសាច់ប្រាក់ បំណុលត្រូវវាស់វែងឡើងវិញនៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ រហូតទាល់តែបំណុលនោះត្រូវបានទូទាត់ស្របតាមកថាខណ្ឌ២៦.១៤។

## ការលាតត្រដាង

២៦.១៨ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានខាងក្រោមអំពីលក្ខណៈ និង ទំហំនៃកិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុនដែលបានកើតឡើងក្នុងការិយបរិច្ឆេទ៖

(ក) ការរៀបរាប់ពីប្រភេទនីមួយៗនៃកិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុនដែលបានកើតឡើង នៅពេលណាមួយក្នុងការិយបរិច្ឆេទ ដោយរួមបញ្ចូលនូវលក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀងនីមួយៗ ដូចជា ការតម្រូវនៃការផ្ទេរ លក្ខខណ្ឌ អតិបរមានៃសិទ្ធិពិសេសដែលបានផ្តល់ ហើយវិធីសាស្ត្រនៃការទូទាត់ (ឧទាហរណ៍មិនថាជា សាច់ប្រាក់ ឬ មូលធន)។

អង្គភាពដែលមានប្រភេទស្រដៀងគ្នា ខ្លាំងនៃកិច្ចព្រមព្រៀងការទូទាត់ ដោយផ្អែកតាមភាគហ៊ុនអាចសរុបព័ត៌មាននេះ។

(ខ) ចំនួន និង តម្លៃមធ្យមទម្ងន់នៃការអនុវត្តសិទ្ធិពិសេស សម្រាប់ទិញភាគហ៊ុនសម្រាប់ក្រុមនីមួយៗនៃសិទ្ធិពិសេស៖

(១) ដែលមាននៅដើមការិយបរិច្ឆេទ

(២) ដែលត្រូវបានផ្តល់ក្នុងការិយបរិច្ឆេទ

(៣) ដែលបានបាត់បង់ក្នុងការិយបរិច្ឆេទ

(៤) ដែលត្រូវបានអនុវត្តក្នុងការិយបរិច្ឆេទ

(៥) ដែលអស់សុពលភាពក្នុងការិយបរិច្ឆេទ

(៦) ដែលលេចធ្លោនៅចុងការិយបរិច្ឆេទ និង

(៧) ដែលអាចអនុវត្តបាននៅចុងការិយបរិច្ឆេទ

២៦.១៩ សម្រាប់កិច្ចព្រមព្រៀងទូទាត់មូលធននផ្អែកតាមភាគហ៊ុនអង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីរបៀបដែលអង្គភាពវាស់វែងតម្លៃសមស្របនៃទំនិញឬសេវាកម្មដែលបានទទួល ឬតម្លៃនៃឧបករណ៍មូលធនដែលបានផ្តល់។ ប្រសិនបើវិធីសាស្ត្រវាយតម្លៃត្រូវបានប្រើ អង្គភាពត្រូវបង្ហាញវិធីសាស្ត្រនិងហេតុផលសម្រាប់ការជ្រើសរើសវា។

២៦.២០ សម្រាប់កិច្ចព្រមព្រៀងទូទាត់សាច់ប្រាក់ផ្អែកតាមភាគហ៊ុន អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីរបៀបដែលបំណុលត្រូវបានវាស់វែង។

២៦.២១ សម្រាប់កិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុនដែលត្រូវបានកែប្រែក្នុងការិយបរិច្ឆេទ អង្គភាពត្រូវលាតត្រដាងការពន្យល់នៃការកែប្រែទាំងនោះ។

២៦.២២ ប្រសិនបើអង្គភាព គឺជាផ្នែកនៃផែនការទូទាត់ដោយផ្អែកតាមភាគហ៊ុនរបស់ក្រុម ហើយអង្គភាព វាស់វែងចំណាយការទូទាត់ផ្អែកតាមភាគហ៊ុន ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកសមស្របមួយនៃចំណាយដែលបានទទួលស្គាល់សម្រាប់ក្រុម អង្គភាពត្រូវលាតត្រដាងអង្គហេតុនោះ និងមូលដ្ឋានសម្រាប់បែងចែកនោះ (សូមមើលកថាខណ្ឌ២៦.១៦)។

២៦.២៣ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោមអំពីផលប៉ះពាល់នៃប្រតិបត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុនលើលទ្ធផលចំណេញ ឬខាតរបស់អង្គភាពសម្រាប់ការិយបរិច្ឆេទ និងនៅលើស្ថានភាពហិរញ្ញវត្ថុ៖

(ក) ការចំណាយសរុបដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទ និង

(ខ) តម្លៃយោងសរុបនៅចុងការិយបរិច្ឆេទសម្រាប់បំណុលដែលកើតពីប្រតិបត្តិការការទូទាត់ដោយផ្អែកតាមភាគហ៊ុន។

# ផ្នែកទី ២៧
# ការថយចុះតម្លៃនៃទ្រព្យសកម្ម

## កម្មវត្ថុនិងវិសាលភាព

២៧.១ ការខាតពីការថយចុះតម្លៃកើតឡើងនៅពេល ដែលតម្លៃយោងនៃទ្រព្យសកម្មលើសពីចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។ ផ្នែកនេះត្រូវបានអនុវត្តក្នុងការទទួលស្គាល់ការថយចុះតម្លៃនៃទ្រព្យសកម្មទាំងអស់ លើកលែងតែចំណុចខាងក្រោមដែលផ្នែកដទៃទៀតនៃស្តង់ដារនេះបង្កើតឡើងនូវការតម្រូវនៃការថយចុះតម្លៃៈ

(ក) ទ្រព្យសកម្មពន្ធពន្យារ (សូមមើលផ្នែកទី២៩ ពន្ធលើប្រាក់ចំណូល)។

(ខ) ទ្រព្យសកម្មកើតចេញពីអត្ថប្រយោជន៍និយោជិត (សូមមើលផ្នែកទី២៨ អត្ថប្រយោជន៍និយោជិត)។

(គ) ទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងវិសាលភាពនៃផ្នែកទី១១ ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ឬផ្នែកទី១២ បញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ

(ឃ) ទ្រព្យវិនិយោគ ដែលវាស់វែងតាមតម្លៃសមស្រប (សូមមើលផ្នែកទី១៦ ទ្រព្យវិនិយោគ)។

(ង) ទ្រព្យសកម្មជីវសាស្ត្រទាក់ទង នឹងសកម្មភាពកសិកម្មដែលវាស់វែងតាមតម្លៃសមស្រប ដកចំណាយប៉ាន់ស្មានក្នុងការលក់ (សូមមើលផ្នែកទី៣៤ សកម្មភាពពិសេស)។

(ច) ទ្រព្យសកម្មដែលកើតចេញពីកិច្ចសន្យាសាងសង់ (សូមមើលផ្នែកទី២៣ ស្តីពីចំណូល)។

## ការថយចុះតម្លៃនៃសន្និធិ

### តម្លៃលក់ដកចំណាយក្នុងការបញ្ចប់ និងលក់

២៧.២ អង្គភាពត្រូវវាយតម្លៃនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ថាតើសន្និធិមួយណាខ្លះបានថយចុះតម្លៃ។ អង្គភាពត្រូវវាយតម្លៃដោយការប្រៀបធៀបតម្លៃយោងនៃធាតុនីមួយៗ (ឬក្រុមនៃសន្និធិស្រដៀងគ្នា - សូមមើលកថាខណ្ឌ២៧.៣) ជាមួយនឹងតម្លៃលក់ដកចំណាយក្នុងការបញ្ចប់ និងលក់។ ប្រសិនបើធាតុមួយនៃសន្និធិ (ឬក្រុមនៃសន្និធិស្រដៀងគ្នា) ថយចុះតម្លៃ អង្គភាពត្រូវកាត់បន្ថយតម្លៃយោងនៃសន្និធិ (ឬក្រុមសន្និធិ) ទៅជា តម្លៃលក់ដកចំណាយក្នុងការបញ្ចប់ និងលក់។ ការកាត់បន្ថយនោះគឺជាការខាតពីការថយចុះតម្លៃ និងត្រូវទទួល ស្គាល់ភ្លាមៗនៅក្នុងចំណេញ ឬខាត។

២៧.៣ ប្រសិនបើគេមិនអាចធ្វើទៅរួចនូវការកំណត់តម្លៃលក់ដកចំណាយក្នុងការបញ្ចប់ និងលក់សម្រាប់ធាតុសន្និធិម្តងមួយៗបានទេ អង្គភាពអាចបញ្ចូលធាតុទាំងអស់នៃសន្និធិដែលទាក់ទងនឹងខ្សែសង្វាក់ផលិតផលដូចគ្នា ដែលមានគោលបំណង ឬការប្រើប្រាស់ចុងក្រោយស្រដៀងគ្នាហើយត្រូវបានផលិត និងផ្សព្វផ្សាយនៅក្នុង តំបន់ភូមិសាស្ត្រដូចគ្នាសម្រាប់គោលបំណងនៃការវាយតម្លៃពីការថយចុះតម្លៃ។

## ការបង្វិលត្រឡប់មកវិញនៃការថយចុះតម្លៃ

២៧.៤ អង្គភាពត្រូវធ្វើការវាយតម្លៃថ្មីសម្រាប់តម្លៃលក់ដកចំណាយក្នុងការបញ្ចប់ និងលក់នៅកាលបរិច្ឆេទរាយការណ៍បន្តបន្ទាប់នីមួយៗ។ នៅពេលដែលស្ថានភាពដែលបានធ្វើឱ្យសន្និធិថយចុះតម្លៃកាលពីមុនមិនកើតឡើងទៀតទេ ឬនៅពេលដែលមានភស្តុតាងច្បាស់លាស់នៃការកើនឡើងនៃតម្លៃលក់ដកចំណាយក្នុងការបញ្ចប់និងលក់ ដោយសារស្ថានភាពសេដ្ឋកិច្ចបានផ្លាស់ប្តូរ អង្គភាពត្រូវបង្វិលត្រឡប់មកវិញនូវចំនួនទឹកប្រាក់នៃការថយចុះតម្លៃ (ពោលគឺការបង្វិលត្រឡប់មកវិញមិនត្រូវលើសពីចំនួនទឹកប្រាក់នៃការខាតពីការថយចុះតម្លៃដំបូង) ដូច្នេះ តម្លៃយោងថ្មីគឺជាតម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃលក់ដកចំណាយក្នុងការបញ្ចប់និងលក់ដែលបានកែប្រែរួច។

# ការថយចុះតម្លៃនៃទ្រព្យសកម្មក្រៅពីសន្និធិ

## គោលការណ៍ទូទៅ

២៧.៥ តែក្នុងករណីដែលចំនួនទឹកប្រាក់ ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មតិចជាងតម្លៃយោង អង្គភាពត្រូវកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មមកចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។ ការកាត់បន្ថយនេះ គឺជាការខាតពីការថយចុះតម្លៃ។ កថាខណ្ឌ ២៧.១១ - ២៧.២០ ផ្តល់ការណែនាំពីការវាស់វែងចំនួនទឹកប្រាក់ ដែលអាចប្រមូលមកវិញបាន។

២៧.៦ អង្គភាពត្រូវទទួលស្គាល់ការខាតពីការថយចុះតម្លៃភ្លាមៗ នៅក្នុងចំណេញ ឬខាត វៀរលែងតែទ្រព្យសកម្មនោះ ត្រូវបានកត់ត្រាតាមតម្លៃដែលបានវាយតម្លៃឡើងវិញ ស្របតាមគំរូនៃការវាយតម្លៃឡើងវិញ ក្នុងផ្នែកទី១៧ ស្តីពីទ្រព្យរោងចក្រ និងបរិក្ខារ។ ការខាតពីការថយចុះតម្លៃនៃទ្រព្យសកម្មដែលបានវាយតម្លៃឡើងវិញ ត្រូវចាត់ចែងជាការថយចុះការវាយតម្លៃឡើងវិញ ស្របតាមកថាខណ្ឌ១៧.១៥យ។

## សូចនាករនៃការថយចុះតម្លៃ

២៧.៧ អង្គភាពត្រូវវាយតម្លៃនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ថាតើមានសញ្ញាណាមួយដែលទ្រព្យសកម្មអាចថយចុះតម្លៃ។ ប្រសិនបើសញ្ញាណាមួយកើតឡើង អង្គភាពត្រូវប៉ាន់ស្មានពីចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម។ ប្រសិនបើមិនមានសញ្ញានៃការថយចុះតម្លៃទេ អង្គភាពមិនចាំបាច់ប៉ាន់ស្មានពីចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបានទេ។

២៧.៨ ប្រសិនបើអង្គភាពមិនអាចប៉ាន់ស្មានចំនួនទឹកប្រាក់ ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មនីមួយៗទេ អង្គភាពត្រូវប៉ាន់ស្មានចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃអង្គភាពបង្កើតសាច់ប្រាក់ ដែលទ្រព្យសកម្មនោះស្ថិតនៅក្នុង។ នេះអាចជាករណីមួយដោយសារការវាស់វែងចំនួនទឹកប្រាក់ដែលអាចប្រមូល មកវិញបានតម្រូវឱ្យធ្វើការព្យាករណ៍លំហូរសាច់ប្រាក់ និងជួនកាលទ្រព្យសកម្មនីមួយៗ មិនអាចបង្កើតលំហូរ សាច់ប្រាក់ដោយខ្លួនឯងបាន។ អង្គភាពបង្កើតសាច់ប្រាក់របស់ទ្រព្យសកម្មមួយគឺជាក្រុមតូចបំផុតនៃទ្រព្យសកម្ម ដែលអាចកំណត់បានដែលរួមបញ្ចូលទ្រព្យសកម្ម ហើយបង្កើតលំហូរសាច់ប្រាក់ចូលដែលមានភាពឯករាជ្យច្រើន ពីលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្មផ្សេងទៀត ឬក្រុមទ្រព្យសកម្មផ្សេងទៀត។

២៧.៩ ក្នុងការវាយតម្លៃថាតើមានសញ្ញាណាដែលទ្រព្យសកម្មអាចត្រូវបានថយចុះតម្លៃ អង្គភាពត្រូវពិចារណា ជាអប្បបរមានូវសញ្ញាដូចខាងក្រោម:

## ប្រភពព័ត៌មានខាងក្រៅ

(ក) នៅក្នុងការិយបរិច្ឆេទ តម្លៃទីផ្សាររបស់ទ្រព្យសកម្មបានធ្លាក់ចុះយ៉ាងខ្លាំងច្រើនជាងការរំពឹងទុកដែលជាលទ្ធផលនៃការកន្លងហួសទៅនៃពេលវេលា ឬការប្រើប្រាស់ធម្មតា។

(ខ) ការផ្លាស់ប្តូរដ៏សំខាន់ៗជាមួយនឹងផលប៉ះពាល់អាក្រក់មកលើអង្គភាពបានកើតមានឡើងនៅក្នុងការិយបរិច្ឆេទ ឬនឹងកើតឡើងនាពេលអនាគតដ៏ខ្លី ក្នុងបរិស្ថានបច្ចេកវិទ្យា ទីផ្សារ សេដ្ឋកិច្ច ឬច្បាប់ ដែលអង្គភាពធ្វើអាជីវកម្ម ឬក្នុងទីផ្សារដែលទ្រព្យសកម្មត្រូវបានប្រើប្រាស់។

(គ) អត្រាការប្រាក់ទីផ្សារ ឬអត្រាទីផ្សារផ្សេងៗនៃចំណេញលើការវិនិយោគបានកើនឡើងនៅក្នុងការិយបរិច្ឆេទ ហើយការកើនឡើងទាំងនោះទំនងជាត្រូវប៉ះពាល់យ៉ាងខ្លាំងនូវអត្រាអប្បហារដែលបានប្រើក្នុងការគណនាតម្លៃប្រើប្រាស់នៃទ្រព្យសកម្ម និង បន្ថយតម្លៃសមស្របដកចំណាយក្នុងការលក់នៃទ្រព្យសកម្ម។

(ឃ) តម្លៃយោងនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាព គឺច្រើនជាងតម្លៃសមស្របប៉ាន់ស្មានរបស់អង្គភាពទាំងមូល (ការប៉ាន់ស្មានបែបនេះអាចត្រូវបានធ្វើឡើង ទាក់ទងទៅនឹងការលក់អង្គភាពមួយផ្នែក ឬទាំងអស់)។

## ប្រភពព័ត៌មានខាងក្នុង

(ង) មានភ័ស្តុតាងពីភាពហួសសម័យ ឬ ការខូចខាតរូបរាងនៃទ្រព្យសកម្ម។

(ច) ការប្រែប្រួលខ្លាំងជាមួយផលប៉ះពាល់អាក្រក់មកលើអង្គភាពបានកើតមានឡើងនៅក្នុងការិយបរិច្ឆេទ ឬត្រូវបានរំពឹងថានឹងកើតឡើងនៅពេលអនាគតដ៏ខ្លី ក្នុងទំហំ ឬឥរិយាបថ ដែលទ្រព្យសកម្មត្រូវបានប្រើ ឬត្រូវបានរំពឹងនឹងប្រើ។ ការផ្លាស់ប្តូរទាំងនេះរួមបញ្ចូលទ្រព្យសកម្មក្លាយជាទំនេរ ផែនការមិនបន្ត ឬកែប្រែ ប្រតិបត្តិការដែលទ្រព្យសកម្មត្រូវបានប្រើប្រាស់ និងផែនការជម្រុះចោលទ្រព្យសកម្មមុនកាលបរិច្ឆេទដែលបាន រំពឹងទុកពីមុន។

(ឆ) មានភ័ស្តុតាងពីការរាយការណ៍ខាងក្នុងដែលបញ្ជាក់ថាដំណើរការសេដ្ឋកិច្ចនៃទ្រព្យសកម្មមានភាពអាក្រក់ ឬនឹងអាក្រក់ជាងការរំពឹងទុក។ នៅក្នុងបរិបទនេះ ដំណើរការសេដ្ឋកិច្ចរួមបញ្ចូលលទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់។

២៧.១០ ប្រសិនបើមានសញ្ញាដែលថាទ្រព្យសកម្មថយចុះតម្លៃ នេះអាចបញ្ជាក់ថាអង្គភាពត្រូវពិនិត្យមើលឡើងវិញនូវអាយុកាលប្រើប្រាស់ដែលនៅសល់ វិធីសាស្ត្ររំលស់ ឬតម្លៃកាកសំណល់សម្រាប់ទ្រព្យសកម្ម និងកែសម្រួលដោយអនុលោមតាមផ្នែកនៃស្តង់ដារនេះដែលអនុវត្តចំពោះទ្រព្យសកម្ម (ឧទាហរណ៍ ផ្នែកទី១៧ និងផ្នែកទី១៨ ទ្រព្យសកម្មអរូបីលើកលែងកេរ្តិ៍ឈ្មោះអាជីវកម្ម) ទោះបីមិនមានការខាតពីការថយចុះតម្លៃត្រូវបានទទួលស្គាល់ចំពោះទ្រព្យសកម្មក៏ដោយ។

## ការវាស់វែងចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន

២៧.១១ ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬអង្គភាពបង្កើតសាច់ប្រាក់គឺជាតម្លៃខ្ពស់ជាងនៃ តម្លៃសមស្របដកចំណាយក្នុងការលក់ និងតម្លៃប្រើប្រាស់។ ប្រសិនបើគេមិនអាចប៉ាន់ស្មានពីចំនួនទឹកប្រាក់ ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មនីមួយៗ សេចក្តីយោងនៅកថាខណ្ឌ ២៧.១២-២៧.២០ ចំពោះ ទ្រព្យសកម្មត្រូវបានអានដោយយោងទៅអង្គភាពបង្កើតសាច់ប្រាក់របស់ទ្រព្យសកម្ម។

២៧.១២ ពុំមានភាពចាំបាច់ក្នុងការកំណត់ទាំងតម្លៃសមស្របដកចំណាយក្នុងការលក់ និងតម្លៃប្រើប្រាស់របស់ទ្រព្យសកម្ម ជារៀងរាល់ដងនោះទេ។ ប្រសិនបើចំនួនទឹកប្រាក់ណាមួយនៃតម្លៃទាំងពីរលើសតម្លៃយោងនៃទ្រព្យសកម្ម នោះទ្រព្យសកម្មមិនបានថយចុះតម្លៃទេ ហើយអង្គភាពមិនចាំបាច់ប៉ាន់ស្មានចំនួនទឹកប្រាក់ផ្សេងទៀតទេ។

២៧.១៣ ប្រសិនបើពុំមានហេតុផលដើម្បីឱ្យជឿថាតម្លៃប្រើប្រាស់នៃទ្រព្យសកម្មលើសតម្លៃសមស្របដកចំណាយក្នុង ការលក់ច្រើន នោះតម្លៃសមស្របដកចំណាយក្នុងការលក់នៃទ្រព្យសកម្មអាចត្រូវបានប្រើជាចំនួនទឹកប្រាក់ ដែលអាចប្រមូលមកវិញបានតែម្តង។ ជារឿយៗករណីនេះតែងកើតឡើងចំពោះទ្រព្យសកម្មដែលរក្សាទុកដើម្បី បញ្ចេញចោល។

## តម្លៃសមស្របដកចំណាយក្នុងការលក់

២៧.១៤ តម្លៃសមស្របដកចំណាយក្នុងការលក់ គឺជាចំនួនទឹកប្រាក់ដែលអាចទទួលបានពីការលក់ទ្រព្យសកម្ម នៅក្នុងប្រតិបត្តិការជំហោងដៃ រវាងភាគីដែលមានការយល់ដឹង និងមានបំណងលក់ ដកថ្លៃបញ្ចេញចោល (កថាខណ្ឌ ១១.២៧-១១.៣២ ផ្តល់ការណែនាំអំពីការវាស់វែងតម្លៃសមស្រប)។

## តម្លៃប្រើប្រាស់

២៧.១៥ តម្លៃប្រើប្រាស់គឺជាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគតដែលបានរំពឹងទុកនឹងត្រូវទទួលបានពីទ្រព្យសកម្ម។ ការគណនាតម្លៃបច្ចុប្បន្ននេះទាក់ទិននឹងដំណាក់កាលខាងក្រោមៈ

(ក) ការប៉ាន់ស្មានលំហូរសាច់ប្រាក់ចូលនិងចេញនាពេលអនាគតដែលនឹងត្រូវទទួលបានពីការបន្តប្រើប្រាស់ទ្រព្យសកម្ម និងពីការបញ្ចេញចោលចុងក្រោយ និង

(ខ) អនុវត្តអត្រាអប្បហារសមស្របចំពោះលំហូរសាច់ប្រាក់អនាគតទាំងនោះ។

២៧.១៦ ធាតុខាងក្រោមត្រូវបានឆ្លុះបញ្ចាំងក្នុងការគណនាតម្លៃប្រើប្រាស់នៃទ្រព្យសកម្មៈ

(ក) ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់អនាគតដែលអង្គភាពរំពឹងថានឹងទទួលបានពីទ្រព្យសកម្ម

(ខ) ការរំពឹងទុកពីការប្រែប្រួលដែលអាចកើតមានឡើងជាចំនួនទឹកប្រាក់ ឬពេលវេលានៃលំហូរសាច់ប្រាក់អនាគតទាំងនោះ។

(គ) តម្លៃពេលវេលានៃសាច់ប្រាក់ ដែលតំណាងដោយអត្រាការប្រាក់ទីផ្សារបច្ចុប្បន្នដែលគ្មានហានិភ័យ

(ឃ) តម្លៃសម្រាប់ប្រកាន់ខ្ជាប់នូវភាពមិនប្រាកដប្រជាដែលមានចំពោះទ្រព្យសកម្ម

(ង) កត្តាផ្សេងទៀត ដូចជាភាពមិនអាចប្តូរជាសាច់ប្រាក់ ដែលអ្នកចូលរួមទីផ្សារគួរឆ្លុះបញ្ចាំងក្នុងការកំណត់តម្លៃលំហូរសាច់ប្រាក់អនាគត ដែលអង្គភាពរំពឹងថានឹងទទួលបានពីទ្រព្យសកម្ម។

២៧.១៧ នៅក្នុងការវាស់វែងតម្លៃប្រើប្រាស់ ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់អនាគតត្រូវរួមបញ្ចូលៈ

(ក) ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់ចូលពីការបន្តប្រើប្រាស់ទ្រព្យសកម្ម។

(ខ) ការប៉ាន់ស្មានលំហូរសាច់ប្រាក់ចេញដែលកើតឡើងជាចាំបាច់ដើម្បីបង្កើតលំហូរសាច់ប្រាក់ចូលពីការបន្តប្រើប្រាស់ទ្រព្យសកម្ម (រួមបញ្ចូលលំហូរសាច់ប្រាក់ចេញដើម្បីរៀបចំទ្រព្យសកម្មសម្រាប់ប្រើប្រាស់) ហើយដែល អាចបង្កដោយផ្ទាល់ ឬត្រូវបែងចែកដោយឈរលើមូលដ្ឋានសមស្របនិងសង្គតិភាព ចំពោះទ្រព្យសកម្ម។

(គ) លំហូរសាច់ប្រាក់សុទ្ធ ប្រសិនបើមាន ដែលត្រូវបានរំពឹងថានឹងទទួលបាន (ឬបង់) សម្រាប់ការបញ្ចេញចោលទ្រព្យសកម្មនៅចុងអាយុកាលប្រើប្រាស់របស់វាក្នុងប្រតិបត្តិការជំហោងដៃរវាងភាគីដែលមានការយល់ដឹង និងមានបំណងលក់។

ប្រសិនបើមាន អង្គភាពអាចប្រើប្រាស់នូវគម្រោងផែនការហិរញ្ញវត្ថុ ឬការព្យាករណ៍ហិរញ្ញវត្ថុដើម្បីប៉ាន់ស្មានលំហូរសាច់ប្រាក់។ ដើម្បីប៉ាន់ស្មានគម្រោងលំហូរសាច់ប្រាក់ក្រោយរយៈពេលដែលបានគ្របដណ្តប់ដោយគម្រោង ឬការព្យាករណ៍ថ្មីៗបំផុត អង្គភាពអាចធ្វើការប៉ាន់ស្មានបន្ថែមដោយផ្អែកលើគម្រោង ឬ ការព្យាករណ៍ ដោយប្រើអត្រាកំណើនថេរ ឬថយចុះសម្រាប់ឆ្នាំបន្តបន្ទាប់ លើកលែងតែអត្រាកើនឡើងអាច បង្ហាញពីភាពត្រឹមត្រូវ។

២៧.១៨ ការព្យាករណ៍លំហូរសាច់ប្រាក់មិនត្រូវបញ្ចូលៈ

(ក) លំហូរសាច់ប្រាក់ចូល ឬចេញ ពីសកម្មភាពហិរញ្ញប្បទាន ឬ

(ខ) ចំណូល ឬចំណាយពន្ធលើប្រាក់ចំណូល

២៧.១៩ លំហូរសាច់ប្រាក់អនាគតត្រូវបានព្យាករសម្រាប់ទ្រព្យសកម្មនៅក្នុងស្ថានភាពបច្ចុប្បន្ន។ ការព្យាករណ៍នៃលំហូរសាច់ប្រាក់អនាគតមិនត្រូវបានបញ្ចូលលំហូរសាច់ប្រាក់ចូល ឬចេញដែលត្រូវបានរំពឹងថានឹងកើតមានឡើងដោយសារៈ

(ក) ការរុះរើនាពេលអនាគតដែលអង្គភាពមិនទាន់មានការតាំងចិត្ត ឬ

(ខ) ការធ្វើឱ្យប្រសើរ ឬការបង្កើនលទ្ធផលរបស់ទ្រព្យសកម្ម។

២៧.២០ អត្រាអប្បហារដែលត្រូវបានប្រើក្នុងការគណនាតម្លៃបច្ចុប្បន្ន ត្រូវតែជាអត្រាមុនការបង់ពន្ធដែលឆ្លុះបញ្ចាំងពីការវាយតម្លៃបច្ចុប្បន្ននៃៈ

(ក) តម្លៃពេលវេលានៃសាច់ប្រាក់ និង

(ខ) ហានិភ័យជាក់លាក់ចំពោះទ្រព្យសកម្មដែលការព្យាករណ៍ពីលំហូរសាច់ប្រាក់អនាគតមិនត្រូវបានកែសម្រួល។ អត្រាអប្បហារដែលបានប្រើដើម្បីវាស់វែងតម្លៃប្រើប្រាស់នៃទ្រព្យសកម្មមិនត្រូវឆ្លុះបញ្ចាំងពីហានិភ័យដែលការព្យាករណ៍លំហូរសាច់ប្រាក់អនាគតត្រូវបានកែសម្រួល ដើម្បីជៀសវាងការរាប់ទ្វេដង។ការទទួលស្គាល់ និងការវាស់វែងការខាតពីការថយចុះតម្លៃសម្រាប់អង្គភាពបង្កើតសាច់ប្រាក់

២៧.២១ ការខាតពីការថយចុះតម្លៃត្រូវបានទទួលស្គាល់សម្រាប់អង្គភាពបង្កើតសាច់ប្រាក់ ប្រសិនបើចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃអង្គភាពតិចជាងតម្លៃយោងនៃអង្គភាព។ ការខាតពីការថយចុះតម្លៃត្រូវបានបែងចែកដើម្បីកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មនៃអង្គភាព តាមលំដាប់លំដោយដូចខាងក្រោមៈ

(ក) ដំបូង ត្រូវកាត់បន្ថយតម្លៃយោងនៃកេរ្តិ៍ឈ្មោះអាជីវកម្មដែលបានបែងចែកទៅអង្គភាពបង្កើតសាច់ប្រាក់ និង

(ខ) បែងចែកទៅទ្រព្យសកម្មផ្សេងទៀតនៃអង្គភាពតាមសមាមាត្រដោយផ្អែកលើមូលដ្ឋាននៃតម្លៃយោងនៃទ្រព្យសកម្មនីមួយៗ នៅក្នុងអង្គភាពបង្កើតសាច់ប្រាក់។

២៧.២២ ប៉ុន្តែអង្គភាពមិនត្រូវកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មណាមួយនៅក្នុងអង្គភាពបង្កើតសាច់ប្រាក់ខាងក្រោមតម្លៃខ្ពស់បំផុតនៃៈ

(ក) តម្លៃសមស្របដកចំណាយក្នុងការលក់ (ប្រសិនអាចកំណត់បាន)

(ខ) តម្លៃប្រើប្រាស់ (ប្រសិនអាចកំណត់បាន) និង

(គ) សូន្យ។

២៧.២៣ ចំនួនទឹកប្រាក់ដែលលើសនៃការខាតពីការថយចុះតម្លៃ ដែលមិនអាចត្រូវបានបែងចែកទៅទ្រព្យសកម្មដោយសារតែការហាមឃាត់នៅក្នុងកថាខណ្ឌ២៧.២២ ត្រូវបានបែងចែកទៅទ្រព្យសកម្មផ្សេងទៀត នៃអង្គភាពតាមសមាមាត្រមូលដ្ឋាននៃតម្លៃយោងនៃទ្រព្យសកម្មផ្សេងទៀតទាំងនោះ។

## ការតម្រូវបន្ថែមសម្រាប់ការថយចុះតម្លៃនៃកេរ្តិ៍ឈ្មោះអាជីវកម្ម

២៧.២៤ កេរ្តិ៍ឈ្មោះអាជីវកម្មមិនអាចត្រូវបានលក់ដោយខ្លួនឯងបានទេ។ កេរ្តិ៍ឈ្មោះអាជីវកម្មក៏មិនបានបង្កើតលំហូរសាច់ប្រាក់ មកឱ្យអង្គភាពដែលមានឯករាជ្យភាពពីលំហូរសាច់ប្រាក់នៃទ្រព្យសកម្មផ្សេងទៀត។ ជាលទ្ធផល តម្លៃសមស្របនៃកេរ្តិ៍ឈ្មោះអាជីវកម្មមិនអាចត្រូវបានវាស់វែងដោយផ្ទាល់។ ដូច្នេះ តម្លៃសមស្របនៃកេរ្តិ៍ឈ្មោះ អាជីវកម្មត្រូវកើតចេញពីការវាស់វែងតម្លៃសមស្របនៃអង្គភាពបង្កើតសាច់ប្រាក់ ដែលមានកេរ្តិ៍ឈ្មោះអាជីវកម្ម ជាផ្នែកមួយ។

២៧.២៥ សម្រាប់គោលបំណងនៃការធ្វើតេស្តពីការថយចុះតម្លៃ កេរ្តិ៍ឈ្មោះអាជីវកម្មដែលបានទិញក្នុងការរួមបញ្ចូល អាជីវកម្មចាប់ពីថ្ងៃទិញមកត្រូវបានបែងចែកទៅអង្គភាពបង្កើតសាច់ប្រាក់នីមួយៗរបស់អ្នកទិញ ដែលរំពឹង ថានឹងទទួលបានអត្ថប្រយោជន៍ពីផលនៃការរួមបញ្ចូល មិនថាទ្រព្យសកម្មឬបំណុលទាំងនោះរបស់អ្នកលក់ ត្រូវបានកំណត់ចំពោះអង្គភាពទាំងនោះនោះទេ។

២៧.២៦ ផ្នែកមួយនៃចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញ បាននៃអង្គភាពបង្កើតសាច់ប្រាក់គឺជាភាគកម្មមិនគ្រប់គ្រងនៅក្នុងកេរ្តិ៍ឈ្មោះអាជីវកម្ម។ សម្រាប់គោលបំណងនៃការធ្វើតេស្តពីការថយចុះតម្លៃ អង្គភាពបង្កើតសាច់ប្រាក់ ដែលមិនមែនជាកម្មសិទ្ធិទាំងស្រុងហើយដែលមានភ្ជាប់ជាមួយនូវកេរ្តិ៍ឈ្មោះអាជីវកម្ម តម្លៃយោងនៃអង្គភាពនោះ ត្រូវបានកែសម្រួលជាសញ្ញាណ មុនពេលធ្វើការប្រៀបធៀបជាមួយនឹងចំនួនទឹកប្រាក់ដែលអាចប្រមូលមក វិញបានដោយការបង្កើននូវតម្លៃយោងនៃកេរ្តិ៍ឈ្មោះអាជីវកម្មដែលបានបែងចែកទៅឱ្យអង្គភាព ដើម្បីរាប់បញ្ចូល នូវកេរ្តិ៍ឈ្មោះអាជីវកម្មដែលត្រូវបែងចែកទៅឱ្យភាគកម្មមិនគ្រប់គ្រង។ តម្លៃយោងដែលបានកែសម្រួលជា សញ្ញាណនេះ ត្រូវបានប្រៀបធៀបជាមួយចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃអង្គភាព ដើម្បីកំណត់ ថាតើអង្គភាពបង្កើតសាច់ប្រាក់ត្រូវបានថយចុះតម្លៃឬទេ។

២៧.២៧ ប្រសិនបើកេរ្តិ៍ឈ្មោះអាជីវកម្មមិនអាចបែងចែកទៅអង្គភាពបង្កើតសាច់ប្រាក់នីមួយៗទេ (ឬក្រុមនៃអង្គភាពបង្កើតសាច់ប្រាក់) តាមមូលដ្ឋានស្មើភាព ដូច្នេះសម្រាប់គោលបំណងនៃការធ្វើតេស្តកេរ្តិ៍ឈ្មោះអាជីវកម្ម អង្គភាពត្រូវធ្វើតេស្តការថយចុះតម្លៃនៃកេរ្តិ៍ឈ្មោះអាជីវកម្ម ដោយកំណត់ពីចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញនៃៈ

(ក) អង្គភាពដែលបានទិញទាំងស្រុង ប្រសិនកេរ្តិ៍ឈ្មោះអាជីវកម្មទាក់ទងនឹងអង្គភាពដែលបានទិញ និងមិនទាន់ត្រូវបានបញ្ចូលគ្នា (បញ្ចូលគ្នា មានន័យថាអាជីវកម្មដែលបានទិញត្រូវបានរៀបចំឡើងវិញ ឬត្រូវបានរំលាយចូល ទៅក្នុងអង្គភាពរាយការណ៍ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងទៀត) ឬ

(ខ) ក្រុមអង្គភាពទាំងមូល ដោយមិនបញ្ចូលអង្គភាពណាដែលមិនត្រូវបានបញ្ចូលគ្នា ប្រសិនកេរ្តិ៍ឈ្មោះអាជីវកម្មទាក់ទងនឹងអង្គភាពត្រូវបានបញ្ចូលគ្នា។

នៅក្នុងការអនុវត្តកថាខណ្ឌនេះ អង្គភាពនឹងត្រូវបំបែកកេរ្តិ៍ឈ្មោះអាជីវកម្មទៅជាកេរ្តិ៍ឈ្មោះអាជីវកម្ម ដែលទាក់ទង នឹងអង្គភាពទាំងឡាយណាដែលត្រូវបានបញ្ចូលគ្នា និងកេរ្តិ៍ឈ្មោះអាជីវកម្មដែលទាក់ទងនឹងអង្គភាពដែលមិន ទាន់ត្រូវបានបញ្ចូលគ្នា។ ជាមួយគ្នានេះដែរ អង្គភាពក៏ត្រូវអនុវត្តតាមការតម្រូវសម្រាប់អង្គភាពបង្កើតសាច់ប្រាក់ នៅក្នុងផ្នែកនេះ នៅពេលគណនាចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន និង

បែងចែកការខាតពីការថយចុះ តម្លៃ និងការបង្វិលត្រឡប់មកវិញនៃទ្រព្យសកម្ម របស់អង្គភាពដែលបានទិញ ឬក្រុមអង្គភាព។

## ការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃ

២៧.២៨ ការខាតពីការថយចុះតម្លៃ ដែលបានទទួលស្គាល់សម្រាប់កេរ្តិ៍ឈ្មោះអាជីវកម្មមិនត្រូវបង្វិលត្រឡប់មកវិញ នៅក្នុងការិយបរិច្ឆេទបន្ទាប់នោះទេ។

២៧.២៩ សម្រាប់គ្រប់ទ្រព្យសកម្មទាំងអស់ក្រៅពីកេរ្តិ៍ឈ្មោះអាជីវកម្ម អង្គភាពត្រូវវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍ នីមួយៗ ថាតើមានសញ្ញាដែលការខាតពីការថយចុះតម្លៃដែលបានទទួលស្គាល់នៅក្នុងគ្រាមុនអាចមិនកើតមានតទៅទៀតដែរឬទេ ឬអាចថយចុះ។ សញ្ញាដែលការថយចុះតម្លៃបានថយចុះ ឬមិនកើតមានតទៅទៀត ជាទូទៅគឺជាភាពផ្ទុយនៃអ្វីដែលបានកំណត់នៅក្នុងកថាខណ្ឌ ២៧.៩។ ប្រសិនបើមានសញ្ញាណាមួយកើតឡើង អង្គភាពត្រូវកំណត់ថាតើការខាតពីការថយចុះតម្លៃមួយផ្នែកឬទាំងអស់កាលពីពេលមុនត្រូវបានបង្វិលត្រឡប់មកវិញ។ នីតិវិធីសម្រាប់ការកំណត់នោះ នឹងត្រូវផ្អែកលើថាតើការខាតពីការថយចុះតម្លៃពីមុនលើតម្លៃទ្រព្យសកម្មត្រូវបានពឹងផ្អែកលើ៖

(ក) ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មនីមួយៗនោះ (សូមមើលកថាខណ្ឌ ២៧.៣០) ឬ

(ខ) ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃអង្គភាពបង្កើតសាច់ប្រាក់ដែលទ្រព្យសកម្មស្ថិតនៅ (សូមមើលកថាខណ្ឌ ២៧.៣១)។

ការបង្វិលត្រឡប់មកវិញនៅពេល ដែលចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបានត្រូវបានប៉ាន់ស្មាន សម្រាប់ទ្រព្យសកម្មដែលបានថយចុះតម្លៃនីមួយៗ

២៧.៣០ នៅពេលការខាតពីការថយចុះតម្លៃគ្រាមុនត្រូវបានពឹងផ្អែកលើចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មដែលបានថយចុះតម្លៃនីមួយៗ ការតម្រូវខាងក្រោមត្រូវបានអនុវត្ត:

(ក) អង្គភាពត្រូវប៉ាន់ស្មានពីចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម នាកាលបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ។

(ខ) ប្រសិនបើចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបានប៉ាន់ស្មាន នៃទ្រព្យសកម្មលើសតម្លៃយោងរបស់វា អង្គភាពត្រូវបង្កើនតម្លៃយោង ទៅស្មើនឹងចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន ដោយអាស្រ័យលើ ការកម្រិតដែលរៀបរាប់ក្នុងចំណុច (គ) ផងដែរ។ ការកើនឡើងនោះគឺជាការបង្វិលត្រឡប់មកវិញនៃការខាតពី ការថយចុះតម្លៃ។ អង្គភាពត្រូវទទួលស្គាល់ការបង្វិលត្រឡប់មកវិញភ្លាមនៅក្នុងចំណេញ ឬខាត វៀរលែងតែ ទ្រព្យសកម្មនោះ ត្រូវបានកត់ត្រាតាមចំនួនទឹកប្រាក់ដែលបានវាយតម្លៃឡើងវិញ ស្របតាមគំរូវាយតម្លៃឡើងវិញ ក្នុងកថាខណ្ឌ១៧.១៥ខ។ ការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃនៃទ្រព្យសកម្មដែលបាន វាយតម្លៃឡើងវិញ ត្រូវចាត់ទុកជាការកើនឡើងការវាយតម្លៃឡើងវិញស្របតាមកថាខណ្ឌ១៧.១៥គ។

(គ) ការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃ មិនត្រូវបង្កើនតម្លៃយោងនៃទ្រព្យសកម្មលើសពីតម្លៃយោងដែលនឹងបានកំណត់ (កាត់កងនឹងរំលស់) ប្រសិនបើពុំមានការខាតពីការថយចុះតម្លៃត្រូវបានទទួលស្គាល់ សម្រាប់ទ្រព្យសកម្មនៅក្នុងឆ្នាំមុនៗ។

(ឃ) បន្ទាប់ពីការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃត្រូវបានទទួលស្គាល់ អង្គភាពត្រូវកែសម្រួលចំណាយរំលស់សម្រាប់ទ្រព្យសកម្មនៅគ្រាខាងមុខដើម្បីបែងចែកតម្លៃយោងកែរួចនៃទ្រព្យសកម្ម ដកចេញនូវតម្លៃកាកសំណល់ (ប្រសិនបើមាន) តាមមូលដ្ឋានជាប្រព័ន្ធលើអាយុកាលដែលនៅសល់។

ការបង្វិលត្រឡប់មកវិញនៅពេលដែលចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបានត្រូវបានប៉ាន់ស្មានសម្រាប់អង្គភាពបង្កើតសាច់ប្រាក់

២៧.៣១ នៅពេលដែលការខាតពីការថយចុះតម្លៃពេលដំបូងបានពឹងផ្អែកលើចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃអង្គភាពបង្កើតសាច់ប្រាក់ដែលទ្រព្យសកម្មស្ថិតនៅ ការតម្រូវខាងក្រោមត្រូវបានអនុវត្តៈ

(ក) អង្គភាពត្រូវប៉ាន់ស្មានពីចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃអង្គភាពបង្កើតសាច់ប្រាក់នោះនាកាលបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ។

(ខ) ប្រសិនបើចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបានប៉ាន់ស្មាន នៃអង្គភាពបង្កើតសាច់ប្រាក់ លើសពី តម្លៃយោងរបស់វា ចំណែកលើសនោះគឺជាការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃ។ អង្គភាពត្រូវបែងចែកចំនួនទឹកប្រាក់នៃការបង្វិលត្រឡប់មកវិញនោះទៅទ្រព្យសកម្មនៃអង្គភាព លើកលែងតែ កេរ្តិ៍ឈ្មោះអាជីវកម្ម សមាមាត្រជាមួយនឹងតម្លៃយោងនៃទ្រព្យសកម្មទាំងនោះ ដោយអាស្រ័យលើការកម្រិតដែលរៀបរាប់ នៅក្នុងចំណុច (គ) ផងដែរ។ ការកើនឡើងទាំងនោះនៅក្នុងតម្លៃយោង ត្រូវចាត់ទុកជាការបង្វិលត្រឡប់ មកវិញនៃការខាតពីការថយចុះតម្លៃសម្រាប់ទ្រព្យសកម្មនីមួយៗ ហើយត្រូវទទួលស្គាល់ភ្លាមនៅក្នុងចំណាយ ឬខាត វៀរលែងតែទ្រព្យសកម្មនោះ ត្រូវបានកត់ត្រាតាមចំនួនទឹកប្រាក់ដែលបានវាយតម្លៃឡើងវិញស្របតាម គំរូវាយតម្លៃឡើងវិញ ក្នុងកថាខណ្ឌ១៧.១៥ខ។ ការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃ នៃទ្រព្យ សកម្មដែលបានវាយតម្លៃឡើងវិញ ត្រូវចាត់ទុកជាការកើនឡើងការវាយតម្លៃស្របតាមកថាខណ្ឌ១៧.១៥គ។

(គ) នៅក្នុងការបែងចែកការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃសម្រាប់អង្គភាពបង្កើតសាច់ប្រាក់ ការបង្វិលត្រឡប់មកវិញមិនត្រូវបង្កើនតម្លៃយោងនៃទ្រព្យសកម្មណាលើសតម្លៃទាបជាងនេះ:

(១) ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញរបស់វា និង

(២) តម្លៃយោងដែលនឹងបានកំណត់ (កាត់កងនឹងរំលស់) ប្រសិនបើពុំមានការខាតពីការថយចុះតម្លៃ ត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មនៅក្នុងគ្រាមុនៗ។

(ឃ) ចំណែកលើសនៃចំនួនទឹកប្រាក់នៃការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃ ដែលមិនអាចបែងចែកទៅទ្រព្យសកម្មបានដោយសារការហាមឃាត់នៅក្នុង (គ) ត្រូវបានបែងចែកតាមសមាមាត្រទៅទ្រព្យសកម្មផ្សេងៗនៃអង្គភាពបង្កើតសាច់ប្រាក់ លើកលែងតែកេរ្តិ៍ឈ្មោះអាជីវកម្ម។

(ង) បន្ទាប់ពីការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃត្រូវបានទទួលស្គាល់ ប្រសិនបើអាចអនុវត្តបាន អង្គភាពត្រូវកែសម្រួលចំណាយរំលស់សម្រាប់ទ្រព្យសកម្មនីមួយៗនៅក្នុងអង្គភាពបង្កើតសាច់ប្រាក់ក្នុងគ្រាអនាគត ដើម្បីបែងចែកតម្លៃយោងដែលបានកែប្រែនៃទ្រព្យសកម្ម ដកចេញនូវតម្លៃកាកសំណល់ (ប្រសិនបើមាន) តាមមូលដ្ឋានជាប្រព័ន្ធលើអាយុកាលដែលនៅសល់។

## ការលាតត្រដាង

២៧.៣២ អង្គភាពត្រូវលាតត្រដាងព័ត៌មានខាងក្រោមសម្រាប់ថ្នាក់ទ្រព្យសកម្មនីមួយៗដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ២៧.៣៣ ៖

(ក) ចំនួនទឹកប្រាក់នៃការខាតពីការថយចុះតម្លៃដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតក្នុងគ្រា និងជាតុគណនីនៅក្នុងរបាយការណ៍ចំណូលពេញលេញ (និងក្នុងរបាយការណ៍លទ្ធផល ប្រសិនបើត្រូវបានបង្ហាញ) ដែលការខាតពីការថយចុះតម្លៃទាំងនោះត្រូវបានរួមបញ្ចូល។

(ខ) ចំនួនទឹកប្រាក់នៃការបង្វិលត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតក្នុងគ្រានិងជាតុគណនីនៅក្នុងរបាយការណ៍ចំណូលពេញលេញ (និងក្នុងរបាយការណ៍លទ្ធផល ប្រសិនបើត្រូវបានបង្ហាញ) ដែលការខាតពីការថយចុះតម្លៃទាំងនោះត្រូវបានបង្វិលត្រឡប់មកវិញ។

២៧.៣៣ អង្គភាពត្រូវលាតត្រដាងព័ត៌មានដែលបានតម្រូវដោយកថាខណ្ឌ ២៧.៣២ សម្រាប់ថ្នាក់ទ្រព្យសកម្មនីមួយៗខាងក្រោម៖

(ក) សន្និធិ

(ខ) ទ្រព្យ រោងចក្រ និងបរិក្ខារ (រួមបញ្ចូលទ្រព្យវិនិយោគ ដែលបានទទួលស្គាល់តាមវិធីសាស្រ្តថ្លៃដើម)

(គ) កេរ្តិ៍ឈ្មោះអាជីវកម្ម

(ឃ) ទ្រព្យសកម្មអរូបី ក្រៅពីកេរ្តិ៍ឈ្មោះអាជីវកម្ម

(ង) ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ

(ច) ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន។

# ផ្នែកទី ២៨
# អត្ថប្រយោជន៍និយោជិត

## វិសាលភាពនៃផ្នែកនេះ

២៨.១ អត្ថប្រយោជន៍និយោជិតគឺជាទម្រង់ទាំងអស់នៃតម្លៃតបស្នង ដែលបានផ្តល់ដោយអង្គភាពក្នុងការដោះដូរសេវាកម្ម ដែលបានផ្តល់ដោយនិយោជិតរួមបញ្ចូលទាំងនាយកនិងថ្នាក់គ្រប់គ្រង។ ផ្នែកនេះអនុវត្តចំពោះអត្ថប្រយោជន៍និយោជិតទាំងអស់ លើកលែងតែប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុន ដែលគ្រប់ដណ្តប់ដោយផ្នែកទី២៦ ស្តីពីការទូទាត់ដោយផ្អែកលើភាគហ៊ុន។ អត្ថប្រយោជន៍និយោជិតដែលគ្រប់ដណ្តប់ដោយផ្នែកនេះ នឹងជាប្រភេទមួយក្នុងចំណោមប្រភេទទាំង៤ខាងក្រោម៖

(ក) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីដែលជាអត្ថប្រយោជន៍និយោជិត (ក្រៅពី អត្ថប្រយោជន៍ពេលបញ្ឈប់) ដែលដល់ពេលត្រូវសងក្នុងរយៈពេល១២ខែបន្ទាប់ពីចុងគ្រាដែលនិយោជិតផ្តល់សេវាកម្មដែលពាក់ព័ន្ធ

(ខ) អត្ថប្រយោជន៍ក្រោយបំពេញការងារ ដែលជាអត្ថប្រយោជន៍និយោជិត (ក្រៅពី អត្ថប្រយោជន៍ពេលបញ្ឈប់) ដែលត្រូវសងបន្ទាប់ពីការបញ្ចប់ការងារ

(គ) អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងទៀត ដែលជាអត្ថប្រយោជន៍និយោជិត (ក្រៅពីអត្ថប្រយោជន៍ក្រោយបំពេញការងារ និងអត្ថប្រយោជន៍ពេលបញ្ឈប់) ដែលមិនទាន់ដល់ពេលសងទាំងស្រុងក្នុងរយៈពេល១២ខែ បន្ទាប់ពីចុងគ្រាដែលនិយោជិតផ្តល់សេវាកម្មដែលពាក់ព័ន្ធ និង

(ឃ) អត្ថប្រយោជន៍ពេលបញ្ឈប់ ដែលជាអត្ថប្រយោជន៍និយោជិតត្រូវសងដែលកើតចេញពី មូលហេតុណាមួយដូចខាងក្រោម៖

(១) ការសម្រេចចិត្តរបស់អង្គភាពដោយបញ្ឈប់ការងាររបស់និយោជិតមុនពេលចូលនិវត្តន៍ធម្មតា ឬ

(២) ការសម្រេចចិត្តរបស់និយោជិត ដោយទទួលយកការកាត់បន្ថយបុគ្គលិកដោយស្ម័គ្រចិត្ត ក្នុងការដោះដូរសម្រាប់អត្ថប្រយោជន៍ទាំងនោះ។

២៨.២ អត្ថប្រយោជន៍និយោជិតរួមបញ្ចូលផងដែរនូវប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុនដែលនិយោជិតទទួលឧបករណ៍មូលធន (ដូចជា ភាគហ៊ុនឬសិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់) ឬសាច់ប្រាក់ ឬទ្រព្យសកម្មផ្សេងទៀតរបស់អង្គភាពជាចំនួនទឹកប្រាក់ដែលផ្អែកលើតម្លៃនៃភាគហ៊ុនរបស់អង្គភាពឬ ឧបករណ៍មូលធនផ្សេងទៀតរបស់អង្គភាព។ អង្គភាពត្រូវអនុវត្តផ្នែកទី២៦ ក្នុងការធ្វើគណនេយ្យកម្មសម្រាប់ ប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុន។

## គោលការណ៍ទទួលស្គាល់ជាទូទៅសម្រាប់អត្ថប្រយោជន៍និយោជិតទាំងអស់

២៨.៣ អង្គភាពត្រូវទទួលស្គាល់ថ្លៃដើមនៃអត្ថប្រយោជន៍និយោជិតទាំងអស់ ដែលនិយោជិតរបស់ខ្លួនបានសិទ្ធិក្នុងការទទួលជាលទ្ធផលនៃសេវាកម្មដែលបានផ្តល់ទៅឱ្យអង្គភាពក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍៖

(ក) ចាត់ទុកជាបំណុល បន្ទាប់ពីការដកចេញចំនួនទឹកប្រាក់ដែលបានបង់ហើយដោយផ្ទាល់ទៅឱ្យនិយោជិត ឬ ជាវិភាគទានទៅឱ្យមូលនិធិអត្ថប្រយោជន៍និយោជិត។ ប្រសិនបើចំនួនទឹកប្រាក់ដែលបានបង់ លើសពីកាតព្វកិច្ចដែលកើតចេញពីសេវាកម្មមុនពេលកាលបរិច្ឆេទរាយការណ៍ អង្គភាពត្រូវទទួលស្គាល់ផ្នែកលើសជាទ្រព្យសកម្មក្នុងវិសាលភាពដែលការបង់មុននឹងនាំដល់ការកាត់បន្ថយក្នុងការទូទាត់នាពេលអនាគត ឬការបង្វិលសងសាច់ប្រាក់។

(ខ) ចាត់ទុកជាចំណាយ លុះត្រាតែផ្នែកផ្សេងទៀតនៃស្តង់ដារនេះតម្រូវឱ្យថ្លៃដើមនោះត្រូវបានទទួលស្គាល់ជាផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្ម ដូចជាសន្និធិ ឬ ទ្រព្យ រោងចក្រ និង បរិក្ខារ។

## អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

### ឧទាហរណ៍

២៨.៤ អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីជាទូទៅរួមបញ្ចូលធាតុដូចជា៖

(ក) ប្រាក់ឈ្នួល ប្រាក់ខែ និង វិភាគទានសម្រាប់សុវត្ថិភាពសង្គម

(ខ) ការអវត្តមានមានតម្លៃតបស្នងរយៈពេលខ្លី (ដូចជា ការឈប់ប្រចាំឆ្នាំមានប្រាក់ខែ និង ការឈប់ពេលឈឺមានប្រាក់ខែ) ពេលដែលភាពអវត្តមានត្រូវបានរំពឹងថានឹងកើតមានឡើងក្នុងរយៈពេល១២ ខែ បន្ទាប់ពីចុងគ្រាដែលនិយោជិតផ្តល់សេវាកម្មនិយោជិតដែលពាក់ព័ន្ធ

(គ) ការចែកប្រាក់ចំណេញនិងប្រាក់បន្ថែមត្រូវសងនៅក្នុងរយៈពេល១២ខែ បន្ទាប់ពីចុងគ្រាដែលនិយោជិតផ្តល់សេវាកម្មដែលពាក់ព័ន្ធ និង

(ឃ) អត្ថប្រយោជន៍មិនមែនរូបិយវត្ថុ (ដូចជា ការថែទាំវេជ្ជសាស្ត្រ លំនៅដ្ឋាន រថយន្ត និង ទំនិញឬសេវាកម្មឥតគិតកម្រៃឬបានឧបត្ថម្ភធន) សម្រាប់និយោជិតបច្ចុប្បន្ន។

## ការវាស់វែងជាទូទៅនៃអត្ថប្រយោជន៍រយៈពេលខ្លី

២៨.៥ ពេលនិយោជិតបានផ្តល់សេវាកម្មទៅឱ្យអង្គភាពក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ អង្គភាពត្រូវវាស់វែងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ ដោយអនុលោមតាមកថាខណ្ឌ ២៨.៣ តាមតម្លៃមិនទាន់ធ្វើអប្បហារនៃអត្ថប្រយោជន៍និយោជិតរយៈពេលខ្លីដែលត្រូវបានរំពឹងថានឹងសងក្នុងការដោះដូរសេវាកម្មនោះ។

## ការទទួលស្គាល់ និង ការវាស់វែង - ការអវត្តមានមានតម្លៃតបស្នងរយៈពេលខ្លី

២៨.៦ អង្គភាពអាចតបស្នងនិយោជិតចំពោះអវត្តមានដែលមានហេតុផលផ្សេងៗ រួមមាន ការឈប់វិស្សមកាលប្រចាំឆ្នាំ និងការឈប់ពេលឈឺ។ ការអវត្តមានមានតម្លៃតបស្នងរយៈពេលខ្លីខ្លះបង្គរ - អត្ថប្រយោជន៍អាចត្រូវបានលើកទៅមុខ និងប្រើក្នុងគ្រាខាងមុខ ប្រសិនបើនិយោជិតនោះមិនប្រើសិទ្ធិទទួលបានសម្រាប់គ្រាបច្ចុប្បន្នទាំងស្រុងទេ។ ឧទាហរណ៍ រួមមានការឈប់វិស្សមកាលប្រចាំឆ្នាំ និងការឈប់ពេលឈឺ។ អង្គភាពត្រូវទទួលស្គាល់ថ្លៃដើមនៃការអវត្តមានមានតម្លៃតបស្នងបង្គរ នៅពេលដែលនិយោជិតផ្តល់សេវាកម្ម ដែលបង្កើនសិទ្ធិទទួលបានរបស់ពួកគេ ទៅការអវត្តមានមានតម្លៃតបស្នងនាអនាគត។ អង្គភាពត្រូវវាស់វែងថ្លៃដើមរំពឹងទុកនៃការអវត្តមានមានតម្លៃតបសង

បង្គរ តាមចំនួនទឹកប្រាក់បន្ថែមមិនទាន់ធ្វើអប្បហារដែលអង្គភាពរំពឹងថានឹងទូទាត់ជាលទ្ធផលនៃសិទ្ធិទទួលបានមិនបានប្រើ ដែលបានបង្គរនៅចុងការិយបរិច្ឆេទរាយការណ៍។ អង្គភាពត្រូវបង្ហាញចំនួនទឹកប្រាក់នេះ ជាបំណុលរយៈពេលខ្លីនៅកាលបរិច្ឆេទរាយការណ៍។

២៨.៧ អង្គភាពត្រូវទទួលស្គាល់ថ្លៃដើមនៃការអវត្តមានមានតម្លៃតបស្នង (មិនបង្គរ) ផ្សេងទៀត ពេលអវត្តមាននោះកើតឡើង។ អង្គភាពត្រូវវាស់វែងថ្លៃដើមនៃការអវត្តមានមានតម្លៃតបស្នងមិនបង្គរ តាមចំនួនទឹកប្រាក់មិនទាន់ធ្វើអប្បហារនៃប្រាក់ខែ និងប្រាក់ឈ្នួលបានបង់ឬត្រូវសង ឬ បំណុលសម្រាប់គ្រាអវត្តមាន។

### ការទទួលស្គាល់ - ផែនការការចែកប្រាក់ចំណេញ និងប្រាក់បន្ថែម

២៨.៨ អង្គភាពត្រូវទទួលស្គាល់ថ្លៃដើមរំពឹងទុកនៃការចែកប្រាក់ចំណេញនិងប្រាក់បន្ថែម តែនៅពេលៈ

(ក) អង្គភាពមានកាតព្វកិច្ចស្របច្បាប់ឬកាតព្វកិច្ចដោយសន្មតបច្ចុប្បន្នក្នុងការធ្វើការទូទាត់បែបនេះ ជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាល (នេះមានន័យថា អង្គភាពមិនមានជម្រើសប្រាកដប្រជា ក្រៅពីធ្វើការទូទាត់) និង

(ខ) អាចធ្វើការប៉ាន់ស្មានដ៏ជឿជាក់ទៅលើកាតព្វកិច្ចនោះ។

## អត្ថប្រយោជន៍ក្រោយបំពេញការងារៈ ភាពខុសគ្នារវាងផែនការវិភាគទានកំណត់ និង ផែនការអត្ថប្រយោជន៍ កំណត់

២៨.៩ អត្ថប្រយោជន៍ក្រោយបំពេញការងារ រួមមាន ជាឧទាហរណ៍:

(ក) អត្ថប្រយោជន៍ចូលនិវត្តន៍ ដូចជា ប្រាក់សោធន និង

(ខ) អត្ថប្រយោជន៍ក្រោយបំពេញការងារផ្សេងទៀត ដូចជា ធានារ៉ាប់រងជីវិតក្រោយបំពេញការងារ និងការថែទាំវេជ្ជសាស្ត្រក្រោយបំពេញការងារ ការរៀបចំទាំងឡាយ ដែលអង្គភាពមួយផ្តល់អត្ថប្រយោជន៍ក្រោយបំពេញការងារគឺជាផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ។ អង្គភាពត្រូវអនុវត្តផ្នែកនេះចំពោះការរៀបចំបែបនេះទាំងអស់ មិនខ្វល់ថាពួកគេពាក់ព័ន្ធឬមិនពាក់ព័ន្ធនឹងការបង្កើតនៃអង្គភាពដោយឡែកដើម្បីទទួលវិភាគទាននិងបង់អត្ថប្រយោជន៍នោះទេ។ នៅក្នុងករណីខ្លះការរៀបចំទាំងនេះត្រូវបានកំណត់ដោយច្បាប់ ជាជាងដោយសកម្មភាពរបស់អង្គភាព។ នៅក្នុងករណីខ្លះការរៀបចំទាំងនេះកើតឡើងពីសកម្មភាពរបស់អង្គភាព ទោះបីក្នុងភាពអវត្តមាននៃផែនការផ្លូវការជាលាយលក្ខណ៍អក្សរក្តី។

២៨.១០ ផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ ត្រូវបានចាត់ថ្នាក់ជាផែនការវិភាគទានកំណត់ ឬផែនការអត្ថប្រយោជន៍កំណត់ដោយផ្អែកលើលក្ខខណ្ឌស្នូលរបស់ផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារទាំងនោះៈ

(ក) ផែនការវិភាគទានកំណត់គឺជាផែនការអត្ថប្រយោជន៍ ក្រោយបំពេញការងារដែលអង្គភាពបង់វិភាគទានថេរទៅឱ្យអង្គភាពដោយឡែក (មូលនិធិ) និង មិនមានកាតព្វកិច្ចស្របច្បាប់ ឬកាតព្វកិច្ចសន្មត ឱ្យបង់វិភាគទានបន្ថែម ឬធ្វើការទូទាត់សងអត្ថប្រយោជន៍ដោយផ្ទាល់ទៅឱ្យនិយោជិតប្រសិនបើ មូលនិធិនោះមិនមានទ្រព្យសកម្មគ្រប់គ្រាន់ដើម្បីបង់អត្ថប្រយោជន៍និយោជិតទាំងអស់ដែលទាក់ទងនឹងសេវានិយោជិតក្នុងគ្រាបច្ចុប្បន្ននិងគ្រាមុន។ ដូច្នេះចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ក្រោយបំពេញការងារ ដែលបានទទួលដោយនិយោជិត ត្រូវបានកំណត់ដោយ ចំនួនទឹកប្រាក់នៃវិភាគទានដែលបានបង់ដោយអង្គភាព (និងប្រហែលដោយនិយោជិតផងដែរ) ទៅឱ្យផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ ឬ ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងជាមួយគ្នាទៅនឹងចំណូលពីការវិនិយោគដែលកើតពីការបង់វិភាគទាននោះ។

(ខ) ផែនការអត្ថប្រយោជន៍កំណត់គឺជាផែនការអត្ថប្រយោជន៍ ក្រោយបំពេញការងារក្រៅពីផែនការវិភាគទានកំណត់។ ក្រោមផែនការអត្ថប្រយោជន៍កំណត់ កាតព្វកិច្ចរបស់អង្គភាពគឺត្រូវ ផ្តល់អត្ថប្រយោជន៍ដែលបានយល់ព្រមចំពោះនិយោជិតបច្ចុប្បន្ននិងអតីតកាល និងហានិភ័យគណនាតាមស្ថិតិ (ដែលអត្ថប្រយោជន៍នឹងមានតម្លៃលើសឬតិចជាងការរំពឹងទុក) និងហានិភ័យវិនិយោគ (ដែលតម្លៃតបស្នងនៃទ្រព្យសកម្មដាក់មួយឡែកដើម្បីផ្តល់ហិរញ្ញប្បទានដល់អត្ថប្រយោជន៍ទាំងនោះ នឹងខុសពីការរំពឹងទុក) ត្រូវរ៉ាប់រង តាមជាតុពិត ដោយអង្គភាព។ ប្រសិនបើបទពិសោធន៍ការគណនាតាមស្ថិតិឬការវិនិយោគអាក្រក់ជាងការរំពឹងទុក កាតព្វកិច្ចរបស់អង្គភាពអាចត្រូវបានបង្កើន និង ផ្ទុយមកវិញ ប្រសិនបើបទពិសោធន៍ការគណនាតាមស្ថិតិឬការវិនិយោគល្អជាងការរំពឹងទុក។

## ផែនការពហុនិយោជក និ ផែនការរបស់រដ្ឋ

២៨.១១ ផែនការពហុនិយោជកនិងផែនការរបស់រដ្ឋត្រូវបានចាត់ថ្នាក់ជាផែនការវិភាគទានកំណត់ ឬផែនការអត្ថប្រយោជន៍កំណត់ដោយឈរលើមូលដ្ឋាននៃលក្ខខណ្ឌនៃផែនការ រួមបញ្ចូលកាតព្វកិច្ចដោយសន្ទតណា ដែលលើសពីលក្ខខណ្ឌផ្លូវការ។ ប៉ុន្តែប្រសិនបើពុំមានព័ត៌មានគ្រប់គ្រាន់ ដើម្បីប្រើគណនេយ្យអត្ថប្រយោជន៍កំណត់សម្រាប់ផែនការពហុនិយោជកដែលជាផែនការអត្ថប្រយោជន៍កំណត់ទេ នោះអង្គភាពត្រូវធ្វើគណនេយ្យកម្មសម្រាប់ផែនការនោះដោយអនុលោមតាមកថាខណ្ឌ២៨.១៣ ហាក់ដូចជាវា គឺជាផែនការវិភាគទានកំណត់ និងធ្វើការលាតត្រដាងដែលតម្រូវដោយកថាខណ្ឌ២៨.៤០។

## អត្ថប្រយោជន៍ដែលបានធានា

២៨.១២ អង្គភាពអាចបង់បុព្វលាភធានារ៉ាប់រង ដើម្បីផ្តល់ហិរញ្ញប្បទានដល់ផែនការអត្ថប្រយោជន៍ ក្រោយបំពេញការងារ។ អង្គភាពត្រូវចាត់ចែងផែនការបែបនេះជាផែនការវិភាគទានកំណត់ លុះត្រាតែ អង្គភាពមានកាតព្វកិច្ចស្របច្បាប់ ឬដោយសន្ទតចំពោះករណីណាមួយខាងក្រោម៖

(ក) បង់អត្ថប្រយោជន៍និយោជិតដោយផ្ទាល់ពេលអត្ថប្រយោជន៍បានដល់កំណត់សង ឬ

(ខ) បង់ចំនួនទឹកប្រាក់បន្ថែមប្រសិនក្រុមហ៊ុនធានារ៉ាប់រងមិនបង់អត្ថប្រយោជន៍និយោជិតសម្រាប់អនាគតទាំងអស់ដែលទាក់ទងនឹងសេវាកម្មនិយោជិតក្នុងគ្រាបច្ចុប្បន្ន និងគ្រាមុន។

កាតព្វកិច្ចដោយសន្ទតអាចកើតឡើងដោយប្រយោលតាមរយៈផែនការ តាមរយៈយន្តការសម្រាប់ កំណត់តម្លៃបុព្វលាភអនាគត ឬ តាមរយៈទំនាក់ទំនងភាគីពាក់ព័ន្ធ ជាមួយក្រុមហ៊ុនធានារ៉ាប់រង។ ប្រសិនបើអង្គភាពរក្សានូវកាតព្វកិច្ចស្របច្បាប់ ឬដោយសន្ទតបែបនេះ អង្គភាពត្រូវចាត់ចែងផែនការនោះជាផែនការអត្ថប្រយោជន៍កំណត់។

# អត្ថប្រយោជន៍ក្រោយបំពេញការងារ៖ ផែនការវិភាគទានកំណត់

## ការទទួលស្គាល់ និង ការវាស់វែង

២៨.១៣ អង្គភាពត្រូវទទួលស្គាល់វិភាគទានត្រូវសងសម្រាប់គ្រា៖

(ក) ជាបំណុល បន្ទាប់ពីដកចេញនូវចំនួនទឹកប្រាក់ណាមួយដែលបានបង់រួច។ ប្រសិនបើ ការទូទាត់វិភាគទាន

លើសពីវិភាគទានដល់ពេលត្រូវបង់សម្រាប់សេវាកម្មមុនកាលបរិច្ឆេទរាយការណ៍ នោះអង្គភាពត្រូវទទួលស្គាល់ផ្នែកដែលលើសជាទ្រព្យសកម្ម។

(ខ) ជាចំណាយ លុះត្រាតែផ្នែកផ្សេងទៀតនៃស្តង់ដារនេះតម្រូវឱ្យថ្លៃដើមនោះនឹងត្រូវបានទទួលស្គាល់ជាផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្មដូចជាសន្និធិ ឬ ទ្រព្យ រោងចក្រ និង បរិក្ខារ។

## អត្ថប្រយោជន៍ក្រោយបំពេញការងារ៖ ផែនការអត្ថប្រយោជន៍កំណត់

### ការទទួលស្គាល់

២៨.១៤ ក្នុងការអនុវត្តគោលការណ៍ការទទួលស្គាល់ជាទូទៅក្នុងកថាខណ្ឌ ២៨.៣ ចំពោះផែនការអត្ថប្រយោជន៍កំណត់ អង្គភាពត្រូវទទួលស្គាល់:

(ក) ជាបំណុលសម្រាប់កាតព្វកិច្ចរបស់អង្គភាពក្រោមផែនការអត្ថប្រយោជន៍កំណត់ ដោយដកចេញទ្រព្យសកម្មផែនការ -'បំណុលអត្ថប្រយោជន៍កំណត់' (សូមមើលកថាខណ្ឌ ២៨.១៥- ២៨.២៣) និង

(ខ) ទទួលស្គាល់ការប្រែប្រួលសុទ្ធក្នុងបំណុលនោះក្នុងអំឡុងគ្រា ជាថ្លៃដើមនៃផែនការអត្ថប្រយោជន៍កំណត់របស់អង្គភាពក្នុងអំឡុងគ្រា (សូមមើលកថាខណ្ឌ ២៨.២៤-២៨.២៧)។

### ការវាស់វែងនៃបំណុលអត្ថប្រយោជន៍កំណត់

២៨.១៥ អង្គភាពត្រូវវាស់វែងបំណុលអត្ថប្រយោជន៍កំណត់សម្រាប់កាតព្វកិច្ចរបស់អង្គភាព ក្រោមផែនការអត្ថប្រយោជន៍កំណត់តាមតម្លៃសរុបសុទ្ធនៃចំនួនទឹកប្រាក់ខាងក្រោម៖

(ក) តម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ចរបស់អង្គភាព ក្រោមផែនការអត្ថប្រយោជន៍កំណត់ (កាតព្វកិច្ចអត្ថប្រយោជន៍កំណត់របស់អង្គភាព) នៅកាលបរិច្ឆេទរាយការណ៍ (កថាខណ្ឌ២៨.១៦-២៨.២២ ផ្តល់ការណែនាំសម្រាប់ការវាស់វែងកាតព្វកិច្ចនេះ)។

(ខ) ដកចេញនូវតម្លៃសមស្របនៅកាលបរិច្ឆេទរាយការណ៍នៃទ្រព្យសកម្មផែនការ (ប្រសិនបើមាន) ចេញពីកាតព្វកិច្ចនឹងត្រូវ ទូទាត់សងដោយផ្ទាល់។ កថាខណ្ឌ ១១.២៧-១១.៣២ ផ្តល់ការណែនាំសម្រាប់កំណត់តម្លៃសមស្របនៃទ្រព្យសកម្មផែនការទាំងនោះ។

### ការរួមបញ្ចូលនៃអត្ថប្រយោជន៍បានផ្ទេរនិងមិនបានផ្ទេរ

២៨.១៦ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចរបស់អង្គភាពក្រោមផែនការអត្ថប្រយោជន៍កំណត់ នៅកាលបរិច្ឆេទរាយការណ៍ត្រូវឆ្លុះបញ្ចាំងពីតម្លៃប៉ាន់ស្មាននៃអត្ថប្រយោជន៍ដែលនិយោជិតរកបានជាចំណូលជាការដោះដូរនូវសេវាកម្មរបស់ពួកគេក្នុងគ្រាបច្ចុប្បន្ន និងគ្រាមុនៗ រួមបញ្ចូលទាំងអត្ថប្រយោជន៍ដែលមិនទាន់បានផ្ទេរ (សូមមើលកថាខណ្ឌ ២៨.២៦) និងរួមបញ្ចូលឥទ្ធិពលនៃរូបមន្តអត្ថប្រយោជន៍ដែលផ្តល់ឱ្យនិយោជិតអត្ថប្រយោជន៍ច្រើនជាង សម្រាប់សេវានៅឆ្នាំក្រោយៗ។ នេះតម្រូវឱ្យអង្គភាពត្រូវកំណត់ថាតើអត្ថប្រយោជន៍ប៉ុន្មាន ចាត់ទុកជារបស់គ្រាបច្ចុប្បន្ននិងគ្រាមុនៗ ដោយផ្អែកលើរូបមន្តអត្ថប្រយោជន៍របស់ផែនការ និង ដើម្បីប៉ាន់ស្មាន( ការសន្មតដែលគណនាតាមស្ថិតិ) អំពីអថេរប្រជាសាស្ត្រ (ដូចជាអត្រាផ្លាស់ប្តូរនិយោជិត និង អត្រាមរណភាព) និង អថេរហិរញ្ញវត្ថុដូចជាការកើនឡើងពេលអនាគតនូវប្រាក់ខែនិងចំណាយវេជ្ជសាស្ត្រ) ដែលមានឥទ្ធិពលលើថ្លៃដើមនៃអត្ថប្រយោជន៍។ ការសន្មតដែល

គណនាតាមស្ថិតិ ត្រូវគ្មានភាពលំអៀង (មិនធ្វេសប្រហែស និងមិនអភិរក្សខ្លាំងពេក) ជៀបគ្នាទៅវិញទៅមកបាន និង ត្រូវបានជ្រើសរើសដើម្បីឈានទៅដល់ការប៉ាន់ស្មានល្អបំផុត នៃលំហូរសាច់ប្រាក់អនាគត ដែលនឹងកើតឡើងក្រោមផែនការ។

## ការធ្វើអប្បហារ

២៨.១៧ អង្គភាពត្រូវវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់បានធ្វើអប្បហារ លើមូលដ្ឋានតម្លៃបច្ចុប្បន្នបានធ្វើអប្បហារ។ អង្គភាពត្រូវកំណត់អត្រាដែលប្រើសម្រាប់ធ្វើអប្បហារការទូទាត់អនាគតដោយយោងតាមអត្រាចំណូលទីផ្សារនៅកាលបរិច្ឆេទរាយការណ៍លើសញ្ញាប័ណ្ណសាជីវកម្មមានគុណភាពខ្ពស់។ នៅបណ្តាប្រទេសដែលមិនមានទីផ្សារជ្រៅសម្រាប់សញ្ញាប័ណ្ណបែបនេះ អង្គភាពត្រូវប្រើអត្រាចំណូលទីផ្សារ (នៅកាលបរិច្ឆេទរាយការណ៍) នៃសញ្ញាប័ណ្ណរដ្ឋាភិបាល។ រូបិយប័ណ្ណ និងរយៈពេលកំណត់នៃសញ្ញាប័ណ្ណសាជីវកម្មឬសញ្ញាប័ណ្ណរដ្ឋាភិបាល ត្រូវមានសង្គតិភាពជាមួយរូបិយប័ណ្ណ និងរយៈពេលប៉ាន់ស្មាននៃការទូទាត់នាពេលអនាគត ។

## វិធីសាស្ត្រវាយតម្លៃតាមការគណនាស្ថិតិ

២៨.១៨ ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុ ប្រសិនបើអង្គភាពអាចប្រើប្រាស់វិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទាន ដើម្បីវាស់វែងនូវកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ និងការចំណាយដែលពាក់ព័ន្ធរបស់អង្គភាព អង្គភាពត្រូវធ្វើប្រើប្រាស់វិធីសាស្ត្របែបនេះ។ ប្រសិនបើអត្ថប្រយោជន៍កំណត់ផ្អែកលើប្រាក់ខែអនាគត វិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទាន តម្រូវឱ្យអង្គភាពវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់របស់អង្គភាព លើមូលដ្ឋានដែលឆ្លុះបញ្ចាំងពីការកើនឡើងប្រាក់ខែអនាគតប៉ាន់ស្មាន។ លើសពីនេះទៀត វិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទានតម្រូវឱ្យអង្គភាពធ្វើការសន្មតតាមការគណនាស្ថិតិផ្សេងៗ ក្នុងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ រួមបញ្ចូលអត្រាអប្បហារ អត្រាចំណេញរំពឹងទុកលើទ្រព្យសកម្មផែនការ អត្រាកើនឡើងប្រាក់ខែរំពឹងទុក អត្រាផ្លាស់ប្តូរនិយោជិតអត្រាមរណភាព និង (សម្រាប់ផែនការវេជ្ជសាស្ត្រអត្ថប្រយោជន៍កំណត់) អត្រានិន្នាការថ្លៃដើមវេជ្ជសាស្ត្រ។

២៨.១៩ ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុ ប្រសិនបើអង្គភាពមិនអាចប្រើវិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទានដើម្បីវាស់វែងកាតព្វកិច្ច និងចំណាយក្រោមផែនការអត្ថប្រយោជន៍កំណត់ អង្គភាពត្រូវបានអនុញ្ញាតឱ្យធ្វើការវាស់វែងងាយៗនូវកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ទាក់ទងនឹងនិយោជិតបច្ចុប្បន្នៈ

(ក) មិនអើពើនឹងការកើនឡើងប្រាក់ខែអនាគត (ពោលគឺ សន្មតប្រាក់ខែបច្ចុប្បន្ននៅបន្តរហូតដល់និយោជិតបច្ចុប្បន្នត្រូវបានរំពឹងថានឹងចាប់ផ្តើមទទួលអត្ថប្រយោជន៍ក្រោយបំពេញការងារ)។

(ខ) មិនអើពើនឹងសេវាអនាគតរបស់និយោជិតបច្ចុប្បន្ន (ពោលគឺ សន្មតបិទចោលផែនការសម្រាប់និយោជិតមានស្រាប់ ក៏ដូចជានិយោជិតថ្មីៗ)។

(គ) មិនអើពើនឹងអត្រាមរណភាពក្នុងពេលផ្តល់សេវាដែលអាចកើតមានឡើង នៃនិយោជិតបច្ចុប្បន្ននៅចន្លោះកាលបរិច្ឆេទរាយការណ៍និងថ្ងៃដែលនិយោជិតត្រូវបានរំពឹងថា នឹងចាប់ផ្តើមទទួលបានអត្ថប្រយោជន៍ក្រោយ បំពេញការងារ (ពោលគឺសន្មតនិយោជិតបច្ចុប្បន្នទាំងអស់នឹងទទួលបានអត្ថប្រយោជន៍ក្រោយបំពេញ ការងារ)។ ប៉ុន្តែ អត្រាមរណភាពបន្ទាប់ពីសេវាកម្ម (ពោលគឺ អាយុកាលមធ្យម) នឹងនៅចាំបាច់ដើម្បីពិចារណា។ អង្គភាពដែលប្រើប្រាស់ការធ្វើឱ្យងាយៗនៃការវាស់វែងដូចបានជម្រាបខាងមុខ ទោះបីជាយ៉ាងនេះក៏ដោយ ត្រូវរួមបញ្ចូលទាំងអត្ថប្រយោជន៍បានផ្ទេរ និង អត្ថប្រយោជន៍មិនបានផ្ទេរ ក្នុងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់របស់អង្គភាព។

២៨.២០ ស្តង់ដារនេះមិនតម្រូវឱ្យអង្គភាពជួលអ្នកគណនាតាមស្ថិតិឯករាជ្យ ដើម្បីធ្វើការវាយតម្លៃការគណនាតាមស្ថិតិពេញលេញដែលត្រូវការក្នុងការគណនាកាតព្វកិច្ចអត្ថប្រយោជន៍កំណត់របស់អង្គភាពនោះ។ ហើយស្តង់ដារនេះក៏មិនតម្រូវថាការវាយតម្លៃការគណនាតាមស្ថិតិពេញលេញ ត្រូវតែធ្វើឡើងជារៀងរាល់ឆ្នាំនោះទេ។ ក្នុងគ្រាចន្លោះការវាយតម្លៃការគណនាតាមស្ថិតិពេញលេញ ប្រសិនបើការសន្មតការគណនាតាមស្ថិតិចម្បងមិនបានប្រែប្រួលខ្លាំងទេ កាតព្វកិច្ចអត្ថប្រយោជន៍កំណត់អាចត្រូវបានវាស់វែងដោយ ការកែសម្រួលពីការវាស់វែងគ្រាមុនសម្រាប់ការប្រែប្រួលក្នុងប្រជាសាស្ត្រនិយោជិតដូចជា ចំនួននិយោជិត និង កម្រិតប្រាក់ខែ។

## ការដាក់ចេញ ការកែប្រែ ការបង្រួម និងការទូទាត់នៃផែនការ

២៨.២១ ប្រសិនបើផែនការអត្ថប្រយោជន៍កំណត់ត្រូវបានដាក់ចេញ ឬផ្លាស់ប្តូរក្នុងគ្រាបច្ចុប្បន្ន អង្គភាពត្រូវបង្កើនឬបន្ថយបំណុលអត្ថប្រយោជន៍កំណត់របស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរ និងត្រូវទទួលស្គាល់ការកើនឡើង (ការថយចុះ) ជាចំណាយ (ចំណូល) ក្នុងការវាស់វែងចំណេញឬខាតក្នុងគ្រាបច្ចុប្បន្ន។ ផ្ទុយមកវិញ ប្រសិនបើផែនការត្រូវបានបង្រួម (ពោលគឺ អត្ថប្រយោជន៍ ឬ ក្រុមនៃនិយោជិតដែលបានគ្របដណ្តប់ត្រូវបានកាត់បន្ថយ) ឬ ទូទាត់សង (កាតព្វកិច្ចរបស់និយោជកត្រូវបានបំពេញរួចទាំងស្រុង) ក្នុងគ្រាបច្ចុប្បន្ន កាតព្វកិច្ចអត្ថប្រយោជន៍កំណត់នោះត្រូវបានបន្ថយឬលុបចោល និង អង្គភាពត្រូវទទួលស្គាល់ចំណេញ ឬខាតដែលជាលទ្ធផលនៅក្នុងចំណេញឬខាតក្នុងគ្រាបច្ចុប្បន្ន។

## ទ្រព្យសកម្មផែនការអត្ថប្រយោជន៍កំណត់

២៨.២២ ប្រសិនបើតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍កំណត់នៅកាលបរិច្ឆេទរាយការណ៍ តិចជាងតម្លៃសមស្របនៃទ្រព្យសកម្មផែនការនៅថ្ងៃនោះ ផែនការនោះមានអតិរេក។ អង្គភាពត្រូវទទួលស្គាល់អតិរេកផែនការជាទ្រព្យសកម្មផែនការអត្ថប្រយោជន៍កំណត់គ្រាន់តែក្នុងវិសាលភាពដែលអង្គភាពនោះអាចប្រមូលបានមកវិញនូវអតិរេកនោះតាមរយៈវិភាគទានដែលថយចុះក្នុងពេលអនាគត ឬតាមរយៈទឹកប្រាក់ឱ្យវិញពីផែនការនោះ។

## ថ្លៃនៃផែនការអត្ថប្រយោជន៍កំណត់

២៨.២៣ អង្គភាពត្រូវទទួលស្គាល់ការប្រែប្រួលសុទ្ធ នៅក្នុងបំណុលអត្ថប្រយោជន៍កំណត់របស់ខ្លួនក្នុងគ្រា ក្រៅពីការប្រែប្រួលដែលបណ្តាលមកពីអត្ថប្រយោជន៍បង់ឱ្យនិយោជិតក្នុងគ្រា ឬវិភាគទានពីនិយោជក ជាថ្លៃនៃផែនការអត្ថប្រយោជន៍កំណត់របស់ខ្លួនក្នុងគ្រា។ ថ្លៃនោះត្រូវបានទទួលស្គាល់ ទាំងស្រុងនៅក្នុងចំណេញឬខាត ជាចំណាយ ឬ ដោយមួយផ្នែកនៅក្នុងចំណេញឬខាត និង ដោយមួយផ្នែកជាធាតុមួយនៃចំណូលលម្អិតផ្សេងៗ (សូមមើលកថាខណ្ឌ ២៨.២៤) លុះត្រាតែផ្នែកមួយផ្សេងទៀតនៃស្តង់ដារនេះ តម្រូវឱ្យថ្លៃនោះត្រូវបានទទួលស្គាល់ជាផ្នែកមួយនៃថ្លៃដើមទ្រព្យ សកម្មដូចជាសន្និធិ ឬ ទ្រព្យ រោងចក្រ និង បរិក្ខារ។

## ការទទួលស្គាល់ - ការជ្រើសរើសគោលនយោបាយគណនេយ្យ

២៨.២៤ អង្គភាពត្រូវបានតម្រូវឱ្យទទួលស្គាល់ចំណេញ និងខាតពីការគណនាស្ថិតិទាំងអស់នៅក្នុងគ្រាដែលចំណេញ និងខាតពីការគណនាស្ថិតិទាំងនោះកើតឡើង។ អង្គភាពត្រូវ:

(ក) ទទួលស្គាល់ចំណេញនិងខាតពីការគណនាស្ថិតិទាំងអស់នៅក្នុងចំណេញឬខាត ឬ

(ខ) ទទួលស្គាល់ចំណេញនិងខាតពីការគណនាស្ថិតិទាំងអស់នៅក្នុងចំណូលលម្អិតផ្សេងៗ ជាការជ្រើសរើសគោលនយោបាយគណនេយ្យ។ អង្គភាពត្រូវអនុវត្តគោលនយោបាយគណនេយ្យដែលបានជ្រើសរើសឱ្យមាន

សង្គតិភាពចំពោះគ្រប់ផែនការអត្ថប្រយោជន៍អត្ថប្រយោជន៍កំណត់ និង ចំណេញនិងខាតពីការគណនាស្ថិតិទាំងអស់របស់អង្គភាព។ ចំណេញ និងខាតពីការគណនាស្ថិតិដែលបានទទួលស្គាល់ នៅក្នុងចំណូលលម្អិតផ្សេងៗត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណូលពេញលេញ។

២៨.២៥ ការប្រែប្រួលសុទ្ធនៅក្នុងបំណុលអត្ថប្រយោជន៍កំណត់ ដែលត្រូវបានទទួលស្គាល់ជាថ្លៃនៃផែនការអត្ថប្រយោជន៍កំណត់ រួមបញ្ចូល៖

(ក) ការប្រែប្រួលក្នុងបំណុលអត្ថប្រយោជន៍កំណត់ដែលកើតចេញពីសេវានិយោជិតដែលបានផ្តល់ក្នុង ការិយបរិច្ឆេទរាយការណ៍

(ខ) ការប្រាក់លើកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ក្នុងការិយបរិច្ឆេទរាយការណ៍

(គ) ការតបស្នងពីទ្រព្យសកម្មផែនការណាមួយ និងការប្រែប្រួលសុទ្ធក្នុងតម្លៃសមស្របនៃសិទ្ធិទទួលសំណងបានទទួលស្គាល់ (សូមមើលកថាខណ្ឌ ២៨.២៨) ក្នុងការិយបរិច្ឆេទរាយការណ៍

(ឃ) ចំណេញ និងខាតពីការគណនាស្ថិតិដែលកើតឡើងក្នុងការិយបរិច្ឆេទរាយការណ៍

(ង) ការកើនឡើង ឬការថយចុះក្នុងបំណុលអត្ថប្រយោជន៍កំណត់ដែលកើតចេញពីការដាក់ចេញនូវផែនការថ្មី ឬការផ្លាស់ប្តូរផែនការមានស្រាប់ក្នុងការិយបរិច្ឆេទរាយការណ៍ (សូមមើលកថាខណ្ឌ ២៨.២១) និង

(ច) ការថយចុះក្នុងបំណុលអត្ថប្រយោជន៍កំណត់ ដែលកើតចេញពីការបង្រួមឬការទូទាត់ផែនការមានស្រាប់ក្នុងការិយបរិច្ឆេទរាយការណ៍ (សូមមើលកថាខណ្ឌ ២៨.២១)។

២៨.២៦ សេវារបស់និយោជិតធ្វើឱ្យកើតឡើងនូវកាតព្វកិច្ចក្រោមផែនការអត្ថប្រយោជន៍កំណត់ ទោះបីជាអត្ថប្រយោជន៍ទាំងនោះយកការជួលឱ្យធ្វើការនាអនាគតកាលជាលក្ខខណ្ឌ (និយាយម្យ៉ាងវិញទៀត អត្ថប្រយោជន៍ទាំងនោះមិនទាន់បានផ្ទេរ)។ សេវានិយោជិតមុនថ្ងៃផ្ទេរធ្វើឱ្យកើតឡើងនូវកាតព្វកិច្ចដោយសន្មតពីព្រោះ នៅ កាលបរិច្ឆេទរាយការណ៍ជាបន្តបន្ទាប់នីមួយៗ ចំនួនទឹកប្រាក់នៃសេវាអនាគតដែលនិយោជិតនឹងត្រូវផ្តល់មុនពេលមានសិទ្ធិទទួលអត្ថប្រយោជន៍ត្រូវបានកាត់បន្ថយ។ ក្នុងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់របស់ខ្លួន អង្គភាពពិចារណាពីភវនីយភាពដែលនិយោជិតមួយចំនួនអាចមិនពេញចិត្តនឹងការតម្រូវដើម្បីផ្ទេរ។ ស្រដៀងគ្នានេះដែរ ទោះបីជាអត្ថប្រយោជន៍ក្រោយបំពេញការងារខ្លះ (ដូចជាអត្ថប្រយោជន៍វេជ្ជសាស្ត្រក្រោយបំពេញការងារ) ក្លាយជាត្រូវសង មានតែក្នុងករណីដែលព្រឹត្តិការណ៍ជាក់លាក់កើតឡើង នៅពេលដែលនិយោជិតមិនត្រូវបានជួលឱ្យធ្វើការតទៅទៀត (ដូចជាការឈឺ) កាតព្វកិច្ចត្រូវបានបង្កើតឡើងពេលនិយោជិតផ្តល់សេវាកម្មដែលនឹងផ្តល់សិទ្ធិក្នុងការទទួលបានផលប្រយោជន៍នោះ ប្រសិនបើព្រឹត្តិការណ៍ជាក់លាក់កើតឡើង។ ភវនីយភាពដែលព្រឹត្តិការណ៍ជាក់លាក់នឹងកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការវាស់វែងនៃកាតព្វកិច្ច ប៉ុន្តែមិនកំណត់ថាតើកាតព្វកិច្ចនោះមានឬអត់ទេ។

២៨.២៧ ប្រសិនអត្ថប្រយោជន៍កំណត់ត្រូវបានកាត់បន្ថយនូវចំនួនទឹកប្រាក់ ដែលនឹងត្រូវបានបង់ទៅឱ្យនិយោជិតក្រោមផែនការឧបត្ថម្ភរបស់រដ្ឋាភិបាល អង្គភាពត្រូវវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់របស់ខ្លួន លើមូលដ្ឋានដែលឆ្លុះបញ្ចាំងពីអត្ថប្រយោជន៍ត្រូវសងក្រោមផែនការរបស់រដ្ឋាភិបាល ប៉ុន្តែមានតែក្នុងករណីដែល៖

(ក) ផែនការទាំងនោះត្រូវបានអនុម័តមុនកាលបរិច្ឆេទរាយការណ៍ ឬ

(ខ) ប្រវត្តិអតីតកាល ឬ ភស្តុតាងដែលអាចជឿជាក់បានផ្សេងទៀត បានបង្ហាញថាអត្ថប្រយោជន៍របស់រដ្ឋទាំងនោះនឹងប្រែប្រួលតាមបែបផែនអាចព្យាករណ៍បានណាមួយ ឧទាហរណ៍ ប្រែប្រួលទៅតាមការប្រែប្រួលអនាគត របស់កម្រិតតម្លៃទូទៅ ឬកម្រិតប្រាក់ខែទូទៅ។

### សំណង

២៨.២៨ ប្រសិនបើអង្គភាពសឹងតែប្រាកដថាភាគីម្ខាងទៀតនឹងសងខ្លះឬទាំងអស់នូវចំណាយ ដែលតម្រូវក្នុងការទូទាត់កាតព្វកិច្ចអត្ថប្រយោជន៍កំណត់ អង្គភាពត្រូវទទួលស្គាល់សិទ្ធិទទួលសំណងរបស់ខ្លួនជាទ្រព្យសកម្មដោយឡែកមួយ។ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មតាមតម្លៃសមស្រប។ ក្នុងរបាយការណ៍ចំណូលពេញលេញ (ឬរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ) ចំណាយដែលពាក់ព័ន្ធនឹងផែនការអត្ថប្រយោជន៍កំណត់ អាចត្រូវបានបង្ហាញជាតួលេខសុទ្ធនៃសំណងដែលបានទទួលស្គាល់។

## អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងទៀត

២៨.២៩ អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងទៀតជាទូទៅរួមបញ្ចូល ឧទាហរណ៍:

(ក) ការអវត្តមានមានតម្លៃតបស្នងរយៈពេលវែង ដូចជា ការឈប់សម្រាកសេវារយៈពេលវែង ឬ ការឈប់សម្រាកពីការងាររយៈពេលវែង

(ខ) អត្ថប្រយោជន៍សេវារយៈពេលវែង

(គ) អត្ថប្រយោជន៍ភាពពិការរយៈពេលវែង

(ឃ) ការចែកប្រាក់ចំណេញ និង ប្រាក់បន្ថែមត្រូវសង ១២ខែ ឬច្រើនជាងបន្ទាប់ពីចុងគ្រាដែលនិយោជិតផ្តល់សេវាកម្មដែលពាក់ព័ន្ធ និង

(ង) តម្លៃតបស្នងពន្យារដែលបានបង់១២ខែ ឬច្រើនជាងបន្ទាប់ពីចុងគ្រាដែលតម្លៃតបស្នងនោះត្រូវបានរកបាន។

២៨.៣០ អង្គភាពត្រូវទទួលស្គាល់បំណុលសម្រាប់អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងទៀត ដែលវាស់វែងតាមចំនួនសរុបសុទ្ធនៃចំនួនទឹកប្រាក់ខាងក្រោម៖

(ក) តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍នៅកាលបរិច្ឆេទរាយការណ៍ ដក

(ខ) តម្លៃសមស្របនៃទ្រព្យសកម្មផែនការ (ប្រសិនបើមាន) ដែលសម្រាប់ទូទាត់កាតព្វកិច្ចដោយផ្ទាល់នាកាលបរិច្ឆេទរាយការណ៍។

អង្គភាពត្រូវទទួលស្គាល់ការប្រែប្រួលសុទ្ធក្នុងបំណុល ក្នុងអំឡុងគ្រា ក្រៅពីការប្រែប្រួលដោយសារអត្ថប្រយោជន៍ដែលទូទាត់ជូននិយោជិតក្នុងអំឡុងគ្រាឬដោយសារវិភាគទានពីនិយោជក ទទួលស្គាល់ជាថ្លៃដើមនៃអត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងទៀតរបស់ខ្លួន ក្នុងអំឡុងគ្រា។ ថ្លៃដើមនោះ ត្រូវទទួលស្គាល់ទាំងស្រុងក្នុងចំណេញ ឬខាត ជាការចំណាយ វៀរលែងតែផ្នែកផ្សេងទៀតនៃស្តង់ដារនេះ តម្រូវឱ្យទទួលស្គាល់ថ្លៃដើមនោះ ជាផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្ម ដូចជាសន្និធិ ឬទ្រព្យ រោងចក្រ និងបរិក្ខារ។

## អត្ថប្រយោជន៍ពេលបញ្ឈប់

២៨.៣១ អង្គភាពមួយអាចមានការសន្យាតាមច្បាប់ តាមកិច្ចសន្យាឬកិច្ចព្រមព្រៀងផ្សេងទៀតជាមួយនិយោជិតឬតំណាងរបស់ពួកគេ ឬ តាមកាតព្វកិច្ចដោយសន្មតផ្អែកលើការអនុវត្តអាជីវកម្ម ទំនៀមទំលាប់ឬការចង់ប្រព្រឹត្តដោយសមធម៌ ដើម្បីធ្វើការទូទាត់ (ឬផ្តល់អត្ថប្រយោជន៍ផ្សេងទៀត) ទៅឱ្យនិយោជិត នៅពេលអង្គភាពនោះបញ្ឈប់ការងាររបស់និយោជិត។ ការទូទាត់បែបនេះគឺជា អត្ថប្រយោជន៍ពេលបញ្ឈប់។

### ការទទួលស្គាល់

២៨.៣២ ពីព្រោះអត្ថប្រយោជន៍ពេលបញ្ឈប់មិនផ្តល់ឱ្យអង្គភាពនូវអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត អង្គភាពត្រូវទទួលស្គាល់អត្ថប្រយោជន៍ទាំងនោះជាចំណាយក្នុងចំណេញ ឬ ខាតភ្លាមៗ។

២៨.៣៣ ពេលដែលអង្គភាពទទួលស្គាល់អត្ថប្រយោជន៍ពេលបញ្ឈប់ អង្គភាពអាចត្រូវធ្វើគណនេយ្យកម្មផងដែរនូវការបង្រួមនៃអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ឬ អត្ថប្រយោជន៍និយោជិតផ្សេងទៀត។

២៨.៣៤ មានតែនៅពេលដែលអង្គភាពបង្ហាញយ៉ាងច្បាស់ថាស្ថិតនៅកាលៈទេសៈណាមួយដូចខាងក្រោម អង្គភាពទើបត្រូវទទួលស្គាល់អត្ថប្រយោជន៍ពេលបញ្ឈប់ជាបំណុលនិងចំណាយ៖

(ក) បញ្ឈប់ការងាររបស់និយោជិត ឬ ក្រុមនិយោជិតមុនពេលថ្ងៃចូលនិវត្តន៍ជម្មតា ឬ

(ខ) ផ្តល់អត្ថប្រយោជន៍ពេលបញ្ឈប់ដែលជាលទ្ធផលនៃការស្នើផ្តល់ ដែលបានធ្វើឡើងដើម្បី លើកទឹកចិត្តការឈប់ពីការងារដោយស្ម័គ្រចិត្ត។

២៨.៣៥ មានតែនៅពេលដែលអង្គភាពមានផែនការលម្អិតបញ្ឈប់ការងារជាផ្លូវការ និងមិនមានភាពអាចទៅរួចជាក់ស្តែងនៃការដកចេញវិញនូវផែនការនោះ ទើបបង្ហាញច្បាស់លាស់ថាអង្គភាពសន្យាអនុវត្តការបញ្ឈប់ការងារ។

### ការវាស់វែង

២៨.៣៦ អង្គភាពត្រូវវាស់វែងអត្ថប្រយោជន៍ ពេលបញ្ឈប់តាមការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតនៃការចំណាយ ដែលនឹងបានតម្រូវឱ្យទូទាត់សងកាតព្វកិច្ចនៅកាលបរិច្ឆេទរាយការណ៍។ ក្នុងករណីនៃការស្នើផ្តល់ដែលបានធ្វើឡើង ដើម្បីលើកទឹកចិត្តការឈប់ពីការងារដោយស្ម័គ្រចិត្ត ការវាស់វែងនៃអត្ថប្រយោជន៍ពេលបញ្ឈប់ត្រូវផ្អែកលើចំនួននិយោជិតដែលរំពឹងថានឹងទទួលយកការស្នើផ្តល់នោះ។

២៨.៣៧ នៅពេលអត្ថប្រយោជន៍ពេលបញ្ឈប់ដល់ពេលទូទាត់លើសពី១២ខែ ក្រោយចុងការិយបរិច្ឆេទរាយការណ៍ អត្ថប្រយោជន៍ពេលបញ្ឈប់ទាំងនោះត្រូវវាស់វែងតាមតម្លៃបច្ចុប្បន្នដែលបានធ្វើអប្បហាររួច។

## ផែនការក្រុម

២៨.៣៨ ប្រសិនបើអង្គភាពក្រុមហ៊ុនមេ ផ្តល់អត្ថប្រយោជន៍ទៅឱ្យនិយោជិតនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយឬច្រើន នៅក្នុងក្រុម ហើយក្រុមហ៊ុនមេនោះបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមដោយប្រើ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ឬស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងនេះត្រូវបានអនុញ្ញាតឱ្យទទួលស្គាល់និងវាស់វែងចំណាយអត្ថប្រយោជន៍និយោជិត លើមូលដ្ឋាននៃការបែងចែកសមស្របនៃចំណាយដែលបានទទួលស្គាល់សម្រាប់ក្រុម។

# ការលាតត្រដាង

## ការលាតត្រដាងអំពីអត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

២៨.៣៩ ផ្នែកនេះមិនតម្រូវឱ្យមានការលាតត្រដាងជាក់លាក់អំពីអត្ថប្រយោជន៍និយោជិតរយៈពេលខ្លី។

## ការលាតត្រដាងអំពីផែនការវិភាគទានកំណត់

២៨.៤០ អង្គភាពមួយត្រូវលាតត្រដាងចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់ក្នុងចំណេញឬខាតជាចំណាយសម្រាប់ផែនការវិភាគទានកំណត់។ ប្រសិនបើអង្គភាពចាត់ចែងផែនការពហុនិយោជកអត្ថប្រយោជន៍កំណត់ ជាផែនការវិភាគទានកំណត់មួយពីព្រោះព័ត៌មានគ្រប់គ្រាន់មិនអាចរកបានដើម្បីប្រើប្រាស់គណនេយ្យអត្ថប្រយោជន៍កំណត់ (សូមមើលកថាខណ្ឌ ២៨.១១) អង្គភាពនោះត្រូវបង្ហាញនូវអង្គហេតុដែលវាជាផែនការអត្ថប្រយោជន៍កំណត់មួយ និងហេតុផលដែលវាកំពុងត្រូវបានធ្វើគណនេយ្យកម្មជាផែនការវិភាគទានកំណត់មួយ ជាមួយនឹងព័ត៌មានដែលអាចរកបានអំពីអតិរេក ឬឱនភាពរបស់ផែនការ និងឥទ្ធិពលសក្តានុពលទៅអនាគតរបស់វា ប្រសិនបើមាន សម្រាប់អង្គភាព។

## ការលាតត្រដាងអំពីផែនការអត្ថប្រយោជន៍កំណត់

២៨.៤១ អង្គភាពត្រូវបង្ហាញនូវព័ត៌មានខាងក្រោមអំពីផែនការអត្ថប្រយោជន៍កំណត់ (លើកលែងផែនការអត្ថប្រយោជន៍ពហុនិយោជកកំណត់ ដែលត្រូវបានធ្វើគណនេយ្យកម្មជាផែនការវិភាគទានកំណត់ ដោយអនុលោមតាមកថាខណ្ឌ២៨.១១ ដែលការលាតត្រដាងក្នុងកថាខណ្ឌ២៨.៤០អនុវត្តជំនួស)។ ប្រសិនបើអង្គភាពមានផែនការអត្ថប្រយោជន៍កំណត់លើសពីមួយ នោះការលាតត្រដាងអាចត្រូវធ្វើជាសរុប ដាច់ដោយឡែកសម្រាប់ផែនការនីមួយៗ ឬការបញ្ចូលជាក្រុមដែលសន្មតថាមានប្រយោជន៍បំផុត៖

(ក) ការពិពណ៌នាទូទៅអំពីប្រភេទនៃផែនការ រួមបញ្ចូលគោលនយោបាយផ្តល់ហិរញ្ញប្បទាន

(ខ) គោលនយោបាយគណនេយ្យរបស់អង្គភាពសម្រាប់ការទទួលស្គាល់ចំណេញនិងខាតពីការគណនាស្ថិតិ (ក្នុងចំណេញឬខាត ឬ ជាធាតុមួយនៃចំណូលលម្អិតផ្សេងៗ) និងចំនួនទឹកប្រាក់នៃចំណេញនិងខាតពីការគណនាស្ថិតិដែលបានទទួលស្គាល់ក្នុងអំឡុងគ្រា។

(គ) ប្រសិនបើអង្គភាពប្រើប្រាស់នូវវិធីសាស្ត្រគណនេយ្យធ្វើឱ្យងាយៗណាមួយ ក្នុងកថាខណ្ឌ២៨.១៩ ក្នុងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់របស់ខ្លួន អង្គភាពត្រូវលាតត្រដាងអង្គហេតុនោះ និងមូលហេតុដែលការប្រើប្រាស់វិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទាន ដើម្បីវាស់វែងកាតព្វកិច្ចរបស់ខ្លួន និងថ្លៃចំណាយក្រោមផែនការអត្ថប្រយោជន៍កំណត់ នឹងនាំឱ្យមានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ។

(ឃ) ថ្ងៃនៃការវាយតម្លៃតាមការគណនាស្ថិតិពេញលេញថ្មីៗបំផុត និង ប្រសិនបើវាមិននៅកាលបរិច្ឆេទរាយការណ៍នោះទេ ការរៀបរាប់នៃការកែសម្រួលដែលបានធ្វើឡើងដើម្បីវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ នៅកាលបរិច្ឆេទរាយការណ៍។

(ង) ការសម្របសម្រួលនៃសមតុល្យដើមគ្រានិងចុងគ្រានៃកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ ដោយបង្ហាញដាច់ដោយឡែកនូវអត្ថប្រយោជន៍ដែលបានបង់ និង ការប្រែប្រួលទាំងអស់ផ្សេងទៀត។

(ច) ការសម្របសម្រួលសមតុល្យដើមគ្រានិងចុងគ្រានៃតម្លៃសមស្របនៃទ្រព្យសកម្មផែនការ និងសមតុល្យ

ដើមគ្រានិងចុងគ្រានៃសិទ្ធិទទួលសំណងណាមួយដែលបានទទួលស្គាល់ជាទ្រព្យសកម្ម ដោយបង្ហាញដោយឡែកប្រសិនបើអាចអនុវត្តបាន៖

(១) វិភាគទាន

(២) អត្ថប្រយោជន៍បានបង់ និង

(៣) ការប្រែប្រួលផ្សេងៗ ក្នុងទ្រព្យសកម្មផែនការ

(ឆ) ថ្លៃដើមសរុបដែលទាក់ទងនឹងផែនការអត្ថប្រយោជន៍ សម្រាប់គ្រាលាតត្រដាងដាច់ដោយឡែកនូវចំនួនទឹកប្រាក់៖

(១) ដែលបានទទួលស្គាល់ក្នុងចំណេញ ឬ ខាតជាចំណាយ និង

(២) ដែលបានរួមបញ្ចូលក្នុងថ្លៃដើមទ្រព្យសកម្ម

(ជ) សម្រាប់ថ្នាក់ទ្រព្យសកម្មផែនការចម្បងនីមួយៗ ដែលត្រូវបញ្ចូលប៉ុន្តែមិនកម្រិតតែចំពោះឧបករណ៍មូលធន ឧបករណ៍បំណុល ទ្រព្យ និង ទ្រព្យសកម្មផ្សេងទៀតទាំងអស់ ភាគរយឬចំនួនទឹកប្រាក់ដែលចំណាត់ថ្នាក់ចម្បងនីមួយៗបង្កើតបាននៃតម្លៃសមស្របនៃទ្រព្យសកម្មផែនការសរុបនៅកាលបរិច្ឆេទរាយការណ៍។

(ឈ) បណ្ដាចំនួនទឹកប្រាក់ដែលបានរួមបញ្ចូលក្នុងតម្លៃសមស្របនៃទ្រព្យសកម្មផែនការសម្រាប់៖

(១) ថ្នាក់នីមួយៗនៃឧបករណ៍ហិរញ្ញវត្ថុផ្ទាល់របស់អង្គភាព និង

(២) ទ្រព្យនីមួយៗដែលបានកាន់កាប់ដោយឬទ្រព្យសកម្មផ្សេងទៀ ដែលត្រូវបានប្រើដោយអង្គភាព។

(ញ) តម្លៃតបស្នងជាក់ស្ដែងនៃទ្រព្យសកម្មផែនការ និង

(ដ) ការសន្មតការគណនាតាមស្ថិតិចម្បងដែលបានប្រើ រួមបញ្ចូល ពេលអាចអនុវត្តបានៈ

(១) អត្រាអប្បហារ

(២) អត្រាការតបស្នងរំពឹងទុកលើទ្រព្យសកម្មផែនការណាមួយសម្រាប់គ្រាទាំងឡាយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(៣) អត្រារំពឹងទុកនៃកំណើនប្រាក់ខែ

(៤) អត្រានិន្នាការថ្លៃដើមវេជ្ជសាស្ត្រ និង

(៥) ការសន្មតការគណនាតាមស្ថិតិជាសារវន្តណាផ្សេងទៀតដែលបានប្រើ។

ការសម្របសម្រួលនៅក្នុង (ង) និង (ច) ខាងលើមិនចាំបាច់ត្រូវបង្ហាញសម្រាប់គ្រាមុនៗទេ។ ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលទទួលស្គាល់និងវាស់វែងចំណាយអត្ថប្រយោជន៍និយោជិតលើមូលដ្ឋាននៃការបែងចែកសមស្របនៃចំណាយដែលបានទទួលស្គាល់សម្រាប់ក្រុម (សូមមើលកថាខណ្ឌ ២៨.៣៨) នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ ត្រូវរៀបរាប់ពីគោលនយោបាយរបស់ខ្លួនសម្រាប់ការធ្វើការបែងចែក និងត្រូវធ្វើការលាតត្រដាងនៅក្នុង (ក)-(ដ) សម្រាប់ផែនការទាំងមូល។

## ការលាតត្រដាងអំពីអត្ថប្រយោជន៍រយៈពេលវែងផ្សេងទៀត

២៨.៤២ សម្រាប់ចំណាត់ថ្នាក់នីមួយៗនៃអត្ថប្រយោជន៍រយៈពេលវែងផ្សេងទៀត ដែលអង្គភាពផ្តល់ទៅឱ្យនិយោជិតរបស់ខ្លួន អង្គភាពត្រូវបង្ហាញអំពីសារជាតិនៃអត្ថប្រយោជន៍នោះ ចំនួនទឹកប្រាក់នៃកាតព្វកិច្ចរបស់ខ្លួន និងកម្រិតនៃការផ្តល់ហិរញ្ញប្បទាននៅកាលបរិច្ឆេទរាយការណ៍។

## ការលាតត្រដាងអំពីអត្ថប្រយោជន៍ពេលបញ្ឈប់

២៨.៤៣ សម្រាប់ចំណាត់ថ្នាក់នីមួយៗនៃអត្ថប្រយោជន៍ពេលបញ្ឈប់ ដែលអង្គភាពផ្តល់ទៅឱ្យនិយោជិតរបស់ខ្លួន អង្គភាពត្រូវបង្ហាញអំពីសារជាតិនៃអត្ថប្រយោជន៍នោះ ចំនួនទឹកប្រាក់នៃកាតព្វកិច្ចរបស់ខ្លួន និងកម្រិតនៃការផ្តល់ហិរញ្ញប្បទាននៅកាលបរិច្ឆេទរាយការណ៍។

២៨.៤៤ នៅពេលដែលមានភាពមិនច្បាស់លាស់អំពីចំនួននិយោជិតដែលនឹងទទួលយក នូវការស្នើផ្តល់នៃអត្ថប្រយោជន៍ពេលបញ្ឈប់ បំណុលយថាហេតុស្ថិតមាន។ ផ្នែកទី២១ សំវិធានធន និង យថាហេតុ តម្រូវឱ្យអង្គភាពលាតត្រដាងព័ត៌មានអំពីបំណុលយថាហេតុរបស់ខ្លួន លុះត្រាតែភាពដែលអាចនៃការហូរចេញសាច់ប្រាក់ដែលបណ្តាលមកពីការទូទាត់សងបំណុលគឺតូចណាស់។

# ផ្នែកទី ២៩
# ពន្ធលើប្រាក់ចំណូល

## វិសាលភាពនៃផ្នែកនេះ

២៩.១ សម្រាប់គោលបំណងនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ពន្ធលើប្រាក់ចំណូល រួមបញ្ចូលទាំងពន្ធក្នុងប្រទេស និងក្រៅប្រទេសដែលផ្អែកលើប្រាក់ចំណេញជាប់ពន្ធ។ ពន្ធលើប្រាក់ចំណូលរួមបញ្ចូលផងដែរនូវពន្ធទាំងឡាយ ដូចជាពន្ធកាត់ទុកដែលត្រូវសងដោយក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន នៅពេលបែងចែក ទៅឱ្យអង្គភាពរាយការណ៍។

២៩.២ ផ្នែកនេះគ្របដណ្តប់លើគណនេយ្យកម្មពន្ធលើប្រាក់ចំណូល។ គណនេយ្យកម្មពន្ធលើប្រាក់ចំណូលតម្រូវឱ្យអង្គភាពត្រូវទទួលស្គាល់លទ្ធផលពន្ធបច្ចុប្បន្ន និងអនាគតនៃប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀតដែលត្រូវបានទទួលស្គាល់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ប្រាក់ពន្ធដែលត្រូវបានទទួលស្គាល់ទាំងអស់នេះរួមមានពន្ធបច្ចុប្បន្ន និងពន្ធពន្យារ។ ពន្ធបច្ចុប្បន្ន គឺជាពន្ធលើប្រាក់ចំណូលត្រូវសង (ដែលអាចប្រមូលមកវិញបាន) នៃប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) សម្រាប់គ្រាបច្ចុប្បន្ន ឬគ្រាមុន។ ពន្ធពន្យារ គឺជាពន្ធលើប្រាក់ចំណូលត្រូវសង ឬអាចប្រមូលមកវិញបានក្នុងគ្រាខាងមុខ ជាទូទៅកើតចេញពីអង្គភាពដែលប្រមូលមកវិញ ឬទូទាត់សងនូវទ្រព្យសកម្ម និងបំណុលរបស់អង្គភាព សម្រាប់តម្លៃយោងបច្ចុប្បន្នរបស់ពួកគេ និងឥទ្ធិពលពន្ធនៃការលើកទៅខាងមុខនូវខាតប្រាក់ពន្ធនិងឥណទានពន្ធដែលបច្ចុប្បន្នមិនទាន់បានប្រើ។

២៩.៣ ផ្នែកនេះមិននិយាយដល់វិធីសាស្រ្តគណនេយ្យកម្មសម្រាប់អំណោយរបស់រដ្ឋាភិបាលទេ (សូមមើលផ្នែកទី២៤ ស្តីពីអំណោយរបស់រដ្ឋាភិបាល)។ ប៉ុន្តែ ផ្នែកនេះពិតនិយាយដល់គណនេយ្យកម្មសម្រាប់ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកើតចេញពីអំណោយបែបនេះ។

## ការទទួលស្គាល់និងការវាស់វែងពន្ធបច្ចុប្បន្ន

២៩.៤ អង្គភាពមួយត្រូវទទួលស្គាល់បំណុលពន្ធបច្ចុប្បន្ន សម្រាប់ពន្ធត្រូវសងលើប្រាក់ចំណេញជាប់ពន្ធ សម្រាប់គ្រាបច្ចុប្បន្ន និងគ្រាមុន។ ប្រសិនបើចំនួនទឹកប្រាក់បានបង់សម្រាប់គ្រាបច្ចុប្បន្ន និងគ្រាមុនលើសពីចំនួនទឹកប្រាក់ត្រូវសងសម្រាប់គ្រាទាំងនោះ អង្គភាពត្រូវទទួលស្គាល់ផ្នែកដែលលើសនោះជាទ្រព្យសកម្មពន្ធបច្ចុប្បន្ន។

២៩.៥ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មពន្ធបច្ចុប្បន្នសម្រាប់អត្ថប្រយោជន៍ខាតប្រាក់ពន្ធដែលអាចលើកទៅក្រោយដើម្បីប្រមូលមកវិញ នូវប្រាក់ពន្ធដែលបានបង់ក្នុងគ្រាមុន។

២៩.៦ អង្គភាពត្រូវវាស់វែងបំណុល (ទ្រព្យសកម្ម) ពន្ធបច្ចុប្បន្ន តាមចំនួនទឹកប្រាក់ដែលខ្លួនរំពឹងថានឹងបង់ (ប្រមូលបានមកវិញ) ដោយប្រើអត្រាពន្ធ និងច្បាប់ ដែលបានអនុម័ត ឬបានអនុម័តជាក់ស្តែងនៅកាលបរិច្ឆេទរាយការណ៍។ អង្គភាពត្រូវចាត់ទុកអត្រាពន្ធ និងច្បាប់ពន្ធ ថាបានអនុម័តជាក់ស្តែង នៅពេលដែលជំហានទៅសេសសល់ នៅក្នុងដំណើរការអនុម័ត មិនត្រូវបានប៉ះពាល់ដល់លទ្ធផលគ្រាមុន និងមិនទំនងជាត្រូវប៉ះពាល់។ កថាខណ្ឌ២៩.៣២-២៩.៣៣ ផ្តល់ការណែនាំបន្ថែមអំពីការវាស់វែង។

# ការទទួលស្គាល់ពន្ធពន្យារ

## គោលការណ៍ទទួលស្គាល់ជាទូទៅ

២៩. ៧ វាកើតមកជាងៗក្នុងការទទួលស្គាល់ទ្រព្យសកម្ម ឬបំណុល ដែលអង្គភាពរាយការណ៍រំពឹងថានឹងប្រមូលមកវិញ ឬទូទាត់សងនូវតម្លៃយោងនៃទ្រព្យសកម្ម ឬបំណុលនោះ។ ប្រសិនបើវាប្រហែលថា ការប្រមូលបានមកវិញ ឬការទូទាត់សងនូវតម្លៃយោងនោះ នឹងធ្វើឱ្យការបង់ពន្ធនាពេលអនាគតមានចំនួនច្រើន (តិច) ជាងការបង់ពន្ធនាពេលអនាគតដែលនឹងជា បើសិនជាការប្រមូលបានមកវិញ ឬការទូទាត់សងបែបនោះ ពុំមានលទ្ធផលពន្ធអ្វីសោះ ផ្នែកនេះតម្រូវឱ្យអង្គភាព ទទួលស្គាល់បំណុលពន្ធពន្យារ (ទ្រព្យសកម្មពន្ធពន្យារ) ជាមួយករណីលើកលែងមានកម្រិតមួយចំនួន។ ប្រសិនបើអង្គភាពនោះរំពឹងថានឹងប្រមូលបានមកវិញនូវតម្លៃយោងនៃទ្រព្យសកម្មមួយ ឬទូទាត់តម្លៃយោងនៃបំណុលមួយ ដោយមិនធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធ នោះពុំមានពន្ធពន្យារ កើតឡើងទាក់ទិននឹងទ្រព្យសកម្ម ឬបំណុលនោះទេ។

២៩. ៨ អង្គភាពមួយត្រូវទទួលស្គាល់ទ្រព្យសកម្ម ឬបំណុលពន្ធពន្យារសម្រាប់ពន្ធដែលអាចប្រមូលបានមកវិញ ឬដែលត្រូវសង ក្នុងគ្រាអនាគតដែលដោយសារប្រតិបត្តិការ ឬព្រឹត្តិការណ៍អតីតកាល។ ពន្ធបែបនេះ កើតចេញពីភាពខុសគ្នារវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលរបស់អង្គភាព ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងតម្លៃសន្មតថាកើតចេញពីទ្រព្យសកម្ម និងបំណុល ដោយអាជ្ញាធរពន្ធដារ (ភាពខុសគ្នាទាំងនេះហៅថា “ភាពខុសគ្នាបណ្តោះអាសន្ន”) និងការលើកទៅមុខនៃខាតប្រាក់ពន្ធនិងឥណទានពន្ធដែលមិនបានប្រើនាពេលបច្ចុប្បន្ន។

## មូលដ្ឋានពន្ធ និងភាពខុសគ្នាបណ្តោះអាសន្ន

២៩.៩ មូលដ្ឋានពន្ធនៃទ្រព្យសកម្ម ជាតម្លៃដែលអាចកាត់កងបានសម្រាប់គោលបំណងពន្ធ ទៅនឹងអត្ថប្រយោជន៍សេដ្ឋកិច្ចជាប់ពន្ធ ដែលនឹងហូរចូលក្នុងអង្គភាព នៅពេលដែលអង្គភាពប្រមូលបានមកវិញនូវតម្លៃយោងនៃទ្រព្យសកម្ម។ ប្រសិនបើអត្ថប្រយោជន៍សេដ្ឋកិច្ចទាំងនោះមិនជាប់ពន្ធទេ មូលដ្ឋានពន្ធនៃទ្រព្យសកម្ម គឺស្មើនឹងតម្លៃយោងរបស់វា។

២៩.១០ មូលដ្ឋានពន្ធនៃបំណុល គឺជាតម្លៃយោងរបស់វា ដកនឹងតម្លៃដែលនឹងអាចកាត់កងបានសម្រាប់គោលបំណងពន្ធ ទៅនឹងបំណុលនោះក្នុងគ្រាអនាគត។ ក្នុងករណីចំណូលដែលត្រូវបានទទួលជាមុន មូលដ្ឋានពន្ធនៃបំណុលដែលបានកើតឡើងបែបនេះជាតម្លៃយោងរបស់វា ដកនឹងចំនួនទឹកប្រាក់ នៃចំណូល ដែលនឹងមិនជាប់ពន្ធក្នុងគ្រាអនាគត។

២៩.១១ ជាតុមួយចំនួនមានមូលដ្ឋានពន្ធ ប៉ុន្តែមិនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ។ ឧទាហរណ៍៖ ថ្លៃស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានទទួលស្គាល់ ជាការចំណាយ នៅពេលធ្វើការកំណត់ចំណេញគណនេយ្យ ក្នុងគ្រាដែលចំណាយទាំងនោះ បានកើតឡើង ប៉ុន្តែមិនអាចអនុញ្ញាតជាការកាត់កង នៅពេលកំណត់ប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) រហូតដល់គ្រាក្រោយមកទៀត។ ភាពខុសគ្នារវាងមូលដ្ឋានពន្ធ នៃថ្លៃស្រាវជ្រាវ និងអភិវឌ្ឍន៍ (ពោលគឺចំនួនទឹកប្រាក់ ដែលអាជ្ញាធរពន្ធដារ នឹងអនុញ្ញាត ជាការកាត់កង ក្នុងគ្រាអនាគត) និងតម្លៃយោងស្មើសូន្យ គឺជាភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន ដែលនាំឱ្យមានទ្រព្យសកម្មពន្ធពន្យារ។

២៩.១២ ភាពខុសគ្នាបណ្តោះអាសន្ន គឺជាភាពខុសគ្នារវាងតម្លៃយោងនៃទ្រព្យសកម្ម ឬបំណុល នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងមូលដ្ឋានពន្ធរបស់វា។ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ភាពខុសគ្នាបណ្តោះអាសន្ន ត្រូវបានកំណត់ ដោយការប្រៀបធៀបតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ជាមួយនឹងមូលដ្ឋានពន្ធសមស្រប។ មូលដ្ឋានពន្ធ ត្រូវបានកំណត់ដោយការយោងលើលិខិតប្រកាសពន្ធរួម នៅក្នុងយុត្តាធិការទាំងឡាយ ដែលលិខិតប្រកាសពន្ធបែបនេះ ត្រូវបានរៀបចំ។ ក្នុងយុត្តាធិការផ្សេងទៀត មូលដ្ឋានពន្ធ ត្រូវបាន


CamEd Business School

កំណត់ដោយការយោងលើលិខិតប្រកាសពន្ធ របស់អង្គភាពនីមួយៗនៅក្នុងក្រុម។

២៩.១៣ ឧទាហរណ៍នៃស្ថានភាព ដែលភាពខុសគ្នាបណ្តោះអាសន្នកើតឡើង រួមមាន៖

(ក) ទ្រព្យសកម្មអាចកំណត់បាន ដែលបានទទួល និងបំណុល ដែលបានរ៉ាប់រង នៅក្នុងការរួមបញ្ចូលអាជីវកម្ម ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របរបស់ពួកវា ស្របតាមផ្នែកទី១៩ ស្តីពីការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម ប៉ុន្តែគ្មានការកែតម្រូវសមមូលណាមួយ ត្រូវបានធ្វើឡើងសម្រាប់គោលបំណងពន្ធ (ឧទាហរណ៍៖ មូលដ្ឋានពន្ធនៃទ្រព្យសកម្ម ប្រហែលនៅជាថ្លៃដើមដដែលនៃម្ចាស់មុន)។ ទ្រព្យសកម្ម ឬបំណុលពន្ធពន្យារ ដែលកើតឡើងដោយសារដូច្នេះ ប៉ះពាល់តម្លៃកេរ្តិ៍ឈ្មោះអាជីវកម្មដែលអង្គភាពមួយទទួលស្គាល់។

(ខ) ទ្រព្យសកម្មត្រូវបានវាស់វែងឡើងវិញ ប៉ុន្តែគ្មានការកែតម្រូវសមមូលណាមួយ ត្រូវបានធ្វើឡើងសម្រាប់គោលបំណងពន្ធ។ ឧទាហរណ៍៖ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះអនុញ្ញាត ឬតម្រូវឱ្យវាស់វែងឡើងវិញនូវទ្រព្យសកម្មមួយចំនួន តាមតម្លៃសមស្រប ឬវាយតម្លៃឡើងវិញ (ឧទាហរណ៍៖ ផ្នែកទី១៦ ស្តីពីទ្រព្យវិនិយោគ និងផ្នែកទី១៧ ស្តីពីទ្រព្យ រោងចក្រ និងបរិក្ខារ)។

(គ) កេរ្តិ៍ឈ្មោះអាជីវកម្មកើតឡើងនៅក្នុងការរួមបញ្ចូលអាជីវកម្ម ឧទាហរណ៍៖ មូលដ្ឋានពន្ធនៃកេរ្តិ៍ឈ្មោះអាជីវកម្មនឹងស្មើសូន្យ ប្រសិនបើអាជ្ញាធរពន្ធដារ មិនអនុញ្ញាតនូវការដាក់ការរំលស់ ឬការថយចុះនៃតម្លៃកេរ្តិ៍ឈ្មោះអាជីវកម្ម ជាការចំណាយដែលអាចកាត់កងបាន នៅពេលដែលប្រាក់ចំណេញជាប់ពន្ធ ត្រូវបានកំណត់ និងមិនអនុញ្ញាតឱ្យចាត់ទុកថ្លៃដើមនៃកេរ្តិ៍ឈ្មោះអាជីវកម្ម ជាការចំណាយដែលអាចកាត់កងបាន នៅពេលបញ្ចេញចោលក្រុមហ៊ុនបុត្រសម្ព័ន្ធ។

(ឃ) មូលដ្ឋានពន្ធនៃទ្រព្យសកម្ម ឬបំណុលនាការទទួលស្គាល់ដំបូង ខុសគ្នាពីតម្លៃយោងដំបូងរបស់វា។

(ង) តម្លៃយោងនៃការវិនិយោគ ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធ ឬភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន មានភាពខុសគ្នាពីមូលដ្ឋានពន្ធនៃការវិនិយោគ ឬភាគកម្ម។ មិនមែនភាពខុសគ្នាបណ្តោះអាសន្នទាំងអស់ខាងលើ សុទ្ធតែធ្វើឱ្យកើតឡើងនូវទ្រព្យសកម្ម និងបំណុលពន្ធពន្យារនោះទេ (សូមមើលកថាខណ្ឌ២៩.១៤ និង២៩.១៦)។

## ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ

២៩.១៤ បំណុលពន្ធពន្យារ ត្រូវបានទទួលស្គាល់សម្រាប់ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធទាំងអស់ លើកលែងតែក្នុងកម្រិតដែលបំណុលពន្ធពន្យារនោះ កើតឡើងពី៖

(ក) ការទទួលស្គាល់ដំបូងនៃកេរ្តិ៍ឈ្មោះអាជីវកម្ម ឬ

(ខ) ការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ឬបំណុល នៅក្នុងប្រតិបត្តិការ ដែល៖

(១) មិនមែនជាការរួមបញ្ចូលអាជីវកម្ម និង

(២) នៅពេលប្រតិបត្តិការ មិនប៉ះពាល់ចំណេញគណនេយ្យ និងប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ)

ទោះបីជាយ៉ាងនេះក្តី សម្រាប់ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ ដែលពាក់ព័ន្ធជាមួយ ការវិនិយោគ ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធ និងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន បំណុលពន្ធពន្យារត្រូវទទួលស្គាល់ស្របតាមកថាខណ្ឌ២៩.២៥។

២៩.១៥ ភាពខុសគ្នាបណ្ដោះអាសន្នមួយចំនួន កើតឡើង នៅពេលដែលចំណូល ឬចំណាយ ត្រូវបានបញ្ចូលក្នុងចំណេញគណនេយ្យនៅក្នុងគ្រាមួយ ប៉ុន្តែត្រូវបានបញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធ នៅក្នុងគ្រាផ្សេង។ ភាពខុសគ្នាបណ្ដោះអាសន្នបែបនេះ ជាញឹកញាប់ ត្រូវបានពិពណ៌នាជាភាពខុសគ្នានៃពេលវេលា។ ខាងក្រោមនេះ គឺជាឧទាហរណ៍នៃភាពខុសគ្នាបណ្ដោះអាសន្នប្រភេទនេះ ដែលជាភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធ ហើយដូច្នេះ នាំឱ្យមានបំណុលពន្ធពន្យារ៖

(ក) ចំណូលការប្រាក់ ត្រូវបានបញ្ចូលក្នុងចំណេញគណនេយ្យតាមមូលដ្ឋានសមាមាត្រពេល ប៉ុន្តែនៅក្នុងយុត្តាធិការមួយចំនួន ប្រហែលជាបញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធ នៅពេលដែលសាច់ប្រាក់ត្រូវបានប្រមូល។ មូលដ្ឋានពន្ធនៃគណនីត្រូវទទួលណាមួយ ទាក់ទិននឹងចំណូលបែបនេះ គឺស្មើសូន្យ ពីព្រោះចំណូលទាំងនេះមិនប៉ះពាល់ប្រាក់ចំណេញជាប់ពន្ធឡើយ រហូតទាល់តែសាច់ប្រាក់ត្រូវបានប្រមូល និង

(ខ) ការរំលស់ដែលត្រូវបានប្រើ នៅពេលកំណត់ប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) អាចខុសគ្នាពីរំលស់ដែលបានប្រើ នៅពេលកំណត់ចំណេញគណនេយ្យ។ ភាពខុសគ្នាបណ្ដោះអាសន្ន គឺភាពខុសគ្នារវាងតម្លៃយោងនៃទ្រព្យសកម្ម និងមូលដ្ឋានពន្ធរបស់វា ដែលជាថ្លៃដើមប្រវត្តិនៃទ្រព្យសកម្ម ដករាល់ការកាត់កងទាំងអស់ ទាក់ទងនឹងទ្រព្យសកម្មនោះ ដែលត្រូវបានអនុញ្ញាតដោយអាជ្ញាធរពន្ធដារ នៅពេលកំណត់ប្រាក់ចំណេញជាប់ពន្ធនៃគ្រាបច្ចុប្បន្ន និងគ្រាមុន។ ភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធ កើតឡើង និងនាំឱ្យមានបំណុលពន្ធពន្យារ នៅពេលការរំលស់ពន្ធ ត្រូវបានពន្លឿន។ ប្រសិនបើការរំលស់ពន្ធ មិនលឿនដូចការរំលស់គណនេយ្យ ភាពខុសគ្នាបណ្ដោះអាសន្នដែលកាត់កងបាន កើតឡើង នាំឱ្យមានទ្រព្យសកម្មពន្ធពន្យារ (សូមមើលកថាខណ្ឌ២៩.១៦) ។

## ភាពខុសគ្នាបណ្ដោះអាសន្នដែលកាត់កងបាន

២៩.១៦ ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ចំពោះរាល់ភាពខុសគ្នាបណ្ដោះអាសន្នដែលកាត់កងបាន ក្នុងកម្រិតមួយ ដែលអាចនឹងមានប្រាក់ចំណេញជាប់ពន្ធសម្រាប់ឱ្យ ភាពខុសគ្នាបណ្ដោះអាសន្នដែលកាត់កងបាន អាចត្រូវបានប្រើប្រាស់ចំពោះ វៀរលែងតែទ្រព្យសកម្មពន្ធពន្យារ កើតចេញពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ឬបំណុលនៅក្នុងប្រតិបត្តិការមួយ ដែល៖

(ក) មិនមែនជាការរួមបញ្ចូលអាជីវកម្ម និង

(ខ) នៅពេលប្រតិបត្តិការ មិនប៉ះពាល់ចំណេញគណនេយ្យ និងប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ)។

ទោះបីជាយ៉ាងនេះក្ដី សម្រាប់ភាពខុសគ្នាបណ្ដោះអាសន្នដែលកាត់កងបាន ដែលពាក់ព័ន្ធជាមួយការវិនិយោគ ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធ និងសម្រាប់ភាគកម្មក្នុងក្រុមហ៊ុនរួមទុន ទ្រព្យសកម្មពន្ធពន្យារ ត្រូវទទួលស្គាល់ស្របតាមកថាខណ្ឌ២៩.២៦។

២៩.១៧ ខាងក្រោមនេះ គឺជាឧទាហរណ៍នៃភាពខុសគ្នាបណ្ដោះអាសន្នដែលកាត់កងបាន ដែលនាំឱ្យមានទ្រព្យសកម្មពន្ធពន្យារ៖

(ក) ថ្លៃអត្ថប្រយោជន៍ចូលនិវត្តន៍ អាចត្រូវបានកាត់កង នៅពេលកំណត់ចំណេញគណនេយ្យ នៅពេលដែលសេវាត្រូវបានផ្ដល់ឱ្យដោយនិយោជិត ប៉ុន្តែត្រូវបានកាត់កង នៅពេលកំណត់ប្រាក់ចំណេញជាប់ពន្ធ នៅពេលដែលវិភាគទាន ត្រូវបានបង់ចូលមូលនិធិដោយអង្គភាពនោះ ឬនៅពេលដែលអត្ថប្រយោជន៍ចូលនិវត្តន៍ ត្រូវបានបង់ដោយអង្គភាពនោះ។ ភាពខុសគ្នាបណ្ដោះអាសន្ន កើតមានរវាងតម្លៃយោងនៃបំណុល និងមូលដ្ឋាន

ពន្ធរបស់វា។ មូលដ្ឋានពន្ធបំណុល ជាធម្មតា គឺស្មើសូន្យ។ ភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន បែបនេះ នឹងនាំឱ្យមានទ្រព្យសកម្មពន្ធពន្យារ ពីព្រោះអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងហូរចូលអង្គភាព ក្នុងទម្រង់ជាការកាត់កងពីប្រាក់ចំណេញជាប់ពន្ធ នៅពេលដែលវិភាគទាន ឬអត្ថប្រយោជន៍ចូលនិវត្តន៍ ត្រូវបានបង់។

(ខ) ទ្រព្យសកម្មមួយចំនួន អាចត្រូវបានកត់ក្នុងបញ្ជីតាមតម្លៃសមស្រប ដោយមិនមានការកែតម្រូវសមមូល ដែលត្រូវបានធ្វើឡើងសម្រាប់គោលបំណងពន្ធ។ ភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន កើតឡើង ប្រសិនបើមូលដ្ឋានពន្ធនៃទ្រព្យសកម្មលើសពីតម្លៃយោងរបស់វា។

២៩.១៨ ការប្រែត្រឡប់មកវិញនៃភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន នាំឱ្យមានការកាត់កង នៅពេលប្រាក់ចំណេញជាប់ពន្ធនៃគ្រាអនាគត ត្រូវបានកំណត់។ អាចនឹងមានប្រាក់ចំណេញជាប់ពន្ធសម្រាប់ឱ្យ ភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន អាចត្រូវបានប្រើប្រាស់ចំពោះ នៅពេលមានភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធគ្រប់គ្រាន់ទាក់ទងនឹងអាជ្ញាធរពន្ធដារតែមួយ និងអង្គភាពជាប់ពន្ធតែមួយ ដែលត្រូវបានរំពឹងថានឹងធ្វើការប្រែត្រឡប់មកវិញ៖

(ក) ក្នុងគ្រាដូចគ្នានឹងការប្រែត្រឡប់មកវិញដែលបានរំពឹងទុកនៃភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន ឬ

(ខ) ក្នុងគ្រា ដែលខាតប្រាក់ពន្ធ ដែលកើតឡើងពីទ្រព្យសកម្មពន្ធពន្យារ អាចត្រូវបានបង្គរថយក្រោយ ឬទៅមុខ។

ក្នុងកាលៈទេសៈបែបនេះ ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់នៅក្នុងគ្រា ដែលភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន កើតឡើង។

២៩.១៩ នៅពេលដែលមានភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ មិនគ្រប់គ្រាន់ ទាក់ទងនឹងអាជ្ញាធរពន្ធដារតែមួយ និងអង្គភាពជាប់ពន្ធតែមួយ ទ្រព្យសកម្មពន្ធពន្យារ ត្រូវទទួលស្គាល់ក្នុងកម្រិតមួយដែល៖

(ក) វាប្រហែលជាអាចថា អង្គភាពនឹងមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ ទាក់ទងនឹងអាជ្ញាធរពន្ធដារតែមួយ និងអង្គភាពជាប់ពន្ធតែមួយ ក្នុងគ្រាដូចគ្នានឹងការប្រែត្រឡប់មកវិញនៃភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន (ឬក្នុងគ្រាដែលខាតប្រាក់ពន្ធកើតឡើងពីទ្រព្យសកម្មពន្ធពន្យារ អាចលើកថយក្រោម ឬទៅមុខ)។ នៅពេលធ្វើការវាយតម្លៃថាខ្លួននឹងមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ ក្នុងគ្រាអនាគត ឬអត់ អង្គភាពមិនអើពើនឹងចំនួនទឹកប្រាក់ជាប់ពន្ធ ដែលកើតឡើងពីភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន ដែលត្រូវបានរំពឹងថានឹងកើតមាន ក្នុងគ្រាអនាគត ពីព្រោះទ្រព្យសកម្មពន្ធពន្យារ ដែលកើតឡើងពីភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន ខ្លួនឯងនឹងត្រូវការប្រាក់ចំណេញជាប់ពន្ធគ្រាអនាគត ដើម្បីត្រូវបានប្រើប្រាស់ ឬ

(ខ) អង្គភាពមានឱកាសធ្វើផែនការពន្ធ ដែលនឹងបង្កើតប្រាក់ចំណេញជាប់ពន្ធ ក្នុងគ្រាសមស្រប។

២៩.២០ នៅពេលដែលអង្គភាពមួយមានប្រវត្តិខាតបង់នាពេលថ្មីៗ អង្គភាពនោះពិចារណាលើការណែនាំនៅក្នុងកថាខណ្ឌ ២៩.២១-២៩.២២។

## ខាតប្រាក់ពន្ធដែលមិនបានប្រើ និងឥណទានពន្ធដែលមិនបានប្រើ

២៩. ២១ ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ចំពោះការលើកទៅមុខនៃខាតប្រាក់ពន្ធដែលមិនបានប្រើ និងឥនទានពន្ធដែលមិនបានប្រើ ក្នុងកម្រិតមួយ ដែលអាចនឹងមានប្រាក់ចំណេញជាប់ពន្ធនាអនាគតសម្រាប់ឱ្យ ខាតប្រាក់ពន្ធដែលមិនបានប្រើ និងឥនទានពន្ធដែលមិនបានប្រើ អាចត្រូវបានប្រើប្រាស់ចំពោះ។ នៅពេលវាយតម្លៃអំពីភាពប្រហែលជាអាចដែលប្រាក់ចំណេញជាប់ពន្ធនឹងអាចរកបាន សម្រាប់ឱ្យខាតប្រាក់ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធដែលមិនបានប្រើ អាចត្រូវបានប្រើប្រាស់ចំពោះ អង្គភាពត្រូវពិចារណាលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

(ក) ថាតើអង្គភាពមានភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធគ្រប់គ្រាន់ ទាក់ទងនឹងអាជ្ញាធរពន្ធដារតែមួយ និង អង្គភាពជាប់ពន្ធតែមួយ ដែលនឹងនាំឱ្យមានចំនួនទឹកប្រាក់ជាប់ពន្ធ សម្រាប់ឱ្យខាតប្រាក់ពន្ធដែលមិនបាន ប្រើ ឬឥណទានពន្ធដែលមិនបានប្រើ អាចត្រូវបានប្រើប្រាស់ចំពោះ មុនពេលពួកវាផុតកំណត់ដែរឬទេ។

(ខ) ថាតើអង្គភាពអាចនឹងមានប្រាក់ចំណេញជាប់ពន្ធ មុនពេលខាតប្រាក់ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធ ដែលមិនបានប្រើផុតកំណត់ដែរទេ។

(គ) ថាតើខាតប្រាក់ពន្ធដែលមិនបានប្រើ បណ្តាលមកពីមូលហេតុដែលអាចកំណត់បាន ដែលទំនងជាមិនកើត ឡើងម្តងទៀតឬទេ និង

(ឃ) ថាតើអង្គភាពអាចមានឱកាសធ្វើផែនការពន្ធ ដែលនឹងបង្កើតប្រាក់ចំណេញជាប់ពន្ធ ក្នុងគ្រាដែលខាតប្រាក់ ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធដែលមិនបានប្រើ អាចត្រូវបានប្រើប្រាស់ដែរទេ។

ប្រសិនបើប្រាក់ចំណេញជាប់ពន្ធមិនទំនងជាមានសម្រាប់ឱ្យ ខាតប្រាក់ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធដែល មិនបានប្រើ អាចត្រូវបានប្រើប្រាស់ចំពោះ នោះទ្រព្យសកម្មពន្ធពន្យារ មិនត្រូវបានទទួលស្គាល់។

២៩.២២ អត្ថិភាពនៃខាតប្រាក់ពន្ធដែលមិនបានប្រើ គឺជាភ័ស្តុតាងដ៏រឹងមាំបញ្ជាក់ថា ប្រាក់ចំណេញជាប់ពន្ធនាអនាគត ប្រហែលជាមិនអាចរកបាន។ ដូច្នេះ នៅពេលដែលអង្គភាពមានប្រវត្តិនៃការខាតបង់នាពេលថ្មីៗ អង្គភាព ទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ ដែលកើតចេញពីខាតប្រាក់ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធដែលមិនបាន ប្រើ គ្រាន់តែក្នុងកម្រិតមួយដែល អង្គភាពមានភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធគ្រប់គ្រាន់ ឬក្នុងកម្រិតមួយដែល មានភ័ស្តុតាងគួរឱ្យជឿបានផ្សេងទៀតបញ្ជាក់ថា ប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់នឹងអាចរកបាន សម្រាប់ឱ្យខាត ប្រាក់ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធដែលមិនបានប្រើ អាចត្រូវបានប្រើប្រាស់ចំពោះ ដោយអង្គភាពនោះ។

## ការវាយតម្លៃឡើងវិញលើទ្រព្យសកម្មពន្ធពន្យារដែលមិនបានទទួលស្គាល់

២៩.២៣ នៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ អង្គភាពវាយតម្លៃឡើងវិញនូវទ្រព្យសកម្មពន្ធពន្យារណាដែលមិនបាន ទទួលស្គាល់។ អង្គភាពទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារដែលមិនបានទទួលស្គាល់ពីមុន ក្នុងកម្រិតមួយដែល ប្រាក់ចំណេញជាប់ពន្ធនាអនាគត អាចនឹងអនុញ្ញាតឱ្យទ្រព្យសកម្មពន្ធពន្យារត្រូវប្រមូលបានមកវិញ។

## ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធ និងភាគកម្មក្នុងក្រុមហ៊ុនរួមទុន

២៩.២៤ ភាពខុសគ្នាបណ្តោះអាសន្ន កើតឡើង នៅពេលដែលតម្លៃយោងនៃការវិនិយោគ ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធ និងភាគកម្មក្នុងក្រុមហ៊ុនរួមទុន (ឧទាហរណ៍៖ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ក្រុមហ៊ុនមេ តម្លៃយោងនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ រួមបញ្ចូល ទាំងតម្លៃយោងនៃកេរ្តិ៍ឈ្មោះអាជីវកម្មដែលពាក់ព័ន្ធ) ខុសគ្នាពីមូលដ្ឋានពន្ធ (ដែលជាញឹកញាប់ គឺជាថ្លៃ) នៃការ វិនិយោគ ឬភាគកម្ម។ ភាពខុសគ្នាបែបនេះ អាចកើតឡើង ក្នុងកាលៈទេសៈផ្សេងៗគ្នាមួយចំនួន ឧទាហរណ៍៖

(ក) អត្ថិភាពនៃប្រាក់ចំណេញដែលមិនបានបែងចែករបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា ក្រុមហ៊ុនញាតិសម្ព័ន្ធ និង ក្រុមហ៊ុនរួមទុន

(ខ) ការប្រែប្រួលលើ អត្រាប្តូរប្រាក់បរទេស នៅពេលដែលក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន មាន មូលដ្ឋាននៅក្នុងប្រទេសផ្សេងគ្នា និង

(គ) ការថយចុះតម្លៃយោងនៃការវិនិយោគ ក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ដល់តម្លៃដែលអាចប្រមូលមកវិញបានរបស់វា។

ការវិនិយោគ អាចត្រូវបានធ្វើគណនេយ្យកម្មខុសគ្នា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ក្រុមហ៊ុនមេ បើប្រៀបធៀបនឹងរបាយការណ៍ហិរញ្ញវត្ថុរួម ដែលក្នុងករណីនេះ ភាពខុសគ្នាបណ្ដោះអាសន្នពាក់ព័ន្ធជាមួយការវិនិយោគនោះ ក៏អាចខុសគ្នាដែរ។ ឧទាហរណ៍៖ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ក្រុមហ៊ុនមេ តម្លៃយោងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ នឹងអាស្រ័យលើគោលនយោបាយគណនេយ្យ ដែលបានជ្រើសរើស ក្នុងកថាខណ្ឌ៩.២៦។

២៩.២៥ អង្គភាពត្រូវទទួលស្គាល់បំណុលពន្ធពន្យារ ចំពោះរាល់ភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធទាំងអស់ ដែលទាក់ទងនឹងការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធនិងភាគកម្មក្នុងក្រុមហ៊ុនរួមទុន ប៉ុន្តែលើកលែងចំពោះករណីដែល លក្ខខណ្ឌទាំងពីរខាងក្រោម ត្រូវបានបំពេញ៖

(ក) ក្រុមហ៊ុនមេ វិនិយោគិន ឬអ្នករួមទុន អាចគ្រប់គ្រងពេលវេលា ក្នុងការប្រែត្រឡប់មកវិញនូវភាពខុសគ្នាបណ្ដោះអាសន្ន និង

(ខ) ភាពខុសគ្នាបណ្ដោះអាសន្ន អាចនឹងមិនប្រែត្រឡប់មកវិញ ក្នុងពេលឆាប់ៗទេ។

២៩.២៦ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ សម្រាប់រាល់ភាពខុសគ្នាបណ្ដោះអាសន្នដែលកាត់កងបាន ដែលកើតចេញពីការវិនិយោគ ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធ និងភាគកម្មក្នុងក្រុមហ៊ុនរួមទុន បានតែក្នុងករណីដែលអាចនឹង៖

(ក) ភាពខុសគ្នាបណ្ដោះអាសន្ន នឹងប្រែត្រឡប់មកវិញ ក្នុងពេលឆាប់ៗ និង

(ខ) ប្រាក់ចំណេញជាប់ពន្ធ នឹងអាចរកបាន សម្រាប់ឱ្យភាពខុសគ្នាបណ្ដោះអាសន្នអាចត្រូវបានប្រើប្រាស់ចំពោះ។

## ការវាស់វែងពន្ធពន្យារ

២៩.២៧ អង្គភាពមួយវាស់វែងបំណុល (ទ្រព្យសកម្ម) ពន្ធពន្យារ ដោយប្រើអត្រាពន្ធ និងច្បាប់ពន្ធដែលត្រូវបានអនុម័ត ឬអនុម័តជាក់ស្ដែងនៅត្រឹមកាលបរិច្ឆេទរាយការណ៍។ អង្គភាពត្រូវចាត់ទុកអត្រាពន្ធនិងច្បាប់ពន្ធ ថាបានអនុម័តជាក់ស្ដែង នៅពេលដែលជំហានដែលនៅសេសសល់ ក្នុងដំណើរការអនុម័តក្នុងពេលអតីតកាល មិនបានប៉ះពាល់ដល់លទ្ធផល និងមិនទំនងជានឹងប៉ះពាល់ដល់លទ្ធផល។

២៩.២៨ ពេលដែលអត្រាពន្ធផ្សេងៗគ្នា អនុវត្តចំពោះប្រាក់ចំណេញជាប់ពន្ធដែលមានកម្រិតខុសៗគ្នា អង្គភាពត្រូវវាស់វែងបំណុល (ទ្រព្យសកម្ម) ពន្ធពន្យារ ដោយប្រើអត្រាពន្ធមធ្យម ដែលបានអនុម័ត ឬអនុម័តជាក់ស្ដែងដែលអង្គភាពរំពឹងអាចអនុវត្តបានចំពោះប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) នៃគ្រាដែលអង្គភាពរំពឹងថាបំណុលពន្ធពន្យារ នឹងត្រូវបានទូទាត់សង (ទ្រព្យសកម្មពន្ធពន្យារនឹងត្រូវបានទទួល)។

២៩.២៩ ការវាស់វែងបំណុលពន្ធពន្យារ និងទ្រព្យសកម្មពន្ធពន្យារ ត្រូវឆ្លុះបញ្ចាំងពីលទ្ធផលពន្ធដែលបានមកពីរបៀបដែលអង្គភាពរំពឹងទុកនៅកាលបរិច្ឆេទរាយការណ៍ ដើម្បីប្រមូលមកវិញ ឬទូទាត់សងនូវតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលទាក់ទិន។ ដូច្នេះ អង្គភាពវាស់វែងបំណុលពន្ធពន្យារ និងទ្រព្យសកម្មពន្ធពន្យារ ដោយប្រើអត្រាពន្ធ និងមូលដ្ឋានពន្ធ ដែលមានសង្គតិភាពជាមួយនឹងរបៀបរំពឹងទុកនៃការប្រមូលមកវិញ ឬការទូទាត់សង។ ឧទាហរណ៍៖

ប្រសិនបើភាពខុសគ្នាបណ្តោះអាសន្ន កើតចេញពីធាតុមួយនៃចំណូលដែលត្រូវបានរំពឹងថានឹងជាប់ពន្ធជាចំណេញមូលធនក្នុងគ្រាអនាគត ចំណាយពន្ធពន្យារ ត្រូវបានវាស់វែងដោយប្រើអត្រាពន្ធចំណេញមូលធន និងមូលដ្ឋានពន្ធដែលមានសង្គតិភាពជាមួយការប្រមូលមកវិញនូវតម្លៃយោងតាមរយៈការលក់។

២៩.៣០ ប្រសិនបើបំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារ កើតចេញពីទ្រព្យសកម្មមិនអាចរំលស់បាន ដែលត្រូវបានវាស់វែង ដោយប្រើគំរូវាយតម្លៃឡើងវិញ ក្នុងផ្នែកទី១៧ ការវាស់វែងបំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារ ត្រូវឆ្លុះបញ្ចាំងពីលទ្ធផលពន្ធនៃការប្រមូលមកវិញនូវតម្លៃយោងនៃទ្រព្យសកម្មមិនអាចរំលស់បានតាមរយៈការលក់។ ប្រសិនបើបំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារ កើតចេញពីទ្រព្យវិនិយោគដែលត្រូវបានវាស់វែងតាមតម្លៃសមស្របនោះ មានការសន្មតដែលអាចបដិសេធបានថា តម្លៃយោងនៃទ្រព្យវិនិយោគ នឹងត្រូវប្រមូលបានមកវិញតាមរយៈការលក់។ ដូច្នេះ វៀរលែងតែការសន្មត ត្រូវបានបដិសេធ ការវាស់វែងបំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារ ត្រូវឆ្លុះបញ្ចាំងពីលទ្ធផលពន្ធនៃការប្រមូលបានមកវិញនូវតម្លៃយោងនៃទ្រព្យវិនិយោគទាំងស្រុងតាមរយៈការលក់។ ការសន្មតនេះ ត្រូវបានបដិសេធ ប្រសិនបើទ្រព្យវិនិយោគ អាចរំលស់បាន និងត្រូវបានរក្សាទុកក្នុងគំរូអាជីវកម្មដែលមានគោលបំណងប្រើប្រាស់ជាដុំកំភួននូវផលប្រយោជន៍សេដ្ឋកិច្ចទាំងអស់ ដែលបង្កប់នៅក្នុងទ្រព្យវិនិយោគតាមពេលវេលា ជាជាងតាមរយៈការលក់។ ប្រសិនបើការសន្មត ត្រូវបានបដិសេធ ការតម្រូវនៃកថាខណ្ឌ២៩.២៩ ត្រូវអនុវត្ត។

២៩.៣១ តម្លៃយោងនៃទ្រព្រសកម្មពន្ធពន្យារ ត្រូវត្រួតពិនិត្រឡើងវិញនៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ។ អង្គភាពត្រូវកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មពន្ធពន្យារ រហូតដល់លែងមានភាពប្រហែលថា នឹងមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់នូវផលប្រយោជន៍នៃទ្រព្យសកម្មពន្ធពន្យារដែលត្រូវបានទទួលស្គាល់នោះមួយផ្នែក ឬទាំងអស់។ ការកាត់បន្ថយបែបនេះ នឹងត្រូវប្រែត្រឡប់មកវិញ រហូតដល់មានភាពប្រហែលថា នឹងមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់។

## ការវាស់វែងពន្ធបច្ចុប្បន្ន និងពន្ធពន្យារ

២៩.៣២ អង្គភាពមិនត្រូវធ្វើអប្បហារទ្រព្យសកម្ម និងបំណុលពន្ធបច្ចុប្បន្ន ឬពន្ធពន្យារទេ។

២៩.៣៣ នៅក្នុងយុត្តាធិការខ្លះពន្ធលើប្រាក់ចំណូល ត្រូវបង់តាមអត្រាខ្ពស់ ឬទាប ប្រសិនបើប្រាក់ចំណេញមួយផ្នែក ឬទាំងអស់ ឬចំណេញរក្សាទុក ត្រូវបានបង់ជាភាគលាភទៅឱ្យម្ចាស់ភាគហ៊ុនរបស់អង្គភាព។ ក្នុងប្រទេសខ្លះទៀតពន្ធលើប្រាក់ចំណូល អាចបង្វិលសងវិញ ឬអាចសង ប្រសិនបើប្រាក់ចំណេញមួយផ្នែក ឬទាំងអស់ ឬចំណេញរក្សាទុក ត្រូវបានបង់ជាភាគលាភ ទៅឱ្យម្ចាស់ភាគហ៊ុនរបស់អង្គភាព។ នៅក្នុងកាលៈទេសៈទាំងពីរនេះ អង្គភាពមួយ ត្រូវវាស់វែងពន្ធបច្ចុប្បន្ន និងពន្ធពន្យារ តាមអត្រាពន្ធ ដែលអនុវត្តចំពោះប្រាក់ចំណេញដែលមិនទាន់បែងចែករហូតដល់អង្គភាពទទួលស្គាល់បំណុលដើម្បីបង់ជាភាគលាភ។ ពេលដែលអង្គភាពទទួលស្គាល់បំណុលដើម្បីបង់ជាភាគលាភ អង្គភាពត្រូវទទួលស្គាល់បំណុល (ទ្រព្យសកម្ម) ពន្ធបច្ចុប្បន្ន ឬពន្ធពន្យារ និងចំណាយ (ចំណូល) ពន្ធដែលទាក់ទិន។

## ពន្ធកាត់ទុកលើភាគលាភ

២៩.៣៤ ពេលដែលអង្គភាពមួយបង់ភាគលាភទៅឱ្យម្ចាស់ភាគហ៊ុន អង្គភាពអាចត្រូវបានតម្រូវឱ្យបង់មួយចំណែកនៃភាគលាភទៅឱ្យអាជ្ញាធរពន្ធដារជំនួសឱ្យម្ចាស់ភាគហ៊ុន។ ចំនួនទឹកប្រាក់បែបនេះដែលបានបង់ ឬនឹងត្រូវបង់ទៅឱ្យអាជ្ញាធរពន្ធដារ គឺត្រូវបានគិតចូលទៅក្នុងមូលធនដោយចាត់ទុកជាផ្នែកមួយនៃភាគលាភ។

# ការបង្ហាញ

## ការបែងចែកនៅក្នុងចំណូលពេញលេញ និងមូលធន

២៩.៣៥ អង្គភាពត្រូវទទួលស្គាល់ចំណាយពន្ធក្នុងសមាសធាតុដូចគ្នា នៃចំណូលពេញលេញសរុប (ពោលគឺ ប្រតិបត្តិការបន្ត ប្រតិបត្តិការមិនបន្ត ឬចំណូលលម្អិតផ្សេងៗ) ឬមូលធន ជាប្រតិបត្តិការ ឬព្រឹត្តិការណ៍ផ្សេងទៀតដែលបានលទ្ធផលជាចំណាយពន្ធ។

## ភាពខុសគ្នារយៈពេលខ្លី/រយៈពេលវែង

២៩.៣៦ ពេលដែលអង្គភាពបង្ហាញទ្រព្យសកម្មរយៈពេលខ្លី និងរយៈពេលវែង និងបំណុលរយៈពេលខ្លី និងរយៈពេលវែង ជាការចាត់ថ្នាក់ដាច់ដោយឡែកក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព អង្គភាពមិនត្រូវចាត់ថ្នាក់ទ្រព្យសកម្ម (បំណុល) ពន្ធពន្យារណាមួយ ជាទ្រព្យសកម្ម (បំណុល) រយៈពេលខ្លីទេ។

## ការកាត់កង

២៩.៣៧ អង្គភាពមួយត្រូវកាត់កងទ្រព្យសកម្មពន្ធរយៈពេលខ្លី និងបំណុលពន្ធរយៈពេលខ្លី ឬកាត់កងទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារ ប្រសិនបើ និងលុះត្រាតែអង្គភាពនោះ មានសិទ្ធិតាមផ្លូវច្បាប់ឱ្យកាត់កង នូវចំនួនទឹកប្រាក់នោះ ហើយអង្គភាពអាចបង្ហាញ ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុថា ខ្លួនមានបំណងទូទាត់សងដោយឈរលើមូលដ្ឋានសុទ្ធ ឬទទួលទ្រព្យសកម្ម និងទូទាត់សងបំណុលព្រមជាមួយគ្នា។

# ការលាតត្រដាង

២៩.៣៨ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានដែលផ្តល់លទ្ធភាព ឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ របស់ខ្លួន ដើម្បីវាយតម្លៃពីប្រភេទ និងផលប៉ះពាល់ហិរញ្ញវត្ថុនៃលទ្ធផលពន្ធបច្ចុប្បន្ន និងពន្ធពន្យារ នៃប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀតដែលបានទទួលស្គាល់។

២៩.៣៩ អង្គភាពត្រូវលាតត្រដាងដោយឡែកនូវសមាសធាតុសំខាន់ៗ នៃចំណាយ (ចំណូល) ពន្ធ។ សមាសធាតុបែបនេះនៃចំណាយ (ចំណូល) ពន្ធ រួមបញ្ចូល:

(ក) ចំណាយ (ចំណូល) ពន្ធបច្ចុប្បន្ន

(ខ) ការកែសម្រួលណាមួយដែលបានទទួលស្គាល់ក្នុងគ្រាសម្រាប់ពន្ធបច្ចុប្បន្ននៃគ្រាមុនៗ។

(គ) ចំនួនទឹកប្រាក់នៃចំណាយ (ចំណូល) ពន្ធពន្យារដែលទាក់ទងនឹងការកើតឡើង និងការប្រែត្រឡប់មកវិញនៃភាពខុសគ្នាបណ្តោះអាសន្ន។

(ឃ) ចំនួនទឹកប្រាក់នៃចំណាយ (ចំណូល) ពន្ធពន្យារដែលទាក់ទងនឹងការផ្លាស់ប្តូរក្នុងអត្រាពន្ធ ឬការកំណត់ពន្ធថ្មីៗ។

(ង) ចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ ដែលកើតចេញពីខាតប្រាក់ពន្ធដែលមិនបានទទួលស្គាល់មុនៗ ឥណទានពន្ធ និងភាពខុសគ្នាបណ្តោះអាសន្ននៃគ្រាមុន ដែលត្រូវបានប្រើ ដើម្បីកាត់បន្ថយចំណាយពន្ធ។

(ច) ការកែសម្រួលចំពោះចំណាយ (ចំណូល) ពន្ធពន្យារដែលកើតចេញពីការផ្លាស់ប្ដូរក្នុងស្ថានភាពពន្ធនៃអង្គភាព ឬម្ចាស់ភាគហ៊ុនរបស់អង្គភាព។

(ឆ) ចំណាយ (ចំណូល) ពន្ធពន្យារដែលកើតចេញពីការកត់ត្រាក្នុងបញ្ជីនូវការថយចុះតម្លៃដែលទាបជាងថ្លៃដើម ឬការប្រែត្រឡប់មកវិញនៃការកត់ត្រាក្នុងបញ្ជីនូវការថយចុះតម្លៃដែលទាបជាងថ្លៃដើមនាកាលមុន នៃទ្រព្យសកម្មពន្ធពន្យារ ស្របតាមកថាខណ្ឌ២៩.៣១។

(ជ) ចំនួនទឹកប្រាក់នៃចំណាយ (ចំណូល) ពន្ធដែលទាក់ទងនឹងការផ្លាស់ប្ដូរក្នុងគោលនយោបាយគណនេយ្យ និងកំហុសឆ្គង ដែលត្រូវបានរួមបញ្ចូលក្នុងចំណេញ ឬខាត ស្របតាមផ្នែកទី១០ ស្ដីពីគោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និងកំហុសឆ្គង) ពីព្រោះទាំងនោះមិនអាចធ្វើគណនេយ្យកម្មត្រឡប់ក្រោយវិញបាន។

២៩.៤០ អង្គភាពមួយត្រូវលាតត្រដាងខ្លឹមសារខាងក្រោមដោយដាច់ដោយឡែកៈ

(ក) ពន្ធបច្ចុប្បន្ន និងពន្ធពន្យារសរុប ដែលទាក់ទងនឹងធាតុ ដែលត្រូវបានទទួលស្គាល់ជាធាតុនៃចំណូលលម្អិតផ្សេងៗ។

(ខ) ពន្ធបច្ចុប្បន្ន និងពន្ធពន្យារសរុប ដែលទាក់ទងនឹងធាតុ ដែលត្រូវកាត់ពី ឬបូកបញ្ចូលទៅក្នុងមូលធនដោយផ្ទាល់។

(គ) ការពន្យល់នៃភាពខុសគ្នាសំខាន់ៗរវាងចំណាយ (ចំណូល) ពន្ធនិងចំណេញគណនេយ្យ គុណនឹងអត្រាពន្ធដែលត្រូវអនុវត្ត។ ឧទាហរណ៍ៈ ភាពខុសគ្នាបែបនេះ អាចកើតចេញពីប្រតិបត្តិការទាំងឡាយ ដូចជា ចំណូល ដែលបានទទួលការលើកលែងពន្ធ ឬការចំណាយ ដែលមិនអាចកាត់កងបាន នៅក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ)។

(ឃ) ការពន្យល់ពីការផ្លាស់ប្ដូរអត្រាពន្ធដែលត្រូវអនុវត្ត ប្រៀបធៀបជាមួយការិយបរិច្ឆេទរាយការណ៍មុន។

(ង) សម្រាប់ប្រភេទនៃភាពខុសគ្នាបណ្ដោះអាសន្ននីមួយៗ និងសម្រាប់ប្រភេទនៃខាតប្រាក់ពន្ធដែលមិនបានប្រើ និងឥណទានពន្ធដែលមិនបានប្រើនីមួយៗៈ

(១) ចំនួនទឹកប្រាក់នៃបំណុលពន្ធពន្យារ និងទ្រព្យសកម្មពន្ធពន្យារនៅចុងការិយបរិច្ឆេទរាយការណ៍ និង

(២) ការវិភាគនៃការផ្លាស់ប្ដូរក្នុងបំណុលពន្ធពន្យារ និងទ្រព្យសកម្មពន្ធពន្យារក្នុងអំឡុងគ្រា។

(ច) ចំនួនទឹកប្រាក់ (និងកាលបរិច្ឆេទផុតកំណត់ បើសិនជាមាន) នៃភាពខុសគ្នាបណ្ដោះអាសន្នដែលកាត់កងបាន ខាតប្រាក់ពន្ធដែលមិនបានប្រើ និងឥណទានពន្ធដែលមិនបានប្រើ ដែលគ្មានទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

(ឆ) ក្នុងហេតុការណ៍ទាំងឡាយដែលបានរៀបរាប់ក្នុងកថាខណ្ឌ ២៩.៣៣ ការពន្យល់អំពីប្រភេទនៃលទ្ធផលពន្ធលើចំណូលដែលអាចមានដែលនឹងកើតចេញពីការទូទាត់នៃភាគលាភទៅឱ្យម្ចាស់ភាគហ៊ុន។

២៩.៤១ ប្រសិនបើអង្គភាពមួយមិនបានកាត់កងទ្រព្យសកម្មនិងបំណុលពន្ធ ស្របតាមកថាខណ្ឌ២៩.៣៧ ពីព្រោះអង្គភាពនោះមិនអាចបង្ហាញដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុថា ខ្លួនមានបំណងទូទាត់សងតាមមូលដ្ឋានសុទ្ធ ឬទទួលទាំងនោះព្រមជាមួយគ្នា នោះអង្គភាពត្រូវលាតត្រដាងពីចំនួនទឹកប្រាក់ដែលមិនទាន់បានកាត់កង និងមូលហេតុដែលការអនុវត្តការតម្រូវនេះ អាចនាំឱ្យមានចំណាយ ឬកិច្ចប្រឹងប្រែងច្រើនហួសហេតុ។

# ផ្នែកទី ៣០
# ការបកប្រែរូបិយប័ណ្ណបរទេស

## វិសាលភាពនៃផ្នែកនេះ

៣០.១ អង្គភាពមួយអាចប្រព្រឹត្តសកម្មភាពបរទេសតាមវិធីពីរយ៉ាង។ អង្គភាពអាចមានប្រតិបត្តិការជារូបិយប័ណ្ណបរទេស ឬអង្គភាពអាចមានប្រតិបត្តិការបរទេស។ លើសពីនេះទៅទៀត អង្គភាពអាចបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជារូបិយប័ណ្ណបរទេស។ ផ្នែកនេះកំណត់ពីរបៀបបញ្ចូលប្រតិបត្តិការរូបិយប័ណ្ណបរទេស និងប្រតិបត្តិការបរទេសនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព និងរបៀបបកប្រែរបាយការណ៍ហិរញ្ញវត្ថុទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញ។ ការធ្វើគណនេយ្យកម្មសម្រាប់ ឧបករណ៍ហិរញ្ញវត្ថុ ដែលទទួលបានតម្លៃពីការប្រែប្រួលនៃអត្រាប្តូរប្រាក់បរទេសជាក់លាក់ (ឧទាហរណ៍៖ កិច្ចសន្យាដោះដូររូបិយប័ណ្ណបរទេសទិញទុកជាមុន និងគណនេយ្យទប់ស្កាត់ហានិភ័យនៃជាតូរូបិយប័ណ្ណបរទេស ត្រូវបានដោះស្រាយក្នុងផ្នែកទី១២ ស្តីពីបញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ។

## រូបិយប័ណ្ណមុខងារ

៣០.២ អង្គភាពនីមួយៗត្រូវកំណត់រូបិយប័ណ្ណមុខងាររបស់ខ្លួន។ រូបិយប័ណ្ណមុខងាររបស់អង្គភាពមួយ គឺជារូបិយប័ណ្ណនៃបរិស្ថានសេដ្ឋកិច្ចចម្បងដែលក្នុងនោះអង្គភាពធ្វើប្រតិបត្តិការ។

៣០.៣ បរិស្ថានសេដ្ឋកិច្ចចម្បងដែលក្នុងនោះអង្គភាពធ្វើប្រតិបត្តិការ គឺជាធម្មតាជាបរិស្ថានសេដ្ឋកិច្ចមួយដែលក្នុងនោះអង្គភាពបង្កើត និងចំណាយសាច់ប្រាក់ជាចម្បង។ ដូច្នេះខាងក្រោមគឺជាកត្តាសំខាន់បំផុត ដែលអង្គភាពមួយពិចារណាក្នុងការកំណត់រូបិយប័ណ្ណមុខងាររបស់ខ្លួន៖

(ក) រូបិយប័ណ្ណ៖

(១) ដែលមានឥទ្ធិពលជាចម្បងលើតម្លៃលក់សម្រាប់ទំនិញ និងសេវាកម្ម (ជារឿយៗនេះនឹងជារូបិយប័ណ្ណដែលតម្លៃលក់សម្រាប់ទំនិញ និងសេវាកម្មរបស់ខ្លួនត្រូវកំណត់និងទូទាត់) និង

(២) នៃប្រទេសដែលកំលាំងប្រកួតប្រជែងនិងវិធានច្បាប់របស់ប្រទេសនោះ កំណត់ជាចម្បងនូវតម្លៃលក់នៃទំនិញ និងសេវាកម្ម។

(ខ) រូបិយប័ណ្ណដែលមានឥទ្ធិពលជាចម្បងលើចំណាយពលកម្ម វត្ថុធាតុដើម និង ចំណាយផ្សេងទៀតក្នុងការផ្តល់ទំនិញ ឬសេវា (ជារឿយៗ នេះជារូបិយប័ណ្ណដែលចំណាយបែបនេះត្រូវបានកំណត់ជា និងទូទាត់ជា)។

៣០.៤ កត្តាខាងក្រោមក៏អាចផ្តល់ផងដែរនូវភ័ស្តុតាងនៃរូបិយប័ណ្ណមុខងាររបស់អង្គភាព៖

(ក) រូបិយប័ណ្ណដែលប្រើប្រាស់ក្នុងការទទួលទឹកប្រាក់ (បោះផ្សាយឧបករណ៍បំណុលនិងមូលធន) ពីសកម្មភាពហិរញ្ញប្បទាន និង

(ខ) រូបិយប័ណ្ណដែលត្រូវបានរក្សាទុកជាទូទៅពេលទទួលទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ។

៣០.៥ កត្តាបន្ថែមទៀតខាងក្រោមត្រូវបានពិចារណា ក្នុងការកំណត់រូបិយប័ណ្ណមុខងារនៃប្រតិបត្តិការបរទេស ហើយថាតើរូបិយប័ណ្ណមុខងាររបស់ប្រតិបត្តិការបរទេសនោះដូចគ្នានឹងរូបិយប័ណ្ណមុខងារនៃអង្គភាពរាយការណ៍ (អង្គភាពរាយការណ៍នៅក្នុងបរិការណ៍នេះ ជាអង្គភាពដែលមានប្រតិបត្តិការបរទេសជាក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុនរបស់ខ្លួន)៖

(ក) ថាតើសកម្មភាពនៃប្រតិបត្តិការបរទេសនោះ ត្រូវបានអនុវត្តជាការលាតសន្ធឹងនៃអង្គភាពរាយការណ៍ជាជាងត្រូវបានអនុវត្តជាមួយនឹងកម្រិតនៃស្វយ័តភាពគួរឱ្យកត់សម្គាល់។ ឧទាហរណ៍នៃករណីមុខ គឺពេលដែលប្រតិបត្តិការបរទេសលក់តែទំនិញដែលបាននាំចូលពីអង្គភាពរាយការណ៍នោះ និងផ្ទេរប្រាក់លក់បាននោះទៅឱ្យអង្គភាពរាយការណ៍។ ឧទាហរណ៍នៃករណីក្រោយ គឺពេលដែលប្រតិបត្តិការបង្គរសាច់ប្រាក់ និងជាតួរូបិយវត្ថុផ្សេងទៀត កើតឡើងចំណាយ រកបានចំណូល និងរៀបចំការខ្ចីប្រាក់ ទាំងអស់នេះ ជាចម្បងប្រើប្រាស់ជារូបិយប័ណ្ណក្នុងស្រុក។

(ខ) ថាតើប្រតិបត្តិការជាមួយអង្គភាពរាយការណ៍គឺជាចំណែកខ្ពស់ឬទាបនៃសកម្មភាពប្រតិបត្តិការបរទេស។

(គ) ថាតើលំហូរសាច់ប្រាក់ពីសកម្មភាពនៃប្រតិបត្តិការបរទេសប៉ះពាល់ដោយផ្ទាល់លើ លំហូរសាច់ប្រាក់នៃអង្គភាពរាយការណ៍ និងបានត្រៀមរួចរាល់ដើម្បីផ្ទេរទៅឱ្យអង្គភាពរាយការណ៍។

(ឃ) ថាតើលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការបរទេស គ្រប់គ្រាន់សម្រាប់សងកាតព្វកិច្ចបំណុលដែលមានស្រាប់ និងដែលបានរំពឹងទុកជាធម្មតា ដោយមិនអាចមានថវិកាផ្តល់ដោយអង្គភាពរាយការណ៍។

# ការរាយការណ៍ប្រតិបត្តិការរូបិយប័ណ្ណបរទេសទៅតាមរូបិយប័ណ្ណមុខងារ

## ការទទួលស្គាល់ដំបូង

៣០.៦ ប្រតិបត្តិការរូបិយប័ណ្ណបរទេសគឺជាប្រតិបត្តិការដែលគណនាតម្លៃ ឬ តម្រូវឱ្យមានការទូទាត់ជារូបិយប័ណ្ណបរទេសដោយរួមមានប្រតិបត្តិការដែលកើតឡើងនៅពេលអង្គភាព៖

(ក) ទិញ ឬលក់ទំនិញ ឬសេវាដែលតម្លៃរបស់វាត្រូវបានគណនាតម្លៃជារូបិយប័ណ្ណបរទេស

(ខ) ខ្ចី ឬផ្តល់កម្ចីថវិកា នៅពេលដែលចំនួនទឹកប្រាក់ដែលត្រូវសង ឬត្រូវទទួលនោះ ត្រូវបានគណនាតម្លៃជារូបិយប័ណ្ណបរទេស ឬ

(គ) បើមិនដូច្នោះទេ ទទួលបានឬបញ្ចេញចោលនូវទ្រព្យសកម្មដែលគណនាតម្លៃជារូបិយប័ណ្ណបរទេស ឬ កើតមានឬទូទាត់បំណុលដែលគណនាតម្លៃជារូបិយប័ណ្ណបរទេស។

៣០.៧ អង្គភាពមួយត្រូវកត់ត្រាប្រតិបត្តិការរូបិយប័ណ្ណបរទេស នៅពេលទទួលស្គាល់ដំបូងទៅតាមរូបិយប័ណ្ណមុខងារ ដោយអនុវត្តទៅលើចំនួនទឹកប្រាក់រូបិយប័ណ្ណបរទេសនោះ នូវអត្រាប្តូរប្រាក់ដល់ដៃរវាងរូបិយប័ណ្ណមុខងារនិងរូបិយប័ណ្ណបរទេសនៅកាលបរិច្ឆេទនៃប្រតិបត្តិការ។

៣០.៨ កាលបរិច្ឆេទប្រតិបត្តិការ គឺជាកាលបរិច្ឆេទដែលប្រតិបត្តិការបំពេញនូវការទទួលស្គាល់លើកដំបូងដោយអនុលោមតាមស្តង់ដារនេះ។ ដើម្បីងាយក្នុងការអនុវត្ត អត្រាប្រហាក់ប្រហែលនឹងអត្រាជាក់ស្តែងនៅកាលបរិច្ឆេទប្រតិបត្តិការជារឿយៗត្រូវបានគេប្រើ ជាឧទាហរណ៍ អត្រាមធ្យមសម្រាប់មួយសប្តាហ៍ ឬ មួយខែ អាចត្រូវបានប្រើសម្រាប់ប្រតិបត្តិការទាំងអស់ក្នុងរូបិយប័ណ្ណបរទេសនីមួយៗ ដែលកើតឡើងនៅក្នុងការិយបរិច្ឆេទនោះ។ ប៉ុន្តែប្រសិនបើអត្រា

ប្តូរប្រាក់ឡើងចុះខ្លាំង ការប្រើអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទនោះមិនសមរម្យទេ។

## ការរាយការណ៍នៅចុងការិយបរិច្ឆេទរាយការណ៍បន្តបន្ទាប់

៣០.៩ នៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ អង្គភាពត្រូវ:

(ក) បកប្រែធាតុរូបិយវត្ថុរូបិយប័ណ្ណបរទេសដោយប្រើអត្រាចុងគ្រា

(ខ) បកប្រែធាតុមិនមែនរូបិយវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមប្រវត្តិជារូបិយប័ណ្ណបរទេស ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រត្តិបត្តិការ និង

(គ) បកប្រែធាតុមិនមែនរូបិយវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមស្របជារូបិយប័ណ្ណបរទេស ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃដែលតម្លៃសមស្របត្រូវបានកំណត់។

៣០.១០ អង្គភាពត្រូវទទួលស្គាល់ នៅក្នុងចំណេញឬខាតក្នុងគ្រាដែលវាកើតឡើង ភាពខុសគ្នាការប្តូរប្រាក់ដែលកើតឡើងក្នុងការទូទាត់ជាតុរូបិយវត្ថុឬក្នុងការបកប្រែជាតុរូបិយវត្ថុនៅអត្រាខុសគ្នាពីអត្រាដែលបានបកប្រែនាការទទួលស្គាល់ដំបូងក្នុងអំឡុងការិយបរិច្ឆេទ ឬក្នុងការិយបរិច្ឆេទមុនៗ លើកលែងតែដូចបានពិពណ៌នាក្នុងកថាខណ្ឌ ៣០.១៣។

៣០.១១ នៅពេលផ្នែកផ្សេងមួយទៀតនៃស្តង់ដារនេះតម្រូវឱ្យចំណេញ ឬខាតលើធាតុមិនមែនរូបិយវត្ថុ ត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ អង្គភាពត្រូវទទួលស្គាល់នូវសមាសភាគការប្តូរប្រាក់ណាមួយ នៃចំណេញឬខាតនោះនៅក្នុងចំណូលលម្អិតផ្សេងៗ។ ផ្ទុយទៅវិញ នៅពេលដែលចំណេញ ឬខាតលើធាតុមិនមែនរូបិយវត្ថុត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត អង្គភាពត្រូវទទួលស្គាល់នូវសមាសភាគការប្តូរប្រាក់ណាមួយ នៃចំណេញឬខាតនោះនៅក្នុងចំណេញ ឬ ខាត។

## ការវិនិយោគសុទ្ធក្នុងប្រតិបត្តិការបរទេស

៣០.១២ អង្គភាពអាចមានជាតុរូបិយវត្ថុ ដែលត្រូវទទួលពីឬត្រូវសងទៅឱ្យប្រតិបត្តិការបរទេស។ ជាតុដែលការទូទាត់សងមិនត្រូវបានធ្វើផែនការឬមិនទំនងជាកើតឡើងក្នុងអនាគតដែលអាចប៉ាន់ស្មានបាន គឺជាតុពិតជាផ្នែកមួយនៃការវិនិយោគសុទ្ធរបស់អង្គភាពនៅក្នុងប្រតិបត្តិការបរទេសនោះនិងត្រូវបានធ្វើគណនេយ្យកម្មស្របតាមកថាខណ្ឌ ៣០.១៣។ ជាតុរូបិយវត្ថុបែបនេះអាចរួមបញ្ចូលគណនីត្រូវទទួល ឬ កម្ចីរយៈពេលវែង។ ជាតុរូបិយវត្ថុទាំងនោះមិនរួមបញ្ចូលគណនីត្រូវទទួល ឬគណនីត្រូវសង។

៣០.១៣ ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណ ដែលកើតឡើងចំពោះជាតុរូបិយវត្ថុដែលបង្កើតជាចំណែកនៃការវិនិយោគសុទ្ធរបស់អង្គភាពរាយការណ៍ក្នុងប្រតិបត្តិការបរទេស ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែកនៃអង្គភាពរាយការណ៍ ឬរបាយការណ៍ហិរញ្ញវត្ថុទោលនៃប្រតិបត្តិការបរទេសនោះ តាមការសមរម្យ។ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលប្រតិបត្តិការបរទេស និងអង្គភាពរាយការណ៍ (ឧទាហរណ៍ របាយការណ៍ហិរញ្ញវត្ថុរួម ពេលដែលប្រតិបត្តិការបរទេសនោះជាក្រុមហ៊ុនបុត្រសម្ព័ន្ធ) ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណបរទេសបែបនេះ ត្រូវបានទទួលស្គាល់ដំបូង នៅក្នុងចំណូលលម្អិតផ្សេងៗ ហើយរាយការណ៍ជាសមាសជាតុមួយនៃមូលធន។ ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណបរទេសទាំងនោះ មិនត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតនៅពេលបញ្ចេញចោលនៃការវិនិយោគសុទ្ធនោះទេ។

## ការផ្លាស់ប្តូររូបិយប័ណ្ណមុខងារ

៣០.១៤ នៅពេលមានការផ្លាស់ប្តូររូបិយប័ណ្ណមុខងាររបស់អង្គភាព អង្គភាពត្រូវអនុវត្តនីតិវិធីបកប្រែ ដែលអាចប្រើបានចំពោះរូបិយប័ណ្ណមុខងារថ្មី ដោយអនុវត្តទៅមុខចាប់ពីថ្ងៃផ្លាស់ប្តូរតទៅ។

៣០.១៥ ដូចបានលើកឡើងក្នុងកថាខណ្ឌ ៣០.២-៣០.៥ រូបិយប័ណ្ណមុខងាររបស់អង្គភាពមួយឆ្លុះបញ្ចាំងពីប្រតិបត្តិការ ព្រឹត្តិការណ៍ និងស្ថានភាពស្នូលដែលទាក់ទងនឹងអង្គភាព។ ដូច្នេះ ការបើរូបិយប័ណ្ណមុខងារត្រូវបានកំណត់ រូបិយប័ណ្ណមុខងារនោះអាចត្រូវបានផ្លាស់ប្តូរតែនៅពេលមានការផ្លាស់ប្តូរទៅលើប្រតិបត្តិការ ព្រឹត្តិការណ៍ និងស្ថានភាពស្នូលទាំងនោះ។ ឧទាហរណ៍ ការប្រែប្រួលនៃរូបិយប័ណ្ណដែលមានឥទ្ធិពលជាចម្បងលើតម្លៃលក់នៃទំនិញនិងសេវាអាចនាំដល់ការផ្លាស់ប្តូររូបិយប័ណ្ណមុខងាររបស់អង្គភាព។

៣០.១៦ ឥទ្ធិពលនៃការផ្លាស់ប្តូររូបិយប័ណ្ណមុខងារ ត្រូវបានធ្វើគណនេយ្យកម្មដោយអនុវត្តទៅមុខ។ និយាយម៉្យាងទៀត អង្គភាពមួយបកប្រែធាតុទាំងអស់ ទៅជារូបិយប័ណ្ណមុខងារថ្មីនោះដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូររូបិយប័ណ្ណមុខងារ។ ចំនួនទឹកប្រាក់ដែលបានបកប្រែរួចសម្រាប់ធាតុមិនមែនរូបិយវត្ថុ ត្រូវបានចាត់ទុកជាថ្លៃដើមប្រវត្តិ។

## ការប្រើនូវរូបិយប័ណ្ណសម្រាប់ការបង្ហាញមួយ ដែលផ្សេងពីរូបិយប័ណ្ណមុខងារនោះ

### ការបកប្រែទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញ

៣០.១៧ អង្គភាពមួយអាចបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជារូបិយប័ណ្ណណាមួយ (ឬរូបិយប័ណ្ណច្រើន)។ ប្រសិនបើរូបិយប័ណ្ណសម្រាប់ការបង្ហាញនោះ ខុសពីរូបិយប័ណ្ណមុខងាររបស់អង្គភាព អង្គភាពត្រូវបកប្រែធាតុនៃចំណូលនិងចំណាយ និងស្ថានភាពហិរញ្ញវត្ថុ ទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញនោះ។ ជាឧទាហរណ៍ នៅពេលក្រុមមួយរួមមានបណ្តាអង្គភាពទោលដែលប្រើប្រាស់រូបិយប័ណ្ណមុខងារផ្សេងគ្នា ធាតុនៃចំណូល និងចំណាយ និង ស្ថានភាពហិរញ្ញវត្ថុនៃអង្គភាពនីមួយៗត្រូវបានបង្ហាញជារូបិយប័ណ្ណរួមមួយ ដូច្នេះទើបរបាយការណ៍ហិរញ្ញវត្ថុរួម អាចត្រូវបានបង្ហាញ។

៣០.១៨ អង្គភាពមួយដែលរូបិយប័ណ្ណមុខងាររបស់ខ្លួនមិនមែនជារូបិយប័ណ្ណនៃសេដ្ឋកិច្ចអតិផរណាខ្ពស់ ត្រូវបកប្រែលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ឱ្យទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញខុសគ្នាដោយប្រើនីតិវិធីដូចខាងក្រោម៖

(ក) ទ្រព្យសកម្ម និងបំណុលសម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗដែលបានបង្ហាញ (ពោលគឺ រួមបញ្ចូលតួលេខប្រៀបធៀប) ត្រូវបានបកប្រែតាមអត្រាចុងគ្រា នៅកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះ។

(ខ) ចំណូល និងចំណាយសម្រាប់របាយការណ៍ចំណូលពេញលេញនីមួយៗ (ពោលគឺ រួមបញ្ចូលតួលេខប្រៀបធៀប) ត្រូវបានបកប្រែតាមអត្រាប្តូរប្រាក់នៅបណ្តាកាលបរិច្ឆេទនៃប្រតិបត្តិការទាំងនោះ និង

(គ) ភាពខុសគ្នាពីការប្តូរប្រាក់ទាំងអស់ដែលកើតឡើងដោយហេតុនេះ ត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ និងរាយការណ៍ជាសមាសធាតុមួយរបស់មូលធន។ ភាពខុសគ្នាពីការប្តូរប្រាក់ទាំងនោះ មិនត្រូវចាត់ថ្នាក់ឡើងវិញជាចំណេញ ឬខាតជាបន្តបន្ទាប់ឡើយ។

៣០.១៩ ដោយមូលហេតុភាពនៃការអនុវត្តបាន អង្គភាពអាចប្រើអត្រាប្រហាក់ប្រហែលនឹងអត្រាប្តូរប្រាក់ នៅបណ្តាកាលបរិច្ឆេទនៃប្រតិបត្តិការទាំងនោះ ជាឧទាហរណ៍ អត្រាមធ្យមសម្រាប់គ្រា ដើម្បីបកប្រែធាតុចំណូល និងចំណាយ។ ប៉ុន្តែ ប្រសិនបើអត្រាប្តូរប្រាក់ឡើងចុះខ្លាំង ការប្រើអត្រាមធ្យមសម្រាប់គ្រាមិនសមស្របទេ។

៣០.២០ ភាពខុសគ្នាពីការប្តូរប្រាក់ ដែលបានលើកឡើងក្នុងកថាខណ្ឌ ៣០.១៨ (គ) កើតចេញពី:

(ក) ការបកប្រែចំណូលនិងចំណាយតាមអត្រាប្តូរប្រាក់ នៅបណ្តាកាលបរិច្ឆេទនៃប្រតិបត្តិការទាំងនោះ និងទ្រព្យសកម្មនិងបំណុលតាមអត្រាចុងគ្រា និង

(ខ) ការបកប្រែនូវទ្រព្យសកម្មសុទ្ធដើមគ្រាតាមអត្រាចុងគ្រាដែលខុសពីអត្រាចុងគ្រាមុន។

នៅពេលដែលភាពខុសគ្នាពីការប្តូរប្រាក់ទាក់ទងទៅនឹងប្រតិបត្តិការបរទេស ដែលត្រូវបានបូករួម ប៉ុន្តែមិនកាន់កាប់ទាំងស្រុង ភាពខុសគ្នាពីការប្តូរប្រាក់បង្គរដែលកើតពីការបកប្រែ និងដែលចាត់ទុកជារបស់ភាគកម្មមិនគ្រប់គ្រង ត្រូវបានបែងចែកទៅឱ្យ និងបានទទួលស្គាល់ជាផ្នែកមួយនៃ ភាគកម្មមិនគ្រប់គ្រងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម។

៣០.២១ អង្គភាពមួយដែលរូបិយប័ណ្ណមុខងាររបស់ខ្លួនជារូបិយប័ណ្ណនៃសេដ្ឋកិច្ចអតិផរណាខ្ពស់ ត្រូវបកប្រែលទ្ធផលនិងស្ថានភាពហិរញ្ញវត្ថុទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញដែលខុសគ្នា ដោយប្រើនីតិវិធីដែលកំណត់ក្នុងផ្នែកទី៣១ អតិផរណាខ្ពស់។

## ការបកប្រែនៃប្រតិបត្តិការបរទេសឱ្យទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់វិនិយោគិន

៣០.២២ ក្នុងការរួមបញ្ចូលទ្រព្យសកម្ម បំណុល ចំណូល និងចំណាយនៃប្រតិបត្តិការបរទេសទៅជាមួយនឹងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយទាំងនោះរបស់អង្គភាពរាយការណ៍ អង្គភាពត្រូវអនុវត្តតាមនិតិវិធីរួមបញ្ចូលធម្មតា ដូចជាការលុបចោលនូវសមតុល្យទៅមកផ្ទៃក្នុងក្រុម និងប្រតិបត្តិការទៅមកផ្ទៃក្នុងក្រុមរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ (សូមមើលផ្នែកទី៩ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក) និងនីតិវិធីការបកប្រែដែលបានកំណត់ក្នុងកថាខណ្ឌ ៣០.១៧-៣០.២១។ ប៉ុន្តែ ទ្រព្យសកម្ម (ឬបំណុល) រូបិយវត្ថុក្នុងក្រុម មិនថាតើរយៈពេលខ្លីឬរយៈពេលវែង មិនអាចត្រូវបានលុបចោលទល់នឹង បំណុល (ឬទ្រព្យសកម្ម) ក្នុងក្រុមដែលឆ្លើយតបដោយគ្មានការបង្ហាញលទ្ធផលនៃការឡើងចុះនៃរូបិយប័ណ្ណ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមទេ។ នេះដោយសារតែជាតួរូបិយវត្ថុនោះតំណាងឱ្យការប្តេជ្ញា ដើម្បីបំលែងរូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយទៀត និងធ្វើឱ្យអង្គភាពរាយការណ៍នោះប្រឈមនឹងចំណេញឬខាតតាមរយៈការឡើងចុះរូបិយប័ណ្ណ។ ដូច្នេះ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម អង្គភាពរាយការណ៍បន្តទទួលស្គាល់ភាពខុសគ្នាពីការប្តូរប្រាក់បែបនេះនៅក្នុងចំណេញឬខាត ឬ ប្រសិនបើវាកើតឡើងពីកាលៈទេសៈដែលបានរៀបរាប់ក្នុងកថាខណ្ឌ៣០.១៣ អង្គភាពត្រូវទទួលស្គាល់វាជាចំណូលលម្អិតផ្សេងៗ។

៣០.២៣ កេរ្តិ៍ឈ្មោះអាជីវកម្មដែលកើតឡើងពីការទិញប្រតិបត្តិការបរទេស ហើយការកែសម្រួលតម្លៃសមស្របណាមួយទៅលើតម្លៃយោងនៃទ្រព្យសកម្មនិងបំណុល ដែលកើតឡើងពីការទិញប្រតិបត្តិការបរទេសនោះ ត្រូវបានចាត់ទុកជាទ្រព្យសកម្មនិងបំណុលនៃប្រតិបត្តិការបរទេសនោះ។ ដូច្នេះ ទ្រព្យសកម្ម និងបំណុលទាំងនោះត្រូវបានបង្ហាញជារូបិយប័ណ្ណមុខងារនៃប្រតិបត្តិការបរទេស ហើយត្រូវបកប្រែតាមអត្រាចុងគ្រា ដោយអនុលោមតាមកថាខណ្ឌ ៣០.១៨។

## ការលាតត្រដាង

៣០.២៤ ក្នុងកថាខណ្ឌ ៣០.២៦ និង ៣០.២៧ ការលើកឡើងនៃ "រូបិយប័ណ្ណមុខងារ" សំដៅ ក្នុងករណីក្រុម ទៅលើរូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុនមេ។

៣០.២៥ អង្គភាពត្រូវបង្ហាញដូចខាងក្រោម:

(ក) ចំនួនទឹកប្រាក់នៃភាពខុសគ្នាពីការប្តូរប្រាក់ ដែលបានទទួលស្គាល់ក្នុងចំណេញឬខាតក្នុងគ្រា លើកលែងតែភាពខុសគ្នាពីការប្តូរប្រាក់ទាំងនោះដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្រប ហើយការប្រែប្រួលកត់ចូលចំណេញឬខាត ដោយអនុលោមតាមផ្នែកទី១១ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន និងផ្នែកទី១២ និង

(ខ) ចំនួនទឹកប្រាក់នៃភាពខុសគ្នាពីការប្តូរប្រាក់ ដែលកើតឡើងក្នុងគ្រានេះ និងត្រូវបានចាត់ថ្នាក់ជាសមាសធាតុដោយឡែក នៃមូលធននៅចុងគ្រា។

៣០.២៦ អង្គភាពមួយត្រូវលាតត្រដាងអំពីរូបិយប័ណ្ណ ដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជា។ ពេលរូបិយប័ណ្ណសម្រាប់ការបង្ហាញ ខុសពីរូបិយប័ណ្ណមុខងារ អង្គភាពត្រូវថ្លែងអង្គហេតុនោះ ហើយត្រូវលាតត្រដាងរូបិយប័ណ្ណមុខងារ និងហេតុផលសម្រាប់ការប្រើប្រាស់រូបិយប័ណ្ណសម្រាប់ការបង្ហាញខុសគ្នា។

៣០.២៧ នៅពេលមានការផ្លាស់ប្តូររូបិយប័ណ្ណមុខងារនៃអង្គភាពរាយការណ៍ ឬ ប្រតិបត្តិការបរទេសសំខាន់ អង្គភាពនោះត្រូវលាតត្រដាងអង្គហេតុនោះ និងមូលហេតុសម្រាប់ការផ្លាស់ប្តូររូបិយប័ណ្ណមុខងារ។

# ផ្នែកទី ៣១
# អតិផរណាខ្ពស់

## វិសាលភាពនៃផ្នែកនេះ

៣១.១ ផ្នែកនេះអនុវត្តចំពោះអង្គភាពដែលមានរូបិយប័ណ្ណមុខងារជារូបិយប័ណ្ណនៃសេដ្ឋកិច្ចអតិផរណាខ្ពស់។ ផ្នែកនេះ តម្រូវឱ្យអង្គភាពបែបនេះ រៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានកែសម្រួល សម្រាប់ឥទ្ធិពលនៃអតិផរណាខ្ពស់។

## សេដ្ឋកិច្ចអតិផរណាខ្ពស់

៣១.២ ផ្នែកនេះមិនបង្កើតឡើងនូវអត្រាដាច់ខាតមួយដែលសេដ្ឋកិច្ចត្រូវបានចាត់ទុកថាមានអតិផរណាខ្ពស់។ អង្គភាព ត្រូវធ្វើការវិនិច្ឆ័យនោះ ដោយពិចារណាគ្រប់ព័ត៌មានទាំងអស់ដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹម សូចនាករដែលអាចកើតឡើងនៃអតិផរណាខ្ពស់ដូចខាងក្រោម៖

(ក) ប្រជាពលរដ្ឋទូទៅចូលចិត្តរក្សាទ្រព្យសម្បត្តិរបស់ពួកគាត់ជាទ្រព្យសកម្មមិនមែនរូបិយវត្ថុ ឬជារូបិយប័ណ្ណបរទេសដែលមានស្ថេរភាពដោយប្រៀបធៀប។ ចំនួនទឹកប្រាក់នៃរូបិយប័ណ្ណក្នុងស្រុកដែលបានរក្សាទុក ត្រូវបានវិនិយោគភ្លាមដើម្បីរក្សាអំណាចទិញ។

(ខ) ប្រជាពលរដ្ឋទូទៅចាត់ទុកចំនួនទឹកប្រាក់រូបិយវត្ថុមិនវាស់វែងជារូបិយប័ណ្ណក្នុងស្រុក ប៉ុន្តែវាស់វែងជារូបិយប័ណ្ណបរទេសដែលមានស្ថេរភាពដោយប្រៀបធៀប។ តម្លៃអាចត្រូវបានលើកឡើងក្នុងរូបិយប័ណ្ណនោះ។

(គ) ការលក់ និងការទិញជំពាក់កើតឡើងតាមតម្លៃដែលសងការខាតរំពឹងទុកនៃអំណាចទិញ ក្នុងគ្រាជំពាក់ ទោះបីគ្រានោះខ្លីក៏ដោយ។

(ឃ) អត្រាការប្រាក់ ថ្លៃឈ្នួល និង តម្លៃត្រូវបានផ្សាភ្ជាប់ទៅនឹងសន្ទស្សន៍តម្លៃ។

(ង) អត្រាអតិផរណាបង្គរក្នុងរយៈពេល៣ឆ្នាំខិតជិត ឬលើស ១០០ ភាគរយ។

## ឯកតាវាស់វែងក្នុងរបាយការណ៍ហិរញ្ញវត្ថុ

៣១.៣ ចំនួនទឹកប្រាក់ទាំងអស់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃអង្គភាពមួយដែលរូបិយប័ណ្ណមុខងារគឺជារូបិយប័ណ្ណនៃសេដ្ឋកិច្ចអតិផរណាខ្ពស់ ត្រូវបានថ្លែងជាទម្រង់ឯកតាវាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍។ ព័ត៌មានប្រៀបធៀបសម្រាប់គ្រាមុនដែលបានតម្រូវដោយកថាខណ្ឌ ៣.១៤ និង ព័ត៌មានដែលបានបង្ហាញអំពីគ្រាមុន ក៏ត្រូវបានថ្លែងជាទម្រង់ឯកតាវាស់វែងបច្ចុប្បន្ននៅកាលបរិច្ឆេទរាយការណ៍។

៣១.៤ ការថ្លែងឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមផ្នែកនេះ តម្រូវឱ្យប្រើប្រាស់សន្ទស្សន៍តម្លៃទូទៅមួយដែលឆ្លុះបញ្ចាំងអំពីការប្រែប្រួលនៃអំណាចទិញទូទៅ។ នៅក្នុងសេដ្ឋកិច្ចភាគច្រើន មានសន្ទស្សន៍តម្លៃទូទៅដែលត្រូវបានទទួលស្គាល់ ធម្មតាត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល ដែលបណ្តាអង្គភាពនឹងយកតាម។

# នីតិវិធីសម្រាប់ការថ្លែងឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុថ្លៃដើមប្រវត្តិ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

៣១.៥ ចំនួនទឹកប្រាក់នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលមិនបានបង្ហាញជាទម្រង់ឯកតារង្វាស់វែង បច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍ត្រូវបានថ្លែងឡើងវិញដោយអនុវត្តសន្ទស្សន៍តម្លៃទូទៅ។

៣១.៦ ជាតុរូបិយវត្ថុមិនត្រូវបានថ្លែងឡើងវិញដោយសារជាតុរូបិយវត្ថុទាំងនោះត្រូវបានបង្ហាញជាទម្រង់ឯកតារង្វាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍។ ជាតុរូបិយវត្ថុគឺជាប្រាក់ដែលរក្សាទុកនិងជាតុត្រូវបានទទួលឬបង់ជាប្រាក់។

៣១.៧ ទ្រព្យសកម្ម និងបំណុលដែលភ្ជាប់ដោយកិច្ចព្រមព្រៀងទៅនឹងការប្រែប្រួលតម្លៃ ដូចជាសញ្ញាប័ណ្ណនិងកម្ចីភ្ជាប់នឹងសន្ទស្សន៍ត្រូវបានកែសម្រួល ដោយអនុលោមតាមកិច្ចព្រមព្រៀង និងត្រូវបានបង្ហាញតាមចំនួនទឹកប្រាក់ បានកែតម្រូវរួចនេះ ក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុបានថ្លែងឡើងវិញ។

៣១.៨ គ្រប់ទ្រព្យសកម្ម និង បំណុលផ្សេងទៀត មិនមែនរូបិយវត្ថុ៖

(ក) ជាតុមិនមែនរូបិយវត្ថុមួយចំនួនត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍ ដូចជាតម្លៃអាចប្តូរជាសាច់ប្រាក់សុទ្ធនិងតម្លៃសមស្រប ដូច្នេះពួកគេមិនត្រូវបានថ្លែងឡើងវិញទេ។ គ្រប់ទ្រព្យសកម្មនិងបំណុលមិនមែន រូបិយវត្ថុផ្សេងទៀត ត្រូវបានថ្លែងឡើងវិញ។

(ខ) ជាតុមិនមែនរូបិយវត្ថុភាគច្រើនត្រូវបានកត់ត្រាតាមថ្លៃដើម ឬ ថ្លៃដើមដករំលស់ ដូច្នេះ ពួកគេត្រូវបាន បង្ហាញតាមចំនួនទឹកប្រាក់បច្ចុប្បន្ននៅថ្ងៃទិញ។ ថ្លៃដើមបានថ្លែងឡើងវិញឬថ្លៃដើមដករំលស់ នៃជាតុទីមួយៗត្រូវបានកំណត់ដោយអនុវត្តចំពោះថ្លៃដើមប្រវត្តិ និងរំលស់បង្គរ នូវការប្រែប្រួលក្នុងសន្ទស្សន៍តម្លៃទូទៅពីថ្ងៃទិញដល់ចុងការិយបរិច្ឆេទរាយការណ៍។

(ខក) ជាតុមិនមែនរូបិយវត្ថុមួយចំនួនត្រូវបានកត់ត្រាតាម តម្លៃបច្ចុប្បន្ននាកាលបរិច្ឆេទទាំងឡាយ ដែលក្រៅពីកាលបរិច្ឆេទទិញ ឬកាលបរិច្ឆេទរាយការណ៍ ឧទាហរណ៍៖ ទ្រព្យ រោងចក្រ និងបរិក្ខារ ដែលត្រូវបានវាយតម្លៃឡើងវិញនៅកាលបរិច្ឆេទមុនណាមួយ។ ក្នុងករណីទាំងនេះ តម្លៃយោង ត្រូវថ្លែងឡើងវិញចាប់ពីកាលបរិច្ឆេទនៃការវាយតម្លៃឡើងវិញ។

(គ) ចំនួនទឹកប្រាក់បានថ្លែងឡើងវិញនៃជាតុមិនមែនរូបិយវត្ថុត្រូវបានកាត់បន្ថយ ដោយអនុលោមតាមផ្នែកទី២៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម ពេលតម្លៃនោះលើសពីចំនួនទឹកប្រាក់ ដែលអាចប្រមូលមកវិញបាន។

៣១.៩ នៅដើមគ្រាដំបូងនៃការអនុវត្តនៃផ្នែកនេះ បណ្តាសមាសជាតុនៃមូលធន លើកលែងចំណេញរក្សាទុក និងអតិរេកការវាយតម្លៃឡើងវិញ ត្រូវបានថ្លែងឡើងវិញដោយប្រើសន្ទស្សន៍តម្លៃទូទៅ ពីថ្ងៃដែលបណ្តាសមាសជាតុត្រូវបានដាក់ទុន ឬក៏បានកើតឡើងតាមរបៀបផ្សេង។ អតិរេកការវាយតម្លៃឡើងវិញណាមួយ ដែលបានកើតឡើងក្នុងគ្រាមុនៗ ត្រូវលុបចោល។ ចំណេញរក្សាទុកដែលបានថ្លែងឡើងវិញ ត្រូវបានទទួលពីចំនួនទឹកប្រាក់ផ្សេងទៀតទាំងអស់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលថ្លែងឡើងវិញ។

៣១.១០ នៅចុងគ្រាដំបូងនិងគ្រាបន្តបន្ទាប់ គ្រប់សមាសជាតុទាំងអស់នៃមូលធនរបស់ម្ចាស់ត្រូវបានថ្លែងឡើងវិញដោយប្រើសន្ទស្សន៍តម្លៃទូទៅពីដើមគ្រាដំបូងឬថ្ងៃដាក់ទុន ប្រសិនបើយឺតជាង។ ការផ្លាស់ប្តូរសម្រាប់គ្រាក្នុងមូលធនរបស់ម្ចាស់ ត្រូវបានលាតត្រដាងដោយអនុលោមតាមផ្នែកទី៦ ស្តីពីរបាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍ចំណូល និងចំណេញរក្សាទុក។

## របាយការណ៍ចំណូលពេញលេញ និងរបាយការណ៍លទ្ធផល

៣១.១១ ជាតុទាំងអស់នៅក្នុងរបាយការណ៍ចំណូលពេញលេញ (និងនៅក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបង្ហាញ) ត្រូវបានបង្ហាញជាទម្រង់ឯកតាវាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍។ ដូច្នេះ ចំនួនទឹកប្រាក់ទាំងអស់ចាំបាច់ត្រូវថ្លែងឡើងវិញដោយប្រើការប្រែប្រួលក្នុងសន្ទស្សន៍តម្លៃទូទៅ ពីបណ្តាថ្ងៃដែលជាតុនៃចំណូលនិងចំណាយត្រូវបានទទួលស្គាល់ជាលើកដំបូងក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ប្រសិនបើអតិផរណាទូទៅសឹងតែស្មើគ្នាពេញមួយគ្រា ហើយជាតុនៃចំណូលនិងចំណាយដែលបានកើតឡើងក៏ប្រហាក់ប្រហែលស្មើគ្នាពេញមួយគ្រា នោះអត្រាមធ្យមនៃអតិផរណាអាចជាសមស្រប។

## របាយការណ៍លំហូរសាច់ប្រាក់

៣១.១២ អង្គភាពមួយត្រូវបង្ហាញជាតុទាំងអស់នៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ ជាទម្រង់ឯកតាវាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍។

## ចំណេញ ឬខាត លើស្ថានភាពរូបិយវត្ថុសុទ្ធ

៣១.១៣ នៅក្នុងគ្រាមានអតិផរណា អង្គភាពដែលរក្សាទុកនូវទ្រព្យសកម្មរូបិយវត្ថុច្រើនជាងបំណុលរូបិយវត្ថុ ខាតអំណាចទិញ ហើយអង្គភាពដែលមានបំណុលរូបិយវត្ថុច្រើនជាងទ្រព្យសកម្មរូបិយវត្ថុ ចំណេញអំណាចទិញ ប្រសិនបើទ្រព្យសកម្មនិងបំណុលទាំងនោះមិនត្រូវបានភ្ជាប់ទៅនឹងកម្រិតតម្លៃ។ អង្គភាពត្រូវរួមបញ្ចូលក្នុងចំណេញឬខាតនូវចំណេញឬខាតលើស្ថានភាពរូបិយវត្ថុសុទ្ធ។ អង្គភាពត្រូវកាត់កងការកែសម្រួលចំពោះទ្រព្យសកម្មនិងបំណុលទាំងនោះ ដែលភ្ជាប់ដោយកិច្ចព្រមព្រៀងចំពោះការប្រែប្រួលតម្លៃ ដែលបានធ្វើឡើងដោយអនុលោមតាមកថាខណ្ឌ៣១.៧ ទល់នឹងចំណេញ ឬខាតលើស្ថានភាពរូបិយវត្ថុសុទ្ធ។

## សេដ្ឋកិច្ចលែងមានអតិផរណាខ្ពស់

៣១.១៤ នៅពេលដែលសេដ្ឋកិច្ចលែងមានអតិផរណាខ្ពស់ ហើយអង្គភាពមិនបន្តរៀបចំនិងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយអនុលោមតាមផ្នែកនេះ អង្គភាពនោះត្រូវចាត់ទុកចំនួនទឹកប្រាក់ដែលបានបង្ហាញ ជារូបិយប័ណ្ណសម្រាប់ការបង្ហាញ នៅចុងការិយបរិច្ឆេទរាយការណ៍មុន ជាមូលដ្ឋានសម្រាប់តម្លៃយោងក្នុងរបាយការណ៍ហិរញ្ញវត្ថុបន្តបន្ទាប់របស់អង្គភាពនោះ។

# ការលាតត្រដាង

៣១.១៥ អង្គភាពដែលអនុវត្តផ្នែកនេះត្រូវលាតត្រដាងដូចខាងក្រោម៖

(ក) អង្គហេតុដែលរបាយការណ៍ហិរញ្ញវត្ថុនិងទិន្នន័យគ្រាមុនៗ ត្រូវបានថ្លែងឡើងវិញសម្រាប់ការប្រែប្រួលក្នុងអំណាចទិញទូទៅនៃរូបិយប័ណ្ណមុខងារ

(ខ) អត្តសញ្ញាណនិងកម្រិតនៃសន្ទស្សន៍តម្លៃនៅកាលបរិច្ឆេទរាយការណ៍ និងការប្រែប្រួលក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន និងការិយបរិច្ឆេទរាយការណ៍មុន និង

(គ) ចំនួនទឹកចំណេញឬខាតលើជាតុរូបិយវត្ថុ។

# ផ្នែកទី ៣២
# ព្រឹត្តិការណ៍ក្រោយចុងការិយបរិច្ឆេទរាយការណ៍

## វិសាលភាពនៃផ្នែកនេះ

៣២.១ ផ្នែកនេះឱ្យនិយមន័យព្រឹត្តិការណ៍ក្រោយចុងការិយបរិច្ឆេទរាយការណ៍ និងកំណត់គោលការណ៍សម្រាប់ការទទួលស្គាល់ ការវាស់វែង និងការលាតត្រដាងព្រឹត្តិការណ៍ទាំងនោះ។

## និយមន័យនៃព្រឹត្តិការណ៍ក្រោយចុងការិយបរិច្ឆេទរាយការណ៍

៣២.២ ព្រឹត្តិការណ៍ក្រោយចុងការិយបរិច្ឆេទរាយការណ៍គឺជាព្រឹត្តិការណ៍ទាំងឡាយណា ដែលមានផលល្អនិងមិនមានផលល្អ ដែលកើតឡើងរវាងចុងការិយបរិច្ឆេទរាយការណ៍ និងថ្ងៃពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។ មានព្រឹត្តិការណ៍២ប្រភេទ៖

(ក) ព្រឹត្តិការណ៍ទាំងឡាយណាដែលផ្តល់ភ័ស្តុតាងនៃលក្ខខណ្ឌដែលបានកើតឡើង នៅចុងការិយបរិច្ឆេទរាយការណ៍ (ព្រឹត្តិការណ៍កែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍) និង

(ខ) ព្រឹត្តិការណ៍ដែលបញ្ជាក់ពីលក្ខខណ្ឌដែលបានកើតឡើងក្រោយចុងការិយបរិច្ឆេទរាយការណ៍ (ព្រឹត្តិការណ៍មិនកែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍)។

៣២.៣ ព្រឹត្តិការណ៍ក្រោយចុង ការិយបរិច្ឆេទរាយការណ៍រាប់បញ្ចូលនូវព្រឹត្តិការណ៍ទាំងអស់ រហូតដល់ថ្ងៃរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ ទោះបីជាព្រឹត្តិការណ៍ទាំងនោះកើតឡើងបន្ទាប់ពីការប្រកាសជាសាធារណៈ នូវចំណេញឬខាត ឬព័ត៌មានហិរញ្ញវត្ថុបានជ្រើសរើសផ្សេងៗ។

## ការទទួលស្គាល់ និងការវាស់វែង

### ព្រឹត្តិការណ៍កែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍

៣២.៤ អង្គភាពមួយត្រូវកែសម្រួលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន រាប់បញ្ចូលទាំងការលាតត្រដាងដែលទាក់ទងផង ដើម្បីឆ្លុះបញ្ចាំងពី ព្រឹត្តិការណ៍កែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍។

៣២.៥ ខាងក្រោមគឺ ឧទាហរណ៍នៃព្រឹត្តិការណ៍កែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍ដែលតម្រូវឱ្យអង្គភាព ធ្វើការកែសម្រួលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ឬដើម្បីទទួលស្គាល់ធាតុទាំងឡាយ ដែលមិនបានទទួលស្គាល់ពីមុន៖

(ក) ការបញ្ចប់ក្តីក្រោយចុងការិយបរិច្ឆេទរាយការណ៍នៃករណីតុលាការ ដែលបញ្ជាក់ថាអង្គភាពមានកាតព្វកិច្ចបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍។ អង្គភាពកែសម្រួលនូវសំវិធានធនណាមួយដែលបានទទួលស្គាល់ពីមុន ដែលទាក់ទិននឹងករណីតុលាការនេះដោយអនុលោមតាមផ្នែកទី២១ ស្តីពីសំវិធានធន និងយថាហេតុ ឬ ទទួលស្គាល់សំវិធានធនថ្មីមួយ។ អង្គភាពមិនគ្រាន់តែលាតត្រដាងនូវបំណុលយថាហេតុប៉ុណ្ណោះទេ។ ការបញ្ចប់ក្តីបែរជាផ្តល់ភ័ស្តុតាងបន្ថែមទៅវិញដើម្បីពិចារណាក្នុងការកំណត់សំវិធានធនដែលគួរបានទទួលស្គាល់ នៅចុងការិយបរិច្ឆេទរាយការណ៍ដោយអនុលោមតាមផ្នែកទី២១។

(ខ) ការទទួលព័ត៌មានក្រោយចុងការិយបរិច្ឆេទរាយការណ៍ ដែលបង្ហាញថាទ្រព្យសកម្មមួយបានថយចុះតម្លៃនៅចុងការិយបរិច្ឆេទរាយការណ៍ ឬថាចំនួនទឹកប្រាក់នៃការខាតពីការថយចុះតម្លៃដែលបានទទួលស្គាល់ពីមុនសម្រាប់ ទ្រព្យសកម្មនោះចាំបាច់ត្រូវធ្វើការកែសម្រួល។ ឧទាហរណ៍៖

(១) ការក្ស័យធនរបស់អតិថិជនដែលកើតឡើងក្រោយចុងការិយបរិច្ឆេទរាយការណ៍ ជាធម្មតាបញ្ជាក់ ថាមានការខាត នៅចុងការិយបរិច្ឆេទរាយការណ៍លើគណនីត្រូវទទួល ហើយថា អង្គភាពនោះចាំបាច់ត្រូវកែសម្រួលតម្លៃយោងនៃគណនីត្រូវទទួល និង

(២) ការលក់សន្និធិក្រោយចុងការិយបរិច្ឆេទរាយការណ៍អាចផ្តល់ភ័ស្តុតាង អំពីតម្លៃលក់របស់សន្និធិទាំងនោះនៅចុងការិយបរិច្ឆេទរាយការណ៍ សម្រាប់គោលបំណងវាយតម្លៃការថយចុះតម្លៃនៅថ្ងៃនោះ។

(គ) ការកំណត់ក្រោយចុងការិយបរិច្ឆេទរាយការណ៍នៃថ្លៃដើមទ្រព្យសកម្មដែលបានទិញ ឬចំណូលពីការលក់ទ្រព្យសកម្ម មុនពេលចុងការិយបរិច្ឆេទរាយការណ៍។

(ឃ) ការកំណត់ក្រោយចុងការិយបរិច្ឆេទរាយការណ៍នៃចំនួនទឹកប្រាក់នៃប្រាក់ចំណេញបែងចែក ឬការទូទាត់ប្រាក់បន្ថែម ប្រសិនបើអង្គភាពមានកាតព្វកិច្ចតាមច្បាប់ឬកាតព្វកិច្ចដោយសន្មត នៅចុងការិយបរិច្ឆេទរាយការណ៍ដើម្បីធ្វើការទូទាត់បែបនេះ ដោយជាលទ្ធផលនៃព្រឹត្តិការណ៍មុនថ្ងៃនោះ (សូមមើលផ្នែកទី២៨ ស្តីពីអត្ថប្រយោជន៍និយោជិត)។

(ង) ការរកឃើញនៃការបន្លំឬកំហុសឆ្គង ដែលបង្ហាញថារបាយការណ៍ហិរញ្ញវត្ថុនោះ មិនត្រឹមត្រូវ។

## ព្រឹត្តិការណ៍មិនកែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍

៣២.៦ អង្គភាពមិនត្រូវកែសម្រួលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ក្រោយចុងការិយបរិច្ឆេទរាយការណ៍។

៣២.៧ ឧទាហរណ៍នៃព្រឹត្តិការណ៍មិនកែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍រួមមាន:

(ក) ការថយចុះតម្លៃទីផ្សារនៃការវិនិយោគចន្លោះចុងការិយបរិច្ឆេទរាយការណ៍និងថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។ ការថយចុះតម្លៃទីផ្សារជាធម្មតាមិនទាក់ទងនិងលក្ខខណ្ឌនៃការវិនិយោគនៅចុងការិយបរិច្ឆេទរាយការណ៍ទេ ប៉ុន្តែឆ្លុះបញ្ចាំងពីកាលៈទេសៈដែលបានកើតឡើងជាបន្តបន្ទាប់។ ដូច្នេះ អង្គភាពមិនកែសម្រួលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការវិនិយោគនោះទេ។ ស្រដៀងគ្នានេះដែរ អង្គភាពមិនធ្វើបច្ចុប្បន្នភាពនូវចំនួនទឹកប្រាក់ដែលបានលាតត្រដាងសម្រាប់ការវិនិយោគនៅចុងការិយបរិច្ឆេទរាយការណ៍ ទោះបីជាអង្គភាពចាំបាច់ត្រូវផ្តល់ការលាតត្រដាងបន្ថែមដោយអនុលោមតាមកថាខណ្ឌ៣២.១០។

(ខ) ចំនួនទឹកប្រាក់ដែលក្លាយជាគណនីត្រូវទទួលដែលកើតឡើងពីការវិនិច្ឆ័យក្ដីដែលមានផលល្អ ឬការបញ្ចប់ក្ដីនៃករណីតុលាការក្រោយកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យចេញផ្សាយ។ នេះនឹងជាទ្រព្យសកម្មយថាហេតុនៅកាលបរិច្ឆេទរាយការណ៍ (សូមមើលកថាខណ្ឌ ២១.១៣) និងការលាតត្រដាងអាច ត្រូវបានតម្រូវដោយកថាខណ្ឌ ២១.១៦។ ប៉ុន្តែ កិច្ចព្រមព្រៀងលើចំនួនទឹកប្រាក់នៃការខូចខាតសម្រាប់ការវិនិច្ឆ័យក្ដី ដែលបានធ្វើឡើងមុនពេលកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែមិនត្រូវបានទទួលស្គាល់ពីមុនដោយសារចំនួនទឹកប្រាក់នោះ មិនអាចត្រូវបានវាស់វែងដោយទុកចិត្តបាន អាចបង្កើតជាព្រឹត្តិការណ៍កែសម្រួល។

### ភាគលាភ

៣២.៨ ប្រសិនបើអង្គភាពប្រកាសភាគលាភទៅឱ្យអ្នកកាន់ឧបករណ៍មូលធនរបស់ខ្លួន ក្រោយចុងការិយបរិច្ឆេទរាយការណ៍ អង្គភាពមិនត្រូវទទួលស្គាល់ភាគលាភទាំងនោះជាបំណុលនៅចុងការិយបរិច្ឆេទរាយការណ៍ទេ។ ចំនួនទឹកប្រាក់នៃភាគលាភអាចត្រូវបានបង្ហាញជាសមាសធាតុដាច់ដោយឡែកមួយ នៃចំណេញរក្សាទុកនៅចុងការិយបរិច្ឆេទរាយការណ៍។

## ការលាតត្រដាង

### កាលបរិច្ឆេទអនុញ្ញាតឱ្យចេញផ្សាយ

៣២.៩ អង្គភាពត្រូវលាតត្រដាងថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យចេញផ្សាយ និងអ្នកណាជាអ្នកផ្ដល់ការអនុញ្ញាត។ ប្រសិនបើម្ចាស់អង្គភាពឬអ្នកផ្សេងទៀតមានអំណាច ក្នុងការកែប្រែរបាយការណ៍ហិរញ្ញវត្ថុក្រោយការចេញផ្សាយ អង្គភាពត្រូវលាតត្រដាងអង្គហេតុនោះ។

### ព្រឹត្តិការណ៍មិនកែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍

៣២.១០ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោម សម្រាប់ចំណាត់ថ្នាក់នីមួយៗនៃព្រឹត្តិការណ៍មិនកែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍៖

(ក) សារជាតិនៃព្រឹត្តិការណ៍ និង

(ខ) ការប៉ាន់ស្មាននៃឥទ្ធិពលហិរញ្ញវត្ថុរបស់ព្រឹត្តិការណ៍មិនកែសម្រួល ឬការថ្លែងបញ្ជាក់ដែលការប៉ាន់ស្មានបែបនេះមិនអាចត្រូវបានធ្វើឡើង។

៣២.១១ ខាងក្រោមគឺជាឧទាហរណ៍នៃព្រឹត្តិការណ៍មិនកែសម្រួលក្រោយចុងការិយបរិច្ឆេទរាយការណ៍ ដែលជាទូទៅត្រូវលាតត្រដាង ការលាតត្រដាងនឹងឆ្លុះបញ្ចាំងពីព័ត៌មានដែលបានដឹង ក្រោយចុងការិយបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យចេញផ្សាយ៖

(ក) ការរួមបញ្ចូលអាជីវកម្មចម្បង ឬការបញ្ចេញចោលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធចម្បងមួយ

(ខ) សេចក្ដីប្រកាសពីផែនការមិនបន្តប្រតិបត្តិការ

(គ) ការទិញទ្រព្យសកម្ម ការបញ្ចេញចោល ឬផែនការបញ្ចេញចោលទ្រព្យសកម្មចម្បង ឬការដកហូតទ្រព្យសកម្មចម្បងដោយរដ្ឋាភិបាល។

(ឃ) ការបំផ្លាញនូវរោងចក្រផលិតសំខាន់ដោយអគ្គិភ័យ។

(ង) សេចក្តីប្រកាស ឬ ការចាប់ផ្តើមនៃការអនុវត្តនៃការស្តាបនាឡើងវិញ

(ច) ការបោះផ្សាយ ឬការទិញមកវិញនូវឧបករណ៍បំណុល ឬឧបករណ៍មូលធនរបស់អង្គភាព

(ឆ) ការប្រែប្រួលទ្រង់ទ្រាយធំមិនធម្មតានៅក្នុងតម្លៃទ្រព្យសកម្ម ឬអត្រាប្តូរប្រាក់បរទេស

(ជ) ការប្រែប្រួលអត្រាពន្ធ ឬច្បាប់ពន្ធដារដែលបានអនុម័ត ឬបានប្រកាសដែលមានឥទ្ធិពលសំខាន់លើទ្រព្យសកម្ម និងបំណុលពន្ធបច្ចុប្បន្ននិងពន្យារ

(ឈ) ឈានចូលក្នុងការសន្យា ឬបំណុលយថាហេតុសំខាន់ ឧទាហរណ៍ ដោយការផ្តល់ការធានាសំខាន់ និង

(ញ) ការចាប់ផ្តើមនៃការប្តឹងសំខាន់ៗ ដែលគ្រាន់តែកើតពីព្រឹត្តិការណ៍ដែលបានកើតឡើងក្រោយចុងការិយបរិច្ឆេទរាយការណ៍។

# ផ្នែកទី ៣៣
# ការលាតត្រដាងពីភាគីពាក់ព័ន្ធ

## វិសាលភាពនៃផ្នែកនេះ

៣៣.១ ផ្នែកនេះតម្រូវឱ្យអង្គភាពបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុនូវការលាតត្រដាងចាំបាច់ ទាំងឡាយដើម្បីទាញការយកចិត្តទុកដាក់ចំពោះភវនីយភាព ដែលស្ថានភាពហិរញ្ញវត្ថុ ចំណេញឬខាតរបស់អង្គភាព ត្រូវបានប៉ះពាល់ដោយសារការមានភាគីពាក់ព័ន្ធ និងដោយប្រតិបត្តិការ ព្រមទាំងសមតុល្យមិនទាន់ទូទាត់ជាមួយភាគីបែបនេះ។

## និយមន័យភាគីពាក់ព័ន្ធ

៣៣.២ ភាគីពាក់ព័ន្ធគឺជាបុគ្គលឬអង្គភាពដែលទាក់ទងនឹងអង្គភាពដែលកំពុងរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន (អង្គភាពរាយការណ៍)៖

(ក) បុគ្គលម្នាក់ ឬសមាជិកជិតស្និទ្ធនៃគ្រួសាររបស់បុគ្គលនោះ ទាក់ទងនឹងអង្គភាពរាយការណ៍ ប្រសិនបើបុគ្គលនោះ៖

(១) ជាសមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់របស់អង្គភាពរាយការណ៍ ឬរបស់ក្រុមហ៊ុនមេនៃអង្គភាពរាយការណ៍

(២) មានការគ្រប់គ្រង ឬការគ្រប់គ្រងរួមលើអង្គភាពរាយការណ៍ ឬ

(៣) មានឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍នោះ។

(ខ) អង្គភាពមួយទាក់ទងនឹងអង្គភាពរាយការណ៍ ប្រសិនបើលក្ខខណ្ឌណាមួយខាងក្រោមអនុវត្ត៖

(១) អង្គភាពនិងអង្គភាពរាយការណ៍គឺជាសមាជិកនៃក្រុម (នេះមានន័យថាក្រុមហ៊ុនមេ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធដូចគ្នានីមួយៗ ទាក់ទងនឹងគ្នា) តែមួយ។

(២) អង្គភាពមួយ ជាក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន នៃអង្គភាពផ្សេតទៀត (ឬជាក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន របស់សមាជិកនៃក្រុមដែលអង្គភាពផ្សេងទៀតគឺជាសមាជិកនៃក្រុមនោះ)។

(៣) អង្គភាពទាំងពីរ គឺជាក្រុមហ៊ុនរួមទុននៃអង្គភាពទី៣តែមួយ។

(៤) អង្គភាពមួយ គឺជាក្រុមហ៊ុនរួមទុននៃអង្គភាពទី៣ ហើយអង្គភាពផ្សេងទៀត គឺជាក្រុមហ៊ុនញាតិសម្ព័ន្ធនៃអង្គភាពទី៣នោះ។

(៥) អង្គភាព គឺជាផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារសម្រាប់អត្ថប្រយោជន៍ និយោជិតនៃអង្គភាពរាយការណ៍ ឬអង្គភាពដែលទាក់ទងទៅនឹងអង្គភាពរាយការណ៍។ ប្រសិនបើអង្គភាពរាយការណ៍ខ្លួនឯងជាផែនការបែបនេះ និយោជកអ្នកផ្តួចផ្តើមក៏មានការទាក់ទងជាមួយអង្គភាពរាយការណ៍នោះផងដែរ។

(៦) អង្គភាពត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមដោយបុគ្គលម្នាក់ដែលបានបញ្ជាក់ក្នុង (ក)។

(៧) អង្គភាព ឬសមាជិកណាមួយនៃក្រុម ដែលអង្គភាពនោះជាផ្នែកមួយនៃក្រុមនោះ ផ្ដល់សេវាបុគ្គលិកគ្រប់គ្រងសំខាន់ ដល់អង្គភាពរាយការណ៍ ឬដល់ក្រុមហ៊ុនមេរបស់អង្គភាពរាយការណ៍។

(៨) បុគ្គលដែលបានបញ្ជាក់ក្នុង (ក)(២) មានឥទ្ធិពលសំខាន់លើអង្គភាព ឬជាសមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់របស់អង្គភាព (ឬរបស់ក្រុមហ៊ុនមេនៃអង្គភាពនោះ)។

៣៣.៣ ក្នុងការពិចារណាអំពីទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ ដែលអាចមាននីមួយៗ អង្គភាពត្រូវវាយតម្លៃជាតុពិតនៃទំនាក់ទំនង និងមិនគ្រាន់តែទម្រង់ច្បាប់នោះទេ។

៣៣.៤ នៅក្នុងបរិការណ៍នៃស្តង់ដារនេះ ដូចខាងក្រោមមិនប្រាកដជាភាគីពាក់ព័ន្ធនោះទេ៖

(ក) អង្គភាពពីរ គ្រាន់តែដោយសារអង្គភាពទាំងពីរនោះ មាននាយក១រូបឬសមាជិកផ្សេងទៀតនៃបុគ្គលិកគ្រប់គ្រងសំខាន់រួម។

(ខ) អ្នករួមទុន២នាក់ គ្រាន់តែដោយសារអ្នករួមទុន២នាក់នោះចែករំលែកការគ្រប់គ្រងរួមទៅលើក្រុមហ៊ុនរួមទុនមួយ។

(គ) ណាមួយដូចខាងក្រោម គ្រាន់តែដោយសារតែទំនាក់ទំនងទៅមកជាធម្មតារបស់ពួកគេជាមួយនឹងអង្គភាពមួយ (ទោះបីជាពួកគេអាចប៉ះពាល់សេរីភាពនៃទង្វើនៃអង្គភាពមួយ ឬចូលរួមក្នុងដំណើការនៃការសម្រេចចិត្តរបស់អង្គភាពនោះ)៖

(១) អ្នកផ្តល់ហិរញ្ញប្បទាន

(២) សហជីពកម្មករ

(៣) សេវាសាធារណៈ ឬ

(៤) ស្ថាប័ន និងភ្នាក់ងាររបស់រដ្ឋាភិបាល

(ឃ) អតិថិជន អ្នកផ្គត់ផ្គង់ អ្នកលក់សិទ្ធិជួញដូរ អ្នកចែកចាយ ឬភ្នាក់ងារទូទៅដែលអង្គភាពមានប្រតិបត្តិការអាជីវកម្មទំហំធំជាមួយ គ្រាន់តែដោយសារតែអនិស្សរភាពសេដ្ឋកិច្ចដែលជាលទ្ធផលនោះ។

# ការលាតត្រដាង

## ការលាតត្រដាងនូវទំនាក់ទំនងរវាងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

៣៣.៥ ទំនាក់ទំនងរវាងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានលាតត្រដាង មិនគិតថាមានឬគ្មានប្រតិបត្តិការភាគីពាក់ព័ន្ធនោះទេ។ អង្គភាពត្រូវលាតត្រដាងនូវឈ្មោះរបស់ក្រុមហ៊ុនមេរបស់ខ្លួននិង ប្រសិនបើខុសគ្នា ភាគីគ្រប់គ្រងចុងក្រោយប្រសិនបើខុសគ្នា។ ប្រសិនបើទាំងក្រុមហ៊ុនមេនិងភាគីគ្រប់គ្រងចុងក្រោយរបស់អង្គភាព មិនបានផលិតរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការប្រើប្រាស់ជាសាធារណៈនោះទេ ឈ្មោះនៃក្រុមហ៊ុនមេធំជាងគេបន្ទាប់ដែលធ្វើដូច្នោះ (ប្រសិនបើមាន) ក៏ត្រូវលាតត្រដាងផងដែរ។

## ការលាតត្រដាងនូវការតបស្នងបុគ្គលិកគ្រប់គ្រងសំខាន់

៣៣.៦ បុគ្គលិកគ្រប់គ្រងសំខាន់ គឺជាបុគ្គល ដែលមានសិទ្ធិអំណាចនិងការទទួលខុសត្រូវធ្វើផែនការ ត្រួតពិនិត្យ និងគ្រប់គ្រងសកម្មភាពរបស់អង្គភាពដោយផ្ទាល់ ឬដោយប្រយោលរួមបញ្ចូលនូវនាយកណាមួយ (មិនថាជាអ្នកប្រតិបត្តិឬមិនមែននោះទេ) នៃអង្គភាពនោះ។ ការតបស្នងរួមបញ្ចូលអត្ថប្រយោជន៍និយោជិតទាំងអស់ (ដែលបានកំណត់ក្នុងផ្នែកទី២៨ ស្តីពីអត្ថប្រយោជន៍និយោជិត) រួមមានអត្ថប្រយោជន៍ទាំងឡាយក្នុងទម្រង់ការទូទាត់ដោយផ្អែកលើភាគហ៊ុន (សូមមើលផ្នែកទី២៦ ស្តីពីការទូទាត់ដោយផ្អែកលើភាគហ៊ុន)។ អត្ថប្រយោជន៍និយោជិតរួមមានគ្រប់ទម្រង់ទាំងអស់នៃតម្លៃតបស្នងដែលបានទូទាត់ ត្រូវសង ឬបានផ្តល់ដោយអង្គភាព ឬតំណាងឱ្យអង្គភាព (ឧទាហរណ៍ ដោយក្រុមហ៊ុនមេរបស់គេ ឬដោយម្ចាស់ភាគហ៊ុន) ក្នុងការដោះដូរនូវសេវាដែលបានផ្តល់ទៅឱ្យអង្គភាពនោះ។ អត្ថប្រយោជន៍និយោជិតក៏រួមបញ្ចូលផងដែរនូវការតបស្នងដែលបានទូទាត់ដោយតាងនាមឱ្យក្រុមហ៊ុនមេរបស់អង្គភាពនោះ អំពីទំនិញ ឬសេវាដែលបានផ្តល់ទៅឱ្យអង្គភាពនោះ។

៣៣.៧ អង្គភាពត្រូវលាតត្រដាងនូវតម្លៃតបស្នងជាចំនួនសរុបរបស់បុគ្គលិកគ្រប់គ្រងសំខាន់។

## ការលាតត្រដាងនូវប្រតិបត្តិការភាគីពាក់ព័ន្ធ

៣៣.៨ ប្រតិបត្តិការភាគីពាក់ព័ន្ធគឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងអង្គភាពរាយការណ៍ និងភាគីពាក់ព័ន្ធ ដោយមិនគិតថាតម្លៃត្រូវបានគេគិតឬអត់នោះទេ។ ឧទាហរណ៍នៃប្រតិបត្តិការភាគីពាក់ព័ន្ធដែលទូទៅចំពោះ អង្គភាពធុនតូចនិងមធ្យម រួមបញ្ចូលតែមិនបានកម្រិតត្រឹម៖

(ក) ប្រតិបត្តិការរវាងអង្គភាព និងម្ចាស់ចម្បង

(ខ) ប្រតិបត្តិការរវាងអង្គភាព និងអង្គភាពផ្សេងទៀតនៅពេលដែលអង្គភាពទាំងពីរស្ថិតនៅក្រោមការគ្រប់គ្រងរួមរបស់អង្គភាព ឬ បុគ្គលទោល និង

(គ) ប្រតិបត្តិការដែលអង្គភាព ឬបុគ្គលដែលគ្រប់គ្រងអង្គភាពរាយការណ៍បានកើតឡើងចំណាយដោយផ្ទាល់ ដែលតាមដើមឡើយត្រូវបានរ៉ាប់រងដោយអង្គភាពរាយការណ៍។

៣៣.៩ ប្រសិនបើអង្គភាពមានប្រតិបត្តិការភាគីពាក់ព័ន្ធ អង្គភាពនោះត្រូវលាតត្រដាងសារជាតិនៃទំនាក់ទំនងភាគីពាក់ព័ន្ធក៏ដូចជាព័ត៌មានអំពីប្រតិបត្តិការ សមតុល្យមិនទាន់បានទូទាត់ និងការសន្យាចាំបាច់ទាំងឡាយសម្រាប់ការយល់ដឹងនៃឥទ្ធិពលសក្តានុពលនៃទំនាក់ទំនងនោះលើរបាយការណ៍ហិរញ្ញវត្ថុ។ ការតម្រូវការលាតត្រដាង គឺបន្ថែមលើការតម្រូវក្នុងកថាខណ្ឌ៣៣.៧ ដើម្បីលាតត្រដាងនូវតម្លៃតបស្នងបុគ្គលិកគ្រប់គ្រងសំខាន់។ ជាអប្បបរមា ការលាតត្រដាងត្រូវរួមបញ្ចូលនូវ៖

(ក) ចំនួនទឹកប្រាក់នៃប្រតិបត្តិការ

(ខ) ចំនួនទឹកប្រាក់នៃសមតុល្យមិនទាន់បានទូទាត់ និង៖

(១) លក្ខខណ្ឌរបស់ពួកគេ រួមបញ្ចូលថាតើលក្ខខណ្ឌទាំងនោះត្រូវបានធានានិងសារជាតិនៃការតបស្នងដែលត្រូវផ្តល់ក្នុងការទូទាត់ និង

(២) ព័ត៌មានលម្អិតនៃការធានាណាមួយដែលបានផ្តល់ ឬបានទទួល។

(គ) សំវិធានធនសម្រាប់គណនីត្រូវទទួលមិនអាចប្រមូលបាន ដែលទាក់ទិននឹងចំនួនទឹកប្រាក់នៃសមតុល្យមិនទាន់បានទូទាត់ និង

(ឃ) ចំណាយដែលបានទទួលស្គាល់ក្នុងគ្រា ដែលទាក់ទងនឹងបំណុលស្អុយឬជាប់សង្ស័យ ត្រូវសងឱ្យដោយភាគីពាក់ព័ន្ធ។

ប្រតិបត្តិការបែបនេះអាចរួមបញ្ចូលការទិញ ការលក់ឬការផ្ទេរនូវទំនិញឬសេវា ភតិសន្យា ការធានា និងការទូទាត់ដោយអង្គភាពតាងនាមឱ្យភាគីពាក់ព័ន្ធឬផ្ទុយមកវិញ។

៣៣.១០ អង្គភាពត្រូវធ្វើការលាតត្រដាង ដែលបានតម្រូវដោយកថាខណ្ឌ៣៣.៩ ដោយឡែកសម្រាប់ចំណាត់ថ្នាក់នីមួយៗដូចខាងក្រោម:

(ក) អង្គភាពទាំងឡាយដែលអង្គភាពនោះមានការគ្រប់គ្រង ការគ្រប់គ្រងរួម ឬ ឥទ្ធិពលសំខាន់លើ

(ខ) អង្គភាពទាំងឡាយលើអង្គភាពដែលមានការគ្រប់គ្រង ការគ្រប់គ្រងរួម ឬឥទ្ធិពលសំខាន់ៗ

(គ) បុគ្គលិកគ្រប់គ្រងសំខាន់នៃអង្គភាព ឬក្រុមហ៊ុនមេរបស់អង្គភាពនោះ (ក្នុងចំនួនសរុប) និង

(ឃ) ភាគីពាក់ព័ន្ធផ្សេងទៀត។

៣៣.១១ អង្គភាពមួយត្រូវបានលើកលែងពីការតម្រូវការលាតត្រដាងនៃកថាខណ្ឌ ៣៣.៩ ដែលទាក់ទងនឹង៖

(ក) រដ្ឋ (រដ្ឋាភិបាលជាតិ រដ្ឋាភិបាលតំបន់ ឬ រដ្ឋាភិបាលមូលដ្ឋាន) ដែលមានការគ្រប់គ្រង ការគ្រប់គ្រងរួម ឬឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍ និង

(ខ) អង្គភាពមួយផ្សេងទៀតដែលជាភាគីពាក់ព័ន្ធពីព្រោះរដ្ឋដូចគ្នាមានការគ្រប់គ្រង ការគ្រប់គ្រងរួម ឬឥទ្ធិពលសំខាន់លើទាំងអង្គភាពរាយការណ៍ និងអង្គភាពផ្សេងទៀត។

ប៉ុន្តែ អង្គភាពនៅត្រូវតែលាតត្រដាងនូវទំនាក់ទំនងក្រុមហ៊ុនមេ-ក្រុមហ៊ុនបុត្រសម្ព័ន្ធតាមការតម្រូវដោយកថាខណ្ឌ ៣៣.៥។

៣៣.១២ ខាងក្រោមគឺជាឧទាហរណ៍នៃប្រតិបត្តិការដែលត្រូវបានលាតត្រដាង ប្រសិនបើប្រតិបត្តិការទាំងនោះធ្វើឡើង ជាមួយភាគីពាក់ព័ន្ធ៖

(ក) ការទិញ ឬលក់ទំនិញ (ផលិតផលសម្រេច ឬមិនទាន់សម្រេច)

(ខ) ការទិញ ឬការលក់ទ្រព្យ និង ទ្រព្យសកម្មផ្សេងទៀត

(គ) ការផ្តល់សេវាកម្ម ឬការទទួលសេវាកម្ម

(ឃ) ភតិសន្យា

(ង) ការផ្ទេរការស្រាវជ្រាវ និងការអភិវឌ្ឍ

(ច) ការផ្ទេរក្រោមកិច្ចព្រមព្រៀងអាជ្ញាបណ្ណ

(ឆ) ការផ្ទេរក្រោមកិច្ចព្រមព្រៀងហិរញ្ញប្បទាន (រួមបញ្ចូលកម្ចី និងការដាក់ទុនមូលធនជាសាច់ប្រាក់ ឬជាសម្ភារ:)

(ជ) លក្ខខណ្ឌនៃការធានា ឬ ទ្រព្យដាក់ធានា

(ឈ) ការទូទាត់បំណុលតាងនាមឱ្យអង្គភាព ឬដោយអង្គភាពតាងនាមឱ្យភាគីមួយទៀត និង

(ញ) ការចូលរួមដោយក្រុមហ៊ុនមេឬក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងផែនការអត្ថប្រយោជន៍កំណត់ ដែលចែករំលែក

ហានិភ័យរវាងអង្គភាពក្នុងក្រុម។

៣៣.១៣ អង្គភាពមិនត្រូវថ្លែងថាប្រតិបត្តិការភាគីពាក់ព័ន្ធត្រូវបានធ្វើឡើងលើលក្ខខណ្ឌដែលសមមូលទៅនឹង លក្ខខណ្ឌដែលអនុវត្តជាទូទៅក្នុងប្រតិបត្តិការជម្មតាលុះត្រាតែលក្ខខណ្ឌបែបនេះអាចត្រូវបានបញ្ជាក់។

៣៣.១៤ អង្គភាពអាចលាតត្រដាងបណ្ដាធាតុដែលមានសារជាតិស្រដៀងគ្នា ជាចំនួនសរុបលើកលែងតែពេលការលាតត្រដាងដោយឡែកចាំបាច់សម្រាប់ការយល់ដឹងនៃឥទ្ធិពលនៃប្រតិបត្តិការភាគីពាក់ព័ន្ធ លើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព។

# ផ្នែកទី ៣៤
# សកម្មភាពពិសេស

## វិសាលភាពនៃផ្នែកនេះ

៣៤.១ ផ្នែកនេះផ្តល់នូវការណែនាំពីការរាយការណ៍ហិរញ្ញវត្ថុដោយ អង្គភាពធុនតូចនិងមធ្យម ដែលទាក់ទិននឹងសកម្មភាពពិសេស៣ប្រភេទ រួមមាន កសិកម្ម សកម្មភាពនិស្សារណកម្ម និងសម្បទានសេវាកម្ម។

## កសិកម្ម

៣៤.២ អង្គភាពដែលប្រើស្តង់ដារនេះដោយប្រើស្តង់ដារនេះ ហើយចូលរួមក្នុងសកម្មភាពកសិកម្ម ត្រូវកំណត់គោលនយោបាយគណនេយ្យរបស់ខ្លួនសម្រាប់ថ្នាក់ទ្រព្យសកម្មជីវសាស្ត្រនីមួយៗរបស់អង្គភាព ដូចខាងក្រោម៖

(ក) អង្គភាពត្រូវប្រើគំរូតម្លៃសមស្របក្នុងកថាខណ្ឌ ៣៤.៤-៣៤.៧ សម្រាប់ទ្រព្យសកម្មជីវសាស្ត្រទាំងនោះដែលតម្លៃសមស្របងាយនឹងកំណត់ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ និង

(ខ) អង្គភាពត្រូវប្រើគំរូថ្លៃដើមក្នុងកថាខណ្ឌ ៣៤.៨-៣៤.១០ សម្រាប់ទ្រព្យសកម្មជីវសាស្ត្រទាំងអស់ផ្សេងទៀត

## ការទទួលស្គាល់

៣៤.៣ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មជីវសាស្ត្រឬផលិតផលកសិកម្មនៅពេលដែល និង មានតែនៅពេលដែល៖

(ក) អង្គភាពគ្រប់គ្រងទ្រព្យសកម្មនោះជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាល

(ខ) អត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលជាប់ទាក់ទងនឹងទ្រព្យសកម្មនោះអាចនឹងហូរចូលអង្គភាព និង

(គ) តម្លៃសមស្របឬថ្លៃដើមទ្រព្យសកម្មនោះ អាចត្រូវបានវាស់វែងបានដោយជឿជាក់ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ។

## ការវាស់វែង - គំរូតម្លៃសមស្រប

៣៤.៤ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មជីវសាស្ត្រនាការទទួលស្គាល់ដំបូង និងនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ តាមតម្លៃសមស្របដកចំណាយក្នុងការលក់របស់ទ្រព្យសកម្មជីវសាស្ត្រនោះ។ ការប្រែប្រួលតម្លៃសមស្របដកចំណាយក្នុងការលក់ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។

៣៤.៥ ផលិតផលកសិកម្មដែលបានប្រមូលផលពីទ្រព្យសកម្មជីវសាស្ត្ររបស់អង្គភាព ត្រូវបានវាស់វែងតាមតម្លៃសមស្របដកចំណាយក្នុងការលក់នៅពេលប្រមូលផល។ ការវាស់វែងបែបនេះគឺជាថ្លៃដើមនៅថ្ងៃនោះនៅពេលអនុវត្តផ្នែកទី១៣ ស្តីពីសន្និធិ ឬផ្នែកដែលអាចអនុវត្តបាន ផ្សេងទៀតនៃស្តង់ដារនេះ។

៣៤.៦ ក្នុងការកំណត់តម្លៃសមស្រប អង្គភាពត្រូវពិចារណាដូចខាងក្រោម៖

(ក) ប្រសិនបើទីផ្សារសកម្មមានសម្រាប់ទ្រព្យសកម្មជីវសាស្ត្រ ឬផលិតផលកសិកម្មក្នុងទីតាំងនិងលក្ខខណ្ឌបច្ចុប្បន្ន ថ្លៃលើកឡើងនៅក្នុងទីផ្សារនោះគឺជាមូលដ្ឋានសមស្របសម្រាប់កំណត់តម្លៃសមស្របនៃទ្រព្យសកម្មនោះ។ ប្រសិនបើអង្គភាពអាចចូលទៅទីផ្សារសកម្មផ្សេងទៀត អង្គភាពត្រូវប្រើតម្លៃដែលមានក្នុងទីផ្សារដែលអង្គភាពរំពឹងថានឹងចូលទៅ។

(ខ) ប្រសិនបើទីផ្សារសកម្មមិនមាននោះទេ អង្គភាពត្រូវប្រើមួយឬច្រើននៃវិធីខាងក្រោម ពេលអាចរកបាន ក្នុងការកំណត់តម្លៃសមស្រប:

(១) តម្លៃប្រតិបត្តិការទីផ្សារថ្មីបំផុត ឱ្យតែថាមិនមានការប្រែប្រួលសំខាន់ក្នុងស្ថានភាពសេដ្ឋកិច្ច នៅចន្លោះថ្ងៃនៃប្រតិបត្តិការនោះ និង ចុងការិយបរិច្ឆេទរាយការណ៍

(២) តម្លៃទីផ្សារសម្រាប់ទ្រព្យសកម្មស្រដៀងគ្នាមានការកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីភាពខុសគ្នា និង

(៣) គំរូស្តង់ដាររបស់ផ្នែក មានដូចជាតម្លៃនៃចម្ការផ្លែឈើដែលគិតជា ក្នុងការនាំចេញមួយថាស មួយល្អី មួយហិចតា និងតម្លៃនៃសត្វចិញ្ចឹមជើងបួន ដែលគិតជា ក្នុងមួយគីឡូនៃសាច់។

(គ) ក្នុងករណីខ្លះ ប្រភពព័ត៌មានដែលរៀបចេញនៅក្នុង(ក) ឬ(ខ) អាចស្នើឱ្យមានការសន្និដ្ឋានខុសគ្នា ចំពោះតម្លៃសមស្របនៃទ្រព្យសកម្មជីវសាស្ត្រឬផលិតផលសិកម្ម។អង្គភាពពិចារណាពីមូលហេតុនូវភាពខុសគ្នា ដើម្បីនាំទៅដល់ការប៉ាន់ស្មានដែលគួរឱ្យជឿជាក់បំផុត នៃតម្លៃសមស្របក្នុងបរិវេណការប៉ាន់ស្មានសមហេតុផលដែលចង្អៀតដោយជៀប។

(ឃ) ក្នុងស្ថានការណ៍ណ៍មួយចំនួន តម្លៃសមស្របអាចកំណត់បានរួចរាល់ដោយគ្មានចំណាយ ឬកិច្ចប្រឹងប្រែងហួសហេតុ ទោះបីថ្លៃឬតម្លៃកំណត់ដោយទីផ្សារមិនមានទេ សម្រាប់ទ្រព្យសកម្មជីវសាស្ត្រក្នុងលក្ខខណ្ឌបច្ចុប្បន្នរបស់ទ្រព្យសកម្មជីវសាស្ត្រនោះ។ អង្គភាពត្រូវពិចារណាថាតើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់សុទ្ធរំពឹងទុកពី ទ្រព្យសកម្មនោះដែលបានធ្វើអប្បហារតាមអត្រាកំណត់ដោយទីផ្សារបច្ចុប្បន្ន បានជាលទ្ធផលនូវការវាស់វែងតម្លៃសមស្រប ដែលគួរឱ្យជឿជាក់ឬអត់។

## ការលាតត្រដាង - គំរូតម្លៃសមស្រប

៣៤.៧ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោម ទាក់ទិននឹងទ្រព្យសកម្មជីវសាស្ត្ររបស់អង្គភាពដែលបានវាស់វែងតាមតម្លៃសមស្រប៖

(ក) ការរៀបរាប់ពីថ្នាក់ទ្រព្យសកម្មជីវសាស្ត្រនីមួយៗ

(ខ) វិធីសាស្ត្រនិងការសន្មតសំខាន់ៗដែលបានប្រើក្នុងការកំណត់តម្លៃសមស្រប នៃចំណាត់ថ្នាក់ផលិតផលកសិកម្មនីមួយៗ នៅពេលប្រមូលផល និង ចំណាត់ថ្នាក់នៃទ្រព្យសកម្មជីវសាស្ត្រនីមួយៗ។

(គ) ការផ្ទៀងផ្ទាត់នៃការប្រែប្រួលតម្លៃយោងនៃទ្រព្យសកម្មជីវសាស្ត្ររវាងដើមគ្រា និងចុងគ្រាបច្ចុប្បន្ន។ ការផ្ទៀងផ្ទាត់នេះត្រូវរួមបញ្ចូលនូវ៖

(១) ចំណេញ ឬខាតដែលកើតចេញពីការប្រែប្រួលតម្លៃសមស្របដកចំណាយក្នុងការលក់

(២) ការកើនឡើងដែលជាលទ្ធផលនៃការទិញ

(៣) ការថយចុះដែលជាលទ្ធផលនៃការប្រមូលផល

(៤) ការកើនឡើងដែលជាលទ្ធផលនៃការរួមបញ្ចូលអាជីវកម្ម

(៥) ភាពខុសគ្នាសុទ្ធពីការប្តូរប្រាក់ដែលកើតឡើងលើការបកប្រែរបាយការណ៍ហិរញ្ញវត្ថុ ទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញផ្សេង និង លើការបកប្រែប្រតិបត្តិការបរទេស ទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់អង្គភាពរាយការណ៍ និង

(៦) ការប្រែប្រួលផ្សេងទៀត។

ការផ្ទៀងផ្ទាត់នេះ មិនចាំបាច់បង្ហាញសម្រាប់ការិយបរិច្ឆេទមុនៗនោះទេ។

## ការវាស់វែង - គំរូថ្លៃដើម

៣៤.៨ អង្គភាពត្រូវវាស់វែងតាមថ្លៃដើមដករំលស់បង្គរនិងការខាតដោយការថយចុះតម្លៃបង្គរ នូវទ្រព្យសកម្មជីវសាស្ត្រទាំងនោះដែលតម្លៃសមស្របមិនអាចកំណត់បានរួចរាល់ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។

៣៤.៩ អង្គភាពត្រូវវាស់វែងផលិតផលកសិកម្មដែលបានប្រមូលផលពីទ្រព្យសកម្មជីវសាស្ត្ររបស់អង្គភាព តាមតម្លៃសមស្របដកចំណាយប៉ាន់ស្មានក្នុងការលក់។ ការវាស់វែងបែបនេះគឺជាថ្លៃដើមនៅថ្ងៃនោះ នៅពេល អនុវត្តផ្នែក១៣ ឬផ្នែកផ្សេងទៀតនៃស្តង់ដារនេះ។

## ការលាតត្រដាង - គំរូថ្លៃដើម

៣៤.១០ អង្គភាពត្រូវលាតត្រដាងដូចខាងក្រោមទាក់ទងនឹងទ្រព្យសកម្មជីវសាស្ត្ររបស់អង្គភាព ដែលបានវាស់វែងដោយប្រើគំរូថ្លៃដើម៖

(ក) ការរៀបរាប់ពីថ្នាក់ទ្រព្យសកម្មជីវសាស្ត្រនីមួយៗរបស់អង្គភាព

(ខ) ការពន្យល់ពីមូលហេតុដែលតម្លៃសមស្របមិនអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បាន ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ

(គ) វិធីសាស្ត្ររំលស់ដែលបានប្រើ

(ឃ) អាយុកាលអាចប្រើបាន ឬ អត្រារំលស់ដែលបានប្រើ និង

(ង) តម្លៃយោងដុលនិងរំលស់បង្គរ (រួមបញ្ចូលទាំងការខាតដោយការថយចុះតម្លៃបង្គរ) នៅដើមគ្រា និងចុងគ្រា។

## ការរុករក និងការវាយតម្លៃធនធានរ៉ែ

៣៤.១១ អង្គភាពមួយដែលប្រើស្តង់ដារនេះ ហើយដែលមានសកម្មភាពរុករក ឬវាយតម្លៃធនធានរ៉ែ ត្រូវកំណត់គោលនយោបាយគណនេយ្យ ដែលបញ្ជាក់ថា តើចំណាយណាខ្លះត្រូវទទួលស្គាល់ជាទ្រព្យសកម្មការរុករកនិងការវាយតម្លៃ ស្របតាមកថាខណ្ឌ១០.៤ និងអនុវត្តគោលនយោបាយនោះប្រកបដោយសង្គតិភាព។ អង្គភាពមួយទទួលបានការលើកលែងពីការអនុវត្តកថាខណ្ឌ១០.៥ ទៅលើគោលនយោបាយគណនេយ្យរបស់ខ្លួន សម្រាប់ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មការរុករកនិងការវាយតម្លៃ។

៣៤.១១ក ខាងក្រោមនេះ គឺជាឧទាហរណ៍នៃបណ្តាចំណាយ ដែលអាចដាក់បញ្ចូលក្នុងការវាស់វែងបឋមនូវទ្រព្យសកម្មការរុករកនិងការវាយតម្លៃ (បញ្ជីនេះរៀបរាប់មិនទាន់អស់ទេ)៖

(ក) ការទទួលបានសិទ្ធិរុករក

(ខ) ការសិក្សាអំពីឋានលេខា តំបន់ភូមិសាស្ត្រ ភូមិសាស្ត្រគីមី និងភូមិសាស្ត្ររូបនិយម

(គ) ការខួងរណ្ដៅរុករក

(ឃ) ការកសាងស្នាមភ្លោះ

(ង) ការយកសំណាក និង

(ច) សកម្មភាពដែលពាក់ព័ន្ធនឹងការវាយតម្លៃពីភាពទៅរួចនៃបច្ចេកទេស និងភាពទៅរួចផ្នែកពាណិជ្ជកម្មនៃការទាញយកធនធានរ៉ែ។

បណ្ដាការចំណាយ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានរ៉ែ មិនត្រូវទទួលស្គាល់ជាទ្រព្យសកម្មការរុករកនិងការវាយតម្លៃឡើយ។

៣៤.១១ខ ទ្រព្យសកម្មការរុករកនិងការវាយតម្លៃ ត្រូវវាស់វែងលើការទទួលស្គាល់ដំបូងតាមថ្លៃដើម។ បន្ទាប់ពីការទទួលស្គាល់ដំបូង អង្គភាពមួយត្រូវអនុវត្តផ្នែកទី១៧ ស្ដីពីទ្រព្យ រោងចក្រ និងបរិក្ខារ និងផ្នែកទី១៨ ស្ដីពីទ្រព្យអរូបីក្រៅពីកេរ្តិ៍ឈ្មោះអាជីវកម្ម ចំពោះទ្រព្យសកម្មការរុករកនិងការវាយតម្លៃ ស្របតាមលក្ខណៈនៃទ្រព្យសកម្ម ដែលទទួលបានស្របតាមកថាខណ្ឌ៣៤.១១ឃ-៣៤.១១ច។ ប្រសិនបើអង្គភាពមានកាតព្វកិច្ចរុះរើ ឬដកចេញជាតុណាមួយ ឬស្ដារទីតាំងឡើងវិញ កាតព្វកិច្ចបែបនោះ និងចំណាយ ត្រូវធ្វើគណនេយ្យកម្ម ស្របតាមផ្នែកទី១៧ និងផ្នែកទី២១ ស្ដីពីសំវិធានធន និងយថាភាព។

៣៤.១១គ ទ្រព្យសកម្មការរុករកនិងការវាយតម្លៃ ត្រូវធ្វើការវាយតម្លៃសម្រាប់ការថយចុះតម្លៃ នៅពេលដែលអង្គហេតុ និងកាលៈទេសៈ បង្ហាញថា តម្លៃយោងនៃទ្រព្យសកម្មការរុករកនិងការវាយតម្លៃ អាចលើសពីចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបានរបស់វា។ អង្គភាពត្រូវវាស់វែង បង្ហាញ និងលាតត្រដាងការខាតពីការថយចុះតម្លៃណាមួយដែលកើតឡើង ស្របតាមផ្នែកទី២៧ ស្ដីពីការថយចុះតម្លៃនៃទ្រព្យសកម្ម លើកលែងតែមានចែងក្នុងកថាខណ្ឌ៣៤.១១ច។

៣៤.១១ឃ សម្រាប់តែគោលបំណងនៃទ្រព្យសកម្មការរុករកនិងការវាយតម្លៃប៉ុណ្ណោះ កថាខណ្ឌ៣៤.១១ងត្រូវយកមកអនុវត្តជំនួសកថាខណ្ឌ២៧.៧-២៧.១០ នៅពេលកំណត់អត្តសញ្ញាណទ្រព្យសកម្មការរុករកនិងការវាយតម្លៃ ដែលអាចថយចុះតម្លៃ។ កថាខណ្ឌ៣៤.១១ង ប្រើពាក្យ ឪទ្រព្យសកម្មឪ ប៉ុន្តែត្រូវអនុវត្តស្មើគ្នា ចំពោះទ្រព្យសកម្មការរុករកនិងការវាយតម្លៃដាច់ដោយឡែក ឬអង្គភាពបង្កើតសាច់ប្រាក់។

៣៤.១១ង អង្គហេតុ និងកាលៈទេសៈមួយ ឬច្រើនខាងក្រោម សបញ្ជាក់ថា អង្គភាពមួយគួរតែធ្វើតេស្តទ្រព្យសកម្មការរុករកនិងការវាយតម្លៃ នូវការថយចុះតម្លៃ (បញ្ជីនេះរៀបរាប់មិនទាន់អស់ទេ)៖

(ក) រយៈពេល ដែលអង្គភាពមានសិទ្ធិធ្វើការរុករក នៅក្នុងតំបន់ជាក់លាក់មួយ បានផុតកំណត់ ក្នុងអំឡុងពេលនោះ ឬនឹងផុតកំណត់ក្នុងពេលអនាគតដ៏ខ្លីខាងមុខ ហើយមិនត្រូវបានរំពឹងថានឹងបន្តជាថ្មី។

(ខ) ការចំណាយសំខាន់ៗលើការរុករក និងវាយតម្លៃធនធានរ៉ែសម្រាប់ជំហានបន្ទាប់ ក្នុងតំបន់ជាក់លាក់ មិនរៀបចំថវិកា និងផែនការ។

(គ) ការរុករក និងវាយតម្លៃធនធានរ៉ែនៅក្នុងតំបន់ជាក់លាក់ មិនបាននាំដល់ការរកឃើញបរិមាណធនធានរ៉ែដែលអាចចំណេញខាងពាណិជ្ជកម្ម ហើយអង្គភាពបានសម្រេចចិត្តមិនបន្តសកម្មភាពបែបនេះនៅក្នុងតំបន់ជាក់លាក់នោះ។

(ឃ) មានទិន្នន័យគ្រប់គ្រាន់ចង្អុលបង្ហាញថា ទោះបីការអភិវឌ្ឍនៅក្នុងតំបន់ជាក់លាក់មួយទំនងជានឹងដំណើរការក៏ដោយ ក៏តម្លៃយោងនៃទ្រព្យសកម្មការរុករកនិងការវាយតម្លៃ មិនទំនងនឹងប្រមូលបានមកវិញពេញលេញពីការអភិវឌ្ឍដែលជោគជ័យ ឬដោយការលក់ទេ។

អង្គភាពត្រូវធ្វើតេស្តការថយចុះតម្លៃ និងទទួលស្គាល់នូវការខាតពីការថយចុះតម្លៃ ស្របតាមផ្នែកទី ២៧។

៣៤.១១ខ អង្គភាពត្រូវកំណត់គោលនយោបាយគណនេយ្យសម្រាប់បែងចែកទ្រព្យសកម្មការរុករកនិងការវាយតម្លៃ ទៅឱ្យអង្គភាពបង្កើតសាច់ប្រាក់ ឬក្រុមនៃអង្គភាពបង្កើតសាច់ប្រាក់ សម្រាប់គោលបំណងវាយតម្លៃ ការថយចុះតម្លៃនៃទ្រព្យសកម្មទាំងនោះ។

## ការរៀបចំសម្បទានសេវា

៣៤.១២ ការរៀបចំសម្បទានសេវាគឺជា ការរៀបចំដែលរដ្ឋាភិបាល ឬស្ថាប័នវិស័យសាធារណៈដទៃ (អ្នកផ្តល់) ធ្វើកិច្ចសន្យាជាមួយប្រតិបត្តិការឯកជនដើម្បីអភិវឌ្ឍ (ឬតំឡើងថ្នាក់) ប្រតិបត្តិនិងថែទាំ ទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធរបស់អ្នកផ្តល់ ដូចជា ផ្លូវ ស្ពាន ផ្លូវក្រោមដីឬកាត់ភ្នំ ព្រលានយន្តហោះ បណ្តាញចែកចាយថាមពល ពន្ធធនាគារ ឬមន្ទីរពេទ្យ។ នៅក្នុងការរៀបចំទាំងនោះ អ្នកផ្តល់ គ្រប់គ្រងឬរៀបចំតម្រង់ថាតើសេវាកម្មណាដែលប្រតិបត្តិករត្រូវផ្តល់ដោយប្រើទ្រព្យសកម្មចំពោះនរណានិងតាមតម្លៃប៉ុន្មាន ក៏ដូចជាគ្រប់គ្រងនូវផលប្រយោជន៍នៅសល់សំខាន់ៗនៅក្នុងទ្រព្យសកម្មនៅចុងរយៈពេលកំណត់នៃការរៀបចំនោះ។

៣៤.១៣ មានចំណាត់ថ្នាក់សំខាន់ៗចំនួន២ នៃការរៀបចំសម្បទានសេវា៖

(ក) ចំណាត់ថ្នាក់ទី១ ប្រតិបត្តិករទទួលទ្រព្យសកម្មហិរញ្ញវត្ថុ-សិទ្ធិគ្មានលក្ខខណ្ឌដើម្បីទទួលចំនួនសាច់ប្រាក់ ឬ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតជាក់លាក់ ឬអាចកំណត់ ពីរដ្ឋាភិបាលក្នុងការតបស្នងនូវការសាងសង់ ឬតំឡើងថ្នាក់ទ្រព្យសកម្មវិស័យសាធារណៈ និង បន្ទាប់មកប្រតិបត្តិការ និងថែទាំទ្រព្យសកម្មនោះក្នុងរយៈពេលមួយជាក់លាក់។ ចំណាត់ថ្នាក់នេះរួមបញ្ចូលការធានាដោយរដ្ឋាភិបាលដើម្បីទូទាត់ ការខ្វះខាតរវាងចំនួនទឹកប្រាក់ដែលបានទទួលពីអ្នកប្រើប្រាស់សេវាសាធារណៈនោះនិងចំនួនទឹកប្រាក់ជាក់លាក់ ឬអាចកំណត់។

(ខ) ចំណាត់ថ្នាក់មួយទៀត ប្រតិបត្តិករទទួលបានទ្រព្យសកម្មអរូបី-សិទ្ធិដើម្បីទទួលការទូទាត់នូវការប្រើ ទ្រព្យសកម្មវិស័យសាធារណៈដែលប្រតិបត្តិករនោះសាងសង់ឬតំឡើងថ្នាក់ និងបន្ទាប់មកប្រតិបត្តិ និងថែទាំក្នុងរយៈពេលមួយជាក់លាក់។ សិទ្ធិទទួលការទូទាត់ពីអ្នកប្រើប្រាស់មិនមែនជាសិទ្ធិគ្មានលក្ខខណ្ឌ ដើម្បីទទួលសាច់ប្រាក់ ពីព្រោះចំនួនទឹកប្រាក់អាស្រ័យទៅលើកម្រិតដែលសាធារណៈប្រើប្រាស់សេវានោះ។

ពេលខ្លះ កិច្ចសន្យាទោលអាចមានប្រភេទទាំងពីរ៖ ក្នុងករណីដែលរដ្ឋាភិបាលបានផ្តល់ការធានាគ្មានលក្ខខណ្ឌនៃការទូទាត់លើការសាងសង់ទ្រព្យសកម្មវិស័យសាធារណៈ ប្រតិបត្តិករនោះមានទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលប្រតិបត្តិករត្រូវពឹងផ្អែកលើសាធារណៈដែលប្រើប្រាស់សេវានោះ ដើម្បីទទួលបានការទូទាត់ ប្រតិបត្តិករមានទ្រព្យសកម្មអរូបី។

## គណនេយ្យកម្ម - គំរូទ្រព្យសកម្មហិរញ្ញវត្ថុ

៣៤.១៤ ប្រតិបត្តិករត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុប្រសិនបើប្រតិបត្តិករនោះមានសិទ្ធិឥតលក្ខខណ្ឌ ដើម្បីទទួលបានសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬតាមការណែនាំរបស់អ្នកផ្តល់សម្រាប់សេវាកម្មសាងសង់នោះ។

ប្រតិបត្តិករត្រូវវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុនោះតាមតម្លៃសមស្រប។ បន្ទាប់ពីនោះទៅ ប្រតិបត្តិករត្រូវអនុវត្តតាមផ្នែកទី១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និងផ្នែកទី១២ ស្តីពីបញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ ក្នុងការធ្វើគណនេយ្យកម្មសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ។

## គណនេយ្យកម្ម - គំរូទ្រព្យសកម្មអរូបី

៣៤.១៥ ប្រតិបត្តិករត្រូវទទួលស្គាល់ទ្រព្យសកម្មអរូបីប្រសិនបើប្រតិបត្តិករទទួលសិទ្ធិ (អាជ្ញាបណ្ណ) ដើម្បីទទួលការទូទាត់ពីអ្នកប្រើប្រាស់សេវាសាធារណៈនោះ។ ប្រតិបត្តិករត្រូវវាស់វែងលើកដំបូងនូវទ្រព្យសកម្មអរូបីនោះ តាមតម្លៃសមស្រប។ បន្ទាប់ពីនោះទៅ ប្រតិបត្តិករត្រូវអនុវត្តតាមផ្នែកទី១៨ ក្នុងការធ្វើគណនេយ្យកម្មសម្រាប់ទ្រព្យសកម្មអរូបីនោះ។

## ចំណូលប្រតិបត្តិការ

៣៤.១៦ ប្រតិបត្តិករនៃការរៀបចំសម្បទានសេវាត្រូវទទួលស្គាល់ វាស់វែង និងលាតត្រដាងចំណូលដោយអនុលោមតាមផ្នែកទី២៣ ស្តីពីចំណូល សម្រាប់សេវាកម្មដែលប្រតិបត្តិករនោះបំពេញ។

# ផ្នែកទី ៣៥
# ការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

## វិសាលភាពនៃផ្នែកនេះ

៣៥.១ ផ្នែកនេះអនុវត្តចំពោះ អង្គភាព អនុវត្តលើកដំបូងនូវស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមដោយមិនគិតពីគ្រោងក្របខ័ណ្ឌគណនេយ្យពីមុនជា ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ឬបណ្តុំផ្សេងទៀតនៃគោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ (GAAP) មានដូចជាស្តង់ដារគណនេយ្យជាតិរបស់អង្គភាព ឬ គ្រោងក្របខ័ណ្ឌផ្សេងទៀតដូចជាមូលដ្ឋានពន្ធលើប្រាក់ចំណូលក្នុងស្រុក។

៣៥.២ អង្គភាព ដែលបានអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម នៅក្នុងការិយបរិច្ឆេទរាយការណ៍មុន តែរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំលើកមុនដែលថ្មីៗបំផុត មិនមានសេចក្តីថ្លែងការណ៍ច្បាស់លាស់ និងឥតលាក់លៀម នៃការអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមនេះ ត្រូវតែអនុវត្តផ្នែកនេះ ឬអនុវត្តត្រឡប់ក្រោយនូវ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ស្របតាមផ្នែកទី១០ ស្តីពីគោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និងកំហុសឆ្គង ហាក់ដូចជាអង្គភាពមិនដែលបានឈប់អនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមនេះ។ នៅពេលដែលអង្គភាពប្រភេទនេះ មិនជ្រើសរើសអនុវត្តតាមផ្នែកនេះ អង្គភាពនេះក៏នៅតែត្រូវបានតម្រូវឱ្យអនុវត្តការតម្រូវឱ្យលាតត្រដាង ក្នុងកថាខណ្ឌ៣៥.១២ក បន្ថែមលើការតម្រូវឱ្យលាតត្រដាងនៅក្នុងផ្នែកទី១០។

## ការអនុវត្តលើកដំបូង

៣៥.៣ អង្គភាពអនុវត្តលើកដំបូងនូវស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាព ធុនតូច និងមធ្យម ត្រូវអនុវត្តផ្នែកនេះក្នុងរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់អង្គភាពដែលស្របតាមស្តង់ដារនេះ។

៣៥.៤ របាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់អង្គភាពដែលស្របតាមស្តង់ដារនេះ គឺជារបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដំបូងដែលអង្គភាពត្រូវធ្វើការថ្លែងការណ៍ច្បាស់លាស់ និងឥតលាក់លៀមក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនោះដែលអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។ របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយអនុលោមតាមស្តង់ដារនេះ គឺជារបាយការណ៍ហិរញ្ញវត្ថុលើកទី១ របស់អង្គភាពប្រសិនបើអង្គភាព ជាឧទាហរណ៍៖

(ក) មិនបានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទមុនៗ

(ខ) បានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុគ្រាមុនថ្មីៗបំផុតក្រោមការតម្រូវថ្នាក់ជាតិ ដែលមិនមានសង្គតិភាពជាមួយស្តង់ដារនេះគ្រប់ផ្នែកទាំងអស់ ឬ

(គ) បានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុលើកមុនថ្មីៗបំផុតស្របតាម ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ។

៣៥.៥ កថាខណ្ឌ ៣.១៧ ឱ្យនិយមន័យសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ។

៣៥.៦ កថាខណ្ឌ៣.១៤តម្រូវឱ្យអង្គភាពលាតត្រដាង ក្នុងសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ នូវព័ត៌មានប្រៀបធៀបទាក់ទងនឹងគ្រាមុនសម្រាប់ចំនួនទឹកប្រាក់រូបិយវត្ថុទាំងអស់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុក៏ដូចជាព័ត៌មានរៀបរាប់និងពិពណ៌នាប្រៀបធៀបជាក់លាក់។ អង្គភាពអាចបង្ហាញព័ត៌មានប្រៀបធៀបនៃគ្រាមុនលើសពីមួយ។ ដូច្នេះ កាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម របស់អង្គភាពគឺជាការចាប់ផ្តើមនៃគ្រាដំបូងបង្អស់ដែល អង្គភាពបង្ហាញព័ត៌មានប្រៀបធៀបពេញលេញដោយអនុលោមតាមស្តង់ដារនេះក្នុងរបាយការណ៍ហិរញ្ញវត្ថុដំបូងរបស់អង្គភាពដែលស្របតាមស្តង់ដារនេះ។

## នីតិវិធីសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរ

៣៥.៧ លើកលែងដូចបានកំណត់ក្នុងកថាខណ្ឌ៣៥.៩-៣៥.១១ នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម របស់អង្គភាព (ពោលគឺ ការចាប់ផ្តើមនៃការិយបរិច្ឆេទដំបូងបង្អស់ដែលបានបង្ហាញ) អង្គភាពត្រូវ៖

(ក) ទទួលស្គាល់គ្រប់ទ្រព្យសកម្មនិងបំណុលដែលការទទួលស្គាល់ត្រូវបានតម្រូវ ដោយស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម

(ខ) មិនទទួលស្គាល់ជាតុជាទ្រព្យសកម្ម ឬបំណុល ប្រសិនបើស្តង់ដារនេះមិនអនុញ្ញាតឱ្យមានការទទួលស្គាល់បែបនេះ

(គ) ចាត់ថ្នាក់ឡើងវិញនូវជាតុដែលអង្គភាពបានទទួលស្គាល់ក្រោមគ្រោងក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុ ពីមុនជាប្រភេទមួយនៃទ្រព្យសកម្ម បំណុល ឬជាសមាសធាតុនៃមូលធន ប៉ុន្តែជាប្រភេទផ្សេងនៃទ្រព្យសកម្ម ពីបំណុល ឬសមាសធាតុនៃមូលធនក្រោមស្តង់ដារនេះ និង

(ឃ) អនុវត្តស្តង់ដារនេះក្នុងការវាស់វែងទ្រព្យសកម្មនិងបំណុលដែលបានទទួលស្គាល់ទាំងអស់។

៣៥.៨ គោលនយោបាយគណនេយ្យដែលអង្គភាពប្រើប្រាស់ក្នុងពេលអនុវត្តស្តង់ដារនេះ អាចខុសពីគោលនយោបាយគណនេយ្យទាំងឡាយដែលអង្គភាពនោះបានប្រើសម្រាប់កាលបរិច្ឆេទដូចគ្នាដោយប្រើគ្រោងក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុពីមុនរបស់អង្គភាពនោះ។ ការកែសម្រួលទាំងឡាយដែលជាលទ្ធផល កើតឡើងពីប្រតិបត្តិការ ព្រឹត្តិការណ៍ ឬស្ថានការណ៍ផ្សេងទៀតមុនពេល កាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ។ ដូច្នេះ អង្គភាពភាពត្រូវទទួលស្គាល់ការកែសម្រួលទាំងនោះ ដោយផ្ទាល់ក្នុងចំណេញរក្សាទុក (ឬ ប្រសិនបើសមស្រប ចំណាត់ថ្នាក់មួយទៀតនៃមូលធន) នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ។

៣៥.៩ នាការអនុវត្តលើកដំបូងនៃស្តង់ដារនេះ អង្គភាពមិនត្រូវប្តូរត្រឡប់ក្រោយនូវគណនេយ្យ ដែលអង្គភាពបានអនុវត្តតាមក្រោមគ្រោងក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុពីមុនសម្រាប់ប្រតិបត្តិការណាមួយនៃប្រតិបត្តិការខាងក្រោម៖

(ក) ការឈប់ទទួលស្គាល់នៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ។ ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់ក្រោមគ្រោងក្របខ័ណ្ឌគណនេយ្យពីមុនរបស់អង្គភាពនោះ មុនកាលបរិច្ឆេទនៃការផ្លាស់ប្តូរមិនត្រូវបានទទួលស្គាល់នៅពេលអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។ ផ្ទុយមកវិញ សម្រាប់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលត្រូវបានឈប់ទទួលស្គាល់ក្រោមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមក្នុងប្រតិបត្តិការដែលបានកើតឡើងមុនពេលកាលបរិច្ឆេទនៃការផ្លាស់ប្តូរ ប៉ុន្តែទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុនោះមិនត្រូវបានឈប់

ទទួលស្គាល់ទេ ក្រោមគ្រោងក្របខ័ណ្ឌគណនេយ្យពីមុនរបស់អង្គភាព អង្គភាពអាចជ្រើស (ក) ឈប់ទទួលស្គាល់ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុទាំងនោះ នាការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ឬ (ខ) បន្តទទួលស្គាល់ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុទាំងនោះ រហូតដល់ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុទាំងនោះត្រូវបានបញ្ចេញចោល ឬទូទាត់។

(ខ) អង្គភាពមិនត្រូវផ្លាស់ប្តូរគណនេយ្យទប់ស្កាត់ហានិភ័យមុន កាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម សម្រាប់ទំនាក់ទំនងទប់ស្កាត់ហានិភ័យដែលលែងមាននាកាលបរិច្ឆេទនៃការផ្លាស់ប្តូរ។ សម្រាប់ទំនាក់ទំនងទប់ស្កាត់ហានិភ័យដែលមាននៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរ អង្គភាពត្រូវអនុវត្តតាមការតម្រូវសម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យនៃផ្នែកទី១២ ស្តីពីបញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការតម្រូវសម្រាប់ការមិនបន្តគណនេយ្យទប់ស្កាត់ហានិភ័យ សម្រាប់ទំនាក់ទំនងហានិភ័យដែលមិនបានបំពេញលក្ខខណ្ឌនៃ ផ្នែកទី១២។

(គ) ការប៉ាន់ស្មានគណនេយ្យ។

(ឃ) ប្រតិបត្តិការមិនបន្ត។

(ង) ការវាស់វែងភាគកម្មមិនគ្រប់គ្រង។ ការតម្រូវរបស់កថាខណ្ឌ៥.៦ ដើម្បីបែងចែកចំណេញឬខាតនិងចំណូលពេញលេញសរុបរវាងភាគកម្មមិនគ្រប់គ្រង និង ម្ចាស់របស់ក្រុមហ៊ុនមេ ត្រូវបានអនុវត្តទៅមុខ ចាប់ពីកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម (ឬចាប់ពីកាលបរិច្ឆេទឆាប់ជាងបែបនេះដោយស្តង់ដារនេះត្រូវបានអនុវត្តដើម្បីថ្លែងឡើងវិញនូវការរួមបញ្ចូលអាជីវកម្ម-សូមមើលកថាខណ្ឌ ៣៥.១០(ក))។

(ច) ប្រាក់កម្ចីរបស់រដ្ឋាភិបាល។ អង្គភាពអនុវត្តលើកដំបូង ត្រូវអនុវត្តទៅមុខនូវការតម្រូវនៅក្នុងផ្នែកទី១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ផ្នែកទី១២ និងផ្នែកទី២៤ ស្តីពីអំណោយរបស់រដ្ឋាភិបាល ចំពោះប្រាក់កម្ចីរបស់រដ្ឋាភិបាល ដែលមាននៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ។ ដូច្នេះ ប្រសិនបើអង្គភាពអនុវត្តលើកដំបូង ដោយតាមគោលការណ៍គណនេយ្យដែលបានទទួលយកទូទៅពីមុនរបស់អង្គភាពនោះ មិនបានទទួលស្គាល់ និងវាស់វែងប្រាក់កម្ចីរបស់រដ្ឋាភិបាល ដោយឈរលើមូលដ្ឋានដែលមានសង្គតិភាពជាមួយស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះទេ នោះអង្គភាពនោះត្រូវប្រើតម្លៃយោងនៃប្រាក់កម្ចីនៃគោលការណ៍គណនេយ្យដែលបានទទួលយកទូទៅពីមុនរបស់អង្គភាពនោះនៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ជាតម្លៃយោងនៃប្រាក់កម្ចីនៅថ្ងៃនោះ និងមិនត្រូវទទួលស្គាល់អត្ថប្រយោជន៍នៃប្រាក់កម្ចីណាមួយរបស់រដ្ឋាភិបាល ក្នុងអត្រាការប្រាក់ក្រោមទីផ្សារ ជាអំណោយរបស់រដ្ឋាភិបាលឡើយ។

៣៥.១០ អង្គភាពអាចប្រើការលើកលែងមួយឬច្រើន ក្នុងចំណោមការលើកលែងខាងក្រោម ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់អង្គភាពដែលស្របតាមស្តង់ដារនេះ៖

(ក) ការរួមបញ្ចូលអាជីវកម្ម។ អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសមិនអនុវត្តផ្នែកទី១៩ ស្តីពីការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម ចំពោះការបញ្ចូលអាជីវកម្មដែលចូលជាធរមានមុនកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ។ ប៉ុន្តែ ប្រសិនបើអង្គភាពអនុវត្តលើកដំបូងថ្លែងឡើងវិញនូវការរួមបញ្ចូលអាជីវកម្មណាមួយដើម្បីអនុលោមតាមផ្នែកទី១៩ អង្គភាពត្រូវថ្លែងឡើងវិញនូវការរួមបញ្ចូលអាជីវកម្មក្រោយៗទាំងអស់។

(ខ) ប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុន។ អង្គភាពអនុវត្តលើកដំបូងមិនតម្រូវឱ្យអនុវត្តផ្នែកទី២៦ ស្តីពីការទូទាត់ដោយផ្អែកលើភាគហ៊ុនចំពោះឧបករណ៍មូលធនដែលត្រូវបានផ្តល់មុនកាលបរិច្ឆេទនៃការផ្លាស់ប្តូរ

ទៅជាស្តង់ដារនេះ ឬចំពោះបំណុលដែលកើតឡើងពីប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុន ដែលត្រូវបានទូទាត់មុនកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ។

(គ) យកតម្លៃសមស្របជាថ្លៃដើមសន្មត។ អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសយកការវាស់វែង ជាតុនៃទ្រព្យរោងចក្រ និងបរិក្ខារ ទ្រព្យវិនិយោគ ឬ ទ្រព្យសកម្មអរូបីនៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះតាមតម្លៃសមស្របរបស់វា និងប្រើប្រាស់តម្លៃសមស្របនោះជាថ្លៃដើមសន្មតនៅថ្ងៃនោះ។

(ឃ) យកការវាយតម្លៃឡើងវិញជាថ្លៃដើមសន្មត។ អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសប្រើការវាយតម្លៃឡើងវិញតាម គោលការណ៍គណនេយ្យដែលបានទទួលស្គាល់ជាទូទៅពីមុនសម្រាប់ជាតុទ្រព្យ រោងចក្រ និង បរិក្ខារ ទ្រព្យវិនិយោគឬ ទ្រព្យសកម្មអរូបី នៅ ឬមុនកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ ជាថ្លៃដើមសន្មតនៅថ្ងៃវាយតម្លៃឡើងវិញ។

(យក) ការវាស់វែងតម្លៃសមស្របជាថ្លៃដើមសន្មត ដែលជម្រុញដោយព្រឹត្តិការណ៍។ អង្គភាពអនុវត្តលើកដំបូងប្រហែលជាបានកំណត់ថ្លៃដើមសន្មតរួចហើយ ស្របតាមគោលការណ៍គណនេយ្យ ដែលបានទទួលយកទូទៅលើកមុនរបស់អង្គភាព សម្រាប់ទ្រព្យសកម្ម និងបំណុលមួយចំនួន ឬទាំងអស់របស់ខ្លួន តាមរយៈការវាស់វែងទ្រព្យសកម្ម និងបំណុលទាំងនោះតាមតម្លៃសមស្របនៅកាលបរិច្ឆេទណាមួយ ដោយសារតែព្រឹត្តិការណ៍ណាមួយ ឧទាហរណ៍៖ ការវាយតម្លៃអាជីវកម្ម ឬផ្នែកមួយនៃអាជីវកម្មសម្រាប់គោលបំណងលក់ដែលបានគ្រោងទុក។ ប្រសិនបើកាលបរិច្ឆេទវាស់វែង៖

(១) គឺនៅចំ ឬមុនកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ អង្គភាពអាចប្រើការវាស់វែងតម្លៃសមស្រប ដែលត្រូវបានជម្រុញដោយព្រឹត្តិការណ៍ ជាតម្លៃសន្មតនៅថ្ងៃវាស់វែងនោះ។

(២) នៅក្រោយកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ប៉ុន្តែក្នុងអំឡុងគ្រាដែលគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុដំបូង ដែលអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ការវាស់វែងតម្លៃសមស្របដែលជម្រុញដោយព្រឹត្តិការណ៍ អាចត្រូវបានប្រើជាថ្លៃដើមសន្មត នៅពេលដែលព្រឹត្តិការណ៍នោះកើតឡើង។ អង្គភាពត្រូវទទួលស្គាល់ការកែសម្រួលដោយផ្ទាល់ នៅក្នុងចំណេញរក្សាទុក (ឬ ប្រសិនបើសមស្រប ប្រភេទមួយផ្សេងទៀតនៃមូលធន) នៅថ្ងៃវាស់វែងនោះ។ នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ អង្គភាពត្រូវបង្កើតថ្លៃដើមសន្មត ដោយការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងកថាខណ្ឌ៣៥.១០ (គ)-(ឃ) ឬវាស់វែងទ្រព្យសកម្ម និងបំណុលទាំងនោះ ស្របតាមការតម្រូវផ្សេងទៀតនៅក្នុងផ្នែកនេះ។

(ង) ភាពខុសគ្នានៃការបកប្រែបង្គរ។ ផ្នែកទី៣០ ស្តីពីការបកប្រែរូបិយប័ណ្ណបរទេស តម្រូវឱ្យអង្គភាពចាត់ថ្នាក់ភាពខុសគ្នាពីការបកប្រែមួយចំនួនជាសមាសធាតុដោយឡែកនៃមូលធន។ អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសសន្មតនូវភាពខុសគ្នានៃការបកប្រែបង្គរសម្រាប់ប្រតិបត្តិការបរទេសទាំងអស់ថាសូន្យ នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម (ពោលគឺ 'ការចាប់ផ្តើមថ្មីស្រឡាង')។

(ច) របាយការណ៍ហិរញ្ញវត្ថុដោយឡែក។ នៅពេលអង្គភាពរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឡែក កថាខណ្ឌ ៩.២៦ តម្រូវឱ្យអង្គភាព ត្រូវធ្វើគណនេយ្យកម្មសម្រាប់ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ និងអង្គភាពគ្រប់គ្រងរួមគ្នា តាមវិធីណាមួយខាងក្រោម៖

(១) តាមថ្លៃដើមដកការថយចុះតម្លៃ

(២) តាម តម្លៃសមស្រប ជាមួយនឹងការប្រែប្រួលនៃតម្លៃសមស្របត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬ ខាត ឬ

(៣) ដោយប្រើប្រាស់វិធីសាស្ត្រមូលធន ដោយគោរពតាមនីតិវិធីនៅក្នុងកថាខណ្ឌ១៤.៨។

ប្រសិនបើអង្គភាពអនុវត្តលើកដំបូង វាស់វែងការវិនិយោគបែបនេះតាមថ្លៃដើម អង្គភាពត្រូវវាស់វែងការវិនិយោគនោះ តាមចំនួនទឹកប្រាក់មួយនៃចំនួនទឹកប្រាក់ខាងក្រោមនៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរ

(១) ថ្លៃដែលបានកំណត់ដោយអនុលោមតាមផ្នែកទី៩ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែក ឬ

(២) ថ្លៃដើមសន្មត ដែលត្រូវជាតម្លៃសមស្របនៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម ឬ តម្លៃយោង នៃគោលការណ៍គណនេយ្យដែលបានទទួលស្គាល់ជាទូទៅ ពីមុន នៅលើថ្ងៃនោះ។

(ឆ) ឧបករណ៍ហិរញ្ញវត្ថុផ្សំ។ កថាខណ្ឌ២២.១៣ តម្រូវឱ្យអង្គភាពបំបែកឧបករណ៍ហិរញ្ញវត្ថុផ្សំទៅជាសមាសធាតុបំណុលនិងមូលធននៅថ្ងៃបោះផ្សាយ។ អង្គភាពអនុវត្តលើកដំបូងមិនចាំបាច់បំបែកសមាសធាតុ ទាំងពីរនោះទេ ប្រសិនសមាសធាតុបំណុលមិនមែនមិនទាន់បានទូទាត់ នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ។

(ជ) ពន្ធពន្យារលើប្រាក់ចំណូល។ អង្គភាពអនុវត្តលើកដំបូងអាចអនុវត្តទៅមុខនូវផ្នែកទី២៩ ស្តីពីពន្ធលើប្រាក់ចំណូល ចាប់ពីកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម។

(ឈ) ការរៀបចំសម្បទានសេវា។ អង្គភាពអនុវត្តលើកដំបូងមិនត្រូវបានតម្រូវឱ្យអនុវត្តកថាខណ្ឌ ៣៤.១២-៣៤.១៦ ចំពោះការរៀបចំសម្បទានសេវាដែលបានចុះកិច្ចព្រមព្រៀងមុនកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ។

(ញ) សកម្មភាពនិស្សារណកម្ម។ អង្គភាពអនុវត្តលើកដំបូងដោយប្រើគណនេយ្យថ្លៃដើមពេញលេញក្រោមគោលការណ៍គណនេយ្យដែលបានទទួលស្គាល់ជាទូទៅ ពីមុនអាចជ្រើសរើសវាស់វែងទ្រព្យសកម្មប្រេង និងឧស្ម័ន (ទ្រព្យសកម្មទាំងនោះដែលបានប្រើក្នុងការរុករក ការវាយតម្លៃ ការអភិវឌ្ឍ ឬការផលិតប្រេងនិងឧស្ម័ន) នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម តាមចំនួនទឹកប្រាក់ដែលកំណត់ក្រោម គោលការណ៍គណនេយ្យដែលបានទទួល ស្គាល់ជាទូទៅពីមុនរបស់អង្គភាព។ អង្គភាពត្រូវធ្វើតេស្តទ្រព្យសកម្មទាំងនោះសម្រាប់ការថយចុះតម្លៃនៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះដោយអនុលោមតាមផ្នែកទី២៧ ស្តីពីការថយចុះតម្លៃនៃទ្រព្យសកម្ម។

(ដ) ការរៀបចំមានភតិសន្យា។ អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសកំណត់ថាតើការរៀបចំកំពុងមាននៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម មានភតិសន្យា (សូមមើលកថាខណ្ឌ ២០.៣) ដោយផ្អែកលើមូលដ្ឋានអង្គហេតុ និងកាលៈទេសៈកំពុងកើតមាននៅថ្ងៃនោះ ជាជាងពេលការរៀបចំបានចូលជាធរមាន។

(ឋ) បំណុលឈប់ប្រើប្រាស់ដែលរួមបញ្ចូលក្នុងថ្លៃដើមនៃទ្រព្យ រោងចក្រ និងបរិក្ខារ។ កថាខណ្ឌ ១៧.១០(គ) ថ្លែងថា ថ្លៃដើមនៃធាតុទ្រព្យ រោងចក្រ និង បរិក្ខារ រួមបញ្ចូលការប៉ាន់ស្មានដំបូងនៃចំណាយក្នុងការរុះរើ និងយកចេញនូវធាតុ និងស្តារឡើងវិញនូវទីតាំងដែលទ្រព្យ រោងចក្រ និង បរិក្ខារតាំងនៅ កាតព្វកិច្ចដែល

អង្គភាពកើតមានពេលជាតុត្រូវបានទិញ ឬជាលទ្ធផលនៃការប្រើជាតុក្នុងអំឡុងគ្រាជាក់លាក់សម្រាប់គោលបំណងដែលផ្សេងពីគោលបំណងផលិតសន្និធិក្នុងគ្រានោះ។ អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសវាស់វែងសមាសជាតុនេះនៃថ្លៃដើមនៃទ្រព្យ រោងចក្រ និងបរិក្ខារនៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម ជាជាងនៅថ្ងៃដែលកាតព្វកិច្ចបានកើតឡើងដំបូង។

(ឌ) ប្រតិបត្តិការដែលជាកម្មវត្ថុនៃនិយតកម្មតម្លៃ។ ប្រសិនបើអង្គភាពអនុវត្តលើកដំបូង កាន់កាប់ជាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ឬទ្រព្យអរូបី ដែលត្រូវបានប្រើ ឬត្រូវបានប្រើពីមុន ក្នុងប្រតិបត្តិការដែលជាកម្មវត្ថុនៃនិយតកម្មតម្លៃ (ពោលគឺ ដើម្បីផ្តល់ទំនិញ ឬសេវាកម្មដល់អតិថិជនក្នុងតម្លៃ/អត្រាដែលបង្កើតឡើងដោយស្ថាប័នដែលមានការអនុញ្ញាត។) អង្គភាពអាចជ្រើសរើសប្រើប្រាស់តម្លៃយោងនៃជាតុទាំងនោះនៃគោលការណ៍គណនេយ្យដែលបានទទួលយកជាទូទៅលើកមុន នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ជាថ្លៃដើមសន្មត។ ប្រសិនបើអង្គភាពអនុវត្តការលើកលែងនេះចំពោះជាតុណាមួយ អង្គភាពមិនចាំបាច់អនុវត្តការលើកលែងនោះចំពោះជាតុទាំងអស់ទេ។ អង្គភាពត្រូវធ្វើតេស្តទ្រព្យសកម្មសម្រាប់ការថយចុះតម្លៃ នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ស្របតាមផ្នែកទី២៧។

(ឍ) អតិផរណាខ្ពស់ធ្ងន់ធ្ងរ។ ប្រសិនបើអង្គភាពអនុវត្តលើកដំបូង មានរូបិយប័ណ្ណមុខងារ ដែលជាកម្មវត្ថុនៃអតិផរណាខ្ពស់ធ្ងន់ធ្ងរ៖

(១) ប្រសិនបើកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ នៅចំ ឬបន្ទាប់ពីកាលបរិច្ឆេទភាពធម្មតានៃរូបិយប័ណ្ណមុខងារ អង្គភាពអាចជ្រើសរើស វាស់ទ្រព្យសកម្ម និងបំណុលទាំងអស់ ដែលបានរក្សាទុកមុនកាលបរិច្ឆេទភាពធម្មតានៃរូបិយប័ណ្ណមុខងារ តាមតម្លៃសមស្រប នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅកាន់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យមនេះ និងប្រើប្រាស់តម្លៃសមស្របនោះ ជាថ្លៃដើមសន្មតនៃទ្រព្យសកម្ម និងបំណុលទាំងនោះ នៅថ្ងៃនោះ និង

(២) ប្រសិនបើកាលបរិច្ឆេទភាពធម្មតានៃរូបិយប័ណ្ណមុខងារ ត្រូវនឹងរយៈពេលប្រៀបធៀប១២ ខែ អង្គភាពអាចប្រើរយៈពេលប្រៀបធៀបតិចជាងដប់ពីរខែ ឱ្យតែបណ្តុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ (ដូចបានតម្រូវដោយកថាខណ្ឌ៣.១៧) ត្រូវបានផ្តល់ជូនសម្រាប់រយៈពេលខ្លីជាងនោះ។

៣៥.១១ ប្រសិនបើមិនអាចធ្វើទៅរួចសម្រាប់អង្គភាពមួយ ក្នុងការធ្វើការកែសម្រួលមួយ ឬច្រើន ដូចបានតម្រូវដោយកថាខណ្ឌ៣៥.៧ នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរ អង្គភាពត្រូវអនុវត្តកថាខណ្ឌ៣៥.៧-៣៥.១០ សម្រាប់ការកែសម្រួលបែបនេះក្នុងគ្រាដំបូងបង្អស់ដែលអាចធ្វើទៅបាន និងត្រូវកំណត់ថា តើចំនួនទឹកប្រាក់ណាខ្លះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មិនទាន់ត្រូវបានថ្លែងឡើងវិញនៅឡើយ។ ប្រសិនបើមិនអាចធ្វើទៅរួចសម្រាប់អង្គភាពដើម្បីផ្តល់ការលាតត្រដាងណាមួយ ដែលបានតម្រូវដោយស្តង់ដារនេះ រួមបញ្ចូលទាំងការលាតត្រដាងសម្រាប់គ្រាប្រៀបធៀប ការខកខានមិនបានធ្វើត្រូវបានលាតត្រដាង។

## ការលាតត្រដាង

### ការពន្យល់នៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

៣៥.១២ អង្គភាពត្រូវពន្យល់ពីរបៀបដែលការផ្លាស់ប្តូរ ពីគ្រោងក្របខ័ណ្ឌរបាយការណ៍ហិរញ្ញវត្ថុមុនរបស់អង្គភាព ទៅជាស្តង់ដារនេះ បានប៉ះពាល់ស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់ដែលបានរាយការណ៍។

៣៥.១២ក អង្គភាព ដែលបានអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម នៅក្នុងគ្រាមុនដូចបានអធិប្បាយក្នុងកថាខណ្ឌ៣៥.២ ត្រូវលាតត្រដាងៈ

(ក) ហេតុផលដែលអង្គភាពនោះបានឈប់អនុវត្ត ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

(ខ) ហេតុផលដែលអង្គភាពនោះកំពុងអនុវត្តឡើងវិញនូវ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម និង

(គ) ថាតើអង្គភាពនោះបានអនុវត្តផ្នែកនេះ ឬស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ត្រឡប់ក្រោយ ស្របតាមផ្នែកទី១០ ដែរឬទេ។

### ការសម្របសម្រួល

៣៥.១៣ ដើម្បីអនុលោមតាមកថាខណ្ឌ៣៥.១២ របាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់អង្គភាព ដែលបានរៀបចំដោយប្រើប្រាស់ស្តង់ដារនេះត្រូវរួមបញ្ចូលៈ

(ក) ការរៀបរាប់ពីសារជាតិនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យនីមួយៗ។

(ខ) ការសម្របសម្រួលមូលធនរបស់អង្គភាព ដែលបានកំណត់ដោយអនុលោមតាមគ្រោងក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុមុនចំពោះមូលធនរបស់អង្គភាពដែលបានកំណត់ដោយអនុលោមតាមស្តង់ដារនេះ សម្រាប់ថ្ងៃទាំងពីរខាងក្រោមៈ

(១) កាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជាស្តង់ដារនេះ និង

(២) ចុងបញ្ចប់នៃគ្រាចុងក្រោយ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំថ្មីៗបំផុត របស់អង្គភាពបានកំណត់ដោយអនុលោមតាមគ្រោងក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុ មុនរបស់អង្គភាពនោះ។

(គ) ការសម្របសម្រួលចំណេញឬខាត ដែលបានកំណត់ដោយអនុលោមតាមគ្រោងក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុមុនរបស់អង្គភាពសម្រាប់គ្រាចុងក្រោយបំផុតក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំថ្មីៗបំផុតរបស់អង្គភាពទៅជាចំណេញ ឬ ខាតរបស់អង្គភាពដែលបានកំណត់ដោយអនុលោមតាម ស្តង់ដារនេះសម្រាប់គ្រាដូចគ្នា។

៣៥.១៤ សិនបើអង្គភាពបានដឹងពីកំហុសឆ្គង ដែលបានកើតឡើងក្រោមគ្រោងក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុពីមុនរបស់អង្គភាព ការសម្របសម្រួលដែលតម្រូវដោយកថាខណ្ឌ៣៥.១៣(ខ) និង (គ) ត្រូវតាមដែលអាចធ្វើទៅរួច

បែងចែកឱ្យច្បាស់នូវការកែតម្រូវ នៃកំហុសទាំងនោះពីការផ្លាស់ប្តូរក្នុងគោលនយោបាយគណនេយ្យ។

៣៥.១៥ ប្រសិនបើអង្គភាពមិនបានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទមុនៗ អង្គភាពត្រូវលាតត្រដាងអង្គហេតុនោះក្នុងរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់អង្គភាពដែលស្របតាមស្តង់ដារនេះ។

# សទ្ទានុក្រម

| | |
|---|---|
| គោលនយោបាយគណនេយ្យ | គោលការណ៍ មូលដ្ឋាន ទម្លាប់ ច្បាប់ និងការអនុវត្តជាក់លាក់ដែលបានប្រើប្រាស់ដោយអង្គភាព ក្នុងការរៀបចំនិងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។ |
| ចំណេញគណនេយ្យ | ចំណេញ ឬខាតសម្រាប់គ្រា មុនពេលកាត់ចេញការចំណាយពន្ធ។ |
| មូលដ្ឋានគណនេយ្យបង្គរ | ឥទ្ធិពលនៃប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀតត្រូវបានទទួលស្គាល់ពេល ដែលប្រតិបត្តិការ ឬ ព្រឹត្តិការទាំងនោះកើនឡើង (និងមិនមែននៅពេលដែលសាច់ប្រាក់ ឬសាច់ប្រាក់សមមូល ត្រូវបានទទួលឬបង់) និង ពួកគេត្រូវបានកត់ត្រា ក្នុងកំណត់ត្រាគណនេយ្យ និងរាយការណ៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃគ្រាដែលព្រឹត្តិការណ៍ ឬ ប្រតិបត្តិការទាំងនោះពាក់ព័ន្ធ។ |
| ការអវត្តមានមានតម្លៃតបស្នងបង្គរ | ការអវត្តមានមានតម្លៃតបស្នងដែលត្រូវបានលើកទៅអនាគត និង អាចត្រូវបានប្រើក្នុងគ្រាអនាគតប្រសិនសិទ្ធិទទួលនៃគ្រាបច្ចុប្បន្នមិនត្រូវបានប្រើពេញលេញ។ |
| ទីផ្សារសកម្ម | ទីផ្សារដែលក្នុងនោះប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុល ប្រព្រឹត្តទៅជាមួយភាពញឹកញាប់ និង ទំហំគ្រប់គ្រាន់ ដើម្បីផ្តល់ព័ត៌មានអំពីការ កំណត់ថ្លៃនៅលើមូលដ្ឋានដែលកំពុងបន្ត។ |
| សកម្មភាពកសិកម្ម | ការគ្រប់គ្រងដោយអង្គភាពនៃការបំលែងជីវសាស្រ្ត នៃទ្រព្យសកម្មជីវសាស្រ្ត សម្រាប់លក់ទៅជាផលិតផលកសិកម្មឬ ទៅជាទ្រព្យសកម្មជីវសាស្រ្តបន្ថែមទៀត។ |
| ផលិតផលកសិកម្ម | ផលិតផលដែលបានប្រមូលផលនៃទ្រព្យសកម្មជីវសាស្រ្តរបស់អង្គភាព។ |
| ការរំលស់លើទ្រព្យសកម្មអរូបី | ការបែងចែកដែលមានលក្ខណៈជាប្រព័ន្ធនៃចំនួនទឹកប្រាក់ ដែលអាចរំលស់បាននៃទ្រព្យសកម្មលើអាយុកាលប្រើប្រាស់របស់វា។ |
| ថ្លៃដើមដករំលស់ នៃទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ | ចំនួនទឹកប្រាក់ដែលទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុល ហិរញ្ញវត្ថុត្រូវបានវាស់វែងនាការទទួលស្គាល់ដំបូងដកប្រាក់ដើមដែលបានសងទៅ បូកឬដកចំនួនទឹកប្រាក់រំលស់បង្គរដោយការប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាពទៅលើភាពខុសគ្នារវាងចំនួនទឹកប្រាក់ដំបូងនោះ និងចំនួនទឹកប្រាក់ដល់កាលកំណត់ រួចហើយដកការបន្ថយណាមួយ (ដោយផ្ទាល់ ឬ តាមរយៈការប្រើគណនីបង្ការ) សម្រាប់ការថយចុះតម្លៃ ឬ ភាពមិនអាចប្រមូលមកវិញបាន។ |
| ទ្រព្យសកម្ម | ធនធានដែលគ្រប់គ្រងដោយអង្គភាព ដែលជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាល និងតាមរយៈនេះអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតត្រូវបានរំពឹងថានឹងហូរចូលអង្គភាព។ |
| ក្រុមហ៊ុនញាតិសម្ព័ន្ធ | អង្គភាពមួយ រាប់បញ្ចូលអង្គភាពមិនចុះបញ្ជីក្រុមហ៊ុន ដូចជាក្រុមហ៊ុនសហកម្មសិទ្ធិដែលអ្នកវិនិយោគមានឥទ្ធិពលសំខាន់ទៅលើនោះ ហើយដែលមិនមែនជាក្រុមហ៊ុនបុត្រសម្ព័ន្ធ និងមិនមែនជាភាគកម្មក្នុងក្រុមហ៊ុនរួមទុន។ |
| ទ្រព្យសកម្មជីវសាស្រ្ត | សត្វ ឬ រុក្ខជាតិដែលមានជីវិត។ |

| | |
|---|---|
| បន្ទុកលើកប្រាក់កម្ចី | ការប្រាក់និងចំណាយផ្សេងទៀតដែលបានកើតឡើងដោយអង្គភាពសម្រាប់ មូលហេតុដែលជាប់ទាក់ទងនឹងការខ្ចីថវិកាអាជីវកម្ម សំណុំបញ្ចូលគ្នានៃសកម្មភាពនិងទ្រព្យសកម្ម ដែលបានធ្វើឡើងនិងគ្រប់គ្រង សម្រាប់គោលបំណងផ្ដល់៖<br>(ក) ការតបស្នងទៅឱ្យវិនិយោគិន ឬ<br>(ខ) ថ្លៃដើមដែលទាបជាង ឬ អត្ថប្រយោជន៍សេដ្ឋកិច្ចផ្សេងទៀតដោយផ្ទាល់ និង តាមសមាមាត្រទៅឱ្យអ្នកកាន់ប័ណ្ណជានារ៉ាប់រង ឬ អ្នកចូលរួម។<br>អាជីវកម្មជាទូទៅរួមមានធាតុចូល ដំណើរការដែលបានអនុវត្តចំពោះធាតុចូលទាំងនោះ និងធាតុចេញដែលជាលទ្ធផលហើយ ដែលត្រូវបានឬនឹងត្រូវបានប្រើដើម្បីបង្កើតចំណូល។ ប្រសិនបើកេរ្តិ៍ឈ្មោះអាជីវកម្មមានវត្តមាន នៅក្នុងសំណុំផ្ទេរនៃសកម្មភាពនិងទ្រព្យសកម្ម សំណុំផ្ទេរនោះត្រូវបានសន្មតជាអាជីវកម្មមួយ។ |
| ការរួមបញ្ចូលអាជីវកម្ម | ការផ្គុំចូលគ្នានៃអង្គភាពឬអាជីវកម្មដោយឡែកៗទៅជាអង្គភាពរាយការណ៍តែមួយ។ |
| តម្លៃយោង | ចំនួនទឹកប្រាក់ដែលទ្រព្យសកម្ម ឬបំណុលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ |
| សាច់ប្រាក់ | សាច់ប្រាក់ក្នុងដៃ និង ប្រាក់បញ្ញើដកបានតាមតម្រូវការ។ |
| សាច់ប្រាក់សមមូល | ការវិនិយោគរយៈពេលខ្លី មានសន្ទនីយភាពខ្ពស់ ដែលងាយបំប្លែងទៅជាចំនួនទឹកប្រាក់បានដឹងនៃសាច់ប្រាក់ និងរងហានិភ័យមិនសំខាន់នៃការប្រែប្រួលតម្លៃ។ |
| លំហូរសាច់ប្រាក់ | លំហូរចូលនិងលំហូរចេញនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល។ |
| អង្គភាពបង្កើតសាច់ប្រាក់ | ក្រុមនៃបណ្ដាទ្រព្យសកម្មដែលអាចកំណត់អត្តសញ្ញាណបានដែលតូចបំផុត ហើយដែលបង្កើតលំហូរចូលនៃសាច់ប្រាក់ដែលមានភាពឯករាជ្យកម្រិតខ្ពស់ពីលំហូរចូលនៃសាច់ប្រាក់ដែលបានមកពីទ្រព្យសកម្មឬបណ្ដាក្រុមនៃបណ្ដាទ្រព្យសកម្មផ្សេងទៀត។ |
| ប្រតិបត្តិការទូទាត់សាច់ប្រាក់ ផ្អែកតាមភាគហ៊ុន | ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដែលក្នុងនោះអង្គភាពទិញទំនិញ ឬសេវាកម្ម ដោយរ៉ាប់រងបំណុល ដើម្បីផ្ទេរសាច់ប្រាក់ ឬទ្រព្យសកម្មផ្សេងទៀតទៅឱ្យអ្នកផ្គត់ផ្គង់នៃទំនិញ ឬសេវាកម្មទាំងនោះ សម្រាប់ចំនួនទឹកប្រាក់ដែលផ្អែកលើថ្លៃ (ឬតម្លៃ) នៃឧបករណ៍មូលធន (រាប់ទាំងភាគហ៊ុន ឬសិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់) របស់អង្គភាព ឬអង្គភាពក្រុមផ្សេងទៀត។ |
| ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ | ការកែសម្រួលនៃតម្លៃយោងនៃទ្រព្យសកម្មឬបំណុល ឬ ចំនួនទឹកប្រាក់នៃការប្រើទ្រព្យសកម្មប្រចាំឆ្នាំ ដែលកើតពីការវាយតម្លៃនៃស្ថានភាពបច្ចុប្បន្ននៃ និង អត្ថប្រយោជន៍អនាគតនិងកាតព្វកិច្ចដែលរំពឹងទុកដែលទាក់ទងនឹងទ្រព្យសកម្ម និងបំណុល។ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យកើតចេញពីព័ត៌មានថ្មី ឬ ការអភិវឌ្ឍថ្មី ដូច្នេះហើយមិនមែនជាការកែតម្រូវកំហុសឆ្គងនោះទេ។ |
| ថ្នាក់ទ្រព្យសកម្ម | បណ្ដុំនៃបណ្ដាទ្រព្យសកម្មដែលមានសារជាតិនិងការប្រើប្រាស់ស្រដៀងគ្នា នៅក្នុងប្រតិបត្តិការរបស់អង្គភាព។ |

**សមាជិកគ្រួសារជិតស្និទ្ធរបស់បុគ្គល** សមាជិកគ្រួសារទាំងនោះ ដែលអ្នកទាំងនោះអាចត្រូវបានរំពឹងថា នឹងមានឥទ្ធិពលលើ ឬទទួលរងឥទ្ធិពលពីបុគ្គលនោះ ក្នុងការទាក់ទងទៅមកជាមួយនឹងអង្គភាព រាប់បញ្ចូលទាំង៖

(ក) កូន និងសហព័ទ្ធ ឬដៃគូរួមរស់របស់បុគ្គលនោះ

(ខ) កូនរបស់សហព័ទ្ធ ឬដៃគូរួមរស់របស់បុគ្គលនោះ និង

(គ) អ្នកនៅក្នុងបន្ទុករបស់បុគ្គលនោះ ឬរបស់សហព័ទ្ធ ឬរបស់ដៃគូរួមរស់របស់បុគ្គលនោះ។

**សមាសធាតុរបស់អង្គភាព** ប្រតិបត្តិការនិងលំហូរសាច់ប្រាក់ដែលអាចត្រូវបានញែកឱ្យដាច់ច្បាស់លាស់ ពីផ្នែកដទៃៗទៀតរបស់អង្គភាព ក្នុងការធ្វើប្រតិបត្តិការ និងសម្រាប់គោលបំណងរាយការណ៍ហិរញ្ញវត្ថុ។

**ឧបករណ៍ហិរញ្ញវត្ថុផ្សំ** ឧបករណ៍ហិរញ្ញវត្ថុមួយដែល តាមទស្សនវិស័យរបស់អ្នកបោះផ្សាយ ផ្ទុកទាំងវត្ថុធាតុបំណុលនិងមូលធន។

**របាយការណ៍ហិរញ្ញវត្ថុរួម** បណ្តារបាយការណ៍ហិរញ្ញវត្ថុនៃក្រុមហ៊ុនមេ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ត្រូវបានបង្ហាញ ជារបាយការណ៍ហិរញ្ញវត្ថុនៃអង្គភាពសេដ្ឋកិច្ចតែមួយ។

**កិច្ចសន្យាសាងសង់** កិច្ចសន្យាដែលបានចរចារជាពិសេសសម្រាប់ការសាងសង់ទ្រព្យសកម្មមួយ ឬទ្រព្យសកម្មជាបណ្តុំដែលពាក់ព័ន្ធទៅមក ឬ អាស្រ័យលើគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ក្នុងក្របខ័ណ្ឌរចនាបទ បច្ចេកវិទ្យា និង មុខងារឬគោលបំណងឬការប្រើប្រាស់ចុង ក្រោយនៃទ្រព្យសកម្មទាំងនោះ។

**កាតព្វកិច្ចដោយសន្មត** កាតព្វកិច្ចដែលកើតឡើងពីសកម្មភាពរបស់អង្គភាព ដែលក្នុងនោះ៖

(ក) ដោយលំនាំបានកំណត់ឡើងនៃការអនុវត្តពីអតីតកាល គោលនយោបាយដែលបានផ្សាយ សេចក្តីថ្លែងការណ៍បច្ចុប្បន្នមានភាពជាក់លាក់គ្រប់គ្រាន់ អង្គភាពបានបង្ហាញឱ្យភាគីផ្សេងៗទៀតថាខ្លួននឹងរ៉ាប់រងការទទួលខុសត្រូវខ្លះ និង

(ខ) ជាលទ្ធផល អង្គភាពបានធ្វើឱ្យភាគីផ្សេងៗទៀតកើតឡើងនូវការរំពឹងទុកសមហេតុផល ថាខ្លួននឹងអនុវត្តការទទួលខុសត្រូវទាំងនោះ។

**ទ្រព្យសកម្មយថាហេតុ** ទ្រព្យសកម្មសក្តានុពលដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាល និង អត្ថិភាពរបស់វានឹងត្រូវបានបញ្ជាក់តែដោយការកើតឡើង ឬការមិនកើតឡើងនៃព្រឹត្តិការណ៍អនាគតមិនច្បាស់លាស់មួយឬលើសពីមួយ ដែលមិនស្ថិតក្នុងការគ្រប់គ្រងទាំងស្រុងរបស់អង្គភាព។

**បំណុលយថាហេតុ** (ក) កាតព្វកិច្ចសក្តានុពលមួយដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាល និង អត្ថិភាពរបស់វានឹងត្រូវបានបញ្ជាក់តែដោយការកើតឡើង ឬការមិនកើតឡើងនៃព្រឹត្តិការណ៍អនាគតមិនច្បាស់លាស់មួយឬលើសពីមួយ ដែលមិនស្ថិតក្នុងការគ្រប់គ្រងទាំងស្រុងរបស់អង្គភាព ឬ

(ខ) កាតព្វកិច្ចបច្ចុប្បន្នមួយដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាល ប៉ុន្តែមិនត្រូវបានទទួលស្គាល់ ពីព្រោះ៖

(១) ការអនុវត្តកាតព្វកិច្ចនោះមិនជាអាចតម្រូវឱ្យធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ចហូរចេញពីអង្គភាព ឬ

(២) ចំនួនទឹកប្រាក់នៃកាតព្វកិច្ចនោះមិនអាចត្រូវបានវាស់វែងជាមួយនឹងភាពជឿជាក់គ្រប់គ្រាន់។

ការគ្រប់គ្រង(នៃអង្គភាព) អំណាចគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុនិងប្រតិបត្តិការរបស់អង្គភាព ដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់អង្គភាពនោះ។

ពន្ធបច្ចុប្បន្ន ចំនួនទឹកប្រាក់នៃពន្ធលើប្រាក់ចំណូលត្រូវបង់ (ត្រូវប្រមូលមកវិញបាន) ដោយមូលហេតុនៃប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នឬការិយបរិច្ឆេទមុនៗ។

កាលបរិច្ឆេទ នៃការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

សម្រាប់ការចាប់ផ្តើមនៃការិយបរិច្ឆេទដំបូងបង្អស់ដែលអង្គភាពបង្ហាញព័ត៌មានប្រៀបធៀបពេញលេញក្រោមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមក្នុងរបាយការណ៍ហិរញ្ញវត្ថុទីមួយរបស់ខ្លួនដែលអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។

ភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន ភាពខុសគ្នាបណ្តោះអាសន្នដែលនឹងបង្កើតជា ចំនួនទឹកប្រាក់ដែលកាត់កងបានក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) នៃការិយបរិច្ឆេទអនាគត នៅពេលដែលតម្លៃយោងនៃទ្រព្យសកម្មឬបំណុលនោះត្រូវបានប្រមូលមកវិញឬទូទាត់សង។

ពន្ធពន្យារ ពន្ធលើប្រាក់ចំណូលត្រូវបង់ (អាចប្រមូលមកវិញបាន) ដោយមូលហេតុនៃប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) សម្រាប់ការិយបរិច្ឆេទអនាគត ដែលជាលទ្ធផលនៃប្រតិបត្តិការឬព្រឹត្តិការណ៍អតីតកាល។

ទ្រព្យសកម្មពន្ធពន្យារ បណ្តាចំនួនទឹកប្រាក់នៃពន្ធលើប្រាក់ចំណូលដែលអាចប្រមូលមកវិញបាន ក្នុងការិយបរិច្ឆេទអនាគត ដោយមូលហេតុនេះ៖

(ក) ភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន

(ខ) ការលើកទៅមុខនៃខាតប្រាក់ពន្ធដែលមិនបានប្រើ និង

(គ) ការលើកទៅមុខនៃឥណទានពន្ធដែលមិនបានប្រើ។

បំណុលពន្ធពន្យារ បណ្តាចំនួនទឹកប្រាក់នៃពន្ធលើប្រាក់ចំណូលត្រូវបង់ក្នុងការិយបរិច្ឆេទអនាគត ដោយមូលហេតុនៃភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ។

បំណុលអត្ថប្រយោជន៍កំណត់ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍កំណត់នាកាលបរិច្ឆេទរាយការណ៍ ដកតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍នៃទ្រព្យសកម្មផែនការ (ប្រសិនបើមាន) ដែលកាតព្វកិច្ចទាំងនោះត្រូវបានទូទាត់សងដោយផ្ទាល់ចេញពីទ្រព្យសកម្មផែនការនោះ។

កាតព្វកិច្ចអត្ថប្រយោជន៍កំណត់ (តម្លៃបច្ចុប្បន្ននៃ) ដោយពុំមានការកាត់ចេញនូវទ្រព្យសកម្មផែនការណាមួយ តម្លៃបច្ចុប្បន្ននៃការទូទាត់អនាគតដែលរំពឹងទុក ដែលត្រូវបានតម្រូវដើម្បីទូទាត់នូវកាតព្វកិច្ចដែលជាលទ្ធផលនៃសេវាកម្មនិយោជិតក្នុងការិយបរិច្ឆេទបច្ចុប្បន្ននិងការិយបរិច្ឆេទមុនៗ។

| | |
|---|---|
| ផែនការអត្ថប្រយោជន៍កំណត់ | បណ្តាផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ ដែលក្រៅពីផែនការវិភាគទានកំណត់។ |
| ផែនការវិភាគទានកំណត់ | ក្រោមផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ ដែលអង្គភាពមួយបង់វិភាគទានថេរទៅក្នុងអង្គភាពដាច់ដោយឡែកមួយ (មូលនិធិមួយ) ហើយនឹងមិនមានកាតព្វកិច្ចតាមច្បាប់ឬដោយសន្មតដើម្បីបង់វិភាគទានលើសពីនេះឬធ្វើការទូទាត់អត្ថប្រយោជន៍ដោយផ្ទាល់ដល់និយោជិត ប្រសិនបើមូលនិធិនោះមិនមានទ្រព្យសកម្មគ្រប់គ្រាន់ដើម្បីបង់អត្ថប្រយោជន៍និយោជិតទាំងអស់ដែលទាក់ទងនឹងសេវាកម្មនិយោជិតនាការិយបរិច្ឆេទបច្ចុប្បន្ននិងការិយបរិច្ឆេទមុនៗ។ |
| ចំនួនទឹកប្រាក់ដែលអាចរំលស់បាន | ថ្លៃដើមនៃទ្រព្យសកម្មមួយ ឬចំនួនទឹកប្រាក់ដទៃទៀតដែលបានជំនួសឱ្យថ្លៃដើម (នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) ដកតម្លៃកាកសំណល់របស់ទ្រព្យសកម្មនោះ។ |
| រំលស់ | ការបែងចែកដែលមានលក្ខណៈជាប្រព័ន្ធនៃចំនួនទឹកប្រាក់ ដែលអាចរំលស់បាននៃទ្រព្យសកម្មលើអាយុកាលប្រើប្រាស់របស់វា។ |
| ការឈប់ទទួលស្គាល់ | ការលុបចោលនូវទ្រព្យសកម្មឬបំណុលណាមួយដែលបានទទួលស្គាល់ពីមុន ចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព។ |
| ការអភិវឌ្ឍ | ការប្រើប្រាស់នូវសមិទ្ធផលការស្រាវជ្រាវឬចំណេះដឹងផ្សេងទៀត ទៅលើផែនការឬរចនាបថសម្រាប់ការ ផលិតនៃសម្ភារៈ ឧបករណ៍ ផលិតផល ដំណើរការងារ ប្រព័ន្ធឬសេវាកម្មថ្មីឬបានកែលម្អជំជុំ មុននឹងការចាប់ផ្តើមនៃការផលិតឬការប្រើប្រាស់លក្ខណៈពាណិជ្ជកម្ម។ |
| ប្រតិបត្តិការមិនបន្ត | សមាសធាតុមួយរបស់អង្គភាពដែលត្រូវបានបញ្ចេញចោលឬត្រូវបានទុកសម្រាប់ លក់ និង<br><br>(ក) តំណាងបន្ទាត់ចម្បងដាច់ដោយឡែកមួយនៃអាជីវកម្ម ឬតំបន់ភូមិសាស្ត្រនៃប្រតិបត្តិការ<br><br>(ខ) ជាផ្នែកមួយនៃផែនការសម្របសម្រួលទោល ដើម្បីបញ្ចេញចោលបន្ទាត់ចម្បងដាច់ដោយឡែកមួយនៃអាជីវកម្មឬតំបន់ភូមិសាស្ត្រនៃប្រតិបត្តិការ ឬ<br><br>(គ) ជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយបានទិញយក ដែលសម្រាប់តែជាមួយនឹងទស្សនៈដើម្បីលក់វិញ។ |
| វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព | វិធីសាស្ត្រមួយនៃការគណនាថ្លៃដើមដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ) និងនៃការបែងចែកចំណូលការប្រាក់ឬចំណាយការប្រាក់លើការិយបរិច្ឆេទដែលពាក់ព័ន្ធ។ |
| អត្រាការប្រាក់ប្រសិទ្ធភាព | អត្រាដែលធ្វើអប្បហារចំៗនូវការទូទាត់ឬការទទួលសាច់ប្រាក់អនាគតប៉ាន់ស្មាន លើអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុឬ នៅពេលសមរម្យ ការិយបរិច្ឆេទខ្លីជាងឱ្យទៅជាតម្លៃយោងសុទ្ធនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ |

ប្រសិទ្ធភាពនៃការទប់ស្កាត់ហានិភ័យ កម្រិតនៃការប្រែប្រួលក្នុងតម្លៃសមស្របឬលំហូរសាច់ប្រាក់នៃ ធាតុទប់ស្កាត់ហានិភ័យដែលបណ្តាលមកពីហានិភ័យបានទប់ស្កាត់ ត្រូវបានកាត់កងដោយការប្រែប្រួលនៅក្នុងតម្លៃសមស្របឬលំហូរសាច់ប្រាក់នៃឧបករណ៍ទប់ស្កាត់ហានិភ័យ។

អត្ថប្រយោជន៍និយោជិត — គ្រប់ទម្រង់ទាំងអស់នៃការតបស្នងដែលបានឱ្យដោយអង្គភាពក្នុងការដោះដូរ សេវាកម្មដែលបានផ្តល់ដោយនិយោជិត។

មូលធន — ភាគកម្មនៅសល់ក្នុងទ្រព្យសកម្មរបស់អង្គភាពបន្ទាប់ពីដកចេញនូវបំណុលទាំងអស់របស់អង្គភាពនោះ។

ប្រតិបត្តិការទូទាត់មូលធន ផ្អែកតាមភាគហ៊ុន ប្រតិបត្តិការទូទាត់ផ្អែកលើភាគហ៊ុនមួយ ប្រភេទដែលក្នុងនោះអង្គភាព៖

(ក) ទទួលទំនិញឬសេវាកម្មជាការតបស្នងសម្រាប់ឧបករណ៍មូលធនរបស់ខ្លួនផ្ទាល់ (រួមទាំងភាគហ៊ុននិងសិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់) ឬ

(ខ) ទទួលទំនិញឬសេវាកម្មប៉ុន្តែមិនមានកាតព្វកិច្ច ក្នុងការទូទាត់ប្រតិបត្តិការនោះជាមួយនឹងអ្នកផ្គត់ផ្គង់។

កំហុសឆ្គង — ការខកខានមិនបានដាក់បញ្ចូលនិងការថ្លែងខុសនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាពសម្រាប់ការិយបរិច្ឆេទមុនៗមួយឬលើសពីមួយ ដែលបណ្តាលមកពីការមិនបានប្រើឬការប្រើខុសនូវព័ត៌មានអាចជឿទុកចិត្តបានដែល៖

(ក) អាចរកបាននៅពេលដែល របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទទាំងនោះបានត្រូវបានអនុញ្ញាតសម្រាប់ការបោះផ្សាយ និង

(ខ) អាចត្រូវបានរំពឹងទុក យ៉ាងសមហេតុសមផលថាត្រូវបានទទួលយកនិងពិចារណាក្នុងការរៀបចំនិងបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ។

ចំណាយ — ការថយចុះក្នុងអត្ថប្រយោជន៍សេដ្ឋកិច្ចអំឡុងការិយបរិច្ឆេទរាយការណ៍ ក្នុងទម្រង់នៃការហូរចេញ ឬតនុកម្ម (ការប្រើអស់) នៃទ្រព្យសកម្ម ឬ ការកើតមានឡើងនៃបំណុលដែលនាំឱ្យមាន ការថយចុះក្នុងមូលធន ក្រៅពីការថយចុះក្នុងមូលធនទាំងនោះដែលទាក់ទងនឹងការបែងចែកទៅឱ្យម្ចាស់។

ការបង្ហាញត្រឹមត្រូវ — ការបង្ហាញស្មោះត្រង់នៃបណ្តាឥទ្ធិពលនៃប្រតិបត្តិការ ព្រឹត្តិការណ៍និងស្ថានការណ៍ផ្សេងទៀតដោយស្របតាមនិយមន័យនិងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់សម្រាប់ទ្រព្យសកម្ម បំណុល ចំណូលនិងចំណាយ។

តម្លៃសមស្រប — ចំនួនទឹកប្រាក់ដែលសម្រាប់ទ្រព្យសកម្មមួយអាចត្រូវបានដោះដូរ បំណុលមួយអាចត្រូវបានទូទាត់សង ឬឧបករណ៍មូលធនដែលប្រគល់ឱ្យមួយអាចត្រូវបានដោះដូរ រវាងបណ្តាភាគីដឹងហេតុការណ៍ ស្ម័គ្រចិត្តនៅក្នុងប្រតិបត្តិការប្រវែងដៃ (ប្រតិបត្តិការប្រក្រតី) មួយ។

តម្លៃសមស្របដកចំណាយក្នុងការលក់ — ចំនួនទឹកប្រាក់ ដែលទទួលបានពីការលក់នៃទ្រព្យសកម្ម ឬអង្គភាពបង្កើតសាច់ប្រាក់មួយក្នុងប្រតិបត្តិការប្រវែងដៃ (ប្រតិបត្តិការប្រក្រតី) មួយរវាងបណ្តាភាគីដឹងហេតុការណ៍ ស្ម័គ្រចិត្ត ដកចំណាយនៃការបញ្ចេញចោល។

ភតិសន្យាហិរញ្ញវត្ថុ — ភតិសន្យាមួយដែលផ្ទេរស្ទើរតែទាំងអស់នូវហានិភ័យនិងការតបស្នង ដែលកើតឡើង

ជាលទ្ធផលនៃកម្មសិទ្ធិនៃទ្រព្យសកម្មមួយ។ កម្មសិទ្ធអាចឬមិនអាចជាទីបញ្ចប់ត្រូវបានផ្ទេរ។ ភតិសន្យាមួយដែលមិនមែនជាភតិសន្យាហិរញ្ញវត្ថុនោះជាភតិសន្យាប្រតិបត្តិការ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ទ្រព្យសកម្មណាមួយដែលជាៈ

(ក) សាច់ប្រាក់

(ខ) ឧបករណ៍មូលធនមួយនៃអង្គភាពមួយផ្សេងទៀត

(គ) សិទ្ធិតាមកិច្ចសន្យាៈ

(១) ដើម្បីទទួលសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុមួយផ្សេងទៀតពីអង្គភាពមួយផ្សេងទៀត ឬ

(២) ដើម្បីដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយអង្គភាពមួយផ្សេងទៀតក្រោមលក្ខខណ្ឌដែលអាចមានផលល្អចំពោះអង្គភាពនោះ ឬ

(ឃ) កិច្ចសន្យាដែលនឹងឬអាចនឹងត្រូវបានទូទាត់ដោយឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់ និងៈ

(១) ក្រោមកិច្ចសន្យានោះ អង្គភាពគឺ ឬអាចមានកាតព្វកិច្ចទទួលនូវចំនួនអថេរនៃឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់ ឬ

(២) កិច្ចសន្យានោះនឹងឬអាចនឹងត្រូវបានទូទាត់ក្រៅពីការដោះដូរចំនួនថេរនៃសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុមួយផ្សេងទៀតសម្រាប់ចំនួនថេរនៃឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់។ សម្រាប់គោលបំ ណងនេះ ឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់មិនរួមបញ្ចូលឧបករណ៍ដែលខ្លួនផ្ទាល់ជាកិច្ចសន្យាសម្រាប់ការទទួលឬការបញ្ជូនឱ្យនាពេលអនាគតនៃឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់។

ឧបករណ៍ហិរញ្ញវត្ថុ កិច្ចសន្យាមួយ ដែលបង្កើតជាទ្រព្យសកម្មហិរញ្ញវត្ថុមួយនៃអង្គភាពមួយ និងបំណុលហិរញ្ញវត្ថុឬឧបករណ៍មូលធនមួយនៃអង្គភាពមួយផ្សេងទៀត។

បំណុលហិរញ្ញវត្ថុ បំណុលណាមួយដែលជាៈ

(ក) កាតព្វកិច្ចតាមកិច្ចសន្យាៈ

(១) ដើម្បីប្រគល់សាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុមួយផ្សេងទៀត ទៅឱ្យអង្គភាពមួយផ្សេងទៀត ឬ

(២) ដើម្បីដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយនឹងអង្គភាពមួយផ្សេងទៀតក្រោមលក្ខខណ្ឌដែលអាចមានផលអាក្រក់ទៅលើអង្គភាព ឬ

(ខ) កិច្ចសន្យាមួយដែលនឹងឬអាចនឹងត្រូវបានទូទាត់ ដោយឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់ និងៈ

(១) ក្រោមកិច្ចសន្យានោះ អង្គភាពគឺ ឬអាចមានកាតព្វកិច្ចបញ្ជូននូវចំនួនអថេរនៃឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់ ឬ

(២) កិច្ចសន្យានោះនឹងឬអាចនឹងត្រូវបានទូទាត់ ក្រៅពីការដោះដូរចំនួនថេរនៃសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុមួយផ្សេងទៀតសម្រាប់ចំនួនថេរនៃឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់។ សម្រាប់គោលបំណងនេះ ឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់មិនរួមបញ្ចូលឧបករណ៍ដែលខ្លួនផ្ទាល់ជាកិច្ចសន្យាសម្រាប់ការទទួលឬការបញ្ជូនឱ្យនាពេលអនាគតនៃឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់។

**ស្ថានភាពហិរញ្ញវត្ថុ** ទំនាក់ទំនងនៃទ្រព្យសកម្ម បំណុល និងមូលធនរបស់អង្គភាពមួយ ដូចបានរាយការណ៍ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

**របាយការណ៍ហិរញ្ញវត្ថុ** ការបង្ហាញដែលមានលក្ខណៈជារចនាសម្ព័ន្ធនូវស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់នៃអង្គភាពមួយ។

**សកម្មភាពហិរញ្ញប្បទាន** បណ្តាសកម្មភាពដែលធ្វើឱ្យមានការប្រែប្រួលនូវទំហំនិងសមាសភាព នៃមូលធនបរិច្ចាគ និងការខ្ចីរបស់អង្គភាព។

**ការសន្យាយ៉ាងមុតមាំ** កិច្ចព្រមព្រៀងត្រូវប្រតិបត្តិតាមមួយសម្រាប់ការដោះដូរនៃចំនួនជាក់លាក់ នៃធនធាននៅតម្លៃជាក់លាក់នាកាលបរិច្ឆេទឬបណ្តាកាលបរិច្ឆេទអនាគតជាក់លាក់។

**អង្គភាពអនុវត្តលើកដំបូងនូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូច និងមធ្យម** អង្គភាពមួយដែលបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំលើកដំបូងរបស់ខ្លួន ដែលអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ដោយមិនខ្វល់ថាគ្រោងក្របខ័ណ្ឌគណនេយ្យពីមុនរបស់អង្គភាពនោះ ជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញឬសំណុំមួយផ្សេងទៀតនៃស្តង់ដារគណនេយ្យ។

**ប្រតិបត្តិការព្យាករណ៍** ប្រតិបត្តិការអនាគតមួយដែលមិនបានសន្យាតែបានរំពឹងទុក។

**ប្រតិបត្តិការបរទេស** អង្គភាពមួយដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ ក្រុមហ៊ុនរួមទុន ឬសាខាមួយនៃអង្គភាពរាយការណ៍មួយ សកម្មភាពនៃប្រតិបត្តិការបរទេសនោះមានមូលដ្ឋានឬធ្វើឡើងនៅក្នុងប្រទេសឬរូបិយប័ណ្ណមួយផ្សេងក្រៅពីប្រទេសឬរូបិយប័ណ្ណរបស់អង្គភាពរាយការណ៍។

**ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ** ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលក្រៅពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។

**រូបិយប័ណ្ណមុខងារ** រូបិយប័ណ្ណនៃបរិស្ថានសេដ្ឋកិច្ចចម្បងដែលក្នុងនោះអង្គភាពធ្វើប្រតិបត្តិការ។

**កាលបរិច្ឆេទភាពជម្ងឺតានៃរូបិយប័ណ្ណមុខងារ** កាលបរិច្ឆេទនៅពេលដែលរូបិយប័ណ្ណមុខងាររបស់អង្គភាពមួយ លែងមានលក្ខណៈណាមួយឬទាំងពីរនៃអតិផរណាខ្ពស់ធ្ងន់ធ្ងរ ឬនៅពេលដែលមានការប្រែប្រួលនៅក្នុងរូបិយប័ណ្ណមុខងាររបស់អង្គភាពទៅជារូបិយប័ណ្ណមួយដែលមិនរងឥទ្ធិពលអតិផរណាខ្ពស់ធ្ងន់ធ្ងរ។

**ការផ្តល់មូលនិធិ (នៃអត្ថប្រយោជន៍ក្រោយបំពេញការងារ)** បណ្តាវិភាគទានដោយអង្គភាពមួយ និងជួនកាលនិយោជិតរបស់អង្គភាពនោះ ទៅក្នុងអង្គភាពឬមូលនិធិមួយដែលដាច់ដោយឡែកតាមផ្លូវច្បាប់ ពីអង្គភាពរាយការណ៍នោះ និងពីអង្គភាពឬមូលនិធិនោះដែលអត្ថប្រយោជន៍និយោជិតត្រូវ

បានទូទាត់ឱ្យ។

ផលចំណេញ — បណ្តាការកើនឡើងក្នុងអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបំពេញនិយមន័យនៃ ផ្នែកលើសនៃចំណូលពីការលក់ដកចំណាយ ប៉ុន្តែមិនមែនជាចំណូលពីការលក់។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ — បណ្តារបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានតម្រង់ទិសទៅរក តម្រូវការព័ត៌មានហិរញ្ញវត្ថុទូទៅនៃអ្នកប្រើប្រាស់ច្រើនមជ្ឈដ្ឋានដែលមិនមានជំហរទាមទាររបាយការណ៍កាត់វាស់តាមបញ្ជាដើម្បីបំពេញតម្រូវការព័ត៌មានជាក់លាក់របស់ពួកគេ។

និរន្តរភាពអាជីវកម្ម — អង្គភាពមួយគឺជាអាជីវកម្មនិរន្តរ៍ វៀរលែងតែថ្នាក់គ្រប់គ្រងមានបំណងជម្រះបញ្ចីអង្គភាពនោះឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសផ្សេងមានតែធ្វើដូច្នេះ។

កេរ្តិ៍ឈ្មោះអាជីវកម្ម — អត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលកើតឡើងពីបណ្តាទ្រព្យសកម្មដែលមិនអាច ត្រូវបានកំណត់អត្តសញ្ញាណរៀងៗខ្លួននិងទទួលស្គាល់ដោយឡែកៗ។

អំណោយរបស់រដ្ឋាភិបាល — ជំនួយដោយរដ្ឋាភិបាលក្នុងទម្រង់នៃការផ្ទេរធនធានទៅឱ្យអង្គភាពមួយ ជាថ្នូរនឹងការអនុលោមតាមលក្ខខណ្ឌខ្លះនាពេលអតីតកាលឬអនាគតដែលពាក់ព័ន្ធនឹងសកម្មភាពប្រតិបត្តិការរបស់អង្គភាពនោះ។

កាលបរិច្ឆេទផ្តល់អំណោយ — កាលបរិច្ឆេទដែលអង្គភាពនិងភាគីផ្សេងមួយទៀត (រួមបញ្ចូលទាំងនិយោជិតម្នាក់) ព្រមព្រៀងទៅលើការរៀបចំការទូទាត់ដោយផ្អែកលើភាគហ៊ុន គឺជាពេលដែលអង្គភាពនោះនិងភាគីម្ខាងទៀតមានការយល់ដឹងរួមនៃនសន្យានិងលក្ខខណ្ឌនៃការរៀបចំនោះ។ នាកាលបរិច្ឆេទផ្តល់អំណោយ អង្គភាពប្រគល់ទៅឱ្យភាគីម្ខាងទៀតនូវសិទ្ធិទៅលើសាច់ប្រាក់ ទ្រព្យសកម្មផ្សេងទៀតឬឧបករណ៍មូលធនរបស់អង្គភាពនោះ ឱ្យតែថាលក្ខខណ្ឌផ្ទេរជាក់លាក់ (ប្រសិនបើមាន) ត្រូវបានបំពេញ។ ប្រសិនបើកិច្ចព្រមព្រៀងនោះត្រូវឆ្លងកាត់ដំណាក់កាលអនុម័ត (ឧទាហរណ៍ ដោយម្ចាស់ភាគហ៊ុន) កាលបរិច្ឆេទផ្តល់អំណោយគឺជាថ្ងៃដែលការអនុម័តនោះត្រូវបានទទួលបាន។

ការវិនិយោគដុល ក្នុងភតិសន្យាចំនួនសរុបនៃ៖

(ក) ការទូទាត់ភតិសន្យាអប្បបរមាត្រូវទទួលដោយភតិបតីក្រោមភតិសន្យាហិរញ្ញវត្ថុមួយ និង

(ខ) តម្លៃកាកសំណល់មិនធានាដែលបង្គរទៅលើភតិបតី។

ក្រុម — ក្រុមហ៊ុនមេមួយ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់របស់ក្រុមហ៊ុនមេនោះ។

ជាតុទប់ស្កាត់ហានិភ័យ — សម្រាប់គោលបំណងនៃគណនេយ្យទប់ស្កាត់ហានិភ័យពិសេស ដោយអង្គភាពធុនតូចនិងមធ្យម ក្រោមផ្នែកទី ១២នៃស្តង់ដារនេះ ជាតុទប់ស្កាត់ហានិភ័យមួយគឺជា៖

(ក) ហានិភ័យអត្រាការប្រាក់នៃឧបករណ៍បំណុលដែលបានវាស់វែងតាមថ្លៃដើមដករំលស់

(ខ) ហានិភ័យការប្តូររូបិយប័ណ្ណបរទេសឬអត្រាការប្រាក់ ក្នុងការសន្យាយ៉ាងមុតមាំឬប្រតិបត្តិការព្យាករណ៍ដែលមានភវនីយកម្រិតខ្ពស់

(គ) ហានិភ័យតម្លៃនៃទំនិញដែលអង្គភាពមាន ឬ ក្នុងការសន្យាយ៉ាងមុតមាំ ឬប្រតិបត្តិ

ការព្យាករណ៍ដែលមានភវនីយកម្រិតខ្ពស់ដើម្បីទិញ ឬ លក់ទំនិញមួយ ឬ

(ឃ) ហានិភ័យការប្តូររូបិយប័ណ្ណបរទេសក្នុងការវិនិយោគសុទ្ធក្នុងប្រតិបត្តិការបរទេសមួយ។

ឧបករណ៍ទប់ស្កាត់ហានិភ័យ សម្រាប់គោលបំណងនៃគណនេយ្យទប់ស្កាត់ហានិភ័យពិសេស ដោយអង្គភាពធុនតូចនិងមធ្យមក្រោមផ្នែកទី១២នៃស្តង់ដារនេះ ឧបករណ៍ទប់ស្កាត់ហានិភ័យមួយគឺជាឧបករណ៍ហិរញ្ញវត្ថុមួយដែលបំពេញខសន្យានិងលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

(ក) វាជាការដោះដូរការប្រាក់មួយ ការដោះដូររូបិយប័ណ្ណបរទេសមួយ កិច្ចសន្យាដោះដូររូបិយប័ណ្ណបរទេសអនាគតមួយ ឬ កិច្ចសន្យាដោះដូរទំនិញអនាគតមួយ ដែលត្រូវបានរំពឹងថាមាន ប្រសិទ្ធភាពខ្ពស់ក្នុងការកាត់កងហានិភ័យដែលបានកំណត់ក្នុងកថាខណ្ឌ ១២.១៧ ដែល ត្រូវបានចាត់ទុកជា ហានិភ័យបានទប់ស្កាត់នោះ។

(ខ) វាជាប់ពាក់ព័ន្ធនឹងភាគីខាងក្រៅនៃអង្គភាពរាយការណ៍ (ពោលគឺ ខាងក្រៅនៃក្រុមផ្នែក ឬអង្គភាពទោលនោះដែលកំពុងត្រូវបានរាយការណ៍អំពី)

(គ) ចំនួនទឹកប្រាក់គំនិតស្មើនឹងចំនួនទឹកប្រាក់ប្រាក់ដើមដែលបានកំណត់ឬ ចំនួនទឹកប្រាក់គំនិតនៃធាតុទប់ស្កាត់ហានិភ័យ។

(ឃ) វាមានកាលបរិច្ឆេទដល់កាលកំណត់ដែលបានកំណត់ ដែលមិនលើសពី៖

(១) កាលបរិច្ឆេទដល់កាលកំណត់នៃឧបករណ៍ហិរញ្ញវត្ថុដែលកំពុងត្រូវបានទប់ស្កាត់ហានិភ័យ

(២) កាលបរិច្ឆេទការទូទាត់ដែលបានរំពឹងទុកនៃការសន្យាទិញឬលក់ទំនិញ ឬ

(៣) កាលបរិច្ឆេទការកើតឡើងនៃប្រតិបត្តិការរូបិយប័ណ្ណបរទេស ឬទំនិញព្យាករណ៍ ដែលកំពុងត្រូវបានទប់ស្កាត់ហានិភ័យដែលមានភវនីយកម្រិតខ្ពស់។

(ង) វាពុំមានលក្ខណៈពិសេសនៃការបង់មុន ការបញ្ឈប់មុន ឬ ការពន្យារទេ។

អង្គភាពមួយដែលជ្រើសរើសអនុវត្ត ស្តង់ដារគណនេយ្យអន្តរជាតិ លេខ៣៩ ក្នុងការធ្វើគណនេយ្យកម្មសម្រាប់ឧបករណ៍ហិរញ្ញវត្ថុត្រូវអនុវត្តនិយមន័យនៃឧបករណ៍ទប់ស្កាត់ហានិភ័យ នៅក្នុងស្តង់ដារនោះជាជាងនិយមន័យនេះ។

ភវនីយកម្រិតខ្ពស់ មានភវនីយភាពច្រើនជាងទំនងជាយ៉ាងគួរឱ្យកត់សម្គាល់។

(ការខាតពី) ការថយចុះតម្លៃ ចំនួនទឹកប្រាក់ដែលតម្លៃយោងនៃទ្រព្យសកម្មមួយ លើសពី៖

(ក) ក្នុងករណីសន្និធិ តម្លៃលក់របស់សន្និធិនោះដកចំណាយក្នុងការបញ្ចប់ផលិតកម្មនិងក្នុងការលក់ ឬ

(ខ) ក្នុងករណីទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុផ្សេងទៀត ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុផ្សេងទៀតនោះ។

ដែលមិនអាចធ្វើទៅរួច ការអនុវត្តការតម្រូវមួយមិនអាចធ្វើទៅរួច គឺនៅពេលដែលអង្គភាពមិនអាចអនុវត្តការតម្រូវ នោះ បន្ទាប់ពីការប្រឹងប្រែងសមហេតុផលគ្រប់មធ្យោបាយដើម្បីអនុវត្ត។

| | |
|---|---|
| អត្រាការប្រាក់ដែលដាក់បន្ទុក | ប្រភេទមួយក្នុងចំណោមអត្រាការប្រាក់ខាងក្រោម ដែលកាន់តែអាចកំណត់យ៉ាងច្បាស់លាស់៖<br>(ក) អត្រាទូទៅសម្រាប់ឧបករណ៍ស្រដៀងគ្នារបស់អ្នកបោះផ្សាយដែលមានចំណាត់ថ្នាក់ឥណទានស្រដៀងគ្នា ឬ<br>(ខ) អត្រាការប្រាក់ដែលធ្វើអប្បហារចំនួនទឹកប្រាក់នាមករណ៍នៃឧបករណ៍នោះ ទៅជាតម្លៃលក់ជាសាច់ប្រាក់បច្ចុប្បន្ននៃទំនិញ ឬសេវាកម្មនោះ។ |
| ចំណូល | បណ្តាការកើនឡើងក្នុងអត្ថប្រយោជន៍សេដ្ឋកិច្ច អំឡុងពេលការិយបរិច្ឆេទរាយការណ៍ក្នុងទម្រង់ជា លំហូរចូលឬការកើនឡើងនៃតម្លៃរបស់ទ្រព្យសកម្ម ឬការថយចុះនៃបំណុលដែលជាលទ្ធផលគឺការកើនឡើងក្នុងមូលធន ក្រៅពីការកើនឡើងក្នុងមូលធនទាំងនោះដែលទាក់ទងនឹងការចេញដើមទុនពីម្ចាស់។ |
| របាយការណ៍លទ្ធផល | របាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញគ្រប់ធាតុទាំងអស់នៃចំណូល និងចំណាយ ដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទរាយការណ៍ ដោយមិនរាប់បញ្ចូលធាតុនៃចំណូលលម្អិតផ្សេងៗ។ |
| ពន្ធលើប្រាក់ចំណូល | ពន្ធក្នុងស្រុកនិងក្រៅស្រុកទាំងអស់ដែលផ្អែកលើប្រាក់ចំណេញជាប់ពន្ធ។ ពន្ធលើប្រាក់ចំណូលក៏រួមបញ្ចូលផងដែរនូវ ពន្ធទាំងឡាយដូចជាពន្ធកាត់ទុក ដែលពន្ធទាំងនោះត្រូវបង់ដោយក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន នាពេលបែងចែកទៅឱ្យអង្គភាពរាយការណ៍។ |
| កិច្ចសន្យាធានារ៉ាប់រង<br>(ព្រឹត្តិការណ៍ដែលបានធានារ៉ាប់រង) | កិច្ចសន្យាមួយដែលភាគីមួយ (អ្នកធានារ៉ាប់រង) ទទួលយកនូវហានិភ័យធានារ៉ាប់រងធំដុំពីភាគីម្ខាងទៀត (អ្នកកាន់ប័ណ្ណធានារ៉ាប់រង) ដោយយល់ព្រមសងអ្នកកាន់ប័ណ្ណធានារ៉ាប់រង ប្រសិនបើព្រឹត្តិការណ៍អនាគតមិនច្បាស់លាស់ណាមួយដែលបានកំណត់ ប៉ះពាល់មិនល្អដល់អ្នកកាន់ប័ណ្ណធានារ៉ាប់រងនោះ។ |
| ទ្រព្យសកម្មអរូបី | ទ្រព្យសកម្មមិនមែនរូបិយវត្ថុមួយដែលអាចកំណត់អត្តសញ្ញាណបាន ដោយគ្មានរូបសណ្ឋានវត្ថុបី។ ទ្រព្យសកម្មបែបនេះអាចកំណត់អត្តសញ្ញាណបាននៅពេលដែលទ្រព្យសកម្មនេះ<br>(ក) អាចបំបែកចេញបាន ពោលគឺអាចត្រូវបានបំបែកចេញ ឬផ្តាច់ខ្លួនចេញពីអង្គភាព និងអាចត្រូវបានលក់ ផ្ទេរ ផ្តល់អាជ្ញាបណ្ណ ជួល ឬដោះដូរដោយឡែកៗឬរួមគ្នាជាមួយកិច្ចសន្យា ទ្រព្យសកម្ម ឬ បំណុលដែលទាក់ទិន ឬ<br>(ខ) កើតឡើងពីសិទ្ធិតាមកិច្ចសន្យា ឬ សិទ្ធិស្របច្បាប់ផ្សេងទៀត ដោយមិនគិតទេថាតើសិទ្ធិទាំងនោះអាចផ្ទេរបាន ឬ បំបែកចេញបានពីអង្គភាព ឬពីសិទ្ធិនិងកាតព្វកិច្ចផ្សេងទៀត។ |

អត្រាការប្រាក់បង្កប់ក្នុងភតិសន្យា — អត្រាអប្បហារដែលនាពេលចាប់ផ្តើមភតិសន្យានោះ ធ្វើឱ្យតម្លៃបច្ចុប្បន្នសរុបនៃ (ក) ការទូទាត់ភតិសន្យាអប្បបរមា និង (ខ) តម្លៃកាកសំណល់មិនបានធានា ឱ្យស្មើនឹងផលបូកនៃ (១) តម្លៃសមស្របនៃទ្រព្យសកម្មភតិសន្យា និង (២) ចំណាយផ្ទាល់ដំបូងទាំងអស់របស់ភតិបតី។

របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល — ការរាយការណ៍ហិរញ្ញវត្ថុមួយដែលមានសំណុំពេញលេញមួយនៃបណ្តារបាយការណ៍ហិរញ្ញវត្ថុឬសំណុំមួយនៃបណ្តារបាយការណ៍ហិរញ្ញវត្ថុបង្រួញ សម្រាប់គ្រាចន្លោះពេលមួយ។

គ្រាចន្លោះពេល — ការិយបរិច្ឆេទរាយការណ៍ហិរញ្ញវត្ថុមួយដែលខ្លីជាងឆ្នាំហិរញ្ញវត្ថុពេញលេញមួយ។

ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ — បណ្តាស្តង់ដារដែលបានអនុវត្តដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។ ស្តង់ដារទាំងនោះរួមមាន៖

(ក) ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ

(ខ) ស្តង់ដារគណនេយ្យអន្តរជាតិ និង

(គ) បណ្តាការបកស្រាយដែលបង្កើតឡើង ដោយគណៈកម្មការការបកស្រាយការរាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ឬ អតីតគណៈកម្មការការបកស្រាយអចិន្ត្រៃយ៍។

តម្លៃមជ្ឈិតិកៈ — ភាពខុសគ្នារវាងតម្លៃសមស្របរបស់ភាគហ៊ុនដែលភាគីម្ខាងទៀតមានសិទ្ធ (មានលក្ខខណ្ឌឬគ្មានលក្ខខណ្ឌ) ដើម្បីទិញ ឬដែលភាគីម្ខាងទៀតនោះមានសិទ្ធដើម្បីទទួល និងតម្លៃ (ប្រសិនបើមាន) ដែលភាគីម្ខាងទៀតនោះត្រូវបាន (ឬនឹងត្រូវបាន) តម្រូវឱ្យបង់សម្រាប់ភាគហ៊ុនទាំងនោះ។ ឧទាហរណ៍ សិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់មួយដែលមានតម្លៃអនុវត្តសិទ្ធិ១៥ឯកតារូបិយប័ណ្ណ ទៅលើភាគហ៊ុនដែលមានតម្លៃសមស្រប២០ឯកតារូបិយប័ណ្ណ មានតម្លៃមជ្ឈិតិកៈ ៥ ឯកតារូបិយប័ណ្ណ។

សន្និធិ — បណ្តាទ្រព្យសកម្មដែល

(ក) រក្សាទុកសម្រាប់លក់ក្នុងដំណើរការធម្មតារបស់អាជីវកម្ម

(ខ) នៅក្នុងដំណើរការផលិតកម្មនៅឡើយសម្រាប់ការលក់បែបនេះ ឬ

(គ) ក្នុងទម្រង់នៃវត្ថុធាតុដើម ឬ សម្ភារៈផ្គត់ផ្គង់ត្រូវប្រើក្នុងដំណើរការផលិតកម្ម ឬ ក្នុងការផ្តល់សេវាកម្ម។

សកម្មភាពវិនិយោគ — ការទិញនិងការបញ្ចេញចោលនូវទ្រព្យសកម្មរយៈពេលវែង និង ការវិនិយោគផ្សេងទៀតដែលមិនរួមបញ្ចូលក្នុងសាច់ប្រាក់សមមូល។

ទ្រព្យវិនិយោគ — អចលនទ្រព្យ (ដី ឬ អគារ ឬ ផ្នែកនៃអគារ ឬ ទាំងពីរ) ដែលរក្សាទុកដោយម្ចាស់ ឬដោយភតិកៈក្រោមភតិសន្យាហិរញ្ញវត្ថុ ដើម្បីរកចំណូលកម្រៃជួល ឬសម្រាប់កំណើនតម្លៃមូលធន ឬទាំងពីរ តែមិនមែនសម្រាប់

(ក) ការប្រើប្រាស់ក្នុងការផលិតឬផ្គត់ផ្គង់ទំនិញឬសេវាកម្មឬសម្រាប់គោលបំណងរដ្ឋបាល ឬ


CamEd Business School

(ខ) ការលក់ក្នុងដំណើរការធម្មតារបស់អាជីវកម្ម។

**ការគ្រប់គ្រងរួម**
ការចែករំលែកនូវការគ្រប់គ្រងដូចបានព្រមព្រៀងតាមកិច្ចសន្យាលើ សកម្មភាពសេដ្ឋកិច្ចណាមួយ។ ការគ្រប់គ្រងរួមមានអត្ថិភាពតែពេលដែល ការសម្រេចចិត្តហិរញ្ញវត្ថុនិងប្រតិបត្តិការយុទ្ធសាស្ត្រទាក់ទងនឹងសកម្មភាពនោះតម្រូវឱ្យមានការយល់ព្រមជាឯកច្ឆន្ទពីភាគីដែលចែករំលែកការគ្រប់គ្រង (អ្នករួមទុន)។

**ក្រុមហ៊ុនរួមទុន**
ការរៀបចំមួយតាមកិច្ចសន្យាដោយហេតុនេះភាគីពីរ ឬលើសពីពីរចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ចណាមួយដែលរងឥទ្ធិពលការគ្រប់គ្រងរួម។ ក្រុមហ៊ុនរួមទុនអាចយកទម្រង់ជាប្រតិបត្តិការគ្រប់គ្រងរួម ទ្រព្យសកម្មគ្រប់គ្រងរួម ឬអង្គភាពគ្រប់គ្រងរួមគ្នា។

**អង្គភាពគ្រប់គ្រងរួមគ្នា**
ក្រុមហ៊ុនរួមទុនមួយដែលទាក់ទងនឹងការបង្កើតក្រុមហ៊ុនសាជីវកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬអង្គភាពផ្សេងមួយទៀត ដែលក្នុងនោះអ្នករួមទុននីមួយៗមានភាគកម្ម។ អង្គភាពនេះធ្វើប្រតិបត្តិការតាមរបៀបដូចគ្នា នឹងអង្គភាពផ្សេងទៀត លើកលែងថាការរៀបចំតាមកិច្ចសន្យាមួយរវៀងបណ្តាអ្នករួមទុន បង្កើតជាការគ្រប់គ្រងរួមទៅលើសកម្មភាពសេដ្ឋកិច្ចរបស់អង្គភាពនោះ។

**ភតិសន្យា**
កិច្ចព្រមព្រៀងមួយ ដោយហេតុនេះភតិបតីផ្ទេរកម្មសិទ្ធិប្រើប្រាស់ទ្រព្យសកម្មណាមួយសម្រាប់រយៈពេលដែលបានព្រមព្រៀងគ្នា ទៅឱ្យភតិកៈដើម្បីបានជាការតបស្នងនូវការទូទាត់មួយឬស៊េរីនៃការទូទាត់។

**អត្រាការប្រាក់កម្ចីបន្ថែមរបស់ភតិកៈ**
អត្រាការប្រាក់ដែលភតិកៈនឹងត្រូវបង់លើភតិសន្យាស្រដៀងគ្នាឬ បើអត្រាការប្រាក់បែបនេះមិនអាចកំណត់បាន អត្រាការប្រាក់ដែលនៅពេលចាប់ផ្តើមភតិសន្យា ភតិកៈនោះនឹងរ៉ាប់រងដើម្បីខ្ចីថវិកាដែលចាំបាច់ដើម្បីទិញទ្រព្យកម្មភតិសន្យានោះ សម្រាប់រយៈពេលស្រដៀងគ្នានិងសុវត្ថិភាពស្រដៀងគ្នា។

**បំណុល**
កាតព្វកិច្ចបច្ចុប្បន្នរបស់អង្គភាពដែលកើតពីព្រឹត្តិការណ៍អតីតកាល ការទូទាត់កាតព្វកិច្ចបច្ចុប្បន្ននោះត្រូវបានរំពឹងទុកថា នឹងនាំឱ្យមានលំហូរចេញពីអង្គភាពនូវធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច។

កម្ចីត្រូវសង បណ្តាបំណុលហិរញ្ញវត្ថុ ក្រៅពីពាណិជ្ជកម្មត្រូវសងរយៈពេលខ្លីតាមលក្ខខណ្ឌឥណទានធម្មតា។

**លក្ខខណ្ឌទីផ្សារដើម្បីផ្ទេរ**
លក្ខខណ្ឌដែលតម្លៃអនុវត្តសិទ្ធិ ការផ្ទេរ ឬភាពអាចអនុវត្តសិទ្ធិបាននៃឧបករណ៍មូលធនមួយ ពឹងផ្អែកទៅលើ ដែលទាក់ទិននឹងតម្លៃទីផ្សារនៃបណ្តាឧបករណ៍មូលធនរបស់អង្គភាពនោះ ដូចជាការទទួលបានតម្លៃភាគហ៊ុនជាក់លាក់ ឬចំនួនទឹកប្រាក់ជាក់លាក់នៃតម្លៃមជ្ឈតិកៈនៃសិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់ ឬការសម្រេចគោលដៅជាក់លាក់ ដែលផ្អែកលើតម្លៃទីផ្សារ នៃបណ្តាឧបករណ៍មូលធនរបស់អង្គភាពនោះ ដោយធៀបគ្នានឹងសន្ទស្សន៍តម្លៃទីផ្សារនៃបណ្តាឧបករណ៍មូលធន នៃអង្គភាពផ្សេងៗទៀត។

**ជាសារវន្ត**
ការខកខានមិនបានដាក់បញ្ចូល ឬការថ្លែងខុសនៃធាតុមានភាពជាសារវន្តប្រសិនបើការខកខានមិនបានដាក់បញ្ចូលឬការថ្លែងខុសទាំងនោះអាច ដោយឡែកៗឬរួមគ្នា មានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដែលបានធ្វើឡើងដោយផ្អែកលើ របាយការណ៍ហិរញ្ញវត្ថុទាំងនោះ។ ភាពជាសារវន្តអាស្រ័យទៅលើទំហំ និងសារជាតិនៃការខកខានមិនបានដាក់បញ្ចូល ឬការថ្លែងខុសដែលត្រូវបានវិនិច្ឆ័យក្នុង

ស្ថានការណ៍ជុំវិញ។ ទំហំ ឬ សារជាតិនៃធាតុនោះ ឬ ការរួមផ្សំទាំងពីរ អាចជាកត្តាកំណត់។

| | |
|---|---|
| ការវាស់វែង | ដំណើរការនៃការកំណត់ចំនួនទឹកប្រាក់រូបិយវត្ថុដែលបណ្ដាធាតុនៃរបាយការណ៍ហិរញ្ញវត្ថុនឹងត្រូវបានទទួលស្គាល់ និង ដាក់រាយការណ៍ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍ចំណូលពេញលេញ។ |
| ការទូទាត់ភតិសន្យាអប្បបរមា | បណ្ដាការទូទាត់ក្នុងរយៈពេលនៃភតិសន្យា ដែលភតិកៈ ត្រូវបានឬអាចត្រូវបានតម្រូវឱ្យធ្វើ ដោយមិនរាប់បញ្ចូលថ្លៃជួលយថាហេតុ ចំណាយលើសេវាកម្ម និងពន្ធដែលត្រូវបង់ និងចេញសងវិញទៅឱ្យភតិបតី រួមជាមួយ៖ |

(ក) សម្រាប់ភតិកៈ ចំនួនទឹកប្រាក់ទាំងឡាយណាដែលធានាដោយភតិកៈ ឬដោយភាគីណាមួយ ដែលមានទំនាក់ទំនងជាមួយភតិកៈ ឬ

(ខ) សម្រាប់ភតិបតី តម្លៃកាកសំណល់ទាំងឡាយណា ដែលបានដាក់ធានាចំពោះភតិបតី ដោយ៖

(១) ភតិកៈ

(២) ភាគីណាមួយ ដែលមានទំនាក់ទំនងជាមួយភតិកៈ ឬ

(៣) ភាគីទីបី ដែលមិនមានទំនាក់ទំនងជាមួយភតិបតី ដែលមានសមត្ថភាពខាងហិរញ្ញវត្ថុ ក្នុងការបំពេញភារកិច្ចក្រោមការធានានោះ។

| | |
|---|---|
| ប៉ុន្តែ ប្រសិនបើភតិកៈមានជម្រើស | ក្នុងការទិញទ្រព្យសកម្មនោះ ក្នុងតម្លៃដែលត្រូវបានរំពឹងថានឹងទាបជាងតម្លៃសមស្របយ៉ាងខ្លាំង នៅកាលបរិច្ឆេទដែលជម្រើសនេះប្រែជាអាចអនុវត្តសិទ្ធិបាន ធ្វើឱ្យជាក់ណាស់សមហេតុផល នៅពេលចាប់ផ្ដើមបង្កើតភតិសន្យានោះដែលជម្រើសទិញទ្រព្យសកម្មនឹងត្រូវបានអនុវត្តសិទ្ធិ ការទូទាត់ភតិសន្យាអប្បបរមា រួមមានការទូទាត់អប្បបរមាត្រូវបង់ក្នុងរយៈពេលភតិសន្យា រហូតដល់កាលបរិច្ឆេទរំពឹងទុកនៃការអនុវត្តសិទ្ធិនៃជម្រើសទិញនេះ និងការទូទាត់ដែលត្រូវបានតម្រូវដើម្បីអនុវត្តសិទ្ធិនៃជម្រើសទិញនោះ។ |
| ធាតុរូបិយវត្ថុ | បណ្ដាឯកតារូបិយប័ណ្ណដែលរក្សាទុក និង ទ្រព្យសកម្មនិងបំណុលត្រូវទទួល ឬ ត្រូវទូទាត់ជាចំនួនថេរឬអាចកំណត់បាននៃឯកតារូបិយប័ណ្ណ។ |
| ផែនការ (អត្ថប្រយោជន៍) ពហុនិយោជក | ផែនការវិភាគទានកំណត់ (ក្រៅពីផែនការរបស់រដ្ឋ) ឬ ផែនការអត្ថប្រយោជន៍កំណត់ (ក្រៅពីផែនការរបស់រដ្ឋ) ដែល៖ |

(ក) ប្រមូលផ្ដុំនូវបណ្ដាទ្រព្យសកម្មដែលបានធ្វើវិភាគទានដោយ អង្គភាពផ្សេងៗដែលមិនស្ថិតក្រោមការគ្រប់គ្រងរួម និង

(ខ) ប្រើទ្រព្យសកម្មទាំងនោះដើម្បីផ្ដល់អត្ថប្រយោជន៍ទៅឱ្យនិយោជិត នៃអង្គភាពច្រើនជាងមួយ ដោយឈរលើមូលដ្ឋានដែល កម្រិតវិភាគទាននិងអត្ថប្រយោជន៍ត្រូវបាន កំណត់ដោយមិនគិតអំពីអត្តសញ្ញាណ នៃអង្គភាពដែលជួលនិយោជិតដែលពាក់ព័ន្ធ។

ការវិនិយោគសុទ្ធក្នុងភតិសន្យា — ការវិនិយោគដុលក្នុងភតិសន្យាដែលបានធ្វើអប្បហារតាមអត្រាការប្រាក់បង្កប់ក្នុងភតិសន្យា។

ភាគកម្មមិនគ្រប់គ្រង — មូលធនក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនមែនជារបស់ក្រុមហ៊ុនមេ ដោយផ្ទាល់ឬដោយប្រយោល។

កំណត់សម្គាល់ (លើរបាយការណ៍ហិរញ្ញវត្ថុ) — កំណត់សម្គាល់ផ្ទុកនូវព័ត៌មានដែលបន្ថែមទៅលើ ព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណូលពេញលេញ របាយការណ៍លទ្ធផល (ប្រសិនបើត្រូវបានបង្ហាញ) របាយការណ៍បញ្ចូលគ្នានៃចំណូលនិងចំណេញរក្សាទុក (ប្រសិនបើត្រូវបានបង្ហាញ) របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់។ កំណត់សម្គាល់ផ្តល់ការពន្យល់បែបពិពណ៌នា ឬការបំបែកការប្រមូលផ្តុំនៃធាតុទាំងឡាយដែលបានបង្ហាញ ក្នុងរបាយការណ៍ទាំងនោះ និង ព័ត៌មានអំពីធាតុនានាដែលមិនបំពេញលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ ក្នុងរបាយការណ៍ទាំងនោះ។

បរិមាណជាសញ្ញាណ — បរិមាណនៃឯកតារូបិយប័ណ្ណ ភាគហ៊ុន ល្បី ផោន ឬ ឯកតាផ្សេងទៀតដែលបញ្ជាក់ក្នុងកិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ។

គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុ — ដើម្បីផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់របស់អង្គភាពមួយដែលមានប្រយោជន៍ សម្រាប់ការធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ច្រើនមជ្ឈដ្ឋាន ដែលមិនមានជំហរទាមទារឱ្យរបាយការណ៍ធ្វើតាមការតម្រូវជាពិសេស ដើម្បីបំពេញសេចក្តីត្រូវការព័ត៌មានជាក់លាក់របស់អ្នកប្រើប្រាស់ទាំងនោះ។

កិច្ចសន្យាដែលនាំឱ្យមានការខាតបង់ — កិច្ចសន្យាមួយដែលក្នុងកិច្ចសន្យានោះ ចំណាយមិនអាចជៀសវាងបានដើម្បីបំពេញកាតព្វកិច្ចក្រោមកិច្ចសន្យានោះ លើសពីអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបានរំពឹងទុកថានឹងត្រូវទទួលបាន ក្រោមកិច្ចសន្យានោះ។

សកម្មភាពប្រតិបត្តិការ — បណ្តាសកម្មភាពផលិតចំណូលចម្បងរបស់អង្គភាព និងបណ្តាសកម្មភាពផ្សេងទៀតដែលមិនមែនជាសកម្មភាពវិនិយោគ ឬហិរញ្ញប្បទាន។

ភតិសន្យាប្រតិបត្តិការ — ភតិសន្យាមួយដែលមិនផ្ទេរហានិភ័យនិងការតបស្នងសឹងតែទាំងអស់ ដែលកើតឡើងដោយសារកម្មសិទ្ធិ។ ភតិសន្យាមួយដែលមិនមែនជាភតិសន្យាប្រតិបត្តិការ នោះគឺជាភតិសន្យាហិរញ្ញវត្ថុ។

ចំណូលលម្អិតផ្សេងៗ — បណ្តាធាតុនៃចំណូលនិងចំណាយ (រួមបញ្ចូលនូវការកែសម្រួលការចាត់ថ្នាក់ឡើងវិញនានា) ដែលមិនត្រូវបានទទួលស្គាល់ក្នុងចំណេញឬខាត ដូចបានតម្រូវឬអនុញ្ញាតដោយស្តង់ដារនេះ។

ម្ចាស់ — អ្នកកាន់នានានូវឧបករណ៍ដែលបានចាត់ថ្នាក់ជាមូលធន។

ក្រុមហ៊ុនមេអង្គភាពមួយដែលមានក្រុមហ៊ុនបុត្រសម្ព័ន្ធមួយឬច្រើន។

លទ្ធផល — ទំនាក់ទំនងនៃចំណូល និង ចំណាយនានារបស់អង្គភាពមួយ ដូចបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលពេញលេញ។

ទ្រព្យសកម្មផែនការ (នៃផែនការអត្ថប្រយោជន៍និយោជិត) ទ្រព្យសកម្មនានាដែលរក្សាទុកដោយមូលនិធិអត្ថប្រយោជន៍និយោជិតរយៈពេលវែងមួយនិងប័ណ្ណធានារ៉ាប់រងនានាដែលបំពេញលក្ខខណ្ឌ។

អត្ថប្រយោជន៍ក្រោយបំពេញការងារ អត្ថប្រយោជន៍និយោជិតនានា (ក្រៅពីអត្ថប្រយោជន៍ពេលបញ្ឈប់) ដែលត្រូវសងបន្ទាប់ពីការបញ្ចប់ការជួលឱ្យធ្វើការ។

ផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ ការរៀបចំផ្លូវការឬមិនផ្លូវការនានាដែលអង្គភាពមួយផ្តល់ អត្ថប្រយោ ជន៍ក្រោយបំពេញការងារនានាសម្រាប់និយោជិតមួយរូប ឬលើសពីមួយរូប។

តម្លៃបច្ចុប្បន្ន ការប៉ាន់ស្មានបច្ចុប្បន្ននៃតម្លៃបានធ្វើអប្បហារបច្ចុប្បន្ននៃ បណ្តាលំហូរសាច់ប្រាក់សុទ្ធអនាគត ក្នុងដំណើរការធម្មតារបស់អាជីវកម្ម។

របាយការណ៍សម្រាប់ការបង្ហាញ រូបិយប័ណ្ណដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជា។

អាចនឹង មានភាពទំនងច្រើនជាងមិនទំនង។

ចំណេញ ឬខាត ការសរុបនៃចំណូលដកចំណាយនានា មិនរាប់បញ្ចូលសមាសធាតុនានានៃចំណូលលម្អិតផ្សេងៗ។

វិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទាន វិធីសាស្ត្រការវាយតម្លៃការគណនាតាមស្ថិតិមួយដែលចាត់ទុកគ្រានីមួយៗ នៃសេវាកម្មជាការបង្កើតនូវឯកតាបន្ថែមមួយនៃសិទ្ធិទទួលបានអត្ថប្រយោជន៍និងវាស់វែងឯកតានីមួយៗដោយឡែកៗពីគ្នាដើម្បីបង្កើតជាបណ្តើរៗនូវ កាតព្វកិច្ចចុងក្រោយ (ជួនកាលត្រូវបានស្គាល់ជា វិធីសាស្ត្រអត្ថប្រយោជន៍បង្គរដោយលៃតាមចំនួនជាក់ស្តែងនៃសេវាកម្ម ឬជាវិធីសាស្ត្រអត្ថប្រយោជន៍/ចំនួនឆ្នាំនៃសេវាកម្ម)។

ទ្រព្យ រោងចក្រ និងបរិក្ខារ ទ្រព្យសកម្មរូបីនានាដែល៖

(ក) ត្រូវបានរក្សាទុកសម្រាប់ប្រើប្រាស់ក្នុងផលិតកម្ម ឬការផ្គត់ផ្គង់ទំនិញឬសេវាកម្មសម្រាប់ការជួលទៅឱ្យអ្នកដទៃ ឬសម្រាប់គោលបំណងរដ្ឋបាល និង

(ខ) ត្រូវបានរំពឹងថានឹងត្រូវបានប្រើក្នុងអំឡុងពេលច្រើនជាងមួយគ្រា។

ការអនុវត្តទៅមុខ (នៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ) ការអនុវត្តគោលនយោបាយគណនេយ្យថ្មីចំពោះប្រតិបត្តិការ ព្រឹត្តិការណ៍ និងស្ថានការណ៍ផ្សេងទៀតនានាដែលបានកើតឡើងបន្ទាប់ពីថ្ងៃដែលគោលនយោបាយគណនេយ្យនោះត្រូវបានផ្លាស់ប្តូរ។

សំវិធានធន បំណុលមួយដែលមានពេលវេលាកើតឡើង ឬចំនួនទឹកប្រាក់មិនប្រាកដ។

ការប្រុងប្រយ័ត្ន ការបញ្ចូលនៃកម្រិតនៃការប្រុងប្រយ័ត្នក្នុងការអនុវត្តនៃការវិនិច្ឆ័យនានា ដែលចាំបាច់ក្នុងការធ្វើការប៉ាន់ស្មាននានាដែលត្រូវបានតម្រូវក្រោមស្ថានការណ៍នៃភាពមិនប្រាកដប្រជាក្នុងកម្រិតមួយដែលទ្រព្យសកម្ម ឬចំណូលមិនត្រូវបានថ្លៃងលើស និង បំណុល ឬចំណាយមិនត្រូវបានថ្លៃងខ្វះ។

ការទទួលខុសត្រូវជាសាធារណៈ អង្គភាពមួយមានការទទួលខុសត្រូវជាសាធារណៈ ប្រសិនបើ៖

(ក) ឧបករណ៍បំណុល ឬមូលធនរបស់អង្គភាពនោះ ត្រូវបានជួញដូរក្នុងទីផ្សារសាធារណៈ ឬអង្គភាពនោះស្ថិតក្នុងដំណើរការនៃការបោះផ្សាយឧបករណ៍បែបនេះសម្រាប់ការជួញដូរក្នុងទីផ្សារសាធារណៈ (ទីផ្សារជួញដូរភាគហ៊ុនក្នុងស្រុកឬ

បរទេស ឬទីផ្សារជួញដូរក្រៅបរិវេណ ដោយរាប់បញ្ចូលទីផ្សារមូលដ្ឋាននិងក្នុងតំបន់) ឬ

(ខ) អង្គភាពនោះទទួលកាន់ទ្រព្យសកម្ម ក្នុងនាមជាអ្នកទទួលបញ្ញើសម្រាប់ក្រុមអ្នកក្រៅដ៏ច្រើន ជាអាជីវកម្មចម្បងមួយក្នុងចំណោមអាជីវកម្មចម្បងនានារបស់អង្គភាពនោះ។

ជួញដូរជាសាធារណៈ (ឧបករណ៍បំណុល ឬមូលធន) ត្រូវបានជួញដូរ ឬក្នុងដំណើរការបោះផ្សាយសម្រាប់ការជួញដូរ ក្នុងទីផ្សារសាធារណៈ (ទីផ្សារជួញដូរភាគហ៊ុនក្នុងស្រុកនិងបរទេស ឬទីផ្សារជួញដូរក្រៅបរិវេណ ដោយរាប់បញ្ចូលទីផ្សារមូលដ្ឋាននិងទីផ្សារក្នុងតំបន់)។

ការទទួលស្គាល់ ដំណើរការនៃការបញ្ចូលទៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬ របាយការណ៍ចំណូលពេញលេញនូវធាតុមួយដែលបំពេញនិយមន័យនៃទ្រព្យសកម្ម បំណុល មូលធន ចំណូល ឬចំណាយ ហើយធាតុនោះបំពេញលក្ខខណ្ឌដូចខាងក្រោម៖

(ក) អត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតទាំងឡាយ ដែលទាក់ទងនឹងធាតុនោះអាចនឹងហូរចូលទៅឬចេញពីអង្គភាព និង

(ខ) ធាតុនោះមានថ្លៃដើម ឬ តម្លៃដែលអាចត្រូវបានវាស់វែងដោយភាពជឿជាក់។

ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន តម្លៃដែលខ្ពស់ជាងនៃតម្លៃសមស្របដកចំណាយក្នុងការលក់ របស់ ទ្រព្យសកម្ម ឬអង្គភាពបង្កើតសាច់ប្រាក់មួយ និងតម្លៃប្រើប្រាស់របស់ទ្រព្យសកម្មឬអង្គភាពបង្កើតសាច់ប្រាក់នោះ។

ភាគីពាក់ព័ន្ធ ភាគីពាក់ព័ន្ធ គឺជាបុគ្គល ឬអង្គភាពមួយដែលមានទំនាក់ទំនងទៅនឹងអង្គភាពដែលកំពុងរៀបចំរបាយ ការណ៍ហិរញ្ញវត្ថុនានារបស់ខ្លួន (អង្គភាពរាយការណ៍)

(ក) បុគ្គលម្នាក់ ឬសមាជិកជិតស្និតនៃគ្រួសាររបស់បុគ្គលនោះ មានទំនាក់ទំនងទៅនឹងអង្គភាពរាយការណ៍ ប្រសិនបើបុគ្គលនោះ៖

(១) ជាសមាជិកម្នាក់នៃបុគ្គលិកគ្រប់គ្រងសំខាន់របស់អង្គភាពរាយការណ៍នោះ ឬនៃក្រុមហ៊ុនមេរបស់អង្គភាពរាយការណ៍នោះ

(២) មានការគ្រប់គ្រង ឬការគ្រប់គ្រងរួមលើអង្គភាពរាយការណ៍នោះ ឬ

(៣) មានឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍នោះ។

(ខ) អង្គភាពមួយពាក់ព័ន្ធនឹងអង្គភាពរាយការណ៍ ប្រសិនបើណាមួយនៃលក្ខខណ្ឌខាងក្រោមអនុវត្ត៖

(១) អង្គភាពនោះ និងអង្គភាពរាយការណ៍នោះជាសមាជិកនៃក្រុមតែមួយ (ដែលមានន័យថាក្រុមហ៊ុនមេ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនបុត្រសម្ព័ន្ធថ្នាក់ដូចគ្នានីមួយៗ មានទំនាក់ទំនងជាមួយគ្នានឹងគ្នា)។

(២) អង្គភាពមួយជាក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុននៃអង្គភាពផ្សេងទៀត (ឬក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុនរបស់សមាជិកនៃក្រុមមួយ ដែលអង្គភាពផ្សេងទៀតជាសមាជិក)។

(៣) អង្គភាពទាំងពីរជាក្រុមហ៊ុនរួមទុននៃអង្គភាពទី៣តែមួយ។

(៤) អង្គភាពមួយ ជាក្រុមហ៊ុនរួមទុនមួយនៃអង្គភាពទី៣ ហើយអង្គភាពផ្សេងទៀតគឺជាក្រុមហ៊ុនញាតិសម្ព័ន្ធមួយនៃអង្គភាពទី៣នោះ។

(៥) អង្គភាពនោះជាផែនការអត្ថប្រយោជន៍ ក្រោយបំពេញការងារសម្រាប់អត្ថប្រយោជន៍និយោជិតនៃអង្គភាពរាយការណ៍នោះ ឬអង្គភាពមួយដែលទាក់ទងនឹងអង្គភាពរាយការណ៍នោះ។

ប្រសិនបើអង្គភាពរាយការណ៍នោះខ្លួនផ្ទាល់ជាផែនការបែបនេះ និយោជកឧបត្ថម្ភនានាក៏មានទំនាក់ទំនងជាមួយនឹងអង្គភាពរាយការណ៍នោះ។

(៦) អង្គភាពនោះត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមដោយបុគ្គលដែលបានកំណត់នៅក្នុង (ក) ។

(៧) អង្គភាពនោះ ឬសមាជិកណាមួយនៃក្រុម ដែលអង្គភាពនោះជាផ្នែកមួយ ផ្តល់សេវាបុគ្គលិកគ្រប់គ្រងសំខាន់ ដល់អង្គភាពរាយការណ៍នោះ ឬដល់ក្រុមហ៊ុនមេនៃអង្គភាពរាយការណ៍នោះ។

(៨) បុគ្គលដែលកំណត់ក្នុង (ក) (២) មានឥទ្ធិពលសំខាន់លើអង្គភាព ឬជាសមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់របស់អង្គភាពនោះ (ឬរបស់អង្គភាពមេនៃអង្គភាពនោះ)។

ប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ — ការផ្ទេរនូវធនធាន សេវាកម្ម ឬ កាតព្វកិច្ចនានារវាងភាគីពាក់ព័ន្ធទាំងឡាយ ដោយមិនគិតថាតើមានការគិតថ្លៃឬអត់។

ភាពទាក់ទិន — គុណភាពនៃព័ត៌មានដែលអនុញ្ញាតឱ្យព័ត៌មាននោះមានឥទ្ធិពល លើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចនានារបស់អ្នកប្រើប្រាស់ ដោយជួយពួកគេវាយតម្លៃព្រឹត្តិការណ៍អតីតកាល បច្ចុប្បន្ន ឬអនាគត ឬ ដោយបញ្ជាក់ ឬកែតម្រូវនូវការវាយតម្លៃអតីតកាលនានា របស់អ្នកប្រើប្រាស់ទាំងនោះ។

ភាពជឿជាក់ គុ — ណភាពនៃព័ត៌មានដែលធ្វើឱ្យព័ត៌មាននោះពុំមានកំហុសនិង ភាពលំអៀងជាសារវន្តព្រមទាំងឆ្លុះបញ្ចាំងដោយស្មោះត្រង់នូវអ្វីដែលព័ត៌មាននោះអះអាងក្នុងការឆ្លុះបញ្ចាំង ឬអាចត្រូវបានរំពឹងទុកដោយសមហេតុផលថានឹងឆ្លុះបញ្ចាំង។

កាលបរិច្ឆេទរាយការណ៍ — ចុងបញ្ចប់នៃគ្រាចុងក្រោយដែលត្រូវបានគ្របដណ្តប់ដោយ របាយការណ៍ហិរញ្ញវត្ថុនានា ឬដោយរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលមួយ។

ការិយបរិច្ឆេទរាយការណ៍ — គ្រាដែលត្រូវបានគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុនានា ឬដោយរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលមួយ។

ការស្រាវជ្រាវ — ការស៊ើបអង្កេតដើមដំបូងនិងបានរៀបចំផែនការដែលប្រព្រឹត្តទៅដោយសង្ឃឹមថា នឹងទទួលបានចំណេះដឹង និងការយល់ដឹងផ្នែកវិទ្យាសាស្ត្រ ឬផ្នែកបច្ចេកទេសថ្មីៗ។

តម្លៃកាកសំណល់ (នៃទ្រព្យសកម្ម) — ចំនួនទឹកប្រាក់ប៉ាន់ស្មានដែលអង្គភាពមួយនឹងទទួលបាននាពេលបច្ចុប្បន្ន ពីការបញ្ចេញចោលនូវទ្រព្យសកម្មមួយ បន្ទាប់ពីកាត់កងចំណាយប៉ាន់ស្មានក្នុងការ

បញ្ចេញចោល ប្រសិនបើទ្រព្យសកម្មបានឈានដល់អាយុកាល និងក្នុងស្ថានភាពដែលបានរំពឹងទុកនៅចុងបញ្ចប់ នៃអាយុកាលអាចប្រើបានរបស់ទ្រព្យសកម្មនោះ។

ការអនុវត្តត្រឡប់ក្រោយ (នៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ) ការអនុវត្តគោលនយោបាយគណនេយ្យថ្មីមួយទៅលើប្រតិបត្តិការ ព្រឹត្តិការណ៍និងស្ថានការណ៍ផ្សេងទៀតនានាហាក់ដូចជាគោលនយោបាយនោះតែងតែត្រូវបានអនុវត្ត។

ចំណូល លំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនានាក្នុងគ្រាដែលបានកើតឡើង ក្នុងដំណើរការសកម្មភាពជម្មតា របស់អង្គភាពមួយនៅពេលដែលលំហូរចូលទាំងនោះបានធ្វើឱ្យកើនឡើងក្នុងមូលធន ក្រៅពីការកើនឡើងដែលពាក់ព័ន្ធនឹងវិភាគទានពីអ្នកចូលរួមមូលធននានា។

របាយការណ៍ហិរញ្ញវត្ថុដោយឡែក ទាំងនោះដែលត្រូវបានបង្ហាញដោយអង្គភាពមួយ ដែលក្នុងនោះអង្គភាពនោះអាចជ្រើសរើស ស្របតាមកថាខណ្ឌ ៩.២៥-៩.២៦ ដើម្បីធ្វើគណនេយ្យកម្មសម្រាប់ការវិនិយោគរបស់ខ្លួន ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ អង្គភាពគ្រប់គ្រងរួមគ្នា និងក្រុមហ៊ុនញាតិសម្ព័ន្ធ តាមថ្លៃដើមដកការថយចុះតម្លៃ តាមតម្លៃសមស្របជាមួយនឹងការប្រែប្រួលនៃតម្លៃសមស្របត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត ឬដោយប្រើប្រាស់វិធីសាស្រ្តមូលធន តាមការគោរពតាមនីតិវិធីនៅក្នុងកថាខណ្ឌ១៤.៨។

ការរៀបចំសម្បទានសេវា ការរៀបចំមួយដោយហេតុនេះ រដ្ឋាភិបាលឬស្ថាប័នសាធារណៈផ្សេងទៀតចុះកិច្ចសន្យាជាមួយនឹងប្រតិបត្តិករឯកជនដើម្បីអភិវឌ្ឍ (ឬ ធ្វើឱ្យប្រសើរឡើង) ធ្វើប្រតិបត្តិការ និងថែទាំនូវទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធរបស់អ្នកផ្តល់ ដូចជាផ្លូវថ្នល់ ស្ពាន ផ្លូវរូង ព្រលានយន្តហោះ បណ្តាញចែកចាយថាមពល ពន្ធនាគារ ឬ មន្ទីរពេទ្យ។

អតិផរណាខ្ពស់ធ្ងន់ធ្ងរ រូបិយប័ណ្ណនៃសេដ្ឋកិច្ចដែលមានអតិផរណាខ្ពស់ អាចនឹងទទួលឥទ្ធិពលអតិផរណា ខ្ពស់ធ្ងន់ធ្ងរ ប្រសិនបើរូបិយប័ណ្ណនោះ មានលក្ខណៈទាំងពីរដូចខាងក្រោម៖

(ក) សន្ទស្សន៍តម្លៃទូទៅដែលអាចទុកចិត្តបាន មិនអាចរកបានសម្រាប់អង្គភាពទាំងអស់ ដែលមានប្រតិបត្តិការ និងសមតុល្យក្នុងរូបិយប័ណ្ណនោះ និង

(ខ) មិនមានអត្ថិភាពនៃភាពអាចប្តូរបាន រវាងរូបិយប័ណ្ណនោះ និងរូបិយប័ណ្ណបរទេសដែលមានស្ថេរភាពជាងតាមដោយផ្ទៀបទៅ។

ការរៀបចំការទូទាត់ដោយផ្អែកលើភាគហ៊ុន កិច្ចព្រមព្រៀងមួយរវាងអង្គភាព (ឬអង្គភាពក្រុមមួយផ្សេងទៀត ឬម្ចាស់ភាគហ៊ុនណាមួយនៃអង្គភាពជាក្រុមណាមួយ) និងភាគីមួយទៀត (រួមទាំងនិយោជិត) ដែលប្រគល់សិទ្ធិឱ្យភាគីផ្សេងទៀត ដើម្បីទទួល៖

(ក) សាច់ប្រាក់ ឬទ្រព្យសកម្មផ្សេងទៀតរបស់អង្គភាពសម្រាប់ចំនួនទឹកប្រាក់ដែលផ្អែកលើថ្លៃ (ឬតម្លៃ) នៃឧបករណ៍មូលធន (រួមបញ្ចូលទាំងភាគហ៊ុន ឬសិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់)របស់អង្គភាព ឬអង្គភាពជាក្រុមផ្សេងទៀត ឬ

(ខ) ឧបករណ៍មូលធននានា (រួមបញ្ចូលទាំងភាគហ៊ុន ឬសិទ្ធិទិញលក់ភាគហ៊ុនក្នុងគ្រានិងតម្លៃកំណត់) របស់អង្គភាព ឬអង្គភាពជាក្រុមផ្សេងទៀត ឱ្យតែបានបំពេញនូវលក្ខខណ្ឌដើម្បីផ្ទេរជាក់លាក់នោះ ប្រសិនបើមាន។

ប្រតិបត្តិការការទូទាត់ដោយផ្អែកលើភាគហ៊ុន ប្រតិបត្តិការមួយដែលក្នុងនោះអង្គភាព៖

(ក) ទទួលទំនិញ ឬសេវាពីអ្នកផ្គត់ផ្គង់ទំនិញ ឬសេវាទាំងនោះ (រួមទាំងនិយោជិត) ក្នុងការរៀបចំការទូទាត់ដោយផ្អែកលើភាគហ៊ុន ឬ

(ខ) ជាប់កាតព្វកិច្ច ក្នុងការទូទាត់ប្រតិបត្តិការជាមួយអ្នកផ្គត់ផ្គង់ នៅក្នុងការរៀបចំការទូទាត់ដោយផ្អែកលើភាគហ៊ុន នៅពេលដែលអង្គភាពជាក្រុមផ្សេងទៀត ទទួលទំនិញ ឬសេវាទាំងនោះ។

អង្គភាពធុនតូច និងមធ្យម អង្គភាពនានាដែល៖

(ក) មិនមានការទទួលខុសត្រូវជាសាធារណៈ និង

(ខ) បោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅដល់អ្នកប្រើប្រាស់ខាងក្រៅ។

អង្គភាពមួយមានការទទួលខុសត្រូវជាសាធារណៈ ប្រសិនបើ៖

(ក) អង្គភាពនោះប្រគល់ ឬ អង្គភាពនោះកំពុងស្ថិតក្នុងដំណើរការនៃការប្រគល់របាយការណ៍ហិរញ្ញវត្ថុទៅឱ្យគណៈកម្មការមូលបត្រ ឬ អង្គភាពនិយតកម្មផ្សេងទៀត ក្នុងគោលបំណង បោះផ្សាយថ្នាក់ឧបករណ៍ណាមួយក្នុងទីផ្សារសាធារណៈ ឬ

(ខ) អង្គភាពនោះទទួលកាន់ទ្រព្យសកម្ម ក្នុងនាមជាអ្នកទទួលបញ្ញើសម្រាប់ក្រុមអ្នកក្រៅដ៏ច្រើន ជាអាជីវកម្មចម្បងមួយក្នុងចំណោមអាជីវកម្មចម្បងនានារបស់អង្គភាពនោះ។

រដ្ឋ រដ្ឋាភិបាលថ្នាក់ជាតិ តាមតំបន់ ឬមូលដ្ឋាន។

ផែនការ (អត្ថប្រយោជន៍និយោជិត) រដ្ឋ ផែនការអត្ថប្រយោជន៍និយោជិតនានា ដែលត្រូវបានបង្កើតឡើងដោយច្បាប់ដើម្បីគ្របដណ្តប់អង្គភាពទាំងអស់ (ឬអង្គភាពទាំងអស់ក្នុងថ្នាក់ជាក់លាក់ណាមួយ ឧទាហរណ៍ វិស័យជាក់លាក់ណាមួយ) និងត្រូវបានធ្វើប្រតិបត្តិការដោយរដ្ឋាភិបាលថ្នាក់ជាតិ ឬមូលដ្ឋាន ឬដោយស្ថាប័នផ្សេងទៀត (ឧទាហរណ៍ ភ្នាក់ងារស្វយ័តមួយដែលបានបង្កើតឡើងជាពិសេស សម្រាប់គោលបំណងនេះ) ដែលមិនរងការគ្រប់គ្រង ឬឥទ្ធិពលដោយអង្គភាពរាយការណ៍នោះ។

របាយការណ៍លំហូរសាច់ប្រាក់ របាយការណ៍ហិរញ្ញវត្ថុមួយដែលផ្តល់ព័ត៌មានអំពីការប្រែប្រួលក្នុងសាច់ប្រាក់ និងសាច់ប្រាក់សមមូល នៃអង្គភាពមួយសម្រាប់គ្រាមួយ ដោយបង្ហាញដាច់ដោយឡែកនូវការប្រែប្រួលនានាក្នុងគ្រាពីសកម្មភាពប្រតិបត្តិការ វិនិយោគ និង ហិរញ្ញប្បទាន។

របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍ហិរញ្ញវត្ថុមួយដែលបង្ហាញចំណេញឬខាតសម្រាប់គ្រា ធាតុនានានៃចំណូល និងចំណាយដែលបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធនសម្រាប់គ្រា ឥទ្ធិពលនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យនិងការកែតម្រូវកំហុសដែលបានទទួលស្គាល់ក្នុងគ្រានិង (អាស្រ័យលើទម្រង់នៃរបាយការណ៍បម្រែបម្រួលមូលធនដែលបានជ្រើសរើសដោយអង្គភាព) ចំនួនទឹកប្រាក់នៃប្រតិបត្តិការជាមួយម្ចាស់កំពុងដើរតួក្នុងតួនាទីរបស់

ពួកគេជាម្ចាស់ ក្នុងគ្រា។

**របាយការណ៍ចំណូលពេញលេញ** របាយការណ៍ហិរញ្ញវត្ថុមួយដែលបង្ហាញធាតុទាំងអស់នៃចំណូល និងចំណាយដែលបានទទួលស្គាល់ក្នុងគ្រាមួយ រួមទាំងធាតុទាំងនោះដែលត្រូវបានទទួលស្គាល់ក្នុងការកំណត់ចំណេញឬខាត (ដែលជា សរុបរងក្នុងរបាយការណ៍ចំណូលពេញលេញ) និង ធាតុនានានៃចំណូលលម្អិតផ្សេងៗ។ ប្រសិនបើអង្គភាពមួយជ្រើសរើសបង្ហាញទាំងរបាយការណ៍លទ្ធផល និងរបាយការណ៍ចំណូលពេញលេញ នោះរបាយការណ៍ចំណូលពេញលេញចាប់ផ្តើមដោយចំណេញឬខាត បន្ទាប់មកបង្ហាញ ធាតុនានានៃចំណូលលម្អិតផ្សេងៗ។

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** របាយការណ៍ហិរញ្ញវត្ថុមួយដែលបង្ហាញពីទំនាក់ទំនងនៃទ្រព្យសកម្ម បំណុល និងមូលធនរបស់អង្គភាពមួយ នៅត្រឹមកាលបរិច្ឆេទជាក់លាក់មួយ (ក៏ត្រូវបានហៅថាតារាងតុល្យការផងដែរ)។

**របាយការណ៍ចំណូល និងចំណេញរក្សាទុក** របាយការណ៍ហិរញ្ញវត្ថុមួយដែលបង្ហាញចំណេញឬខាត និងការប្រែប្រួលក្នុងចំណេញរក្សាទុកសម្រាប់គ្រាមួយ។

**ក្រុមហ៊ុនបុត្រសម្ព័ន្ធ** អង្គភាពមួយ រួមទាំងអង្គភាពមិនចុះបញ្ជីក្រុមហ៊ុន ដូចជាក្រុមហ៊ុនសហកម្មសិទ្ធិ ដែលត្រូវបានគ្រប់គ្រងដោយអង្គភាពមួយទៀត (ហៅថាក្រុមហ៊ុនមេ)។

**មូលដ្ឋានពន្ធ** មូលដ្ឋានពន្ធនៃទ្រព្យសកម្ម ឬបំណុលមួយ គឺជាចំនួនទឹកប្រាក់ដែលជារបស់ទ្រព្យសកម្ម ឬបំណុលនោះសម្រាប់គោលបំណងពន្ធ។

**ចំណាយពន្ធ** ចំនួនទឹកប្រាក់សរុបដែលត្រូវបានរួមបញ្ចូលក្នុងចំណូលពេញលេញសរុប ឬមូលធនសម្រាប់ការិយបរិច្ឆេទរាយការណ៍ ទាក់ទងនឹងពន្ធបច្ចុប្បន្ន និង ពន្ធពន្យារ។

**ប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ)** ប្រាក់ចំណេញ (ខាត) សម្រាប់ការិយបរិច្ឆេទរាយការណ៍មួយដែលពីលើនោះពន្ធលើប្រាក់ចំណូលគឺត្រូវបង់ ឬត្រូវប្រមូលមកវិញបាន ត្រូវបានកំណត់ដោយអនុលោមតាមច្បាប់ដែលបានបង្កើតឡើងដោយអាជ្ញាធរពន្ធដារ។ ប្រាក់ចំណេញជាប់ពន្ធស្មើនឹងចំណូលជាប់ពន្ធ ដក ចំនួនទឹកប្រាក់ដែលអាចកាត់ចេញបានពីចំណូលជាប់ពន្ធ។

**ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ** ភាពខុសគ្នាបណ្តោះអាសន្ននានាដែលនឹងនាំឱ្យមានចំនួនទឹកប្រាក់ជាប់ពន្ធ ក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) នៃគ្រាអនាគត នៅពេលដែលតម្លៃយោងនៃទ្រព្យសកម្ម ឬបំណុល ត្រូវបានប្រមូលមកវិញ ឬត្រូវបានទូទាត់សង។

**ភាពខុសគ្នាបណ្តោះអាសន្ន** ភាពខុសគ្នានានារវាងតម្លៃយោងនៃទ្រព្យសកម្ម ឬបំណុលមួយ ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងមូលដ្ឋានពន្ធរបស់ទ្រព្យសកម្ម ឬបំណុលនោះ។

**អត្ថប្រយោជន៍ពេលបញ្ឈប់** អត្ថប្រយោជន៍និយោជិតត្រូវសងដែលកើតចេញពី មូលហេតុណាមួយដូចខាងក្រោម៖

(១) ការសម្រេចចិត្តរបស់អង្គភាពដោយបញ្ឈប់ការងាររបស់និយោជិតមុនពេលចូលនិវត្តន៍ធម្មតា ឬ

(២) ការសម្រេចចិត្តរបស់និយោជិតដោយទទួលយកការកាត់បន្ថយបុគ្គលិកដោយស្ម័គ្រចិត្ត ក្នុងការដោះដូរសម្រាប់អត្ថប្រយោជន៍ទាំងនោះ។

**ភាពខុសគ្នានៃពេលវេលា** ចំណូលឬចំណាយនានាដែលត្រូវបានទទួលស្គាល់ក្នុងចំណេញឬខាតក្នុងគ្រាមួយ ប៉ុន្តែ

| | |
|---|---|
| | ត្រូវបានបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធ ក្នុងគ្រាផ្សេងគ្នាក្រោមច្បាប់ឬបទបញ្ញាពន្ធ។ |
| ភាពទាន់ពេល | ការផ្ដល់ព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុនានា នៅខាងក្នុងក្របខ័ណ្ឌពេលវេលាសម្រាប់ធ្វើសេចក្ដីសម្រេចចិត្ត។ |
| ចំណូលពេញលេញសរុប | ការប្រែប្រួលក្នុងមូលធនក្នុងគ្រាមួយដែលកើតចេញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀតនានា ក្រៅពីការប្រែប្រួលទាំងនោះដែលកើតចេញពីប្រតិបត្តិការជាមួយម្ចាស់ក្នុងតួនាទីរបស់ពួកគេជាម្ចាស់ (ស្មើនឹងផលបូកនៃចំណេញឬខាត និងចំណូលលម្អិតផ្សេងៗ)។ |
| ថ្លៃប្រតិបត្តិការ (ឧបករណ៍ហិរញ្ញវត្ថុ) | កំណើនថ្លៃដើម ដែលបណ្ដាលដោយផ្ទាល់មកពីការទិញ ការបោះផ្សាយ ឬការបញ្ចេញចោលឧបករណ៍ហិរញ្ញវត្ថុមួយ។ កំណើនថ្លៃដើមមួយ ជាថ្លៃដើមមួយ ដែលនឹងមិនអាចកើតឡើងបានទេ ប្រសិនបើអង្គភាពមិនបានទិញ បោះផ្សាយ ឬបញ្ចេញចោលឧបករណ៍ហិរញ្ញវត្ថុនោះ។ |
| ភាគហ៊ុនរតនៈ | ឧបករណ៍មូលធនរបស់អង្គភាពផ្ទាល់ ដែលរក្សាទុកដោយអង្គភាពនោះ ឬសមាជិកផ្សេងទៀតនៃក្រុមរួម។ |
| ភាពអាចយល់បាន | គុណភាពនៃព័ត៌មានក្នុងរបៀបមួយដែលធ្វើឱ្យមានការយល់បាន ដោយអ្នកប្រើប្រាស់នានាដែលមានចំណេះដឹងសមរម្យផ្នែកធុរកិច្ចនិងសកម្មភាពសេដ្ឋកិច្ចនិងគណនេយ្យនិងមានឆន្ទៈក្នុងការសិក្សា ព័ត៌មានជាមួយនឹងភាពព្យាយាមសមរម្យ។ |
| អាយុកាលអាចប្រើបាន | គ្រាដែលទ្រព្យសកម្មមួយត្រូវបានរំពឹងថាអាចប្រើបានដោយអង្គភាពមួយ ឬចំនួននៃផលិតកម្ម ឬឯកតាស្រដៀងគ្នានានាដែលត្រូវបានរំពឹងថានឹងទទួលបាន ពីទ្រព្យសកម្មនោះ ដោយអង្គភាពមួយ។ |
| តម្លៃប្រើប្រាស់ | តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគតនានាដែលត្រូវបានរំពឹងថា នឹងត្រូវបានទាញយកពីទ្រព្យសកម្ម ឬ អង្គភាពបង្កើតសាច់ប្រាក់មួយ។ |
| អ្នករួមទុន | ភាគីមួយនៃក្រុមហ៊ុនរួមទុន ដែលមានការគ្រប់គ្រងរួមលើក្រុមហ៊ុនរួមទុននោះ។ |
| ផ្ទេរ | ក្លាយជាមានសិទ្ធិទទួល។ ក្រោមការរៀបចំការទូទាត់ដោយផ្អែកលើភាគហ៊ុន សិទ្ធិរបស់ភាគីម្ខាងទៀត ត្រូវទទួលបានសាច់ប្រាក់ ទ្រព្យសកម្មផ្សេងទៀត ឬឧបករណ៍មូលធននៃអង្គភាពនោះផ្ទេរ ពេលសិទ្ធិទទួលរបស់ភាគីម្ខាងទៀតមិនជាប់លក្ខខណ្ឌតទៅទៀតលើការបំពេញនៃលក្ខខណ្ឌដើម្បីផ្ទេរណាមួយ។ |
| អត្ថប្រយោជន៍បានផ្ទេរ | អត្ថប្រយោជន៍នានា ដែលសិទ្ធិត្រូវទទួលអត្ថប្រយោជន៍ទាំងនោះមិនជាប់លក្ខខណ្ឌនៃការបន្តការងារក្រោមលក្ខខណ្ឌនានានៃផែនការអត្ថប្រយោជន៍ចូលនិវត្តន៍មួយ។ |
| លក្ខខណ្ឌដើម្បីផ្ទេរ | លក្ខខណ្ឌនានាដែលកំណត់ថាតើអង្គភាពទទួលបានសេវា ដែលផ្ដល់សិទ្ធិឱ្យភាគីម្ខាងទៀត ទទួលបានសាច់ប្រាក់ ទ្រព្យសកម្មផ្សេងទៀត ឬឧបករណ៍មូលធនរបស់អង្គភាព ក្រោមការរៀបចំការទូទាត់ដោយផ្អែកលើភាគហ៊ុនដែរឬទេ។ លក្ខខណ្ឌដើម្បីផ្ទេរ គឺជាលក្ខខណ្ឌសេវា ឬលក្ខខណ្ឌបំពេញការងារ។ លក្ខខណ្ឌសេវា តម្រូវឱ្យភាគីម្ខាងទៀតបំពេញសេវា ដែលបានកំណត់រយៈពេល។ លក្ខខណ្ឌបំពេញការងារ តម្រូវឱ្យភាគីម្ខាងទៀត បំពេញសេវា ដែលបានកំណត់រយៈពេល និងសម្រេចគោលដៅលទ្ធផលការងារដែលបានកំណត់ (ដូចជាការបង្កើនជាក់លាក់នូវប្រាក់ចំណេញរបស់អង្គភាព |

ក្នុងរយៈពេលមួយជាក់លាក់)។ លក្ខខណ្ឌបំពេញការងារ អាចរាប់បញ្ចូលលក្ខខណ្ឌទីផ្សារ ដើម្បីផ្ទេរ។

គ្រាផ្ទេរ — អំឡុងគ្រាដែលក្នុងអំឡុងគ្រានោះលក្ខខណ្ឌដើម្បីផ្ទេរជាក់លាក់ទាំងអស់ នៃការរៀបចំការទូទាត់ដោយផ្អែកលើភាគហ៊ុន ត្រូវតែបានបំពេញ។

# តារាងប្រភព

ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម ត្រូវបានបង្កើតឡើងដោយៈ

(ក) ការដកស្រង់ទស្សនៈជាមូលដ្ឋានពីគ្រោងក្របខ័ណ្ឌ សម្រាប់ការរៀបចំនិងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (គ្រោងក្របខ័ណ្ឌក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ) ព្រមទាំងគោលការណ៍ និងការណែនាំជាកាតព្វកិច្ច ដែលពាក់ព័ន្ធពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិពេញលេញ និង

(ខ) ការពិចារណាលើការកែតម្រូវ ដែលសមស្រប ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីត្រូវការរបស់ អ្នកប្រើប្រាស់ និងការពិចារណាលើថ្លៃដើម-អត្ថប្រយោជន៍។

តារាងខាងក្រោមបង្ហាញពីប្រភពចម្បងៗ នៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ដែលជាប្រភពដើមនៃគោលការណ៍នានានៅក្នុងផ្នែកនីមួយៗនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូច និងមធ្យម។

| | ផ្នែកនៅក្នុង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម | ប្រភព |
|---|---|---|
| | អារម្ភកថា | អារម្ភកថានៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិ |
| ១ | អង្គភាពធុនតូច និងមធ្យម | - |
| ២ | ទស្សនៈ និងគោលការណ៍ទូទៅ | គ្រោងក្របខ័ណ្ឌ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ, ស្តង់ដារគណនេយ្យអន្តរជាតិ (IAS) ១ ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ |
| ៣ | ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១ |
| ៤ | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១ |
| ៥ | របាយការណ៍ចំណូលពេញលេញ និងរបាយការណ៍លទ្ធផល | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១ |
| ៦ | របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍ចំណូលពេញលេញ និងចំណេញរក្សាទុក | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១ |
| ៧ | របាយការណ៍លំហូរសាច់ប្រាក់ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ៧ របាយការណ៍លំហូរសាច់ប្រាក់ |
| ៨ | កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១ |

| | | |
|---|---|---|
| ៩ | របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២៧ របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ដូចបានធ្វើវិសោធនកម្ម |
| ១០ | គោលនយោបាយ ការប៉ាន់ស្មាន និងកំហុសឆ្គងគណនេយ្យ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ៨ គោលនយោបាយគណនេយ្យ ការប្រែប្រួលលើការប៉ាន់ស្មាន និងកំហុសឆ្គងគណនេយ្យ |
| ១១ និង ១២ | ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និង បញ្ហាដទៃទៀតរបស់ឧបករណ៍ហិរញ្ញវត្ថុ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ៣២ ឧបករណ៍ហិរញ្ញវត្ថុ៖ ការបង្ហាញ, ស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩ ឧបករណ៍ហិរញ្ញវត្ថុ៖ ការទទួលស្គាល់ និងការវាស់វែង, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ៧ ឧបករណ៍ហិរញ្ញវត្ថុ៖ ការលាតត្រដាង |
| ១៣ | សន្និធិ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២ សន្និធិ |
| ១៤ | ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២៨ ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ |
| ១៥ | ការវិនិយោគក្នុងក្រុមហ៊ុនរួមទុន | ស្តង់ដារគណនេយ្យអន្តរជាតិលេខ៣១ ភាគកម្មក្នុងក្រុមហ៊ុនរួមទុន |
| ១៦ | ទ្រព្យវិនិយោគ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ៤០ ទ្រព្យវិនិយោគ |
| ១៧ | ទ្រព្យ រោងចក្រ និងបរិក្ខារ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១៦ ទ្រព្យ រោងចក្រ និងបរិក្ខារ |
| ១៨ | ទ្រព្យសកម្មអរូបីក្រៅពីកេរ្តិ៍ឈ្មោះអាជីវកម្ម | ស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៨ ទ្រព្យសកម្មអរូបី |
| ១៩ | ការរួមបញ្ចូលអាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្ម | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ៣ ការរួមបញ្ចូលអាជីវកម្ម |
| ២០ | ភតិសន្យា | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១៧ ភតិសន្យា |
| ២១ | សំវិធានធន និងយថាភាព | ស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៧ សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព |
| ២២ | បំណុល និងមូលធន | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១, ស្តង់ដារគណនេយ្យអន្តរជាតិលេខ៣២ |
| ២៣ | ចំណូលពីការលក់ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១១ កិច្ចសន្យាសាងសង់, ស្តង់ដារគណនេយ្យអន្តរជាតិលេខ១៨ ចំណូលពីការលក់ |
| ២៤ | អំណោយរបស់រដ្ឋាភិបាល | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២០ គណនេយ្យសម្រាប់អំណោយរបស់រដ្ឋាភិបាល និងការលាតត្រដាងអំពីជំនួយរបស់រដ្ឋាភិបាល |
| ២៥ | បន្ទុកលើប្រាក់កម្ចី | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២៣ បន្ទុកលើប្រាក់កម្ចី |
| ២៦ | ការទូទាត់ផ្អែកលើភាគហ៊ុន | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ២ ការទូទាត់ផ្អែកលើភាគហ៊ុន |
| ២៧ | ការថយចុះតម្លៃនៃទ្រព្យសកម្ម | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២, ស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៦ ការថយចុះតម្លៃនៃទ្រព្យសកម្ម |

| | | |
|---|---|---|
| ២៨ | អត្ថប្រយោជន៍និយោជិត | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១៩ អត្ថប្រយោជន៍និយោជិត |
| ២៩ | ពន្ធលើប្រាក់ចំណូល | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១២ ពន្ធលើប្រាក់ចំណូល |
| ៣០ | ការបកប្រែរូបិយប័ណ្ណបរទេស | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២១ ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់បរទេស |
| ៣១ | អតិផរណាខ្ពស់ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២៩ ការរាយការណ៍ហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចដែលមានអតិផរណាខ្ពស់ |
| ៣២ | ហេតុការណ៍ក្រោយពេលចប់ការិយបរិច្ឆេទរាយការណ៍ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ១០ ហេតុការណ៍ក្រោយការិយបរិច្ឆេទរាយការណ៍ |
| ៣៣ | ការលាតត្រដាងភាគីពាក់ព័ន្ធ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ២៤ ការលាតត្រដាងភាគីពាក់ព័ន្ធ |
| ៣៤ | សកម្មភាពជំនាញ | ស្តង់ដារគណនេយ្យអន្តរជាតិលេខ៤១ កសិកម្ម, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ៦ ការរុករក និងការវាយតម្លៃធនធានរ៉ែ |
| ៣៥ | ការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ១ ការអនុវត្តលើកដំបូងនូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ |

# ការសម្រេចអនុម័តដោយក្រុមប្រឹក្សាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម ដែលបានចេញផ្សាយនៅក្នុងខែកក្កដា ឆ្នាំ២០០៩

---

ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងអង្គភាពមធ្យម (IFRS for SMEs) ត្រូវសម្រេចអនុម័តសម្រាប់ការចេញផ្សាយ ដោយសមាជិកចំនួនដប់បីរូប ក្នុងចំណោមសមាជិកទាំងដប់បួនរូប នៃក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។ លោក Leisenring បានជំទាស់។ មតិជំទាស់របស់គាត់ ត្រូវបានសរសេរចូល បន្ទាប់ពីមូលដ្ឋានសម្រាប់ការសន្និដ្ឋាន។

| | |
|---|---|
| Sir David Tweedie | ប្រធាន |
| Thomas E Jones | អនុប្រធាន |
| Mary E Barth | |
| Stephen Cooper Philippe Danjou | |
| Jan Engstrom | |
| Robert P Garnett | |
| Gilbert Gelard | |
| Prabhakar Kalavacherla James J Leisenring Warren J McGregor | |
| John T Smith | |
| Tatsumi Yamada | |
| Wei-Guo Zhang | |